គណៈកម្មការទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៣ លេខ ១ ខែមករា

ព.ស. ២៥០៣ គ.ស. ១៩៦១

ភ្នំពេញ

# ដំណឹងគួរសោកស្ដាយ

ព្រះតេជព្រះគុណ ព្រះសាសនមុនី មាស-គង់ ចៅអធិការវត្តពិភទ្ធរង្សី (ចិនដំដែក) សង្កាត់លេខ ២ ក្រុងភ្នំពេញ, ពជាគណៈថ្នាក់ទោ បានទទួលអនិច្ចធម្មនៅថ្ងៃសៅរ៍ ២ កើតខែកត្តិក ឆ្នាំជូតទោស័ក ព.ស. ២៥០៣ (៥ វិច្ឆិកា ១៩៦០) ដោយរោគជរា ។

ក្រុមសិស្សានុសិស្សនឹងក្រុមញាតិមិត្ត ទាំងបព្វជិតទាំងគ្រហស្ថ បានតម្កល់សពរបស់លោកទុកអស់រយៈវេលា ៣ ខែ ១៧ថ្ងៃ ដើម្បីធ្វើទក្ខិណានុប្បទាន ឧទ្ទិសកុសលប្រគេនចំពោះវិញ្ញាណក្ខន្ធរបស់លោក ។

នៅថ្ងៃសៅរ៍–អាទិត្យ–ច័ន្ទ–អង្គារ ៤–៥–៦–៧ កើត ខែផល្គុណ ឆ្នាំជូតទោស័ក ព.ស. ២៥០៣ (១៨_១៩-២០ នឹង ២១ ខែកុម្ភៈ១៩៦១) ក្រុមសិស្សានុសិស្ស នឹងក្រុមញាតិមិត្តទាំងបព្វជិតទាំងគ្រហស្ថ បានធ្វើបុណ្យឈាបនកិច្ច តាមប្រពៃណីនៃព្រះពុទ្ធសាសនាយ៉ាងអធិកអធម។

ក្រុមពុទ្ធសាសនបណ្ឌិត្យ មានសេចក្ដីវិយោគសោកស្ដាយពន់ពេក ដោយព្រះតេជព្រះគុណអង្គនេះ ជាបណ្ឌិតប្រកបដោយឧត្តមគតិមួយរូប ខាងផ្នែកព្រះពុទ្ធសាសនា ។ ការអនិច្ចធម្មរបស់ព្រះតេជព្រះគុណអង្គនេះ ឈ្មោះថាខាតបង់អ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាមួយរូបយ៉ាងជំនាញ ។

ធ្ង

F278

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ទំព័រ

*ផ្នែកសាសនា*

- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . . ១
- ព្រះអភិធម្មបិដក គម្ពីរព្រះកថាវត្ថុ (តមក) លោក ប៊ូ-ប៊ូ រៀបរៀង. . . . ១៧
- ខុទ្ទកសភិហិណី (តមក) សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ . . . . . . . . . . . . ៣១
- មហោសថជាតក (តមក) លោក អ៊ុម-ភន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-តូរ ពិនិត្យ . . . . . . . . . . . ៣៩

*ផ្នែកអក្សរសាស្ត្រ*

- វប្បធម៌ខ្មែរ លោក លី-ធាមតេង រៀបរៀង . . ៤៩
- ពាក្យខ្មែរ ប្រែពីបរទេស ដោយគណៈកម្មការវប្បធម៌ . . . . . . . . . ៥៧
- វចនានុក្រម សំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . ៥៩
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . ៦០
- ល្បែងគៀរ លោក ញុង-សឿង រៀបរៀង . . ៧០
- រឿងព្រេងទាក់ទងដោយការស្ថាបនាប្រាសាទអង្គរ លោក ព្រំ-ទិម រៀបរៀង៨០

*ផ្នែកកំណត់ហេតុនិងប្រវត្តិការណ៍*

- ពិធីអនុសាវរីយ៍មហាសន្និបាតនៃអន្តរសង្ឃលើកទី០៧ . . . . . . . . . ៩២
- ព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ . . . , . . ១០៩

មួយឆ្នាំ មាន១២សៀវភៅ ដំឡៃជាវ ២៣០រៀល

33e Année — No 1 — Janvier 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire publiée par l'Institut - Bouddhique de Phnom-Penh

## Sommaire

### Partie religieuse

Pages

- La Vie du Buddha (suite) par Vèn - *PANG KHAT* . . . . . 1
- Prah Abhidhammapitaka, Kampi Preah Kathavathu (suite) par *M. BOU - FO* . . . . . 17
- Madhurasavahini (suite) par Samdech Preah Dhammalikhita *LOUIS EM*, revu et corrigé par Vèn. *NHÉAN - CHHOEUN* . . . 31
- Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM - PHON*, revu etcorrigé par Vèn. *KEM - TO* . . . 39

### Partie litétraire

- La Culture Khmère par *M. LY - THEAM - TENG* . . . . . 49
- Activités de la Commission Culturelle . . . . . . . . . . . . . . . 57
- Dictionnaire Sanscrit-Khmèr (suite) par *VÉN . PANC - KHAT* . . 59
- Histoire de Sam-Kok (suite) traduite par Oknha *NOU - KAN* . . . . . . 61
- Le jeu de "Eav" par *M. NHOUNG - SŒUNG* . . . . . 70
- La fondation d'Angkor d'après une légende khmère par *M. NHEM - KHEM* . . . . . 81

### Notes et chroniques

- Le 17ème Congrès des Dignitaires religieux . . . . . . . . . . 92
- Cérémonie d'ensvelissement des cendres de *S.M. PRÉAH MOHA KANCHANAKAUD* . . . . . 109

Prix d'abonnement annuel (comprenant 12 numéros): 23oloo

ផ្នែកសាសនា

# ពុទ្ធជីវប្បវត្តិ

(តមក)

ព្រះមហាប៉ាង-ខាត់ រៀបរៀង

## អវិទូរេនិទាន ពុទ្ធបូជាកថាទី៣

១–សេចក្ដីប្រាថ្នានាងសុជាតា, ២–ទ្រង់ឧបមហាសុបិន ៥ យ៉ាង, ៣– នាងសុជាតាថ្វាយមធុបាយាស, ៤– ទ្រង់សោយមធុបាយាស, ៥ ពុទ្ធដំណើរទៅកាន់ពោធិមណ្ឌល ។

### ១- សេចក្ដីប្រាថ្នានាងសុជាតា

មាននាងទារិកាម្នាក់ឈ្មោះ សុជាតា កើតក្នុងត្រកូលសេនកុដុម្ពីនៅក្នុងសេនានិគម ទុរុវេលាប្រទេស កាលនាងមានវ័យវឌ្ឍនាធំចំរើនឡើង នាងបានធ្វើសច្ចប្រណិធានចំពោះទេវតា ដែលអាស្រ័យនៅនិគ្រោធ-ព្រឹក្សធំមួយដើមថា "ខ្ញុំម្ចាស់សូមឲ្យបានស្វាមីប្រកបដោយបុញ្ញសម្បត្តិ ហើយឲ្យបានបុត្រឋិតនៅក្នុងបឋមគភ៌, បើខ្ញុំម្ចាស់បានសម្រេចសេចក្ដីប្រាថ្នា ក្នុងកាលណា, ខ្ញុំម្ចាស់នឹងធ្វើពលិកម្មបូជាដែលមានតម្លៃមួយសែនកហាបនៈ ក្នុងកាលនោះ" ។ ចំណេរកាលមក នាងសុជាតាបានសម្រេចសមតាមសេចក្ដីប្រាថ្នា នាងរៀបចំពលិកម្មបូជាទេវតា ដោយមធុបាយាសនៅថ្ងៃ១៥ កើតខែពិសាខ ។

មានសេចក្ដីដំណាលថា មធុបាយាសនេះអស្ចារ្យចំឡែកណាស់

នាងសុជាតាធីតាសេនកុដុម្ពី បានឲ្យយកមេគោ១.០០០ទៅឃ្វាលនៅព្រៃវល្លិឈើឯម ហើយនាងរូតយកទឹកដោះពីមេគោ ៥០០ ក្នុងចំនួនមេគោទាំង ១.០០០ នោះ ទៅឲ្យមេគោ៥០០ផឹក; រូតយកទឹកដោះពីមេគោ២៥០ ក្នុងចំនួនមេគោ៥០០នោះ ទៅឲ្យមេគោ ២៥០ ផឹកហើយបន្ថយយ៉ាងនេះ ហូតទៅដល់មេគោ ៨ ។ នាងសុជាតាធ្វើដូច្នេះ ប្រាថ្នាឲ្យទឹកដោះគោមានឱជារសផ្អែមដ៏ក្រៃលែង ។ ពេលរូតទឹកដោះគោ ក៏មានអស្ចារ្យវិសេសហូរចុះ កាន់ភាជន៍មិនចាំបាច់យកដៃរូត ពេលចំអិនមធុបាយាសក៏មានអស្ចារ្យ ពពុះទឹកដោះហូរវិលជាទក្ខិណាវដ្ត ដើងក្រានមិនមានផ្សែង ពួកទេពតាយកឱជារសមកបង់ក្នុងភាជន៍មធុបាយាសនោះ ។ នាងសុជាតាឃើញហេតុអស្ចារ្យដូច្នោះ មានចិត្តត្រេកអរក្រៃលែង ហើយប្រើនាងបុណ្ណទាសីថា "នាងចូរទៅបោសជម្រះនៅក្រោមដើមនិគ្រោធឲ្យស្អាតបាត" ។

## ២-ទ្រង់មហាសុបិន ៥ យ៉ាង

ក្នុងរាត្រីយប់ ១៤ កើតខែពិសាខនោះ ព្រះបរមពោធិសត្វទ្រង់មហាសុបិន ៥ ប្រការ ដែលជាបុព្វនិមិត្តអស្ចារ្យ ជាហេតុនាំឲ្យទ្រង់ជ្រាបថាទ្រង់នឹងបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ដូចព្រះពុទ្ធដីកាដែលទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា(១)

---

១ អង្គុត្តរនិកាយ បញ្ចកនិបាតសៀ.៤៥ ទំព័រ ២២៤ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ មុនពីការត្រាស់ដឹង មាននមហាសុបិន៥យ៉ាង កើតប្រាកដឡើង ។ មហាសុបិន ៥ យ៉ាងនោះ តើដូចម្ដេច ?

១-ម្នាលភិក្ខុទាំងឡាយ! មហាប្រឹថពីនេះ ជាសំណាំងដ៏ប្រសើរ ស្ដេចភ្នំឈ្មោះហិមវន្តជាខ្នើយ ព្រះហស្ដឆ្វេងសណ្ដូកចុះក្នុងសមុទ្រខាងកើត ព្រះហស្ដស្ដាំសណ្ដូកចុះក្នុងសមុទ្រខាងលិច ព្រះបាទទាំងគូសណ្ដូកចុះក្នុងសមុទ្រខាងត្បូង,

២-ម្នាលភិក្ខុទាំងឡាយ ! មានស្មៅចំពៀនមួយសរសៃដុះលេចពីផ្ចិតទៅទល់នឹងអាកាស,

៣- ម្នាលភិក្ខុទាំងឡាយ! មានដង្កូវខ្លួនសក្បាលខ្មៅវារចេញពីព្រះបាទទាំងគូ (ចាប់ដើមពីចុងក្រចក) ចោមរោមជិតជិវាបដល់មណ្ឌលនៃជង្គង់,

៤- ម្នាលភិក្ខុទាំងឡាយ មានបក្សី ៤ ពួក មានសម្បុរផ្សេងៗគ្នា ហើរមកពីទិសទាំង ៤ មកក្រាបចុះទៀបបាទមូល

ក៏ត្រឡប់ជាសម្បុរសទាំងអស់ទៅវិញ,

៥ - ម្នាលភិក្ខុទាំងឡាយ តថាគតបង្ក្រមលើភ្នំលាមកធំ មិនប្រឡាក់ដោយលាមកឡើយ ។

ម្នាលភិក្ខុទាំងឡាយ! មហាសុបិនទី ១ ប្រាកដឡើង ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ ដែលតថាគតត្រាស់ដឹងហើយ,

ម្នាលភិក្ខុទាំងឡាយ! មហាសុបិនទី ២ ប្រាកដឡើង ដើម្បីត្រាស់ដឹងនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលតថាគតត្រាស់ដឹងហើយ ត្រាតែទេវតា និងមនុស្សទាំងឡាយប្រកាសបានដោយប្រពៃ,

ម្នាលភិក្ខុទាំងឡាយ! មហាសុបិនទី ៣ ប្រាកដឡើង ដើម្បីត្រាស់ដឹងនូវគុណ ដែលពួកគ្រហស្ថច្រើន ស្លៀកពាក់គ្រឿងប្រដាប់មានពណ៌ស ដល់នូវតថាគតជាសរណៈស្មើដោយជីវិត,

ម្នាលភិក្ខុទាំងឡាយ! មហាសុបិនទី ៤ ប្រាកដឡើង ដើម្បី

ត្រាស់ដឹងនូវគុណ ដែលវណ្ណៈទាំង ៤ នេះគឺ ខត្តិយៈ ១ ព្រាហ្មណៈ ១ វេស្សៈ ១ សូទ្ទៈ ១ ចេញចាកផ្ទះមកបួសក្នុងធម៌វិន័យដែលតថាគតសំដែង ធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិដ៏ប្រសើរ ។

ម្នាលភិក្ខុទាំងឡាយ! មហាសុបិនទី ៥ ប្រាកដឡើង ដើម្បីត្រាស់ដឹងនូវគុណ ដែលតថាគត ជាបុគ្គលមានលាភ គឺបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយបរិក្ខារ តែតថាគតមិនជាប់ជំពាក់ មិនជ្រប់សុបសៅ ក្នុងលាភទាំងនោះឡើយ មានការឃើញនូវលាភនោះថាជាទោស មានបញ្ញាជាគ្រឿងរលាស់ចេញ ទើបបរិភោគ។

ម្នាលភិក្ខុទាំងឡាយ, កាលតថាគតអរហន្តសម្មាសម្ពុទ្ធនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មុនពីការត្រាស់ដឹង មហាសុបិនទាំង ៥ នោះ ក៏បានកើតប្រាកដឡើង ។

## ៣-នាងសុជាតាថ្វាយមធុបាយាស

*ព្រះមហាបុរសរត្ន បានបំពេញទុក្ករកិរិយាគម្រប់ ៦ វស្សា ហើយ ថ្ងៃ ១៥ កើតខែពិសាខឆ្នាំរកា វេលាព្រឹក ទ្រង់ពុទ្ធដំណើរទៅប្រថាប់ក្រោមនិគ្រោធព្រឹក្ស ញុំាងសកលមណ្ឌលនិគ្រោធព្រឹក្សឲ្យភ្លឺរុងរឿងដោយរស្មី*

ដែលផ្សាយចេញពីព្រះសរីរកាយ ៗ នាងបុណ្ណទាសីទៅបោសសំអាត ទីឋាននោះ ឃើញព្រះបរមពោធិសត្វគង់បែរព្រះភក្ត្រ ទៅកាន់បាចីនទិស មានរស្មីព្រោងព្រាយដូចមាស ក៏គិតថា ថ្ងៃនេះ ទេពតានិគ្រោធព្រឹក្ស ចុះមកចាំទទួលពលិកម្មហើយ នាងមានសេចក្ដីត្រេកអរក្រៃលែង ក៏ប្រញាប់ប្រញាល់យកសេចក្ដីនេះទៅប្រាប់នាងសុជាតាវិញ ៗ នាងសុជាតា បានស្ដាប់ពាក្យនាងបុណ្ណទាសីហើយ មានបីតិសោមនស្សណាស់និយាយ ទៅកាន់នាងបុណ្ណទាសីវិញថា បើដំណឹងនេះជាសេចក្ដីពិត យើងនឹង តាំងនាងឲ្យជាធីតានៃយើង ៗ លុះចំអិនមធុបាយាសរួចស្រេចហើយ នាងសុជាតា មាននាងបុណ្ណទាសីជាគ្នា ទូលមធុបាយាស ធ្វើដំណើរ ទៅកាន់និគ្រោធមូលដែលជាទេពល័យនោះ នាងបានឃើញព្រះមហាបុរសគ្នេ នឹកស្មានថា ទេពតានិគ្រោធព្រឹក្ស មានចិត្តសោមនស្សក្រៃលែង បង្អោនកាយ ដើរចូលទៅកាន់ព្រះបរមពោធិសត្វ ហើយលើក ភាជន៍មធុបាយាសដាក់ថ្វាយលើព្រះហស្ត ៗ ព្រះមហាបុរសបើកនេត្រា ទតនាងសុជាតា, នាងសុជាតា ដឹងអាការដូច្នោះហើយ ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ! ខ្ញុំម្ចាស់ថ្វាយមធុបាយាស ព្រមទាំងភាជន៍មាស នេះផង ហើយក្រាបទូលតទៅទៀតថា សេចក្ដីប្រាថ្នានៃខ្ញុំម្ចាស់បាន សម្រេចបរិបូណ៌ហើយ ទើបនាងសុជាតា វិលត្រឡប់ទៅកាន់គេហដ្ឋាន

ខ្លួនវិញ ដោយសេចក្ដីត្រេកអរក្រៃលែង ។

## ៤- ទ្រង់សោយមធុបាយាស

លុះព្រះបរមពោធិសត្វបានទទួលមធុបាយាសហើយ ទ្រង់ក្រោកចាកនិគ្រោធព្រឹក្ស ធ្វើពុទ្ធដំណើរទៅកាន់ឆ្នេរស្ទឹងនេរញ្ជរា ចុះស្រង់ទឹកហើយ ទើបស្ដេចនិសីទនាការទៀបឆ្នេរស្ទឹង បែរព្រះភ័ក្ត្រទៅកាន់បូព៌ាទិស ទ្រង់ពូតបាយាសជាពំនូតៗ ប៉ុនផ្លែត្នោត ចំនួន ៧ពំនូត ៧ ដង ជា ៤៩ពំនូត ហើយទ្រង់ធ្វើភត្តកិច្ចអស់ឥតសេសសល់ សមគួរនឹងញាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ៤៩ថ្ងៃដោយបរិបូណ៌ ។ ធ្វើភត្តកិច្ចរួចហើយ ព្រះមហាបុរសត្ថ កាន់យកភាជន៍នៃមធុបាយាស ទៅកាន់ឆ្នេរស្ទឹងនេរញ្ជរា ទ្រង់អធិដ្ឋានថា បើតថាគត បានត្រាស់ដឹងសម្មាសម្ពោធិញាណ សូមឲ្យភាជន៍នេះអណ្ដែតច្រាសខ្សែទឹក អធិដ្ឋានហើយ ស្ដេចបណ្ដែតភាជន៍លើទឹកធាក ។ ខណៈនោះ ភាជន៍មាសនោះ ហាក់ដូចមានចិត្តសំដែងអាការដូចសុវណ្ណហង្ស អណ្ដែតលឿនលយ ច្រាសខ្សែទឹកទៅឆ្ងាយប្រមាណ ៨០ ហត្ថ ទើបលិចចុះ ត្រង់ទៅវិមានកាឡនាគរាជ ទៅប៉ះទង្គិចនឹងភាជន៍នៃអតីតពុទ្ធទាំង ៣ អង្គ ឮសូរគិរ ៗ ហើយចុះទៅប្រតិស្ឋាននៅខាងក្រោមភាជន៍នៃអតីតពុទ្ធទាំងឡាយនោះ ។ កាលនោះ កាឡនាគរាជកំពុងនិទ្រាលក់ និមិត្តតែឮសំឡេងគិរៗនេះហើយ ភ្ញាក់

ឡើងពោលពាក្យថា ថ្ងៃនេះ មានព្រះពុទ្ធមួយអង្គត្រាស់ដឹងទៀតហើយ ពីថ្ងៃមុន មានព្រះពុទ្ធមួយព្រះអង្គត្រាស់រួចទៅហើយ ក៏មានចិត្តត្រេកអរក្រៃលែង ហើយទៅកាន់ទីប្រតិស្ឋានការផន់ ពោលសរសើរពុទ្ធគុណជាអនេកប្រការ ៗ

ឯព្រះបរមពោធិសត្វ ទតព្រះនេត្រឃើញកាផន់ អណ្តែតច្រាសទឹកដោយសេចក្តីអស្ចារ្យយ៉ាងនេះហើយ ទ្រង់អស់សង្ស័យ នឹកក្នុងព្រះទ័យថាអាត្មាអញនឹងបានត្រាស់ដឹងសម្មាសម្ពោធិញាណពិតប្រាកដ ហើយស្តេចវិលត្រឡប់ចូលទៅកាន់សាលវ័ន ដែលកំពុងតែរីកផ្កាស្គុសស្គាយក្រអូបឈ្ងុយឈ្ងប់ ទ្រង់សម្រេចសម្រាន្តឥរិយាបថក្នុងទិវាវិហារក្រោមសាល-ព្រឹក្សមួយដើម ៗ សាយណ្ហសម័យ ព្រះពាយបក់ក្លិនផ្កាក្រអូបផ្សាយពេញអរញ្ញមណ្ឌលសន្ទឹករក្ខាលគារល្វៃ មានសាខាទោរទន់ បក់រវិចដោយរយោបក់រំភើយ រហើយត្រសៀក ហាក់ដូចជាមានចិត្តវិញ្ញាណក្រាបនមស្ការ ជាសក្ការដង្ហោយហៅ សូមនិមន្តទៅត្រាស់ដឹងឆាប់ទៅ ព្រះបរមពោធិសត្វ ស្តេចលីលាឆ្ពោះព្រះភក្ត្រទៅកាន់ពោធិមណ្ឌល ៗ

## ៥-ពុទ្ធដំណើរទៅកាន់ពោធិមណ្ឌល

ព្រះបរមពោធិសត្វ ប្រកបដោយសិរីសម្បត្តិដ៏ប្រសើរ ទ្រង់ពុទ្ធដំណើរសីហនាទគគាតឥតក្តីកតាមមគ្គវិថី មានព្រាហ្មណ៍ម្នាក់ឈ្មោះ

សោត្ថិយ បានស្បូវ ៨ ក្តាប់យកទៅថ្វាយ ទ្រង់ទទួលហើយ យាត្រាឆ្ពោះទៅកាន់ពោធិមណ្ឌល ដល់ហើយទ្រង់ប្រទក្សិណអស្សត្ថព្រឹក្ស ៣ ជុំ ទើបស្តេចក្រាលស្បូវនោះខាងទក្ខិណទិសាភាគនៃពោធិព្រឹក្ស ឯផែនពសុធាក៏កម្បនាការសំដែងអាការហាក់ដូចជាក្រាបទូលថា ទីនេះមិនមែនជាគេនបល្ល័ង្កទេ ស្តេចលើកទៅក្រាលខាងបច្ឆិមទិសាភាគ គទៅខាងឧត្តរទិសាភាគទៀត ទិសទាំង ២នេះ ក៏សំដែងកម្បនាការដូចគ្នាទៀត ទីបំផុតទើបស្តេចលើកទៅក្រាលខាងបុព្វទិសាភាគ នៃពោធិព្រឹក្ស ផែនពសុធាក្រឡាប្រឹថពីតាំងនៅស្ងៀម ហាក់ដូចជាក្រាបទូលថាទីនេះជាគេនបល្ល័ង្កហើយ ក៏ទ្រង់សម្រេចនិសីទនាការ ពត់ព្រះភ្នែនពែន ព្រះបាទដ៏ស្អាត បែរព្រះប្រឹស្ដាង្គទៅកាន់ពោធិមូល បែរព្រះភ័ក្ត្រទៅកាន់បុព្វទិស ហើយតាំងសច្ចាធិដ្ឋានដ៏មាំថា (១)

កាមំ តចោ នហារូ ច អដ្ឋិ ច អវសិស្សតុ
សព្វម្បិ ហិទំ សរីរេ មំសលោហិតំ ឧបសុស្សតុ

សូមឲ្យនៅសល់តែស្បែក សរសៃនឹងឆ្អឹងកុះ តែឯសាច់ឈាមក្នុងសរីរៈទាំងមូលនេះ ចូលឲ្យរីងស្ងួតស្វិតក្រៀមក្រញង់ទៅ បើមិនបានត្រាស់ដឹងម្តងនេះទេ អាត្មាអញមិនព្រមក្រោកចាកបល្ល័ង្កនេះឡើយ ” ។

១_ ឯកនិបាតជាតក ។

# អវិទូរេនិទាន មារវិជយកថាទី ៨

១-មារកេណ្ឌពល, ២-មារធិភដណ្ដើមបល្លង្ករត្ន, ៣-ទេវតាសរសើរបារមី ។

## ១-មារកេណ្ឌពល

ក្នុងសម័យនោះ ទេវបុត្តមារ(១) មានចិត្តបាបកំពុងស្វែងរកទោសព្រះបរមពោធិសត្វ លុះបានឮសំឡេងសាធុការពរនៃពួកទេវនិករដូច្នោះហើយ ក៏ក្រេវក្រោធក្រៃពេក គិតថា ព្រះសិទ្ធត្ថកុមារនេះ ប្រាថ្នាចង់ឲ្យផុតអំណាចនៃអាត្មាអញ បើដូច្នោះ គួរអាត្មាអញនឹងទៅបំផ្លិចបំផ្លាញ កុំឲ្យកន្លងអំណាចអាត្មាអញបាន ក៏ឃោសនាកេណ្ឌពលយាត្រាទ័ពចេញទៅ ។ ឯសេនាមារនោះច្រើនណាស់ មីរដេរដាសរាប់ពុំបាន ខាងមុខ ខាងឆ្វេង ខាងស្ដាំ ខាងក្រោយរហូតដល់កណ្ដាប់ចក្រវាឡជាបំផុត ស្រែករហ៊ោរកញ្ជ្រៀវឮសូរកងរំពងទាំងផែនពសុធា កំរើករំពើកញាប់ញ័រសកលលោក ។ វសវត្តីមារ ឡើងកាន់ដំរីគិរីមេខល និមិត្តជាដៃច្រើនកាន់អាវុធបរពួកពលយាត្រាទ័ពចរចេញទៅ, គួរខ្លាចតក់ស្លុតរន្ធត់ក្រៃពេក ខ្លះពណ៌ខ្មៅ ខៀវ លឿង ក្រហម ខ្លះមានខ្លួនជាទុដ្ឋ ក្បាលជាសេះ, ខ្លះមានខ្លួនជាមនុស្ស ក្បាលជាខ្លា, ខ្លះមានក្បាលច្រើន ផ្សេងគ្នាជាអនេករាប់មិនបាន មកកំញើញព្រះពោធិសត្វ ។ ពួកទេវតាទាំងមួយម៉ឺនលោកធាតុ មានសក្កទេវរាជនឹងព្រះព្រហ្មជាប្រធាន ដែល

---

១ វសវត្តីមារ ។

ចូលមកកាន់ទីសមោសរសើរបារមី ធ្វើគ្រឿងសក្ការបូជាថ្វាយព្រះបរមពោធិសត្វ កាលណា សេនាមារលើកទ័ពចូលមកដោយជិតពោធិ-មណ្ឌលហើយ កាលនោះក៏បបួលគ្នាហោះព្រៀវព្រៃទៅកាន់ទីស្ថានសំនៅសព្វខ្លួនវិញ ឥតមានទេវតាណាមួយ អាចហ៊ានស្ថិតនៅកំដរព្រះពោធិសត្វឡើយ, ស្តេចទ្រង់ប្រថាប់នៅទីនោះតែមួយព្រះអង្គឯង ។

មារពិរោធស្រែកបញ្ជាកងទ័ពថា នែអ្នកនិរទុក្ខទាំងឡាយ ! សិទ្ធត្ថកុមារជាបុត្រព្រះបាទសុទ្ធោទនៈនេះ ឥតអ្នកណាមួយប្រៀបផ្ទឹមឲ្យត្រឹមស្មើឡើយ យើងទាំងឡាយនឹងចូលទៅតយុទ្ធពីមុខមិនបានទេ ត្រូវយើងចូលលុកពីខាងក្រោយវិញ ។ ឯព្រះមហាបុរសស្តេចក្រឡេកទតទៅទីជុំវិញព្រះអង្គ មិនឃើញមានអ្នកណាមួយឡើយ សក្កទេវរាជកាន់ស័ង្ខជ័យ ព្រះមហាព្រហ្មកាន់ស្វេតច្ឆត្រ ហោះត្រឡប់ទៅកាន់វិមានវិញ ទេវតាទាំងឡាយ ក៏រត់ខ្ចាត់ខ្ចាយចោលព្រះអង្គអស់រលីង ស្តេចទតទៅឧត្តរទិសឃើញពួកពលសកលយោធាសេនាមារ លុកចូលមកមីរដេរដាសពាសពេញគ្រៀបគ្រាស្តេចទ្រង់នឹកក្នុងព្រះទ័យថា " អាត្មាអញឥតមានអ្នកណាមួយជាទីពឹងពំនាក់សោះ ក្នុងទីនេះមានតែបារមីទាំង ១០ ប្រការនេះជាបរិស័ទ បើដូច្នោះ គួរតែអាត្មាអញយកបារមីទាំង ១០ ប្រការនេះជាខែល ជាគ្រឿងសស្ត្រាវុធ ច្បាំងតគាំងពាំងនឹងស្តេចមារ នឹង

សេនាមារ ក៏បាក់បង់ឲ្យបរាជ័យ បាលបាញ់គេដងដៃ ក្នុងគ្រាឥឡូវនេះ" ។

## ២- មារាធិរាជដណ្តើមបល្ល័ង្ក

លំដាប់នោះ មហាបុរសត្រាស់ថា "ព្រះពោធិសត្វដែលមានបារមី បំពេញហើយ ត្រូវបានបល្ល័ង្កនេះក្នុងថ្ងៃដែលបានត្រាស់ជាព្រះពុទ្ធ នែមារ! បើអ្នកបានបំពេញពុទ្ធការកធម៌មែន តើអ្នកណាជាសាក្សីអ្នក? មារាធិរាជឆ្លើយថា ពួកពលយើងទាំងអស់នេះ ជាបន្ទាល់សាក្សីយើង ។ ថាហើយក៏លើកដៃចង្អុលទៅពួកពល ពេលនោះ ពួកពលសកលយោធា ទាំងអស់ក៏ឆ្លើយតបមកវិញ ព្រួសន្ធឹកគឹកកងរំពងហាក់ដូចជារហែកផែនដី ថា "យើងទាំងអស់គ្នានេះជាបន្ទាល់សាក្សី", មារាធិរាជក្រាបទូលតបទៅវិញថា «សិទ្ធត្ថ? ថាបើអ្នកបានបំពេញបារមី ចុះអ្នកមានអ្នកណាជាបន្ទាល់សាក្សីឬទេ?" ព្រះមហាសត្វឆ្លើយតបមារវិញថា "បន្ទាល់សាក្សីអ្នក សុទ្ធតែជាបុគ្គលមានចេតនាដឹងថា អ្នកបានបរិច្ចាគទានជាដើម, តែអាត្មាមិនមានបុគ្គលណាមួយ ដែលមានចេតនាជាបន្ទាល់សាក្សីទេ, ឯរឿងបរិច្ចាគទានក្នុងអត្តភាពឯទៀតៗនោះ យើងស្មេះទុកសិនចុះ យើងយកតែរឿងឲ្យទាន ក្នុងកាលដែលយើងកើតជា មហាវេស្សន្តរពោធិសត្វ យើងបានឲ្យទាន ១០៧ ដង, រឿងនេះមហាប្រឋពីទាំងមូលនេះ ឥតមានចេតនាទេ តែអាចធ្វើជាបន្ទាល់សាក្សីយើងបាន, មានព្រះបន្ទូលរួច

ហើយ ទ្រង់ចង្អុលទៅត្រង់ផែនដី ហើយទ្រង់ត្រាស់ថា កាលយើងកើតជាមហាវេស្សន្តរពោធិសត្វ យើងបានឲ្យទាន ១០៧ ដង អ្នកជាបន្ទាល់សាក្សីបានដឹងឮមែនឬទេ ? មហាប្រថពីស្រែកឮសូរសន្ធឹកសន្ធាប់ខ្លាំងក្រៃ លើសលែងសេនាមារទៅទៀត ឆ្លើយឮសំឡេងតែមួយថា បពិត្រព្រះសិទ្ធត្ថ ! យើងជាបន្ទាល់សាក្សីព្រះអង្គ, មហាទានដែលព្រះអង្គបានបរិច្ចាគហើយនោះជាឧត្តមទានមែន ៗ ដំរីគិរីមេខលនៃពួកមារ និមិត្តតែបានឮថា ទានព្រះមហាវេស្សន្តរពោធិសត្វ ក៏ស្ទុតជង្គង់ដល់ដី មារសេនាក៏រត់ខ្ចាត់ខ្ចាយប្រញាប់ទៅកាន់ទិសានុទិស , ឥតមានពលណាមួយទៅកាន់ផ្លូវមួយគ្នាពីនោះឡើយ បោះគ្រឿងសីសាភរណៈនិងនិវត្ថាភរណៈ គ្រឿងអាវុធយុទ្ធភណ្ឌ ដេរដាសពាសពេញលើផ្ទៃប្រថពី យកជីវិតគេចរៀងៗខ្លួន ៗ

## ៣_ទេវតាសរសើរបារមី

លំដាប់នោះ ទេវតា កាលឃើញពួកពលមារអន្តរធានដូច្នេះ ក៏ស្រែកថ្វាយពរសព្ទសាធុការថា: ព្រះសិទ្ធត្ថរាជកុមារ មានជ័យហើយៗ ៗ នាគគ្រុឌទាំងឡាយបន្លឺសំឡេងគឹកកងឡើង ទេពតាព្រហ្មបបួលគ្នាកាន់គ្រឿងសក្ការបូជាក៏ផ្កា ហោះហើរប្រៀវប្រែ ចូលមកគាល់ព្រះមហា

ពោធិសត្វ ពោលសរសើរគុណបារមីថ្វាយពរគ្រប់ ៗ គ្នាថា[១]

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ,
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា នាគគណា មហេសិនោ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ,
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
សុបណ្ណសង្ឃាបិ ជយំ មហេសិនោ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ,
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា ទេវគណា មហេសិនោ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ,
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា ព្រហ្មគណាបិ តាទិនោ ។

---

១ ឯកនិបាតជាតក ។

ប្រែថា កាលនោះ ពួកនាគទាំងឡាយ ជាអ្នកស្វែងរកនូវគុណធម៌ដ៏ធំ ត្រេកអរក្រៃពេកនឹងជ័យជំនះ ស្រែកឃោសនាទៀបពោធិមណ្ឌលថា "ឱហ្ន៎! ព្រះពុទ្ធអង្គទ្រង់ប្រកបដោយសិរីសួស្តី ព្រះអង្គមានជ័យហើយ! ឯមារមានសន្តានចិត្តបាប បរាជ័យហើយ!" ។

ឯគ្រុឌទាំងឡាយ ជាអ្នកស្វែងរកគុណធម៌ដ៏ធំ ត្រេកអរក្រៃពេកនឹងជ័យជំនះ ស្រែកឃោសនាទៀបពោធិមណ្ឌលថា "ឱហ្ន៎! ព្រះពុទ្ធអង្គទ្រង់ប្រកបដោយសិរីសួស្តី ព្រះអង្គមានជ័យហើយ! ឯមារពាលមានសន្តានចិត្តលាមកអាក្រក់ បរាជ័យហើយ!" ។

លំដាប់នោះ ពួកទេវតា ជាអ្នកស្វែងរកនូវគុណធម៌ដ៏ធំទូលាយ ត្រេកអរក្រៃពេកនឹងជ័យជំនះ ស្រែកខ្មោសនាការទៀបពោធិមណ្ឌលថា "ឱហ្ន៎! ព្រះពុទ្ធអង្គ ទ្រង់ប្រកបដោយសិរីសួស្តី ព្រះអង្គមានជ័យហើយ! ឯមារសន្តានចិត្តលាមក បរាជ័យហើយ!" ។

គ្រានោះ ពួកព្រហ្មជាអ្នកស្វែងរកប្រយោជន៍ដូចគ្នាដែរ ត្រេកអរក្រៃលែងនឹងជ័យជំនះ ស្រែកលាន់ឮសន្ធឹកគឹកកងរំពងក្រៃ ទៀបពោធិមណ្ឌថា "ឱហ្ន៎! ព្រះពុទ្ធអង្គ ទ្រង់ប្រកបដោយសិរីសួស្តី ព្រះអង្គមានជ័យហើយ! ឯមារមានសន្តានចិត្តអាក្រក់ក្រៃ បរាជ័យចាញ់ព្រះអង្គហើយ!" ។

ទេវតាទាំងឡាយ ទាំងមួយម៉ឺនលោកធាតុ បបួលគ្នា កាន់គ្រឿងសក្ការបូជាមាលាផ្កាកម្រងគ្រឿងលាប ហោះហើរដេរដាសពាសពេញ គ្រៀបគ្រាមូលមកបូជាព្រះមហាសត្វហើយស្ថិតនៅរៀងរាយ ៗ កាលព្រះអាទិត្យ មិនទាន់អស្តង្គតនៅឡើយ ព្រះមហាបុរសទ្រង់កំចាត់បង់នូវមារនឹងពលសេនាមារហើយ ពួកទេវតាទាំងឡាយ កំពុងបូជា ដោយគ្រឿងសក្ការៈ បោះផ្កាព្រោងព្រាត ធ្លាក់ដេរដាសពាសពេញនៅជិតពោធិមណ្ឌល ទ្រង់គង់ពត់ព្រះភ្នែនពែនព្រះបាទស្អាតបរិសុទ្ធ តាំងសមាធិបម្រុងឲ្យបានត្រាស់ក្នុងថ្ងៃនោះ ។

(នៅមានត)

---

# ព្រះអភិធម្មបិដក

## គម្ពីរព្រះកឋាវត្ថុ

លោក ប៊ូ-ប៉ូ ប្រែរៀបរៀង

## ឧជិសកថា

(តអក)

---

អសង្ខារបរិនិព្វាយីនោះ បានដល់ព្រះអនាគាមិបុគ្គលកើតក្នុងជាន់សុទ្ធាវាសណាមួយ ប្រកបសេចក្ដីព្យាយាមមិនលំបាក ដល់នូវព្រះអរហត្ត ដោយសប្បាយឥតលំបាក យ៉ាងនេះឈ្មោះថា អសង្ខារបរិនិព្វាយី ។

៥ ឧ អនាគាមិ ជលំ បត្វា ឧទ្ធំសោតអកនិដ្ឋគាមី នោះ

បានដល់ព្រះអរិយបុគ្គលដល់នូវអនាគាមិផលក្នុងមនុស្សលោកនេះ អស់ជីវិតិន្ទ្រីយ៍ចាកមនុស្សលោកហើយ ទៅកើតក្នុងជាន់សុទ្ធាវាសទាំងបួន ចាប់ដើមអំពីជាន់អវិហាឡើងទៅ កើតក្នុងជាន់ណា មិនអាចដល់នូវព្រះអរហត្តក្នុងជាន់នោះទេ, លុះរលត់បញ្ចក្ខន្ធ ឡើងទៅកើតក្នុងជាន់អកនិដ្ឋ ដល់នូវព្រះអរហត្តយ៉ាងនេះ មាននាមថា ឧទ្ធំសោតអកនិដ្ឋគាមី ។

សកវាទី ព្រះអរហន្តលះកិលេសបានប៉ុន្មាន ? មានប៉ុន្មានពួក ?

បរវាទី – ព្រះអរហន្តលះកិលេសបានទាំងអស់ ឥតសល់កិលេសណាមួយទេ បើចាត់ដោយសង្ខេបមានពីរពួក គឺព្រះអរហន្តសុក្ខវិបស្សកៈមួយពួក ព្រះអរហន្តបានអភិញ្ញាប្រាំមួយនឹងបានវិជ្ជាបីមួយពួក, បើចាត់

ដោយពិស្ដារមានមួយរយប្រាំបី (១០៨) ពួក ។

ព្រះអរហន្ដឈ្មោះថាសុក្ខវិបស្សកៈនោះ ជាព្រះអរហន្ដសម្រេចព្រះអរហត្ត កាត់បាបធម៌អស់អាសវៈក៏ពិតហើយ ប៉ុន្ដែហោះហើរដើរឮដីអាកាសពុំបាន ដូចជាព្រះចក្ខុបាលត្ថេរ ។

ព្រះអរហន្ដបានអភិញ្ញាប្រាំមួយ នឹងបានវិជ្ជាបីនោះ ហោះទៅឮដីអាកាសបាន រឮកបុព្វេនិវាសញ្ញាណឃើញ បានទិព្វចក្ខុនឹងទិព្វសោតដឹងចិត្តរបស់អ្នកដទៃ ធ្វើឫទ្ធិបានផ្សេង ៗ ដូចជាព្រះមហាមោគ្គល្លានត្ថេរជាដើម ។

ព្រះអរហន្ដដែលចែកដោយពិស្ដារមាន១០៨ពួកនោះ ដោយអំណាចនៃសទ្ធាធិក, បញ្ញាធិក នឹងបដិបត្ដិបួនជាប្រធាន អ្នកប្រាជ្ញគប្បីសន្និដ្ឋានដោយន័យដែលវិសជ្ជនាមកនេះចុះ ។

កង្ខុធិសកថានេះ មានសេចក្ដីថា សកវាទីសួរព្រះអរិយបុគ្គលថា : ព្រះអរិយបុគ្គលលះកិលេសបានដោយឯកទេសនោះ តើព្រះអរិយបុគ្គលមានឈ្មោះថា ឯកទេសអរិយបុគ្គលដែរឬទេ ? ។

បរវាទីអាចារ្យវិសជ្ជនាថា ព្រះអរិយបុគ្គលទាំងឡាយពុំមានឈ្មោះថា ឯកទេសអរិយបុគ្គលទេ ក្រនឹងវិសជ្ជនាឲ្យច្បាស់លាស់ ក្រនឹងស្ដាប់ឲ្យចូលចិត្ត; ព្រោះថាគម្ពីរព្រះបរមត្ថមានខអត្ថសុខុមគម្ភីរភាពណាស់ ក្រ

ទាំងអ្នកស្តាប់ ក្រុទាំងអ្នកសំដែងទាំងពីរខាង ប៉ុន្តែបណ្ឌិតជាតិគប្បីធ្វើមនសិការកំណត់ថា ជាព្រះពុទ្ធាធិប្បាយប្រោសប្រទានព្រះសទ្ធម្មទេសនា ហើយតាំងចិត្តគោរពចំពោះព្រះធម៌ដ៏ជាក្រសែព្រះពុទ្ធដីកា គ្រាន់បានជាធម្មសវនានុត្តរិយានិសង្ស នឹងប្រកបដោយផល អាចការពារនូវទុគ្គតិបានអស់សែននៃកប្ប ហេតុតែបានស្តាប់ព្រះសទ្ធម្មទេសនា សមតាមក្រសែព្រះពុទ្ធដីកាដែលត្រាស់ទុកក្នុងឧរាទប្បាដិមោក្ខថា ៖

សទ្ធម្មស្សវនំ សុត្វា សព្វស្មឹ ជិនសាសនេ
កប្បានិ សតសហស្សានិ ទុគ្គតឹ សោ ន គច្ឆតិ ។

បុគ្គលណាបានស្តាប់ព្រះសទ្ធម្មទេសនា ក្នុងព្រះពុទ្ធសាសនានៃសម្តេចព្រះជិនស្រីសម្មាសម្ពុទ្ធជាអម្ចាស់ទាំងពួង បុគ្គលនោះនឹងកន្លងបង់នូវទុគ្គតិ គឺមិនបានទៅកាន់ទុគ្គតិ អស់កាលដ៏យូរប្រមាណបានសែននៃកប្ប អានិសង្សដែលបានស្តាប់ព្រះសទ្ធម្មនោះ សម្តេចព្រះពុទ្ធអង្គទ្រង់ត្រាស់ទុកយ៉ាងនេះ ។

ឧទ្ទិសកថាចប់

អនេញ្ជកថា

អរហា អនេញ្ជឋិតោ បរិនិព្វាយតីតិ អាមន្តា ៗ

ននុ អរហា បកតិចិត្តេ ឋិតោ បរិនិព្វាយតីតិ អាមន្តា ៗ

អរហា កិរិយាភិចិត្តេ ឋិតោ បរិនិព្វាយតីតិ ៗ

ភរៈនេះ នឹងបានវិសជ្ជនាក្នុងអនេញ្ជកថាតទៅ ដំណើរសេចក្តីតាមព្រះបាលីថា ភគវា សម្តេចព្រះមានព្រះភាគ ដ៏ជាទីសេពគប់នៃទេវតានឹងមនុស្សទាំងឡាយ កាលព្រះអង្គប្រទានព្រះសទ្ធម្មទេសនា ឧបិសកថាចប់ហើយ លំដាប់ពីនោះ ទ្រង់ត្រាស់ទេសនានូវអនេញ្ជកថាតទៅ តាំងជាសកវាទីនឹងបរវាទី ដូចន័យខាងដើមថា ៖

សកវាទី អរហា អនេញ្ជឋិតោ បរិនិព្វាយតិ ព្រះអរហន្តអស់អាសវៈហើយ ឋិតនៅក្នុងអនេញ្ជធម៌ គឺតាំងនៅក្នុងភាពជាអ្នកពុំមានចិត្តញាប់ញ័រ ហើយទើបចូលកាន់ព្រះនិព្វានពិតមែនឬ ?

បរវាទី ទទួលថា អាមន្តា អើ! ព្រះអរហន្តឋិតនៅក្នុងអនេញ្ជធម៌ហើយ ទើបចូលកាន់ព្រះនិព្វានពិតមែន ៗ

សកវាទី– ននុ អរហា បកតិចិត្តេ ឋិតោ បរិនិព្វាយតិ ព្រះអរហន្តឋិតនៅក្នុងចិត្តជាប្រក្រតីហើយ ទើបចូលកាន់ព្រះនិព្វាន នឹងឋិតនៅក្នុងកិរិយាចិត្តហើយ ទើបចូលកាន់ព្រះនិព្វានពិតមែនឬ ?

បរវាទី– អាមន្តា អើ! ពិតមែនដូចពាក្យអ្នកថាហើយ ។

សកវាទី វិបាកចិត្តេ បិតោ ព្រះអរហន្តបិតនៅក្នុងវិបាកចិត្តហើយ ទើបចូលទៅកាន់ព្រះនិព្វាន, បិតនៅក្នុងវិបាកអព្យាកតចិត្តហើយ ទើបចូលកាន់ព្រះនិព្វាន ពិតមែនឬទេ ?

បរវាទី– ព្រះអរហន្តដែលនឹងចូលកាន់ព្រះនិព្វាននោះ រមែងបិតនៅក្នុងវិបាកចិត្ត, បិតនៅក្នុងវិបាកអព្យាកតចិត្តហើយ ទើបចូលកាន់ព្រះនិព្វាន ដូចពាក្យអ្នកថាពិតមែនហើយ ។

សកវាទី– ភគវា ចតុត្ថជ្ឈានា វុដ្ឋហិត្វា សម្តេចព្រះមានព្រះភាគជាម្ចាស់ កាលនឹងស្តេចចូលកាន់ព្រះនិព្វាន ព្រះអង្គចូលកាន់ចតុត្ថជ្ឈាន ចេញចាកចតុត្ថជ្ឈានហើយ ទើបចូលកាន់ព្រះនិព្វានមែនឬ? ឬថាព្រះអង្គចូលកាន់ព្រះនិព្វានក្នុងចន្លោះនៃចតុត្ថជ្ឈាន ?

បរវាទី– ទទួលថា អាមន្តា អើ! មែនដូចពាក្យអ្នកថាហើយ សម្តេចព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលកាន់ព្រះនិព្វានក្នុងចន្លោះនៃចតុត្ថជ្ឈាននឹងបញ្ចមជ្ឈានគត្តា ក្នុងចន្លោះកណ្តាលនៃចតុត្ថជ្ឈាន នឹងបញ្ចមជ្ឈាននោះឯង ព្រះអង្គចូលកាន់ព្រះនិព្វាន; កវត្ថុចិត្តេ បិតោ សម្តេចព្រះមានព្រះភាគ កាលនឹងស្តេចចូលកាន់ព្រះនិព្វាននោះ ព្រះអង្គបិតនៅក្នុងកវត្តចិត្តជាអព្យាក្រឹត មិនចាត់ជាកុសលជាអកុសលឡើយ ។

សព្វេ ហិ សត្តា មែនពិត សត្វទាំងឡាយទាំងពួងដែលកើតមកជាសត្វជាបុគ្គលមានជីវិតទាំងអស់ កាលនឹងស្លាប់នោះមិនដែលកន្លងភវង្គចិត្តទេ; ភវង្គបរិយោសានេ សត្តា សត្វទាំងឡាយធ្វើមរណៈកាលដោយចុតិចិត្ត ក្នុងទីបំផុតនៃភវង្គចិត្តដួចគ្នាទាំងអស់ ឯភវង្គចិត្តនេះ មិនមែនជាចំណែកកុសល នឹងអកុសលទេ ភវង្គចិត្តនោះជាភ្នាក់ងារញាំងជីវិតឲ្យរស់នៅតែប៉ុណ្ណោះ ដូចជាទឹកដែលមាននៅក្នុងជលាល័យគឺសមុទ្រ ទឹកនោះថាស្អាតជាប្រក្រតី; បើមានទឹកពណ៌ទៀវជាដើម ចូលមកលាយឡំវេលាណា ក៏ក្លាយជាទឹកមានពណ៌ទៀវទៅវិញ ទឹកនោះនឹងថាជាទឹកចាស់ក៏មិនបាន នឹងថាជាទឹកថ្មីក៏មិនត្រូវ ទឹកចាស់នោះ គឺជាទឹកថ្លា ប៉ុន្តែជាទឹកមានពណ៌ទៀវទៅវិញ ព្រោះហេតុទឹកឯទៀតចូលមកលាយឡំ ៗ ឯភវង្គចិត្តនេះសោត នឹងចាត់ជាកុសលក៏ចាត់មិនបាន នឹងថាជាអកុសលក៏ថាមិនបាន ព្រោះភវង្គចិត្តនោះមិនមែនជាកុសល មិនមែនជាអកុសល គឺជាអព្យាក្រិត បើចេតសិកខាងកុសលមកអាស្រ័យ ក៏ឈ្មោះថាកុសលចិត្ត បើអកុសលចេតសិកមកអាស្រ័យ ក៏ឈ្មោះថាអកុសលចិត្ត ៗ ភវង្គចិត្តនេះ បើទោសមានអភិជ្ឈាជាដើម ចូលមកបៀតបៀនហើយ ក៏សៅហ្មងទៅ; អនភិជ្ឈាទីហិ គុណេហិ បើគុណទាំងឡាយគឺអនភិជ្ឈា សេចក្តីមិនលោភជាដើម មកពាល់ត្រូវហើយ

ក៏ថាស្អាតបរិសុទ្ធផុតសៅហ្មង; ភវង្គចិត្តជាអព្យាក្រិត កាលចេតសិក
មកអាស្រ័យនោះជាទោសជាគុណទៅ ភវង្គចិត្តនោះទំនុកបម្រុងតែត្រង់
មិនឲ្យអស់ជីវិតប៉ុណ្ណោះ បានដល់ចិត្តជាប្រក្រតីដើម ។ បកតិមនោ
ហិ មែនពិត បកតិចិត្តនោះឯងឈ្មោះថាភវង្គចិត្ត កាលសត្វនឹងអស់ជីវិត
ក៏អស់ដោយអំណាចភវង្គចិត្តឃ្លាតចាកទី (ចុតិ) ។ ការសំដែងចិត្តនេះ
កម្រនឹងពន្យល់ឲ្យឃើញច្បាស់បានណាស់; ហេតុនេះ សូមលើកឧទា-
ហរណ៍មកបញ្ជាក់ដូចនាងឧបាសិកាម្នាក់ជាអ្នកមានសទ្ធា ជាទីពឹងពាក់
អាស្រ័យរបស់ព្រះមហាមិត្តត្ថេរ មានសេចក្ដីដំណាលថា ៖

ថេរោ កិរ កស្សកលេណេ បដិវសតិ បានឮមកថា
ព្រះមហាមិត្តត្ថេរនោះ អាស្រ័យនៅក្នុងកស្សកលេណវិហារ ។ តស្ស
គោចរគាមេ ក្នុងស្រុកជាទីត្រាច់គោចរភិក្ខាចារនៃព្រះមហាមិត្តត្ថេរ
នោះ មានមហាឧបាសិកាម្នាក់ ជាមនុស្សមានសទ្ធាជ្រះថ្លា បុត្តំ វិយ
កត្វា ធ្វើព្រះមហាថេរនោះឲ្យដូចជាកូនប្រុសរបស់ខ្លួន ឧស្សាហ៍ប្រតិបត្តិ
បំរើដោយចតុប្បច្ច័យ ។ ឯកទិវសំ អរញ្ញំ គច្ឆតិ មានមួយថ្ងៃ
មហាឧបាសិកានោះរៀបចំដំណើរនឹងចេញទៅព្រៃ ទើបហៅកូនស្រីមកផ្ដាំថា
អម្ម ម្នាលនាង ឯងចូរកុំធ្វេសប្រហែសនឹងការកុសល ចូរខំយកចិត្តទុក
ដាក់ បុរាណតណ្ឌុលា អង្ករចាស់ម៉ែដាក់ក្នុងភាជន៍ឯណោះ ទឹកដោះ

សប្បុទឹកអំពៅទៅក្នុងទីឯណា៖ ឯងចូរយកមកដណ្តាំបាយ រួចលាយជាមួយនឹងទឹកដោះទឹកអំពៅ និងសប្បៀប្រគេនលោកម្ចាស់មហាមិត្តត្ថេរជាបងប្រុសរបស់ឯងផង សល់អំពីនោះឯងចូរបរិភោគជាអាហារទៅចុះ ។

នាងធីតាសួរមាតាថា តំ កុញ្ជិ សប្បិ ចុះម៉ែនឹងបរិភោគនូវភោជនឯណា ? មហាឧបាសិកាប្រាប់ថា រត្តិយោ បក្កំ អញបរិភោគបាយកកដែលដណ្តាំសល់ពីល្ងាចមិញ ជាមួយទឹកជ្រក់រួចស្រេចហើយ ។ នាងធីតាសួរថា ធិវា តំ កុញ្ជិ សប្បិ ចុះវេលាថ្ងៃម៉ែនឹងបរិភោគភោជនាហារឯណា? ។ មហាឧបាសិកាប្រាប់ថា សាកបណ្ណំ បក្ខិ-បិត្វា ឯងចូរដាក់ស្លឹកឈើដ៏ជូរ បបរជាមួយក្រុងអង្ករទុកឲ្យម៉ែ ។ វិលមកវិញ នឹងបរិភោគបបរនោះពេលថ្ងៃ; មហាឧបាសិកាផ្តាំធីតាស្រេចហើយ ក៏ទៅឯព្រៃតាមកិច្ចនៃខ្លួន ។

ចីវរំ ចារុបេត្វា ចំណែកព្រះមហាមិត្តត្ថេរនោះ កាលមហា-ឧបាសិកាកំពុងតែនិយាយជាមួយកូនស្រី លោកក៏និមន្តចូលទៅដល់ផ្ទះហើយ បានឮមហាឧបាសិកាផ្តាំកូនស្រីដូច្នោះ ទើបឲ្យឱវាទទូន្មានខ្លួនលោកថា តាវ កញ្ជិយេន កុញ្ជិ បានឮថា មហាឧបាសិកាបរិភោគបាយកកជាមួយទឹកជ្រក់ពីព្រលឹម ហើយបរិភោគចុងអង្ករដែលផ្តាំឲ្យកូនស្រីបបរទុកឲ្យក្នុងពេលថ្ងៃត្រង់; ចំណែកខ្លួនអ្នកឯងគេប្រាប់ធីតាឲ្យចំអិន

គោជនាហារ យ៉ាងឧត្តមថ្លៃថ្លាណាស់; ព្រោះតែខ្លួនអ្នកឯងនេះ បានជាមហាឧបាសិកាមានកង្វល់ច្រើន ស្មើតែចេញទៅធ្វើស្រែចម្ការមិនរួច មហាឧបាសិកាចំធ្វើកុសលយ៉ាងនេះ ព្រោះតែចង់បានសម្បត្តិបីប្រការ គឺសម្បត្តិមនុស្ស សម្បត្តិសួគ៌ នឹងសម្បត្តិព្រះនិព្វាន ចុះខ្លួនអ្នកឯងអាចនឹងឲ្យសម្បត្តិទាំងបីប្រការដល់មហាឧបាសិកាបានដែរឬមិនបានទេ? បើខ្លួននៅប្រកបដោយរាគៈទោសៈនឹងមោហៈយ៉ាងនេះ មិនគួរនឹងបរិភោគអាហារបិណ្ឌបាតរបស់មហាឧបាសិកានេះទេ លុះតែប្រាសចាកកិលេសមានរាគៈជាដើម ទើបសមគួរនឹងបរិភោគបាន បត្តំ ថវិកាយ បក្ខិ-បិត្វា គិតដូច្នេះហើយ ក៏ប្រកបាត្រចូលក្នុងស្ពាយបាត្រវិញ ដោះខ្សែត្រឡប់ទៅឯកសកលេណវិហារ ដាក់បាត្រទុកក្រោមគ្រែហាលចីវរលើខ្សែស្បៀង ហើយអធិដ្ឋានតាំងចិត្តព្យាយាមថា "អរហត្តំ អបា-បុណិត្វា បើអាត្មាអញមិនបានសម្រេចព្រះអរហត្តទេ នឹងមិនលះបង់សេចក្តីព្យាយាមឡើយ" អធិដ្ឋានដូច្នេះហើយ ក៏តាំងចិត្តចំរើនវិបស្សនាកម្មដ្ឋាន បុរេភត្តំ ឯវ បានសម្រេចព្រះអរហត្តផលញាណ ក្នុងកាលជាបុរេភត្ត គឺពេលព្រឹកនោះ ជាព្រះមហាខីណាស្រពដ៏ប្រសើរក្នុងបវរ-ពុទ្ធសាសនា ។ រុក្ខាម្ហិ អធិវត្ថា ទេវតាដែលស្ថិតនៅដើមឈើ ក្បែរទ្វារគុហានោះ បន្លឺឧទានគាថាថា នមោ តេ បុរិសាជញ្ញ បពិត្រ

លោកម្ចាស់ឈ្មោះថាបុរិសាជានេយ្យ ខ្ញុំសូមថ្វាយបង្គំដល់លោកម្ចាស់ដ៏ជា ជិនបុត្រ នមោ តេ បុរិសុត្តម បពិត្រលោកម្ចាស់អ្នកឧត្តមជាងបុរស ខ្ញុំសូមនមស្ការដល់លោកម្ចាស់, លោកម្ចាស់អស់អាសវៈហើយ ជាទក្ខិណេយ្យបុគ្គលគួរនឹងទទួលទក្ខិណាទាន បពិត្រព្រះករុណា អ្នកមាន សីលាទិគុណដ៏ចំរើន តុម្ហាទិសានំ ឧត្តា ស្ត្រីជកបានប្រគេនបិណ្ឌបាតទាន ដល់ព្រះមហាថេរទាំងឡាយដូចជាលោកម្ចាស់ នឹងផុតចាកទុក្ខ ជាប្រាកដឥតសង្ស័យឡើយ ។

ថេរោ ឧដ្ឋហិត្វា ព្រះមហាមិត្តត្ថេរលុះបានសម្រេចព្រះអរហត្ត ហើយ ទើបក្រោកពីអាសនៈចេញមកបើកទ្វារបន្ទប់សម្លឹងមើលកាល ក៏ ដឹងថានៅជាវេលាភិក្ខាចារ មិនទាន់ហួសកាលបិណ្ឌបាតទេ ក៏ស្លៀកស្បង់ ដណ្ដប់ឧត្តរាសង្គៈ យុំសម្ពត់សង្ឃាដី កាន់បាត្រចូលទៅក្នុងស្រុក សម្បាទេត្វា ចំណែកជីតានៃមហាឧបាសិកា ក៏ចាត់ចែងខាទនីយៈភោជនីយាហារ តាមបណ្ដាំមាតាស្រេចហើយ អង្គុយចាំមើលផ្លូវព្រះមហាថេរក្បែរ ទ្វារផ្ទះដោយសំគាល់ថា ព្រះមហាថេរនឹងមកដល់ឥឡូវនេះ ឃរទ្វារំ សម្បត្តេ ព្រះមហាមិត្តត្ថេរនិមន្តទៅដោយសម្រួមឥន្ទ្រិយ៍ដល់ទ្វារផ្ទះ, ជីតានៃមហាឧបាសិកាចុះមកទទួលយកបាត្រ ឡើងទៅលើផ្ទះ ដាក់ភោជនាហារដែលខ្លួនចាត់ចែងទុកបម្រុងនោះ ពេញបាត្រហើយយកមកប្រគេន

ព្រះមហាថេរ ៗ ធ្វើអនុមោទនាថា សុខំ ហោតុ សេចក្តីសុខចូរមានដល់នាង; រួចហើយនិមន្តត្រឡប់ទៅឯ កសកលេណវិហារវិញ ។

សកវាទី សួរតទៅទៀតថា ព្រះអរហន្តដែលស្ថិតនៅក្នុងអនេញ្ជធម៌ហើយ បានឈ្មោះថាមានចិត្តប្រាសចាកកាមកិលេស ដែលគ្រាំនៅក្នុងខន្ធសន្តាន, ព្រះអរហន្តនោះ បង្អោនចិត្តទៅដើម្បីនឹងសំដែងឫទ្ធិមានប្រការផ្សេងៗបានដែរ ឬមិនបានទេ ?

បរវាទី- អាមន្តា អើ! អរិយា អនេញ្ជប៉ត្តោ ព្រះអរហន្តដែលស្ថិតនៅក្នុងអនេញ្ជធម៌ គឺមិនបានញាប់ញ័រដោយតណ្ហា មានៈនឹងទិដ្ឋិនោះ រមែងសំដែងឫទ្ធិបានផ្សេងៗ តាមសេចក្តីប្រាថ្នា ។

សកវាទី- ពាក្យដែលអ្នកថា ព្រះអរហន្តមិនញាប់ញ័រដោយតណ្ហា មានៈនឹងទិដ្ឋិនោះ រមែងសំដែងឫទ្ធិបានផ្សេងៗដូច្នេះ ពាក្យនេះមិនសមនឹងពាក្យខាងចុងទេ; ពាក្យក្នុងព្រះសូត្រនោះថា ព្រះមហាមោគ្គល្លានត្ថេរជាអគ្គសាវកខាងឫទ្ធិ ពួកតិត្ថិយ៍ជួលចោរទាំងឡាយឲ្យទៅសម្លាប់ ចោរទាំងនោះទៅប្រុងសម្លាប់ក្នុងថ្ងៃទីមួយ នឹងទីពីរ សម្លាប់មិនបាន ព្រោះលោកសំដែងឫទ្ធិហោះគេចចេញទៅ លុះដល់ថ្ងៃជាគម្រប់បី លោកមិនសំដែងឫទ្ធិ មិនហោះគេចចេញ លោកនៅឲ្យចោរសម្លាប់ ចោរទាំងនោះវាយលោកនឹងដំបងឲ្យបែកបាក់ឆ្អឹងល្អិតល្អះចប៉ុនគ្រាប់អង្ករបាក់ ហើយ

លោកចូលឈានសមាបត្តិទៅគាល់សម្តេចព្រះបរមសាស្តា ក្រាបទូលលាទៅបរិនិព្វានក្នុងប្រទេសឈ្មោះកាឡសិលា ; បើអាងថាព្រះអរហន្តស្ថិតនៅក្នុងអនេញ្ជធម៌ ហើយអាចសំដែងឫទ្ធិបានតាមចិត្តប្រាថ្នា, ចុះហេតុអ្វីបានជាព្រះមហាមោគ្គល្លានត្ថេរ មិនសំដែងឫទ្ធិផ្សេងៗឲ្យពួកចោរខ្លាចចេញទៅ ? បែរជានៅស្ងៀមឲ្យពួកចោរសម្លាប់បាន ? ។ ពាក្យដែលអ្នកថាព្រះអរហន្តស្ថិតនៅក្នុងអនេញ្ជធម៌នោះ អាចសំដែងឫទ្ធិផ្សេងៗបាន ពាក្យនេះមិនស្របគ្នានឹងពាក្យដែលថា ព្រះមហាមោគ្គល្លានត្ថេរពួកចោរប្រហារឲ្យចូលកាន់ព្រះនិព្វាន ពាក្យមុននឹងពាក្យក្រោយមិនសមគ្នា អាជាធាហិ ឯត្តហំ អ្នកចូរទទួលទូវទោសរបស់អ្នកដែលយើងសង្កត់សង្កិនចុះ ។

បរវាទី- ឆហោរិ វត្តេញ អ្នកកុំគប្បីថាដូច្នេះ មិនសមគួរទេ ធម្មតាព្រះអរហន្តដែលស្ថិតនៅក្នុងអនេញ្ជធម៌ហើយ ក៏រមែងសំដែងឫទ្ធិបានផ្សេង ៗ តាមប្រាថ្នា ; ខ្ញុំសូមសួរទៅអ្នកវិញ ចុះស្តេចនន្ទោបនន្ទនាគរាជនោះ ព្រះមហាមោគ្គល្លានត្ថេរទូន្មានឲ្យអស់ពុតកំណាចដោយសំដែងឫទ្ធិទាល់តែបានប្រគល់កាយថ្វាជីវិតដល់ព្រះរតនត្រ័យ តាំងនៅក្នុងសរណគមន៍មែនឬទេ ? ។

សកវាទី- អើ! អើចឹងមែនហើយ ការដែលព្រះមហាមោគ្គល្លានត្ថេរនឹងសំដែងឫទ្ធិទូន្មាននន្ទោបនន្ទកុជង្គនោះ ក៏អាស្រ័យសម្តេចព្រះមានព្រះ

ភាគ ទ្រង់ត្រាស់អនុញ្ញាត ជាដើមហេតុដែរ ។

ឯកស្មឹ ការេ សមយេ បានឮថា សម័យមួយ អនាថបិណ្ឌិក-មហាសេដ្ឋីស្ដាប់ព្រះសទ្ធម្មទេសនាក្នុងសំណាក់នៃព្រះមានព្រះភាគ កាលចប់ព្រះសទ្ធម្មទេសនាហើយ ទើបនិមន្តសម្ដេចព្រះបរមទសពលព្រមទាំងព្រះភិក្ខុសង្ឃប្រាំរយ ឲ្យទៅទទួលអាហារបិណ្ឌបាតទាន ក្នុងផ្ទះនៃខ្លួន អង្គសម្ដេចព្រះបរមទសពល ក៏ទទួលអារាធនាដោយតុណ្ហីភាព ។ អនាថបិណ្ឌិកមហាសេដ្ឋី ថ្វាយបង្គំលាត្រឡប់ទៅផ្ទះវិញ ។

តំ ធិវសំ បច្ចូសកាលេ ក្នុងវេលាបច្ចូសសម័យជិតភ្លឺថ្ងៃនោះ សម្ដេចព្រះមានព្រះភាគចេញចាកមហាករុណាសមាបត្តិ ទ្រង់ពិចារណាមើលពួកវេនេយ្យសត្វទាំងពួង ដែលមានឧបនិស្ស័យក្នុងមុីននៃលោកជាតុ ក៏ឃើញស្ដេចនន្ទោបនន្ទនាគរាជមកជាប់នៅក្នុងសំណាញ់ គឺព្រះពុទ្ធ-ញ្ញាណ ទើបទ្រង់អាវជ្ជនាការពិចារណាតទៅទៀត ក៏ទ្រង់ជ្រាបច្បាស់ថា ព្រះមហាមោគ្គល្លាននឹងទូន្មាននាគរាជឲ្យអស់ពុតត្បុតបាន ហើយនឹងឲ្យស្ថិតនៅក្នុងព្រះត្រៃសរណគមន៍ផង លុះរាត្រីភ្លឺជ្រះស្រឡះហើយ ទើបត្រាស់នឹងព្រះអានន្ទឲ្យផ្ដៀងព្រះសង្ឃប្រាំរយថា "តថាគតនឹងស្ដេចទៅទទួលបិណ្ឌបាតក្នុងផ្ទះអនាថបិណ្ឌិកមហាសេដ្ឋី តាមនភាល័យប្រទេសថៃទេវតារិក" ។ ព្រះអានន្ទត្ថេរ ក៏ផ្ដៀងព្រះសង្ឃប្រាំរយអង្គតាមទ្រង់បង្គាប់ៗ

តំ ទិវសំ សជ្ជយឹសុ ក្នុងថ្ងៃនោះ ពួកបរិស័ទនាគចាត់ចែងទីកន្លែងដីកស្រុក ដើម្បីស្តេចនន្ទោបនន្ទនាគរាជ ។ ទិព្វរតនបល្លង្កេ និសីទិត្វា គ្រានោះ នាគរាជទ្រង់គង់លើរតនបល្ល័ង្កជាទិព្យក្រោមបវរសេតច្ឆត្រ មាននាគបរិស័ទចោមរោមជុំជិត នាគនារីច្រៀងរាំដេញដំប្រគំដូរ្យតន្ត្រីមានប្រការផ្សេង ៗ សម្លឹងមើលនូវទិព្យក្រយាហារដែលនាគបរិស័ទចាត់ចែងយកមកដម្កល់ទុកក្នុងទីនោះ ។

អថខោ ភគវា គ្រានោះ សម្តេចព្រះមានព្រះភាគមានព្រះខីណាស្រពសង្ឃជាច្រើន ប្រមាណប្រាំរយអង្គ ចោមរោមហែហម ហោះតាមផ្ទៃអាកាស ស្តេចនន្ទោបនន្ទនាគរាជមើលឃើញព្រះអង្គយ៉ាងណា ព្រះអង្គក៏ទ្រង់ឃើញយ៉ាងនោះ បែរព្រះភក្ត្រឆ្ពោះទៅស្ថានតាវត្តិង្សពិភព ។ គ្រានោះ ស្តេចនន្ទោបនន្ទនាគរាជគិតថា ឥមេ មុណ្ឌកា ស្រមណ៍ត្រងោលទាំងនេះ នឹងទៅឯតាវត្តិង្សពិភព ហោះរំលងលើក្បាលអញ ហាក់ដូចជាពោយធុលីខាងឆ្វេងស្មាំត្រូវក្បាលអញៗ នឹងធ្វើកិច្ចរាំងកុំឲ្យទៅរួច គិតហើយក៏ទៅឯជើងភ្នំព្រះសុមេរុរាជគិរី និរមិតសរីរៈឥន្ទ្រីយ៍ឲ្យធំរួបរឹតភ្នំព្រះសុមេរុដោយភ្នែនប្រាំពីរជុំហើយ បើកពពារប៉ាំងបិទភ្នំព្រះសុមេរុ ។

(នៅមានត)

(តមក)

# សម្តេចព្រះធម្មលិខិត លំ-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈិន ពិនិត្យ

កាលនោះ សេនាគុត្តក៏បានហៅនន្ទកុមារ ឲ្យចូលមកដល់ហើយ ក៏លើកធីតារបស់ខ្លួនឲ្យជាភរិយានៃនន្ទកុមារ ហើយចែកសម្បត្តិជាច្រើន ដល់នន្ទកុមារនោះឯង ។

លុះកន្លងទៅបាន ៧ ថ្ងៃ នន្ទកុមារបានដើរចេញទៅក្នុងទីនោះៗ ដើម្បីសម្រាកស្ងួន ក៏មានគំនិតមួយកើតឡើងជាថ្មីថា: អាត្មាអញនឹងទៅឃើញនូវព្រៃឧទ្យានជាមង្គលរបស់ស្តេចឥឡូវនេះឯង; ហេតុតែបុណ្យព្រេងមកដាស់តឿន នន្ទកុមារក៏ដើរចូលទៅក្នុងព្រៃឧទ្យាន ហើយឡើងទៅដេកទទូរក្បាលលើផែនថ្មមង្គលសិលា សម្រាប់ធ្វើអភិសេកមហាក្សត្រិយ៍ពីបុរាណ ក្នុងទីនោះឯង ។ ដួនជាថ្ងៃនោះ ព្រះបាទពារាណសីបរមក្សត្រិយ៍ ទ្រង់សោយព្រះទិវង្គតកន្លងទៅបាន ៧ ថ្ងៃហើយ ។ ពួកសេវកាមាត្យក្តី បុរោហិតក្តី ក៏បបួលគ្នាចាត់ចែងធ្វើបូជាសរីរកិច្ច ព្រះបរមក្សត្រិយ៍រួចស្រេចហើយ ក៏អង្គុយប្រជុំគ្នានៅមុខព្រះលាន ប្រឹក្សាគ្នាថា: ព្រះមហាក្សត្រិយ៍ជាម្ចាស់របស់យើងទាំងឡាយ ព្រះអង្គមានតែ

ព្រះរាជធីតាមួយព្រះអង្គ ឯព្រះរាជបុត្រពុំមានឡើយ, ធម្មតារាជសម្បត្តិក្នុងព្រះនគរ តែគ្មានស្តេចសោយរាជ្យហើយ, ពុំបានស្ថិតស្ថេរនៅយូរឡើយ នឹងវិនាសទៅជាពុំខានពិត ។

ដូច្នេះ ត្រូវតែយើងទាំងឡាយគិតផ្សងរកអ្នកមានបុណ្យ នឹងបាននាំយកមកអភិសេកឲ្យសោយរាជ្យទើបបាន ។ ប្រជាពលរដ្ឋទាំងឡាយមានសេនាបតីជាដើម ក៏ព្រមព្រៀងគ្នាបានយកបុស្សរថមកទឹមសេះសិន្ធពបួនគូ មានសម្បុរដូចផ្កាកុមុទ ហើយដម្កល់នូវគ្រឿងរាជកកុធភណ្ឌទាំងប្រាំ មានស្វេតច្ឆត្រជាប្រធាន នឹងខ្សែសម្រាប់បរ លើរាជរថស្រេចហើយក៏ផ្សងលែងរាជរថនោះទៅ ហើយប្រគំនូវភ្លេងតូរ្យតន្ត្រីតាមក្រោយ ។

ឯសេះក៏នាំរាជរថចេញទៅតាមទ្វារខាងកើត មានមុខសំដៅទៅកាន់សួនឧទ្យាន ។ ហេតុដែលបណ្ដាលឲ្យសេះ នាំរាជរថផ្ទោះទៅកាន់ព្រៃឧទ្យាននោះ ដោយបុណ្យដែលនន្ទកុមារ បានកសាងសន្សំទុកមកអំពីបុព្វជាតិនោះឯង ។

កាលនោះ មនុស្សពួកខ្លះពោលថា: យើងទាំងឡាយត្រូវតែញ៉ាំងរាជរថឲ្យត្រឡប់មកវិញ ។

ចំណែកព្រាហ្មណ៍បុរោហិត ក៏និយាយឃាត់ហាមថា : អ្នកទាំងឡាយមិនត្រូវឃាត់រាជរថឲ្យត្រឡប់មកវិញឡើយ ។ ឯសេះទាំងគូរសោត

ក៏នាំរាជរថនោះចូលទៅដល់ឧទ្យានហើយ ធ្វើប្រទក្សិណបីជុំ មានសភាព ដូចជាប្រុងប្រៀបនឹងទទួលកុមារឲ្យជិះលើរាជរថ ទើបស្ថិតនៅនឹងក្នុងទី នោះឯង ។

ទើបបុរោហិត យកដៃបើកសំពត់ដណ្តប់ចេញ ហើយរមិលមើល លក្ខណៈផ្ទៃបាទជើងទាំងពីរ, លុះបានដឹងបានយល់សព្វគ្រប់ហើយ ក៏ ពោលថា ក្នុងជម្ពូទ្វីបនេះ ត្រូវលើកទុកសិនចុះ ឯកុមារដែលប្រកប ដោយលក្ខណៈយ៉ាងនេះ ប្រាកដជាបុគ្គលអាចនឹងសោយរាជសម្បត្តិ ជា ក្សត្រិយ៍ដ៏ប្រសើរក្នុងទ្វីបធំទាំងបួន, មានទ្វីបតូច ៗ ពីរពាន់ជាបរិវារបាន ដោយពិត; កាលបើបុរោហិត បានពោលដូច្នេះហើយ ក៏ចាត់ពួកភ្លេងឲ្យ ប្រគំនូវភ្លេងតូរ្យតន្ត្រីទាំងឡាយបីដង ដើម្បីពិចារណាមើលនូវប្រាជ្ញានៃ កុមារនោះជាថ្មីទៀត ។

កាលនោះ នន្ទកុមារបានបើកភ្នែកឡើងរមិលមើលជនទាំងឡាយ នោះ ហើយសួរថា: អ្នកទាំងឡាយចូលមកប្រជុំគ្នានៅទីនេះ តើដោយ មានហេតុអ្វី ?

អាមាត្យទាំងឡាយពោលគួបព្រមគ្នាថា: បពិត្រព្រះសម្មតិទេព រាជសម្បត្តិក្នុងក្រុងពារាណសីត្រូវបានដល់ព្រះអង្គហើយ ។

នន្ទកុមារសួរថា: ចុះព្រះរាជាជាម្ចាស់នៃអ្នកទាំងឡាយ តើស្តេច

ទៅណាទៅ? ។ អាមាត្យទាំងឡាយពោលតបវិញថា: បពិត្រព្រះសម្មតិទេព ព្រះរាជាជាម្ចាស់នៃយើងទាំងឡាយ ទ្រង់ព្រះទិវង្គតទៅកាន់បរលោកនាយហើយ ។ នន្ទកុមារសួរទៀតថា: ព្រះរាជាជាម្ចាស់នៃអ្នកទាំងឡាយទ្រង់ព្រះទិវង្គតកន្លងទៅបានប៉ុន្មានថ្ងៃហើយ ? ។ អាមាត្យទាំងឡាយពោលតបថា : ព្រះរាជាជាម្ចាស់នៃយើងទាំងឡាយទ្រង់ព្រះទិវង្គតកន្លងទៅបាន ៧ ថ្ងៃហើយ ។ នន្ទកុមារសួរទៀតថា: ស្តេចជាម្ចាស់នៃអ្នកទាំងឡាយមានព្រះរាជបុត្រ ព្រះរាជធីតាខ្លះដែរឬទេ ? ។ អាមាត្យពោលតបថា: ស្តេចជាម្ចាស់នៃយើងមានតែព្រះរាជធីតា ពុំមានព្រះរាជបុត្រឡើយ សូមព្រះអង្គទ្រង់ជ្រាប ។ នន្ទកុមារបានស្តាប់ហើយពោលថា : បើដូច្នេះ អាត្មាអញនឹងទទួលសោយរាជសម្បត្តិដោយពិត ។

លំដាប់នោះ អាមាត្យទាំងឡាយនឹងបុរោហិត ព្រមទាំងមហាជនទាំងអស់ ក៏ព្រមព្រៀងគ្នា បានចាត់ចែងធ្វើមណ្ឌបកែវ ដើម្បីនឹងអភិសេក ទើបទៅដង្ហែព្រះរាជធីតាមកធ្វើប្រដាប់ស្អិតស្អាងស្រេចហើយនាំចូលទៅកាន់សួនឧទ្យាន រៀបធ្វើពិធីអភិសេកកុមារឲ្យសោយរាជ្យជាម្ចាស់ជីវិតនៃខុន ។ ហើយអភិសេកព្រះរាជធីតាឲ្យជាព្រះអគ្គមហេសីក្នុងកាលនោះឯង ។

កាលនោះ អាមាត្យទាំងឡាយ បាននាំយកសំពត់សម្រាប់រាជ្យ

ដីមានដំឡៃមួយសែនកហាបណៈមកថ្វាយនន្ទកកុមារនោះ ដើម្បីទ្រង់ស្លៀកធ្វើអភិសេកតាមព្រះបវេណីអំពីបុរាណរៀងមក ។

នន្ទកកុមារសួរថា: តាតា ម្នាលអ្នកទាំងឡាយ ! សំពត់នេះ តើជាសំពត់សម្រាប់ធ្វើអ្វី? អាមាត្យទាំងឡាយក្រាបបង្គំទូលថា : បពិត្រព្រះសម្មតិទេព, សំពត់នេះ សម្រាប់ថ្វាយបរមក្សត្រិយ៍ស្តេចទ្រង់ស្លៀកអភិសេក ។

នន្ទកកុមារបានស្តាប់ហើយក៏សួរផ្ទួនទៀតថា: ម្នាលអ្នកទាំងឡាយ សំពត់នេះមានសាច់គ្រាស់ណាស់ មិនដូច្នេះទេឬ? ។ ពួកអាមាត្យក្រាបបង្គំទូលថា : បពិត្រព្រះសម្មតិទេព ! បណ្តាសំពត់សម្រាប់មនុស្សទាំងឡាយប្រើប្រាស់ មិនមានសំពត់ណាដទៃមានសាច់ល្អិតម៉ដ្ឋ ជាងសំពត់នេះឡើយ សូមទ្រង់ជ្រាប ។ នន្ទកកុមារសួរទៀតថា: ចុះព្រះរាជាជាម្ចាស់នៃអ្នកទាំងឡាយស្លៀកសំពត់យ៉ាងហ្នឹងឬ? ។

អាមាត្យក្រាបបង្គំទូលថា : បពិត្រព្រះសម្មតិទេព! ក្សត្រិយ៍ជាម្ចាស់នៃយើងទាំងឡាយ ព្រះអង្គតែងទ្រង់សំពត់មានសភាពយ៉ាងនេះឯង ។

លុះនន្ទកបរមក្សត្រិយ៍បានស្តាប់ហើយ ទ្រង់ត្រាស់ថា : បើដូចនេះ យើងសំគាល់ថាព្រះរាជាជាអម្ចាស់នៃអ្នកទាំងឡាយ ជាបុគ្គលឥតបុណ្យដោយពិត ; ណ្ហើយចុះ! ត្រូវអ្នកទាំងឡាយយកកុណ្ឌីមាសមកឲ្យយើង ។

និងបានឲ្យនូវសំពត់សម្រាប់ស្លៀកដណ្ដប់ឥឡូវនេះឯង ។

ឯអាមាត្យទាំងឡាយ ក៏បានយកកុណ្ឌីមាសនាំចូលមកថ្វាយមួយរំពេចនោះឯង ។

ទើបនន្ទកបរមក្សត្រិយ៍នោះ ទ្រង់កាន់យកកុណ្ឌីមាសហើយលាងព្រះហស្ដ ព្រះឱស្ឋ ចាប់យកទឹកដោយព្រះហស្ដ ហើយបាចសាចទៅក្នុងទិសខាងកើត ។

លំដាប់នោះមានកប្បព្រឹក្ស ១៦ ដើម ទំលាយនូវផែនដីដុះឡើងមួយរំពេចនោះដែរ ទើបព្រះនន្ទកពជទ្រង់បាចទឹកទៅទិសខាងត្បូង ក៏មានកប្បព្រឹក្ស ១៦ ដើមដុះឡើងទៀត; ទ្រង់បាចទឹកទៅទិសខាងលិចក៏មានកប្បព្រឹក្ស ១៦ ដើមដុះឡើងទៀត; បាចទឹកទៅទិសខាងជើង ក៏មានកប្បព្រឹក្ស ១៦ ដើមដុះឡើងទៀត រួមទាំងអស់ត្រូវជាកប្បព្រឹក្ស ៦៤ ដើម កើតឡើងប្រាកដ ដោយផលានិសង្សចីវរទានពីអតីតកាលនោះឯង ។

ព្រះនន្ទកពជបរមក្សត្រិយ៍សោត ស្ដេចកាន់យកសំពត់ទិព្យមួយមកទ្រង់ស្លៀក; យកសំពត់ទិព្យមួយមកទ្រង់ដណ្ដប់ ហើយត្រាស់បង្គាប់ទៅសេវកាមាត្យទាំងឡាយ ថា : អ្នកទាំងឡាយ ត្រូវចាត់ឲ្យវាយស្គរ ត្រាច់ទៅក្នុងនគរទាំងអស់ថា : ស្ត្រីទាំងឡាយ ដែលនៅក្នុងដែនព្រះបាទនន្ទកពជទាំងអស់ជាស្ត្រីអ្នកក្បាញរវៃ; ចាប់ដើមអំពីថ្ងៃនេះទៅ មិនត្រូវឲ្យរវល់

ចំពោះការត្បាញរវៃទៀតឡើយ ត្រូវយកសំពត់ទិព្យអំពីដើមកប្បព្រឹក្សមក ស្លៀកដណ្ដប់ប្រើប្រាស់តាមចិត្តចុះ; ស្រេចហើយស្ដេចតាត់ឲ្យលើកស្វេត. ច្ឆត្របើកបាំងពីលើព្រះអង្គ ដ៏ប្រដាប់ស្អិតស្អាងដោយប្រពៃ គង់លើដំរី ដ៏ប្រសើរយាងកួលទៅក្នុងព្រះនគរ; លុះបានដល់ហើយ ក៏យាងចុះពីដំរី ឡើងទៅកាន់ប្រាង្គណ៍ប្រាសាទដ៏ប្រសើរ សោយមហាសម្បត្តិ ប្រកប ដោយសិរីសួស្ដី ជាសុខក្សេមក្សាន្ត ឥតមានទុក្ខភ័យអ្វីបៀតបៀនព្រះអង្គ ឡើយ មានព្រះនាមល្បីប្រាកដថា: "ព្រះបាទនន្ទកមហារាជ" ដោយពិតៗ

ព្រោះហេតុដូច្នោះ អ្នកប្រាជ្ញទាំងឡាយអំពីមុន លោកសំដែង សរសើរផលានិសង្សទាន ដោយបទព្រះគាថាទាំងឡាយដូច្នេះថា :

យថា សាសបមត្តម្ហា ពីជា និគ្រោធបាទបោ
ជាយតេ សតសាខាឌ្ឍោ មហានិលម្ពកោបមោ
តថេវ បុញ្ញកម្មម្ហា អណុម្ហា មហប្ផលំ
ហោតីតិ អប្បំ បុញ្ញន្តិ នាវមញ្ញេយ្យ បណ្ឌិតោ ៗ

អធិប្បាយថា: ដើមជ្រៃដ៏ស្កុកស្កុមម៉ាំមួន ដោយមែកមួយរយមាន ឧបមាដូចកំពូលភ្នំប្រកបដោយពពកដ៏ធំ ដើមជ្រៃនោះដុះកើតមកតែអំពី ពូជប្រមាណប៉ុនគ្រាប់ស្ពៃ មានឧបមាយ៉ាងណាមិញ ផលច្រើនកើតមក តែអំពីបុញ្ញកម្មមានប្រមាណតិចពិត មានឧបមេយ្យយ៉ាងនោះដែរ ៗ

ព្រោះហេតុដូច្នោះ អ្នកប្រាជ្ញមិនគប្បីមើលងាយថា បុណ្យមានប្រមាណតិចដូច្នេះឡើយ គប្បីចូលចិត្តថា បុណ្យដែលបុគ្គលធ្វើមានប្រមាណតិចទេ តែនឹងឲ្យផលច្រើនចំរើនឡើងដោយវិសេសពិត ៗ

---

(នៅមានត)

# មហោសថជាតក

(តមក)

លោក អ៊ឹម-គន ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស គឹម-គូរ ពិនិត្យ

បពិត្រអើយ រីបិង្គុត្តរមាណពនោះមិញ, ទុព្វេត្តា ជាអ្នកឥតបុណ្យ ចង្រៃកាឡកណ្ណី ៗ រីនាងកុមារីស្រីតែនប្រសើរ ប្រកបនូវបុណ្យនោះ ច្រើន ៗ រីបិង្គុត្តរមាណព ជាអ្នកឥតបុណ្យ ឥតលក្ខណៈ មិនមានចិត្ត ជាប់ជំពាក់អាល័យនៃនាងដល់តិចឡើយ ប៉ុន្តែដោយខ្លាចចិត្តទិសាបា-មោក្ខាចារ្យហើយ ពុំអាចដើម្បីនឹងស្រដីទំលាយ ឲ្យអន្តរាយបង់ពាក្យ ទិសាបាមោក្ខនោះមិញ ក៏យកនូវកូនក្រមុំសំឡាញ់ឲ្យទៅជាប្រពន្ធបិង្គុ-ត្តរមាណព ៗ លុះវេលារាត្រី បិង្គុត្តរមាណពទៅដេកលើកំពលដ៏ មានសិរីសួស្តី គឺនាងកុមារីក្រាលប្រដាប់ហើយ, នាងចូលទៅនឹងដេក រួមរាសនានឹងបិង្គុត្តរមាណព ៗ ដឹងជានាងទៅដេកនឹងអាត្មា ក៏ម្នា ក្រោកដោះឡើងទៅដេកលើកំពលដំណេកឯដីវិញ ៗ នាងកុមារីក្រោក រត់មកប្រយោជន៍មឹងទៅដេកជាមួយបិង្គុត្តរមាណព ៗ បិង្គុត្តរមាណពក៏ រត់ចុះមកដេកឯដីវិញទៀត ៗ កាឡកណ្ណី ជាម សទ្ធិ សិរិ-យា ន សមេតិ បពិត្រអើយ រីអ្នកចង្រៃកាឡកណ្ណី នឹងអ្នកដ៏មាន

សិរីសួស្តី មិនដែលនឹងជិតគ្នាបានឡើយ ឧបមាបីដូចជាគេយកភ្លើងទៅ ដួលពេលក្តៅក្រហាយនឹងគ្នាណាស់ហោង ៗ ឯនាងកុមារីដេកនៅលើ សិរីសយនាតែម្នាក់ឯង ៗ ចំណែកបណ្ឌិតមាណពនោះ ទៅដេកឯផែនដី តែម្នាក់ឯង ៗ

ឃរំ សត្តាហំ វីតិនាមេត្វា តំ អាទាយ អាចរិយំ វន្ទិត្វា ឯតក ធិក្ខាមិ បពិត្រអើយ រីបណ្ឌិតមាណព នូវនាងកុមារីមិនគប្បី សម្រេច នូវកិច្ចសំឡាញ់ជាគំរប់ ៧ ថ្ងៃ ៗដ៏ប្រការដូច្នេះឯង ម្ល៉ោះហើយ បណ្ឌិតមាណពចូលទៅក្រាបសំពះលាគ្រូអាចារ្យនឹងទៅលំនៅឋានអាត្មា ៗ ទើបអាចារ្យដណ្តឹងថា ម្នាលបណ្ឌិតមាណពអើយ បើបាទៅស្រុកហើយ តើនាងកុមារីកូនស្រីអញ ចៅនឹងយកទៅផងឬទុកនៅអាយ ? បណ្ឌិត-មាណពស្តាប់ហើយឆ្លើយថា បពិត្រអ្នកគ្រូអើយ ! ថាបើនាងមានចំណង់ នឹងចង់ទៅ ក៏ឲ្យនាងទៅនឹងអម្ចាស់ចុះ ៗ ទិសាបាមោក្ខាចារ្យស្តាប់ហើយ ស្រដីដណ្តឹងទៅនាងកុមារីថា ម្នាលកូនស្ងួនសំឡាញ់អាពុក នាងនឹងទៅ ជាមួយប្តី ឬ នាងនឹងនៅអាយ ? រីនាងកុមារី ហេតុតែជាស្រីទល់គំនិត នាងគិតពិចារណាថា ធម្មតាស្រីនៅឆ្ងាយពីប្តី គេថាជាមេម៉ាយចំណាយ មាត់គេ នាងគិតដូច្នោះហើយ ឆ្លើយប្រាប់អាពុកថា បពិត្រអ្នកអាពុកអើយ ខ្ញុំនឹងទៅជាមួយប្តីខ្ញុំហោង ៗ

រីអ្នកទាំងពីរលោអាចារ្យដើររៀនកបដកបមក ធ្វើដំណើរតាមផ្លូវ គ្មានសំណេះសំណាលនឹងគ្នាដល់តិចតួច ទៅវិញទៅមកសោះនឡើយ ៗ រីបិង្គុតរមាណព នឹងនាងកុមារី ដើររៀរកបដកបមកដល់ ស្រុកមិថិលា-មហានគរ យល់នូវដើមទុទុម្ពរ បរិបូណ៌ដោយនូវផ្លែទុំច្រើនសព្វែកគ្រប់មែក ពុំឆ្ងាយពីទ្វារព្រះនគរ, បិង្គុតរមាណពយល់ហើយ ហេតុសម្រេកឥម្ចាន់មកបៀតបៀន ក៏ឡើងទៅបេះប្រឡេះផ្លែទុទុម្ពរបរិភោគ ៗ រីនាងកុមារីសោត ហេតុតែសេចក្ដីស្រេកឃ្លានខ្លាំង ក៏ដើរចូលទៅកាន់ដើមទុទុម្ពរអង្វរថា សាមិ ហៃអ្នកស្វាមីអើយ! ចូរអ្នកទម្លាក់មកខ្ញុំបរិភោគផងៗ រីបិង្គុតរមាណព ស្ដាប់ហើយខឹងក្រញឹងថា មេឯទគ្មានដៃជើងឡើងមកបេះឬ? អញនេះ, មិនមែនខ្ញុំមេហាងឯងទេ ៗ រីនាងកុមារី កាលណាបើឮបិង្គុតរមាណព ជាប្ដីស្រដីដូច្នោះហើយក្ដី នាងម្នីម្នាឡើងញដឹរលើចុងមែកល់ផ្នែកប្រគាប បេះផ្លែទុទុម្ពរបរិភោគ បន្ទាប់សម្រេកគម្លាន ៗ រីបិង្គុតរមាណព ដឹងថានាងឡើងមកដូច្នោះក្ដី ក្រញូវស្រូតសំរូតចុះមកអំពីដើមទុទុម្ពរ, កាប់បន្លាសម្រាស់ មកស្រាស់ដើមទុទុម្ពរហើយស្រដីថា ម្នាលស្រីចង្រៃកាឡកណ្ណីអើយ ចូរមេហាងឯងទៅនេះចុះម្ល៉េះហើយ អញបានរួចអំពីហាងហើយ អញអរណាល់, ស្រដីម៉្លោះហើយ បិង្គុតរមាណពរត់ចោលនាងកុមារី ទៅកាន់ឋានលំនៅអាត្មា

នោះហោង ៗ នាងកុមារីមិនអាចដើម្បីនឹងចុះមកបានឡើយ បិតនៅឰដ៏ចុងមែកលផ្លែកប្រគាបឧទុម្ពរនោះឯងហោង ៗ

តំ ធិវសំ រាជា ឧយ្យានំ គច្ឆន្តោ ទត្វា តីធ្យត្វា សាយណ្ហសមយេ ហត្ថិក្ខន្ធេ ធិសីធិត្វា ឆករំ បរិសន្តោ តំ ធិស្វា បដិពទ្ធចិត្តោ ហុត្វា សបរិគ្គហា អបរិគ្គហាតិ បុច្ឆាបេសិ បពិត្រអើយ មានកាលសម័យថ្ងៃមួយមិញ ព្រះបាទវិទេហរាជជាមហាក្សត្រធំក្រៃ មានព្រះរាជហឫទ័យស្តេចលីលាចេញទៅប្រពាតឧទ្យាន មានមុខមន្ត្រីហែហមជាបរិវារ ស្តេចត្រអាលគង់លើដំរីមង្គលអំពលនូវគ្រឿងប្រដាប់ លុះសម័យថ្ងៃល្ងាចរសៀលទន់ទាប ស្តេចនឹងលីលាត្រឡប់ចូលមកកាន់ព្រះនគរ មកដល់ដើមឧទុម្ពរហើយ ស្តេចទតទៅយល់នាងកុមារីបិតឰដ៏ចុងឧទុម្ពរ ហើយព្រះមហាក្សត្រមានព្រះរាជហឫទ័យប្រតិព័ទ្ធ ស្រឡាញ់នាងនោះមហិមាក្រៃពេក ស្តេចប្រើអាមាត្យទៅដណ្តឹងថា ស្រីនេះមានប្តីពិភក្តិរក្សាហើយ ឬនៅ ? ៗ រាជអាមាត្យស្តាប់ព្រះបន្ទូលព្រះមហាក្សត្រហើយ ក៏ទៅដណ្តឹងនាង ដូចព្រះបន្ទូល, នាងកុមារីឮហើយ ឆ្លើយប្រាប់រាជអាមាត្យថា ប្តីខ្ញុំមាន តែពុំដែលសន្ទនារម្យសនាទឹងគ្នាទេ, ឥឡូវនេះ ខ្ញុំឡើងមកនៅលើចុងឧទុម្ពរ គាត់កាប់បន្ទាស្រាស់រត់ចោលខ្ញុំទៅ ដូចអ្នករាជអាមាត្យយល់ស្រាប់ ៗ

អមច្ចោ តមត្ថំ រញ្ញោ អារោចេសិ បពិត្រអើយ ឮដំ
កាលនោះ រាជអាមាត្យស្តាប់ហើយ ក៏វិលត្រឡប់មកក្រាបទូលអាថ៌
ដំណើរនៃនាង ។ ព្រះមហាក្សត្រជ្រាបហើយ មានព្រះរាជហឫទ័យ
ថ្លៃត្រេកអរដ៏ពេញនូវព្រះអំណរបន្ទូលថា នាទ្រព្យសម្រាប់បរិវារ បើ
ឥតនឹងអម្ចាស់ហើយ គប្បីឡើងជាព្រះរាជទ្រព្យសម្រាប់ព្រះមហាក្សត្រ
នោះហោង ស្តេចទ្រង់ព្រះចិន្តាពិចារណា នូវប្រការអម្បាលនោះហើយ
ឲ្យដាក់នាងចុះមក ហើយលើកឡើងដំកើងលើខ្នងបាដំរីជ័យ ហើយ
អភិសេកជាព្រះអគ្គមហេសីធំឧត្តមក្រៃ ។ បពិត្រអើយ, តាប់ដើម
អំពីថ្ងៃនោះទៅ រីនាងនោះលុះជាសំឡាញ់ពេញព្រះរាជហឫទ័យ ក្សត្រ
ថ្ងៃ សន្មតឲ្យព្រះនាមករ បំរើនព្រះពរ ហៅឈ្មោះថានាង ឧទុម្ពរ ។
អំពីថ្ងៃអភិសេកនោះទៅហោង ។

អថេកទិវសំ រញ្ញោ ឧយ្យានគមនត្ថាយ ទ្វារគាម-
ភសិ គេហិ មគ្គំ បដិជគ្គាបេសុំ ។ បពិត្រអើយ, មានកាល
សម័យថ្ងៃមួយ ព្រះបាទវិទេហរាជ ស្តេចមានព្រះចំណង់នឹកចង់ទៅ
ប្រពាតឧទ្យាន មានព្រះបន្ទូលឲ្យប្រាប់បង្គាប់ប្រើអស់អ្នកផងទាំងអម្បាល
មាណ នៅទៀបទ្វារព្រះនគរឲ្យចូលចាំងដំរះមាគ៌ា ប្រយោជន៍ជាដំណើរ
ស្តេចនឹងទៅឧទ្យាន ។ រីបិង្គុត្តរមាណពចងក្បិនកន្ទប កាន់ចបបូកផ្លូវ

ដោយនូវមុខងារពុំទាន់ស្រេច ស្តេចគង់ព្រះរាជរថជាមួយនាងខុជ្ជុត្តរ បរចេញទៅដល់ទ្វារព្រះនគរ ។ នាងខុជ្ជុត្តរទៅ យល់បណ្ឌិតមាណព ជាមនុស្សចៅទ្រំអប្បលក្ខណ៍ ជំរះផ្លូវដូច្នោះក្តី នាងសើចហើយគិតថា បុរសអប្បលក្ខណ៍កាឡកណ្ណីនេះ ពុំអាចដើម្បីនឹងទ្រទ្រង់នូវសិរីសួស្តី បានឡើយ ។ ស្តេចយល់នាងសើចដូច្នោះក្តី ស្តេចទ្រង់ខ្ញាល់មានព្រះបន្ទូលដណ្តឹងនាងថា នាងសើចអ្វី? នាងខុជ្ជុត្តរទៅទូលថា បពិត្រក្សត្រថ្លៃប្រសើរអើយ បុរសចូកផ្លូវនោះជាប្តីដើមនៃខ្ញុំ វាឲ្យខ្ញុំឡើងលើចុងល្វា វាយកបន្លាស្រោសហើយវារត់ទៅ ឥឡូវនេះ, ខ្ញុំមើលយល់បុរសអប្បលក្ខណ៍ជាអ្នកចៅទ្រំកាឡកណ្ណីបង់សិរីសួស្តីដូច្នោះ, ហេតុនោះបានជាខ្ញុំសើច ស្តេចស្តាប់ហើយទ្រង់ព្រះក្រោធពិរោធមហិមា ប្រវាចាប់ព្រះខាន់កាន់ហូតចេញ ហើយមានព្រះបន្ទូលថា មឹងស្រដីមុសាវាទពុំពិត សំដីយល់ហេតុប្រសដខែសង្ស័យក្នុងចិត្តហើយ ទើបមឹងសើច នាងស្តាប់ព្រះបន្ទូលព្រះមហាក្សត្រដូច្នោះហើយ នាងភិតភ័យក្រៃមហិមា ខំទូលថា បពិត្រក្សត្រថ្លៃប្រសើរអើយ ! សូមទានចូរព្រះអង្គដណ្តឹងអ្នកប្រាជ្ញឲ្យពិចារណា បើខ្ញុំមុសាវាទពុំពិតត្រង់ សូមព្រះអង្គធ្វើតាមដោយនូវទោសកុំសន្តោសខ្ញុំឡើយ ។ ស្តេចស្តាប់ពាក្យនាងហើយ មានព្រះបន្ទូលដណ្តឹងទៅអាចារ្យសេនកថា សេនក! ហៃអាចារ្យសេនកអើយ

នាពាក្យនាងស្រដីដូច្នោះ តើព្រះស្តេចជឿឬទេ? អាចារ្យសេនកទូលថា ទេ! បពិត្រមហារាជអើយ ខ្ញុំមិនជឿឡើយ, ពុំដែលមានអ្នកឯណាបោះបង់ចោលនូវស្រីមានរូបល្អនោះបានឡើយ ។ នាងឮពាក្យអាចារ្យសេនក ទូលដូច្នោះហើយ រឹងរិតភ័យក្រៃមួយសាទៀត ។ រីព្រះមហាក្សត្រាធិរាជសោត ព្រះអង្គទ្រង់ព្រះចិន្តាគិតថា រីអាចារ្យសេនកនេះជាអ្នកកំឡៅ តើនឹងដឹងអ្វី? គួរគប្បីអញដណ្តឹងទៅមហោសថឲ្យប្រាកដសិន ទើបស្តេចសូត្រនូវគាថានេះថា ៖

ឥត្ថី សិយា រូបវតី សា ច សីលវតី សិយា
បុរិសោ តំ ន ឥច្ឆេយ្យ សទ្ទហាសិ មហោសថាសិ ។

ឱ៎ហោបាមហោសថអើយ រីស្រីប្រកបនូវរូបឆោមសល្អ មានសីលព្រឹទ្ធស្រគត់ ប្រតិបត្តិថ្វី គប្បីមានដូចនាងនេះដូច្នេះ, ហើយមានបុរសមិនយកស្រីនោះមកជាភរិយាអាត្មា តើបាជឿឬទេ? រីពោធិសត្វមហា-បុរសរតន៍ប្រសើរ ស្តាប់ដំណើរព្រះបន្ទូលដណ្តឹងដូច្នោះហើយ ទើបពោធិសត្វទូលជាគាថាដូច្នេះថា :

សទ្ទហាមិ មហារាជ បុរិសោ ទុព្ភគោ សិយា
សិរី ច កាឡកណ្ណី ច ន សមេន្តិ កុទាចនំ ។

បពិត្រព្រះភូមិន្ទនរិន្ទនរនាថ ព្រះបាទនារាយណ៍នរបតីស្រីសម្មតិ

ទេពក្សត្រថ្ងៃប្រសើរអើយ រីសម្តេចព្រះអគ្គមហេសី ស្រដីទូលព្រះអង្គដូច្នោះ នោះខ្ញុំជឿពិត; រីបុរសឥតបុណ្យអប្បលក្ខណ៍ជាអ្នកចង្រៃកាឡកណ្ណី មិនដែលនឹងបិតទៅជិតខាងស្រីមានវរលក្ខណ៍បានឡើយ បីដូចត្រើយសមុទ្រខាងឯអាយ នឹងត្រើយសមុទ្រខាងឯនាយឆ្ងាយពីគ្នា ពុំនោះបីដូចអាកាសនឹងក្រឡាមហាប្រឹថពីពុំដែលនឹងជិតគ្នាបាន មានប្រការម្តេចមិញ, រីបុរសចង្រៃអប្បលក្ខណ៍ ពុំដែលបិតខាងអ្នកមានសិរីសួស្តីបាន ដូច្នោះហោង ។

ស្តេចស្តាប់ពាក្យពោធិសត្វទូល ដោយនូវហេតុប្រការអម្បាលនោះហើយ ស្តេចស្រាកព្រះហឫទ័យខ្វល់លេតបង់ ទ្រង់ព្រះអំណរនឹងពោធិសត្វ ហើយមានព្រះបន្ទូលថា ហៃបាមហោសថអើយ បើអញឥតពីបាហើយ ម្ល៉េះសមអញនឹងបង់ស្រីរ័តន៍ប្រសើរ តាមដំណើរពាក្យអាចារ្យសេនក ជាអ្នកអន្ធពាលស្រោលសេចក្តីស្រដីខុសនឹងច្បាប់បុរាណ រីអញបាននាងនោះគង់ជីវិត ហេតុដ្បិតតែពាក្យបាឯង ស្តេចសរសើរពោធិ-សត្វនូវប្រការអម្បាលនោះហើយ ស្តេចឲ្យយកមាសមួយសែនដំឡឹងមកបូជាពោធិសត្វកាលនោះហោង ។

រីនាងឧទុម្ពរទេវី ក្រាបថ្វាយបង្គំព្រះមហាក្សត្រហើយទូលថា ទេវ បពិត្រព្រះអម្ចាស់អើយ រីជីវិតនៃអញខ្ញុំ បានគង់នោះនៅតាំងម្ល៉េះនេះ

ហេតុអាស្រ័យនឹងចៅមហោសថ ឥឡូវនេះ ខ្ញុំសូមពរអំពីព្រះអង្គ ទុកចៅមហោសថនេះជាប្អូនបង្កើតខ្ញុំហោង ។ ព្រះបាទវិទេហរាជមានព្រះបន្ទូលថាម្នាលនាងឧទុម្ពរទេវីអើយ ពាក្យនាងស្រដីមកនោះពិរោះៗ ពេក អញនឹងឲ្យនាងដូចប្រាថ្នា ចូរនាងទទួលយកហោង ។ ទើបនាងឧទុម្ពរ-ទេវី ទូលព្រះមហាក្សត្រវិញទៀតថា បពិត្រអម្ចាស់អើយ ចាប់ដើមអំពីថ្ងៃនេះទៅ ទោះបីខ្ញុំធនូវសារពើចំណីផ្អែមពិសារតិចតួចក្តី ក៏ខ្ញុំមិនបង់នៃប្អូនខ្ញុំនោះ ទោះវេលាគួរក្តីពុំគួរក្តី ខ្ញុំសូមឲ្យបើកជូននូវចំណីទៅចៅមហោសថកុំឲ្យឃាត់ខាំងឡើយ ។ ព្រះមហាក្សត្រមានព្រះបន្ទូលថា កទួ ហៃនាងអើយ អញព្រមអនុញ្ញាតឲ្យតាមចិត្តនាងហោង ។ ព្រះបាទវិទេហរាជសោត ស្តេចវិលមកកាន់ព្រះរាជមន្ទីរវិញហោង ។

សិរីកាឡកណ្ណិ បញ្ហា និដ្ឋិតោ ។ រីនឹងស្រដីអ្នកមានសិរីសួស្តីនឹងអ្នកចង្រៃអប្បលក្ខណ៍នេះមិញ ក៏សូរេចនូវប្រការអម្បាលនេះឯងហោង ។

អបរស្មិំ ទិវសេ... មានកាលសម័យថ្ងៃមួយ, ព្រះបាទវិទេហរាជ ស្តេចសោយព្រះក្រយាស្ងោយនាព្រឹកស្រេច ស្តេចលីលាយាត្រាទៅ ដោយនូវចំលួយ (ចន្លោះ) ប្រាសាទកូវ ស្តេចមើលមើលទៅដោយនូវលន្លែកបង្អួច យល់ពពែមួយនឹងឆ្កែមួយនោះកំពុងធ្វើជាមិត្ត

សន្ទាៈផងគ្នា ។ គិរ ដូចយើងបានឮមក រីពពៃនោះ មានកាលមួយ ថ្ងៃ ទៅធីស្ពៅដែលគេទុកនៅក្នុងពេងដ៏រនោះ គេយល់ពពៃពាំនាំស្ពៅ ចេញទៅទីងធីដូច្នោះក្ដី វាបានដំបងដេញទៅដោយនូវកំឡាំងឆាប់ទាន់ ហើយវាយត្រូវត្រង់ខ្នងពពៃលុះនូវវេទនា មានខ្នងនោះធុនក្រញាន ស្រែករត់ទៅដេកអាស្រ័យនៅខាងជញ្ជាំងធំនោះហោង ។

តាំ ធិវសរមេវ . . . កាលថ្ងៃនោះឯង មានឆ្កែមួយដើរទៅរកធី នៅខាងពេងគ្រូធំ រីអ្នកគ្រូនោះ ចំអិនបាយត្រីសាច់ឆ្អិនស្រេចហើយ ចេញទៅសម្លុតញើសឯក្រៅ, រីឆ្កែធុំក្លិនសាច់មានរសឆ្ងាញ់ពិសា ក៏ពុំ អាចដើម្បីទីងអត់បានឡើយ លបចូលទៅក្នុងពេងគ្រូធំ ក៏បើកគ្រប កាជន៍នោះឡើងហើយ ពាំនាំសាច់នោះចេញមក, រីអ្នកគ្រូនោះឮនូវស័ព្ទ ឆ្កែបើកនូវគ្របកាជន៍នោះហើយ ម្ចាមាចូលទៅយល់ឆ្កែពាំនាំសាច់ដូច្នោះ ក្ដី វាពំងទ្វារម្ចាមាប្រវាចាប់បានកំណាត់ឈើវាយត្រូវខ្នងឆ្កែ, រីឆ្កែនោះទម្លាក់ សាច់ហើយ ស្ទុះរោលចេញទៅ, រីអ្នកគ្រូរត់ដេញតាមទៅ វាយឆ្កែ ដោយដំបង ត្រូវឆ្កែបាក់ហោង ខ្នងធុនក្រញាន ហើយលើកជើងមួយ រត់ទៅខាងដំណេកពពៃនោះហោង ។

(នៅមានត)

# ផ្នែកអក្សរសាស្ត្រ

## វប្បធម៌

## លោក លី-ធាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

ដើម្បីនឹងអធិប្បាយ ឲ្យបានជ្រៅជ្រះអំពីវប្បធម៌ យើងសូមធ្វើការវែកញែកបញ្ជាក់ឲ្យល្អិតល្អន់បន្តិច ក្នុងអត្ថន័យរបស់ពាក្យវប្បធម៌នេះសិន ព្រោះជាការជំរះមន្ទិលសង្ស័យ របស់បណ្ដាមិត្តអ្នកអានខ្លះ ដែលមានសេចក្ដីងឿងឆ្ងល់ក្នុងសន្តានចិត្តថា៖ ហេតុអ្វីហ្ន៎! ក៏និយាយពីរឿងវប្បធម៌ហើយវប្បធម៌ទៀត មិនចេះអស់មិនចេះហើយសោះ ? តើវប្បធម៌នោះជាអ្វីទៅ ? មានអ្វីខ្លះជាសាខារបស់វប្បធម៌នេះ? នរណាជាអ្នកមានភារៈរក្សានឹងលើកដំកើងវប្បធម៌ ?

ចំពោះសំនួរទាំងប៉ុន្មានខាងលើ យើងអាចធ្វើជាសេចក្ដីអធិប្បាយពង្រីកអត្ថន័យតាមទស្សនៈសរុបខាងក្រោមនេះ៖

បើតាមរូបសព្ទ ពាក្យថា វប្បធម៌ បានន័យថា៖ ការបណ្ដុះនូវក្បួនគម្រា, ការបង្កើននូវក្បួនខ្នាតឬមុខវិជ្ជាផ្សេងៗ, ដូច្នេះ, បើពោលឲ្យខ្លីថា

អ្វីដែលជាសេចក្ដីចំរើន, សេចក្ដីចេះដឹង, អំពើល្អគលាស់ គឺសុទ្ធតែហៅថាវប្បធម៌ទាំងអស់ ។ ប្រសិនណាជាយើងល្បង ធ្វើការពិនិត្យសង្កេតបន្តិចទៅទៀត យើងអាចរកឃើញសាខាដែលជាគោលសំខាន់ៗ ក្នុងវប្បធម៌ដូចតទៅ ៖

១- សិល្បៈរបាំ _ ជាការផ្ដិតលំនាំ តាមសេចក្ដីចំរើន ខាងកាយវិការរបស់មនុស្សគឺជាដំណាងដំណើរវិវត្តន៍នៃមនុស្សជាតិ ។

២- តន្ត្រី _ ជានិមិត្តរូបនៃស្មារតីរបស់មនុស្ស គឺជាសូរសំនៀងនៃមនោសញ្ចេតនា ក្នុងដំណើរចំរើនឡើងនៃជីវភាពមនុស្ស ។

៣- អក្សរសាស្ត្រ _ មានកំណាព្យកាព្យឃ្លោង, ពាក្យសំដី, សំនួរវោហារ, ការលាតត្រដាងជាផ្ទៃរឿងរ៉ាវជាដើម សុទ្ធសឹងជាការផ្ដិត យកតាមលំនាំរបបរស់នៅ ដែលចំរើនទៅ គ្មានឈប់ឈរនៃមនុស្សជាតិនិងធម្មជាតិ ។

៤- លទ្ធិសាសនា _ ជាការត្រិះរិះខាងផ្លូវគំនិត, បញ្ញា, ស្មារតីដែលបង្កើតបានជាគុណប្រយោជន៍មួយយ៉ាងសំខាន់ ខាងផ្នែកហ្វឹកហ្វឺនសន្ដានចិត្ត ។

៥- ក្បាច់ចំឡាក់រចនា _ ជាការសំដែងចេញនូវសភាពរបស់គំនិត

ដែលគិតឃើញ តាមដំណើរជឿនលឿនជាលំដាប់នៃប្រាជ្ញាមនុស្ស ។

៦- ការអប់រំ _ គោលគឺចរិយាសាស្ត្រ ឬ សុជីវធម៌ ដែលមនុស្សជាតិចំរើនសព្វថ្ងៃត្រូវការជានិច្ច សំរាប់រៀបចំអង្គកាយក្នុងជីវភាពរបស់ខ្លួន ។

៧- វិទ្យាសាស្ត្រ - ជាវិជ្ជាចំរើនក្នុងការស្រាវជ្រាវរករកចំពោះបញ្ហា ឬរូបភាពវត្ថុអ្វីមួយ ឲ្យឃើញដើមចមប្រាកដជាក់ស្តែង ។ ល ។

បើយើងបើកបញ្ចេញអាថ៌កំបាំង រកឃើញអវយវៈរបស់អង្គនៃវប្បធម៌ ដូចមានគោលជាគោល ៗ ខាងលើនេះហើយ យើងនាំគ្នាធ្វើការពិចារណាបន្តិចទៅទៀត ចំពោះវប្បធម៌ជាតិខ្មែរ ដែលជាជាតិកំពូលស្នេហ៍របស់យើង ហើយដែលជាការៈចាំបាច់របស់យើង ជាកុលបុត្រ - កុលធីតាបុព្វបុរសខ្មែរ ដែលបានកសាងវប្បធម៌សំរាប់ជាតិ ជាយូរអង្វែងមកហើយដែរ ។ យើងឆ្លើយឲ្យខ្លីដូចនេះថា៖ "ខ្មែរយើងមានវប្បធម៌ប្រចាំជាតិជាក់ច្បាស់ណាស់ " ។

បានជាហ៊ានពោលដូចនេះ ព្រោះយើងសង្កេតឃើញពិតជាក់ស្តែងថា ខ្មែរមានសិល្បៈរបាំរបស់ជាតិ ប្រកបដោយលក្ខណៈពិសេសបំផុតដែលល្បីរន្ទឺកិត្តិនាមសាយសព្វនៅអាស៊ីកាគ្នេយ៍ និងបច្ចុប្បន្នកាលនេះ ព្រួសហូតដល់ផ្នែកអឺរ៉ុបនិងអាមេរិកថែមទៀត ។ ក្បាច់របាំពរែកនេះមានលំនាំលក្ខណ្ឌជាក់លាក់មិនមែនធ្វើដោយព្រាវ ៗ ទេ ។ មើលចុះ! ការ

ពត់អង្គកាយ អែនអនសមរម្យទៅតាមចង្វាក់ញ៉ាំញី ប្រកបដោយអវយវៈទន់ភ្លន់កែក្រាយគ្មានខ្ចោះ ៗ ព្រមជាមួយនោះ សៀងជួរដន្ត្រីក្រឡុលទន់លោច ជួយពត់ជួយសម្រួលក្បាច់រាំ ដ៏មានសូរចំរៀងអមជាមួយផង ៗ ការដាក់ទឹកមុខ នឹងភាពពង់កាយ លំអដោយអលង្ការណ៍ផងនោះ ក៏ត្រូវបានជាប្រដាប់លើកដំកើងសិល្បៈរបាំយើងនេះដែរ ៗ ក្បាច់ក្បូរ ដែលយើងពណ៌នានេះ មានអាយុវែងឆ្ងាយណាស់ បើពោលឲ្យឆ្ងាយចាំថា តាំងពីគ្រាដែលខ្មែរកសាងប្រាសាទអង្គររាងជាង ១០ សតវត្សរ៍មកហើយ ៗ ហើយនៅគ្រាជាមួយនោះទៀតការរចនាខាងចំឡាក់រូបភាពផ្សេង ៗ ក៏ឧប្បត្តិឡើងយ៉ាងត្រចះត្រចង់ណាស់ដែរ ៗ យើងឃើញហើយ ប្រាង្គប្រាសាទក្តី ស្ពាន ឬបង្កាន់ដៃអមសងខាងមាគ៌ានៃប្រាសាទបុរាណយើងក្តី ឬនៅតាមវត្ថុសក្ការៈផ្សេង ៗ មានព្រះស្តូប និងវត្តអារាមជាដើមក្តី សុទ្ធសឹងតែមានក្បាច់ចំឡាក់ងទន្ទាំរស់រវើក សូម្បីពេលវេលាទំបំផ្លិចបំផ្លាញជាយូរមកហើយ ក៏ពុំទាន់អស់សោភ័ណនៅឡើយ បែរជាបង្កើតបានជាបញ្ហាពិសេស ៗ ឲ្យយើងត្រិះរិះក្នុងគ្រាបច្ចុប្បន្ននេះទៅវិញ ៗ

អក្សរសាស្ត្ររបស់ខ្មែរសោតទៀត ក៏មានរូបរាងមកជាអង្វែងហើយដែរ ដែលទទួលការលូតលាស់ជាលំដាប់តាមយុគ តាមសម័យ របស់

ស្រុកទេស ដែលប្រព្រឹត្តទៅតាមដំណើរប្រវត្តិសាស្ត្រ ៗ ជាភស្តុតាងដូចផ្ទាំងសិលាចារឹក រាប់ពាន់សន្លឹកដែលអ្នកស្រាវជ្រាវរកឃើញមានចុះកាល-បរិច្ឆេទ តាំងពីសតវត្សរ៍ទី ៤, ទី ៥ មក ៗ ផ្នែកវណ្ណកម្មជារឿងក៏រកឹមានជាក់ស្តែងទៀត ដូចជារឿងរាមកេរ្តិ៍ នឹងរឿងមហាភារតៈ ជាតួយ៉ាង ៗ រឿងទាំងនេះ មិនត្រឹមតែចារឹកទុកពីពាក្យសំដីវោហាររបស់ខ្មែរ ក្នុងសម័យនោះទេ ថែមទាំងលាតត្រដាងខាងផ្នែកគំនិតដ៏ជ្រាលជ្រៅទៀត ព្រោះសុទ្ធតែជារឿងនិទានពីការច្បាំង យកឈ្នះចាញ់រវាងសភាវៈទាំងពីរ គឺអំពើល្អ នឹងអំពើអាក្រក់, យុត្តិធម៌ នឹងអយុត្តិធម៌, សប្បុរស នឹងអសប្បុរស ៗលៗ លក្ខណៈពិសេសរបស់វណ្ណកម្មខ្មែរមួយទៀត គ្រង់សំដីចងជាបទបែបដោយឡែក ១ ពីគ្នា ៗ បើយើងមិនពិចារណាឲ្យជ្រៅទេ យើងអាចយល់ច្រឡំថា ខ្មែរបង្កើតបទបែបក្នុងអក្សរសាស្ត្រនេះ នាំឲ្យវិលពិបាកអានឥតប្រយោជន៍ ៗ តែបើតាមការពិតមិនដូចនោះទេ ៗ មនុស្សយើងក្នុងការប្រព្រឹត្តទៅនៃជីវិត រមែងប្រកបដោយកាយវិការប្លែក ១ ពីគ្នា ក្នុងគ្រាដើរកំសាន្ត, ក្នុងពាក្យសន្ទនា, ក្នុងសំដីកំហឹងរឹងរូស, ក្នុងភាពកំប្លុកកំប្លែង ឬក្នុងសំដីដ៏អូញលួងលោមជាដើម ៗ តាមដំណើរកាយវិការទាំងហ្នឹងហើយ ដែលអ្នកអក្សរសាស្ត្រពីបុរាណរបស់យើង បង្កើតជាបទបែបដោយឡែក ១ ដើម្បីតំណាងឫកពារបស់មនុស្ស ឲ្យបានដូចមែនទែន ៗ

ម្យ៉ាងទៀត ក្នុងបទបែបនេះ ក៏មានស័ព្ទសូរផង រណ្ដំគ្នាគួរជាទីទាក់អារម្មណ៍អ្នកស្ដាប់ ៗ មិនតែប៉ុណ្ណោះ ជើងកាព្យ ឬពាក្យឃ្លោងរបស់ខ្មែរយើង មានលក្ខណៈប្លែកត្រង់ការចាប់ចុងជួន គឺឲ្យសំដីប្រទាក់ប្រទងណែងណងនឹងគ្នាដឹកណាស់ផង ៗ

ចំពោះលទ្ធិសាសនា ដែលយើងបានរាប់ខាងលើ បញ្ចូលក្នុងចំណោមសាខារបស់វប្បធម៌ដែរនោះ, បើយើងប្រមើលបញ្ឆាក់បន្តិចទៅទៀត ក៏ឃើញថា ហុចប្រយោជន៍ឲ្យបណ្ដាជនយើងជាច្រើនក្រៃលែងដែរ ដ្បិតជាគោលគំនិតខាងអប់រំសតិបញ្ញាស្មារតីជននិមួយៗ រៀងដរាបតាំងពីគួបមក ៗ យើងពោលឲ្យចំថា៖ លទ្ធិសាសនា ជាមូលដ្ឋានខាងគំនិតមួយយ៉ាងមាំក្នុងស្មារតីសាមគ្គីធម៌ ៗ មើលចុះ បើមនុស្សក្នុងប្រទេសណាកាន់លទ្ធិសាសនាមួយគ្នា អ្នកដឹកនាំប្រទេសនោះ ងាយនឹងណែនាំណាស់ ដ្បិតប្រជាជាតិពុំមានប្រកាន់ចិត្តបង់គំនុំនឹងគ្នា ៗ មួយទៀតបើប្រើវិធីណែនាំនោះ ផ្ដែកទៅតាមទ្រឹស្ដីនៃលទ្ធិសាសនា ដែលធ្លាប់គោរពរាប់អានមកស្រាប់ផង ក៏រឹងរឹតតែងាយមូលមាត់គ្នាណាស់ទៅទៀត ៗ ដោយមានគុណប្រយោជន៍ដូចនេះ ទើបគ្រប់ប្រទេសក្នុងលោកតែងតែប្រកាន់យកសាសនារៀង ៗ ខ្លួន ៗ

បើពោលពីការអប់រំវិញ ក៏ឃើញថាខ្មែរយើងមានចងក្រងខាងវិធី

អប់រំគ្នីគ្នាជាយូរមកហើយដែរ ។ តាមសាស្ត្រាស្លឹករឹតជាច្រើនច្បាប់ បុព្វបុរសយើងបានចារចងក្រង ជាពាក្យទូន្មានប្រៀនប្រដៅដល់កូនចៅខ្មែរ ឲ្យចេះពត់ហាត់កាយវាចាចិត្ត ដើម្បីឲ្យបានត្រឹមត្រូវតាមតម្រាយក្រិត្យក្រម ពោលគឺគន្លងសីលធម៌ដ៏ល្អប្រពៃ ។

ឯវិទ្យាសាស្ត្រ ដែលជាមែកមួយយ៉ាងសំខាន់ក្នុងវប្បធម៌ទំនើបនេះ ពីដើមមក ក៏ខ្មែរយើងសំគីគិតដល់ណាស់ដែរ ។ យើងឃើញកស្តុតាង យ៉ាងងាយដឹង, ងាយស្គាល់បំផុតគឺប្រាសាទអង្គរ ដែលបុព្វបុរស បានសាងដោយវិធីប្រើវិទ្យាសាស្ត្រ ដូចយ៉ាងស្ថាបនកម្ម មានគំនូរគំពេងហាត់ដៅនៃតួប្រាសាទ, វិធីលើកស្ទូចដុំថ្មដ៏ធំមហិមាដាក់បន្តបគ្នាឲ្យទាល់តែបានខ្ពស់ស្កឹមស្កៃ នឹងវិធីលាយធាតុធរណី ឲ្យកើតបានជាថាវរវត្ថុជាប់លាប់បានអាយុវែងក្រៃលែងមកជាដើម ។

យើងមិនមែនចេះតែពោលទន្ទេញពីអង្គរវត្ត ដោយព្រាវ ៗ ឬដោយអាងតែគ្មាននរណាកើតទាន់នោះទេ គឺយើងពោលដោយចេះសិក្សាស្រាវជ្រាវរកន័យរបស់បូជនីយដ្ឋានទាំងនោះផង ទើបប្រសើរ ព្រោះជួនកាលថ្មមួយដុំតូចសោះ តែមានខ្លឹមសារជ្រាលជ្រៅសិក្សាមិនអស់មិនហើយ ។

ហេតុនេះ ភារៈយើងជាខេមរជាតិក្នុងបច្ចុប្បន្នកាល ត្រូវតែនាំគ្នាសើរើនូវវប្បធម៌ចាស់ ៗ ឲ្យអស់សិន សឹមសិក្សាថែមទៅក្នុងវប្បធម៌ទំនើប ។

ទៀត ៗ ព្រោះថា ជាតិណា សាសន៍ណាក៏ដោយ, បើគេចង់សិក្សា ឲ្យបានចេះពិតប្រាកដខាងវប្បធម៌ គេត្រូវសិក្សាជាដំបូង ពីវប្បធម៌បុរាណរបស់ជាតិខ្លួនជាមុន ដើម្បីបង្កើតមូលដ្ឋាន គឺឫសកែវមួយឲ្យមាំសិន ហើយគេចាប់សិក្សាបំបែកពីវប្បធម៌ទំនើបជាបន្ត ៗ ទៅទៀត ៗ ត្រង់នេះ យើងនឹកឃើញឧទាហរណ៍មួយ ដូចជាដើមរុក្ខជាតិនានា ៗ ដើម្បីឲ្យដើមរុក្ខានោះ មានសភាពមាំទាំឥតព្រួយបារម្ភដោយខ្យល់ព្យុះ ឬទឹកជន់ ត្រូវដើមឈើនោះចាក់ឫសកែវឲ្យស៊ប់មាំមួនក្នុងធរណី សិន រួចសឹមបែកមែកសាខាជាក្រោយ ៗ បើដើមឈើណាមានសណ្ឋានដូចនេះ ប្រាកដជាមែក, ធាង, ស្លឹក, ត្រួយ, លូតលាស់បានល្អគ្រប់កាល ហើយជៀសវាងពីមហន្តរាយព្យុះផង ៗ

(នៅមានត)

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

*ដោយយល់ឃើញថា ជាការមានប្រយោជន៍យ៉ាងវិសេសដល់អ្នកអានភាគច្រើន ទើបយើងស្រង់យកមកចុះប្រគេន.ជូនបន្តិចម្តងៗក្នុងទំព័រនេះ នូវពាក្យដែលគណៈកម្មការវប្បធម៌ បានប្រែចេញពីភាសាបារាំងមកជាខេមរភាសា ដូចតទៅនេះ៖*

| | |
|---|---|
| Livret scolaire | សៀវភៅសិក្ខាធារិក |
| Racine crampon | ឫសតោង |
| Racine pivotante | ឫសស្នឹង |
| Racine adventive | ឫសព្រយុង |
| Racine fasciculée | ឫសស្រែ |
| Recensement agricole | ដំរឿងកសិកម្ម |
| Vulgarisation agricole | ឧត្តានកសិកម្ម |
| Floraison n.f. | រដូវផ្កា, បុប្ផការ, បុប្ផកាល |
| Fructification n.f. | រដូវផ្លែ, ផលការ |
| Renseignements culturaux | ពត៌មានខាងវប្បកម្ម |
| Pluviométrie n.m. | វស្សមាត្រវិធី |
| Pluviomètre n.f. | វស្សមាត្រ |
| Hygrométrie n.f. | មេឃមាត្រវិធី |
| Nicotine n.f. | និកូតរស |
| Pipérine n.f. | ម្រេចរស |

| | | |
|---|---|---|
| Caféine | n.f. | ការហ្វេរស |
| Croisement | n.m. | ការបង្កាត់ |
| Pollinisation | n.f. | រង្វិលំអងផ្កា, ការកេយលំអងផ្កា |
| Tout venant | | ពូជរាយ |
| Franc pied | | ពូជបណ្តុះ |
| Acidité du sol | | ភាពជូរនៃដី, អម្ពិលភាព |
| Alcalinité du sol | | ភាពប្រៃនៃដី, លោណភាព |
| Neutralité du sol | | អព្យាក្រិតភាពនៃដី |
| Sous-sol | n. m. | អធោប្រថពី |
| Sonde agrologique | | ចង្រប់ក្សេត្រភូមិ |
| Agrologie | n. f. | ក្សេត្រភូមិវិទ្យា |
| Sécateur | n. m. | កន្ត្រៃកាត់ឈើ |
| Ecartement | n. m. | ប្រលោះ, ប្រឡោះ |
| Plante herbacée ou herbe | n. f. | តិណជាតិ |
| Plantes aborescentes | | រុក្ខជាតិ |
| Arbrisseau | n. m. | គុម្ពព្រឹក្ស |
| Arbuste | n. m. | ចុល្លព្រឹក្ស |
| Lianes | n. f. | វល្លិជាតិ |
| Botanique | n. f. | ភូតគាមសាស្ត្រ |
| Plante adventice | | ភូតគាមដុះឯង |
| Modernisation de l'agriculture | | ទំនើបនីយកម្មនៃកសិកម្ម |
| Désherbant | n. m. | ថ្នាំតិណឃាត |
| Phytopharmacie | n. f. | ភូតគាមោសថវិទ្យា (ភូតគាមោសថវិទ្យា) |
| Phytopathotique | | ភូតគាមរោគវិទ្យា |
| Azotobactère | | អស្សូតូប័កទែរ |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

*ព្រះមហា ប៉ាង - ខាត់ រៀបរៀង*

អតិបទ្ធិន គុ (ដី) ដែលមានស្នាមដាំក្រហមក្រៃពេក ។

អតិបរិក្លិដ្ឋ គុ. ដែលឈឺក្រៃលែង ។

អតិបរិក្ខត គុ ដែលរបួសក្រៃលែង ។

អតិបរិចយ បុំ. កិរិយាសន្សំក្រៃលែង ។

អតិបរុស គុ. សាហាវក្រៃលែង, ស្រួចក្រៃពេក ។

អតិបា ធាតុ. ដឹកក្រៃលែង ។

អតិបាត បុំ. កិរិយាធ្លាក់ក្រៃលែង, ការធ្វេសប្រហែស, ការភ្លេច ។

អតិបាតក នបុំ. ទោសធ្ងន់ក្រៃលែង ។

អតិបាតិន គុ. ដែលធ្លាក់ចុះក្រៃលែង, ដែលលឿនក្រៃលែង, ដែលបណ្ដែតបណ្ដោយ ។

អតិបាត្យ គុ ដែលគប្បីបណ្ដែតបណ្ដោយ ។

អតិបារ គុ. ដែលទូលាយក្រៃលែង ។

អតិបិតាមហ គុ. អតិបិតាមហា ដែលកន្លងជីតាដោយក្រៃលែង ។

អតិបិត្ឫ គុ. ដែលកន្លងបិតាដោយក្រៃលែង ។

អតិបិឝុន គុ. អាក្រក់ក្រៃលែង, ដែលញុះញង់ក្រៃលែង ។

អតិបីឍន ឧបុ. កិរិយាបេតបៀនក្រៃលែង ។

អតិបុណ្យ គុ. ដែលមានបុណ្យក្រៃលែង។ – វន្ត គុ. ដែលមានបុណ្យក្រៃលែង ។

អតិបូរ ឧបុ. ស្ទឹងហូរខ្លាំង, កិរិយាហូរក្រៃពេក ។

អតិបូរ៌ គុ. ដែលកន្លងទៅយូរក្រៃពេក ។

អតិភ្ឫ ធាគុ. ពេញក្រៃពេក ។

អតិបេឝល គុ. ដែលប្រសប់ក្រៃលែង, ដែលឆ្លាតខ្លាំង ។

អតិបៅរុឞ គុ. ដែលក្លៀវក្លាក្រៃលែង ។

អតិប្រកាឝ គុ. ដែលប្រកាសក្រៃលែង, ដែលល្បីល្បាញ ៗ ពោ ។

អតិប្រគេ ក្រិ. វិ. ព្រឹកព្រហាមណាស់ ។

អតិប្រជ្វល ធាគុ. បំភ្លឺក្រៃលែង, ក្រាល ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៣

ឧកញ៉ាវិបុលរាជសេនា ង៉ូ-ហ៊ាង ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ |
| អ្នកវាងវៃឆ្លាសបើបានអាន |
| នឹងបេះឧបាយកលបំណាន |
| ទាំងមានសន្តានស្នេហាជាតិ ។ |

ជីវយីឮដូច្នោះក៏តក់ស្លុតស្មារតី ហើយបង្គាប់ស៊ុនខៀនថាឲ្យវិលទៅវិញចុះ ចាំថ្ងៃក្រោយយើងនឹងទៅសួរឡូពី ។ ស៊ុនខៀនក៏លាជីវយីទៅវិញ ។ ឡោសុកក៏សួរជីវយីថា ស៊ុនខៀនជំពបលោកថា ឡូពីនឹងខុងបេងលើកទាហានទៅតាំងនៅមាត់កំពង់អីកាំង លោកក៏យកតក់ស្លុតស្មារតីដោយហេតុអ្វី ? ។ ជីវយីថា ពីព្រោះយើងឃើញហេតុថា ឡូពីនឹងខុងបេងមុខជាដណ្ដើមយកស្រុកឡាំកុនជាប្រាកដ បានជាយើងភ័យបារម្ភណាស់ ដែលយើងធ្វើការគ្រានេះក៏ខូចបង់ទ្រព្យរបស់ មាសប្រាក់ ដែលចំណាយឲ្យសេនាទាហានប្រើប្រាស់ នឹងស្បៀងអាហារជាច្រើន

ឯស្រុកឡាំកុននោះ ក៏ដូចជានៅក្នុងកណ្ដាប់ដៃយើងហើយ បើត្រឡប់ជាបានស្រុកនោះទៅឡៅពី, ខុនបេងវិញ យើងក៏នឹងមានសេចក្ដីតូចចិត្តដូចជាស្លាប់ខ្លួន, ហេតុនេះ ទើបយើងភ័យបារម្ភណាស់ ។ ឡោស៊ុកថា បើដូច្នោះ តើលោកនឹងគិតប្រការម្ដេចវិញ ដើម្បីនឹងឲ្យឡៅពីនឹងខុនបេងលើកទាហានថយទៅពីទីនោះ ឲ្យឆ្ងាយពីដែនស្រុកឡាំកុនបាន ? ។ ជីវ-យីតបថា យើងត្រូវគិតឲ្យទៅនិយាយនឹងឡៅពី ដោយសេចក្ដីល្អសុភាពសិន បើឡៅពីមិនស្ដាប់យើងទេ សឹមយើងគិតកំចាត់ចេញឲ្យបាន ។ ឡោស៊ុកថា លោកគិតនោះត្រូវណាស់ បើលោកត្រូវការទៅរកឡៅពីវេលាណា ខ្ញុំបាទនឹងទៅផង ។ ខណៈនោះ ជីវយីក៏នាំឡោស៊ុកទៅជាមួយនឹងទាហាន ៣ ពាន់ ចុះទូកចម្បាំងចេញពាកកងទ័ព ដើម្បីនឹងទៅរកឡៅពី ។

ឯស៊ុនខៀនកាលត្រឡប់ទៅដល់ ក៏ចូលទៅជំរាបឡៅពីតាមរឿងជីវយីនិយាយនោះសព្វគ្រប់ ។ ឡៅពីឮដូច្នោះ ក៏ប្រឹក្សានឹងខុនបេងថា ដែលជីវយីប្រុងនឹងមកគំនាប់យើងនោះ លោកយល់ឃើញប្រការម្ដេច? ។ ខុនបេងថា ឯចិត្តជីវយីនោះ មិនមែនរាប់អានខ្ញុំនឹងលោកដោយស្មោះត្រង់ ហើយចង់មកគំនាប់ដោយត្រង់ទេ គឺប្រុងនឹងមកដោយមន្ទិលសង្ស័យថា យើងមុខជាដណ្ដើមយកស្រុកឡាំកុន ។ ឡៅពីថា បើជីវយីមកជាក្បួនទ័ព

តើយើងនឹងត្រូវគិតប្រការម្តេច ៗ ខុនបេងទុនខ្សិបប្រាប់ឡៅពីឲ្យឆ្លើយ តបពាក្យសំដី ទៅនឹងដីវយើសព្វគ្រប់ ហើយប្រើទាហានឲ្យរៀបចំទូក ចម្បាំងចេញទៅចតនៅមាត់កំពង់ ថាបើឃើញដីវយើមកដោយកាច ក៏ ឲ្យជួយគ្នាច្បាំងការពារតាមការ ទទួលមានបំរើចូលមកដំរាបថា ឃើញ ដីវយើនឹងឡោសុក លើកទាហានមកប្រហែល ៣ ពាន់ ចតទូកនៅមាត់ កំពង់ ៗ ឡៅពីក៏ប្រើជូឡុងឲ្យនាំទាហានប្រហែល ៥០ នាក់ ចេញទៅ ទទួលដីវយើដល់ក្រៅបន្ទាយ ដីវយើក៏ឲ្យទាហានតាំងពួនឈប់នៅខាងក្រៅ ហើយនាំឡោសុក ចូលទៅក្នុងបន្ទាយ, ឡៅពីនឹងខុនបេង ក៏ចេញទៅ ទទួលដីវយើៗ ចូលមកអង្គុយទីសមគួរ ហើយក៏គំនាប់គ្នាទៅវិញទៅមក ហើយឡៅពីឲ្យរៀបតុះលៀងអាហារ អញ្ជើញដីវយើនឹងឡោសុកបរិភោគ ផឹកស្រា ឡៅពីក៏សរសើរដីវយើថា ដែលលោករិះគិតកំចាត់ចូចូចេញបាន ក្នុងគ្រានេះ អាណាប្រជានុរាស្ត្របានសេចក្តីសុខក្សេមក្សាន្ត ព្រោះលោក ជាច្រើនណាស់ ៗ ដីវយើសួរឡៅពីថា ដែលលោកឃុំនាំទាហានមក តាំងនៅទីនេះ លោកគិតនឹងទៅវាយយកស្រុកឡាំកុនឬអ្វី? ៗ ឡៅពី ថា តាមពាក្យដែលខុនបេងខ្សិបប្រាប់ទៅដីវយើថា ដែលខ្ញុំលើកមកតាំង នៅទីនេះ ព្រោះគិតថាលោកនឹងលើកទ័ពទៅវាយស្រុកឡាំកុន ខ្ញុំនឹង លើកទាហានទៅជួយជាការរហ័សផង បើលោកមិនទៅទេ ខ្ញុំគិតថា

នឹងលើកទៅវាយស្រុកឡាំគុន ជូនលោកមិនបាច់ឲ្យលោកព្រួយក៏បាន ។ ជីវយើឮដូច្នោះ ក៏អស់សំណើចហើយថា ខ្ញុំជាជាតិទាហាននៅស្រុកកាំងតាំង ខ្ញុំក៏គិតមកជាដរាបថា នឹងលើកទ័ពទៅវាយយកអាណាខេត្រខាងទិសឧត្តរ ឲ្យជាបំណាច់ជូនដៃជាមុន តែទទួលបូចូលើកកងទ័ពចុះមកវាយយកខេត្រទ័ណ្ឌ ខាងទិសទក្សិណគ្រានេះ បានជាខ្ញុំនៅចាំតស៊ូច្បាំងនឹងបូចូទាល់តែបែករត់ទៅវិញ ខ្ញុំក៏ខាតបង់ស្បៀងអាហារនឹងរបស់ទ្រព្យដែលត្រូវការបំណាយក្នុងសង្គ្រាមច្រើនណាស់ ឯស្រុកឡាំគុនគ្រានេះ បីដូចជានៅក្នុងកណ្ដាប់ដៃខ្ញុំហើយ បើខ្ញុំប៉ងយកពេលណាក៏បានដោយងាយណាស់ ហេតុម្ដេចលោកថាខ្ញុំនឹងមិនយកវិញ ។ ទៀតពីថា កាលបូចូបែកទៅនោះ បានតាត់ពោយ៉ានឲ្យទៅឈររក្សាស្រុកឡាំគុន ហើយទុកទាហានសុទ្ធតែមានថ្វីដៃ ឲ្យទៅរក្សាគយតាមច្រកផ្លូវគ្រប់អន្លើ ឯពោយ៉ាននោះ ក៏មានកំឡាំងក្លៀវក្លាហានណាស់ ខ្ញុំក្រែងលោកទៅធ្វើការនោះមិនបានដូចបំណងគិត ។ ជីវយើថា បើខ្ញុំវាយយកស្រុកឡាំគុននោះមិនបានទេ ឲ្យលោកទៅវាយយកចុះ ។ ទៀតពីឮដូច្នោះ ក៏ឆ្លើយថាដែលលោកមានប្រសាសន៍ដូច្នេះ ខ្ញុំសុំឲ្យឡោសុកនឹងខុងបេងដែលមកជួបជុំគង់ទីនេះ ជួយជាបន្ទាល់សាក្សីផងចុះ បើអំណើះតទៅមុខ ជីវយើប្រែពាក្យសំដីវិញយ៉ាងម្ដេច ខ្ញុំត្រូវយកអ្នកទាំង២ហើយ ។ ជីវយើថា

ខ្ញុំកើតមកជាប្រុសបានចេញនិយាយថាម្ដេចហើយ មិនត្រឡប់កែប្រែវិញទេ ៗ ខុនបេនក្អែនថា ដីវយើនេះ បើនឹងចរចាអ្វីក៏រមែងពិតប្រាកដណាស់ បើដូច្នោះត្រូវឲ្យដីវយើទៅវាយយកស្រុកឡាំគុនជាមុនចុះ បើក្រងាយប្រការម្ដេច សិមឡៅពីលើកទៅធ្វើការជាក្រោយ ៗ ដីវយើនឹងឡៅស៊ុកក៏លាឡៅពី ខុនបេន ចុះទូកត្រឡប់ទៅ ៗ

ឡៅពីនិយាយនឹងខុនបេនថា ឯការដែលដីវយើទៅវាយស្រុកឡាំគុននោះ មុខជានឹងបានជាប្រាកដ ខ្ញុំនៅគិតព្រួយមួយយ៉ាងថា សព្វថ្ងៃនេះខ្លួនយើងនឹងរកស្រុកនៅសំណាក់អាស្រ័យគ្មានសោះ បើដូច្នោះនឹងត្រូវគិតដូចម្ដេច? ៗ ខុនបេនថា ពីដើមខ្ញុំបាននិយាយជំពបលោក ឲ្យទទួលយកស្រុកកេងដីវទុកជាទីអាស្រ័យ ដើម្បីនឹងគិតការតទៅ លោកមិនចេះជឿស្ដាប់ពាក្យខ្ញុំសោះ គ្រានេះលោកគិតឃើញហើយឬ បានជានិយាយថាព្រួយចិត្តដូច្នេះវិញ ៗ ឡៅពីថា កាលពីដើម លោកបាននិយាយមែនហើយ ដែលខ្ញុំមិនព្រមយកស្រុកកេងដីវទុកនោះ ព្រោះហេតុថាជាស្រុករបស់ឡៅពៀវ ឥឡូវស្រុកកេងដីវត្រឡប់បានទៅចូចូវិញ ខ្ញុំនឹងរិះគិតវាយយកឲ្យបាន ៗ ខុនបេនថា លោកកុំបីព្រួយឡើយ ចូរបង្អង់ឈប់ឲ្យដីវយើវាយយកស្រុកឡាំគុនឲ្យបានសិន ខ្ញុំនឹងរិះគិតកលឧបាយមិនឲ្យរវល់ដល់ទាហានទាំងពួង នឹងឲ្យបានស្រុកឡាំគុនដោយងាយ ៗ

ឡៅពីសួរថា លោកនឹងរិះគិតប្រការម្ដេច? ។ ខុនបេនថា លោកកុំអាលសួរសិនឡើយ ក្រោយសឹមដឹង ឡៅពីមានអំណរពន់ប្រមាណណាស់ មិនបានសួរតទៅទៀត ។

ឯដីវយីនឹងឡៅសុកលុះវិលទៅដល់បន្ទាយ ឡៅសុកក៏សួរដីវយីថា ហេតុម្ដេចបានជាលោកនិយាយនឹងឡៅពីថា បើលោកវាយយកស្រុកឡាំគុនមិនបាន ថាឲ្យឡៅពីវាយយកស្រុកឡាំគុនវិញនោះជាយ៉ាងម្ដេច? ។ ដីវយីថា ដែលខ្ញុំថានឹងឡៅពីយ៉ាងនោះគឺជាពាក្យបញ្ឆោតទេតើ ព្រោះខ្ញុំថាឲ្យឡៅពីមានចិត្តក្អើនកំរើកឡើង ហើយថាគ្រានេះ យើងនឹងលើកទៅវាយយកស្រុកឡាំគុន តើនរណានឹងទទួលអាសាចេញទៅជាទ័ពស្រួចៗ ដីវយឹមឆ្លើយថា ខ្ញុំបាទសុំអាសាលើកទាហានជាកងមុខទៅមុន ។ ទើបដីវយីបើកទាហាន ៥ ពាន់ ឲ្យឈីសេង, គេងហាងទៅជាមួយនឹងដីវយឹម ហើយបង្គាប់ថាឲ្យស្រួតលើកឆ្លងទន្លេហ័នតុទៅមុនចុះ យើងនឹងលើកកងទ័ពហ្លួងទៅតាមជាក្រោយ ដីវយឹមនឹងឈីសេង, គេងហាងក៏លើកទាហាន ៥ ពាន់ចេញទៅ លុះទៅដល់គយអ៊ុយឡេង ឈីសេង, គេងហាងក៏លើកគ្នាចូលច្បាំងកាច់យកគយនោះមិនបាន ទើបនាំទាហានពង្វាងគយទៅជិតទៀបស្រុកឡាំគុនហើយ ក៏ឲ្យតាំងបន្ទាយនៅប្របទីនោះ ។

ខណៈនោះបំរើសេះចូលទៅប្ដឹងបោយិនថា ឥឡូវកងទ័ពស្រុកកាំង

តាំងលើកមកច្បាំងទៀតហើយ តាំងបន្ទាយនៅជិតស្រុកយើងនេះ ៗ ចៅឃិនត្រូវដូច្នោះ ក៏ប្រឹក្សានឹងទាហានទាំងពួងថា ឥឡូវដីវយើប្រើឈីសេងគេងហាង លើកទ័ពមកប៉ងធ្វើឲ្យអន្តរាយស្រុកយើង ឯស្បៀងអាហារដែលមានក្នុងស្រុកនេះក៏ច្រើន យើងត្រូវតែការពាររក្សាស្រុក ទុកខាងក្នុងកុំឲ្យសត្រូវចូលមកបាន បើយូរទៅសត្រូវគង់នឹងដាច់ស្បៀងលើកទៅឯង ៗ នីវយើមថា ដែលនឹងតាំងរក្សាស្រុកតែពីខាងក្នុងឲ្យសត្រូវដាច់ស្បៀងនោះ សត្រូវក៏នឹងបានចិត្ត, ប្រការ ១ ទៀត ទាហានរបស់យើងក៏គង់មានគិតតូចចិត្តថា យើងខ្លាចញញើត ខ្ញុំនឹងសុំអាសាលើកទាហាន ៥០០ ចេញទៅតទល់ការពារ ចៅឃិនយល់ឃើញត្រូវ ក៏ចាត់ចែងទាហាន ៥០០ ឲ្យ ឯនីវយើមក៏លើកទាហាន៥០០ នោះចេញទៅច្បាំងនឹងគេងហាងឃើញដូច្នោះ ក៏ទាញសេះបង្អង់ឈប់ ហើយប្រកាសប្រាប់ទាហានទាំងពួងឲ្យចោមឡោមព័ទ្ធនីវយើមទុកឲ្យដាច់ នីវយើមក៏ស៊ូតច្បាំងនៅក្នុងចំណោមទាហានដោយក្លៀវក្លា ៗ

ឯចៅឃិននៅលើសើនបន្ទាយ ឃើញគេងហាងឡោមព័ទ្ធនីវយើមនៅក្នុងចំណោមដូច្នោះ ក៏តែងខ្លួនពាក់គ្រឿងឡើងសេះនាំទាហានប្រហែល ៣០០ ស្រូតចេញវាកទ្វារស្រុក ទំលុះពារទ័ពសត្រូវចេញទៅ ដើម្បីនឹងជួយនីវយើម ៗ ឈីសេងៈឃើញដូច្នោះ ក៏បរសេះចូលតច្បាំងនឹងចៅឃិន

យូរណាស់ ឈើសេងគទល់ពុំបានក៏ញាក់សេះថយតែទៅ ៗ ហោយិនក៏នាំជីវយើមចេញមកបានពីក្នុងចំណោម លុះក្រឡេកឃើញទាហានដែលសល់តាមចេញមកប្រហែល ៤០ នាក់ ហោយិនក៏នាំជីវយើមត្រឡប់វិលទៅគងវិញ ប៉ុននឹងសងសឹកទាហានទាំងពួង ៗ ឯហោស៊ុននៅលើសេះក្រឡេកឃើញហោយិនលើកចេញទៅច្បាំងជាប់ដៃគ្នា ក៏ឡើងសេះកាន់លំពែងនាំទាហានជំនួយចូលទៅជួយប្រឡូកគ្នាជាប្រឡំបល់ បានចាក់កាប់សម្លាប់គ្នាស្លាប់ជាច្រើន ៗ ឯជីវយើម, ឈើសេង, គេងហង លុះតទល់ពុំឈ្នះ ក៏នាំទាហានដែលសល់នោះថយទៅ ហោយិនក៏មានជ័យជំនះ ហើយនាំហោស៊ុននឹងជីវយើម នូវអស់ទាហានត្រឡប់ចូលទៅស្រុកវិញ ៗ

កាលជីវយើម លើកទាហានមកជួបនឹងកងទ័ពជីវយើ ក៏ពណ៌នាសេចក្ដីដែលបានទៅធ្វើការសង្គ្រាម ហើយបែកទ័ពត្រឡប់មកនោះ ឲ្យជីវយើស្ដាប់គ្រប់ប្រការ ៗ ជីវយើក្ដៅហើយខឹងណាស់ បង្គាប់ឲ្យទាហានយកខ្លួនជីវយើមទៅសម្លាប់ ទីប្រឹក្សានឹងទាហានទាំងពួងក៏នាំគ្នាអង្វរសុំទោសជីវយើ ៗ ក៏លើកទោស ហើយប្រមូលទាហានលើកទៅតាំងបន្ទាយក្ជាប់គ្នាឯស្រុកឡាំគុននោះ ខ្ញុំយល់ឃើញថាមិនត្រូវទេ ព្រោះហោយិនឲ្យហោហងជាប្អូន លើកទាហានទៅតាំងបន្ទាយនៅស្រុកអ៊ីឡេង ឥឡូវកងទ័ពយើង លើកកងចូលទៅហួសគយអ៊ីឡេងហើយ បើហោហងដឹង

គឺនឹងលើកមកវាយខ្ទប់ ខ្ញុំនឹងសុំអាសាលើកទៅវាយគយអ៊ីឡេង ឲ្យទាហានបោហង់បែកខ្ញែកគ្នាសិន រួចសឹមលើកចូលទៅតាំងបន្ទាយក្ដាប់ជិតគ្នានឹងស្រុកឡាំគុន ដើម្បីនឹងធ្វើសង្គ្រាមតទៅ ។ ដីវយើយល់ឃើញត្រូវ ក៏ចាត់ទាហានឲ្យកាំឡេង ៣ ពាន់ ។ កាំឡេងក៏លើកទាហានស្រួករូតចេញទៅជិតគយអ៊ីឡេង ។

បំរើសេះក៏ចូលទៅឲ្យដំណឹងពោយិនថា ឥឡូវដីវយើប្រើកាំឡេងលើកទ័ពទៅវាយគយអ៊ីឡេងហើយ ។ ពោយិនឮដូច្នោះ ក៏ប្រឹក្សានឹងទាហានទាំងពួងថា ត្រូវគិតយ៉ាងម្ដេច? ។ តិនកៀវថា បើនឹងបង្អង់ទុកឲ្យយូរក៏នឹងខូចគយអ៊ីឡេងជាប្រាកដ បើគយនោះខូចហើយ ស្រុកឡាំគុនក៏យើងរក្សាការពារមិនឈ្នះ ។

(នៅមានត)

# ល្បែងអៀវ

## លោក ញង-សឿង រៀបរៀង

មានសេចក្ដីដំណាលថា តាំងពីយូរឆ្នាំណាស់មកហើយ មានលោកគ្រូសង្ឃរាជ.១ អង្គគង់គ្រប់គ្រងវត្តមួយ ៗ លោកគ្រូនោះមានអំណាចកាចណាស់ ៗ ក្នុងការប្រដៃប្រដៅសិស្សគណ. លោកតែងប្រើតែរំពាត់នឹងដំបងព្រនង់ជាជំនួសទណ្ឌកម្មក្នុងច្បាប់វិន័យ ៗ លោកតែងមានថេរដីកាថា ទណ្ឌកម្មព្រះមិនឈ្នះទណ្ឌកម្មលោកទេ ៗ ភិក្ខុសាមណេរនឹងក្មេងវត្តទាំងអស់ ខ្លាចលោកជាងយក្ស មិនដែលហ៊ានមើលចំព្រះភក្ត្រលោកដល់ម្ដងណាសោះឡើយ ៗ នៅកុដិលោកមានបំពង់ឫស្សីធំមួយ បោះដែកគោលភ្ជាប់នឹងសសរ ហើយដាក់រំពាត់ផ្ដៅនឹងឫស្សីគ្រប់ធុន មានតាំងពីប៉ុនចង្កឹះរហូតដល់ប៉ុនមេដៃមេជើង ៗ ពល់តែពេលដែលលោកត្រូវវាយ, សិស្សណាមានកំហុស សិស្សនោះត្រូវលូនចូលទៅថ្វាយបង្គំរំពាត់ក្នុងបំពង់នោះ ៣ ដង ហើយសុំអញ្ជើញដោយពាក្យថា "ខ្ញុំសុំអញ្ជើញលោកទៅជួយកាត់សេចក្ដី" រួចហើយក្រោកឈរឡើងសំឡឹង ជ្រើសរើសតាមស្ម័គ្រចិត្តរបស់ខ្លួន ស្រឡាញ់ធុនណា ទើបដកហូតធុននោះកាន់ទ្រដោយដៃទាំងពីរយកទៅប្រគេនលោកភ្លាម ៗ កាលណាលោកបានវាយរួចហើយ សាមីខ្លួនត្រូវទទួលរំពាត់ពីលោកដោយដៃទាំងពីរយកទៅស៊កទុកក្នុងបំពង់

វិញ ថ្វាយបង្គំរំពាត់នោះ ៣ ដងទៀត ទើបថយចេញទៅ ៗ លស់ថ្ងៃតិចណាស់ ដែលមិនត្រូវរំពាត់នឹងមាត់ជេរពោលប្រដែប្រដៅ ៗ តែទោះបីយ៉ាងណា ក៏គង់នៅមានសិស្សគណខិលខូចខ្ទះពុំខាន ដូចយើងធ្លាប់បានឮចាស់ ៗ និយាយមកហើយថា "គ្រូកាច សិស្សខូច" ។

ពិតដូច្នោះមែន, មានភិក្ខុ ២ រូបជាអ្នកខិលរបុិលរបូច ខូចមាត់កណាស់ខាងឯចំអកឡកឡឺយត្លុកកំប្លែង បាននាំគ្នាដាក់គោរម្យងារឲ្យលោកគ្រូសង្ឃរាជពីរបីយ៉ាងថា «មហាជម្ពូ-មហាក្រឡេកឆេះ-អគ្គីនេត្រ» ។

ក្នុងពេលដែលលោកគ្រូសង្ឃរាជ មានការនិមន្តចេញទៅកាន់ទីឆ្ងាយពីវត្តម្ដងៗ, បណ្ដាភិក្ខុទាំងពីររូបនោះ ណាមួយតែងតែឡើងទៅលើកុដិលោកគ្រូសង្ឃរាជ ទៅអង្គុយត្រង់កន្លែងលោក ធ្វើពុតពារទឹកមុខនឹងសំដីសំដៅ គ្រាប់តាមដំណើរលោកគ្រូសង្ឃរាជ ហើយនិយាយមុិកប្រាយត្លុកកំប្លែងលេងជាល្បែងផ្សេងៗ នាំឲ្យលោកសង្ឃឯទៀតៗ ព្រមទាំងក្មេងវត្តចោមរោមសើចគឹលៗ សប្បាយរីករាយ ជាឯកច្ឆាន ៗ ពាក្យចាស់ថា ·"ឆ្មាមិននៅ កណ្ដុរឡើងរាជ្យ" ។ មិនតែប៉ុណ្ណោះទេ ភិក្ខុទាំងពីររូបនោះចូលចិត្តណាស់ទៅទៀតខាងលេងល្បែងអៀវគ្នា ៗ រាល់តែពេលយប់ដែលចេញពីសូត្រធម៌ថ្វាយបង្គំព្រះក្នុងព្រះវិហារ , ភិក្ខុខិលទាំងពីរ តែងព្រយិតប្រគោងជិះកអៀវគ្នា ធ្វើសេះម្ដងម្នាក់តាំងពីដំណើរ

ព្រះវិហារហូតដល់កុដិរបស់ខ្លួនជាធម្មតា ។ ក្នុងពេលយប់មួយនោះ ជាពេលខាងរនោច, នៅវេលាចេញពីសូត្រធម៌ក្នុងព្រះវិហារ, លោកគ្រូសង្ឃរាជដែលកាលពីមុនៗ ជាប់តែចេញក្រោយគេ លោកបែរជានិមន្តចេញទៅដំណាលនឹងលោកបរិស័ទឯទៀត ៗ ដែរ ដោយលោកមានកិច្ចការនៅកុដិលោក ។ ពេលនោះ ស្រាប់តែភិក្ខុពាល ១ អង្គស្ទុះលោតភ្លែតទៅព្រយិតប្រតោងអៀវលោកគ្រូសង្ឃរាជ ដោយស្មានថាគូកនរបស់ខ្លួន ព្រោះកំពស់កំពពង់ពេលោកគ្រូសង្ឃរាជ នឹងគូកននោះស្រដៀងៗគ្នា ប្លែកតែលោកគ្រូសង្ឃរាជលោកចាស់ជាងប៉ុណ្ណោះ, ដៃទាំងពីរលូកព័ទ្ធចាក់ស្រេះរឹតកលោកគ្រូសង្ឃរាជយ៉ាងតឹង ជើងទាំងពីរព័ទ្ធបង្កេះពត់ទៅខាងមុខប្រជុំចុងគ្នាត្រង់ផ្ចិតហើយកេវកៀបត្បៀតប្រទាក់គ្នាយ៉ាងមាំ រួចហើយក៏គាំងគោះក្បាលជង្គង់ទាំងសងខាងរបស់ខ្លួន ត្រង់បង្កេះលោកគ្រូសង្ឃរាជព្រមទាំងស្រែកបណ្តើរថា « អៀវ ៗ អាចំប៉ា! អៀវ ៗ! មើលអាចំប៉ា ម្តងណេះលុនឲ្យលឿនបន្តិចមើល! » ។ ពេលនោះលោកគ្រូសង្ឃរាជទៅជាហួសបើគិត នៅស្ងៀមឈឹងឥតមាត់កមួយម៉ឺះសោះបេះតែចំប្រឹងនិមន្តទៅទាំងត្រដេវត្រដរ ណាមួយរឹតតឹងបំពង់កខ្លាំងណាស់ដកដង្ហើមរកកល់លែងចួបគ្នាម្តង ៗ ទៅហើយ ណាមួយរឹតតឹងធ្ងន់ជាបល្វែងក្រោមណាស់ទៅទៀត រកតែកំសៀតយោលជើងបោះជំហាន ទៅ

មុខស្ទើរពុំរួច ប៉ុន្តែលោកចេះតែខំប្រឹងទ្រើប ៗ ទៅទាំងជ្រុលជ្រេក ដោយលោកគិតថា កុំឲ្យភិក្ខុនោះអៀនខ្មាស ព្រោះវាបានជាជ្រុលហួសទៅហើយ ។ បន្តិច ៗ ឮសូរតែមាត់ "អៀវ អាចំប៉ា-អៀវ ! យើ ! អាចំប៉ាម្តងណោះ ក៏ដូចជាតតេះតតះអីខ្លាំងម៉្លេះ ថ្ងៃនេះបែបស៊ីស្មៅមិនសូវឆ្អែតឬយ៉ាងម៉េច" ។ រីឯលោកបរិស័ទឯទៀតៗដែលនិមន្តចេញមកពីព្រះវិហារដែរនោះ ក៏មិនបានជាយកចិត្តទុកដាក់ចាប់ភ្លឹកនឹកនាក្នុងរឿងនេះប៉ុន្មាន ព្រោះស្មានថា គេអៀវគ្នាគេដូចធម្មតាមុន ៗ ។ លុះដិតទៅដល់មុខកុដិ , លោកគ្រូសង្ឃរាជ ហាក់ក្រៃណាទឹងហត់ អត់ទ្រាំតទៅទៀតមិនបានក៏ឈប់ហើយតាំងមានថេរដីកាទាំងអាក់អួលថា " ម៉េចអាប្រមឹតត្រយូវ[1]! អាឯងចង់ឲ្យអញស្លាប់ឬយ៉ាងម៉េច ! ។ ឮតែពាក្យប៉ុណ្ណោះ ភិក្ខុនោះភ្ញាក់ព្រើត ដោយស្គាល់ជាក់ជាមាត់លោកគ្រូសង្ឃរាជ មិនដឹងជាដៃទឹងជើងខ្វិន របូតចេញពីកន្ទឹងចង្កេះលោកគ្រូសង្ឃរាជផង ៗ លោកគ្រូសង្ឃរាជ ស្រែកយ៉ាងបន្ទាន់បន្ទាប់នោះភ្លាម " ចាប់ ៗ ជួយចាប់វាឲ្យបាន" ។ ភិក្ខុសាមណេរក្នុងវត្តបានឮដូច្នោះក៏ស្រឡាំងកាំងផ្អើលឆោឡោឈូឆរ មកចោមរោមពិតទូលសួររឿងរ៉ាវលោកគ្រូសង្ឃរាជក្នុងពេលនោះភ្លាម ប៉ុន្តែមានអ្នកណារត់ទៅតាមចាប់បាន បើភិក្ខុនោះប្រាស់ក្រដឹងរត់ភីងកែងជាប់គូថ ល្មាំងកាត់គុម្ពចេកកៀនកុដិ បុនព្យុះសង្ឃរាទៅខាងលិច

---

១ - ក្លាយមក ពីពាក្យ 'ប្រមឹត្យុ' ( សេចក្តីស្លាប់ ) ។

វត្តបាត់ទៅហើយ; ហើយម្យ៉ាងទៀត គេពុំទាន់បានដឹងរឿងរ៉ាវយ៉ាងណាៗ នៅឡើយផង ។

ចំណែកលោកគ្រូសង្ឃរាជ កាលបានរួចពីកណ្ដាប់ដៃភិក្ខុទិលនោះហើយ ក៏ដាក់គូថស្រិចនៅលើកាំជណ្ដើរកុដិ ដង្ហក់យូសខសៗ ប៉ុនគេយោលខ្លួន; បែកញើសប៉ុនៗ គ្រាប់ពោត ហានិយាយថាដូចម្ដេចក៏មិនកើត ។ តមក ១ ស្របក់ ទើបលោកមានថេរដីកាជាច់ៗ ទាំងនៅហត់ហេប ៗ ហើយ ទាំងខ្លាចអាក់អន់ព្រះទ័យ យ៉ាងហួសប្រមាណផងថា "ហ៊ឹះ ! អា... អានេះ វា... វាលេងឯងដល់ថ្នាក់តែម្ដងហើយ, ឆាន់[១] តាំងពីកើតមកដកបដល់ចំណាស់ប៉ុណ្ណេះហើយ មិនដែលដល់ម្ល៉ឹងសោះ ទើបតែល្ងាចនេះ យ័អ៊ុនចុះខ្ញាំង ធ្លាក់ខ្លួនទៅជាអាចំប៉ារបស់គេតែម្ដង — ឆាន់ទើបនឹងចុះផុតកាំជណ្ដើរវិហារបន្តិចមក ស្រាប់តែវាលោតក្លុតគោងកអៀវឯងជាប់តែម្ដង — មានផ្លូវអីទៀត, បើវាលេងរឹតបំពង់កឯងរកកល់លៀនអណ្ដាតទៅហើយ,— ណាមួយវាកៀបត្បៀតក្លៀកឯងទាំងសងខាងយ៉ាងតឹងណែនតាំង រកតែឈានជើងស្ទើរពុំរួច ហើយមានទាំងគ្លៀកយកក្បាលដន្ទង់វាគោះត្រង់កណ្ដៀតទឹកឯងថែមទៀតផង;— វាឲ្យឯងលុនឲ្យលឿន, រួចវាថាឯងស៊ីស្លៅមិនឆ្អែតពីថ្ងៃ បានជាកងបែបគេះគត់អស់

---

១ លោកគ្រូសង្ឃរាជតែងតែពោល ទៅកាន់លោកបរិស័ទថា "ឆាន់" (ពាក្យ [illegible]) [illegible] ។

កំឡាំង ៗ ហ៊ឹះ ! ឆាន់ដឹងថាវាប្រឡំនឹងគូកនវាហើយ; តែប្រឡំនេះវា
ហួសប្រមាណណាស់ វ៉ះៗ តែនឹងជាច់ខ្យល់ឆាប់; ឆាន់មិនដឹងជាអា
ណាមួយ ព្រោះវាពោបអៀវគងងពីក្រោយ រកតែងាកមើលមុខវាមិនកើត
សោះ; ឆាន់ស្មានថា ប្រហែលជាអាម៉ប់ ឬអាមោយហើយមើលទៅ
ព្រោះឮថាអាពីរនាក់នេះវាខិលខូចណាស់ ចូលចិត្តលេងល្បែងអៀវគ្នា
ស្ទើរតែរាល់យប់ ៗ ភិក្ខុសាមណេរទាំងអស់ក៏បានឆ្លើយស្របថា ពិតជា
លោកម៉ប់ ឬលោកមោយប្រាកដហើយព្រះតេជព្រះគុណ ព្រោះអ្នកទាំង
ពីរនាក់នេះ ដូចជាខិលជ្រុលបន្តិចហើយទានប្រោស ! គេតែងតែលេង
ល្បែងអៀវគ្នាជាធម្មតា ៗ លោកគ្រូសង្ឃពជបានបន្ទូលដីកាទៅទៀតថា
ឆាន់គុំថា គង់មានថ្ងៃណាមួយ ចាំពីគវាឲ្យធ្ងន់ដៃតែម្តងពីរឿងល្បែងព្រើល
នេះតែឥឡូវនេះ មិនទាន់ទាំងបានសំពងវាផង- វាលេងឯងមុនទ្រមមាតិកា
ទៅហើយ; ហ៊ុះ ! អានេះអត់ទោសឲ្យវាមិនបានទេ គោងតែរកចាប់វាឲ្យ
បានទាំងយប់នេះ យកមកចងព្យួរនឹងខ្សែរ៉ត សំពងវាឲ្យអស់ដៃពីរបីថ្ងៃ
ហើយផ្សឹកវាចោលឲ្យស្រឡះចេញទើបបាន ៗ គ្រានោះ លោកបរិស័ទ
ខ្លះបានពិត្រទូលថា ខ្ញុំករុណាបានឃើញដែរ តែនឹកស្មានថា គេអៀវគ្នា
គេដូចធម្មតាមុន ៗ បានជាមិនអើពើនឹងយកចិត្តទុកដាក់អ្វីប៉ុន្មាន; រឿង
នេះ ដូចជាទាស់បន្តិចដែរ ទើព្រះតេជព្រះគុណ ស្រែកឲ្យ..ដឹងខ្លួនតាំងពី

ដំបូងមកម្ល៉េះនោះ មិនដល់ទៅប៉ុណ្ណឹងសោះ ។ លោកគ្រូសង្ឃរាជតបក្ដាមថា អីចឹងមែន ស្ដាយណាស់ តែពេលនោះពុំដូចជាយ៉ាងម៉េចមិនដឹង នឹកម្ដងថាទីងស្រែកឲ្យរកដីងខ្លួន នឹកម្ដងទៀតថា កុំអាលមាត់... ណ្ហើយ ឥឡូវនេះ ពុំជ្រួលហួសអស់ទៅហើយ;— ចូរលោកទាំងអស់គ្នាប្រញាប់ប្រញាល់ទៅជួយពិនិត្យរកឲ្យឃើញផាប់ ៗ ។— ចូររកមើលអាទាំងពីរនាក់នោះ តើអាណាតែបាត់ខ្លួន អាណាមួយនៅក្នុងវត្តនៅឡើយ;— បើបាត់អាណា គឺអានោះឯងហើយ ដែលពុំអៀវធាន់ ។— កាលណាបើបានដឹងការត្រឹមប៉ុណ្ណោះហើយ ចាំលៃលកតទៅទៀត ។ ភិក្ខុសាមណេរទីងក្នុងវត្តទាំងអស់ ក៏បាននាំគ្នាម្នីម្នាស្ទុះស្ទាទៅរកមើលឯកន្លែងលោកម៉ប់ទីងលោកមោឃ តែរកមិនឃើញទាំងពីរនាក់ បានពិនិត្យឆែកឆេររកតទៅទៀតគ្រប់កុដិ សាលាទាំងអស់ក្នុងវត្ត ក៏មិនចួបប្រទះសោះ ទើបនាំគ្នាមកពិគ្រទូល លោកគ្រូសង្ឃរាជវិញតាមដំណើរ ។ លោកមានថេរដីកាថា ណ្ហើយ! បើមិនឃើញយប់នេះ ព្រឹកស្អែកគង់តែឃើញពុំខាន, តែគួរឲ្យឆ្ងល់ដែរថា បើអាមនុស្សមានកំហុសតែម្នាក់ទេ ម្ដេចក៏បាត់ខ្លួនទៅទាំងពីរនាក់ ។ លោកគ្រូសង្ឃរាជមានថេរដីកាតែប៉ុណ្ណោះហើយ ក៏និមន្តចូលទៅក្នុងកុដិលោកទៅ, តែក្នុងរាត្រីនោះ លោកសឹងមិនលក់សោះ ព្រោះលោកនឹកសព្វ ៗ ទៅ រីងរឹតតែក្ដៅឡើង ៗ ក្ដៅក្រង់ "អៀវអាចំប៉ា

អៀវ !" ក្តៅណាស់ទៅទៀតត្រង់ដែល "តឹងបំពង់ករកកល់ផុតដង្ហើមម្តង ៗ" នោះឯង ៗ ក្នុងពេលយប់នោះ ភិក្ខុសាមណេរដែលបានទៅកាន់កន្លែងរៀនខ្លួនហើយ ក៏ប្រជុំជំនុំគ្នាស៊ើបលាន់ៗ ថា នេះគឺជាកម្មពៀរវេរាតាមទាន់ ឲ្យផលក្នុងបច្ចុប្បន្នដល់ព្រះតេជព្រះគុណយើង ពីព្រោះលោកវាយគេខ្លាំងណាស់ គ្មានលស់ថ្ងៃណាសោះ ចំណែកម៉ប់នឹងមោយ ដែលល្ហាំងគេចបាត់ខ្លួនទាំងពីរនាក់ ក៏គឺបាបឲ្យផលទាន់ភ្នែកដែរ មកពីរបិុលរប៉ូចខ្ចូចខាងឯលេងល្បែងអៀវគ្នា មិនសូវកោតក្រែងវេអងវេការដល់វិន័យសិក្ខា ជាយូរមកហើយ ៗ

ចំណែកលោកគ្រូសង្ឃរាជព្រឹកឡើងព្រលឹមស្រាងៗ លោកតើនឡើងចេញមកក្រៅ, ស្រាប់តែឃើញញោមប្រុសរបស់ភិក្ខុម៉ប់នឹងភិក្ខុមោយ អង្គុយបត់ជើងត្រង់កនហាលយ៉មុខកុដិ លោកក៏ធ្វើព្រះភក្ត្រក្រញូវហើយឥតរកសួរអ៊ីមួយម៉ាត់សោះ ដោយលោកស្មានថាប្រាកដជាភិក្ខុទាំងពីររូបនោះ បានទៅនិយាយពឹងពាញោមរបស់ខ្លួនពីល្ងាច ឲ្យចូលមកសុំលន់តួទោសពៃរ៍លោកហើយមើលទៅ ៗ ឯបុរសទាំងពីរនាក់ក៏តាំងក្រាបថ្វាយបង្គំផ្គួងៗ ហើយអង្គុយប្រហោងប្រណម្យ ដោយមានទឹកមុខស្លុតក្រៀមនឹងស្ងៀមស្ងាត់ មិនទាន់ហ៊ានផ្តើមពិត្រទូលសាកសួរអ៊ីនៅឡើយ ព្រោះឃើញព្រះភក្ត្រលោកមិនស្រួល ៗ មួយស្របក់

ក្រោយដែលបានបឺតបារីស្លឹកសន្ដែក បង្ហុយផ្សែងទ្រលោម ពីរ-បី សារួច ហើយ ស្រាប់តែលោកគ្រូមានថេរដីកាថា កុំបាច់នាំគ្នាមកអង្វរគេសុំទោសតែអី ម្ល៉េះហើយ គ្មានអត់ឱនឲ្យអាណាទេ, តាមចិត្តក្ដៅ ចង់តែសំពងអាជ្ញ ជំនួសកូនឥឡូវហ្នឹងផង(១) ព្រោះឪពុកខូច បានជាជាប់ពូជមកកូនរពិល ចុះចេញឲ្យឆាប់ៗ កុំមករវែរ ៗ បុរសទាំងពីរនាក់ ភិតភ័យញ័ររន្ធត់ ម្នាក់ក្រោកឈរទៀងសំឡឹងគេមើលប្រករត់ តែម្នាក់ទៀត មិចក្អកជាសញ្ញាឲ្យអង្គុយមកវិញ ហើយក៏ប្រថុយទូលតបទាំងញញីញញ័រថា "សូមព្រះតេជព្រះគុណម្ចាស់មេត្តាអត់ទោស តើកូនរបស់សត្វជាខ្ញុំ(២) មានរឿងរ៉ាវនឹងទោសកំហុសដូចម្ដេចខ្លះ ទានប្រោស?" ៗ លោកគ្រូសង្ឃរាជគំហក "កុំបាច់ធ្វើពើហាក់មិនដឹង ! ក្រែងពីយប់មិញបានជួបគ្នាដឹងរឿងរ៉ាវអស់ហើយតើ" ៗ ឧបាសក : "ករុណាទានប្រោស ! លោកទាំងពីរអង្គ បាននិមន្តទៅផ្ទះពីយប់មិញ បានប្រាប់រឿងរ៉ាវអស់ហើយអ៊ីចឹងមែន ទើបបានសត្វជាខ្ញុំទាំងពីរនាក់នាំគ្នាមកនេះ, តែរឿងដែលបានដឹងពីយប់នោះគឺជាការប្រសើរល្អណាស់ទានប្រោស ; លុះដល់មកជួបព្រះតេជព្រះគុណផ្ទាល់ក្នុងពេលនេះ ក៏ស្រាប់តែប្រែត្រឡប់ទៅ

---

១- លោកគ្រូសង្ឃរាជដាច់ដើម មានអំណាចណាស់ អាចវាយទាំងពីកូនរហូតដល់ឪពុកម្ដាយក៏បាន ។ ២- ឧបាសកយើងពីដើមនិយាយជាមួយព្រះសង្ឃថា "សត្វជាខ្ញុំ" ។ សព្វថ្ងៃនេះ គេប្រើពាក្យថា "ខ្ញុំព្រះករុណា ដែលអាចក្លាយមកទៀតថា "ខ្ញុំកូរណា" ដូច្នេះវិញ ។

ជារឿងពីរមួយផ្សេងដែលនាំឲ្យកើតទុក្ខព្រួយខ្លាំងទៅវិញ" ។ លោកគ្រូសង្ស័យពេកហាក់ដូចជាអន់ខ្វល់បន្តិច ហើយសួរបញ្ជាក់ ដោយបន្ទរសំឡេងថា "រឿងយ៉ាងម៉េចវិញ និយាយមកមើល" ។ ឧបាសកៈ "បាទ ព្រោស! ពីយប់មិញប្រហែលជាម៉ោងជាង១០ ទៅហើយ, លោកកូនម៉ប់ នឹងលោកក្មួយមោឃ បាននិមន្តទៅផ្ទះសត្វជាខ្ញុំទាំងពីរនាក់ហើយប្រាប់ថា ព្រឹកស្អែកនេះ ព្រះតេជព្រះគុណ មានកិច្ចត្រូវនិមន្តទៅភ្នំពេញ សុំឲ្យសត្វជាខ្ញុំទាំងពីរនាក់រៀបចំគោរទេះ ស្រួតត្រូឲ្យដល់មកវត្តនេះពីព្រលឹមស្រាង ៗ ដើម្បីជូនដំណើរព្រះតេជព្រះគុណទៅដល់ថ្នល់ឡាន; ថាព្រះតេជព្រះគុណ យកខ្លួនលោកទាំងពីរអង្គជូនទៅភ្នំពេញជាមួយដែរ លោកទាំងពីរអង្គ បានទាំងសុំបច្ច័យសម្រាប់ធ្វើសោហ៊ុយនឹងទិញអីវ៉ាន់នេះនោះខ្លះផង; សត្វជាខ្ញុំទាំងពីរនាក់ក៏បានប្រគេនបច្ច័យ តាមសមគួរ ហើយបានទាំងនិយាយទៀតផងថា មានសេចក្ដីត្រេកអរណាស់ ដោយបានព្រះតេជព្រះគុណមានមេត្តាអនុគ្រោះរាប់រកជាកូនជាចៅ; និមន្តទៅណាម្ដងៗ យកតាមជាប់ទៅជាមួយផង ។ លោកទាំងពីរអង្គ កាលបានទទួលបច្ច័យហើយ ក៏បំរើនពរលាត្រឡប់មកវត្តវិញតាំងពីយប់មិញម៉្លេះ, ចំណែកសត្វជាខ្ញុំ ពីយប់មុញនេះ មិនហានទទួលទានដំណេកសោះ ព្រោះខ្លាចក្រែងលក់ជ្រុលហួសម៉ោងខកដំណើរព្រះតេជព្រះគុណ នាំគ្នា

ប្រញាប់ប្រញាល់ស្ទូតរូតតាំងពីមាន់រងាវម្តង បានមកដល់ទី នេះតាំងពីនៅងងឹតព្រិលៗ ម្ល៉េះ ទានប្រោស ! ខ្ញុំគោរទេះដាក់ទៅកៀនរបងខាងត្បូងកុដិ បានប្រុងប្រៀបរៀបចំ មានទាំងចង្ហាន់បង្ការតាមផ្លូវទុកជាស្រេច; សូមទានមេត្តាប្រោស ! រឿងរ៉ាវខាងសត្វជាខ្ញុំទាំងពីរនាក់មានតែត្រឹមប៉ុណ្ណេះ សូមទានជ្រាប" ។ ឧបាសកបានបន្តសំដីទៅទៀតថា ចំណែករឿងរ៉ាវខាងព្រះតេជព្រះគុណឯណោះ តើយ៉ាងណាវិញ បានជាវាផ្ទុយគ្នាស្រឡះយ៉ាងនេះ? សូមទានមេត្តាពន្យល់សត្វជាខ្ញុំឲ្យបានដឹងផងទានប្រោស? ។ លោកគ្រូសង្ឃរាជ លោតែញញឹមបន្តិចហើយមានថេរដីកាថា "ហ៊ឹះ ! អីដូច្នោះវិញទេ អាត្មាស្មាននេះខុសស្រឡះតែម្តង ឱយ៉ា ! អាចោរនេះ វាលេងដើរស្នៀតច្រើនគន្ទាក់ណាស់តើ វាលេងឯងឯណោះទ្រមខ្លួនមួយធាករួចហើយ វាទៅកុហកបោកប្រាសញោមឯផ្ទះឯណោះមួយឈុតថែមទៀត ដើម្បីយកសោហ៊ុយធ្វើដំណើររត់ឲ្យបានឆ្ងាយ- ឃើអើ ! រឿងនេះ វិវរធំណាស់តើ ! បើដូច្នោះ ឃើញថាអត់ទុនឲ្យវារួចខ្លួនមិនបានទេ ព្រោះវាមានទោសដល់ទៅពីរជាន់ គោងតែប្រឹងប្រែងតាមរកវាទាំងពីរនាក់ឲ្យឃើញជាដាច់ខាត ។

(នៅមានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## រឿងព្រេងទាក់ទងដោយការស្ថាបនាប្រាសាទអង្គរវត្ត

### លោក ញ៉ែម-ខឹម រៀបរៀង

កាលពី ព.ស. ៦០០ មានចិនម្នាក់ឈ្មោះ លិម-សេង រស់នៅក្នុងខេត្តសៀងហៃ ។ លិម-សេង អាយុចំនួន ៤០ ឆ្នាំ ។ គាត់ជាមនុស្សកំសត់ទុគ៌តណាស់, គាត់បានខ្ចីប្រាក់អ្នកជំនួញម្នាក់ ចំនួន ៤ ណែន ហើយទៅនៅស៊ីឈ្នួលបំរើអ្នកម្ចាស់បំណុលនោះ ។ ម្ចាស់បំណុលបានកម្រៃឲ្យគាត់កាប់ឆ្ការព្រៃមួយកន្លែងនៅក្បែរមាត់ទន្លេ ដើម្បីដាំដំណាំ ។ នៅរដូវដែលបុប្ផជាតិទាំងឡាយត្រូវរីកផ្កា, លិម-សេង តែងបេះផលដំណាំដែលគាត់បានដាំជាពល់ថ្ងៃ យកទៅជូនម្ចាស់គាត់ ។

ថ្ងៃមួយ, មាននាងទេពធីតា ៤ នាក់ស្ថិតនៅឯប្រាសាទព្រះឥន្ទ្របានហោះមកលេងប្រឡែងគ្នាឯស្ថានក្រោម, ហើយបានឃើញផ្កានៅក្នុងសួនច្បារតាលិម-សេង រីកព្រោងព្រាតស្គុះស្គាយ ក៏បបួលគ្នាចូលទៅក្នុងសួននោះ ។ ទេពធីតាម្នាក់ឈ្មោះ ទិព្វសុគាចន្ទ ក៏បានបេះផ្កាលិម-សេង អស់ ៦ ទង ព្រោះផ្កានោះមានក្លិនក្រអូបសាយល្អ ។ ចំណែកទេពធីតាឯទៀត បានដើរលេងពាសពេញក្នុងសួនច្បារនោះដែរ

តែឥតបានកាច់ផ្កាលេងទេ ។

លុះត្រឡប់ទៅដល់ស្ថានទេវតាវិញ, ទេពធីតាសួគត្រង់ក៏បានទូល ព្រះឥន្ទ្រពីរឿងនាងទិព្វសុគាចនួលួចបេះផ្កាគេ ។ ព្រះឥន្ទ្រក៏ទ្រង់ សួរទៅនាងមានទោស ហើយផ្ដន្ទាទោសថា ត្រូវឲ្យចុះមកនៅស្ថាន កណ្ដាលរស់នៅជាមួយមនុស្សលោក ចំនួន ៦ ឆ្នាំ នឹងត្រូវបានទៅជា ប្រពន្ធ តាលិម សេងនោះ ។

នាងទិព្វសុគាចនួ ខ្មាសគេផង អស់សង្ឃឹមក្នុងចិត្តផង, ក៏ហោះ ចុះមកស្ថានក្រោមជួបនឹងតាលិម.សេង ហើយនិយាយប្រាប់គាត់ថា នាងបានលួចបេះផ្កាគាត់អស់ ៦ ទង ឥឡូវ ព្រះឥន្ទ្រដាក់ទោសឲ្យ នាងចុះមកធ្វើជាប្រពន្ធចំនួន៦ ឆ្នាំ ។

- លិម.សេងក៏ឆ្លើយថា "ខ្ញុំក្រណាស់ ខ្ញុំពុំអាចទទួលនាងធ្វើ ជាប្រពន្ធបានទេ ទៅហ្វាយខ្ញុំចិត្តអាក្រក់ណាស់ គាត់ឲ្យបាយខ្ញុំ ទទួលទានល្មមគ្រាន់តែរស់ ។

- យ៉ាងម៉េចក៏ដោយ (នាងទេវីឆ្លើយ) ចាំខ្ញុំជួយលោកតា ។ ខ្ញុំនឹងបង្រៀនវិជ្ជាសិល្បៈលោកតា ដែលគ្មាននរណាមួយចេះ ។ បើ លោកតាមិនព្រមទទួលខ្ញុំធ្វើជាប្រពន្ធ , តើធ្វើម្ដេចខ្ញុំនឹងបានប្រតិបត្តិតាម ការវិនិច្ឆ័យនៃព្រះឥន្ទ្រ ។ សូមលោកតាអាណិតទៅផង ។

គាលិម-សេង ក៏ព្រមទទួលនាងទិព្វសុគាចន្ទ មកនៅជាក្រុមញាតិគាត់ ៗ គាត់ពេញចិត្តនឹងនាងទេវីនេះណាស់ព្រោះជាស្ត្រីមានរូបសម្បត្តិល្អលើសស្រីនានា ៗ មិនយូរប៉ុន្មានគាត់ក៏មានសេចក្តីស្នេហាលើរូបនាង ៗ .

នាងទិព្វសុគាចន្ទ កាលបើបានមករស់នៅជាមួយលោកគាយើងយូរមក, សង្កេតឃើញនូវសេចក្តីលំបាកវេទនានឹងចិត្តស្មោះត្រង់របស់គាត់, ក៏កើតមានចិត្តអាណិតគាយើងជាខ្លាំង ៗ ទើបនាងសួរទៅគាយើងថា:

– គាបានខ្ចីលុយគេអស់ប៉ុន្មាន ?

ប្រាំមួយណែន !

– កាលបើលោកគាខ្ចីគេតែ ៦ ណែនដូច្នេះ លោកគានឹងត្រូវរស់នៅតែម្នាក់ឯងទេ ? ៗ ឥឡូវនេះ, សូមលោកគាទៅខ្ចីគេឲ្យបាន ៤ ណែនថែមទៀត, ទៅនឹងបានមកនៅបំរើគេជាមួយលោកគាផង ៗ លុយដែលយើងនឹងទៅខ្ចីគេថែមទៀតនោះ យើងនឹងយកចាយវាយប្រើការឲ្យបានផលប្រយោជន៍ច្រើន ៗ

លិម-សេង ក៏បានទៅខ្ចីលុយពីម្ចាស់បំណុលខ្លួនបាន ៤ ណែនទៀតយកមកឲ្យនាងទិព្វសុគាចន្ទ ។ នាងទិព្វសុគាចន្ទ ក៏សុំឲ្យលោកគាទៅរកទិញសូត្រឲ្យអស់តំឡៃចំនួន ៤ ណែនប្រាក់ យកមកឲ្យនាង ៗ

គាយើងក៏ទិញបានសូត្រនៅជាសំបុកចំនួន២០នាក់ ៗ នាងទិព្វសុគាចន្ទក៏រៃសូត្រនោះ ហើយត្បាញធ្វើជាសំពត់ផ្សេង ៗ មានសំពត់ប៉ាក់ជារូបស្លឹកឈើ, រូបសត្វ និងជារូបគំនូរផ្សេង ៗ ទៀតច្រើនកប់ពុំអស់ ។ នាងបានត្បាញសំពត់ល្អ ៗ ណាស់ ដែលសម័យនោះគ្មានអ្នកណាធ្វើបានដូចនាងឡើយ ។ កាលបើត្បាញបានសំពត់ច្រើនហើយ នាងក៏ប្រើប្តីនាង ឲ្យយកសំពត់ទាំងនោះទៅជូនចៅហ្វាយខ្លួន ។ អ្នកម្ចាស់បំណុលយកដៃស្ទាបសំពត់មើល មានសេចក្តីស្ងប់ក្នុងចិត្តក្រៃលែង, ព្រោះគ្មានអ្នកណាមួយអាចចេះត្បាញដូចេះបានឡើយ ។ អ្នកម្ចាស់បំណុលពោលសរសើរលោកតា លិម-សេង ជាច្រើន, ហើយដោយអំណាចគាត់កើតសេចក្តីសប្បាយពន់ពេក, គាត់ក៏បានឲ្យលុយ៥០ណែនទៅតា·យើង, ព្រមទាំងឈប់ទាយកវិញ នូវប្រាក់ដែលតាយើងបានជំពាក់គាត់ពីពេលមុនមកទាំងអម្បាលមាណ ។ មិនតែប៉ុណ្ណោះ, អ្នកម្ចាស់បំណុលបាននាំងបញ្ជូនមនុស្សឲ្យទៅរៀនវិជ្ជាត្បាញសូត្រពីនាងទិព្វសុគាចន្ទផង ។ នាងទិព្វសុគាចន្ទក៏បានទិញសំបុកសូត្រ (សំបុកដង្កូវនាង) ជាច្រើនហាបយកមកបង្រៀនសិស្សចៅហ្វាយតា យើងឲ្យរៃ ឲ្យត្បាញរាល់ថ្ងៃ ។

មិនយូរប៉ុន្មាន តា លិម-សេង ក៏បានឡើងទៅជាអ្នកមានម្នាក់មានអំណាច និងមានគេកប់រកជាច្រើន ។

ចំនួនជាមួយឆ្នាំក្រោយមក , នាងទេពសុគាចន្ទ បានបុត្រប្រុសម្នាក់ ។ ទារកនេះពិសេសពន់ពេក នៅពេលដែលវាចេះវារ វាបានដីកដីធ្វើជាកំពែងការពារ, ពេលចេះអង្គុយ វាគូរលេងនៅដីធ្វើជារូបសត្វ, រូបមនុស្ស គឺថាវាចូលចិត្តតែគូរដីលេងឥតចេះខ្ជិល, ឥតឈប់ឈរ ។ វាជាក្មេងពុំចេះនៅស្ងៀមមួយស្របក់បានឡើយ ។ អាស្រ័យហេតុដូច្នេះ ម្តាយក៏ដាក់ឈ្មោះថាព្រះពិស្ណុការ[១] ។

លុះកុមារបានវ័យចំនួន៥ ឆ្នាំ, នាងទេពសុគាចន្ទ ក៏គ្រប់ផុតកំណត់ ៦ ឆ្នាំ, ដែលព្រះឥន្ទ្របានផ្តន្ទាទោសតម្រូវឲ្យនាងមកធ្វើជាប្រពន្ធ តា លិម-សេង ។ ដូច្នេះ, នាងក៏បេះផ្កាចំនួន ៦ ទង យកទៅដាក់នៅលើខ្នើយដេក រួចក៏ហោះទៅកាន់ស្ថានព្រះឥន្ទ្រវិញ ។

លុះដល់ពេលបាយ, តា លិម-សេង ដោយមានសេចក្តីងឿងឆ្ងល់មិនឃើញប្រពន្ធចេញមកញុំាបាយ, ក៏ចូលទៅក្នុងបន្ទប់ឃើញផ្កា៦ ទង ដាក់ចោលលើខ្នើយក៏យល់ន័យនេះមួយរំពេច ។ តា លិម-សេងក៏យំទួញសោករលឹកប្រពន្ធក្មេង ដែលគេរត់ចោលគាត់បាត់ទៅ ។ អ្នកជិតខាងបានដឹង គេជួយអាណិតគាត់គ្រប់ ៗ គ្នា ។ ចំណែកព្រះពិស្ណុការវិញ បានរត់រកម្តាយគ្រប់ច្រកល្ហកទាំងអស់ បង្កូរស្រែក

១ ព្រះវិស្សកម្ម ។

ហៅលាន់ឮរំពង ហើយយំខ្សឹកខ្សួលសោកបោកខ្លួនជាមួយឪពុក ។

គ្រានោះ នៅក្នុងព្រះរាជអាណាចក្រកម្ពុជា ព្រះបាទប្រទេសរាជទ្រង់សោយព្រះទិវង្គតទៅ ព្រះអង្គឥតមានព្រះរាជបុត្រាបុត្រី១អង្គ ដើម្បីសោយរាជ្យស្នងព្រះអង្គទេ ។ ព្រះញាតិវង្សព្រះបាទថោងក៏ផុតរលត់ត្រឹមនេះ ។ គេសង្កេតមាននៅសល់តែក្រុងហ្លួង និងក្រាយហ្លួង ពីរនាក់ប៉ុណ្ណោះទេ ដែលជាអ្នកជាប់លោហិតក្សត្រ ។ កាលបើដូច្នេះ, ព្រះរាជបល្ល័ង្កក៏ត្រូវស្ងាត់នៅទំនេរ ។

ជំណាលពីបុរសកំសត់ម្នាក់ដែលប្រកបរបរចិញ្ចឹមជីវិតដោយកាប់ឧសលក់នៅក្នុងព្រៃ ។ ថ្ងៃមួយ, នៅពេលដែលបុរសនោះកំពុងប្រកបកិច្ចការខ្លួនតាមធម្មតា ស្រាប់តែមានភ្លៀងធ្លាក់យ៉ាងខ្លាំង បុរសបានរត់ទៅជ្រកនៅក្នុងខ្ទមអ្នកតាមួយ ។ និយាយពីព្រះឥន្ទ្រាធិរាជ ដែលជាស្ដេចនៃទេវតា នៅពេលនោះព្រះអង្គបាននិម្មិតខ្លួនធ្វើជាមាន់គកពីរ មួយពណ៌សមួយពណ៌ខ្មៅ ។ មាន់ខ្មៅមកទំលើសសរកន្ទោងនៃខ្ទម មាន់សមកទំលើដំបូលខ្ទម ។ មួយសន្ទុះមក មាន់សរងាវ ។ ឯមាន់ខ្មៅដែលចេះនិយាយភាសាមនុស្សក៏និយាយថា: "នរណាហ៊ានមករងាវលើក្បាលអញដូច្នេះ? តើអ្នកឯងមានឫទ្ធិអំណាចយ៉ាងណាទៅ ?

-យើងមានឫទ្ធិអំណាចខ្លាំងណាស់ (មាន់សឆ្លើយ) ។ បើសិនជា

នរណាមួយបានស៊ីសាច់ខ្ញុំ អ្នកនោះនឹងបានឡើងជាស្តេចផែនដី ។

មាន់ខ្មៅក៏ឆ្លើយថា:

"បើសិនជាមនុស្សប្រុសណាមួយស៊ីក្បាលខ្ញុំ អ្នកនោះឯងនឹងបាន ជាស្តេចសង្ឃ ។ បើសិនជាមនុស្សស្រីណាស៊ីសាច់ភ្លៅខ្ញុំ ស្រីនោះនឹង បានជាអគ្គមហេសីស្តេច ។ បើសិនជាជនប្រុសណាស៊ីសាច់ទ្រូងខ្ញុំ ជន នោះនឹងបានសោយរាជ្យ ។ ដូច្នេះ, កុំមើលងាយខ្ញុំឲ្យសោះ!"

តមក, មាន់សក៏ហើរបាត់ទៅ ឯមាន់ខ្មៅនៅទំនឹងសសរកន្ទោង ដដែល: បុរសកំសត់ក៏លប ៗ ចូលទៅចាប់មាន់ខ្មៅបាន ហើយសម្លាប់ ភ្លាមយួរយកទៅផ្ទះខ្លួន ។ បុរសក៏និយាយការសម្ងាត់នេះប្រាប់ប្រពន្ធ។ មានសេចក្តីរីករាយក្រៃលែង យកមាន់នោះទៅចំអិនធ្វើម្ហូប រួចដួសដាក់ ចាន ដាក់ថាសលើកយកមកបម្រុងនឹងអាស្រ័យ ។ ប៉ុន្តែនៅពេលនោះ បុរសប្តីក៏និយាយទៅកាន់ប្រពន្ធថា:

"យើងជិតបានមកុដពាក់ហើយ ដូច្នេះ ត្រូវយើងយកម្ហូបវិសេស នេះទៅឯមាត់ស្ទឹង យើងមុជទឹកដុសខ្លួនឲ្យស្អាត យកសំលៀកបំពាក់ ថ្មី ៗ មកស្លៀកពាក់ហ៊ុំហា រួចសឹមយើងចាប់ញ៉ាំម្ហូបមាន់នេះ ។

បុរសប្តីប្រពន្ធក៏ជញ្ជូនម្ហូបអាហារទៅដាក់មាត់ទឹក រួចមុជទឹកក្នុង ស្ទឹងលេងយ៉ាងសប្បាយ លុះងើបពីទឹកឡើងបុរសប្តីប្រពន្ធកេមើលថាស

ដាក់ម្ហូបពុំឃើញ ៗ ទឹករលកបានគួចយកថាសនោះរសាត់ទៅតាមខ្សែទឹកបាត់ទៅ ៗ

នៅថ្ងៃនោះ. មានទ្រមាក់ដំរីម្នាក់ឈ្មោះតា គាត់បាននាំដំរីគាត់ជាច្រើនទៅចុះត្រាំទឹកស្ទឹងនោះ បានឃើញថាសនោះអណ្តែតមករកគាត់ ៗ លើកយកថាសនោះទៅបង្ហាញព្រះសង្ឃជាមេកុដិមួយអង្គ ៗ លោកសង្ឃបានស្គាល់ច្បាស់នូវគុណភាពនៃសាច់នោះ ក៏ចាប់យកក្បាលមាន់ឆាន់ទៅរួចលោកប្រទានសាច់ទ្រូងទៅឈ្មោះ តា សាច់ភ្លៅទៅនាង វង់ ប្រពន្ធឈ្មោះ តា ប៉ុន្តែ លោកឥតមានពុទ្ធដីកាថាដូចម្តេចឡើយ ៗ តា និងនាងវង់ ក៏បបួលគ្នាត្រឡប់ទៅផ្ទះវិញទៅ ៗ

និយាយពីបុរសប្តីប្រពន្ធ គាត់បានដើររកថាសម្ហូបនោះគ្រប់កន្លែងអស់ ប៉ុន្តែពុំឃើញ គិតថាប្រាកដជានរណាមកលួចយករបស់គាត់ហើយក៏ប្រទេចផ្តាសាជនពុំស្គាល់មុខនោះជាច្រើនរាប់ពុំអស់ ៗ

បន្ទាប់ពីនោះមកបីថ្ងៃ, នៅក្នុងនគរក៏មានការប្រជុំគណៈរដ្ឋមន្ត្រី ៗ នៅក្នុងសម័យប្រជុំនោះ រដ្ឋមន្ត្រីទាំងឡាយក៏ប្តូរយោបល់គ្នាថា: "ព្រះរាជាណាចក្រយើង ពុំទាន់មានព្រះមហាក្សត្រគ្រងរាជ្យនៅឡើយ ៗ ដូច្នេះ, ត្រូវបញ្ចេញដំរីមកចងកូប ហើយបួងសួងដល់ទេវតា សូមឲ្យដំរីទាំងឡាយចេញទៅលុតជង្គង់ដោយខ្លួនឯង នៅមុខជនណាមួយដែល

អាចអង្គុយលើរាជបល្ល័ង្កបាន ហើយសូមឲ្យដំរីលើកបុរសនោះដាក់លើក្បាល នាំមកទីនេះ ដើម្បីយើងនឹងរៀបធ្វើបុណ្យអភិសេក ឲ្យបុរសនោះឡើងសោយរាជ្យក្នុងព្រះនគរ ។

គេក៏យកដំរីមករៀបចំចងកូប នឹងគ្រឿងលំអឯទៀតជាច្រើនស្កេកស្កះ ហើយលែងឲ្យវាដើរទៅតាមចិត្តវា ។ ដំរីក៏ដើរសំដៅទៅរកតា នឹងនាងវង់, ហើយលុតជង្គង់នៅមុខជនទាំងពីរ រួចលើកជនទាំងពីរនោះដាក់លើក្បាល បញ្ជូនមកកាន់ព្រះបរមរាជវាំង ។ គណៈនោះរដ្ឋមន្ត្រីក៏រៀបចំធ្វើបុណ្យរាជាភិសេកភ្លាមតាមប្រពៃណី ។ បុរសតាក៏បានទទួលព្រះបរមនាមថាជា ទេវង់អស្ចារ្យ ។

ក្រុង-ហ៊ូវ នឹងក្រោយ ហ៊ូវ មានសេចក្តីអាក់អន់ព្រះទ័យមិនព្រមចំណុះចូលនឹងមហាក្សត្រអង្គថ្មី ក៏រត់ទៅឯស្រុកបាកាន ខេត្តពោធិ៍សាត់ ហើយទ្រង់បានសង់ប្រាសាទមួយនៅទីនោះ ។

ដំណាលពីព្រះឥន្ទ្រាធិរាជ ទ្រង់សង្កេតឃើញព្រះអគ្គមហេសីនៃមហាក្សត្រអង្គថ្មី ពុំទាន់មានព្រះរាជបុត្រានៅឡើយ, ក៏ទ្រង់ព្រះចិន្តាថា:

"យើងនឹងផ្តល់ព្រះរាជបុត្រមួយអង្គដល់ព្រះនាងវង់ ។ ព្រះរាជបុត្រនេះមានសញ្ជាតិជាព្រះឥន្ទ្រសុទ្ធ ដើម្បីឲ្យជាប់ជាព្រះញាតិវង្សសោយរាជ្យក្នុងប្រទេសខ្មែរជានិរន្តរ៍តទៅ ។

ថ្ងៃមួយ, នៅពេលដែលព្រះមហាក្សត្រិយានីវង្ស ទ្រង់យាងចេញពីមហាប្រាសាទ, ព្រះឥន្ទ្រទ្រង់ហោះចេញមកនៅលើអាកាស ។ មនុស្សលោកមើលព្រះអង្គពុំឃើញទេ; ប៉ុន្តែ គេគ្រាន់តែឃើញពន្លឺមួយយ៉ាងធំទៀវសន្ធឹងកាត់អាកាស ។ អ្នកស្រុកស្រែកឆោឡោឡើងថា "ពន្លឺធ្លាក់! ពន្លឺធ្លាក់! ព្រះឥន្ទ្រក៏ទម្លាក់កម្រងផ្កាមកលើព្រះកាយព្រះនាងវង្ស, ហើយទ្រង់ហោះត្រឡប់ទៅនគរព្រះអង្គវិញបាត់ទៅ ។

ព្រះនាងអគ្គមហេសីវង្ស ទ្រង់មានព្រះគភ៌ពីត្រឹមពេលនោះមក ហើយទ្រង់ប្រសូតព្រះរាជបុត្រាមួយព្រះអង្គ ព្រះនាម "ព្រះកេតុមាលា" មានន័យថា ពន្លឺផ្កា ។

សូមដំណាលពីព្រះពិស្ណុការវិញ, អ្នកចំរើនរកម្តាយគ្រប់ច្រកល្ហកអស់ហើយ, ប៉ុន្តែឥតបានដឹងថាម្តាយទៅឯណា ។ កុមារក៏កើតទុក្ខរកទីបំផុតគ្មាន ទើបថ្ងៃមួយសួរឪពុកថា:

"តើនរណាមួយជាម្តាយខ្ញុំ?

–ម្តាយកូនឯងជាទេពធីតា គាត់ត្រូវមករស់នៅក្នុងស្ថានមនុស្សយើងនេះតែត្រឹម ៦ ឆ្នាំទេ, ឥឡូវគាត់ត្រឡប់ទៅស្ថានទេវតាវិញហើយ ។ ស្ថាននោះនៅឆ្ងាយណាស់, ឪពុកពុំដឹងជាម្តាយឯងនៅត្រង់ណាទេ!" ។

កុមារនៅស្ងៀម; ប៉ុន្តែចេះតែនឹកទៅរកម្តាយឥតមានភ្លេច ក៏សម្រេច

ចិត្តថានឹងចេញទៅរកម្តាយឲ្យទាល់តែឃើញ ទោះជួបគ្រាំងយ៉ាយយាក់យ៉ាងណា, ក៏កុមារពុំយល់ស្របតាមជាដាច់ខាត ។ ព្រះពិស្ណុការកុមារបានធ្វើដំណើរចេញទៅ, ដើរកាត់ព្រៃចូលកាល, លេចកាលចូលព្រៃ, ពេលឃ្លានបេះផ្លែរុក្ខជាតិនានាធ្វើជាអាហារ, សំលៀកបំពាក់រហែករយ៉ុយ៉ែអស់ ។ ប៉ុន្តែដោយហេតុតែកុមារមានកុសលល្អ, ថ្ងៃមួយ ពួកទេពធីតាបានចុះមកលេងនៅលើភ្នំមួយ ហើយបណ្តាទេពធីតាទាំងនោះ, ព្រះនាងទិពសុតាចន្ទ ក៏បានមកលេងនៅទីនោះនឹងគេដែរ ។ នាងកំពុងដើរកាច់ផ្កាតាមដងព្រៃចង់ជាប់ ។ ព្រះពិស្ណុការបានឃើញស្ត្រីយ៉ាងល្អៗដូច្នោះក៏នឹកថា:

"អស់ពេលជាច្រើនឆ្នាំណាស់មកហើយ ដែលអញដើរចេញពីទីភូមិដែលមានមនុស្សលោកនៅ, អស់ពេលជាច្រើនឆ្នាំណាស់មកហើយដែលអញឥតដែលបានជួបមនុស្សលោកណាម្នាក់សោះ សំលៀកបំពាក់អញក៏រហែកដាច់ដាច, ហើយអញពុំអាចរកអ្វីមកផ្លាស់បានទេក្រៅពីយកស្លឹកឈើមកចងបិទបាំងខ្លួន ដូច្នេះ, មនុស្សស្រីទាំងឡាយដ៏ល្អៗក្រៃលែងនេះ មកពីទីស្ថានណា? មិនមែនជាពួកទេពធីតាទេឬ?» ។

(នៅមានត)

# ផ្នែកកំណត់និងប្រវត្តិការណ៍

## ពិធីអនុសំវច្ឆរៈមហាសន្និបាត
## នៃមន្ត្រីសង្ឃលើកទី ១៧

ពិធីអនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី១៧ បានចាប់ផ្ដើមឡើងនៅថ្ងៃទី ១មករា ឆ្នាំ ១៩៦១ ក្រោមអធិបតីភាពនៃសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ គឺនៅវត្តឧណ្ណាលោម និងវត្តបទុមវតីរាជវរារាម ។

ពីម៉ោង ១៨ ទៅម៉ោង ១៩ នៃថ្ងៃនោះ ជាពេលបើកឱកាសធ្វើមហាសន្និបាតនៃមន្ត្រីសង្ឃនេះ លោក សរ-គឹមកួយ អនុរដ្ឋលេខាធិការក្រសួងធម្មការ ដោយមានសហការីរបស់លោក ជូនដំណើរអមផង បានអញ្ជើញទៅកាន់វត្តឧណ្ណាលោម និងវត្តបទុមវតីរាជវរារាម ដើម្បីបើកសម័យធ្វើមហាសន្និបាត ។

នៅព្រឹកថ្ងៃ ទី ២ មករា, វេលាម៉ោង៧ និង ៣០នាទី មានការនិមន្តព្រះសង្ឃទាំង ២ គណៈ ចំនួន ៣០ អង្គ ស្វាធ្យាយព្រះសត្តប្បករណាភិធម្ម ឧទ្ទិសព្រះរាជកុសលថ្វាយចំពោះព្រះបិតរ នៅព្រះចេតិយទាំងគូខាងមុខព្រះវិហារព្រះកែវមរកត ។ លុះដល់ម៉ោង ១០ និង ៣០ នាទី, ព្រះសង្ឃទាំង ២ គណៈ [illegible] គឺនៅវត្តឧណ្ណាលោម និងនៅវត្តបទុមវតី ចំពោះមុខរដ្ឋមន្ត្រីក្រសួងធម្មការ ។

ក្នុងថ្ងៃទី ២ មករាដដែល វេលាម៉ោង ១៦ និង ៣០ នាទី ក្រសួងធម្មការ បានបើកធ្វើពិធីអនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៧ នៅក្នុងថែវនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ។

ពេលបើកពិធីនេះ គេសង្កេតឃើញព្រះរាជាគណៈឋានានុក្រម មេគណ, អនុគណ, ចៅអធិការ និងភិក្ខុ-សាមណេរទាំងឡាយ ទាំងពីរគណៈ ដែលគង់នៅវត្តនានាក្នុងព្រះរាជធានី និងមកពីខេត្តក្រៅជាច្រើនរយអង្គ បាននិមន្តមកកាន់មហាសន្និបាត មីរដេរដាសពាសពេញបរិវេណនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ប្រកបដោយរបៀបរៀបរយ សមរម្យទៅតាមសមណសារូប ដើម្បីចង់ឃើញព្រះភក្ត្រសម្ដេចព្រះប្រមុខរដ្ឋ ដែលព្រះអង្គទើបតែនឹងទ្រង់ព្រះនិវត្តន៍អំពីបរទេស មកកាន់មាតុប្រទេសវិញ; ជាពិសេស គឺសំដែងនូវសេចក្ដីនឹករលឹកចំពោះព្រះអង្គ ។ មានឥស្សរសមណៈ និងឥស្សរជនជាច្រើនបាននិមន្ត បានអញ្ជើញមកក្នុងពិធីនេះ ។

ផ្នែកឥស្សរសមណៈខាងបព្វជិតគឺ: សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, សម្ដេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ដែលមានព្រះពោធិវង្ស ហួត-តាត, ព្រះវន្នរតន៍ អ៊ុំ-ខ្លូត, ព្រះធម្មលិខិត ម៉ុង-សេស, ព្រះមង្គលទេពាចារ្យ ព្រះពុទ្ធាចារ្យ ,

ព្រះមហាព្រហ្មមុនី ទេព-អ៊ូ, ព្រះធម្មឧត្តម, ព្រះអរិយកស្សប និងព្រះរាជា. គណៈ ឋានានុក្រមជាច្រើនអង្គទៀត និមន្តអមផងបាននិមន្តមកជាប្រធានក្នុងឱកាសនោះ ។

ផ្នែកឥស្សរជនខាងគ្រហស្ថ គេសង្កេតឃើញលោក ជួប-ហែល ប្រធានរដ្ឋសភា ព្រមទាំងសមាជិកសភាទាំងពីរ, ឯកឧត្តម ជូ-ព្រឿង នាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងធម្មការ, ឯកឧត្តម ទេព-ផន ឧបនាយករដ្ឋមន្ត្រី, ឧត្តមសេនី លន់-ណុល, សហជីវិន គូ-រុន, សហជីវិន ជាជិនកុក ជាទេសរដ្ឋមន្ត្រី, ព្រមទាំងសមាជិករាជរដ្ឋាភិបាលជាច្រើនទៀត, ដែលយើងសូមអភ័យទោស ដោយពុំបានកប់នាមឲ្យសព្វគ្រប់, លោកឧកញ៉ាមហាមន្ត្រី ឆេង-ហាក់ នាយកក្រុមព្រះរាជមន្ទីរ, លោកភួង-សន នាយកការិយាល័យ លោក លឹម-ឆ្នូនសេង នាយខុទ្ទកាល័យ ក្រសួងធម្មការ ព្រមទាំងបុគ្គលិកក្រសួងនេះ និងពុទ្ធបរិស័ទជាច្រើនទៀត បានយាង បានអញ្ជើញទៅរួបរួមក្នុងពិធីនោះផង ។

នៅវេលាម៉ោង ១៧ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ជាព្រះមាតាជាតិ, សម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាឯករាជ្យជាតិ, សម្តេចក្រុមព្រះ ស៊ីសុវត្ថិ-មុនីរេត ប្រធានឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ដោយមានឯកឧត្តម សាន-យុន អគ្គនាយកក្រសួងនានាក្នុងព្រះបរមរាជវាំង,

ឯកឧត្តម ពីទូដីម៉ុងតេរ៉ូ សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក, លោកអ៊ឹង-ហ៊ុង-សាធ លេខាធិការផ្ទាល់នៃសម្តេចព្រះឧបយុវរាជ លោកយឹម-ក្រយ៉ង់ នាយខុទ្ទកាល័យមន្ទីរព្រះរាជាយុត្តកៈ, អ្នកអង្គម្ចាស់ស៊ីសុវត្ថិពង្សមុនី លេខាធិការផ្ទាល់នៃសម្តេចព្រះមហាក្សត្រិយានី, លោកវរសេនីទោ មាស-ហ៊ីល, លោកវរសេនីត្រី សរ-ហោ, លោកអនុសេនីឯក ផេង-គង់, លោក ប៊ូ-ហ៊ីល ព្រះរាជអង្គរក្ស, លោកឧកញ៉ាពិភ័ក្តិរាជាម៉ៅ-ចយ ព្រមទាំងព្រះរាជបរិពារជាច្រើនទៀត ហែអមព្រះអង្គផង បានស្តេចយាងទៅកាន់កន្លែងប្រារព្ធពិធី ។ នៅពេលនោះ ក្រុមទាហានរក្សាព្រះអង្គនិងក្រុមភ្លេងព្រះរាជទ្រព្យបានធ្វើគារវកិច្ច និងបន្លឺបទចរយាត្រាថ្វាយជាព្រះរាជកិត្តិយស ។

ក្រោយដែលសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ទ្រង់ទទួលបដិសណ្ឋារកិច្ច អំពីឥស្សរជន និងយាងថ្វាយបង្គំព្រះសង្ឃរួចហើយ ក្រុមតន្ត្រីព្រះរាជទ្រព្យក៏បានបន្លឺបទនគររាជថ្វាយ ជាព្រះរាជកិត្តិយស ។

ឥស្សរជនទាំងឡាយ ដែលនៅរង់ចាំក្រាបថ្វាយបង្គំទទួល និងសំដែងសេចក្តីស្វាមីភក្តិចំពោះព្រះអង្គ ក៏បានដង្ហែព្រះរាជដំណើរចូលគង់ប្រថាប់នៅលើព្រះសុវណ្ណកោដ្ឋៈ នាយ៉ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

លំដាប់នោះ ឯកឧត្តម ផូ-ព្រឿង ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងធម្មការ ក៏បានឡើងថ្លែងសុន្ទរកថាមួយ មានសេចក្តីដូចតទៅនេះ ៖

សូមព្រះតេជះដ៏កល់លើត្បូង

សូមព្រះរាជទាន ក្រាបបង្គំទូលសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត

សូមព្រះរាជទាន ក្រាបបង្គំទូលសម្តេចសហជីវិន ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ក្នុងនាមនៃក្រសួងធម្មការ និងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានថ្វាយនូវអំណរព្រះករុណាធិគុណ ព្រមទាំងកតញ្ញូធម៌ដ៏ជ្រាលជ្រៅ ចំពោះសម្តេចទាំងពីរព្រះអង្គ ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកជាព្រះរាជាធិបតានីភាព និងជាព្រះរាជាធិបតីភាព ក្នុងព្រះពិធីអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទី ១៧ សម្រាប់ឆ្នាំជូតទោស័កនេះ ដោយសោមនស្សប្រេតនាដ៏ក្រៃលែង ។

សូមទ្រង់ព្រះមេត្តាប្រោស !

លំដាប់តទៅនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះវរោកាសល្អងធូលីព្រះបាទ ប្រាស្រ័យជាមួយសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ និងព្រះថេរានុត្ថេរៈទាំងអស់ ដែលបាននិមន្តមកជួបជុំ ក្នុងមហាសន្និបាតនេះ ដើម្បីនឹងបានប្រគេនពត៌មានខ្លះអំពីកិច្ចការខាងព្រះពុទ្ធសាសនា និងខាងអាណាចក្រ ។

សូមថ្វាយបង្គំសម្ដេចទាំងពីរព្រះអង្គ ព្រមទាំងព្រះថេរានុត្ថេរៈទាំងអស់ដោយគោរព ។

ខ្ញុំព្រះករុណា សូមថ្លែងនូវសោមនស្សរីករាយយ៉ាងក្រៃលែង ចំពោះសម្ដេចនឹងព្រះករុណាគ្រប់ព្រះអង្គ ដែលបាននិមន្តមកកាន់ទីប្រជុំនេះ ព្រោះការជួបជុំជាឱកាសមួយដ៏ប្រសើរ អាចនាំមកនូវសេចក្ដីរុងរឿងនឹងសេចក្ដីចំរើន ជូនជាតិ-សាសនា នឹងព្រះមហាក្សត្រ ។

សម្ដេច!

ព្រះករុណាគ្រប់ព្រះអង្គ!

ដូចសម្ដេចនឹងព្រះករុណាគ្រប់ព្រះអង្គ បានជ្រាបច្បាស់ហើយថា ប្រទេសកម្ពុជា ដែលមានព្រះពុទ្ធសាសនាប្រតិស្ឋាននេះ ទុកជាភ័ព្វមួយដ៏ប្រសើរក្រៃលែង ព្រោះព្រះពុទ្ធជាព្រះបរមគ្រូ ព្រះអង្គបានដកព្រះទ័យចេញផុតពីកាមារម្មណ៍គ្រប់យ៉ាង ហើយព្រះអង្គពេញព្រះទ័យចំពោះសន្តិភាពយ៉ាងក្រៃលែង អាស្រ័យហេតុដូច្នេះហើយ ទើបព្រះអង្គទ្រង់ប្រដៅពុទ្ធបរិស័ទឲ្យលះបង់អាឃាត ព្យាបាទជីវិតគ្នាទៅវិញទៅមក រហូតដល់បាណកសត្វ គឺសត្វល្អិតតូចតាច ក៏ទ្រង់ហាមមិនឲ្យសម្លាប់ដែរ ។

ខ្ញុំព្រះករុណាមានសេចក្ដីសង្ឃឹមយ៉ាងមាំលើព្រះសង្ឃ ដែលជាសិស្សផ្ទាល់នៃព្រះពុទ្ធជាងគ្រហស្ថៈ នឹងប្រកាន់សេចក្ដីប្រតិបត្តិខាង

សន្តិភាព តាមគម្រោយនៃព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាយផ្លូវទុកឲ្យដើរ ពួក-ពុទ្ធសាសនិកជនទាំងអស់ក្នុងសាកលលោក ទោះបីជាតិខ្មែរក្ដី ជាតិបរទេសក្ដី ដែលមានសទ្ធាជឿជាក់ចំពោះព្រះពុទ្ធសាសនាមែនៗ បានបង្កើតសមាគមពុទ្ធសាសនាច្រើនប្រទេស ដើម្បីធ្វើការទាក់ទងគ្នាប្រាថ្នាចំពោះតែសន្តិភាពម្យ៉ាង ។

លទ្ធផលដ៏ប្រសើរនេះហើយ ដែលមានកិត្តិស័ព្ទ ផ្សាយទូទៅពេញសាកលលោកថា ព្រះពុទ្ធសាសនាប្រដៅមនុស្សឲ្យដើរឆ្ពោះទៅរកសេចក្ដីស្ងប់ គឺសន្តិភាព ។

សម្ដេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋនិងជាព្រះអគ្គមគ្គុទ្ទេសក៍ ប្រ-ទេសកម្ពុជាសព្វថ្ងៃនេះ ព្រះអង្គទ្រង់មានព្រះរាជហឫទ័យស្នេហាសន្តិភាពជាទីបំផុត រហូតដល់សាកលលោកទាំងមូល បានទទួលស្គាល់ច្បាស់ថាព្រះអង្គជាព្រះវីរបុរសមួយរូប ស្នេហាសន្តិភាពដោយពិត ដូចជានៅប្រទេសម៉ុងហ្គោលីក្នុងពេលថ្មីៗនេះ ក្រុមជំនុំសង្ឃ ដែលមានព្រះសង្ឃនា-យកគេជាប្រធាន បានជំនុំថ្វាយព្រះបរមនាមដល់ព្រះអង្គថា ព្រះមហា-បដិបបុរស មួយរូប សម្រាប់បង្ហាញសាកលលោកឲ្យឃើញច្បាស់ នូវលទ្ធផលនៃសន្តិភាព ។

ព្រះតេជព្រះគុណ ក៏បានជ្រាបច្បាស់អំពីព្រះកិត្តិនាមរបស់ព្រះអង្គ

សព្វគ្រប់ហើយ; ខ្ញុំព្រះករុណាពុំអាចទូលពុទ្ធដីកាឲ្យវែងឆ្ងាយទេ ដ្បិតសន្តិភាពនេះជាកំពូលនយោបាយគ្រប់ប្រទេសទាំងអស់ មានអានុភាពទ្រទ្រង់ជីវភាពប្រជាពលរដ្ឋផង ទ្រទ្រង់ឯករាជ្យជាតិផង ឲ្យមានដំហររឹងប៉ឹងយ៉ាងជាក់ស្តែង; ព្រោះថា អ្នកស្រុកប្រកបអាជីវកម្មបានដោយស្រួលអាស្រ័យមកពីស្រុកសាន្តត្រាណ កាលៈបើអ្នកស្រុកប្រកបការងារបានពេញលេញហើយ ជាគុណធម៌អាចទ្រទ្រង់នូវឯករាជ្យជាតិឲ្យមានលក្ខណៈពេញបរិបូណ៌; កាលបើឯករាជ្យពេញបរិបូណ៌ហើយ ព្រះពុទ្ធសាសនាក៏រុងរឿងដែរ ។ អាស្រ័យហេតុនេះហើយ បានជាសម្តេចព្រះប្រមុខរដ្ឋយើង ព្រះអង្គខំបំពេញព្រះវិរិយភាពស្ទើរគ្រប់ប្រទេស ឲ្យគេទទួលស្គាល់សន្តិភាព តាមព្រះយោបល់ព្រះអង្គ ដើម្បីសេចក្តីសុខ-ចំរើននៃសាកល-លោក ព្រមទាំងធ្វើឲ្យសាកលលោក ស្គាល់នូវគុណានុភាពនៃប្រទេសខ្មែរកាន់តែជាក់ស្តែងឡើងថែមទៀត ។

ខ្ញុំព្រះករុណា ក្នុងឋានៈជាពលរដ្ឋខ្មែរមួយរូប ដែលមានបំណងចង់ឲ្យជាតិ -សាសនា- នឹងព្រះមហាក្សត្រ ពោលគឺប្រជាជាតិ បានស្គាល់នូវវឌ្ឍនភាពគ្រប់គ្រាន់ ឲ្យបានទទួលនូវសេចក្តីចំរើនរុងរឿង សមនឹងឋានៈជាប្រទេសឯករាជ្យអព្យាក្រិតភាព ។ សូមព្រះតេជព្រះគុណគ្រប់ព្រះអង្គ មេត្តាជួយណែនាំព្រះសង្ឃគ្រប់វត្ត ឲ្យមានព្រះទ័យស្ងប់ស្ងាត់

តាមព្រះមាគ៌ានយោបាយនៃសម្ដេចព្រះប្រមុខរដ្ឋយើង ។ ទូលព្រះបង្គំជាខ្ញុំ.ខ្ញុំព្រះករុណា បានសង្កេតឃើញព្រះថេរានុត្ថេរៈទាំងឡាយ ក្នុងប្រទេសក្ដី ក្រៅប្រទេសក្ដី ដែលបានចេញទៅបន្តវិជ្ជានៅបរទេសទាំងប៉ុន្មាន សឹងបានជ្រាបច្បាស់នូវគោលការណ៍ទាំងឡាយ ដែលខ្ញុំព្រះករុណាបានទូលមកដោយត្រួសៗនេះជាប្រាកដថា ព្រះរាជនយោបាយដ៏ផ្ដើមរបស់ព្រះប្រមុខរដ្ឋយើង មានអព្យាក្រិតភាពជាមាគ៌ានយោបាយរបស់ប្រទេស ព្រោះអព្យាក្រិតនេះជួយទ្រទ្រង់សន្តិភាពឲ្យបានគង់វង្ស ។ ដោយហេតុនេះហើយ បានជាពុទ្ធចក្រនឹងអាណាចក្រក្នុងប្រទេសយើង ត្រូវតែមានការប្រាស្រ័យទាក់ទងគ្នាជាដរាប ទើបអាចនឹងបំពេញមុខការ ព្រមទាំងប្រយោជន៍ផ្សេងៗ ដល់គ្នានឹងគ្នាទៅវិញទៅមកបាន ។

ជាទីបំផុត ទូលព្រះបង្គំជាខ្ញុំក្រោមល្អងធូលីព្រះបាទ សូមប្រសិទ្ធិពរបួងសួងចំពោះគុណព្រះរតនត្រ័យ ព្រមទាំងទេវតាទាំងមួយម៉ឺនលោក.ធាតុ ជួយទ្រទ្រង់ព្រះពុទ្ធសាសនា នឹងសម្ដេចទាំងពីរព្រះអង្គ សូមព្រះអង្គបានប្រកបដោយបរមសុខ ព្រះជន្មាយុយឺនយូរ ដើម្បីជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋគ្រប់ប្រភេទតទៅ ។

សូមព្រះពុទ្ធសាសនា រុងរឿងចំរើនឡើងជាលំដាប់, សូមសម្ដេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ នឹងព្រះថេរានុត្ថេរៈទាំងអស់ ព្រមទាំង

អស់លោកមន្ត្រីគ្រប់តំណែង នឹងប្រជាពលរដ្ឋទូទៅបានប្រកបដោយសេចក្តីសុខតាំងនៅក្នុងសាមគ្គីភាព ពួតដៃគ្នាកសាងប្រទេសជាតិ ឲ្យបានជាអាទ្យប្រទេសមួយក្នុងសាកលលោក ដៃផ្ទៃតាមព្រះមាគ៌ានយោបាយសម្តេចព្រះប្រមុខរដ្ឋតទៅ ។

× ×

×

លុះចប់សុន្ទរកថានៃឯកឧត្តម ថូ-គ្រឿង នាយករដ្ឋមន្ត្រី នឹងជារដ្ឋ-មន្ត្រីក្រសួងធម្មការហើយ, ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត អគ្គាធិការពុទ្ធិកសិក្សា ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ជាតំណាងនៃមន្ត្រីសង្ឃទាំងអស់ បានថ្លែងនូវសុន្ទរកថាមួយ ដូចតទៅនេះ៖

សូមថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត

សូមថ្វាយព្រះពរ សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

ក្នុងនាមនៃមន្ត្រីសង្ឃគ្រប់ឋានៈក្នុងខេត្តក្រៅនឹងក្នុងរាជធានី ដែលឋិតនៅក្រោមឱវាទនៃសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ហើយដែលបាននិមន្តមកជួបជុំក្នុងមហាសន្និបាតនេះ អាត្មាភាពសូមថ្វាយព្រះពរ ថ្លែងនូវអំណរព្រះគុណដ៏ខ្ពង់ខ្ពស់បំផុត ចំពោះសម្តេចព្រះមហាក្សត្រិយានី នឹងសម្តេចព្រះប្រមុខរដ្ឋ ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកជា

ព្រះរាជាធិបតីក្នុងពិធីអនុសំវច្ឆរមហាសន្និបាតទី ១៧ នៃមន្ត្រីសង្ឃនេះ ។

សូមថ្វាយព្រះពរ៖

អម្បាញ់មិញនេះ, ឯកឧត្តមនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងក្រសួងធម្មការ បានថ្លែងសេចក្ដីថ្វាយពតិមានអំពីមហាសន្និបាតនេះ ដែលមានសេចក្ដីទាក់ទងដល់គុណសម្បត្តិនៃព្រះពុទ្ធសាសនា ដល់គណៈសង្ឃ និងដល់ប្រទេសកម្ពុជា រួចហើយ ។

ឥឡូវនេះ, អាត្មាភាពជាតំណាងមន្ត្រីសង្ឃទាំងអស់ សូមព្រះរាជទានព្រះរាជឱកាស ដើម្បីថ្វាយពតិមានខ្លះ អំពីសេចក្ដីពេញចិត្ត សេចក្ដីរីករាយរបស់សង្ឃ ចំពោះភ័ព្វវាសនានៃប្រទេសកម្ពុជា និងព្រះពុទ្ធសាសនា ជាការឆ្លើយតបនឹងសេចក្ដីថ្លែងនៃឯកឧត្តមទទួលបន្ទុកខាងក្រសួងធម្មការ ដូចមានតទៅនេះ ៖

ព្រះសង្ឃទាំងអស់បានដឹងច្បាស់លាស់ណាស់ថា ប្រទេសកម្ពុជា បានរួចផុតអំពីអំណាចនៃបរទេសហើយ បានទទួលឋានៈជាប្រទេសឯករាជ្យ អព្យាក្រឹត ដោយសារព្រះរាជសកម្មប្រយុទ្ធ ដ៏អង់អាចនៃសម្ដេចព្រះប្រមុខរដ្ឋ ។ លុះបានដឹងដូច្នេះហើយ ក៏កើតមានចិត្តត្រេកអររីករាយយ៉ាងខ្លាំងក្លា ព្រមទាំងមានគារវកិច្ចប្រកបដោយកតញ្ញូតាធម៌យ៉ាងក្រៃលែង ចំពោះព្រះអង្គសម្ដេចព្រះប្រមុខរដ្ឋជានិច្ចនិរន្តរ៍ ឥតមានអ៊ូនឹងមក

បំបាក់បំបែកបានឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ ព្រះសង្ឃទាំងអស់ សឹង មានសេចក្ដីសង្ឃឹមយ៉ាងកក់ក្ដៅបំផុត ចំពោះរាជរដ្ឋាភិបាលសង្គមរាស្ត្រ-និយមបច្ចុប្បន្នដែលមានព្រះអង្គសម្ដេចព្រះប្រមុខរដ្ឋ ជាអគ្គមគ្គុទ្ទេសក៍ជា នឹងជួយឧបត្ថម្ភព្រះពុទ្ធសាសនាឲ្យមានវឌ្ឍនភាពតទៅមុខជាដរាប ។

ចំពោះព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា នាអតីតកាលដែលធ្លាប់ បានទទួលសេចក្ដីឧបត្ថម្ភគាំទ្រអំពីព្រះមហាក្សត្រិយ៍ ក្នុងបុរាណកាលនោះ អាត្មាភាពពុំចាំបាច់នាំយកមកថ្លែងក្នុងទីនេះឡើយ ដោយមានសិលាចារឹក បុរាណ ដែលទាក់ទងដល់ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា បានប្រាប់ បញ្ជាក់ឲ្យច្បាស់លាស់ជាភស្តុតាងស្រាប់មកហើយ ។

រីឯក្នុងបច្ចុប្បន្នកាលនេះ ព្រះសង្ឃក្ដី ប្រជាពលរដ្ឋជាពុទ្ធសាសនិក ក្ដី សុទ្ធសឹងតែបានឃើញច្បាស់នឹងចក្ខុ នូវព្រះពុទ្ធសាសនា ដែលបាន ទទួលព្រះបរមរាជូបត្ថម្ភ អំពីព្រះមហាក្សត្រិយ៍ជានិច្ចនិរន្តរ៍ ។ មាន ឧទាហរណ៍ដូចជាការសិក្សាខាងព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជានេះ ដែលមាន ៣ ផ្នែកគឺ ពុទ្ធិកបឋមសិក្សា ពុទ្ធិកមធ្យមសិក្សា នឹងពុទ្ធិកឧត្ដម សិក្សា ព្រមទាំងការសិក្សាធម្មវិន័យ បានប្រព្រឹត្តទៅកាន់សេចក្ដីចំរើន ដោយមានរបៀបរៀបរយល្អសព្វថ្ងៃនេះ គឺប្រាកដជាដោយសារព្រះ ករុណាធិគុណនៃព្រះមហាក្សត្រតាមលំដាប់កាល រៀងរហូតមកដល់

បច្ចុប្បន្នរជ្ជកាលដែលមានសម្តេចព្រះមហាក្សត្រិយានី នឹងសម្តេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភកពុទ្ធិកសិក្សានេះ ព្រះសង្ឃទាំងអស់បានដឹងច្បាស់ថា ប្រសិនបើមិនមានព្រះមហាក្សត្រជាអគ្គពុទ្ធសាសនូបត្ថម្ភកទេ ប្រាកដជាពុំអាចនឹងកើតឡើងបាន ចំរើនឡើងបាន ដូចសព្វថ្ងៃនេះឡើយ ។

ក្រៅពីការសិក្សា មានកិច្ចការដទៃទៀត ដូចការគ្រប់គ្រងគណៈសង្ឃក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ឲ្យមានរបៀបរៀបរយ បានប្រព្រឹត្តទៅ ដោយសុខសន្តិភាព ក៏អាស្រ័យនឹងព្រះបរមកដូបត្ថម្ភដែរ ។ ព្រះគុណរបស់ព្រះអង្គ ដែលជួយទ្រទ្រង់ឲ្យព្រះពុទ្ធសាសនាបានសុខ បានចំរើនលូតលាស់ មានពន្លឺរស្មីត្រចះក្នុងផ្លូវសិក្សា នឹងផ្លូវប្រតិបត្តិនេះ ជាព្រះគុណដ៏ខ្ពង់ខ្ពស់បំផុត ជ្រាលជ្រៅបំផុត ឥតមានព្រះសង្ឃរូបណាមួយបំភ្លេចបានឡើយ ។

សូមថ្វាយព្រះពរ!

អាត្មាភាពសូមថ្វាយសេចក្តីបញ្ជាក់ជាថ្មីម្តងទៀតថា ព្រះសង្ឃទាំងអស់ក្នុងប្រទេសកម្ពុជា តែងមានការយល់ឃើញថា ព្រះសង្ឃទុកដូចជាទាសនៃព្រះពុទ្ធ អាចរក្សាការពារព្រះពុទ្ធសាសនាដោយផ្ទាល់ ក្នុងផ្ទៃក្នុងបាន ប៉ុន្តែមិនអាចការពារសត្រូវខាងក្រៅ ដែលចូលមកប្រទូស្តបានឡើយ ឧទាហរណ៍ដូចប្រទេសឥណ្ឌាក្នុងសម័យបុរាណ ដែលជាកន្លែងប្រភពនៃ

ព្រះពុទ្ធសាសនា ៗ នៅទីនោះ មិនយូរប៉ុន្មាន ព្រះពុទ្ធសាសនា ក៏ត្រូវរលាយរលុបអស់ ដោយហេតុមកពីឥតមានព្រះមហាក្សត្រជួយការពារ ឥតមានរដ្ឋាភិបាលជួយគាំទ្រ ព្រះពុទ្ធសាសនាក៏ត្រូវរលាយដោយស្នាដៃនៃសត្រូវ មានឥស្លាមិកជនជាដើម ៗ

ព្រះពុទ្ធសាសនា ដែលផ្សាយចូលមកក្នុងប្រទេសកម្ពុជា តាំងពីក្រោយព្រះពុទ្ធទ្រង់ចូលបរិនិព្វានប្រមាណ ២៣៦ ឆ្នាំម៉្លេះ ក្នុងសម័យដែលព្រះអរហន្ត ២ អង្គគឺ ព្រះសោណៈ នឹងព្រះឧត្តរៈមហាថេរជាសមណទូតនាំមកផ្សាយ ក្នុងរជ្ជកាលនៃព្រះបាទធម្មាសោកមហារាជ ៗ ព្រះពុទ្ធសាសនានេះ បានតម្កល់នៅក្នុងប្រទេសកម្ពុជា រហូតមកដល់បច្ចុប្បន្ននេះ ដោយអាស្រ័យការឧបត្ថម្ភគាំពារនៃព្រះមហាក្សត្រក្នុងប្រទេសតៗមក ៗ

ដោយហេតុដូចខាងលើនេះ បានជាក្នុងបច្ចុប្បន្ននេះ ព្រះសង្ឃទាំងអស់ តែងបានទទួលសេចក្ដីរីករាយសប្បាយ ចំពោះព្រះពុទ្ធសាសនាដែលមានទីពឹងពុំខាក់លើព្រះមហាក្សត្រិយ៍នឹងរាជរដ្ឋាភិបាល នឹងអាចជួយឧបត្ថម្ភឲ្យបានសុខចំរើន ជួយការពារមិនឲ្យរលាយរលត់បាត់បង់ទៅបាន ៗ

សូមថ្វាយព្រះពរ!

ត្រង់ពាក្យថាព្រះពុទ្ធសាសនា បានសុខចំរើនដោយសារព្រះបរម-

ភជួបត្ថម្ភ៍នោះ ជាការជាក់ស្តែងណាស់ ព្រោះព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជាបានទទួលការគោរពនិងភក្តីភាព អំពីព្រះមហាក្សត្រ អំពីឥស្សរជននិងអំពីប្រជាពលរដ្ឋទូទៅ ព្រមទាំងបានទទួលការឧបត្ថម្ភ៍គ្រប់យ៉ាង នាំឲ្យព្រះពុទ្ធសាសនាបានលូតលាស់ចំរើនឡើងគ្រប់ផ្នែក រហូតដល់បានទទួលឋានៈជាសាសនារបស់រដ្ឋ ។

ត្រង់ពាក្យថាព្រះពុទ្ធសាសនា បានទទួលការឃុំគ្រងការពារនោះក៏ជាការជាក់ស្តែងណាស់ ព្រោះព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា មានចែងទុកក្នុងច្បាប់ថា អ្នកណាបៀតបៀន ឬប្រមាថមើលងាយពុំបាន ។ល។

មិនត្រឹមតែប៉ុណ្ណោះឡើយ ព្រះសង្ឃទាំងអស់ក្នុងប្រទេស ដែលជាកូនចៅរបស់ប្រជាពលរដ្ឋគ្រប់ប្រភេទ ដែលបានបួសក្នុងព្រះពុទ្ធសាសនា បានឈ្មោះថាភិក្ខុ ថាសាមណេរ ឬសមណៈ ឬក៏ហៅថាព្រះសង្ឃ ។ នេះ ក៏បានទទួលសេចក្តីគោរពរាប់អាន និងការជួយឧបត្ថម្ភគាំទ្រឲ្យបានសុខស្រួល និងសេចក្តីចំរុងចំរើនដែរ ។

ដោយហេតុនេះហើយ បានជាព្រះសង្ឃទាំងអស់ តែងមានគារវភក្តីយ៉ាងខ្លាំងក្លាប្រកបដោយកតញ្ញូតាដ៏ជ្រាលជ្រៅ ចំពោះព្រះករុណាធិគុណនៃសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះប្រមុខរដ្ឋឥតមានអ្វីនឹងមកធ្វើឲ្យរលាយរលត់បានឡើយ ។

នៅអវសាននេះ អាត្មាភាពក្នុងនាមនៃព្រះសង្ឃទាំងអស់ សូមថ្វាយនូវព្រះពរបវរសួស្តី ជោគជ័យមហាមង្គលវិបុលសុខគ្រប់ប្រការ ចំពោះសម្តេចព្រះមហាក្សត្រិយានី ចំពោះសម្តេចព្រះប្រមុខរដ្ឋ សូមទ្រង់បានប្រកបដោយព្រះជន្មវស្សាយឺនយូរ មានព្រះសុខភាពបរិបូរ ឈ្នះមារសត្រូវគ្រប់ទិសទី កុំបីឃ្លៀងឃ្លាតឡើយ ។

×

× ×

តមក ព្រះសង្ឃបានសូត្រជយន្តោ ថ្វាយព្រះពរជ័យ ចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ។ មួយរំពេចនោះ សម្តេចព្រះប្រមុខរដ្ឋជាទីគោរពនឹងជាទីស្នេហារបស់ពលរដ្ឋខ្មែរ ព្រះអង្គទ្រង់សព្វព្រះពជហឫទ័យថ្លែងព្រះសុន្ទរកថាមួយយ៉ាងវែង ប្រកបដោយអត្ថ-ន័យដ៏សំខាន់ៗ ជាទីបំផុត ។ ជាពិសេស គឺព្រះអង្គបានផ្ដែផ្ដាំចំពោះព្រះសង្ឃ ដែលលោកមានព្រះនេត្រទិព្វ ព្រះសោតទិព្វ សុំជួយពង្រីកផែនការ ៤ ឆ្នាំ សុំឲ្យជួយពន្យល់ណែនាំទាយកទាយិកាឲ្យយល់ច្បាស់ អំពីប្រយោជន៍ព្រៃព្រឹក្សា គឺសុំឲ្យជួយហាមប្រាមកូនចៅ កុំឲ្យដុតព្រៃដែលបណ្តាលឲ្យឆាបឆេះដល់ឈើល្អៗ, នឹងសុំហាមកុំឲ្យចាប់ត្រីនៅខែណាដែលវាកំពុងពងកំពុងកូន, ព្រោះឈើព្រៃ នឹងត្រីនេះហើយដែលជាផ្ទើមប្រមាត់របស់សេដ្ឋកិច្ចជាតិ ។ល។ ព្រះពជបន្ទូលមានសេចក្តីទូលំទូលាយ

ណាស់ ហើយសុទ្ធតែសំខាន់ៗ បំផុត យើងមិនអាចនឹងរៀបរាប់ឲ្យចប់សព្វគ្រប់បាន ។

ពិធីអនុសំវច្ឆរមហាសន្និបាតនេះ បានចប់សព្វគ្រប់នៅវេលាម៉ោង២២ នៃរាត្រី ។ នៅពេលនោះ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង, សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់បានស្តេចយាងនិវត្ត ចូលកាន់ព្រះបរមរាជវាំងវិញ ដោយមានព្រះរាជបរិវារផ្តល់ព្រះអគ្គតាមហែ និងក្រុមក្មេងព្រះរាជទ្រព្យ ធ្វើគារវកិច្ច ដូចកាលព្រះអគ្គយាងមកដល់ ។

# ព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិ
# នៃព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ

ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម-សុរាម្រិត ព្រះចៅប្រទេសកម្ពុជា ជាទីស្នេហា និងជាទីគោរពដ៏ខ្ពង់ខ្ពស់នៃប្រជាជាតិខ្មែរ ព្រះអង្គសោយព្រះទិវង្គត នៅថ្ងៃអាទិត្យទី៣ ខែមេសា គ.ស.១៩៦០, វេលាម៉ោង១២ និង៤៥នាទី ក្នុងព្រះជន្មវស្សាគំរប់៦៦ឆ្នាំ ។ ព្រះរាជរដ្ឋាភិបាលបានថ្វាយព្រះមរណនាមថា "ព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ" ។

ប្រជាជាតិខ្មែរ ដោយមានសម្ដេចព្រះមហាក្សត្រិយានីព្រះមាតាជាតិ សម្ដេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ ជាព្រះប្រមុខរដ្ឋ ព្រមទាំងព្រះរាជរដ្ឋាភិបាល បានតម្កល់ព្រះបរមសពរបស់ព្រះអង្គ ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ក្នុងព្រះបរមរាជវាំង អស់រយៈកាល៤ខែ ១៧ថ្ងៃ ។

លុះមកដល់ថ្ងៃទី ២០ ខែសីហា ព.ស. ២៥០៣ គ.ស ១៩៦០ ទើបរៀបចំធ្វើព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព ក្រោមព្រះរាជាធិបតីភាពនៃសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ។ ព្រះរាជពិធីនេះ បានប្រព្រឹត្តទៅដ៏មហោឡារិកអធិកអធមមហិមា អស់រយៈកាល ៧ យប់ ៧ ថ្ងៃ ទើបហើយស្រេច ។

លុះសម្រេចព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពហើយ បានតម្កល់

ព្រះបរមអដ្ឋិ នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ អស់រយៈពេល ៤ ខែ ១៥ ថ្ងៃ គិតរហូតមកដល់ខែមករា ១៩៦១ ទើបធ្វើព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិក្នុងព្រះចេតិយ នាបរិវេណនៃព្រះវិហារព្រះកែវមរកត ។

ដោយក្រុមពុទ្ធសាសនបណ្ឌិត្យ មានចិត្តក្រៀមក្រំសោកស្តាយអា-ឡោះអាល័យព្រះអង្គក្រៃពេក នឹងមានចិត្តកតញ្ញូចំពោះព្រះករុណាធិគុណដ៏ខ្ពង់ខ្ពស់នៃព្រះអង្គ ព្រោះព្រះអង្គជាព្រះមហាក្សត្រដ៏ប្រកបដោយគតិ-បណ្ឌិតទ្រង់ទសពិធរាជធម៌ ជាអគ្គពុទ្ធសាសនូបត្ថម្ភ ទ្រង់បានទំនុកបំរុងវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ជាទីផ្សាយក្បួនច្បាប់ ធម៌វិន័យ ពុទ្ធឱវាទជាដើម ទើបបាននិពន្ធអត្ថបទថ្លែងអំពីព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិនៃព្រះអង្គទុកជាទីរលឹកដោយគោរពតទៅ ។

ព្រះរាជពិធីនេះ ធ្វើអស់រយៈពេល ៥ ថ្ងៃ ៥ យប់ ដូចរៀបរាប់ដោយសង្ខេបតទៅនេះ ៖

ថ្ងៃទី ១ (១១ មករា ១៩៦១) ជាថ្ងៃចូលព្រះរាជពិធីដ៏ប្រកបដោយជោគជ័យមង្គល សិរីសួស្តីមហាប្រសើរ ។ ក្នុងថ្ងៃនេះ វេលាម៉ោង ៩, ៣០ នាទី នៅព្រះទីនាំងទេវាវិនិច្ឆ័យ, សម្តេចព្រះមហាក្សត្រយានីជាអម្ចាស់ជីវិតលើត្បូង នឹងសម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ស្តេចយាង ដោយមានព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមហែផង បានស្តេចយាង

អញ្ជើញមកដល់ ។ សម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋអញ្ជើញស្តេចយាង ព្រះរាជព្រះបរមអដ្ឋិព្រះករុណា ព្រះមហាការុញាធិរាជ ចេញពីហោព្រះអដ្ឋិទៅដំកល់នៅលើព្រះមហាបុស្បបុក នាមុខព្រះមហាស្វេតច្ឆ័ត្រ និមន្តព្រះសង្ឃ៦៦ អង្គ ថ្វាយព្រះសត្តប្បករណាភិធម្ម ។

ថ្ងៃទី ២ (១២ មករា ១៩៦១) ជាថ្ងៃដង្ហែព្រះបរមអដ្ឋិ ចេញអំពីព្រះទីនាំងទេវាវិនិច្ឆ័យ ទៅតម្កល់ក្នុងមហាបុស្បបុក នាព្រះវិហារព្រះកែវមរកត ។

ថ្ងៃដង្ហែនោះ វេលាម៉ោង ៦ ព្រឹក, នៅព្រះទីនាំងទេវាវិនិច្ឆ័យ មានការជួបជុំព្រះរាជវង្សានុវង្ស ក្សត្រី ក្សត្រា ជំទាវ ខុនណាង រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ សមាជិកសភាទាំងពីរ នាហ្មឺនសព្វមុខមន្ត្រី ទាហាន ស៊ីវិល មន្ត្រីកិត្តិយសជាច្រើន ។

ម៉ោង ៦ នឹង ៣០ នាទី, អគ្គទូតនានា នឹងករិយាអញ្ជើញមកដល់ៗ

ម៉ោង ៦ នឹង ៤៥ នាទី សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង, សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ស្តេចយាងដល់ ដោយមានព្រះរាជបរិពារៈផ្ទាល់ព្រះអង្គតាមហែផង ។ ទ្រង់ស្តេចយាងដល់ភ្លាមក្រោយអំពីការថ្វាយបង្គំហើយ លោកឧកញ៉ាមហាមន្ត្រី ឆេង - ហាក់ នាយកក្រុមព្រះរាជមន្ទីរទទួលធុង, រួចនិមន្តព្រះសង្ឃ ៦៦ អង្គថ្វាយព្រះ

សត្តប្បករណាភិធម្ម ។

លុះចប់ហើយ, ថ្វាយបង្គំព្រះបរមអដ្ឋិ ៣ ដង តាមសង្ខាក់គង ១០ អន្ទង ។

សម្តេចព្រះឧបយុវរាជ អញ្ជើញស្តេចយាងព្រះកោដ្ឋព្រះបរមអដ្ឋិ ចេញពីមហាបុស្សបុក ទៅតម្កល់លើព្រះសាលៀងកុង នៅកើយខាងមុខព្រះទីនាំងទេវាវិនិច្ឆ័យ ហើយដង្ហែទៅតម្កល់នៅលើព្រះរាជរថបុស្សបុក នាមុខព្រះបរមរាជវាំង ដោយសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូងស្តេចយាងហែជាព្រះរាជាធិបតានីភាព ដែលមានព្រះរាជបរិវារទាំងទាហាន-ស៊ីវិល តាមហែព្រះអង្គផង ។

សូមជ្រាបថា ក្នុងព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិនេះ មានពិធីបញ្ចុះព្រះអដ្ឋិនៃព្រះអង្គម្ចាស់ក្សត្រីនរោត្តម-គន្ធបុប្ផា ជាព្រះរាជបុត្រីនៃសម្តេចព្រះនរោត្តម-សីហនុ ព្រះប្រមុខរដ្ឋផង ។ វេលាដង្ហែព្រះបរមអដ្ឋិ មានដង្ហែព្រះអដ្ឋិនៃព្រះអង្គម្ចាស់ក្សត្រីនោះក្នុងពេលជាមួយនោះដែរ ។

ចំណែកព្រះអដ្ឋិនៃព្រះអង្គម្ចាស់ក្សត្រីនរោត្តម គន្ធបុប្ផា ក៏បានតម្កល់លើព្រះសាលៀងកុងមួយផ្សេង ដង្ហែពីខាងក្រោយព្រះបរមអដ្ឋិ ទៅតម្កល់នៅលើព្រះរាជរថគ្រឿងជាន់មួយទៀត នៅខាងក្រោយព្រះរាជរថបុស្សបុកតម្កល់ព្រះបរមអដ្ឋិ ។

ម៉ោង៧ ទីង៣០នាទីក្បួនហែចេញ ។ បារគូថ្វាយស័ង្ខ ភ្លេងទាំងអស់ប្រគំថ្វាយ, ស្គរកាំភ្លើងធំ ១០១ ណាត់ក៏បានបន្ទឺឡើង ។ ក្បួនហែចេញទៅតាមមហាវិថីសុធារស,វិថីសម្តេចអ៊ុក,មហាវិថីព្រះបាទនរោត្តម, មហាវិថីព្រះបាទសុរាម្រឹត នឹងមហាវិថីសុធារស ចូលវត្តព្រះកែវមរកត ដោយក្បួនហែជាសណ្តាប់ ។ យ៉ាងមហោឡារិក ដូចមានកុងកម្មវិធីក្បួនហែសព្វគ្រប់ស្រាប់ ។

ម៉ោង ៩,១៥ នាទី ក្បួនហែមកដល់, អញ្ជើញស្តេចយាងព្រះកោដ្ឋចុះពីព្រះទីនាំងបុស្សបុក ទៅតម្កល់នៅព្រះសាលៀងកុង រួចហែចូលទៅឈប់នៅមុខវិហារព្រះកែវមរកត ។ សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង, សម្តេចព្រះឧបយុវរាជ ស្តេចយាងហែ ដោយព្រះរាជបរិពារទាំងទាហាន ស៊ីវិលតាមហែផង ។ល។ លុះដល់យ៉ព្រះវិហារព្រះកែវមរកត សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់អញ្ជើញស្តេចយាងព្រះកោដ្ឋព្រះបរមអដ្ឋិទៅតម្កល់លើមហាបុស្សបុក ក្នុងព្រះវិហារព្រះកែវមរកត ។

ក្នុងពេលជាមួយនោះ មានពិធីអញ្ជើញព្រះកោដ្ឋព្រះអដ្ឋិព្រះអគ្គម្ចាស់ក្សត្រី នរោត្តម-គន្ធបុប្ផា ទៅតម្កល់លើព្រះសាលៀងកុង រួចហែចូលទៅឈប់នៅព្រះវិហារព្រះកែវមរកត អញ្ជើញស្តេចយាងទៅតម្កល់លើព្រះបញ្ចាតូប ក្នុងព្រះវិហារនោះដែរ ។ បន្ទាប់មក និមន្តព្រះសង្ឃ ៦៦

អង្គថ្វាយព្រះសត្តប្បករណាភិធម្ម ហើយថ្វាយបង្គំព្រះបរមអដ្ឋិ ៣ ដង តាមសង្កាត់គង់ ។

ព្រះរាជពិធីក្បួនហោបានចប់សព្វគ្រប់នៅម៉ោង ១០ និង ៣០នាទី ។

ម៉ោង១៨ និង១៥នាទី ចូលព្រះរាជពិធីដោយហោរាសូត្រប្រកាសទេវតា, អុជប្រទីបថ្លាលាតាមកំពែង ជុំវិញព្រះវិហារ និងតាមព្រះចេតិយ-ដ្ឋាន ព្រមទាំងតុដែលតាំងជាទីសក្ការបូជា ។ នៅអមមាត់ទ្វារខាងកើតគឺតុសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ, មាត់ទ្វារខាងត្បូងតុព្រះរាជាគណៈ ទាំងពីរគណៈ, មាត់ទ្វារខាងជើងតុរបស់លោកសង្ឃខាងមហា-យាន និងកៅដាយ ។

ម៉ោង១៩ ជួបជុំព្រះរាជវង្សានុវង្សក្សត្រ ក្សត្រា ជិទាវ ខុនណាង រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ សមាជិកសភាទាំងពីរ នាមុនសព្វមុខមន្ត្រី (ពាហាន - ស៊ីវិល) មន្ត្រីកិត្តិយស នៅក្នុងព្រះវិហារព្រះកែវមរកត ហើយនិមន្តព្រះសង្ឃ២២អង្គ មានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន ចូលមកគង់លើអាសនៈ ដើម្បីចំរើនព្រះបរិត្ត ។

ម៉ោង១៩, ១០នាទី សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋដោយមានព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមហែផង ស្តេចយាងដល់ ទ្រង់ប្រារព្ធនមស្ការព្រះរតនត្រ័យ ទ្រង់សមាទាន

និច្ចសីល ទ្រង់ព្រះសណ្ដាប់ព្រះបរិត្ត និងព្រះធម៌ទេសនាធម្មគារវៈ រហូតដល់ម៉ោង ២១-១០នាទី ទើបស្ដេចយាងត្រឡប់ចូលព្រះបរមរាជវាំង ។

ថ្ងៃទី៣ (១៣ មករា ១៩៦១) ថ្ងៃនេះ ម៉ោង ១០ ព្រឹក សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងចេញប្រថាប់នៅក្នុងព្រះវិហារព្រះកែវមរកត ។

ក្រោយពីសម្ដេចទាំងពីរព្រះអង្គទ្រង់ប្រារព្ធទៀនធូបនមស្ការព្រះរតនត្រ័យ ទ្រង់សមាទាននិច្ចសីល ទ្រង់ព្រះសណ្ដាប់ព្រះសង្ឃ ១០០ អង្គ ថ្វាយព្រះសត្តប្បករណាភិធម្ម ទ្រង់ប្រារព្ធរាប់បាត្រ ហើយអាចារ្យវេរសង្ឃភត្ត ឧទ្ទិសព្រះរាជកុសល ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ និងថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធព្រះអង្គម្ចាស់ក្សត្រីនរោត្តម-គន្ធបុប្ផា ។ នៅពេលព្រះសង្ឃកំពុងធ្វើភត្តកិច្ច សម្ដេចទ្រង់សព្វព្រះរាជហឫទ័យ ស្ដេចយាងទតផ្ទាល់ព្រះអង្គនិងទ្រង់ព្រះបញ្ជាឲ្យចាត់ចែងចង្ហាន់ ប្រគេនព្រះសង្ឃ ដោយទឹកព្រះទ័យជ្រះថ្លាមហាស្ចារ្យ រហូតដល់ម៉ោង១១,៤០ ទើបស្ដេចយាងចូលព្រះបរមរាជវាំងវិញ ។

នៅពេលល្ងាចនៃថ្ងៃនេះ ដូចល្ងាចថ្ងៃទី ២ ដែរ, ប៉ុន្តែថ្ងៃនេះ, មានសំដែងរឿងទសជាតក៍ ។

ថ្ងៃទី៤ (១៤មករា ១៩៦១) ពេលព្រឹកថ្ងៃនេះ ដូចពេល

ព្រឹកថ្ងៃទី៣ ។ ពេលល្ងាចក៏ដូចជាពេលល្ងាចថ្ងៃទី៣ដែរ; ប៉ុន្តែថ្ងៃនេះ មានសំដែងរឿងបឋមត្រាស់ និងអភិសេកព្រះពុទ្ធរូប ។

ថ្ងៃទី៤ (១៤ មករា ១៩៦១) ថ្ងៃនេះជាថ្ងៃធ្វើព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិ ។

ម៉ោង៩, ៣០នាទី ជួបជុំព្រះរាជវង្សានុវង្សដូចព្រឹកថ្ងៃទី២ ។

ម៉ោង៩, ៤៥នាទី អគ្គទូតនានាអញ្ជើញដល់ដូចថ្ងៃទី២ ។

ម៉ោង១០ សម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ទ្រង់យាងដល់ព្រះវិហារព្រះកែវមរកត; ហោរសូត្រប្រកាសទេវតា បារគូថ្វាយស័ង្ខ-ភ្លេងពិណពាទ្យ រួចនិមន្តព្រះសង្ឃ ១០ អង្គថ្វាយព្រះសត្តប្បករណាភិធម្ម ។ បន្ទាប់មកសម្តេចព្រះប្រមុខរដ្ឋ អញ្ជើញស្តេចយាងព្រះកោដ្ឋព្រះបរមអដ្ឋិ ហែចេញពីព្រះវិហារ ទៅប្រទក្សិណព្រះចេតិយ៣ជុំ ដោយមានព្រះរាជវង្សានុវង្ស អគ្គទូត ប្រជាទាយកាទាំងពីរ និងគណៈរដ្ឋមន្ត្រីតាមហែផង ។ លុះគ្រប់ ៣ ជុំហើយ សង្ឃការី ១នាក់ និមន្តព្រះពុទ្ធរូបឡើងទៅតម្កល់លើកំពូលព្រះចេតិយ ។ ខណៈនោះ, សម្តេចព្រះប្រមុខរដ្ឋ អញ្ជើញស្តេចយាងព្រះបរមអដ្ឋិទៅបញ្ចុះក្នុងព្រះចេតិយ ដែលនៅពេលនោះ បារគូថ្វាយស័ង្ខ-ភ្លេងពិណពាទ្យ- ភ្លេងក្លងខែក - តន្ត្រីព្រះរាជទ្រព្យ និងក្រុមទាហានទាំងអស់គោរពយ៉ាងស្ងប់

សៀម ស្គរកាំភ្លើងធំ ១០១ ណាត់ក៏បន្លឺឡើងព្រមនៅពេលជាមួយគ្នានោះ; ព្រះសង្ឃ៣០០អង្គថ្វាយជយន្តោ ។ លុះតម្កល់ព្រះបរមអដ្ឋិក្នុងព្រះចេតិយរួចហើយ មានពិធីថ្វាយបង្គំ៣ដងតាមចង្វាក់គង ។

បន្ទាប់មកសម្ដេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ទ្រង់ព្រះកោដ្ឋព្រះអដ្ឋិព្រះអង្គម្ចាស់ក្សត្រីនរោត្តម- គន្ធបុប្ផា ហែប្រទក្សិណព្រះចេតិយដែលតាំងនៅខាងកើតព្រះចេតិយនៃព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ ៣ ជុំ ដោយមានព្រះរាជវង្សានុវង្ស អង្គទូត ប្រធានសភាទាំងពីរ គណៈរដ្ឋមន្ត្រីតាមហែ ។ លុះគ្រប់៣ជុំហើយ, សង្ឃការី១នាក់ និមន្តព្រះពុទ្ធរូបឡើងទៅតម្កល់លើកំពូលព្រះចេតិយ ។ ពេលនោះ, សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់ព្រះកោដ្ឋព្រះអដ្ឋិទៅបញ្ចុះក្នុងព្រះចេតិយ, ក្រុមបារគូថ្វាយស័ង្ខ - ភ្លេងពិណពាទ្យ - ភ្លេងក្លងខែក តន្ត្រីព្រះរាជទ្រព្យ នឹងក្រុមទាហានទាំងអស់គោរព ។ ក្នុងពេលជាមួយគ្នានោះ, ព្រះសង្ឃ ៣០០ អង្គក៏ថ្វាយជយន្តោ ។

ព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិក្នុងព្រឹកនេះ ចប់នៅម៉ោង ៧,៣០ រួចហើយ សម្ដេចព្រះមហាក្សត្រិយានី សម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងចូលព្រះរាជវាំងវិញ ។

នៅពេលម៉ោង ១០ ព្រឹកក៏មានព្រះរាជពិធីដូចថ្ងៃទី៣-៤ ដែរ ។

ម៉ោង១៦ បានជួបជុំព្រះរាជវង្សានុវង្ស ដូចពីពេលព្រឹក ។

ម៉ោង ១៧ សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និង សម្ដេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ស្ដេចយាងមកដល់ព្រះវិហារព្រះកែវមរកត ។ ក្រោយពីនោះ ទ្រង់ថ្វាយព្រះទៀនធូបនមស្ការព្រះរតនត្រ័យ ទ្រង់សមាទាននិច្ចសីល ទ្រង់ព្រះសណ្ដាប់ព្រះធម្មទេសនាត្រៃបី ៣ អង្គ អានត្រៃ៤ អង្គ ហត្ថបាស ១០០ អង្គ នៅក្នុងព្រះវិហារព្រះកែវមរកត ។

បប់កិច្ចទេសនា សម្ដេចព្រះមហាក្សត្រិយានី សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់ព្រះនិវត្តន៍ចូលព្រះបរមរាជវាំងវិញ ។

យើងសូមបញ្ជាក់ថា: ចាប់តាំងពីម៉ោង ២០ ទៅ មានអុជកាំជ្រួចនៅភ្លឺទៀន, បញ្ចាំងភាពយន្ត ណាំងស្បែក ណាំងទ្រលុង នៅមុខព្រះបរម-រាជវាំង និងនៅវាលព្រះមេរុ រាល់យប់, ចំពោះយប់ទី ៣ ក្រុមល្ខោនព្រះរាជទ្រព្យ និងល្ខោនជាតិ សំដែងរឿងទសជាតក៍, យប់ទី ៤ រឿងពុទ្ធប្រវត្តិ នៅក្នុងវិហារព្រះកែវមរកត ។

ព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិ បានចប់សព្វគ្រប់នៅវេលាម៉ោង ១ អធ្រាត្រនៃរាត្រីថ្ងៃទី ១៩ មករា ១៩៦១ ។

ពុទ្ធសាសនបណ្ឌិត្យ សូមឧទ្ទិសកុសលចំពោះវិញ្ញាណក្ខន្ធរបស់ព្រះតេជព្រះគុណព្រះសាសនមុនី មាស-គង់ សូមព្រះតេជព្រះគុណបានទទួលនូវសេចក្ដីសុខក្សេមក្សាន្ត ក្នុងសម្បត្តិមនុស្ស, សម្បត្តិទេព្តា ៗ ជាពិសេស នៅទីបំផុត, សូមព្រះតេជព្រះគុណបានដល់នូវឋានបរមសុខស្ងប់ គឺព្រះនិព្វានកុំបីឃ្លៀងឃ្លាតឡើយ ។

ពុទ្ធសាសនបណ្ឌិត្យ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៣ លេខ ២ ខែកុម្ភៈ

ព.ស. ២៥០៣ គ.ស. ១៩៦១

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា នឹងអក្សរសាស្ត្រ

បេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង ទំព័រ

ផ្នែកសាសនា


- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ១១៩
- ព្រះនិព្វាន ឬ និព្វាណ លោកកុម្ម៉ង់ដង់ រូវែរត៍ រៀបរៀង . . . ១៣៨
- ព្រះអភិធម្មបិដក គម្ពីរព្រះកថាវត្ថុ (តមក) លោក ប៊ូ-ប៊ូ រៀបរៀង . . . ១៤៩
- ឧត្តរសភិហាណី (តមក) សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង
  ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ . . . . . . . . . . . ១៦០
- មហោសថជាតក(ត): លោកអ៊ុម-ភនធម្មរតី សាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-ត្រួតពិនិត្យ . ១៦៩
- សង្គហវត្ថុកថា (ពាក្យកាព្យ) លោក ហេង-សមអាន រៀបរៀង . . . ១៧៩


ផ្នែកអក្សរសាស្ត្រ


- វប្បធម៌ខ្មែរ (តមក) លោក លី-ធាមតេង រៀបរៀង . . . ១៩៧
- ពាក្យខ្មែរ ប្រែពីបរទេស ដោយគណៈកម្មការវប្បធម៌ . . . . . . . . ២០៤
- វចនានុក្រម សំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ២០៥
- រឿងសាមទ្វារ (តមក) នាញ៉ា ទូ-កន ប្រែ . . . . ២០៦
- ល្បែងគៀរ (ត និងចប់) លោក ញូង-សឿង រៀបរៀង . . ២១១
- រឿងព្រេងទាក់ទងដោយការស្ថាបនាប្រាសាទអង្គរ(ត) លោកញ៉ឹម-ទឹម រៀបរៀង . . ១២៣ ២២៣


ផ្នែកព័ត៌មាននិងប្រវត្តិការណ៍


- មហាសន្និបាតលើកទី ១២ នៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ . . . . . . ២២៦


មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជាវ ២៣០ ៛០០

## ផ្នែកសាសនា

### ពុទ្ធប្រវត្តិ

(តមក)

*ព្រះមហា ប៉ាង-ខាត់ រៀបរៀង*

## សន្តិកនិទាន អភិសម្ពោធិកថាទី ៩

១- ព្រះមហាបុរសត្រាស់ដឹង ២- ទ្រង់ជ្រាបច្បាស់ថាត្រាស់ដឹង ៣- សេចក្តីអស្ចារ្យក្នុងពេលត្រាស់ដឹង ៤- សត្តមហាឋាន ៥- ទ្រង់ព្រៀងជាព្រះពុទ្ធ ៦- ទ្រង់ជាកូនមាន់ច្បង ៧- ទ្រង់ជាបុគ្គលខ្ពស់ផុត ៨- ទ្រង់ជាព្រះតថាគត ។

### ១- ព្រះមហាបុរសត្រាស់ដឹង

*សុរិយមណ្ឌលផ្កាយនគាស ក្លីក្រហមឆ្អៅលើមេឃា មានពណ៌មួយពាន់ផ្កាយចេញពីអស្តង្គតប្រទេស ចន្ទមណ្ឌលរះឡើងក្រឡង់ ក្លីត្រដាក់លឿនលយតាក់ចុះឡើងកាន់អាកាសវេហាស៍ ព្រះមហាបុរសទ្រង់ប្រកបនិសីទនាការ បំពេញសមាធិក្រោមពោធិមណ្ឌលអបរាជិតបល្ល័ង្កញ៉ាំងរុក្ខមណ្ឌលឲ្យត្រកៀកដោយឆព្វណ្ណរង្សីគឺ ពណ៌ខៀវ, លឿង, ក្រហម, ស, ហង្សបាទ, និងផ្លេកៗ ពេលស្មើក្លីថា ក្នុងបឋមយាមទ្រង់បានត្រាស់ដឹងនូវបុព្វេនិវាសានុស្សតិញ្ញាណ ដូចពុទ្ធភាសិតដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារថា(១)*

"ម្នាលរាជកុមារ! តថាគតត្រិះរិះថា យើងទៅចាំបាន កាល

១ ពោធិរាជកុមារសូត្រ រាជវគ្គ ម. ម. សៀវ. ២៤ ទំព័រ ៣៨៦ ។

33e Année — No 2 — Février 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire

### Partie religieuse

Pages

— La Vie du Buddha (suite) par Vèn · *PANG KHAT* . . . . 119
— Le Nirvana par le Commandant *ROBERT* . . . . . . . . . 138
— Prah Abhidhammapitaka, Kampi de Preah Kathavathu (suite) par *M. BOU-PO* . . . . 149
— Madhurasavahini (suite) par Samdech Preah Dhammalikhita *LOUIS-EM*, revu et corrigé par Vèn· *NHÉAN-CHHOEUN* . . . . 160
— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM-PHON*, revu et corrigé par Vèn · *KEM-TO* . . . . 169
— Sanghavathu katha (poême) par *M. HENG-SAM-AN* . . 179

### Partie littéraire

— La Culture Khmère (suite) par *M. LY-THEAM-TENG* . . 197
— Activités de la Commission Culturelle . . . . . . . . . . . . . . 204
— Dictionnaire Sanscrit-Khmèr (suite) par Vèn *PANG-KHAT* . . 205
— Histoire de Sam-Kok (suite) traduite par Oknha *NOU-KAN* . . . . . . . 206
— Le jeu de "Eav" (suite et fin) par *M. NHOUNG-SŒUNG* . . 211
— La fondation d'Angkor d'après une légende khmère par *M. NHEM-KHEM* . . . . . 223

### Notes et chroniques

— Le 12 ème Congrès de l'Association des Amis du Bouddhisme au Cambodge . . . 226

Prix d'abonnement annuel (comprenant 12 numéros): 23o$oo

ប្រត់ព្រះន័ង្គលរបស់សក្កៈជាបិតា យើងអង្គុយនៅក្រោមម្លប់ជម្ពូព្រឹក្ស បានស្ងាត់ហើយចាកកាមទាំងឡាយ ស្ងាត់ហើយចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន មានវិតក្កៈនិងវិចារៈ មានបីតិនិងសុខ ដែលកើតពីវិវេកហើយគិតថា នេះជាផ្លូវត្រាស់ដឹងបានដែរឬ! ម្នាលរាជកុមារ! វិញ្ញាណដែលស្ទុះទៅតាមសតិ ក៏កើតដល់តថាគតថា នេះហើយប្រាកដជាផ្លូវត្រាស់ដឹង ។

ម្នាលរាជកុមារ! តថាគតបរិភោគអាហារដ៏គ្រោតគ្រាតគឺបាយនិងនំកុម្មាស បម្រុងរាងកាយឲ្យមានកម្លាំង ហើយស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយបានដល់បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈានសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

ម្នាលរាជកុមារ! តថាគត កាលបើចិត្ត តាំងនៅល្អបរិសុទ្ធផូផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារកម្ម មិនបាន

ញាប់ញ័រតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ តថាគតរលឹកឃើញនូវបុព្វេ-និវាសាច្រើនប្រការ គឺរលឹកបាន ១ ជាតិ ២ ជាតិ ។ល។ តថាគតរលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ ម្នាលរាជកុមារ! នេះជាវិជ្ជាទី ១ ដែលតថាគតបានក្នុងបឋមយាមនៃរាត្រី អវិជ្ជាក៏បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលជាអ្នកមិនប្រមាទ ព្យាយាមដុតកំដៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វានដោយពិត ។

ម្នាលរាជកុមារ! តថាគត កាលបើចិត្ត តាំងនៅល្អ បរិសុទ្ធផូរផង់ ឥតមានទីទួលគឺកិលេស ប្រាសចាកឧប-ក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម មិនបានញាប់ញ័រទៅតាមអារម្មណ៍ ដោយប្រការដូច្នេះហើយ ក៏បង្អោនចិត្តទៅដើម្បីចុតូបបាតញាណ គឺប្រាជ្ញាដឹងនូវចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ ។ តថាគតមានទិព្វចក្ខុកន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញពពួកសត្វដែលច្យុត ដែលកើត

ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានរូបល្អ រូបអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។ល។ តថាគតឃើញច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ។ ម្នាលរាជកុមារ! នេះជាវិជ្ជាទី ២ ដែលតថាគតបានហើយក្នុងមជ្ឈិមរាត្រី អវិជ្ជាបាត់ហើយ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅហើយ ពន្លឺក៏កើតឡើង ដល់តថាគតដែលជាអ្នកមិនប្រមាទ ព្យាយាមដុតកំដៅកិលេសឲ្យក្តៅ មានចិត្តផ្ចាញ់ទៅកាន់ព្រះនិព្វានដោយពិត ។

ម្នាលរាជកុមារ! តថាគត កាលបើចិត្ត តាំងនៅល្អ បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម មិនបានញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញាណ ។ តថាគតបានដឹងច្បាស់តាមពិតថា នេះទុក្ខ នេះជាបដិបទាជាហេតុឲ្យរលត់សេចក្តីទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាអាសវៈ នេះជាបដិបទាឲ្យដល់នូវសេចក្តីរលត់អាសវៈ ។ កាលតថាគត ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តរបស់តថាគត ក៏រួចចាកកាមាសវៈផង រួចចាកភវាសវៈផង

រូបជាកអវិជ្ជាសវៈផង កាលចិត្តរបស់រូបស្រឡះហើយ សេចក្ដីដឹងក៏កើតប្រាកដថា ចិត្តផុតស្រឡះហើយ ជាតិអស់ហើយ ព្រហ្មចរិយធម៌ បាននៅចប់ហើយ កិច្ចដែលត្រូវធ្វើក៏ធ្វើស្រេចហើយ ឥតមានកិច្ចដទៃប្រព្រឹត្តទៅដើម្បីកិច្ចនេះទៀតឡើយ ។ ម្នាលរាជកុមារ! នេះឯងជាវិជ្ជាទី ៣ ដែលតថាគតបានហើយក្នុងបច្ឆិមយាមនៃរាត្រី អវិជ្ជាបាត់ទៅហើយ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅហើយ ពន្លឺក៏កើតឡើង ដល់តថាគតដែលជាអ្នកមិនប្រមាទ អ្នកព្យាយាមដុតកំដៅកិលេស ឲ្យក្ដៅ មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វានដោយពិត" ។

## ២– ទ្រង់ជ្រាបច្បាស់ថាព្រះអង្គត្រាស់ដឹង

*លុះព្រះមហាបុរសត្រាស់ដឹងនូវវិជ្ជាទាំង ៣ ប្រការស្រេចក្នុងវេលាបច្ចូសសម័យហើយ ទើបព្រះអង្គជ្រាបច្បាស់ថាបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ ដូចព្រះពុទ្ធដីកាដែលទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា*(១)

"ម្នាលភិក្ខុទាំងឡាយ! តថាគត មានជាតិ ជរា សេចក្ដីសោក សេចក្ដីសៅហ្មងជាធម្មតា បានដឹងច្បាស់នូវទោសក្នុង

១– បាសរាសិសូត្រ ឧបម្មវគ្គ ម. មូ. សៀវ ២១ ទំព័រ ១៤៤ ។

ជាតិ ក្នុងជរា ក្នុងសេចក្ដីសោក ក្នុងសេចក្ដីសៅហ្មង ហើយស្វែងរកព្រះនិព្វានដែលមិនមានជាតិ មិនមានជរា មិនមានសេចក្ដីសោក មិនមានសេចក្ដីសៅហ្មង មិនមានគុណជាតអ្វីស្មើ ជាទីក្សេមចាកយោគៈ ក៏បានដល់នូវព្រះនិព្វានដ៏ប្រសើរបំផុតនោះ ទាំងញាណជាគ្រឿងឃើញគឺសព្វញ្ញុតញ្ញាណ ក៏កើតដល់តថាគតថា "វិមុត្តិរបស់តថាគតមិនរំភើបដោយរាគា-ទិក្កិលេស នេះជាជាតិទីបំផុតរបស់តថាគត តទៅនេះ ភពថ្មីទៀតមិនមានឡើយ" ។

*ព្រះមហាបុរសជ្រាបច្បាស់ថា ព្រះអង្គបានត្រាស់ដឹងនូវអនុត្តរសម្មា-សម្ពោធិញ្ញាណហើយ ទើបទ្រង់បន្លឺព្រះឧទាននូវ១គាថា ឈ្មោះបឋមពុទ្ធវចនៈ ដែលព្រះអតីតពុទ្ធទាំងឡាយទ្រង់មិនដែលលះបង់ ទ្រង់តែងតែពោលជាដំបូងបង្អស់ថា*(១)

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុនគេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

---

១- ឯកនិបាតជាតក ។

"កាលតថាគតមិនទាន់បានជួបប្រទះ (នូវពោធិញ្ញាណ) រវល់តែស្វែងរកនូវជាងផ្ទះគឺតណ្ហា អ្នកធ្វើនូវផ្ទះគឺអត្តភាព ហើយអន្ទោលទៅអស់សង្សារមានជាតិ ជាអនេក ជាតិគឺការកើតរឿយ ៗ រមែងនាំមកនូវសេចក្តីទុក្ខព្រួយឥតឈប់ឈរ ។ នែជាងផ្ទះគឺតណ្ហា ! (ឥឡូវនេះ) តថាគតជួបអ្នកហើយ ឃើញអ្នកហើយ, តាំងពីថ្ងៃនេះតទៅអនាគត អ្នកធ្វើផ្ទះគឺអត្តភាពនេះឲ្យតថាគតទៀតមិនបានទេ ឆ្អឹងជំនីរគឺកិលេសទាំងអស់របស់អ្នក តថាគតកាច់បំបាក់ខ្ទេចខ្ទីអស់ហើយ មេដំបូលផ្ទះគឺអវិជ្ជារបស់អ្នក ក៏តថាគតប្រហារខ្ទាត់ខ្ទាយអស់ហើយដែរ, ចិត្តរបស់តថាគតបានដល់ហើយនូវព្រះនិព្វាន ដែលអស់មានសង្ខារទៀតហើយ តថាគតបានដល់នូវការអស់ទៅនៃតណ្ហាហើយដោយពិតប្រាកដ" ។

## ៣ - សេចក្តីអស្ចារ្យក្នុងពេលត្រាស់ដឹង

*កាលនោះ មានសេចក្តីអស្ចារ្យចំឡែកកើតឡើង ដូចព្រះគម្រាស់ដែលទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា* (១)

---

១- ភយវគ្គ ភិក្ខុបណ្ណាសក ម. អំ. សៀ. ៤២ ទំព័រ ៣៣២ ។

"ម្នាលភិក្ខុទាំងឡាយ ! កាលតថាគត បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោកនេះនឹងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទេពតាព្រមទាំងមនុស្ស មានពន្លឺរស្មីភ្លឺព្រោងព្រាយប្រមាណមិនបាន ក្រៃលែងជាងទេវានុភាព ។ សូម្បីតែលោកន្តរនរកដែលធ្លាប់តែងងឹតអន្ធការសូន្យសុងជានិច្ច ចក្ខុវិញ្ញាណចាក់មិនធ្លុះ ពន្លឺព្រះអាទិត្យព្រះចន្ទហោលរស្មីទៅមិនដល់ក្នុងទីនោះ ពន្លឺព្រោងព្រាយក្រៃពេកប្រមាណមិនបាន ក្រៃលែងជាងទេវានុភាព ក៏កើតឡើង ។ សត្វដែលកើតក្នុងនរកនោះ បានឃើញនូវគ្នានឹងគ្នាដោយពន្លឺនោះ បបួលគ្នានិយាយអឺងកងឡើងថា "នែអ្នកដ៏ចំរើនទាំងឡាយ ! សត្វដទៃក្រៅពីអាត្មាអញដែលកើតក្នុងទីនេះមានដែរតើហ្ន៎ ! ។

ម្នាលភិក្ខុទាំងឡាយ ! នេះជាហេតុអស្ចារ្យទី ៣ ដែលមិនធ្លាប់កើត ក៏កើតឡើង ព្រោះការកើតឡើងនៃតថាគត ជាអរហន្តសម្មាសម្ពុទ្ធ" ។

ត្រាស់ដឹងនៅថ្ងៃ ៤ ១៥ ៦ ឆ្នាំរការ ក្នុងព្រះជន្មាយុគម្រប់ ៣៥ វស្សា នាគយាសីសប្រទេស ( ពុទ្ធគយា ) ។

## ៤ _ សត្តមហាឋាន

សប្តាហ៍ទី ១ _ ព្រះពិជិតមារទ្រង់ប្រថាប់នៅលើបល្ល័ង្កជ័យក្រោម ពោធិព្រឹក្សអស់រយៈ ៧ ថ្ងៃ ពិចារណាពុទ្ធការកធម៌ ដែលទ្រង់បានបំពេញ អស់ ៤ អសង្ខេយ្យ កំរៃមហាសែនកប្ប ហើយសោយវិមុត្តិសុខ ។

ក្នុងបឋមយាម ទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ ជាអនុលោមប្បដិលោមថា[១]

" ម្នាលភិក្ខុទាំងឡាយ ! សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។ល។ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សេចក្ដីសោកស្ដាយ សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ លំបាកចិត្ត និងសេចក្ដីបង្អៀតបង្អល់ចិត្ត ក៏កើតមានព្រម ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ! នេះហៅថា បដិច្ចសមុប្បាទធម៌ ។

១- អភិសមយសំយុត្ត ពុទ្ធវគ្គ សំយុត្ត: សៀវ. ៣១ ទំព័រ ២ ។

ម្នាលភិក្ខុទាំងឡាយ ! ការរលត់នៃសង្ខារ ព្រោះរលត់នៃអវិជ្ជា ឥតមានសេសសល់ រលត់វិញ្ញាណ ព្រោះរលត់សង្ខារ ។ល។ ជរាមរណៈរលត់ ព្រោះរលត់ជាតិ សេចក្តីសោកស្តាយ ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្តនឹងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏រលត់ទៅ ។ ការរលត់ទៅនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ" ។

*លុះទ្រង់ជ្រាបច្បាស់យ៉ាងនេះហើយ ទើបទ្រង់បន្លឺឧទានគាថាយ៉ាងនេះថា*(១)

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មំ ។

"ធម៌ទាំងឡាយគឺបដិច្ចសមុប្បាទធម៌កើតប្រាកដដល់ខីណា-សវព្រាហ្មណ៍ ដែលជាអ្នកមានព្យាយាមញុំាងកិលេសឲ្យក្តៅ ជាអ្នកដុតបំផ្លាញនូវកិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួងនៃខីណាសវព្រាហ្មណ៍ រមែងស្ងប់រម្ងាប់

១- វិនយបិដក មហាវគ្គ សៀវ. ៦ ទំព័រ ៣ ។

ទៅ ក្នុងកាលនោះ ព្រោះខីណាសវព្រាហ្មណ៍ទាំងឡាយ បានយល់ច្បាស់ហើយនូវធម៌ព្រមទាំងហេតុ" ។

*ក្នុងមជ្ឈិមយាម ទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ ជាកូនសោនៃទុក្ខ ជាអនុលោមបដិលោម ។ លុះជ្រាបច្បាស់យ៉ាងនេះហើយ ទើបទ្រង់បន្លឺនូវឧទានគាថាយ៉ាងនេះថា[១]*

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ ខយំ បច្ចយានំ អវេទិ ។

"ធម៌ទាំងឡាយ កើតប្រាកដដល់ខីណាសវព្រាហ្មណ៍ ដែលជាអ្នកមានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ អ្នកដុតបំផ្លាញនូវកិលេសក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួងនៃខីណាសវព្រាហ្មណ៍នោះ រមែងស្ងប់រម្ងាប់ទៅ ក្នុងកាលនោះ ព្រោះខីណាសវព្រាហ្មណ៍នោះ បានជ្រាបច្បាស់នូវព្រះនិព្វានជាទីអស់ទៅនៃបច្ច័យ" ។

*ក្នុងបច្ឆិមយាម ទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ ជាអនុលោមបដិ-*

---

១– វិនយបិដក មហាវគ្គ សៀវ. ៦ ទំព័រ ៥ ។

*លោមម្តងទៀត ។ លុះទ្រង់ជ្រាបច្បាស់យ៉ាងនេះហើយ ទើបទ្រង់បន្លឺនូវឧទានគាថាយ៉ាងនេះថា*(ក)

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
វិធូបយំ តិដ្ឋតិ មារសេនំ
សុរិយោវ ឱភាសយមន្តលិក្ខំ ។

“ធម៌ទាំងឡាយ កើតប្រាកដដល់ខីណាសវព្រាហ្មណ៍ ដែលជាអ្នកមានព្យាយាម ញាំងកិលេសឲ្យក្តៅ ជាអ្នកដុតបំផ្លាញកិលេសក្នុងកាលណា ខីណាសវព្រាហ្មណ៍នោះ រមែងកំចាត់បង់នូវមារព្រមទាំងសេនានៃមារហើយឋិតនៅ ក្នុងកាលនោះ បីដូចព្រះអាទិត្យរះឡើងកំចាត់បង់នូវងងឹត ហើយធ្វើឲ្យអាកាសភ្លឺរុងរឿងដោយរស្មីរបស់ខ្លួនហើយឋិតនៅដូច្នោះឯង”។

សប្តាហ៍ទី ២– *ព្រះពិជិតមារស្តេចចេញពីពោធិបល្លង្ក ក្រោមពោធិព្រឹក្ស ទៅប្រថាប់នៅឦសាននៃពោធិមណ្ឌល ទ្រង់រំពឹងនូវសព្វញ្ញុតញ្ញាណដែលទ្រង់បានសម្រេច មិនប៉ព្រិចព្រះនេត្រាអស់រយៈ ៧ ថ្ងៃ ។ ទីនេះមាននាមប្រាកដថា “អនិមិសចេតិយ” ។*

---

១. វិនយបិដក មហាវគ្គ លេខ ៦ ទំព័រ ៣ ។

សប្តាហ៍ទី ៣– ព្រះសុគតមុនីនាថ ស្តេចក្រោកពីអនិមិសចេតិយហើយ ស្តេចចង្ក្រមទៅវិញទៅមកនៅចន្លោះអនិមិសចេតិយនឹងពោធិបល្ល័ង្កអស់ការៈ ៧ ថ្ងៃ ។ ទីនេះមាននាមប្រាកដថា "រតនចង្ក្រមចេតិយ" ។

សប្តាហ៍ទី ៤ – ព្រះបរមលោកនាថ ស្តេចចេញពីរតនចង្ក្រមចេតិយ ទៅប្រថាប់នៅទិសពាយ័ព្យពោធិមណ្ឌល ទ្រង់ពិចារណានូវអភិធម្មអស់ការៈ ៧ ថ្ងៃ ។ ទីនេះមាននាមប្រាកដថា "រតនឃរចេតិយ" ។

សប្តាហ៍ទី ៥ – ព្រះអរហំសម្មាសម្ពុទ្ធ ស្តេចពុទ្ធដំណើរទៅកាន់អជបាលនិគ្រោធ រំពឹងនូវពោធិញាណដែលទ្រង់បានឃើញ (ត្រាស់ដឹង) សោយធម្មបីតិហើយប្រថាប់នៅដោយវិមុត្តិសុខ ។ កាលនោះមារបិត្តបាប បានបញ្ជូនមារធីតាទាំង ៣ គឺ នាងតណ្ហា ១ នាងអរតី ១ នាងរាគា ១ ទៅល្បួងព្រះអង្គ ។ កាលនោះព្រះសុគតផុតវិស័យមារ ត្រាស់ចំពោះមារធីតាទាំងឡាយថា[១]

យស្ស ជិតំ នាវជីយតិ
ជិតមស្ស នោយាតិ កោចិ លោកេ
តំ ពុទ្ធមនន្តគោចរំ
អបទំ កេន បទេន នេស្សថ ។

---
១. ឯកនិបាត ។

យស្ស ជាលិនី វិសត្តិកា
តណ្ហា នត្ថិ កុហិញ្ចិ នេតវេ
តំ ពុទ្ធមនន្តគោចរំ
អបទំ កេន បទេន នេស្សថ ។

“ជ័យជំនះរបស់ព្រះសម្មាសម្ពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ មិនមានកិលេសណាមួយក្នុងលោកទៅតាមជ័យជំនះរបស់ព្រះសម្មាសម្ពុទ្ធអង្គនោះបានឡើយ, នាងទាំងឡាយនឹងនាំព្រះពុទ្ធអង្គនោះ ដែលព្រះអង្គមានគោចរមិនមានទីបំផុត ទ្រង់មិនមានកិលេស ដូចជាស្នាមជើង ដោយកិលេស ដូចជាស្នាមជើងម្ដេចបាន ?

មួយទៀត, ព្រះពុទ្ធអង្គណា មិនមានតណ្ហា ជាបណ្ដាញជាពិសពុល ដើម្បីនាំទៅក្នុងភពណាមួយ, នាងទាំងឡាយនឹងនាំទៅឲ្យព្រះពុទ្ធអង្គនោះ ដែលមានគោចរមិនមានទីបំផុត ព្រះអង្គមិនមានកិលេស ដូចជាស្នាមជើង ដោយកិលេសដូចជាស្នាមជើង ដូចម្ដេចបាន ?”

BIBLIOTHEQUE P.P. D'EXTREME ORIENT



មារធីតាទាំងឡាយ លុះបានស្ដាប់នូវក្រសែនៃព្រះតម្រាស់យ៉ាងនេះហើយ ក៏អន្តរធានបាត់ទៅ ។

លំដាប់នោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះ ហុំហុំកជាតិកៈ ជាអ្នកធ្លាប់តែគម្រាមអ្នកផងថា "ហុំហុំ" ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ពោលពាក្យជាសារាណីយកថា ហើយអង្គុយក្នុងទីសមគួរមួយ ទើបទូលសួរថា ព្រះគោតម! បុគ្គលដែលបានឈ្មោះថា ព្រាហ្មណ៍នោះ តើដោយហេតុប៉ុន្មានយ៉ាង? ធម៌អ្វីដែលធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍បាន? ព្រះភគវន្តមុនី ត្រាស់ឧទានគាថា ឆ្លើយថា[1]

យោ ព្រាហ្មណោ ពាហិតបាបធម្មោ
និហុំហុំកោ និក្កសាវោ យតត្តោ
វេទន្តគូ វុសិតព្រហ្មចរិយោ
ធម្មេន សោ ព្រហ្មវាទំ វទេយ្យ
យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេ ។

"អ្នកណាមានបាបធម៌បន្សាត់បង់ហើយ លះលែងគម្រាមអ្នកផងថា ហុំហុំ ហើយ មានទឹកអម្ចត់គឺរាគាទិក្កិលេសលះចោលហើយ មានចិត្តសង្រួមហើយ ដេះដល់នូវវេទ (មគ្គញាណទាំង ៤) មានមគ្គព្រហ្មចរិយៈចប់ហើយ, មួយទៀត អ្នកណា

---
១- វិនយបិដក មហាវគ្គ បឋមភាគ សៀវ. ៦ ទំព័រ ៨ ។

មិនមានគំនរគឺរាគាទិក្កិលេសក្នុងលោក អ្នកនោះទើបគួរហៅជាព្រាហ្មណ៍ដោយធម៌បាន" ។

ព្រះពិជិតមារ ស្តេចគង់ក្រោមអជបាលនិគ្រោធនេះអស់ពារៈ ៧ ថ្ងៃ ។ ទីនេះមាននាមប្រាកដថា "អជបាលនិគ្រោធ" ។

សប្តាហ៍ទី ៦_ ព្រះមានព្រះភាគ ស្តេចទ្រង់ចេញពីអជបាលនិគ្រោធហើយ ចូលទៅប្រថាប់ក្រោមមុចលិន្ទព្រឹក្ស សោយវិមុត្តិសុខ ដែលកើតពីសមាបត្តិក្នុងទីនោះ ។ កាលនោះ មហាមេឃ ពុំដូកាល បង្អុរទ្ប់ភ្លៀងធំអស់ពារៈ ៧ ថ្ងៃ ។ មាននាគរាជមួយចេញពីលំនៅខ្លួន ហើយមកពេនព័ទ្ធព្រះកាយព្រះបរមសាស្តា ៧ ជុំ ដោយភេនរបស់ខ្លួន បិទបាំងការពារភ្លៀងមិនឲ្យត្រូវទឹកបាន ។ ព្រះបរមលោកនាថ ទ្រង់ជ្រាបចិត្តនាគរាជហើយ ទើបបន្លឺឧទានគាថាក្នុងពេលនោះថា(១)

សុខោ វិវេកោ តុដ្ឋស្ស
សុតធម្មស្ស បស្សតោ
អព្យាបជ្ជំ សុខំ លោកេ
បាណភូតេសុ សញ្ញមោ
សុខា វិរាគតា លោកេ

---

១_ វិនយបិដក មហាវគ្គ បឋមភាគ សៀវ. ៦ ទំព័រ ១០ ។

គាថាធំ សមត្តគាថា

អស្មិមានស្ស វិនយោ

ឯតំ វេ បរមំ សុខំ ។

"សេចក្ដីស្ងាត់ចាកកិលេសនៃអ្នកត្រេកអរ ដោយមគ្គញាណ មានធម៌បេះដឹងហើយ ឃើញធម៌ដោយញាណចក្ខុ ជាគុណនាំឲ្យកើតសេចក្ដីសុខ, ការមិនព្យាបាទ ការសង្រួមចំពោះសត្វទាំងឡាយ ជាគុណនាំឲ្យកើតសេចក្ដីសុខក្នុងលោក, ការវៀរណាយចាករាគៈ គឺការប្រព្រឹត្តិកន្លង នូវកាមទាំងឡាយ គឺជាគុណនាំឲ្យកើតសេចក្ដីសុខក្នុងលោក, ការកំចាត់បង់នូវអស្មិមានះណា ការកំចាត់បង់នូវអស្មិមានះនោះឯង ជាបរមសុខ" ។

*ព្រះជិនស្រីទ្រង់គង់ក្រោមមុចលិន្ទព្រឹក្សអស់រយៈ ៧ ថ្ងៃ ។ ទីនេះមាននាមប្រាកដថា " មុចលិន្ទស្រះ " ។*

សប្ដាហ៍ទី ៧ *ទីបំផុតថ្ងៃទី ៧ ព្រះមុនីនាថចេញពីមុចលិន្ទព្រឹក្សហើយចូលទៅកាន់រាជាយតនព្រឹក្ស ទ្រង់ពក់ព្រះភ្នែនពែនព្រះបាទក្រោមរាជាយតនព្រឹក្សអស់រយៈ ៧ ថ្ងៃទៀត សោយវិមុត្តិសុខដែលកើតពីសមាបត្តិ ។ កាលនោះ មានពាណិជពីរនាក់ ឈ្មោះតបុស្ស ១, ភល្លិក ១*

បាននាំសត្វផងទាំងសត្វជុំ ចូលទៅបូជាព្រះជិនស្រី ។ ព្រះមហាមុនីទ្រង់ទទួលភោជននេះដោយបាត្រថ្មកែវ ដែលមហារាជទាំង ៤ នាំយកមកថ្វាយ ហើយទ្រង់ធ្វើភត្តកិច្ចក្នុងទីនោះ ។ ពាណិជទាំងពីរនាក់នោះសូមដល់នូវព្រះតថាគតនឹងព្រះធម៌ជាសរណៈស្មើដោយជីវិត ហើយក៏បាននាមបញ្ញត្តិជាទ្វេវាចិកឧបាសក មុនដំបូងក្នុងលោក ។ ព្រះមហាមុនីស្តេចគង់ក្រោមរាជាយតនព្រឹក្សអស់វារៈ ៧ ថ្ងៃ ។ ទីនេះមាននាមប្រាកដថា “រាជាយតនៈ” ។ គណនាគ្រាកប់តាំងពីថ្ងៃដែលទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណមក ហើយប្រថាប់ក្នុងសត្តមហាឋានអស់វារៈ ៧ ថ្ងៃ ៧ ដង ត្រូវជា ៤៩ ថ្ងៃ ។

## ៥. ទ្រង់ប្រកាសព្រះអង្គជាព្រះពុទ្ធ

លុះទ្រង់បានត្រាស់ដឹងបរិបូណ៌ហើយ ព្រះមានព្រះភាគទ្រង់ប្តេជ្ញាព្រះអង្គថា ព្រះពុទ្ធដូចព្រះតម្រាស់ដែលត្រាស់បញ្ជាក់ចំពោះទោណព្រាហ្មណ៍ថា (១)

“ ម្នាលព្រាហ្មណ៍ ! តថាគតមិនកើតជាទេវតា ជាគន្ធព្វ ជាយក្ស ជាមនុស្សទេ ។ ម្នាលព្រាហ្មណ៍ ! បើតថាគតកើតជាទេវតា ជាគន្ធព្វ ជាយក្ស ជាមនុស្ស ព្រោះ

១. បឋមបណ្ណាសកៈ ចក្កវគ្គ ច. អំ. សៀវ. ៤២, ទំព័រ ៩២ ។

តថាគត មិនទាន់លះបង់អាសវៈទាំងឡាយណា អាសវៈទាំងឡាយនោះ តថាគត បានលះបង់ស្រឡះហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀត ។

ម្នាលព្រាហ្មណ៍! ផ្កាព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី កើតក្នុងទឹក បរិវេនក្នុងទឹក ដុះផុតពីទឹក មិនជាប់ដោយទឹកវិញទេ យ៉ាងណាមិញ, ម្នាលព្រាហ្មណ៍! តថាគតដែលកើតក្នុងលោក បរិវេនក្នុងលោក រមែងគ្របសង្កត់នូវលោក មិនបានជាប់ជំពាក់ដោយលោកវិញ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍! អ្នកចូរចំណាំតថាគតថា "ព្រះពុទ្ធ" ដូច្នេះចុះ" ។

(នៅមានត)

# ព្រះនិព្វាន ឬ និព្វាណ

លោក គុម្ភដ៍ជង់ រ៉ូបេរត៍ រៀបរៀង

ក្រមការ ជុំ-មៅ ប្រែជាភាសាខ្មែរ

---

ក្នុងពុទ្ធសាសនា, គោលចារឹកដែលពុទ្ធសាសនិកជន ជាអនេកសំដៅយក ដោយខំធ្វើសីល ធ្វើទានទឹងខំការនានានោះ គឺដើម្បីឲ្យបានជាតិកំណើតល្អទៅអនាគតកាល; ឯចំណែកអ្នកបួស ដែលខំកសាងតាំងពីច្រើនជាតិមក សំដៅយកថ្នាក់ខ្ពស់ ជាងនោះទៅទៀត គឺព្រះនិព្វាន ហើយក៏ខំប្រតិបត្តិតាមគោលចារឹក តាមផ្លូវដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងទុកមក អ្នកប្រាជ្ញម្នាក់ឈ្មោះ សង្ឃក្រ បានចារឹកទុកថា ដែលចេញចាកវដ្ដសង្សារទៅបំពេញផ្នួសជាបព្វជិតនោះ គឺព្រោះតែប្រាថ្នាឲ្យបានដល់ព្រះនិព្វាន ១ មុខប៉ុណ្ណោះ ។

ចំណែកខាងអ្នកដែលជាឃរាវាស ក៏មានបំណងប្រាថ្នាយកទីនេះដែរ ប៉ុន្តែ គង់នឹងមានជាតិណាមួយទៅខាងមុខ នឹងចូលបំពេញផ្នួសខំបំពេញការនាំយកថ្នាក់ខ្ពស់នេះ ។

គម្ពីរសំយុត្តនិកាយមានសំដែងថា ក្នុងរូបបុគ្គលដែលរួចចាកទុក្ខ គឺបុគ្គលដែលបានច្បាស់នូវអរិយសច្ចទាំង ៤ ប្រការមានកើតប្រាជ្ញាជាគ្រឿងផុតទុក្ខ គឺគ្មានពូជណានឹងកើតទៀត ព្រោះបានធ្វើបំពេញកិច្ចគ្រប់ស្ថាន ហើយគ្មានត្រឡប់មកក្នុងលោកនេះវិញទេ នេះហើយដែលហៅថាចេះ ។ -

គម្ពីរមហាវគ្គសំដែងថា មានផ្លូវ២យ៉ាង ដែលអ្នកបួសត្រូវវៀរសាង ចេញ; ផ្លូវទី១គឺដែលបណ្តោយខ្លួនឲ្យលុះក្នុងអំណាចកាមគុណដែលហៅថា កាមសុខល្លិកានុយោគ ផ្លូវនេះជាផ្លូវអាក្រក់គ្រោតគ្រាតហើយឥតប្រយោជន៍; ផ្លូវទី២ គឺ ដែលធ្វើខ្លួនឲ្យនឿយហត់ឥតអំពើដែលហៅថា អត្តកិលមថានុយោគ ផ្លូវនេះជាផ្លូវពិបាក ហើយឥតប្រយោជន៍; តថាគតបានវៀរសាងលះបង់ផ្លូវទាំង ២ យ៉ាងនេះចោលចេញហើយ ។ ដោយអំណាចលះបង់នេះ តថាគតបានរកឃើញផ្លូវកណ្តាលដែលហៅថា មជ្ឈិមបដិបត្តិ ជាផ្លូវនាំទៅកាន់ពន្លឺភ្លឺស្វាង, នាំទៅកាន់ប្រាជ្ញា, ទៅកាន់ទីសុខ, ទៅកាន់ទីចេះ, ទៅកានវិជ្ជាពិតប្រាកដ, នឹងនាំទៅកាន់ព្រះនិព្វាន ។

គម្ពីរមជ្ឈិមនិកាយមានសំដែងយ៉ាងលះ ហើយមានបែបផែនជាក់ច្បាស់ជាងខាងលើនេះទៅទៀត គឺថាព្រះនិព្វាននោះ ជាកន្លែងដែលព្រះអរហន្តទាំងឡាយ លោករំលត់ជាតិលោក; ព្រះនិព្វានជាគោលរបស់ព្រះអរហន្ត; ព្រះនិព្វានជាទីបំផុតរបស់ព្រះអរហន្ត ។

សេចក្តីទាំង ៣ បទដែលស្រង់យកមកពីក្នុងគម្ពីរទាំង ៣ នេះ ព្រមទាំងសេចក្តីឯទៀតផ្សេង ៗ ដែលមានជាច្រើន ធ្វើឲ្យយើងឃើញថា គោលដៅកំពូទីបំផុតរបស់ព្រះពុទ្ធសាសនា គឺសេចក្តីឃើញច្បាស់នូវព្រះនិព្វាន ក្រៅពីនោះសុទ្ធតែជាកិច្ចដែលធ្វើ ដើម្បីឲ្យបានដល់ទៅទីនោះ

ប៉ុណ្ណោះ, ឯអរិយមគ្គឬផ្លូវដ៏ប្រសើរនោះ ជាផ្លូវដែលនាំឲ្យរកឃើញវិជ្ជា បំផុត គឺព្រះនិព្វាននេះឯង ។

ពិតមែនតែន័យផ្សេង ៗ ដែលសំដែងអំពីអដ្ឋង្គិកមគ្គនោះ ស្រណុក ងាយយល់ដល់យើងកល់គ្នា ទោះជាតិនានាក្នុងបស្ចិមប្រទេសក៏ដោយ; ចំណែកព្រះនិព្វាននោះមិនមែនងាយយល់ដូច្នោះឡើយ ។

តាមដែលបានសិក្សាមកឃើញថា ធម៌អាថ៌ទាំងឡាយក្នុងព្រះពុទ្ធ-សាសនា ប្រហែលជាគ្មានគោលត្រង់ណាផ្សេងទៀត ដែលនាំឲ្យមាន សេចក្ដីជជែកប្រកែកគ្នា ដូចត្រង់កន្លែងព្រះនិព្វាននេះឡើយ ។ បាន ជាថាដូច្នេះ ព្រោះគោលត្រង់នេះជាគោលធំបំផុត ជាទីសម្រេចរបស់ អ្នកដែលសំដៅយក ។ ដើម្បីឲ្យបានព្រះនិព្វាននោះ ពុទ្ធបរិស័ទបាន តយុទ្ធមកជាច្រើនជាតិ នឹងគណនាគ្រាកប់ពុំបាន ។ ដូច្នេះ, យើងត្រូវ ទំរកន័យផ្សេង ៗ ដែលព្រះគន្ថរចនាចារ្យទាំងឡាយ លោកបានចារឹកទុក ក្នុងគម្ពីរនានា ដើម្បីនឹងបានជួយដល់យើងឲ្យកើតជាគំនិត ១ ឬជាសេចក្ដី យល់ឃើញ ១ ឡើង, ប្រសិនបើជាយើងធ្វើភាននោះឃើញថាជាការ ស្រួលល្អណាស់ ។

ជាដំបូងយើងត្រូវនិយាយអំពីពាក្យដែលហៅថា និញ្វាន ។ និព្វាន នោះមានតាំងពីមុនកើតមានព្រះពុទ្ធសាសនាទៅទៀត ហើយក្នុងជាន់នោះ

ពាក្យនេះមានន័យដូច្នេះទៅហើយ គឺភ័ព្វសំណាងខ្ពស់បំផុត នឹងសេចក្តីរលត់ជាតិកំណើតក្នុងលោកនេះ ។

គម្ពីរសំយុត្តសុត្ត សំដែងថាមានពុទ្ធបរិស័ទជាច្រើនសួរព្រះសារីបុត្តត្ថេរថា និព្វាន, និព្វាន នោះតើជាអ្វី? ព្រះសារីបុត្តត្ថេរតបវិញថា ដែលហៅថា និព្វាន នោះ គឺសេចក្តីរលត់នូវលោភៈ ទោសៈ នឹងមោហៈ ។

យើងបានឃើញសេចក្តីមួយក្នុងគម្ពីរធម្មបទសំដែងថា: បើកាលណាកំចាត់បង់នូវសង្ខារបានហើយ នឹងបានច្បាស់នូវព្រះនិព្វាន ។

គម្ពីរសុត្តនិបាតសំដែងថា កន្លែងណាដែលគ្មានអ្វីសោះ, ដែលគ្មានជំពាក់នឹងអ្វីសោះ, ដែលមិនមែនជាធម្មតា, កន្លែងនោះហើយដែលហៅថានិព្វាន, ហៅថាផុតចាស់ផុតស្លាប់ ។ សេចក្តីទាំងប៉ុន្មាននេះ នាំឲ្យយើងយល់ថា និព្វាននេះបានដោយមនុស្សម្នាក់កំចាត់បង់នូវលោភៈ ទោសៈ មោហៈ នឹងសង្ខារ គឺ សេចក្តីតាក់តែង ព្រមទាំងអំពើដែលធ្វើមកពីជាតិមុន ៗ ចេញ ។

គម្ពីរធម្មបទសំដែងថា: អ្នកណាដែលរត់រួចផុតអំពីវដ្តសង្សារបានឆ្លងផុតទៅត្រើយនាយ ហើយបានឡើងលើច្រាំង គឺបានសំឡឹងពិចារណាច្រើន មិនដុនដាបខ្វាក់ខ្វាយ ឥតសេចក្តីលោភ បានលះបង់

នូវវត្ថុដែលកស្រ័យនៅលើដីគោល ហើយបានដល់នូវព្រះនិព្វាន អ្នកនោះហើយតថាគតហៅថាជាព្រាហ្មណ៍ពិត ៗ ។

គម្ពីរសុត្តនិបាត សំដែងថា វត្ថុជាច្រើនរាប់មិនអស់ក្នុងលោកនេះ គេតែងបានឃើញ, បានឮ, បានគិត, ត្រង់កិរិយាដែលកំចាត់បង់នូវសេចក្តីប្រាថ្នា ឬការអាក់អន់ចិត្តក្នុងវត្ថុទាំងនោះដែលមកប៉ះពាល់ហើយ ឈ្មោះថា អមតនិព្វាន ។ អ្នកឯណាដែលបានយល់ច្បាស់សេចក្តីទាំងនេះ អ្នកនោះឯងជាមនុស្សមានគំនិត ជាមនុស្សមិនប្រឡោតដោយលោកធម៌ឡើយ ព្រោះបានឃើញធម៌ច្បាស់ប្រាកដណាស់, អ្នកឯណាដែលវៀចាកពីសេចក្តីប្រាថ្នាក្នុងលោក អ្នកនោះបានសេចក្តីក្សេមក្សាន្ត ។

គម្ពីរអេកធ្វេយ្យសុត្ត មានសំដែងថា បើពុទ្ធបរិស័ទណាមួយបានកាត់បំបាត់នូវកាមគុណអស់ហើយ, បានកាត់បំបាត់នូវសេចក្តីជឿខុសថា "របស់ទាំងឡាយក្នុងលោកនេះទៀង" បានហើយ, បានបំបាត់នូវសេចក្តីល្ងង់ហើយ, មានសេចក្តីប្រាថ្នាឲ្យបានស្គាល់ឲ្យបានដល់បែបផែននៃព្រះអរហត្ត ឬឲ្យដល់សេចក្តីទំនេចិត្តគំនិត នោះត្រូវឲ្យតាំងនៅក្នុងសេចក្តីត្រង់ដោយពេញទី ត្រូវឲ្យស្លូតត្រង់នឹងសេចក្តីស្ងប់ស្ងាត់របស់ចិត្តដែលក្លឹមកពីខាងក្នុង, ត្រូវឲ្យពិចារណាមើលរបស់ទាំងឡាយ, ត្រូវឲ្យនៅស្ងាត់តែម្នាក់ឯង ។

យើងត្រូវបន្ថែមសេចក្តីទាំង ២ ខាងក្រោមនេះថែមទៀត ដែលមានសំដែងក្នុងគម្ពីរអភិធម្មកោស ។ សេចក្តីទី ១ មានសំដែងថា សេចក្តីលះបង់ជ្រះស្រឡះ, សេចក្តីដែលបរិសុទ្ធិ, សេចក្តីដែលស្ងិតស្រពោន, សេចក្តីដែលស្ងប់ស្ងាត់, សេចក្តីដែលកំចាត់បំបាក់បង់, សេចក្តីដែលរលាយរលត់សេចក្តីដែលផុតចាកទុក្ខទាំងអស់ជាស្រឡះ, សេចក្តីដែលមិនកើតទៀត, សេចក្តីដែលមិនលុះក្នុងអំណាចនៃអវិជ្ជា, សេចក្តីដែលទុក្ខមិនបង្កើតឡើងទៀតនោះហើយ ជាសេចក្តីស្ងិតស្រពោន សេចក្តីដ៏ឧត្តមដែលត្រូវដឹងថាសេចក្តីលះបង់ចោលនូវឧបាទិចេញ ជាសេចក្តីរម្ងាប់នូវតណ្ហា ជាសេចក្តីស្ងប់ស្ងាត់ ជាសេចក្តីបំបាក់បំបាត់បង់, ជាព្រះនិព្វាន ។ សេចក្តីទី ២ សំដែងថាសច្ចទី ៣ ឬ ព្រះនិព្វាននោះ គឺសេចក្តីបំបាក់បង់នូវទុក្ខនោះឯងដែលត្រូវយល់ថាជាសេចក្តីកំចាត់បង់នូវតណ្ហា សេចក្តីដែលធ្វើនូវតណ្ហាឲ្យស្ងប់ស្ងាត់ សេចក្តីដែលបោះបង់ចោលនូវតណ្ហា សេចក្តីដែលរួចពីតណ្ហា ។

ន័យក្នុងគម្ពីរទាំងប៉ុន្មាន ដូចបានពោលមកខាងលើនេះ មានបែបតែម្យ៉ាងក៏ពិតមែន ប៉ុន្តែបានសេចក្តីផ្សេងពីគ្នាខ្លះ ដែលយើងត្រូវតែចាំក្នុងវេលានេះ គឺន័យខ្លះថា សេចក្តីលត់នូវលោភៈ ទោសៈ និងមោហៈ, សេចក្តី ១ ទៀត និយាយពីផុតពូជមិនកើតទៀត, មានន័យ ២ ដែលសំដែងថាព្រះនិព្វាននោះ គេអាចនឹងបានតាំងពីកាលមានរូបរស់នៅ, ន័យ ១

ទៀតថា អ្នកឯណាដែលបានដល់ព្រះនិព្វាននោះ ជាអ្នកបរិបូណ៌ដោយសេចក្តីសំឡឹងច្រើន; គម្ពីរសុត្តនិបាតសំដែងថាអ្នកឯណា ដែលបានដល់ព្រះនិព្វាននោះជាមនុស្សព្រិចារណាច្រើន ហើយស្ងួត,; ខាងក្រោយនេះគាថាទី ១ សំដែងថាអ្នកឯណាដែលបានដល់ព្រះនិព្វាននោះ បានស្គាល់នូវសេចក្តីដែលផុតចាកទុក្ខ ៗ

តាមដែលបានសង្កេតពិនិត្យមើលសេចក្តីទាំងប៉ុន្មាន ដូចបានពោលមកខាងលើ មិនឃើញមានន័យណាមួយ សំដែងអំពីព្រះនិព្វានថាសូន្យទទេ ជាផុតអ្វី ៗ ទាំងអស់ ដូចជាអ្នកកាន់ពុទ្ធសាសនាគណៈខ្លះនឹងជាតិអឺរ៉ុបខ្លះ ដែលគេធ្លាប់ជឿមកដល់សព្វថ្ងៃនេះឡើយ ៗ

គម្ពីរសំយុត្តនិកាយ បានសំដែងដោយច្បាស់ប្រាកដ អំពីយមកភិក្ខុដែលមានចិត្តវើវាយ ដោយយល់ថាភិក្ខុ ១ អង្គដែលគ្មានប្រព្រឹត្តល្មើសអ្វីសោះ វេលាដែលបានទំលាយខន្ធទៅនោះ រលត់ទាំងអស់គឺគ្មាននៅសល់អ្វីជាខាងក្រោយពេលដែលស្លាប់ ហើយវេលានោះព្រះសារីបុត្តបានកែដំរង់យមកភិក្ខុ ពីគំនិតខុសនោះបានឡើងវិញ ៗ

មាននិទាន ១ សំដែងអំពីពុទ្ធបរិស័ទ ១ អង្គឈ្មោះ ធព ដែលបានហោះទៅកណ្តាលអាកាសដោយចិត្តឯង នៅចំពោះព្រះភក្ត្រព្រះសម្មាសម្ពុទ្ធ ហើយចូលនិព្វានក្នុងវេលានោះឥតមានសល់អ្វី ជាកងកាយបន្តិចសោះ ៗ ព្រះពុទ្ធអង្គមានព្រះបន្ទូលថា អណ្តាតភ្លើងដែលថយបន្តិចម្តង ៗ

ហើយរលត់ទៅ គេមិនអាចនឹងដឹងថាអណ្ដាតភ្លើងនោះទៅឯណា មានប្រការដូចម្ដេចមិញ, ឯព្រះអរហន្តដែលលោករួចខ្លួនស្រឡះពីវដ្ដសង្សារ លោកបានផ្ដាច់កាត់នូវសេចក្ដីប្រាថ្នា ហើយដែលលោកបានដល់ទីសុខឥតប្រែប្រួលនោះ វេលាដែលលោកចំលាយខន្ធទៅ ក៏គេមិនអាចនឹងដឹងបាន មានប្រការដូច្នោះឯង; សេចក្ដីត្រង់នេះ មានអ្នកប្រាជ្ញជាតិបារាំងសេសម្នាក់ឈ្មោះ លុីដឺឡាវ៉ាឡេពូស្សាំង កត់សំគាល់ថា ៖ ទាននេះនិយាយច្បាស់ប្រាកដណាស់ គឺភ្លើងក៏មិនសូន្យ ព្រះអរហន្តក៏មិនសូន្យ, ឯព្រះអរហន្តដែលលោកបានដល់នូវព្រះនិព្វាននោះ មិនមែនជាមនុស្សមានជីវិត មិនមែនជាអត្តភាព មិនមែនជារូបសោយអារម្មណ៍ មិនមែនជារូបដែលមានចិត្តត្រេចទៅ ដូចកាលពីដើមនោះឡើយ ។

គម្ពីរនេត្តិបករណ៍ មានសំដែងសេចក្ដី ២ បទដូចមានខាងក្រោយនេះ ។ បទទី ១ សំដែងថា អ្នកឯណាដែលគិតថាគេអាចនឹងចេញពីជាតិដោយឥតជាតិបាន អ្នកនោះឯងមិនរបូតរួចពីជាតិឡើយ ។ បទទី ២ សំដែងថា ព្រះអរហន្តដែលលោកបានដល់នូវព្រះនិព្វាននោះ ជ្រៅពន់ប្រមាណណាស់ មិនអាចនឹងវាស់ មិនអាចនឹងគណនាបាន; លោកថាដែលបានដល់នូវព្រះនិព្វាននោះ គឺព្រោះកំចាត់បំបាក់បង់នូវសេចក្ដីប្រាថ្នា សេចក្ដីស្អប់ខ្ពើម, ការគុំគួននឹងសេចក្ដីល្ងង់បានអស់ហើយ ។

ក្នុងបទទី ១ នោះ យើងឃើញសេចក្ដីថា គេមិនអាចនឹងចេញផុតពី

ជាតិដោយសូន្យទទេឡើយ ព្រោះសេចក្ដីដែលថាឥតជាតិនោះ គឺសូន្យទទេនោះឯង ហើយក្នុងបទទី ២ សំដែងអំពីសេចក្ដីកំចាត់បំបាក់ ប៉ុន្តែកំចាត់បំបាក់នោះ គឺកំចាត់បំបាក់នូវសេចក្ដីប្រាថ្នា, សេចក្ដីស្អប់ខ្ពើម, ការគុំគួន, នឹងសេចក្ដីល្ងង់, មិនមែនកំចាត់បំបាក់អ្វីទាំងអស់ ។

បំណែកខាងពួកជនដែលនៅក្នុងបស្ចិមប្រទេស យល់ថាព្រះនិព្វានជាសភាវៈសូន្យទទេនោះ មកពីមិនបានព្យាយាមរិះរកន័យឲ្យបានជ្រៅទូលាយ ។ បំណែកខាងពួកជនក្នុងបូពាប្រទេសវិញ យល់ថាអ្វី ៗ ទាំងអស់មិនដែលមកពីទទេ ហើយមិនដែលត្រឡប់ទៅរកទទេវិញ ។ តាមពិតខាងក្រោយសេចក្ដីមរណៈដែលជាធម្មតារបស់សត្វនោះ ធាតុផ្សេង ៗ ដែលផ្សំផ្គុំគ្នាបានជារូបសត្វ ក៏បែកធ្លាយរលាយចាកគ្នាចេញតាមភាពសានទីទៃពីគ្នា ប៉ុន្តែក្នុងធាតុនីមួយ ៗ ទាំងនេះ ឬ ក្នុងអនុធាតុទាំងឡាយរបស់ធាតុទាំងនេះ ឥតមានធាតុណាមួយសោះសូន្យឡើយ គឺនឹងទៅប្រជុំផ្គុំគ្នាជាថ្មីកើតជារូបក្នុងបណ្ដោះអាសន្នទៀតទៅខាងមុខ ។ សេចក្ដីនេះឃើញច្បាស់ណាស់ គ្មានអ្វីឲ្យច្បាស់ជាងនេះទៅទៀតឡើយ ។ តាមសេចក្ដីទាំងប៉ុន្មានដែលបានពណ៌នារៀបរាប់មកខាងលើនេះ ឃើញថាតាមដោយយោបល់របស់ព្រះសម្មាសម្ពុទ្ធនោះ ព្រះនិព្វានហាក់ដូចជាមិនមែនពេកសោះសូន្យជាស្រឡះឡើយ ។

សេចក្ដីនេះបើអធិប្បាយមកទាល់ប៉ុណ្ណោះនេះ គឺនិយាយតែពីព្រះនិព្វាន

ដែលនៅក្នុងលោក ឬ ដែលពាក្យបាលីហៅថា សឧបាទិសេស-និព្វាន ។ ក្នុងគម្ពីរឥតិវុត្តកៈ អធិប្បាយថា ពុទ្ធបរិស័ទណាបាន រលាស់ខ្លួន ឲ្យរួចផុតពីសេចក្ដីជំពាក់ក្នុងលោក, ផុតពីសេចក្ដីវង្វេង ដោយអំណាចបានចំរើនមេត្តាភាវនា បានហាត់ហ្វឹកហ្វឺនចិត្ត ហើយបាន ដល់នូវព្រះអរហត្តដោយអំណាចផលបុណ្យជាឧបនិស្ស័យពីជាតិមុនៗមក ពុទ្ធបរិស័ទនោះ ក៏អាចនឹងស្គាល់នូវព្រះនិព្វានបាន ។ ពុទ្ធបរិស័ទ ណាដែលបានដល់ទីនេះហើយ បាននាមថាព្រះអរហន្តវិសេស ពិតតែ មានរូបនៅរស់មែន តែឯចិត្តនោះថាស្អាតគ្មានសៅហ្មង ដូចគ្នានឹងចិត្ត ដែលមានខ្លួនឆ្ងាយទៅហើយ ។ ព្រះអរហន្តលោកមានរូបរស់នៅតទៅ ដូចជាបុថុជ្ជនធម្មតាដែរ ខ្លួនលោកក៏ត្រូវការបរិភោគអាហារ ហើយដោយ អំណាចអាហារនេះ ធាតុផ្សេងៗដូចយ៉ាង គំនិត, កំឡាំង, ប្រាជ្ញាស្មារតី, ក៏គង់នៅមានជានិច្ច ទាំងវេទនា, សញ្ញា, សង្ខារ, ក៏នៅប្រព្រឹត្តទៅ តាមមុខក្រសួងតែរៀងខ្លួន; ឯសង្ខារក្ខន្ធគង់នៅ, ទាំងវិញ្ញាណក្ខន្ធក៏គង់ នៅដែរ ប៉ុន្តែវិញ្ញាណបរិសុទ្ធណាស់ ព្រោះសេចក្ដីវង្វេង, សេចក្ដីប្រាថ្នា, សេចក្ដីដែលជាប់ជំពាក់នឹងភព, សេចក្ដីស្អប់ខ្ពើមគុំគួន, នោះបានកំចាត់ បោះបង់ចោលជាស្រេច ដោយអំណាចសេចក្ដីព្យាយាមពីជាតិមុនៗ មក និងដោយអំណាចសេចក្ដីចំរើនមេត្តាភាវនាក្នុងជាតិនេះ ។ កាលណា ព្រះអរហន្តទំលាយខន្ធទៅនោះ ឥតមានប្រែប្រួលភាពសណ្ឋានអ្វីឡើយ

ព្រោះកាលដែលរូបលោកនៅរស់នោះ លោកបានដល់ទៅមាត់ទ្វារព្រះនិព្វានទៅហើយ ។

សេចក្តីប៉ុណ្ណេះ ត្រង់ដែលព្រះអរហន្ត លោកចេញពីនិព្វានមានរូបចូលក្នុងនិព្វានឥតរូប ដូចមានសេចក្តីដែលនឹងពណ៌នាទៅនេះ៖

និព្វានដែលត្រូវបានក្នុងកាលរូបរស់នៅនោះ ព្រះអរហន្តលោកនៅមានធាតុផ្សេង ៗ ដែលមានរូប ឬឥតរូបផ្គុំគ្នាឡើងបានជាអត្តភាពរបស់មនុស្សនៅឡើយ ត្រង់នេះហើយដែលយើងហៅថា និព្វានមានឧបាទិ ឬថាសឧបាទិសេសនិព្វាន គឺមានខន្ធទាំងអស់គង់នៅ ដូចយ៉ាងរូបក្ខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, នឹងវិញ្ញាណក្ខន្ធ, លុះវេលាដែលសេចក្តីស្លាប់មកដល់ ឧបាទិទាំងប៉ុន្មានដែលគង់នៅ ក៏រលាយប្រាសចាកគ្នាទីទៃចេញ លែងប្រមូលផ្តុំគ្នាជាថ្មីទៀត ហើយព្រះអរហន្តក៏ចូលនិព្វានដែលគ្មានឧបាទិ ឬអនុបាទិសេសនិព្វាន ។ គេអាចនិយាយថា សេចក្តីដែលលះបង់នូវ លោភៈ ទោសៈ មោហៈ ចេញនោះ ជាទីអរហត្ត ឬ ជានិព្វានមានឧបាទិ ហើយការដែលផុតជាតិកំណើតនោះ ជាព្រះនិព្វានគ្មានឧបាទិ ។

(នៅមានត)

ព្រះអភិធម្មបិដក

# គម្ពីរព្រះកថាវត្ថុ

លោកប៊ូ - ប៉ូ ប្រែរៀបរៀង

## អនេញ្ជកថា

(៣៦៣)

អថ ខោ អាយស្មា រដ្ឋបាលោ លំដាប់នោះឯង ព្រះរដ្ឋ·បាលត្ថេរ អ្នកមានអាយុ ក្រាបទូលសួរព្រះមានព្រះភាគថា បុព្វេ កេត្ត បពិត្រព្រះអង្គដ៏ចំរើន កាលពីដើម ខ្ញុំព្រះអង្គធ្លាប់ឃើញភ្នំព្រះសុមេរុនៅក្នុងទីនេះជាប្រាកដ ឃើញដើមភ្នំព្រះសុមេរុ ឃើញតាវត្តិង្សពិភពនិងវេជ-យន្តប្រាសាទ ឃើញទង់ជ័យនៅលើវេជយន្តប្រាសាទផង ចុះឥឡូវនេះ ហេតុអ្វីក៏បាត់របស់ទាំងនោះអស់ទៅឯណាមិនឃើញ ។

សម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលរដ្ឋបាល តុម្ហាកំ តាបិតោ ស្តេចនន្ទោបនន្ទនាគរាជមានចិត្តអាឃាតព្យាបាទក្រោធខឹងនឹងអ្នករាល់គ្នា គិតនឹងប្រទូសរ៉ាយ បានជារួបរឹតភ្នំព្រះសុមេរុដោយខ្លួនប្រាំពីរជុំ បិទបាំងភ្នំព្រះសុមេរុដោយពពារ ហេតុដូច្នេះ បានជាអ្នកមិនឃើញនូវភ្នំព្រះសុមេរុ និងវេជយន្តប្រាសាទព្រមទាំងទង់ជ័យ ។

ព្រះរដ្ឋបាលត្ថេរក្រាបទូលថា ខ្ញុំព្រះអង្គនឹងទៅទូន្មាននន្ទោបនន្ទនាគរាជ សម្តេចព្រះបរមលោកនាថមិនទ្រង់អនុញ្ញាត ។

ក្នុងលំដាប់នោះ ព្រះអរហន្តទាំងប្រាំរយអង្គមានព្រះភទ្ទិយត្ថេរនឹង ព្រះរាហុលត្ថេរជាដើម នាំគ្នាក្រាបទូលសូមទៅទូន្មានស្តេចនាគ ប៉ុន្តែព្រះមានព្រះភាគមិនទ្រង់អនុញ្ញាតឡើយ វៀរលែងតែព្រះមហាមោគ្គល្លាន-ត្ថេរចេញ ។

អវសានេ ក្នុងកាលជាទីបំផុត ព្រះមហាមោគ្គល្លានត្ថេរក្រាបទូលសូមទៅទូន្មានស្តេចនាគ ព្រះមានព្រះភាគក៏ទ្រង់អនុញ្ញាតត្រាស់ថា ទមេហិ មោគ្គល្លាន ម្នាលមោគ្គល្លាន អ្នកចូរទៅទូន្មាននន្ទោបនន្ទនាគរាជឲ្យអស់ពុតត្បុត ឲ្យជ្រះថ្លាក្នុងបវរពុទ្ធសាសនាចុះ ។ អត្តភាវំ វិជហិត្វា ព្រះមហាមោគ្គល្លានត្ថេរទទួលព្រះពុទ្ធដីកាហើយថ្វាយបង្គំ ធ្វើឫទ្ធិនិម្មិតព្រះអង្គជានាគរាជធំសម្បើម ហោះតាមអាកាសទៅពេនព័ទ្ធរឹតខ្លួននន្ទោបនន្ទនាគរាជ ឲ្យជាប់នឹងភ្នំព្រះសុមេរុបានដប់បួនជុំដោយ ក្បែនផណកភារដាក់សង្កត់លើពពាររបស់នន្ទោបនន្ទនាគរាជ សង្កិនផ្ទប់ទៅនឹងភ្នំព្រះសុមេរុ ។ ធូមាយិ នន្ទោបនន្ទនាគរាជសំដែងឫទ្ធិឲ្យកើតជាផ្សែងភ្លើងហុយទ្រលោមឡើង ដោយបំណងនឹងប្រទូសរ៉ាយសម្លាប់ព្រះមហាមោគ្គល្លានត្ថេរ ។ មានៈថេរោទីថា ម្នាលនាគរាជ អ្នកសំគាល់ថាផ្សែងភ្លើងមានតែក្នុងខ្លួនរបស់អ្នកឯងម្នាក់ប៉ុណ្ណោះទេឬ? ព្រះមហាថេរថា យើងក៏សំដែងឫទ្ធិឲ្យកើតជាផ្សែងភ្លើងយ៉ាងច្រើន លើសជាងផ្សែងភ្លើងស្តេចនាគ ។ ជ បជ្ជលិ ផ្សែងភ្លើងរបស់ស្តេចនាគឥតបៀតបៀនព្រះ

មហាថេរឲ្យលំបាកបន្តិចសោះ ។ ចំណែកផ្សែងភ្លើងរបស់ព្រះមហាថេរ បៀតបៀនស្តេចនាគ ៗ គិតថា អ្នកនេះ តើជាអ្នកណាមកធ្វើបាបអញ សង្កត់គៀតអញទៅនឹងក្អឲ្យអញបានទទួលសេចក្តីលំបាកខ្លាំង គិតរួចសួរថា ភោ ត្វំ អ្នកនេះ មានឈ្មោះដូចម្តេច ?

ព្រះមហាម៉ោគ្គល្លានត្ថេរប្រាប់ថា អហំ មោគ្គល្លានោ នាម យើងជាសមណៈមាននាមថាមោគ្គល្លាន ។

ស្តេចនាគនិយាយថា ភន្តេ បពិត្រលោកម្ចាស់! បើថាព្រះករុណាជាសមណៈហើយ ចូរសំដែងខ្លួនឲ្យខ្ញុំឃើញច្បាស់ផង ខ្ញុំនឹងជឿសំដីលោកម្ចាស់ ។

ព្រះមហាមោគ្គល្លានត្ថេរ ក៏លែងធ្វើអត្តភាពជានាគពជ ត្រឡប់មានអត្តភាពជាភិក្ខុ ស្លៀកដណ្តប់សំពត់ពណ៌លឿង ហើយចូលទៅតាមរន្ធច្រមុះខាងស្តាំរបស់ស្តេចនាគ រួចចេញមកវិញតាមរន្ធច្រមុះខាងឆ្វេង ចូលទៅតាមរន្ធច្រមុះខាងឆ្វេង ហើយចេញមកវិញតាមរន្ធច្រមុះខាងស្តាំ ព្រះមហាមោគ្គល្លានត្ថេរចូលទៅក្នុងរន្ធច្រមុះខាងស្តាំនឹងខាងឆ្វេងដូច្នោះ ។

លំដាប់នោះ ស្តេចនាគហាមាត់ឲ្យព្រះមហាថេរចូលទៅក្នុងមាត់ខ្លួន ដោយគំនិតប្រុងនឹងទំពាព្រះមហាថេរឲ្យខ្ទេចខ្ទី ។ ព្រះមហាថេរក៏ចូលទៅតាមប្រហោងមាត់ដែលស្តេចនាគហាជ្រងនោះ ហើយនិមន្តចង្ក្រមនៅក្នុងពោះស្តេចនាគ ។

អជ្ជេវា កតកា ក្នុងគ្រានោះ សម្តេចព្រះភគវន្តមុនីត្រាស់ប្រាប់ព្រះមហាមោគ្គល្លានត្ថេរថា ម្នាលមោគ្គល្លាន អ្នកកុំប្រមាទធ្វេសប្រហែសឡើយ មហិទ្ធិកោ ឃសោ ដ្បិតស្តេចនាគនេះ មានឫទ្ធិច្រើនណាស់ អ្នកចូរធ្វើមនសិការឲ្យមែនទែន ៗ

ព្រះមហាមោគ្គល្លានត្ថេរក្រាបទូលតបវិញថា បពិត្រព្រះមានព្រះភាគ ឥទ្ធិបាទទាំងបួន ខ្ញុំព្រះអង្គបានចំរើនឲ្យបរិបូណ៌ហើយ ១ ធ្វើឲ្យជាកំពូលឈាន ឲ្យជាគែជាទីតាំងបាន សន្សំឲ្យមាំមួនក្នុងសន្តាន បើនាគរាជទាំងឡាយមានឫទ្ធិច្រើន ដូចជានន្ទោបនន្ទនាគរាជនេះ រាប់រយ រាប់ពាន់ រាប់ម៉ឺន រាប់សែនក្តី ក៏ខ្ញុំព្រះអង្គទូន្មានបានទាំងអស់ដែរ ៗ

នន្ទោបនន្ទនាគរាជបានឮថេរពាក្យដូច្នោះ ទើបគិតថា បវិសន្តោ ច និក្ខមន្តោ កាលព្រះមហាមោគ្គល្លានចូលទៅក្នុងពោះអញ ៗ មិនឃើញសោះ និក្ខមនកាលេ ក្នុងកាលព្រះមហាមោគ្គល្លានចេញមកវិញ អញនឹងដាក់ត្រង់ចន្លោះចង្កូមហើយនឹងទំពាស៊ីជាអាហារ គិតហើយប្រាប់ថា បពិត្រព្រះមហាមោគ្គល្លាន សូមលោកម្ចាស់កុំធ្វើបាបខ្ញុំឲ្យលំបាកឡើយ ចូរចេញពីពោះខ្ញុំមកវិញ ៗ ព្រះមហាមោគ្គល្លានត្ថេរ ក៏និមន្តចេញមកហើយឈរនៅចំពោះមុខស្តេចនាគ ៗ បណ្តាលជាខ្យល់ពិសឲ្យបក់ចេញ ទៅតាមរន្ធច្រមុះ បំណងឲ្យត្រូវព្រះមហាមោគ្គល្លានត្ថេរ ៗ ក៏ចូលកាន់បត្តិជ្ឈាន ពិសនាគរាជមិនអាចបៀតបៀនបានឡើយ ដោយ

ហោចទៅ សូម្បីតែពេមមួយសរសៃក៏ឥតកម្រើកសោះ ។ ស្តេចនាគឃើញដូច្នោះក៏គេចរត់ចេញទៅ ។ ព្រះមហាថេរនិម្មិតជាស្តេចគ្រុឌហើរដេញទៅដោយកម្លាំងដ៏ខ្លាំង ។ ស្តេចនាគក៏និម្មិតជាមាណពថ្វាយបង្គំហើយទូលថា ខ្ញុំសូមដល់នូវលោកម្ចាស់ជាទីពឹង តាំងពីថ្ងៃនេះជាដើមទៅ ។ ព្រះមហាមោគ្គល្លានត្ថេរទូន្មានស្តេចនាគឲ្យជ្រះថ្លាក្នុងគុណដូច្នេះហើយ ក៏នាំមកគាល់ព្រះបរមសាស្តាចារ្យ ថ្វាយបង្គំហើយក្រាបទូលប្រគល់កាយថ្វាយខ្លួនជាខ្ញុំនៃព្រះរតនត្រ័យ ។

អ្នកប្រាជ្ញគប្បីចូលចិត្តថា ព្រះមហាមោគ្គល្លានត្ថេរនោះ ទូន្មាននន្ទោបនន្ទនាគរាជបានដោយឥទ្ធិឫទ្ធិ ដែលនឹងធ្វើឫទ្ធិបានក៏អាស្រ័យដល់មហាឥញ្ជិតធម៌ ។ ក្នុងកាលដែលពួកចោរបោមព័ទ្ធ ព្រះមហាមោគ្គល្លានត្ថេរមិនសំដែងឫទ្ធិគេចរត់ទៅនោះ ព្រោះលោកពិចារណាជ្រាបថានឹងអស់ព្រះជន្មសង្ខារចូលកាន់ព្រះនិព្វានក្នុងកាលដ៏គួរ ប្រការមួយទៀត កម្មក្នុងអតីតជាតិមិនអាចនឹងពាំងពបាន លោកជ្រាបដូច្នេះ បានជាមិនសំដែងឫទ្ធិគេចរត់ចេញ ។

សកវាទី អហោ អនេញ្ញោ បរោ ព្រះអរិយបុគ្គលដែលបានសម្រេចព្រះអរហត្តផល ស្ថិតនៅក្នុងភាពជាព្រះអរហន្តហើយ លោកនៅមានព្រះទ័យញាប់ញ័រដែរ ឬក៏លែងញាប់ញ័រហើយ ?

បរវាទី- អាមន្តា អើ! ដូចជាយើងទទួលពាក្យរបស់អ្នក ព្រះ

អរិយបុគ្គលដែលបានសម្រេចព្រះអរហត្តផលហើយ លោកលែងញាប់ញ័រ ដោយឥញ្ជិតធម៌គឺតណ្ហា មានះទិដ្ឋិទៀតហើយ ព្រោះឥញ្ជិតធម៌ទាំងនោះលោកកាត់ចោលដាច់ជ្រះស្រឡះហើយ លែងមកគ្របសង្កត់សន្តានលោកបានទៀតហើយ ។ អនេញ្ជប្បត្តោ ព្រះអរហន្តដែលមានព្រះទ័យដល់នូវសេចក្ដីមិនញាប់ញ័រនោះ សូម្បីលោកចង់សំដែងឫទ្ធិយ៉ាងណា ក៏ចេះតែធ្វើបានតាមសេចក្ដីប្រាថ្នាយ៉ាងនោះ ឥតទើសទាល់ឡើយ ដូចព្រះពុទ្ធដីកាត្រាស់ទុកថា ៖

ឯវំ សមាហិតេ ចិត្តេ វិគតុបក្កិលេសេ ព្រះយោគាវចរកុលបុត្រក្នុងព្រះពុទ្ធសាសនានេះ មានចិត្តតាំងមាំមួនល្អ ប្រាសចាកឧបក្កិលេសលែងញាប់ញ័រហើយ ឥទ្ធិវិធំ បច្ចានុភោតិ រមែងបានសោយនូវឥទ្ធិវិធីមានប្រការផ្សេងៗ នឹងបានសម្រេចនូវអភិញ្ញាទាំងប្រាំមួយប្រការ មានទិព្វចក្ខុជាដើម មានអាសវក្ខយញ្ញាណជាបរិយោសាន ។

ព្រះយោគាវចរកុលបុត្រ ដែលនឹងបានសម្រេចព្រះអរហត្តផលញាណនោះ ដោយហេតុមានប្រការផ្សេងៗ គ្នា ប្លែកគ្នា អង្គខ្លះពិចារណាចីវរ អង្គខ្លះពិចារណាបិណ្ឌបាត អង្គខ្លះពិចារណាសេនាសនៈ អង្គខ្លះពិចារណាគិលានភេសជ្ជបច្ច័យ ទើបបានសម្រេចព្រះអរហត្តផល ។ ព្រះអរិយបុគ្គលដែលបានសម្រេចព្រះអរហត្តផល ដោយហេតុពិចារណានូវចីវរបច្ច័យនោះ ដូចជាព្រះចុល្លបន្ថកត្ថេរ មានសេចក្ដីដំណាលថា ៖

ព្រះចុល្លបន្ថកត្ថេរនៅជាមួយព្រះមហាបន្ថកត្ថេរជាបង ។ ព្រះមហាបន្ថកត្ថេរឲ្យទន្ទេញគាថាបួនបាទ សាមសិបពីរតួអក្សរប៉ុណ្ណោះ រហូតដល់បួនខែមិនចាំសោះ ។ ព្រះមហាបន្ថកត្ថេរបណ្តេញឲ្យដើរចេញពីព្រះវិហារ ។ ព្រះចុល្លបន្ថកត្ថេរគិតថា អញនឹងទៅផ្ទះសឹកជាឃរាវាសក៏អាចធ្វើការកុសលយោងខ្លួនឲ្យផុតចាកវដ្តសង្សារបានដូចគ្នា គិតដូច្នេះហើយ ក៏ដើរចេញមកតាមមាគ៌ា ។

តេន ខោ បន សមយេន កកាក់ ក៏សម័យនោះឯងសម្តេចព្រះមានព្រះភាគទ្រង់ជ្រាបនូវហេតុនោះ ម្យ៉ាងទៀត ទ្រង់ឃើញថាព្រះចុល្លបន្ថកត្ថេរជាពុទ្ធវេនេយ្យ ព្រះអង្គទើបស្តេចទៅឈរប្រតិស្ឋាននៅក្បែរខ្លោងទ្វារ បានទតឃើញព្រះចុល្លបន្ថកត្ថេរដើរមកចំពោះព្រះភក្ត្រទើបទ្រង់ត្រាស់ហៅឲ្យចូលមកជិតព្រះអង្គ ហើយសួរថា កុហឹ ករោមាលចុល្លបន្ថក! អ្នកនឹងទៅកាន់ប្រទេសឯណា? ។ ព្រះចុល្លបន្ថកត្ថេរក្រាបទូលថា បពិត្រព្រះមានព្រះភាគ ព្រះមហាបន្ថកត្ថេរ ជាបងរបស់ខ្ញុំព្រះអង្គ បណ្តេញឲ្យដើរចេញពីព្រះមហាវិហារ លែងឲ្យនៅគង់អាវាសជាមួយ ហេតុនោះ ខ្ញុំព្រះអង្គសូមថ្វាយបង្គំលាទៅ នឹងលាព្រះវិន័យសិក្ខាបទដោយកំណត់ថានឹងសឹកជាគ្រហស្ថ ហើយនឹងប្រតិបត្តិតាមសិក្ខាបទរបស់គ្រហស្ថ ក៏អាចជាទីពឹងដល់ខ្លួនបាន ។

កកាក់ សម្តេចព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រះចុល្លបន្ថកត្ថេរ

ជាពុទ្ធវេនេយ្យ ទើបត្រាស់ថា ម្នាលចុល្លបន្ថក! មម សាសនេ បព្វជិតោ អ្នកនេះបួសក្នុងសាសនារបស់តថាគត មិនមែនសាសនារបស់មហាបន្ថកត្ថេរទេ ចុះហេតុដូចម្តេចបានជាអ្នកមិនមករកតថាគត ។ ព្រះចុល្លបន្ថកត្ថេរបានស្តាប់ព្រះពុទ្ធដីកាយ៉ាងនេះហើយ ក៏មានចិត្តត្រេកអរក្នុងព្រះពុទ្ធសាសនា តស្ស ចិត្តាការំ ញត្វា សម្តេចព្រះបរមសាស្តាទ្រង់ជ្រាបថា ព្រះចុល្លបន្ថកត្ថេរត្រេកអរក្នុងព្រះពុទ្ធសាសនាហើយ ទើបត្រាស់សំដែងព្រះសទ្ធម្មទេសនាថា រាគោ រជោតិ វុច្ចតិ ជាដើម សេចក្តីថា រាគៈ គឺសេចក្តីជម្រេកក្នុងកាមគុណទាំងប្រាំ តថាគតហៅថា ធូលី ទោសៈ នឹង មោហៈ គឺចិត្តប្រទូសរ៉ាយនឹងសេចក្តីវង្វេង ក៏តថាគតហៅថា ធូលី ដូចគ្នាដែរ វិប្បជិ ត្វំ អ្នកចូរលះបង់នូវរាគៈទោសៈមោហៈទាំងបីប្រការនោះឲ្យដាច់ចេញពីសន្តានចុះ ។ កាលព្រះចុល្លបន្ថកត្ថេរបានឮដូច្នោះហើយ ក៏បញ្ជូនបញ្ញាទៅតាមក្រសែព្រះពុទ្ធ-ដីកា ពិចារណាដោយព្រះត្រៃលក្ខណញ្ញាណ គឺឃើញបញ្ចសង្ខារដោយអនិច្ចំ ទុក្ខំ អនត្តា ពិចារណាឃើញ រូប វេទនា សញ្ញា សង្ខារវិញ្ញាណមិនទៀង នឹងឃើញថា ជាតិ ជរា ព្យាធិ មរណៈជាដើមជាទោសរមែងនាំមកនូវទុក្ខ នឹងឃើញថាចក្ខុនឹងរូប, សោតៈនឹងសម្លេងជាដើមក៏មិនមែនខ្លួន មិនមែនជារបស់ខ្លួន ឃានប្រសាទនឹងជិវ្ហាប្រសាទនឹងក្លិនរស ដែលកំណត់ថាជារបស់ខ្លួននោះក៏មិនមែន កាយសោតទៀត

ក៏មិនមែនរបស់ខ្លួន គ្រឿងសម្ផស្សទាំងអស់ដែលជាអារម្មណ៍នៃកាយ ក៏មិនមែនរបស់ខ្លួន នឹងហេតុរឿងរ៉ាវទាំងពួង ដែលត្រូវដឹងដោយចិត្ត ក៏មិនមែនជារបស់ខ្លួន ។ កាលព្រះចុល្លបន្ថកត្ថេរពិចារណាឃើញដូច្នេះ ក៏ញុំាងវិបស្សនាឲ្យចំរើនច្រើនឡើង លះបង់នូវបុថុជ្ជនគោត្រភូញ្ញាណ បាន យាងចូលកាន់អរិយគោត្រភូញ្ញាណ បានសម្រេចព្រះអរហត្ត កាត់កិលេសដាច់ជាសមុច្ឆេទប្បហាន ព្រមដោយបដិសម្ភិទាញាណ តាំងនៅក្នុងអនេញ្ជធម៌ លែងញាប់ញ័រដោយតណ្ហា មានៈនិងទិដ្ឋិតាមធម្មតា ហេតុនេះ បានជាពោលថា ព្រះអរហន្តទាំងឡាយដែលនឹងញុំាងខ្លួនឲ្យតាំងនៅក្នុងអនេញ្ជធម៌បាននោះ ក៏ព្រោះតែអាស្រ័យហេតុពិចារណានូវបញ្ចសង្ខារដោយអនិច្ចំ ទុក្ខំ អនត្តា ។ ពោលមកនេះ ដោយអំណាចនៃបុគ្គលដែលមានបារមីចាស់ក្លាកើតក្នុងបច្ឆិមភវិកជាតិ ទើបអាចនឹងឃើញព្រះត្រៃលក្ខណ៍ខ្ជាប់ខ្ជួនបាន ។ ក៏ឯសត្វដែលកើតមកក្នុងបច្ចុប្បន្ននេះ បានឃើញសង្ខារទាំងប្រាំដោយអនិច្ចំ ទុក្ខំ អនត្តាខ្លះដែរ តែឃើញមួយដងមួយកាល ឃើញមិនខ្ជាប់ខ្ជួន ឃើញត្រឡប់ត្រឡិន មាត់ចេះតែថា អនិច្ចំ ទុក្ខំ អនត្តា ឯក្នុងចិត្តឥតឃើញដូចមាត់ថានោះសោះ ហេតុនោះ ទើបមិនបានស្ថិតនៅក្នុងអនេញ្ជធម៌ ។

សកវាទី - ព្រះចុល្លបន្ថកត្ថេរនោះ កើតក្នុងបច្ឆិមភវិកជាតិនឹងបានសម្រេចព្រះអរហត្តផលជាពិតប្រាកដ ចុះហេតុដូចម្តេច បានជា

លោកល្ងង់ខ្លៅ ទន្ទេញតែគាថាបួនបាទប៉ុណ្ណោះដល់បួនខែនៅតែមិនចាំ អាស្រ័យអកុសលកម្មដែលលោកធ្វើទុកមកយ៉ាងណា ?

បរកេទ៌- ឬខេត្ត ក៏ធ្វើកាលពីជាតិមុន ព្រះពុទ្ធបទុមុត្តរ កំពុងនៅអន្ទោលទៅក្នុងវដ្តសង្សារ បានកើតជាបុត្រត្រកូលមួយមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាប្រកបដោយបញ្ញាឈ្លាសវៃ រៀនព្រះត្រៃបិដកចេះចាំបានស្ទាត់ជំនាញ ៗ គ្រាមួយ, មានភិក្ខុមួយរូបល្ងង់ខ្លៅទន្ទេញព្រះពុទ្ធវចនៈមិនចាំចេះតែភ្លេចមុខភ្លេចក្រោយ សូត្រខុសខ្លះត្រូវខ្លះ ប្រឡូកប្រឡំគ្នា ៗ ភិក្ខុអ្នកមានប្រាជ្ញាច្រើនចេះចាំព្រះត្រៃបិដកស្ទាត់នោះ ឃើញភិក្ខុល្ងង់ខ្លៅសូត្រមិនត្រូវចេះតែខុសកែវដូច្នោះ ក៏សើចចំអកចំអន់លេង ភ្លេចនឹកថាជាអកុសលកម្ម ៗ ភិក្ខុល្ងង់ខ្លៅបានឮពាក្យចំអកឡកឡឺយដូច្នោះ ក៏អៀនខ្មាស់ណាស់ឈប់លែងរៀនសូត្រព្រះពុទ្ធវចនៈ តាំងពីគ្រានោះមក ៗ ហេតុតែអំពើអកុសល ដែលភិក្ខុអ្នកមានប្រាជ្ញាច្រើនសើចចំអកឲ្យភិក្ខុល្ងង់ខ្លៅអៀនខ្មាស់ លែងរៀនសូត្រព្រះពុទ្ធវចនៈដូច្នោះ ភិក្ខុអ្នកមានប្រាជ្ញាច្រើននោះ លុះអស់ជីវិតហើយ ទៅកើតក្នុងនរកជាយូរយារគ្រាប់រង្គាត់នៅក្នុងវដ្តសង្សារ សោយទុក្ខនឹងសុខតាមយថាកម្ម គឺកុសលនឹងអកុសលដែលខ្លួនបានធ្វើទុក ៗ ឥមស្មិ ពុទ្ធុប្បាទេ លុះដល់មកសម័យព្រះពុទ្ធជាម្ចាស់នៃយើងត្រាស់ឡើងនេះ ភិក្ខុអ្នកមានប្រាជ្ញាច្រើនពីគ្រានោះ បានមកកើតក្នុងផ្ទៃធីតាសេដ្ឋី ដោយទៅប្រសូត

ក្បែរចិញ្ចើមថ្ពល់ បានជាមាននាមបញ្ញត្តិថា “ចុល្លបន្ថក” លុះចំរើនធំឡើងបានបួសតាមព្រះមហាបន្ថកត្ថេរជាបង ជាភិក្ខុប្រដៅងាយ ប៉ុន្តែល្ងង់ខ្លៅ ព្រោះផលនៃអកុសលកម្មដែលខ្លួនសើចចំអកឲ្យភិក្ខុមួយរូបនោះជាអបរាបរវេទនីយកម្ម ។ ហេតុដូច្នោះ បណ្ឌិតគប្បីសន្និដ្ឋានថា អ្នកមានឧបនិស្ស័យជាបច្ឆិមភវិកសត្វ នឹងបានសម្រេចព្រះអរហត្តក្នុងជាតិនោះហើយ អកុសលកម្មដែលសើចចំអកឲ្យភិក្ខុដទៃអៀនខ្មាស់ ទាល់តែលែងរៀនសូត្រព្រះសទ្ធម្មនោះ នៅតែតាមមកឲ្យផលធ្វើឲ្យព្រះចុល្លបន្ថកត្ថេរល្ងង់ខ្លៅបាន ។ ហេតុនេះ បើសាធុសប្បុរស បានឃើញអ្នកដែលមានចិត្តជ្រះថ្លាក្នុងព្រះសទ្ធម្មដ៏ជាពុទ្ធភាសិតហើយ ត្រូវមានចិត្តអាណិតមេត្តាជួយរំលឹកដាស់តឿនឲ្យរៀនសូត្រ នឹងពន្យល់ឲ្យចេះដឹងនូវពាក្យខាងដើមខាងកណ្តាលនឹងចុងបំផុតផង ដើម្បីឲ្យបានផលជាអ្នកមានប្រាជ្ញាច្រើនចេះដឹងព្រះពុទ្ធវចនៈទាំងខ្លួនឯង ទាំងអ្នកដទៃ ។

(នៅមានត)

មធុរសវាហិណី

(តមក)

# សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឺន ពិនិត្យ

លុះកាលកន្លងយូរទៅ ៗ មានថ្ងៃមួយជាខាងក្រោយ ព្រះនាងទេវី បានឃើញសម្បត្តិព្រះបរមក្សត្រិយ៍ជាអស្ចារ្យហើយ ក៏សំដែងនូវអាការ អាណិតអាសូរខ្លួនថា: ឱ! អាត្មាអញអើយវង្វេងងងឹតពន់ពេក ៗ

ព្រះបរមក្សត្រិយ៍ទ្រង់ព្រះសណ្ដាប់ហើយ ទើបទ្រង់ត្រាស់សួរថា ម្នាលនាងទេវី! តើមានហេតុដូចម្ដេច? ៗ

ព្រះនាងទេវីក្រាបទូលថា: បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់យល់ ថា សម្បត្តិរបស់ព្រះអង្គធំក្រៃពេកណាស់ ព្រោះតែអំពើជាកុសលដែល ព្រះអង្គបានបំពេញ ក្នុងកាលពីមុនកន្លងមកយូរណាស់ហើយ ឥឡូវនេះ គួរតែព្រះអង្គ ខំខ្វល់ខ្វាយបំពេញកុសល ឲ្យបានច្រើនដើម្បីជាប្រយោជន៍ តទៅក្នុងអនាគតទៀត ៗ

ព្រះបាទទន្ទកមហាកដទ្រង់ព្រះសណ្ដាប់ហើយ ក៏ត្រាស់តបថា: អើ! នាងទេវី, បើដូច្នេះ តើយើងនឹងឲ្យទានដល់បុគ្គលឯណា ៗ

ព្រះនាងទេវីក្រាបទូលថា: បពិត្រព្រះសម្មតិទេព យើងគួរតែ ឲ្យទានដល់បុគ្គលអ្នកមានសីលទើបប្រសើរ ផ្សិតជម្ពូទ្វីបនេះធំណាស់

តុំមែនសូន្យតាកព្រះអរហន្តទាំងឡាយទេ មុខជានឹងមានព្រះអរហន្តខ្លះ តុំលែងឡើយ សូមព្រះអង្គទ្រង់តាក់តែងទេយ្យទានបំរុងទុកចុះ គង់នឹងបានព្រះអរហន្តទាំងឡាយក្នុងកាលឥឡូវនេះឯង ។

សម្តេចព្រះនរិន្ទ្រាធិបតី លុះទ្រង់ព្រះសណ្តាប់ព្រះសវន័យនាងទេវីហើយ ដល់ថ្ងៃព្រឹកឡើងទៀតព្រះអង្គបានបរិច្ចាគព្រះរាជទ្រព្យរណ្តាប់តាក់តែងមហាទាន មានទាំងគ្រឿងបរិក្ខារគ្រប់ប្រដាប់ជាស្រេច ។

ចំណែកឯព្រះនាងទេវី ក៏បានធ្វើសច្ចកិរិយាផ្សងនិមន្តថា បើព្រះអរហន្តទាំងឡាយអង្គណា មានប្រាកដក្នុងទិសនេះ សូមព្រះអរហន្តទាំងឡាយអង្គនោះនិមន្តមកក្នុងវាំងនេះ ដើម្បីទទួលយកនូវចង្ហាន់នៃយើងទាំងឡាយឥឡូវនេះ នាងទេវីបានពោលពាក្យសច្ចនិមន្តយ៉ាងនេះហើយ ក៏បែរព្រះភក្រ្តចំពោះទៅកាន់ព្រៃហិមពាន្តក្នុងទិសខាងជើង ព្រះហស្តចាប់ផ្កាជាច្រើន បោះឡើងទៅនាផ្ទៃអាកាស ហើយក្រាបដោយទ្រូងនមស្សការថ្វាយបង្គំចំពោះព្រះអរហន្តទាំងឡាយនោះហោង ។

ចំណែកឯផ្កាទាំងឡាយនោះសោត ក៏ជាអស្ចារ្យអណ្តែតត្រសែតទៅតាមអាកាសហោះសំដៅតែមួយរំពេច ក៏បានធ្លាក់ចុះទៀបព្រះបាទនៃព្រះមហាបទុមបច្ចេកពុទ្ធ ដែលជាធំវិសេសជាងព្រះបច្ចេកពុទ្ធទាំងប្រាំរយ ព្រះអង្គជាបុត្រនៃនាងបទុមវតី ដែលលោកគង់នៅក្នុងហិមវន្តប្បទេស នោះឯង ។

ព្រោះហេតុនេះបានជា ព្រះអរហន្តទាំងឡាយពោលជាបទព្រះគាថាដូច្នេះថា :

អហោ បស្សថ កោធានិ វិម្ហយំ បុញ្ញកម្មុនោ
អចេតនានិ ឫក្ខានិ ទុគ្គតិច្ចេសុ ព្យាវដា ។

អធិប្បាយថា ឱ! អ្នកទាំងឡាយអើយ ឥឡូវនេះ អ្នកទាំងឡាយត្រូវមើលមើលនូវសេចក្ដីស្ញើមជាទីអស្ចារ្យនៃបុញ្ញកម្មនេះចុះ សូម្បីឈើទាំងឡាយគ្មានចិត្តគ្មានចេតនានោះសោះ គង់អាចខ្វល់ខ្វាយប្រព្រឹត្តទៅក្នុងកិច្ចជាអ្នកបំរើឲ្យសម្រេចដោយដូវទុគ្គតបាន ។

កាត្តកាមេន លោកស្មឹ សកលំ អត្តនោ សិំ
សព្វត្ថាមេន កាតព្វំ បុញ្ញំ បុញ្ញវតា សទា ។

បុណ្យទាំងអស់ដែលបុគ្គលអ្នកមានបុណ្យ មានប្រាថ្នាដើម្បីធ្វើឲ្យជាអំណាចរបស់ខ្លួនក្នុងលោក ត្រូវធ្វើឲ្យសម្រេចដោយកំឡាំងទាំងពួងសព្វ ៗ កាលដោយពិត ។ ក្នុងលំដាប់នោះ ព្រះមហាបទុមបច្ចេកពុទ្ធទ្រង់បានជ្រាបហេតុសព្វគ្រប់ហើយ បាននិមន្តព្រះបច្ចេកពុទ្ធជាប្អូនទាំងឡាយ ឲ្យមកជួបជុំហើយពោលថា : ម្នាលអ្នកទាំងឡាយស្មើដោយយើង! ឥឡូវនេះ ព្រះបាទនន្ទកមហារាជ បាននិមន្តលោកទាំងឡាយដើម្បីទទួលភត្ត ដូច្នេះ ត្រូវតែលោកទាំងឡាយទទួលនិមន្តរបស់ព្រះអង្គនោះ ទើបគួរ ។

ឯព្រះបច្ចេកពុទ្ធទាំងឡាយនោះ បានទទួលនិមន្តព្រមគ្នាទាំងអស់ ហើយក៏ហោះមកតាមអាកាសវេហាស៍ បានមកដល់កំនិមន្តចុះទៀបទ្វារពំងខាងដើងក្នុងខណៈនោះឯង ។

មនុស្សទាំងឡាយបានឃើញហើយ ក៏ចូលទៅក្រាបទូលព្រះមហាក្សត្រិយ៍ថា: បពិត្រព្រះសម្មតិទេព ព្រះបច្ចេកពុទ្ធទាំង ប្រាំរយអង្គបាននិមន្តមកដល់ហើយ សូមព្រះអង្គទ្រង់ជ្រាប ។

ឯព្រះបរមក្សត្រិយ៍ព្រមទាំងព្រះនាងទេវី លុះទ្រង់ព្រះសណ្ដាប់ហើយ ក៏យាងចេញទៅទទួលដំណើរព្រះបច្ចេកពុទ្ធទាំងឡាយ បានថ្វាយបង្គំហើយទទួលយកបាត្រ និមន្តព្រះបច្ចេកពុទ្ធទាំងអស់ឡើងទៅឯប្រាសាទគង់នៅលើទីអាសនៈដ៏សមគួរហើយ បានថ្វាយទក្ខិណាទានដល់ព្រះបច្ចេកពុទ្ធទាំងឡាយក្នុងប្រាសាទនោះឯង ។

លុះព្រះបច្ចេកពុទ្ធទាំងឡាយបានធ្វើភត្តកិច្ចស្រេចហើយ ព្រះបាទនន្ទកុមារ ព្រះអង្គក្រាបចុះទៀបបាទមូល នៃព្រះបច្ចេកពុទ្ធជាសង្ឃត្ថេរ ព្រះនាងទេវី ក្រាបចុះទៀបបាទមូល នៃព្រះបច្ចេកពុទ្ធជាសង្ឃនវកៈ ហើយធ្វើសេចក្ដីប្ដេជ្ញាថា: លោកម្ចាស់ទាំងឡាយនឹងមិនលំបាកដោយបច្ច័យទាំងបួន យើងខ្ញុំទាំងឡាយសោតនឹងបានសំរេចដោយបុណ្យ ។ ដូច្នេះ, សូមលោកម្ចាស់ទាំងឡាយ ប្រទាននូវសេចក្ដីបដិញ្ញា ដល់យើងខ្ញុំទាំងឡាយ ដើម្បីគង់នៅក្នុងទីនេះ ព្រះបរមក្សត្រិយ៍ នឹងព្រះនាង

ទៅ បានសូមបេព្វជ្ជាដូច្នេះហើយ ក៏ចាត់ភ្នាក់ងារជាច្រើនឲ្យតាក់តែងនូវទីសេនាសនៈទាំងឡាយ មានវិហារ ទីដេកទីអង្គុយជាដើមក្នុងសួនឧទ្យានជារបោះស្ថាន ដ៏សប្បាយថ្វាយដល់ព្រះបច្ចេកពុទ្ធទាំងនោះ ហើយបានបំរើដោយបច្ច័យទាំងបួនអស់កាលជាប់មិនដាច់ឡើយ ។ កាលបើព្រះបច្ចេកពុទ្ធទាំងឡាយ ចូលព្រះនិព្វានទៅហើយ ក៏បានចាត់ធ្វើសរីរកិច្ចល្អប្រពៃ មានបូជាព្រះភ្លើងដោយខ្លឹមចន្ទន៍ ខ្លឹមក្រស្នាជាដើម ហើយរើសយកព្រះធាតុទៅបញ្ចុះក្នុងព្រះចេតិយសំរាប់ធ្វើសក្ការបូជាជាប្រក្រតី ហើយដល់នូវសេចក្ដីសំវេគថា : លោកដែលមានអានុភាពធំយ៉ាងនេះ គង់មានសេចក្ដីមរណៈមកបៀតបៀនបានដែរ ចំណង់បើបុគ្គលព្រាកដស្មើដោយយើងទាំងឡាយនេះ កាលណាឡើយនឹងចៀសរួច មុខជាយើងនឹងស្លាប់ដោយពិត ៗ លុះមានសេចក្ដីសំវេគកើតឡើងយ៉ាងនេះហើយ ព្រះបរមក្សត្រិយ៍នឹងព្រះនាងទេវីទាំងពីរអង្គ ក៏លះបង់រាជសម្បត្តិ ស្វេតច្ឆត្រប្រគល់ឲ្យព្រះរាជបុត្រច្បងគ្រងរាជសម្បត្តិស្នងព្រះអង្គ ហើយក្សត្រិយ៍ទាំងពីរពង្ស ទ្រង់ចេញទៅបំពេញព្រះផ្នួសបួសជាឫសី នៅអាស្រ័យក្នុងព្រៃឧទ្យាន ចំរើននូវឈាននឹងអភិញ្ញាឲ្យកើតឡើង ទ្រង់ញ៉ាំងកាលឲ្យប្រព្រឹត្តកន្លងទៅដោយសេចក្ដីសុខក្នុងឈាន លុះដល់កាលជាទីបំផុតនៃអាយុគឺចុតិចិត្ត(?)ជីវិត បានឡើងទៅកើតក្នុងស្ថានព្រហ្មលោកនាយពោង ៗ

លុះមកដល់ពុទ្ធកាលព្រះមានព្រះភាគជាម្ចាស់នៃយើង ព្រះអង្គបាន

គ្រាស់ជាព្រះពុទ្ធប្រាកដក្នុងលោកហើយ ជនទាំងពីរនាក់នោះ ក៏បានច្យុតចុះមកអំពីព្រហ្មលោកកើតក្នុងត្រកូលព្រាហ្មណ៍ដ៏ស្តុកស្តម្ភមួយ រួចហើយបានចេញទៅបួសក្នុងសំណាក់ព្រះពុទ្ធសាសនាតមក ។

ចំណែកឯព្រះបាទនន្ទកមហារាជ បានជាព្រះមហាកស្សបត្ថេរ ដ៏ប្រសើរជាងភិក្ខុទាំងឡាយអ្នកទ្រទ្រង់នូវធុតង្គដ៏ល្បីទៅក្នុងលោក បីដូចជាព្រះចន្ទនឹងព្រះអាទិត្យរះឡើងក្នុងលោកក្នុងកាលនោះឯង ។ នាកាលព្រះមានព្រះភាគព្រះអង្គទ្រង់ចូលព្រះបរមនិព្វានទៅហើយ ក្រោយនោះព្រះមហាកស្សបត្ថេរ លោកបានចាត់ចែងធ្វើសង្គាយនាធម៌វិន័យ ញុំាងព្រះពុទ្ធសាសនាឲ្យបានរុងរឿងផ្សាយទៅក្នុងលោក ។

ចំណែកឯព្រះនាងទេវី ជាអគ្គមហេសីនៃព្រះបាទនន្ទកមហារាជនោះ បានមកជានាងភទ្ទកាបិលានីថេរី អ្នកទ្រទ្រង់នូវធុតង្គដ៏ប្រសើរក្នុងព្រះពុទ្ធ-សាសនានៃព្រះសម្មាសម្ពុទ្ធដោយពិត ។

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយ លោកពោលជាបទព្រះគាថាដូច្នេះថា :

ទត្វា បុរេត្វាបរំ ច ចរេត្វា
បច្ចេកពុទ្ធស្ស ឧភតមត្តំ
កត្វា សរដ្ឋំ កុរុទីបលោកំ
មហានុភាគេ វសុធាធិបោសិ

តុម្ហេ ភោន្តោ ខលុ សីលវន្តេ
ធនាជ ធានំ មុញ្ចថ បសន្នំ
តំ វោ បតិដ្ឋា ច ភវន្តរស្មឹ
ចិន្តាមណីសន្និភតញ្ញ ហោតីតិ ។

អធិប្បាយថា : ព្រះមហាកស្សបត្ថេរកាលកើតជាកុដុម្ពិក បាន ត្រេចទៅក្នុងព្រៃដ៏ធំតនាទិសខាងកើត បានថ្វាយនូវសំពត់ល្អមជាសំពត់ អនុពត ដល់ព្រះបច្ចេកពុទ្ធមួយព្រះអង្គប៉ះធ្វើជាចីវរ (អំណោយផលបុណ្យ ប៉ុណ្ណោះ កុដុម្ពិកនោះ) បានកើតជាស្តេចជាធំលើផែនដី មានឫទ្ធិអានុភាព ច្រើន អាចធ្វើជម្ពូទ្វីបទាំងមូលឲ្យល្អរុងរឿងបាន ។

ម្នាលអ្នកទាំងឡាយដ៏ចំរើន មានពាក្យជាស់តឿនថា ត្រូវអ្នក ទាំងឡាយខ្វល់ខ្វាយបំណាយទ្រព្យឲ្យទានដែលជាបុណ្យ គឺព្រះពុទ្ធអ្នក ប្រាជ្ញតែងសរសើរហើយ ដល់លោកអ្នកមានសីលទាំងឡាយចុះ ។

ទាននោះនឹងបានជាទីពឹងនៃអ្នកទាំងឡាយផង មានរស្មីរុងរឿងដូច ជាកែវចិន្តាមណីផង នឹងមានប្រាកដក្នុងភពតូចធំ (ឮដ៏អនាគតកាល ពុំលែងឡើយ) ។

សម្តែងរឿងនិទានព្រះបាទនន្ទកមហារាជជាបឋមក្នុងវគ្គទីពីរ ក៏ចប់ សេចក្តីដោយសង្ខេបតែប៉ុណ្ណោះហោង ។

## អញ្ញតរមនុស្សវត្ថុកថា

សំដែងរឿងនិទានមនុស្សកំសត់ម្នាក់ មានឈ្មោះពុំប្រាកដ ដោយបទបាលីថា: អញ្ញតរំ កតវតិ បរិជិត្ថេត ដូច្នេះជាដើម:

អធិប្បាយថា: កាលព្រះមានព្រះភាគជាម្ចាស់នៃយើងទ្រង់ចូលព្រះបរមនិព្វានទៅហើយ មានមនុស្សកំសត់ម្នាក់ មានឈ្មោះពុំប្រាកដ នៅអាស្រ័យក្នុងស្រុកមួយ ទៀបនគរបាតលីបុត្ត ។

លុះដល់សម័យថ្ងៃមួយ បុរសកំសត់នោះក៏បានចេញទៅកាន់ស្រុកដទៃមួយទៀត បានយកសំពត់សាដកពីរមកស្លៀកហើយដើរទៅកាន់ដងព្រៃធំ ។

វេលានោះ មានចោរម្នាក់ បានឃើញមនុស្សកំសត់នោះដើរទៅក្នុងព្រៃតែម្នាក់ឯង ស្លៀកសំពត់សាដកថ្មីដូច្នោះហើយ ក៏គិតថាអាត្មាអញនឹងដណ្ដើមយកសំពត់ពីបុរសនេះឥឡូវនេះឯង ចោរគិតដូចនេះហើយក៏ស្ទុះរត់ដេញតាមបុរសនោះទៅ ។

ឯបុរសកំសត់ បានឃើញចោររត់មកអំពីចម្ងាយ ហើយគិតថា: អាត្មាអញមិនអាចនឹងរត់ទៅឲ្យរួច ទាំងមិនអាចតប្រយុទ្ធជាមួយនឹងចោរនេះបានឡើយ, បើទុកជាអាត្មាអញមិនប្រាថ្នានឹងឲ្យវាក៏គង់វានឹងដណ្ដើមយកអំពីអាត្មាអញពុំខានឡើយ អំពើដែលអាត្មាអញមិនឲ្យនេះ នឹងត្រឡប់ទៅជាអំពើឥតប្រយោជន៍ដោយពិត ។

ដូច្នេះ ត្រូវតែអាត្មាអញញុំាងសទ្ធាចិត្ត ឲ្យកើតឡើងជាមុន ហើយឲ្យសំពត់ដល់ចោរនេះចុះ ដោយអំណាចនៃទានប៉ុណ្ណេះនឹងបានបុណ្យច្រើនទៅអនាគតពុំខានឡើយ; លុះបុរសនោះគិតយ៉ាងនេះហើយ ក៏ធ្វើតាមគំនិតដែលគិតនោះឯង ។

គ្រានោះ ចោរក៏មកដល់ហើយ យកដៃចាប់បញ្ចោសអន្ទែលសំពត់នោះ ដោយប៉ុនប៉ងចង់បានពន់ពេក ។

(នៅមានត)

# មហោសថជាតក

(តមក)

លោក អ៊ុម-ភន ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស កឹម-តូរ ពិនិត្យ

លំដាប់នោះ, ឯពពែដណ្ដឹងឆ្កែថា ហៃសំឡាញ់អើយ រីសំឡាញ់ឯងមានខ្នងនោះកោងក្រញោនលើកជើងមួយនោះ តើហេតុអ្វី? ជាខ្យល់ចូលចាប់ជោគព្រះស្តេចឬម្តេច? ។ ឆ្កែដណ្ដឹងទៅពពែវិញថា ដូច្នោះព្រះស្តេចឯង មានខ្នងនោះក្រញោនដេកនៅដូច្នោះ តើជាខ្យល់ចូលចាក់ជោគនៃព្រះស្តេចឬម្តេច? ។ សោ ឯឡកោ រីឯពពែនោះប្រាប់ឆ្កែដោយនូវដំណើរអាត្មា, ឆ្កែក៏ប្រាប់ពពែដោយនូវដំណើរអាត្មា ។ ពពែដណ្ដឹងទៅឆ្កែវិញទៀតថា សាមិ ម្នាលសំឡាញ់អើយ! រីព្រះស្តេចតើអាចដើម្បីនឹងទៅកាន់ផ្ទះគ្រួនោះវិញទៀតបានឬទេ? ។ ឆ្កែនោះថា ម្នាលសំឡាញ់អើយ, អញមិនអាចនឹងទៅបានឡើយ បើអញខំទៅហើយ រីជីវិតនៃអាត្មាក៏ឥតអង្គីមានឡើយ ។ រីសំឡាញ់ឯង តើអាចដើម្បីនឹងទៅកាន់ពេងដំរីនោះវិញទៀតបានឬទេ ? ពពែថាហៃសំឡាញ់អើយ, អញមិនអាចដើម្បីនឹងទៅកាន់ពេងដំរីនោះវិញទៀតបានឡើយ បើអញទៅហើយ ជីវិតនៃអញឥតអង្គីមានឡើយ ។

គោ (ឧភោ សត្តា) សត្វទាំងពីរនោះ គិតនូវឧបាយថា ឥឡូវនេះ ទោះយោបីដូច្នោះ តើយើងនឹងរស់ជីវិតដោយកាលម្តេចទៅ ? ។ លំដាប់នោះ ពពែថា: សំឡាញ់អើយ, រីយើងទាំងពីរ បើបិតនៅរួមសំរាកសហានជាមួយគ្នា ឧបាយកលក៏មានហោង ។ រីឆ្កែនោះថា បើនៅជាមួយផងគ្នា តើព្រះស្តងនឹងគិតធ្វើឧបាយកលដូចម្តេច ? ចូរព្រះស្តងប្រាប់មកហោង ។ ទើបពពែថា: សំឡាញ់អើយ, ចាប់ដើមអំពីនេះទៅ ចូរព្រះស្តងទៅកាន់ពេនក្រមាក់ដំរីនោះ កុំគិតសង្កានឹងព្រះស្តងឡើយ, ក៏គិតថា ឆ្កែនេះពុំដែលស៊ីស្មៅ ម្ល៉ោះហើយក៏មុខជាប្រហែស, កាលណាក៏ស្ងាត់ហើយ ចូរព្រះស្តងនាំស្មៅមកឲ្យអញផងហោង ។ រីអញសោតនឹងចូលទៅកាន់ពេនគ្រូ, រីអ្នកគ្រូសោតមិនសង្កានឹងអញទេ ទុកចិត្តថា ពពែនេះមិនដែលនឹងស៊ីសាច់ ម្ល៉ោះហើយក៏ប្រហែស កាលណាបើស្ងាត់ហើយ អញនឹងនាំត្រីសាច់មកឲ្យព្រះស្តង, រីឧបាយកលនេះយល់គាប់ពិតហោង ។ រីឆ្កែនោះសោតទៅឯពេនដំរី តែងនាំនូវកណ្តាប់ស្មៅមកទុកខាងជញ្ជាំងផង ។ រីពពែក៏ទៅកាន់ពេនគ្រូ នាំនាំនូវដុំសាច់ពេញទាំងមាត់ នាំមកទុកក្នុងហានោះឯងហោង ។ រីឆ្កែស៊ីសាច់ ពពែស៊ីស្មៅ សត្វទាំងពីរនោះ សមគ្គា សម្មោទមាជា មានចិត្តត្រេកអរនឹងគ្នាសំណាក់ នៅនឹងជញ្ជាំងផង ចិញ្ចឹមជីវិតដោយនូវឧបាយកលនោះហោង ។

ភជា តេសំ ។ល។ បុច្ឆិសក្ខុអ៊ីតិ ព្រះបាទវិទេហរាជ ស្តេចទតទៅឃើញសត្វទាំងពីរយកគ្នាជាមិត្តសន្ថវៈដូច្នោះហើយ ទ្រង់ព្រះចិន្តាគិតថា : រីសត្វទាំងពីរនេះ សត្រូវនឹងគ្នាសព្វថ្ងៃនេះមកនៅទីលំនៅមួយជាមិត្តសន្ថវៈផងគ្នា, រីហេតុអំពើនេះ អំពីមុនមកពុំដែលបានឃើញ, សព្វថ្ងៃនេះ អញមកឃើញដូច្នេះ អញនឹងយកហេតុនេះចងជាអាថ៌ប្រស្នាហើយអញនឹងដណ្តឹងអ្នកប្រាជ្ញទាំង ៤, បើអ្នកឯណាពុំយល់នូវអាថ៌ប្រស្នានោះទេ អញនឹងបំបរបង់បេញពីស្រុក, បើអ្នកឯណាដឹងហើយ អញធ្វើសក្ការបូជាអ្នកប្រាជ្ញនោះហោង, រីថ្ងៃនេះឯងជាវេលាកាលគួរ ដល់ថ្ងៃស្អែក ឯងអញនឹងដណ្តឹងអស់អ្នកប្រាជ្ញផង កាលដែលឡើងមកគាល់បំរើនោះហោង ។ សោ ទុតិ ទិវសេ លុះព្រឹកឡើងវិញទៀត, ពោធិសត្វនូវអាចារ្យទាំង ៤ រៀងទៅគាល់ព្រះមហាក្សត្រ ទើបព្រះមហាក្សត្រមានព្រះបន្ទូលដណ្តឹងអស់អាថ៌ប្រស្នានឹងអ្នកទាំង ៤ សូត្រជាបទគាថាដូច្នេះថា:

យេសំ ន កទាចិ ភូតបុព្វំ
សក្ខំ សត្តបទម្បិ ឥមស្មិ លោកេ
ជាតា អមិត្តា ទុវេ សហាយា
បដិសន្ធាយ ចរន្តិ កិស្ស ហេតុ ។

(គោ បញ្ចប ល្ហ៊ិតា) ម្នាលអ្នកប្រាជ្ញទាំង ៤ អើយ វិសត្វផង ទាំងឡាយឯណាមានដើរនោះ ៧ កន្ទុះ មកយកគ្នាជាមិត្តសន្ថវ: អំពីមុន មក ពុំដែលមានឮដំណោកនេះ, ដ្បិតសត្វទាំង ២ នេះជាសត្រូវផងគ្នា, ឥឡូវនេះ មកកើតមានជាសំឡាញ់ផងគ្នា ជឿទុកចិត្តគ្នា ហេតុប្រការ ដូចម្តេច? ចូរអ្នកទាំងឡាយ ស្រដីឆ្លើយនូវអាថ៌ប្រស្នានោះមក នាឥឡូវ នេះហោង ៗ បើអ្នកទាំងឡាយមិនអាចដើម្បីនឹងស្រដីឆ្លើយអាថ៌ប្រស្នា នោះបាន ឮដំកាលហួបបាយព្រឹកនេះហើយ អញនឹងបំបរបង់អ្នក ទាំងឡាយចេញអំពីស្រុកនេះ ប្រយោជន៍អញឥតអង្គីមានទីងអ្នកប្រាជ្ញ ទាំងឡាយនេះឡើយ ដោយហេតុមានកំណើតជាអ្នកល្ងង់ខ្លៅដូច្នេះ ៗ

សេណកោ អត្តាសនេ បិសិណ្ហោ វិអាចារ្យសេនកអង្គុយ នៅឮដំអាសនាប្រសើរ ៗ វិពោធិសត្វសោត អង្គុយអាសនាជាបង្អស់ បានពិចារណានូវអាថ៌ប្រស្នានោះមិនយល់សោះឡើយ, វិពោធិសត្វគិតថា ព្រះមហាក្សត្រនេះ មានប្រាជ្ញានេះយូរ សមបើមានយ.ប់ហេតុអ្វីមួយ តិចតួច ទើបមកចងជាអាថ៌ប្រស្នានេះ ដោយនូវហេតុនោះឯងមិនទេ ឡើយ ៗ វិអាចារ្យទាំង ៤ រំពឹងដញ្ញឹងគិតនូវអាថ៌ប្រស្នាក៏មិនយល់ដល់ តិចឡើយ ឧបមាដូចអ្នកមួយចូលទៅក្នុងល្វែងងងឹតអន្ធការ មានប្រការ ម្តេចមិញ, វិអាចារ្យទាំង ៤ រំពឹងគិតពុំយល់ដូច្នោះហោង ៗ សេណកោ

រីអាចារ្យសេនក រមិលមើលពោធិសត្វហើយគិតថា រីចៅមហោសថ ដឹងអាថ៌ប្រស្នានេះហើយឬម្តេចអេះ? ។

សោ មហាសត្តោ រីព្រះមហោសថសោតរមិលមើលទៅកាន់ អាចារ្យសេនក, រីអាចារ្យសេនកដឹងនូវបំណងនៃពោធិសត្វធ្វើអាការ រមិលមើលនោះហើយ ក៏សំគាល់ថា ចៅមហោសថនេះ ពុំអាចដើម្បី នឹងឆ្លើយនូវប្រស្នានោះ ហេតុនឹងចង់អវកាស, ។ រីអញសោត នឹង បំពេញចំណង់ចិត្តនៃមហោសថ ក៏គិតដូច្នោះ ហើយសើចនូវសំណើច នោះខ្ចាំង ហើយទូលថា បពិត្រមហាកដអើយ បើយើងខ្ញុំទាំងនេះពុំអាច ឆ្លើយប្រស្នានេះបាន តើមហាកដនឹងបំបរបង់យើងខ្ញុំទាំងនេះមែនពិត ឬម្តេច? ។ ព្រះបាទវិទេហកដមានព្រះបន្ទូលថា អាម បណ្ឌិតាតិ នៃហអ្នកប្រាជ្ញអើយ បើគេអាថ៌ប្រស្នានេះពុំយល់ឡើយ អញនឹងបំបរបង់ មែនពិត ឲ្យចេញផុតអំពីស្រុកនេះហោង ។ ទើបអាចារ្យសេនកទូលព្រះ មហាក្សត្រទៀតថា បពិត្រមហាកដអើយ, រីអម្ចាស់ចង់ដាក់អាថ៌ប្រស្នា នេះមកឲ្យយើងខ្ញុំទាំងនេះឆ្លើយនោះ យើងខ្ញុំទាំងនេះ ពុំអាចដើម្បីនឹង ឆ្លើយនូវប្រស្នានេះថ្វាយព្រះអង្គឥឡូវនេះបានឡើយ ដ្បិតអាថ៌ប្រស្នានេះ ជាក់ជាំង សូមអម្ចាស់អត់ទ័ងបន្តិច ខ្ញុំនឹងក្រាបលាទៅត្រិះរិះគិតឲ្យជំហាន ស្ងាត់ ហើយខ្ញុំនឹងមកឆ្លើយថ្វាយព្រះអង្គ ដ្បិតឥឡូវនេះ អស់មហាជន ជនទាំងឡាយមកជុំកោលាហលវល់ច្រើន យើងខ្ញុំជាអ្នកប្រាជ្ញទាំង ៤

មានចិត្តគំនិតរោះព្រាយខ្វាយជាអនេក មិនអាចដើម្បីនឹងឆ្លើយនូវប្រស្នានោះបានឡើយ ។ ហេតុនោះ យើងខ្ញុំទាំងឡាយនឹងអង្គុយឋានស្ងាត់ដោយខ្លួនទីទៃ ហើយនឹងត្រិះរិះគិតនូវអាថ៌ប្រស្នាទាំងនេះ ពិចារណានៅឋានស្ងាត់នោះហោង ។

រាជា តស្ស វាចំ សុត្វា ។ល។ ព្រះមហាក្សត្រស្តាប់ពាក្យអាចារ្យសេនកទូលដូច្នោះហើយ មានព្រះហឫទ័យត្រេកអរ មានព្រះបន្ទូលគំរាមថា បើអ្នកឯណាឆ្លើយប្រស្នានេះពុំបានទេ អញនឹងបំបរបង់ចេញអំពីស្រុកហោង ។ តេ ចត្តារោបិ បណ្ឌិតា បាសាទា ឱតរិសុ អ្នកប្រាជ្ញទាំង ៤ ក្រាបលាព្រះមហាក្សត្រ ចុះអំពីប្រាសាទទៅហើយ អាចារ្យសេនកស្រដីនឹងអាចារ្យទាំង ៣ ថា ព្រះមហាក្សត្រមានព្រះបន្ទូលដណ្តឹងប្រស្នាអាថ៌កំបាំងទាំងនេះ បើអ្នកឯណាឆ្លើយនូវអាថ៌ប្រស្នានេះពុំបានទេ ភ័យសោកនឹងកើតមានដល់អ្នកនោះហោង ។ ដូច្នេះ អ្នកទាំងឡាយ បរិភោគនូវអាហារបាយទឹកហើយ ចូរពិចារណានូវប្រស្នានោះ ដោយប្រពៃហោង, ម្នោះហើយអាចារ្យទាំង ៤ នោះចុះទៅកាន់ឋានលំនៅអាត្មាទីទៃ ៗ ហោង ។ ឯពោធិសត្វក្រាបលាព្រះមហាក្សត្រហើយ ទៅកាន់សំណាក់នៃនាងឧទុម្ពរទេវីដណ្តឹងថា បពិត្រអ្នកនាងឧទុម្ពរទេវីក្សត្រីប្រសើរអើយ, នាថ្ងៃនេះក្តី អំពីម្សិលមិញក្តី, ព្រះមហាក្សត្រ តើស្តេចគង់នៅឋានឯណាដ៏លង់យូរម្ល៉េះ ? ។ នាង

ឧត្តរទេវីស្រដីថា ម្នាលបាមហោសថអើយ, កាលអំពីម្សិលមិញ, ព្រះមហាក្សត្រស្ដេចយាត្រាទៅដោយនូវល្វែកចំលួយប្រាសាទ ហើយ ទ្រង់ចេញទៅដោយនូវល្វែកបង្អួចនោះហោង ។

លំដាប់នោះ, ពោធិសត្វស្ដាប់ពាក្យនាងឧត្តរប្រាប់ដូច្នោះហើយ ទ្រង់ព្រះចិន្តាគិតថា ព្រះមហាក្សត្រ សមបើមានយល់អ្វីមួយបន្តិចបន្តួច ហើយ ក៏គិតដោយនូវហេតុយោបល់យល់មិនទៅឡើយ ។ ទើបពោធិ-សត្វលានាងឧត្តរ ហើយទៅឰដ៏ឋាន ដែលព្រះមហាក្សត្រទៅនោះ រមិលមើលចុះទៅខាងឯក្រោម ក៏យល់ឆ្កែនឹងពពែធ្វើនូវអំពើជាមិត្តសន្ថវៈ ផងគ្នាដូច្នោះ ពោធិសត្វអ្នកក៏កត់សំគាល់ក្នុងព្រះហឫទ័យថា ប្រស្នា នៃស្ដេចនេះ គិតតាមដោយហេតុយល់សត្វនោះហោង ។ ពោធិសត្វ យល់សត្វទាំងពីរដូច្នោះហើយ ព្រះអង្គវិលចុះទៅកាន់លំនៅនៃអាត្មា ហើយលីលាចូលទៅស្រង់ជំរះព្រះអង្គដោយទឹកអប់ ត្រឡប់នូវគន្ធពិដោរ រួចហើយ បរិភោគអាហារមានឱជារសស្រេច ស្ដេចគង់សម្រាន្តសប្បាយ ព្រះអង្គហោង ។

ឥតោ បរំ តយោ បណ្ឌិតា បញ្ហំ អទិស្វា សេនកស្ស សន្តិកំ អគមិំសុ ។ បពិត្រអើយ, អាចារ្យ បុក្កុស, កាមិន្ទ, ទេវិន្ទ, ទាំង ៣ រៈគិតរំពឹងនូវអាថប្រស្នានោះពុំយល់ឡើយ ក៏នាំគ្នា ទៅកាន់សំណាក់អាចារ្យសេនក, រីឯអាចារ្យសេនកយល់អ្នកទាំង ៣

ដូច្នោះហើយ ក៏ដណ្ដឹងថា ម្ដេចទៅអ្នកទាំងឡាយ! យល់អាថ៌ប្រស្នានោះហើយឬនៅឡើយ? អាចារ្យទាំង ៣ ឆ្លើយថា អាចរិយ ហៃអ្នកអាចារ្យអើយ យើងទាំងនេះគិតមិនយល់ដល់តិចឡើយ ។ ទើបអាចារ្យសេនកថា បើមិនយល់ដូច្នេះតើ ស្ដេចនឹងបំបរបង់យើងទាំងឡាយចេញអំពីស្រុកនេះមិនទេឡើយ ។ រីអាចារ្យទាំង ៣ ដណ្ដឹងទៅអាចារ្យសេនកវិញថា ដូច្នោះឯអាចារ្យឯងតើម្ដេចទៅ? យល់អាថ៌ប្រស្នានោះហើយឬនៅឡើយ? ។ រីអាចារ្យសេនកឆ្លើយថា អ្នកទាំងឡាយអើយ អញក៏ពុំយល់ដែរ, បើដូច្នេះ តើយើងនឹងគិតដូចម្ដេច? នាកាលអំពីម្សិលមិញនោះ យើងក្រាបទូលព្រះមហាក្សត្រនូវពាក្យសីហនាទថា យើងលាមករិះគិតរកអាថ៌ប្រស្នានេះឲ្យយល់ ហើយយើងនឹងឡើងទៅឆ្លើយថ្វាយព្រះមហាក្សត្រ, ឥឡូវនេះ យើងរិះគិតរកអាថ៌ប្រស្នានេះពុំយល់ នឹងឆ្លើយថ្វាយពុំបាន, ដូច្នេះ សមព្រះមហាក្សត្រខ្ញាល់នឹងយើងហោង, រីអាថ៌ប្រស្នានេះសោត យើងទាំងឡាយក៏មិនអាចដើម្បីនឹងយល់ឡើយ, មានតែចៅមហោសថអ្នកប្រាជ្ញ ទើបអាចយល់អាថ៌ប្រស្នានេះបាន, ដ្បិតគាត់មានប្រាជ្ញាប្រតិពលយល់នូវអាថ៌ប្រស្នាជាវេយជាពន់គុណ ក្រៃលែងនឹងយើងទាំងឡាយនេះ, បើដូច្នោះ យើងនឹងនៅឯណាបាន មានតែយើងទៅកាន់ចៅមហោសថអ្នកប្រាជ្ញ ទើបនឹងអាចដណ្ដឹងសួរនូវអាថ៌ប្រស្នានេះ ។

តេ ចត្តារោ បណ្ឌិតា ។ល។ អ្នកប្រាជ្ញទាំង ៤ នោះ នាំគ្នាទៅដល់ទ្វារផ្ទះពោធិសត្វ ហើយដណ្ដឹងទៅថា: ចៅមហោសថ នៅទេហ៎:? ពោធិសត្វឮហើយឆ្លើយថា ខ្ញុំនៅទេ, ចូរអ្នកអាចារ្យចូលមកហោង, ម្នោះហើយអាចារ្យទាំង ៤ ចូលទៅក្នុងផ្ទះពោធិសត្វ ហើយធ្វើនូវបដិសណ្ឋារបណ្ដាលមេត្រីស្រដីដណ្ដឹងពោធិសត្វថា កឹ ៈណ្ឌិត ហៃអ្នកប្រាជ្ញអើយ រីឯចំប្រស្នានេះ តើបានគិតយល់ហើយ ឬនៅទៀយ ។ ពោធិសត្តោ តេសំ កថំ អាហ ពោធិសត្វស្ដាប់ពាក្យអាចារ្យទាំង ៤ ដណ្ដឹងដូច្នោះហើយ ឆ្លើយថា អាចរិយ ហៃអាចារ្យអើយ រីឯចំប្រស្នានេះ អញបានគិតហើយ បើអញមិនបានគិត តើនឹងមានអ្នកឯណាមួយដទៃក៏នឹងអាចគិតបាន ។ ទើបអាចារ្យទាំង ៤ ស្រដីថា ហៃមហោសថអ្នកប្រាជ្ញអើយ បើចៅបានគិតយល់ដូច្នោះក៏ជាហើយ ចូរចៅសំដែងប្រាប់យើងឲ្យដឹងផង៉ា; រីពោធិសត្វស្ដាប់ហើយគិតថា បើអញមិនប្រដៅអ្នកទាំងនេះទេ សមព្រះមហាក្សត្រនឹងទ្រង់ព្រះក្រោធពិរោធ បំបរបង់អ្នកប្រាជ្ញទាំង ៤ នេះចេញអំពីស្រុក ហើយព្រះមហាក្សត្រនឹងធ្វើនូវសក្ការបូជាអញ ដោយរតនវត្ថុ ៧, រីអ្នកពាលទាំង ៤ នោះសោត នឹងវិនាសប្រាសចេញអំពីសម្បត្តិពុំលែងឡើយ, បើដូច្នេះ គួរអញនឹងណែប្រដៅអ្នកទាំង ៤ កុំឲ្យវិនាសប្រាសចេញអំពីសម្បត្តិឡើយ,

ទាំង ៤ អើយ បើអ្នកទីងចង់ដឹងអាថ៌ប្រស្នានេះ អញនឹងណែប្រដៅអ្នក ហោង, ម៉្លោះហើយពោធិសត្វអ្នកឲ្យអាចារ្យទាំង ៤ អង្គុយឰ៍ឋានទាប ហើយឲ្យលើកកំបង់អញ្ជលីប្រណម្យ, ហើយពោធិសត្វបង់ជាព្រះគាថា ឲ្យអាចារ្យទាំង ៤ ទន្ទេញរៀនដោយខ្លួនទីទៃ ១ ឲ្យបានដឹងជាក់ច្បាស់ ប្រាកដ ឲ្យជ្រាបតែព្រះអង្គមហាសត្វឯង ហើយពោធិសត្វផ្តាំថា អ្នកទាំងឡាយរៀនចាំហើយ ចូរអ្នកទាំងឡាយឆ្លើយព្រះបាលីនេះថ្វាយព្រះមហាក្សត្រហោង ។ រីអាចារ្យទាំង ៤ រៀនទន្ទេញដោយខ្លួនចាំសព្វគ្រប់ ហើយ លាពោធិសត្វវិលទៅកាន់លំនៅអាត្មា លុះព្រឹកឡើងនាំគ្នាទៅកាន់ប្រាសាទព្រះមហាក្សត្រ លុះទៅដល់ហើយក្រាបថ្វាយបង្គំព្រះមហាក្សត្រ ហើយអង្គុយទៅលើកំពលអាសនាមួយអន្លើសមគួរនឹងអាត្មា ។ ពោធិសត្វមហាបុរសរតន៍ប្រសើរ ក៏លីលាឡើងទៅដល់ហើយក្រាបថ្វាយបង្គំព្រះមហាក្សត្រ ហើយអង្គុយទៅលើកំពលមួយអន្លើ សមគួរនឹងអាត្មាហោង ។

(នៅមានត)

# សង្គហវត្ថុគាថា

## បរិយាយអំពីរបៀបបណ្តុះសាមគ្គីនិងផ្សាសាមគ្គី

លោក ហេង-សមអាន

អតីតគ្រូបង្រៀនយុទ្ធសាស្ត្រ នៃមជ្ឈមណ្ឌលសិក្សាពលថ្មើរជើងខេត្តពោធិសាត់

រៀបរៀង

---

បទពាក្យ ៧

ឧបាយសម្រាប់សង្គ្រោះគ្នា　ស្រោចស្រង់ជន្មាឲ្យបានសុខ
ចំពោះមនុស្សជាតិមិនរើសមុខ　ព្រះពុទ្ធត្រាស់ទុក ៤ ប្រការ ៗ

### សង្គហៈ ទី ១

ទី ១- ទាន រំលែកចែក　ឲ្យជាចំណែកដោយមេត្តា
ដល់មនុស្សទូទៅក្នុងលោកា　ជ្រះថ្លាបរិច្ចាគដោយស្មោះស្ម័គ្រ ៗ
ទាននេះលោកចែកចេញជាពីរ　មានក្នុងគម្ពីរប្រាកដជាក់
១- ឲ្យចំពោះមនុស្សម្នាក់ ៗ　ហៅអសាធារណទាន ៗ
មាតាបិតាឲ្យអាហារ　ប្រដាប់ប្រដាសព្វធនធាន
មាសប្រាក់កែវកងដែលលោកមាន　ចែកឲ្យជាទានបុត្តធីតា ៗ
នាយចៅហ្វាយចែកចាយមាសប្រាក់　សំលៀកបំពាក់ព្រហូលផ្កា
ឲ្យដល់កម្មករដោយមេត្តា　យ៉ាងនេះហៅថា “ការសង្គ្រោះ” ៗ

ឯបុត្តធីតាដល់ខ្លួនធំ　　រូបពេញក្រមុំពេញកម្លោះ
មានប្តីប្រពន្ធរួមស្ម័គ្រស្មោះ　　ប្រឹងគ្នាបន្ទោះខំធ្វើការ ៗ
បានមាសបានប្រាក់ទិញចំណី　　ខោអាវថ្មីៗព្រមមុយអា
ជូនទៅមាតានឹងបិតា　　ចាក់ថ្នមរក្សាបានសប្បាយ ៗ
កូនក្មួយកម្មករទាំងប្រុសស្រី　　មានចិត្តមេត្រីនាយចៅហ្វាយ
ឧស្សាហ៍សួរសុខទុក្ខក្នុងកាយ　　ជូនបរបាយដោយប្រណីត ៗ
ទានសភាពនេះលោកហៅអ-　　សាធារណប្រាកដពិត
វ៉ែកទានឹងបូជាគុណអតីត　　តបស្នងសងពិតគុណដែលមាន ៗ
២. ឲ្យចំពោះជនទូរទៅ　　លោកហៅ "សាធារណទាន"
មហាក្សត្រមន្ត្រីនឹងអ្នកមាន　　ដាក់ទានទូទៅដោយមេត្តា ៗ
ចំពោះមនុស្សសត្វទាំងអស់ផង　　មិនឲ្យសៅហ្មងក្នុងចិន្តា
លះបង់កំណាញ់សង់សាលា　　ជីកស្រះដាំផ្កាលើកផ្លូវថ្នល់ ៗ
សាងមន្ទីរពេទ្យការជម្ងឺ　　សម្រាប់មនុស្សឈឺជាសាកល
នឹងសាងសាលារៀនឲ្យដល់　　មហាជនរៀនគល់រៀនសីលវៃយ ៗ
ទានជាសាធារណ៍ទាំងអស់នេះ　　ជាទានវិសេសល្អប្រពៃ
មានអានិសង្សច្រើនក្រាស់ក្រៃ　　ជាទានថ្លាថ្លៃលើសលើទាន ៗ
អាចឲ្យសុខសួស្តីជាច្រើនដល់　　មនុស្សទាំងសាកលក្រនឹងមាន
ទទួលសុខស្រួលអំពីទាន　　មានស្រះមានស្ពានមានសាលា ៗ

ទានមានអានិសង្សច្រើនលើសគេ
គម្ពីរដីកាពុទ្ធសាសនា
សុខនៃបុគ្គលតែម្នាក់ ៗ
សុខស្រួលសប្បាយគេទុកគ្មាន
បុគ្គលតែម្នាក់មិនអាចនៅ
បើប្រៀបនឹងសុខជនច្រើនគ្នា
សុខនៃត្រកូលវង្សគ្រួសារ
ទាំងមា ទាំងមីងមិនញេម
សុខក្នុងគ្រួសារសុខប្រសើរ
បើប្រៀបនឹងសុខជននានា
សុខនៃជនរួមជាតិទាំងឡាយ
ជាសុខទូលាយពិតប្រាកដ
សុខជនរួមជាតិសុខប្រសើរ
សុខស្រួលទូលាយក្នុងភាក
សុខស្រួលយ៉ាងនេះគង់មិនស្មើ
ជនសាកលលោកទាំងប្រុសស្រី
ព្រោះជាសាធារណសុខ
ពិភពលោកនេះដែលត្រូវបាន

តាមខ្ញុំរិះរេបានសិក្សា
ឃើញថា "សាធារណទាន" ៗ
បញ្ជាក់តាមថ្នាក់ក្រនឹងមាន
តែសុខមិនមានជាតិខ្លឹមសារ ៗ
រមែងព្រាត់ទៅជាធម្មតា
នោះប្រាកដជាសុខតែល្មម ៗ
មាតាបិតាកូនចៅព្រម
សុខស្រួលទាំងព្រមនៅយូរយារ ៗ
គ្រាន់បើព្រោះសុខបានច្រើនគ្នា
ឈ្មោះថាពិតជាអន់ប្រាកដ ៗ
ប្រុសស្រីជិតឆ្ងាយកាយពលរដ្ឋ
ទាំងនៅម៉ត់ចត់គ្រប់វេលា ៗ
គ្រាន់បើព្រោះសុខជាសាធារណ៍
សុខបានច្រើនគ្នាទាំងប្រុសស្រី ៗ
ប្រសើរដល់សុខលើផែនដី
ជាសក្តិក្នុងក្តីដែលត្រូវបាន ៗ
ក្នុងដែនភូមិស្រុកស្ថិតលើស្ថាន
សុខស្រួលក្សេមក្សាន្តឥតឧបមា ៗ

ទានជាឧបាយយោគយឹកយោង　ដឹកនាំគោងឈោងទាញចិត្ត
ដល់អ្នកទទួលគ្រប់រូបា　ឲ្យស្និទ្ធស្នេហាអ្នកអំណោយ ។
បើសិនជាម្ដាយឬឪពុក　តែលាក់ទ្រព្យទុកមិនចែកឲ្យ
ដល់បុត្រធីតាលុះពេលក្រោយ　នោះនាំឲ្យក្ដាយកូនទៅស្អប់ ។
ឬក៏ទៅហ៊ាយអ្នកត្បិតត្បៀត　កំណាញ់ចោលមៀតត្បៀតទាំងសព្វ
មិនចែករំលែករបស់ទ្រព្យ　ជាទីសំអប់នៃកម្មករ
អ្នកបរិច្ចាគជាសាធារណ៍　ដល់គ្នានឹងគ្នាដោយស្មោះសរ
កិត្តិនាមល្បីល្បាញផ្សាយខ្ចរ　អ្នកមានអ្នកក្រត្រេកអរណាស់ ។
តែមុននឹងឲ្យត្រូវរំពឹង　ត្រិះរិះសញ្ជឹងមើលឲ្យច្បាស់
ផលល្អអាក្រក់កុំផ្ដេសផ្ដាស　ក្រែងប៉ះប្រទះខូចអាសា ។
ឲ្យហើយខូចវិញក៏សឹងមាន　ដូចមនុស្សសុំទាននៅក្នុងផ្សារ
មិនមែនជាមនុស្សខ្វិនពិការ　កម្លាំងដូចខ្លាឬកដូចឆ្កែ ។
ប៉ុន្តែជាមនុស្សខ្ជិលមុខក្រាស់　មិនចេះអៀនខ្មាសចែប្រចែប្រ
គ្មានទីដំណេកដេកដូចឆ្កែ　ជ្រកកំពង់ផែក្បែរផ្ទះផ្សារ ។
ព្រឹកល្ងាចដើរសុំគេប្រែកព្រូក　សុំបេរាវទឹកកក កាកអាហារ
សុំអាវ សុំប្រាក់ សុំក្រមា　ម្នាះហើយទិញស្រាផឹកសប្បាយ ។
ឯសូមបែបនេះ ទុកជាឲ្យ　ប៉ុន្មានក៏ដោយក៏អន្តរាយ
ព្រោះជាមនុស្សខ្ជិលចេះតែចាយ　សាបសូន្យអន្តរាយទ្រព្យរបស់ ។

បើឲ្យមិនបានរិះសញ្ជឹង　　ពិនិត្យសំឡឹងមើលឲ្យអស់
ឬកអ្នកទទួលទ្រព្យរបស់　　មិនហៅសប្បុរសទានឡើយណា ៗ
ជនជាសប្បុរសមិនគិតកាញ់　　លះបង់កំណាញ់ដោយបញ្ញា
បរិច្ចាគធនធានគ្រប់ប្រការ　　ផ្គត់ផ្គង់សាសនា ប្រទេសជាតិ ៗ
ជាសារប្រយោជន៍បានទូទៅ　　មិនត្រោះសំដៅតែក្រុមញាតិ
ទោះសាសន៍ដទៃកាយក្លាយឃ្លាត　　ដែលជាមនុស្សជាតិដូច ១ គ្នា ៗ
ទានដែលអ្នកឲ្យអ្នកទទួល　　ចិត្តស្មើស្រុះស្រួលគ្រប់វេលា
បរិសុទ្ធទាំងពីរដូច ១ គ្នា　　យ៉ាងនេះហៅថា សង្គហៈ ៗ
បើគ្រាន់តែបេះលះធនធាន　　ចែកចាយជាទានដោយចិត្តស្ម័គ្រ
ប៉ុន្តែមិនចេះពាក្យពក់ទាក់　　ពីរោះស្មោះស្ម័គ្រស្និទ្ធមេត្រី ៗ
វត្ថុដែលឲ្យច្រើនក្រាស់ក្រៃ　　សុទ្ធតែតម្លៃថ្លៃថោងថ្មី
ហាក់ដូចជាតិចពុំគប្បី　　ព្រោះតែសំដីពោលទ្រគោះ ៗ
បើពោលពាក្យល្អគួរស្នេហ៍ស្និទ្ធ　　អ្នកផងជាប់ចិត្តស្នេហ៍ស្ម័គ្រស្មោះ
សូម្បីតែឲ្យតិចតួចសោះ　　បានឈ្មោះថាឲ្យច្រើនអស្ចារ្យ ៗ
ហេតុនោះទើបអង្គព្រះសម្ពុទ្ធ　　ទ្រង់មានបុណ្យផុតមនុស្សទេព្ដា
ទ្រង់ត្រាស់ បេយ្យវជ្ជៈថា　　ប្រការទីពីរក្នុងបាលី ៗ

## សង្គហៈ ទី ២

ទី ២- បេយ្យវជ្ជៈ　　ពោលពាក្យពក់ទាក់ស្និទ្ធមេត្រី

ពីរោះគាប់ចិត្តជនប្រុសស្រី បាស់ក្ដីក្មេងក្ដីចង់ស្ដាប់ពាក្យ ។
ឈ្លាសគួរបង្ហើសណ្ឋានៈ ទទួលពាក់ពាក់មិនឲ្យឃ្លាត
ពោលពាក្យពីរោះទៅគេញាតិ នឹងជនមេជាតិកួរសង្គម ។
ខុសក្រហាំពាក់ទង់ក្បាប់ពាក់ពាក់ មិនប្រកាន់ថ្នាក់សក្ដិតូចៈធំ
ពោលពាក្យពីរោះល្អសុខុម ដល់មនុស្សតូច-ធំក្នុងលោកា ។
ផ្ដើមខ្លួនជាទីពេញទឹកចិត្ត ឲ្យមនុស្សឆ្ងាយជិតស្និទ្ធស្នេហា
បានមាសបានប្រាក់ច្រើនប្រការ ដូចមានគាថាព្រះពុទ្ធត្រាស់ ។

មនាបមេវ ភាសេយ្យ នាមនាបំ កុទាចនំ
មនាបំ ភាសមានស្ស គរុភារំ ឧទព្ពហិ
ធនញ្ច នំ អលាភេសិ តេន ចត្តមនោ អហុ(១)

"គ្រប់ពេលទាំងនឹងកាត្រ បុគ្គលប្រុសស្រីទាំងក្មេងចាស់
ត្រូវពោលពាក្យផ្អែមពីរោះច្បាស់ មិនត្រូវពោលបង្អាសប្រាសល្អឡើយ ។
កាលព្រាហ្មណ៍ពោលពាក្យស្នេហ៍ស្និទ្ធស្នាល គោនន្ទវិសាលមិនកន្ដើយ
ទាំអូសរទេះធ្ងន់បានហើយ គោញុំាងព្រាហ្មណ៍ឲ្យបានមាសប្រាក់ ។
អត្ថសញ្ញា ក៏ថា ពាក្យមានខ្លឹមសារ, ពាក្យត្រជាក់
និយាយពន្យល់អត្ថសព្ទ: អ្នកស្ដាប់ពាក់ពាក់គាប់អាន ។
ដោយឃើញប្រយោជន៍ពិតប្រាកដ ស្ដាប់យកជាវត្តប្រតិបត្តិបាន
បណ្ដុះបញ្ញាច្បាគ្រប់ប្រាណ អ្នកពោលក៏បានជាមេស្នេហ៍ ។

១– ខុទ្ទកនិកាយ ឯកនិបាតជាតក បឋមភាគ ។

ព្រះពុទ្ធបារមីរស្មីថ្កើង តម្កើងព្រះអានន្ទថេរ
ជាធម្មកថិកថ្លឹកត្រៃ អាចប្រែដោះសារធម្មបរិយាយ ។
បរិស័ទ ៤ ពួក,ពួកណាមួយ កើតកង្វល់ព្រួយមិនសប្បាយ
គ្រាន់តែបានឃើញព្រះរូបកាយ ក៏បានរសាយតាកទុក្ខា ។
បើព្រះអានន្ទសំដែងធម៌ បរិស័ទត្រេកអរសោមនស្ស
មិនចេះឆ្អែតឆ្អន់ដោយកថា របស់ព្រះមហាអានន្ទឡើយ ។
ព្រះសម្ពុទ្ធបរមគ្រូ ជាសព្វញ្ញូពុំកន្តើយ
ទូន្មានបរិស័ទឥតស្រាកឡើយ ដឹកនាំដល់ត្រើយព្រះនិព្វាន ។
ពន្យល់ឲ្យលះបង់អធម៌ ញ៉ាំងឲ្យត្រេកអរនឹងសីលទាន
កាន់យកនូវធម៌ផ្លូវនិព្វាន ទានសីលភាវនាបីប្រការ ។
ថែមទាំងបានអគ្គព្រះសាវ័ក ឈ្លាសវៃពិតទ័គ្គស្ទួយសាសនា
ព្រះសារីបុត្រទ្រង់បញ្ញា រកមនុស្សទេព្ដាប្រដូចគ្មាន ។
ព្រះអានន្ទចាំធម៌ទាំងអស់ ឥតខ្ចោះទេសនាព្រះទ្រង់ញាណ
ព្រះអនុរុទ្ធបារមីមាន ស្ទាក់ខាងចូលឈានដូចព្រះពុទ្ធ ។
ព្រះមោគ្គល្លានមានឫទ្ធិ សាវ័កទី ២ ខ្លាំងមោះមុត
អាចហែលមុជជ្រែកក្នុងសមុទ្រ ហោះឡើងខ្ពស់ផុតអាកាសា ។
ព្រះមោគ្គល្លានមានបារមី អាចផ្កាប់ផែនដីឆ្វេងហត្ថា
ព្រះហស្ដខាងស្ដាំដាក់សក្ដា មនុស្សនឹងទេព្ដា យួន-ចិន-ខ្មែរ ។

ព្រះមោគ្គល្លានពន្លឺមុនី អាចចាប់គ្រវីភ្នំសុមេរុ
បាក់ដូចកូនក្មេង ចិន-យួន-ខ្មែរ គ្រវីអែកឡែដូចខ្លោះឯង ។
ព្រះមោគ្គល្លានមានពលា អាចមូរមេឃាដ៏ធំធេង
ដូចមូរកន្ទេល,ផ្ដៅ,កន្ទ្រង ដោយឥតប្រឹងប្រែងព្រះអង្គប្រាណ(១) ។
ដោយមានសាវ័កឈ្លាសមោះមុត ទើបព្រះសម្ពុទ្ធប្រតិស្ឋាន
សាសនាស្ថិតនៅអវសាន គ្រប់បានប្រាំពាន់ព្រះវស្សា ។
រ់បាទន់កូន់ដ៏ឧត្តម ញុំាងប្រយោជន៍ធំក្នុងកិច្ចការ
ដឹកនាំប្រទេសនិងសាសនា ទើបលោកហៅថា សដ្ឋរាជ ។
បើបេះធ្វើមាននិងនិយាយ ពីពេះរួសពយគួររួមរ័ក្ស
ប៉ុន្តែជាមនុស្សចិត្តមិនស្ម័គ្រ គ្រាន់តែពក់ទាក់ពាក្យសំដី ។
មិនធ្វើប្រយោជន៍ជាសាធារណ៍ ដល់ក្នានិងគ្នា ទាំងប្រុសស្រី
ជាហេតុនាំឲ្យស្ងួនស្រេចក្ដី ស្និទ្ធស្នាលមេត្រីទៅវិញបាន ។
ប្រព្រឹត្តប្រយោជន៍ជាសាធារណ៍ គ្រប់ពេលវេលាមិនដែលខាន
ជាគុណប្រយោជន៍ហ៊ែងបំណាន មហាជនគប់អានស្និទ្ធស្នេហា ។
ហេតុនោះទើបព្រះសព្វញ្ញូ ជាគ្រូលើមនុស្សនិងទេព្ដា
ទ្រង់ត្រាស់អត្ថចរិយា ប្រការទីបីពិតប្រាកដ ។

១- បាកធម្មបទដ្ឋកថា ភាគទី ៦ ត្រង់យមកប្បាដិហារ្យ ។

## សង្គហៈ ទី ៣

ទី ៣- អត្ថចរិយា    បាលីប្រែថាការប្រព្រឹត្ត
ជាសារប្រយោជន៍ល្អពិត ៗ    ដល់មនុស្សឆ្ងាយជិតក្នុងវង្សា ៗ
វេយ្យាវច្ចៈជួយចាត់ចែង    ខ្វល់ខ្វាយខ្នះខ្នែងក្នុងកិច្ចការ
ឲ្យបានសម្រេចដូចប្រាថ្នា    បានឆាប់រួចការទាំងនោះឯង ៗ
មាតាបិតាជួយខ្វល់ខ្វាយ    ជួយកូនទាំងឡាយក្នុងការស្វែង
រកទ្រព្យសម្បត្តិ, ផ្ទះសំបែង    នឹងជួយខ្នះខ្នែងការសិក្សា ៗ
ចំណែកប៉ែកកូនទាំងប្រុសស្រី    ខំជួយឃ្លាតខ្វីក្នុងកិច្ចការ
របស់មាតានឹងបិតា    ជួយគ្រប់កិច្ចការដោយពក់ពាក់ ៗ
នាហ្នឹងតូចធំជួយខ្វល់ខ្វាយ    ដល់ជនទាំងឡាយមកពឹងពាក់
ទំនុកបំរុងប្រុងស្មោះស្ម័គ្រ    ឲ្យមានយសសក្តិមាសប្រាក់តាយ ៗ
រមែងជាទីស្និទ្ធមេត្រី    នៃជនប្រុសស្រីគ្រប់រូបកាយ
ដែលបានមកពីទីជិតឆ្ងាយ    ពឹងឲ្យដោះស្រាយឆាកជីវ៍ ៗ
ជនមកជ្រកកោនត្រូវម៉ឺងម៉ាត់    ខំប្រឹងប្រតិបត្តិគ្រប់កិច្ចការ
ដែលលោកឲ្យធ្វើឲ្យសិក្សា    ប្រឹងគ្រប់កិច្ចការទាំងប្រុសស្រី ៗ
ធ្វើខ្លួនឲ្យលោកទុកចិត្តបាន    ហើយលោកប្រកាន់ចិត្តមេត្រី
ស្រឡាញ់ពេញចិត្តទាំងប្រុសស្រី    ទើបកើតសិរីសួស្តីពិត ៗ

ECOLE FRANCAISE D'EXTREME ORIENT BIBLIOTHEQUE

មិត្រក័ក្តិខ្វះខ្វែងជួយខ្វល់ខ្វាយ   កិច្ចការទាំងឡាយរបស់មិត្រ
ដោយកម្លាំងកាយ-វាចា-ចិត្ត   សេចក្តីស្នាលស្និទ្ធស្និតយូរយារ ។
បើទុកជាវង្សសាច់ញាតិជិត   តែមិនចេះគិតគុណៈគ្នា
មិនស្មើនឹងមិត្តចិត្តល្អជា   ជួយកិច្ចការគ្នាដោយចិត្តស្ម័គ្រ ។
វិស្សាសា បរមា ញាតី   រាប់អានមេត្រីក្តីរមៀក
ជាញាតិប្រសើរក្រៃអនេក   កែវកងមាសប្រាក់ថ្លៃមិនស្មើ ។
ធម្មសមាចរជា   ប្រែថា ដឹកនាំតាមដំណើរ
ផ្លូវលោកផ្លូវធម៌ល្អប្រសើរ   ដូចនាំឲ្យដើរផ្លូវសិក្សា ។
ឬជួយដឹកនាំឲ្យបានដល់   កម្មជាកុសលផ្លូវសាសនា
ឲ្យមានសាមគ្គីស្និទ្ធស្នេហា   រាប់ជាគ្រួសារគេអង្វែង ។
ព្រះថេរៈជាធម្មកថិក   ធ្វើព្រះឧស្សាហ៍ឥតខានសំដែង
ធម៌ដឹកនាំសត្វឲ្យខ្វះខ្វែង   ប្រឹងប្រែងធ្វើបុណ្យលះអបាយ ។
សត្វណាប្រព្រឹត្តអបាយមុខ   ជាគំនរទុក្ខក្តៅក្រហាយ
ដឹកនាំសត្វនោះឲ្យចៀសឆ្ងាយ   លះបង់អបាយ ៤ ប្រការ ។
ការធ្វើប្រយោជន៍ល្អពិត ១   ដល់មនុស្សឆ្ងាយជិតគង់លោកា
ទៅវិញទៅមកគេសុខា   យ៉ាងនេះហៅថា សង្គហៈ ។
បើចេះធ្វើតាមចេះនិយាយ   ពាក្យល្អពណ្ណពយគួររមៀក
នឹងធ្វើប្រយោជន៍ជាសារៈ   ដល់គ្នាដោយស្ម័គ្រហាក់សន្តាន ។

តែជាមនុស្សមិនចេះរៀបចំ ឲ្យល្មមសមរម្យដល់មាត្រាបាន
ចាស់ថាបង់ពោយមិនមើលព្រាណ ដាក់ដាំដើងក្រានមិនមើលផ្ទាំង ៗ
ជាហេតុនាំឲ្យសេចក្ដីស្និទ្ធ- ស្ពាលអស់ពីចិត្តដែលសម្រាំង
សាបសូន្យអន្តរាយទៅជាខ្មាំង ទន់ខ្សោយកម្លាំងសាមគ្គីធម៌ ៗ
បើប្រព្រឹត្តល្មមសមនឹងមាត្រ មនុស្សលោកគ្រប់ជាតិញាតិគ្រេកអរ
រាប់អានមេត្រីស្ន័ត្រស្មោះសរ មូលមកកុះករបងស្នេហា ៗ
ហេតុនោះព្រះលោកវិទូ ជាសព្វញ្ញូសាស្ដាចារ្យ
ទ្រង់ត្រាស់សមានត្តតា រាប់ថាទីបួនប្រាកដជាក់ ៗ

## សង្គហៈ ទី ៤

ទី ៤– សមានត្តតា បាលីប្រែថាភាពជាអ្នក
តាំងខ្លួនស្មើៗ ក្នុងធម្មៈ អធិប្បាយបញ្ជាក់តទៅថា ៗ
បុគ្គលវ័យក្មេងមានយសស័ក្តិ មានមាសមានប្រាក់មានបរិវារ
រុងរឿងថ្កុំថ្កើងខ្ពស់ថ្ងៃថ្លា ធ្វើខ្ញូវតែរិយាចេះកោតក្រែង ៗ
គាប់គួរគំនាប់ដល់ញាតិមិត្រ មានវ័យចាស់ពិតគ្រប់កន្លែង
ជួបទីណាៗក៏សំដែង គោរពកោតក្រែងយ៉ាងរាបសារ ៗ
ពីដើមមានចិត្តមិនគ្នាន់ក្នាញ់ រាប់អានស្រឡាញ់គ្នាយ៉ាងណា
ក្រោយមកក៏នៅតែស្នេហា យ៉ាងនោះលុះត្រាថាវរៈ ៗ

សាច់សារលោហិតមិត្រជិតឆ្ងាយ  រីកពាយសប្បាយក្រៃអន័គ្ស
ដោយបានទទួលគារវៈ  ពីអ្នកមានស័ក្តិ មានទ្រព្យ ។
រមែងស្រឡាញ់ពេញទឹកចិត្ត  គបគទៅពិតឥតឃ្លាតឃ្លា
ទើបចងសាមគ្គីរវាងគ្នា  បានទៅយូរយារជាប់ជិតស្និទ្ធ ។
បុគ្គលវ័យស្មើប្រាកដជាក់  សំដែងពាក់ទាក់យ៉ាងពេញចិត្ត
ស្រឡាញ់ពប់អានគ្នាជិតដិត  មិនមើលងាយមិត្តជិតនិងឆ្ងាយ ។
បុគ្គលមានស័ក្តិជាមន្ត្រី  ឬជាសេដ្ឋីល្បីសុះសាយ
អាណិតអ្នកតូចតាចទាំងឡាយ  នៅទីជិតឆ្ងាយផ្សាយស្មើគ្នា ។
មនុស្សនឹងមនុស្សធ្លាប់ពប់គ្នាស្និទ្ធ  ស្រឡាញ់ជាមិត្រចិត្តល្អជា
ចេះជួយជ្រោមជ្រែងកិច្ចការគ្នា  គ្រប់ពេលវេលាមិនប្រែប្រួល ។
រក្សាមិត្តធម៌ល្អកល្យាណ  មិនប្រកាន់ប្រាណបានសុខស្រួល
មិនមែនសាច់ញាតិក៏ទទួល  រួបរួមស្រុះស្រួលជាសាមគ្គា ។
សមានត្តតា មិនរើង្អឹង  មិនប្រកាន់ខឹងចេះរាប់គ្នា
តាំងខ្លួនស្មើ ៗ គ្រប់វេលា  នេះជាបុគ្គលាធិដ្ឋាន ។
ព្រះសង្ឃព្រះទ័យត្រង់ទៀងទាត់  គង់នៅក្នុងវត្តជាសុខសាន្ត
ដោយអំណាចធម៌ល្អកល្យាណ  ដែលបានហៅ សមានត្តតា ។
សមានត្តតា គ្មានក្នុងបក្ស  នោះប្រាកដជាក់បែកប្រេះធារ
អន្តរាយសាមគ្គីខូចអសារ  មិនអាចនឹងផ្សាជាប់វិញបាន ។

ហេតុនោះអស់លោកជាមេធំ　　នៃក្រុមសង្គមកុំខាន
បំភ្លឺពន្យល់មនុស្សគ្រប់ប្រាណ　　ឲ្យបានត្រឹមត្រូវផ្លូវប្រពៃ ។
កំចាត់បំបាត់ជនពាលក្បត់　　ដែលល្មើសនូវបទច្បាប់វិន័យ
ទើបសាមគ្គីធម៌ល្អប្រពៃ　　ស្ថិតនៅយូរក្រៃឥតឧបមា ។
ការតាំងខ្លួនស្មើមិនរឹងត្អឹង　　មិនប្រកាន់ខឹង,មានមេត្តា
ចាត់ជាធម្មចរិយា　　បែកខាងធម្មាធិដ្ឋានៈ ។
សមានត្តតា ធម៌សំខាន់　　គឺមិនប្រកាន់ដោយយសសក្តិ
ដោយជាតិ·ត្រកូលនឹងទឹកប្រាក់　　ស្មើ ៗ ឥតអាក់សក្តិសមរម្យ ។
សមានត្តតា អាចយឹតយោង　　គោងឈោងទាញចិត្តមនុស្សតូចធំ
ឲ្យមានសាមគ្គីក្នុងសង្គម　　នេះចំហៅថា សង្គហៈ ។

## តំ សាជកកថា (១)

### បទព្រហ្មគីតិ

ធម៌ ៤ ប្រការនេះ　　អាចចងស្រេះតែរួមរក្ស
ចិត្តមនុស្សឲ្យស្មោះស្ម័គ្រ　　រួមរាក់ទាក់ស្និទ្ធស្នេហា ។
ប្រមូលមនុស្សទាំងឡាយ　　នៅជិតឆ្ងាយក្នុងលោកា
ឲ្យមូលស្មើចិត្តា　　រួមដៃជាសាមគ្គី ។
ប្រៀបដូចជាភ្លៅរថ　　អាចបរបត់លើធរណី
ឲ្យលឿនឆ្ពោះទៅទី　　ដែលបំណងប៉ងប្រាថ្នា ។

---

១– ពាក្យគោលដែលញុំាងសង្គហៈ ទាំង ៤ នោះឲ្យបានសម្រេច ។

កាលបើសង្គហៈ		មិនមានជាក់ក្នុងគ្រួសារ
មាតានឹងបិតា		មិនសង្គ្រោះកូនទាំងឡាយ ។
ឯកូនទាំងស្រីប្រុស		ក៏មិនខុសពីពុក-ម្តាយ
មិនជូនបបរបាយ		ថ្នាក់ថ្នមកាយគារវៈ ។
អ្នកប្រាជ្ញពិចារណា		ឃើញច្បាស់ថា សង្គហៈ
ទាំង ៤ ប្រការជាក់		ល្អអនគ្ឃឥតឧបមា ។
ទើបលោកបានប្រព្រឹត្ត		ដោយកាយចិត្តនឹងវាចា
នូវធម៌ ៤ ប្រការ		ប្រពៃជាថ្លៃឧត្តម ។
ហេតុនោះបានជាលោក		ទទួលគោគជោគជ័យសម
នូវគុណសម្បត្តិធំ		ជាទីស្នេហ៍មនុស្សទាំងឡាយ ។
ការជួយយោងសង្គ្រោះ		អស់ពីពោះជាឧបាយ
ដឹកនាំមនុស្សទាំងឡាយ		ឲ្យស្រុះស្រាយជាសាមគ្គី ។
ជាផ្នែកឧបត្ថម្ភ		នៃអ្នកធំតាមវេណី
ដែលស្ថិតនៅក្នុងទី		បុព្វការីខ្ពង់ខ្ពស់ផុត ។
ឪពុកម្តាយចិត្តស្ម័គ្រ		មានភារៈសង្គ្រោះបុត្រ
អាចារ្យចិត្តល្អផុត		សង្គ្រោះសិស្សស្មើ ៗ គ្នា ។
អ្នកធំខ្ពស់យសសក្តិ		មានភារៈគ្រប់វេលា
សង្គ្រោះរាស្ត្រប្រជា		ស្មើ ៗ គ្នាទាំងតូច-ធំ ។

អ្នកមានទ្រព្យសម្បត្តិ    ប្រសើរគាត់ថ្លៃឧត្តម
ការៈខាងរៀបចំ    សង្គ្រោះជនមកពឹងពាក់ ៗ
ជនដែលបានសង្គ្រោះ    អស់ពីពោះដោយចិត្តស្ម័គ្រ
ដល់ជនមកពឹងពាក់    អាស្រ័យស្នាក់ទាំងប្រុសស្រី ៗ
ជនអ្នកសង្គ្រោះនោះ    លោកឲ្យឈ្មោះតាមបាលី
ហៅថា បុព្វការី    របស់ជនទាំងនោះឯង ៗ
ឯបុព្វការីជន    មានគុណធ្ងន់ពន់ប្រមាណ
រមែងទទួលបាន    បដិការគុណា ៗ
ធម៌ ៤ ប្រការនេះ    ថ្លៃវិសេសឥតឧបមា
បើបុគ្គលណា ១    បានដែលកធ្វើឲ្យសម ៗ
រមែងតែងចំរើន    បានកើតកើនយសសក្តិធំ
ឬសេដ្ឋឧត្តម    ជនតូច-ធំស្នេហ៍មេត្រី ៗ
សឹងមានឧទាហរណ៍    រឿងក៏រល្អក្នុងបាលី
ខ្ញុំកាត់បំប្រួញខ្លី    ជាសេចក្តីបញ្ជាក់ថា ៗ
កាលព្រះបរមគ្រូ    សព្វញ្ញូសាស្តាចារ្យ
មនុស្សលោកនឹងទេព្តា    នមស្ការជាប្រក្រតី ៗ
ស្តេចទ្រង់ប្រថាប់គង់    នៅនាក្រុងអាឡវី
ភិក្ខុ ភិក្ខុនី    គាល់ប្រក្រតី ស្តាប់ទេសនា ៗ

មានឧបាសកម្នាក់ ឈ្មោះហត្ថកៈចិត្តជ្រះថ្លា
ចូលគាល់ព្រះសាស្ដា មានបរិវារហែហមផង ។
ព្រះពុទ្ធជាអម្ចាស់ ស្ដេចទ្រង់ត្រាស់តាមទំនង
" អ្នកមានបរិវារផង ច្រើនកន្ទងហែហមអ្នក : ។
តើអ្នកជួយសង្គ្រោះ បុគ្គលនោះដោយមាសប្រាក់
ឬដោយពាក្យពក់ទាក់ ដូចម្ដេចអ្នកប្រាប់មកក៏ ? " ។
ហត្ថកៈ ក្រាបបង្គំ ព្រះបរមសាស្ដាចារ្យ
បន្ទន់កាយទូលថា " ខ្ញុំករុណាចិត្តស្មោះស្ម័គ្រ ។
សង្គ្រោះជនប្រុសស្រី ចាស់ក្មេងក្ដីមេត្រីរក្ស
ដោយធម៌សង្គហៈ វត្ថុទាំង ៤ ប្រការ ។
ជាធម៌ដែលព្រះអង្គ ទ្រង់ស្រោចស្រង់ត្រាស់ទេសនា
ទូន្មានមនុស្សទេព្ដា ខ្ញុំករុណាធ្វើទាំងអស់ ។
ខ្ញុំករុណាសង្គ្រោះ បុគ្គលនោះមិនឲ្យខ្វះ
- ដោយឲ្យទ្រព្យរបស់ ប្រាក់កាសចាយគ្រប់ប្រការ ។
- ដោយពោលពាក្យពក់ទាក់ ស្មើស្មោះស្ម័គ្រស្និទ្ធស្នេហា
ហៅប្អូន, បង ឬ តា ជាភាពមេត្រីស្និទ្ធ ។
- ដោយខ្វល់ខ្វាយខ្នះខ្នែង ជួយចាត់ចែងកិច្ចការពិត
[illegible] [illegible] ។

– ខឹងដោយមិនរើងគ្អឹង
មាន សរមាឧត្តា
ខ្ញុំករុណាសង្កេត
តើចូលចិត្តខឹងអ្វី

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ
ប្រទានសាធុការ
ព្រះអង្គទ្រង់សរសើរ
ដូចមានពុទ្ធតម្រាស់

" ម្នាលហត្ថកៈចិត្តល្អ
សម្រេចផលថ្លៃថ្លា
បុរសណាដែលបាន
ឲ្យចូលចិត្តមេត្រី
បុគ្គលនោះគ្រប់ប្រាណ
នូវធម៌ល្អវិចិត្រ

ធម៌ ៤ ប្រការនេះ
ជាធម៌សម្រាប់ផ្សារ
ឬជាមេកំណើត
ភប់អានស្និទ្ធស្នាក់

ប្រកាន់ខឹងដោយទោសា
ស្មើ ១ គ្នាជាសាមគ្គី ៗ
មើលហេតុគេទាំងប្រុសស្រី
កំតម្រូវតាមចិន្តា " ៗ
រុងរឿងស្ងាចដោយបញ្ញា
ថាត្រូវហើយប្រពៃណាស់ ៗ
តាមដំណើរនោះច្បាស់ ១
យ៉ាងច្បាស់ ១ ប្រាកដថា ៗ
ប្រព្រឹត្តធម៌ ៤ ប្រការ
ជននានាចូលមេត្រី ៗ
គៀងគរប្រាណជនប្រុសស្រី
បានច្រើនគ្នាមករមមិត្ត ៗ
សុទ្ធតែបានសម្រេចពិត
សង្គហៈ ៤ ប្រការ " ៗ
ថ្លៃវិសេសឥតឧបមា
នូវសាមគ្គីដែលបែកបាក់ ៗ
នាំឲ្យកើតចិត្តស្មោះស្ម័គ្រ
រៀបរមកេរ្តិ៍ជាសាមគ្គី ៗ

ហេតុនេះពុទ្ធបរិស័ទ | គួរប្រតិបត្តិឲ្យពេញទី
ទើបអាចថែសាមគ្គី | ឲ្យស្ថិតនៅ ហាវរ: ។

ខ្ញុំបាទហេង សមអាន | ចិត្តក្សេមក្សាន្តសទ្ធាស្ម័គ្រ
រៀបរៀងសង្គហ: | គ្រប់ ៤ វគ្គតាមពុទ្ធដីកា ។
ខ្ញុំលើកជាកាព្យឃ្លោង | ដើម្បីលោងទាញចិន្តា
បរិស័ទឲ្យជ្រះថ្លា | ចូលចិត្តអានបានពីរោះ ។
ចង្ក្រងមកប៉ុណ្ណេះ | លោកអ្នកចេះសូមសង្គ្រោះ
បើមិនសូវពីរោះ | អភ័យទោសខ្ញុំបាទផង ។
អក្ខរៈពាក្យបាលី | ឬសំដីទាស់គ្គាំគ្គង
លើសខ្វះផ្ទោះរំលង | សូមលោក-អ្នកប្រោសមេត្តា ។
រៀបរៀងតែប៉ុណ្ណេះ | ខ្ញុំសូមស្មេះឈប់ចរចា
សន្មត់ប្រាកដថា | និដ្ឋិតា សមគួរហោង ។ ។

ផ្នែកអក្សរសាស្ត្រ

# ប្រភពនិងការចំរើននៃវប្បធម៌

លោក លី-ធាមតេង

*សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ*

រៀបរៀង

កាលគ្រាមុន យើងបានរើគាស់កកាយរកមែកធាងរបស់វប្បធម៌រួចម្ដងហើយ ដើម្បីជម្រះសេចក្ដីមន្ទិលមួយថា អ្វីហៅថាវប្បធម៌? ឬវប្បធម៌មានអ្វីខ្លះ? ។ កាលនោះ យើងបានពណ៌នាថាអ្វីៗ ដែលក្បួនគម្រោ ឬមុខវិជ្ជាបង្កើតនូវការចេះដឹង ហៅថាវប្បធម៌ ។

ក្នុងគ្រានេះ យើងបន្តការពិនិត្យសិក្សាតទៅទៀត ចំពោះប្រភពដើមនៃវប្បធម៌ និងសេចក្ដីចំរើនរបស់វប្បធម៌នេះផង ។ ដ្បិតបញ្ហានេះ ជាយូរមកហើយ យើងពុំទាន់បានយកចិត្តទុកដាក់សង្កេតពិនិត្យឈ្វេចឈ្វើឲ្យជាក់ច្បាស់នៅឡើយ ដោយហេតុយើងទុកដាក់ថាវប្បធម៌នេះ មានរូបកងស្រាប់ជាអង្គឯងមកហើយ ។ តាមពិតយើងពោលរួចហើយថា វប្បធម៌ខ្មែរ មានអង្គកាយជាអង្គឯងមកមែន ប៉ុន្តែបើដេញរកដើមកំណើតបំផុត ឬប្រភពដើមបំផុតនោះ ឃើញថាវប្បធម៌មិនមែនកើតឡើងដោយឯងៗ ដូចធម្មជាតិនានា មានសិលា, ដី, ទឹក, រុក្ខជាតិ ឬភ្លៀងផ្គរនោះឡើយ ។ បានសេចក្ដីថា វប្បធម៌ប្រាកដជាមានអ្នកបង្កើត ទើបផុះដាលតពូជតអំបូរ

ទៅកើត ៗ តើនណាទៅ, ជនជំពូកណាទៅ ដែលបង្កើតមុខវិជ្ជានេះ? អ្នកសិក្សាទាំងឡាយ អាស្រ័យដោយសារបញ្ញាក្តីស្មានក្នុងចំណេះចេះដឹង អាចឆ្លើយបានភ្លាមថា គឺពពួកអ្នកប្រាជ្ញបុរាណ ៗ ឯយុគសម័យរបស់អ្នកប្រាជ្ញទាំងនោះ យោលទៅតាមអារ្យធម៌របស់ប្រទេសដែលមានការស៊ីវិឡៃចំរើនឡើងបន្តិចម្តង ៗ ជាលំដាប់ ៗ រីឯអ្នកប្រាជ្ញដើមក្នុងការបង្កបង្កើតវប្បធម៌នេះ អាស្រ័យលើបញ្ញាត្រិះរិះសម្បើមណាស់ ព្រោះក្បួនខ្នាតសិក្សាគ្រាដំបូង មិនមែនសម្បូណ៌ដូចកាលបច្ចុប្បន្ននេះទេ ៗ សោតឯគ្រូបាអាចារ្យ ក៏ពុំមានគ្រប់គ្រាន់សម្បូណ៌ហូរហៀរ សំរាប់ជួយពន្យល់ជួយណែនាំឲ្យអ្នកសិក្ខាកាមជន ពេលគឺអ្នកព្យាយាមសិក្សាធ្យាយនោះបានរកឃើញ ឬ ដោះស្រាយចំពោះបញ្ហានីមួយ ១ បានដោយស្រួលឡើយ ។ តែទោះបីមានការលំបាកលំបិន យ៉ាប់យ៉ឺនក្នុងកិច្ចត្រិះរិះស្រាវជ្រាវដើម្បីរៀបចំចងក្រងជាក្បួនខ្នាតយ៉ាងណាក៏ដោយ ពពួកស្ថាបត្យករយើង នៅតែននៀលខ្លួន ស៊ូទ្រាំពាររករិះគិតឲ្យទាល់តែបានសម្រេចប្រាជ្ញាដែរ ៗ ពោលចំពោះបញ្ហានេះ យើងល្បងធ្វើការបកស្រាយរកហេតុផលឲ្យបានពិស្តារបន្តិច សំរាប់កំចាត់បង់សេចក្តីងឿងឆ្ងល់បន្តិចបន្តួចក្នុងចិត្តគំនិតយើងពីមុនមក ៗ មើលចុះអ្នកបង្កើតតួរអក្សរៈសំរាប់កត់ត្រាពាក្យពេចន៍ក្បួនខ្នាត ជាប្រយោជន៍ដល់មនុស្សជាតិខ្លួនទៅ, ប្រឹងអង្គុយគិតដេកគិត រៀបចំបែបណាឲ្យតែផ្សេផ្សំគំនូសទាំងឡាយដែលគេបង្កើតនោះ

កើតបានទៅជាពាក្យមួយមានតំណាងរូបវត្ថុ ឬ សភាពអរូបីយ៍អ្វីមួយ ៗ អ្នកប្រាជ្ញជាតិខ្លះ ដល់ទៅបែកប្រាជ្ញានឹកឃើញ ប្រឌិតតំនួសអក្សរយកតាមសភាពរូបវត្ថុ ឬ រូបគ្រឿងអ្វីមួយដែលខ្លួនស្គាល់ ៗ ឧបមាថា :បើចង់រកអក្សរថា "បក្សី" គេគូររូបបក្សីមួយជាដំណាង, បើរកពាក្យថារូបផ្ទះ, ភ្នំ, ឈើ, ភ្លើង, មនុស្ស ។ល។ គេក៏យករូបវត្ថុទាំងនេះធ្វើជាមូលដ្ឋាន ហើយកាឡៃថែមថយខ្លះទាល់តែកើតបានជារូបរាងអក្សរមួយ ៗ ឡើង ៗ ចំណែកអ្នកវិទ្យាសាស្ត្រវិញ, គិតហើយគិតទៀត, ល្បងម្តងហើយម្តងទៀត, ពិសោធហើយពិសោធទៀត ទាល់តែឃើញច្បាស់ថា: ការពិចារណារបស់ខ្លួននេះ ត្រូវតាមការពិតជាក់ស្តែង មានសភាពសក្តិសិទ្ធិឬទេ? បើឃើញត្រូវជាក់លាក់ហើយ ទើបហ៊ានចងក្រងជាក្បួនតម្រាឡើង សំរាប់ឲ្យអ្នកក្រោយសិក្សាតាមខ្លួនបានដោយងាយ ៗ នេះយើងពោលសំដៅអ្នកវិទ្យាសាស្ត្រគ្រប់ប្រភេទ ទោះវិទ្យាសាស្ត្រខាងរូប-និយម ឬ អរូបនិយមក្តី ៗ រីឯអ្នកបង្កបង្កើតនូវវិធីកំរែក, សំដីវោហារជាកំណាព្យកាព្យឃ្លោង, ជាបទច្រៀងច្រើនចង្វាក់ច្រើនយ៉ាងសោតទៀត ក៏ខ្លះខ្វែងសន្ទឹកណាស់ដែរ គឺគាត់រិះរកតាំងពីហេតុផលដើម ធ្វើបែបណាឲ្យសិល្បៈរបស់គាត់ស្ថិតនៅជាសិល្បៈមនុស្សជាតិ ពោលគឺសិល្បៈសំរាប់ជីវិតមនុស្ស ជួយពត់ហាត់ចិត្តមនុស្ស, ជួយរកប្រយោជន៍ឲ្យមនុស្សវិញផង ៗ មិនតែប៉ុណ្ណោះ អ្នកប្រាជ្ញជាសិល្បកររបស់ជាតិនីមួយ ៗ មាន

ជាតិខ្មែរយើងជាពិសេស ហើយដែលតែងតែនាំឲ្យសិល្បៈយើងពិតជារបស់យើងថែមទៀត គឺជាកុំឲ្យច្រឡំបល់ជាមួយគេ ព្រោះចង់បង្ហាញលក្ខណៈរបស់ជាតិក្នុងនោះ ៗ ឧបមាថា បើលេងភ្លេង គ្រាន់តែភ្លេងចាប់ផ្ដើមឡើង គេអាចដឹងបានថា បទនេះជាបទខ្មែរ បទនោះជាបទរបស់ជាតិអ្វីផ្សេងៗទៀត ៗ ចំពោះការផ្ដើមគំនិតវាងក្បាច់ចំឡាក់វិញ ក៏មានលក្ខណៈមិនប្លែកគ្នាពីសិល្បៈដែលពោលមកហើយនេះដែរ ៗ

ដោយហេតុមានកស្តុតាង ដូចបានពណ៌នាត្រួស ៗ មកនេះហើយ ទើបយើងកល់គ្នាដឹងថា វប្បធម៌ មិនមែនកើតឯងដូចជាធម្មជាតិនានាទេ វប្បធម៌ពិតជាមានអ្នកបង្កើត ទោះតិចច្រើនក្ដី ក៏ចេះតែបង្កើតថែមគ ៗ គ្នា សូម្បីតែមកដល់សព្វថ្ងៃហើយ ក៏នៅតែត្រូវបង្កើតមិនឈប់ឈរ ដូចយ៉ាងនៅប្រទេសយើងសព្វថ្ងៃ ដែលកំពុងជុះជាលគ្មានអាក់ ក៏តែងមានអង្គការបង្កបង្កើតខាងផ្នែកវប្បធម៌នេះដែរ ដូចជាក្រុមស្រាវជ្រាវទំនៀមទំលាប់នៅពុទ្ធសាសនបណ្ឌិត្យ, មជ្ឈមណ្ឌលស្រាវជ្រាវនៅវិទ្យាស្ថានជាតិគរុកោសល្យ, វិជ្ជាស្ថានពិសោធខាងឧសថ, គណកម្មការវប្បធម៌ ក្រុមបច្ចេកទេសនៅក្រសួងសិក្សាធិការ និង សមាគមអ្នកនិពន្ធខ្មែរជាដើម ទោះបីខ្លះជាអង្គការរបស់រាជការក្ដី ខ្លះជាអង្គការឯកជនក្ដី ក៏សុទ្ធតែមានមុខងារត្រិះរិះរៀងខ្លួន ដើម្បីបង្កបង្កើតវប្បធម៌របស់ជាតិឲ្យកាន់តែបានចំរើនគ្រប់គ្រាន់ឡើង ឲ្យសមនឹងឋានៈ ប្រទេសលូតលាស់យ៉ាងលឿន

ក្នុងគ្រាបច្ចុប្បន្ន ដោយការដឹកនាំនៃសម្ដេចសហជីវិន ដ៏ជាអគ្គមគ្គុទ្ទេសក៍ជាតិ និងជាព្រះបិតាឯករាជ្យជាតិខ្មែរ ។

សេចក្ដីដែលបានបរិយាយមកហើយខាងលើ ជាការត្រិះរិះពីដើមចមវប្បធម៌ ឥឡូវយើងបន្តការត្រិះរិះទៅលើសេចក្ដីចំរើនរបស់វប្បធម៌នេះទៀត ។

សេចក្ដីចំរើនរបស់វប្បធម៌ ស្ថិតនៅលើការសិក្សាទាំងស្រុង គឺថាស្រុកណាប្រទេសណាមានការសិក្សាលូតលាស់ច្រើន ស្រុកនោះប្រទេសនោះឈ្មោះថាបានចំរើនខាងវប្បធម៌ ។ ហេតុនេះហើយ បានជាយើងនាំគ្នាសំគាល់យ៉ាងប្រាកដថា អគារសិក្សានានា ពិតជាគ្រឹះនៃវប្បធម៌ ជាមូលដ្ឋានពង្រីកនូវវប្បធម៌ ឲ្យត្រកុំត្រកាលខ្ពង់ខ្ពស់ត្រដឹមត្រដែតឡើង ។ អ្នកសិក្សាទាំងឡាយ សុទ្ធតែកំពុងក្រេបជញ្ជក់នូវរសជាតិវប្បធម៌ ដែលមានចងក្រងជាក្បួនខ្នាតរួចមកហើយ ទោះទាំងវិជ្ជាខាងភាសា, គណិតសាស្ត្រ, ប្រវត្តិសាស្ត្រ, ភូមិសាស្ត្រ, វិទ្យាសាស្ត្រជាដើម តែបើខ្វះខាតខ្វះ អ្នកបង្រៀនតែងតែហ្វឹកហ្វឺនខ្លួនថែមឲ្យទាល់តែបានស្រួល ក្នុងការសិក្សារបស់សិស្ស ។ ក្រៅពីអគារសិក្សា យើងឃើញវប្បធម៌ចំរើនបានមួយផ្នែកទៀតខាងការផ្សាយ ដូចយ៉ាងការផ្សាយតាមវិទ្យុ, តាមសៀវភៅដែលបោះពុម្ពច្រើនពាន់ក្បាល, តាមវង់ល្ខោនដែលប្រឹងពត់ហាត់សិល្បៈមានមកស្រាប់, តាមអង្គការអប់រំផ្សេង ៗ, តាមរូបភាព ឬ

បំឡាក់របនាគ្រប់បែបយ៉ាង, តាមវង់តន្ត្រីដែលមាននៅគ្រប់ស្រុកតូចស្រុកធំ ។ល។

បើយើងប្រៀបធៀបការផ្សាយទាំងពីរផ្នែកខាងលើនោះ ឃើញថា ការផ្សាយទី ១ មានរបៀបរៀបចំជាក្រុមជាពួក ឬមានគ្រូជាអ្នកណែនាំបង្ហាត់បង្ហាញ គឺមានកំណត់ជាថ្នាក់ជាជាន់ហួរហែគ្នា ដែលនៅគ្រាសព្វថ្ងៃប្រជាពលរដ្ឋខ្មែរយើង កំពុងមមាញ្ញស្រវាស្រទាញរកផ្តល់ឲ្យដល់កូនចៅដែលនៅបឋមវ័យនៅឡើយ សំរាប់ជួយកសាងវាសនាកូនចៅទាំងនោះទៅអនាគតកាលទៀត ។ ចំណែកការផ្សាយផ្នែកទី ២ ពុំចាំបាច់ចាត់ជាក្រុមជាពួក, កំណត់វ័យ ឬ កំណត់ជាន់ថ្នាក់អ្វីឡើយ ។ ជនណាមួយក៏អាចបង្កើតការចំរើនបានដែរ ដោយឧស្សាហ៍ព្យាយាមអាន, ព្យាយាមទស្សនា, ព្យាយាមស្តាប់ ហើយពិចារណាសង្កេតរកហេតុផលនោះ ក៏យើងរាប់បានថាជាអ្នកសិក្សាដែរ ហើយបែបសិក្សានេះជាទុកលំទូទៅណាស់ផង ។

សរុបសេចក្តីទៅ ប្រភពដើម និងសេចក្តីចំរើននៃវប្បធម៌រមែងតែទាក់ទងជាប់ជាមួយគ្នាជានិច្ច ហើយដំណើរជឿនលឿនទៅមុខនៃផ្នែកទាំងពីរនេះ ក៏ត្រូវមានចង្វាក់ស្របគ្នាដែរ ។ ត្រង់នេះ យើងប្រៀបឧបមានឹងដើមឈើម្តងទៀតថា: ប្រភពដើមនៃវប្បធម៌ដូចជាគល់ឈើ ដែលត្រូវមានសភាពមាំទាំ ដើម្បីទ្រទ្រង់នូវមែកធាងដែលតែងតែដុះដាលជា

លំដាប់ ៗ ឯការចំរើននៃវប្បធម៌ ដូចជាស្ទឹក, ផ្លែផ្កាឈើ ដែលត្រូវតែលូតលាស់អាស្រ័យដោយគល់របស់ខ្លួនតាក់ឫសយ៉ាងមាំល្អ ៗ ហេតុនេះហើយ បានជានៅគ្រាសព្វថ្ងៃនេះ ប្រទេសយើងដែលកំពុងតែមានវឌ្ឍនៈភាព ដូចពោលមកហើយខាងលើ យើងតែងនាំគ្នាប្រឹងប្រែងឲ្យបានសមរម្យ ល្អត្រកាលទាំងពីរខាង សំរាប់ផ្តល់ប្រយោជន៍ជូនជាតិខាងផ្នែកវប្បធម៌នេះ ៗ

---

# ពាក្យខ្មែរប្រែចេញពីបរទេស
## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Antibiotique | *n. et a* | បដិបក្ខប្រាណ |
| Plante maraichère | | ភូតគាមបន្លែ |
| Plante ornementale | | ភូតគាមលំអ |
| Plante florale | | ភូតគាមផ្កា |
| Plante fruitière | | ភូតគាមផ្លែ |
| Plante textile | | ភូតគាមភិយនីយ |
| Plante saccharifère | | ភូតគាម សករ |
| Plante oléagineuse | | ភូតគាម ប្រេង |
| Plante à stimulant | | ភូតគាម ឧទ្ទីប័ក |
| Plante industrielle | | ភូតគាម ឧស្សាហកម្ម |
| Plante d'ombrage | | ភូតគាម ម្លប់ |
| Plante de couverture | | ភូតគាម ជារូបន៍ |
| Stimulant | *n. et a.* | ឧទ្ទីប |
| Fumigation | *n. f.* | ធូបនកម្ម |
| Emulsion | *n. f.* | តេលូទកា |
| Nébulisation | *n. f.* | អព្ភកម្ម |
| Décoction | *n. f.* | ការស្ងោរ, ទឹកថ្នាំស្ងោរ |
| Infusion | *n. f.* | ការជុង, ទឹកជុង |
| Distillation | *n. f.* | ការបិត |
| Théâtre d'opération | | រណរង្គ |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

*ព្រះមហា ប៉ាង - ខាត់ រៀបរៀង*

---

**អតិប្រណាយ** ពុំ. កិរិយាទន់ទោនក្រៃលែង ។

**អតិប្រណុទ៑** (នុទ) ធាតុ. បន្សាត់បង់, បំផ្លាញ (សត្រូវ) ។

**អតិប្រត្យាសង្គ** ពុំ. កិរិយាទាក់ទងក្រៃលែង, កិរិយាប្រឡូកប្រឡល់ ។

**អតិប្របទ៑,** ធាតុ. ស្រោចស្រង់, ជួយចម្លង (ទៅលោកខាងមុខ) ។

**អតិប្រពន្ធ** ពុំ. កិរិយាប្រពន្ធក្រៃលែង ។

**អតិប្រមាណ** គុ. អតិប្រមាណ ។

**អតិប្រមាទ** គុ. ដែលប្រមាទក្រៃលែង ។

**អតិប្រលោភិត** គុ. ដែលទង់ទាញក្រៃលែង ។

**អតិប្រវត្តិន៑** គុ. ដែលប្រព្រឹត្តទៅក្រៃលែង ។

**អតិប្រវា** ធាតុ បក់ក្រៃលែង ។

**អតិប្រវិទ្ធ** គុ. ដែលបាញ់ក្រៃលែង ។

**អតិប្រវឫទ្ធ** គុ. ដែលចាស់ក្រៃលែង, ដែលចំរើនក្រៃលែង, ដែលឡើងអំនួត ៗ ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៣

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកចង់វៃឆ្លាតបើបានអាន<br>នឹងចេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ ។ |

ខណៈនោះ ហោយិនក៏ប្រើហាស៊ុនទឹងឌីវយឺមឲ្យលើកទាហានចេញទៅលបដើរតាមផ្លូវកាត់ ទឹងបានជួយហោហងការពាររក្សាគយអ៊ីឡេងទុកឲ្យបាន ហាស៊ុនទឹងឌីវយឺមលើកទៅដល់កណ្ដាលផ្លូវ ក៏ប្រើទាហានស្រូតទៅប្រាប់ហោហងថា ហោយិនប្រើយើងទាំង២នាក់ឲ្យនាំទាហានមកជួយ ឲ្យហោហងបង្ខំលើកទ័ពចេញទៅច្បាំងនឹងឌីវយឺម កាំឡេង យើងទាំង ២ នឹងលើកវាយប្រសព្វចូលមកទៀត ។ បំរើសេះក៏ស្រូតទៅប្រាប់ហោហង ។ ឮដូច្នោះក៏អរណាស់ ឲ្យបំរុងទាហានត្រៀមទុកជាស្រេច ។

ឯកាំឡេង កាលទៅដល់គយអ៊ីឡេងហើយ ក៏តាំងបន្ទាយភ្ជាប់ជិតគ្នា ។ ហោហងឃើញដូច្នោះ ក៏លើកទាហានបើកទ្វារបន្ទាយចេញទៅ

គតាំងច្បាំងគ្នាសន្ធឹកសន្ធាប់ ហើយថយទ័ពរត់ទៅ ៗ ខណៈកាំឡេង លើកទ័ពចូលទៅនៅក្នុងបន្ទាយអ៊ុំឡេង, ឯទាហានដែលរត់ទៅនោះ ក៏ទៅជួបនឹងជីវយឺម ហើយសាសព្វគ្រប់រឿងដែលច្បាំងគ្នាគ្រប់ប្រការ លុះពេលអគ្រាត្រ ទោហង, ទោស៊ុន, ជីវយឺមក៏លើកត្រឡប់មកព័ទ្ធបន្ទាយអ៊ុំឡេងវិញ ៗ ជីវយីដឹងដូច្នោះក៏ភ័យណាស់ នៅមិនទាន់ប្រឹក្សាប្រការម្ដេច, ទៀតៅថា សុំឲ្យលោកបែងរំលែកទាហានទៅជួយកាំឡេងទៀតទើបបាន ៗ ជីវយីតបថា ដែលអ្នកនឹងឲ្យបែងទាហានទៅជួយកាំឡេងទៀតទើបបាន ព្រោះទាហានកងទ័ពយើងក៏នៅស្ដួចស្ដើងតិចណាស់ ខ្លាចដឹងដល់ទោយិន ១ នឹងលើកទ័ពមកខ្ទប់ពាយ យើងក៏នឹងចុះការដោយសឹកសត្រូវ ៗ

លីបងថា កាំឡេងនោះមានថ្វីដៃខ្លាំងពូកែ ក្នុងស្រុកកាំងតាំងជាទាហានឯក បើលោកនឹងមិនបែងរំលែកទាហានទៅជួយ នោះក្រែងកាំឡេង អន់ចិត្តតាំងកិច្ចការរបស់លោកក៏នឹងទន់ថយអស់ទៅ ៗ ជីវយីតបថា គំនិតខ្ញុំចង់បែងរំលែកទាហានទៅជួយហើយ តាំងខ្លួនខ្ញុំក៏ចង់ទៅឯងផងទៀត តែថាបន្ទាយដែលតាំងនៅនេះ ក្រែងមនុស្សអស់តាំងនេះនឹងរក្សាទុកមិនបាន ៗ លីបងថា ឲ្យឡេងថងនៅរក្សាបន្ទាយទុកក្នុងរវាង ១០ ថ្ងៃ លោកជាកងហ្លួង ខ្ញុំបាទនឹងសុំអាសាលើកជាទ័ពស្រួចទៅជួយកាំឡេងទើបសមគួរ ៗ ជីវយីក៏បង្គាប់ឲ្យឡេងថង នៅរក្សាបន្ទាយ ៗ

ទៀនថនក៏ទទួល តែសូមសន្យា ១០ ថ្ងៃនឹងរកប្រាក់ទុកឲ្យគង់ បើលើសពីនោះក្រែងលើសកម្លាំង ។

ជីវយើថា គន់ ១០ ថ្ងៃខ្ញុំនឹងវិលត្រឡប់មកវិញឲ្យដល់ ហើយបែងចាហានឲ្យទៀនថន ១ មុឺន សល់ពីនោះជីវយើនឹងលីបង់ ក៏លើកទៅដល់ពាក់កណ្តាលផ្លូវ លីបង់ថា គយអ៊ុទៀននោះ ខាងទិសឯត្បូងមានផ្លូវកាត់ទៅស្រុកឡាំគុនផ្លូវ ១ សុំឲ្យលោកចាត់ទាហានទៅកាត់ឈើរំលំគ្រប់លើផ្លូវឲ្យអស់ បើទាហានរត់ទៅផ្លូវនោះមុខជាទៅមិនរួច គង់នឹងទាល់សេះនឹងគ្រឿងសស្ត្រាវុធអស់ពុំខាន យើងបានយកទុកជាកម្លាំង ។ ជីវយើយល់ត្រូវផង ក៏ចាត់ទាហាន ៥០០ ឲ្យទៅកាប់រំលំឈើគ្រប់លើផ្លូវតាមពាក្យលីបង់ ហើយលើកកងទ័ពទៅជិតគយអ៊ុទៀន ជីវយើក៏ប្រឹក្សានឹងទាហានទាំងពួងថា នរណានឹងអាចយកអាសាទៅវាយតុះទំលាយទៅប្រាប់កាំទៀនឲ្យបានដឹងថា យើងលើកកងទ័ពមកដល់ហើយ ឲ្យកាំទៀនច្បាំងទំលាយចេញមក យើងនឹងវាយខ្ទប់ចូលទៅ ជីវថាយ ទទួលអាសាជិះសេះកាន់ដាវវាយទំលាយទ័ពទាហានចូលទៅដល់ក្បែរបន្ទាយ កាំទៀនឃើញដូច្នោះក៏បើកទ្វារទទួល ។ ជីវថាយចូលមក ជីវថាយឆ្លើយប្រាប់កាំទៀន តាមរឿងរ៉ាវដែលវាយទំលាយទ័ពចូលមកនោះ ឲ្យកាំទៀនស្តាប់គ្រប់ប្រការ កាំទៀនក៏មានសេចក្តីត្រេកអរណាស់ ទើបចាត់ប្រើទាហានឲ្យរៀបប្រចាំការទុកជាស្រេច ។

ឯទោហាន ទោស៊ុន ក៏ធ្វើសំបុត្រឲ្យបំរើសេះនាំទៅដល់ ទោយិន ជាសេចក្តីថា ខ្ញុំបាទបានឡោមព័ទ្ធកាំឡេងទុកក្នុងបន្ទាយយូរថ្ងៃហើយ ឥឡូវដីវយើលើកកងទ័ពមកជួយកាំឡេង ហើយទោហានក៏ចាត់ចែងត្រៀមទាហានទុកតាំង ២ អន្ទើ កន្ទួងគយប៉ងនឹងគប្បាំងនឹងកាំឡេង - ដីវយើក្រោយនោះដីវយើក៏បរពលគប្បាំងនឹងទោហានជាច្រួលច្របល់ ៗ កាំឡេងបានឮស្ករចម្បាំងគ្នាជាអឺកអាធិក ក៏លើកទាហានវាយខ្ទប់ចេញមកពីក្នុងបន្ទាយ កាប់សម្លាប់ទាហានទោហានស្លាប់ជាច្រើន ទោហាន, ទោស៊ុន ទីវឃើម តទល់មិនបាន ក៏នាំទាហានរត់ទៅតាមផ្លូវកាត់ ៗ ដីវយើក៏លើកទាហានដេញតាមទៅ ទាហានទោហាន ឃើញឈើរលំគ្របលើផ្លូវទៅមិនរួច ក៏ចោលសេះនឹងគ្រឿងសស្ត្រាវុធទាំងអស់ នាំគ្នារត់យកតែខ្លួនទៅ ៗ

កាលដីវយើលើកទាហានតាមទៅនោះ ក៏បានសេះនឹងអាវុធជាច្រើន ហើយក៏លើកស្រែកទៅដល់មាត់ផ្លូវ ទាន់ប្រទះនឹងកងទ័ពទោយិនលើកមកជួយទោហានតាមសំបុត្រក៏បានគតាំងច្បាំងគ្នាជាពន្ទឹក លុះដល់ពេលព្រលប់ក៏មិនចាញ់មិនឈ្នះ ទោយិនក៏នាំទោហាន ទោស៊ុន ត្រឡប់ចូលស្រុកឡាំគុន ហើយប្រឹក្សាគ្នាថា ឥឡូវយើងខូចគយអ៊ីឡេងហើយ មុខជាយើងនឹងការពារស្រុកឡាំគុនមិនឈ្នះទេ គិតហើយក៏បើកស្រោមសំបុត្រដែលចូធូសរសេរទុកឲ្យនោះមើល លុះដឹងក្នុងសេចក្តីទាំងពួងសព្វគ្រប់

ហើយ គឺឲ្យយកទង់ទៅដោតទុករៀងតាមសើនបន្ទាយ ឲ្យទាហានទាំងពួងរែកស្ពាយអាហារ ធ្វើបីដូចជានាំគ្នារត់ចោលស្រុកឡាំគុន ហើយបង្គាប់គ័នគៀវ ងីវយឺម ឲ្យបើកទ្វារស្រុកទុកពាំតបន់ ឲ្យជីកអន្លង់តាមក្បែរមាត់ទ្វារយកដើមកប្ចូកគ្របពីលើមាត់អន្លង់ឲ្យជិត កុំឲ្យឃើញស្នាមស្គាល់បាន បើទាហានដីវយើនឹងលើកចូលមក គឺនឹងដើរទៅជាន់ធ្លាក់ទៅក្នុងអន្លង់នោះ ហើយនឹងចាប់បានដោយងាយ ឯខ្លួនអ្នកទាំង ២ ត្រូវឲ្យនាំទាហានឆ្ពោះទៅបង្កប់ពួនគ្រប់ទ្វារទាំង ៣ ។

(នៅមានត)

# ល្បែងអៀវ

(តនិងចប់)

## លោក ញូង-សឿង រៀបរៀង

លោកគ្រូមានថេរដីកាតទៅទៀតថា ឯរឿងខាងណោះគឺមានអាម្នាក់វាអៀវកអាត្មាពីល្ងាចមិញ ពេលចេញពីសូត្រធម៌ក្នុងព្រះវិហារ តែមិនដឹងជាក់ជាអាណាមួយទេ ព្រោះវារត់បាត់ក្លាមទាំងពីរនាក់ តាំងពីពេលនោះម៉្លេះ តែណ្ហើយ! អាត្មាខ្ជិលនិយាយឲ្យវែងឆ្ងាយ តែនិយាយទៅវានាំឲ្យរឹតតែក្តៅថែមទៀត បើអ្នកចង់ដឹងហ្នូរ៉ែ ចូរសាកសួរលោកសង្ឃក្នុងវត្តនេះចុះ រួចហើយចូរនាំគ្នាប្រញាប់ប្រញាល់ទៅជួយស៊ើបសួររកវាឲ្យឃើញហើយនាំយកមកឲ្យអាត្មាកុំខាន ។ ឧបាសកទាំងពីរនាក់ហាក់ភ្ញាក់ខ្លួនព្រើត គក់ទ្រូងទះស្មា ដំឡើងក្អកស្តោះដោយទោមនស្សយ៉ាងខ្លាំងហើយលាន់មាត់ថា "គួរបើដែរ! មកប្រព្រឹត្តអំពើច្រឡើសបើសឈ្លានពានលើព្រះតេជព្រះគុណយ៉ាងនេះ! យើ! ស្តាយណាស់! បើបានដឹងរឿងនេះតាំងពីល្ងាចម៉្លេះ នុះសត្វជាខ្ញុំតាប់ចង់នាំយកមកប្រគេនព្រះតេជព្រះគុណស្រេចទៅហើយ យើអើ! កូននេះចំជាកូនខិលខូចកូនឈាមអាក្រក់ កូនពាលចង្រៃ! បើដូច្នោះ ត្រូវតែតាមរកឲ្យឃើញហើយធ្វើទោសទណ្ឌកម្មយ៉ាងធ្ងន់ ទើបជួនល្មមនឹងការប្រព្រឹត្តិល្មើសនេះប៉ុន្តែសូមមានមេត្តាអត់ទោស ចំណែកខាងសត្វជាខ្ញុំទាំងពីរនាក់ក្នុងពេល

នេះមិនដឹងជានឹងស្ទុះស្ទាទៅស្កាត់គេនៅទីណាទេ ព្រោះណាមួយជាប់រវល់នឹងស្រែកំពុងទុំពេញ ១ ស្រែ ណាមួយទៀតគឺពុំគ្មានសោហ៊ុយតែម្ដងបានប្រោស ហេតុនេះតាមតែព្រះតេជព្រះគុណមេត្តាចាត់ការឲ្យលោកសង្ឃក្នុងវត្តជួយស៊ើបសួរគេឲ្យបានផងចុះ ម្យ៉ាងទៀត សត្វជាខ្ញុំទាំងពីរនាក់ កាលយកកូនទាំងពីរមកប្រគេនផ្ញើទុកនឹងព្រះតេជព្រះគុណតាំងពីនៅតូច ១ មកនោះ គឺបានបវារណារួចជាស្រេចហើយថា សាច់ស្បែកប្រគេនព្រះតេជព្រះគុណទាំងអស់ សូមទុកតែភ្នែកនឹងឆ្អឹងប៉ុណ្ណោះទេ(១) ។ លោកគ្រូកាលបានឮពាក្យនេះហើយ ក៏ធ្វើទឹកព្រះកក្រៃបែបស្មើ មួយស្របក់ទើបមានថេរដីកាថា អីចឹងក៏បានដែរ តែថាបើឃើញពកទៅផ្ទះកុំឲ្យលាក់បំពួនឲ្យសោះ ត្រូវតែល្បួងលួងបញ្ឆោតយ៉ាងណានាំខ្លួនពកយកមកឲ្យអាត្មាឲ្យបានតែបាន ។ ឧបាសកទាំងពីរទូលតបស្របថា សូមកុំព្រួយព្រះទ័យ ឲ្យតែឃើញទៅផ្ទះ សត្វជាខ្ញុំមុខជាសំពងមុនព្រះតេជព្រះគុណហើយបានប្រោស រួចចាំនាំយកមកប្រគល់ប្រគេនជាក្រោយ ហើយតាមតែព្រះតេជព្រះគុណថែមថយយ៉ាងណា ១ ក៏តាមព្រះទ័យទៀតចុះ សត្វជាខ្ញុំឥតសមគំនិតប្ដូកាន់ដឹងអ្វីទេមនុស្សវេចិល

---

១– ទំនៀមខ្មែរយើងពីដើម កាលយកកូនទៅឲ្យនៅវត្ត គេតែងប្រគល់ហើយបវារណាលោកគ្រូចៅអធិការថាដូច្នេះឯង បានសេចក្ដីសុំឲ្យលោកជេរស្ដីប្រដៅប្រដៅបង្ហាត់បង្រៀនទុកដូចជាកូនចៅ ព្រមទាំងវាយធ្វើបាបរហូតដល់ដាច់ស្បែកនឹងសាច់ហូរឈាមយ៉ាងណា ក៏តាមត្រូវការចុះ កុំតែខ្វាក់ភ្នែកនឹងបាក់ឆ្អឹងខ្នងប៉ុណ្ណោះ ។

ខ្ចប ៗ ពេលយ៉ាងនេះរួចហើយ អ្នកទាំងពីរចុះពីលើកុដិទៅយកកញ្ចប់ ថ្នាយនឹងម្ហូបគ្រៀមគ្រោះ ដែលខ្លួនដាក់ទុកក្នុងរទេះនោះមកប្រគេនលោក ហើយក៏ក្រាបថ្វាយបង្គំលាដោយគោរព ត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ ។ ចំណែកលោកគ្រូសង្ឃរាជ លុះឆាន់ព្រឹករួចហើយ ក៏ចាត់ការឲ្យគេតាមអង្កេតស៊ើបសួររកលោកទាំងពីរអង្គ គ្រប់ច្រកល្ហកតាមការណ៍តទៅ ។

យើងនឹងសាត្រឡប់ទៅរកតាមដាន រឿងពីល្ងាចបន្តិចវិញសិន តើភិក្ខុរូបណាដែលអៀវលោកគ្រូសង្ឃរាជ ហើយភិក្ខុទាំងពីររូបនោះគេចខ្លួនបាត់ទៅទីណា ដោយឧបាយដូចម្ដេចខ្លះ ។

ភិក្ខុខិល ១ អង្គដែលអៀវលោកគ្រូពីល្ងាចនោះ ស្មានថាមុខជាមានគេតាមប្រកិតពីក្រោយពុំខាន ក៏បានរត់យ៉ាងលឿនទៅទាំងយប់ កាត់គ្រោកកាត់គ្រាំងតាមផ្លូវខ្លះ កាត់ព្រៃផ្សេងខ្លះ លុះដល់ហបហត់ខ្លាំង ក៏ឈប់សម្រាកអង្គុយផ្អែកយូសខស ១ ក្នុងវាលស្រែមួយកន្លែងនាទិសខាងលិច ចម្ងាយប្រហែលជាង ១ គីឡូពីវត្ត ចាំស្ដាប់ផងការមើល តើមានគេតាមចាប់ខ្លួនឬទេ មួយស្របក់ គូសដែកភ្លើងអុជបារីមួយចិតបង្ហុយផ្សែងគ្រុល ស្រាប់តែបានដឹងថា ឈើផ្កា ១ ក្រង់បាទជើងភ្លើង បំភ្លឺភ្លើងមើល ទើបឃើញមានស្នាមបន្ទាមុតពីរបីអន្លើ ហើយបានឃើញជាយស្បង់ចីពររហែកពីរបីកន្លែងទៀត ដោយទាក់ទិងបន្លា ។ ភិក្ខុបិតបារីបណ្ដើរ ប្រុងផ្ទៀងស្ដាប់បណ្ដើរក្រែងឮសូរមាត់គេមកតាមចាប់ នៅតែភ័យញ័រផ្អុក ៗ

ក្នុងខ្លួនជានិច្ច ដោយត្រិះរិះរកផ្លូវដោះស្រាយណាមួយពុំទាន់ឃើញជាក់ប្រាកដសោះ ហើយក៏ប្រះខ្លួនចំរេតផ្អែកទៅនឹងភ្លឺស្រែ ដើម្បីសម្រាកកំឡាំងបន្តិច ៗ

រីឯភិក្ខុជាគូកន ១ អង្គទៀតដែលនៅឯវត្ត ក្នុងពេលដែលគេកំពុងផ្អើលល្ហូរមកចោមរោមលោកគ្រូសង្ឃរាជទាំងអស់គ្នានោះ បានមកជាមួយនឹងគេដែរ លុះបានស្តាប់ដឹងការណ៍សព្វគ្រប់ហើយ ក៏គិតថា រឿងនេះប្រាកដជានឹងពលដាលជាប់ទាក់ទងដល់ខ្លួនផងពុំខាន ទើបលបដោះខ្លួនយ៉ាងប្រញាប់ពីទីនោះ ស្ទុះស្ទាទៅកាន់កុដិ បើកហិបយកឆាយារបស់ខ្លួន នឹងរបស់គូកនដែលនៅកន្លែងក្បែរគ្នា ហើយឆក់យកតែពិល ១ បុះរឹងបោះជំហានវែង ៗ សំដៅទៅទិសខាងលិចវត្ត ក្នុងពេលនោះភ្លាមបេះតែនឹកប៉ផ្អុកថា មុខជាមានភិក្ខុសាមណេរដេញតាមក្រោយជាពុំខាន ម្លោះហើយលោកប្រឹងស្ទូតរូតទៅល្បឿនជាដពប ហើយពុំហ៊ានបញ្ចាំងពិលញឹកញាប់ពេកទេ ព្រោះខ្លាចក្រែងគេឃើញពន្លឺ ៗ លុះកាត់ព្រៃទៅមួយសន្ទុះធំ បានទៅដល់ភ្លឺស្រែ ស្រាប់តែបានឃើញពន្លឺតូចដូចភ្លើងបារី ចួនកាលបាត់ ចួនកាលឃើញ នៅត្រង់កន្លែងមួយ, ភិក្ខុឃើញក៏នឹកភ័យអរ ៗ មិនហ៊ានបញ្ចាំងពិលពីចម្ងាយទេ ដើរលបសន្សឹម ៗ ទៅជិតប្រហែលជាង ១០ ម៉ែត្រ ទើបបញ្ចាំងពិលភ្លែតតម្រង់ចំពន្លឺនោះ បានឃើញមុខស្គាល់ជាក់ជាមិត្តរបស់ខ្លួនហើយ ក៏តាំងស្រែកហៅភ្លាម

"មោយ ៗ!" ៗ ភិក្ខុមោយភ្ញាក់ព្រើតព្រលឹងបុងសក់ ប្រាសខ្ទីង លឿនជាងទន្សាយឆ្កែដេញ ក្មេងពិលចាំងប្រកិតដឹតជាប់ពីក្រោយ ដោយបន្ថែមសំឡេងយ៉ាងតឹងបំពង់កផងថា " ឈប់មោយ! ឈប់មោយ! គ្នាយើងទេ!" ៗ ស្រេចតែមិនខ្វីធ្វើព្វ ឬឆ្លើយតបតសោះ, មោយយើងពឹតតែរវើរតល្បឿនថែមឡើងជាដពប តែអ្នកក្រោយក៏លឿន អ្នកមុខក៏លូតបូតគ្នាមិនដាច់ កាច់ល្បឿនគ្នាមិនបាន ឯក្មេងពិលនៅតែជាប់ពីក្រោយគូថជានិច្ច ៗ ភិក្ខុមោយ រត់ត្របាញ់ជើងបណ្តើរនឹកស្តាយបណ្តើរថា ពាស់ការធំតែម្តង បើកុំតែឈប់សម្រាកជក់បារីមិនអីសោះ ៗ លុះធ្លងផុតវាលស្រែវែងឆ្ងាយ ប្រហែលពីរគីឡូ ក៏ចូលដល់ផ្លូវទេះមានខ្សាច់ អ្នកទាំងពីរបែបពងផាស់សរសៃជើងបោះជំហានទៅមុខ បេះតែចង់ថយក្រោយ យូរ ៗ ទៅ ទប់អាត្មាលែងត្រង់ ហើយក្នុងមួយខ្លួន ៗ លែងលឿនស្មើភាគគ្នាហើយ គឺងោកទោរតែក្បាលទៅមុខ ឯជើងនឹងគូថលូតងរឯងស្ទួតនៅខាងក្រោយ តែទោះបីយ៉ាងណា អ្នកទាំងពីរក៏បេះតែប្រឹងត្រដរយោលជើងទៅទាំងត្រដេបត្រដាប ព្រោះអ្នកមុខភ័យអាសន្នបន្ទាន់ខ្លាំងក្រែងគេតាមទាន់ចាប់ខ្លួនបាន ឯអ្នកក្រោយក៏ភ័យដែរ ភ័យក្រែងអ្នកមុខគេចខ្លួនបាត់ព្រាត់គូកន ៗ មួយសន្ទុះធំទៅទៀត ភិក្ខុមោយកាន់តែឃ្លាតឆ្ងាយបន្តិច ព្រោះខ្លួនជាអ្នកមានរឿងផ្ទាល់ គោងតែលៃយ៉ាងណាឲ្យតែខាងរួចខ្លួន ៗ ដល់ទីបំផុតភិក្ខុមោយ លើកជើង --

គទៅទៀតលែងរួចសោះ កំស្រាប់បានបង្គោលរបង ១ ប៉ុនកំភួនដៃនៅក្បែរផ្លូវនេះ ហើយដែលខ្ញុំបានក្រឡេកឃើញដោយសារពន្លឺពិលពីក្រោយ ៗ កាលបានព្រួនដ៏ដាប់នៅដៃហើយ ហោយយើងក៏ត្រដរស្ទុះទៅផ្អែកទល់ខ្នងនឹងគល់ទ្រយឹង ១ ដើមកៀនផ្លូវនេះ ឈរបង់ដាំទែនជ្រួង ដើងប្រុងស្ងៀតសង្កៀតធ្មេញតទល់នឹងសត្រូវ ហាក់បីដូចពលយក្សឈរចាំយាមខ្លោងទ្វារអាទេសក័ណ្ឋា ហើយក៏តាំងស្រែកកំឡាថា "ពេលនេះអញជាកូនខ្មោចស្រេចទៅហើយ បើអាណាចង់ទៅស្រុកខ្មោចឲ្យចូលមកចុះ" ។ អ្នកតែតាមៈក្រោយបញ្ចាំងពិលក្លែតបានឃើញអាការរបស់មិត្រដូច្នោះក៏ទប់ង៉ក់ ស្រែកតពីចម្ងាយបន្តិចថា "មោយឆ្កួតទេឬ? លេងអីដូច្នេះ គ្នាយើងទេតើ អាចោរអន្ធពាន!" ។ មោយៈ "ទេ ចុះម៉េះហើយអត់គ្នាគេគ្នាយើងអីទៀតទេ បើចង់សុខឲ្យថយប្រញាប់ តែបើចង់ទុក្ខឲ្យចូលមកចុះ គ្រានេះមោយឈប់រត់ទៀតហើយ ស៊ូបូរនទាលដេកដីឲ្យទាល់តែរេចបង្គោលរបង ១ នេះសាកល្បងមើល តើរាំនឹងទៅជាយ៉ាងណា ចូរបើដាបកំឡាំងដល់ម៉េះក៏ដោយ" ។ គួកនសរសៀរចូលទៅជិតបញ្ឆាក់ទៀត "មោយឯងប្រឡំហើយ! អញទេតើ! អាចោររំបល់កាច់! គ្នាចំប្រឹងរត់តាមមកជួយដោះទុក្ខធុរៈខ្លួន ៗ ទៅជាចង់ច្បាំងគ្នាឯងទៅវិញ! នែមោយ! មោយឯងស្ដាប់មាត់អញបានទេ! រឿងខ្លួនប៉ុនក្ដីមិនគិត ទៅគិតតែសំដែងឫទ្ធិពីកូនខ្មោច កូនមនុស្សឯណាព្រើល ៗ

ទៅវិញចុយ! អាល័យតែឆ្កួតយ៉ាងនេះ គិតលោកតាមមកទាន់ឥឡូវហ្នឹង ហើយ» ។ មោយៈ "អូ! ម៉ប់ទេឬ?" ។ ម៉ប់ៈ "បើមិនម៉ប់ អាណាវិញ" ។ អ្នកទាំងពីរបានដើរចូលមកជិតគ្នាហើយ មោយក៏បោះដំបងចោល ទើបនិយាយទាំងហត់ហេប ៗ ថា "ខ្មោចអាស្ដូប្រទាញ! អីចឹង ៗ មិនបញ្ជាក់ឲ្យគ្នាដឹងច្បាស់តាំងពីដំបូងទេ បណ្ដោយឲ្យគ្នាបោលពីរបីគីឡូជិតសោះខ្យល់ដាច់អម្បាញ់មិញ អញដកដង្ហើមលែងរួចគ្នាម្ដង ៗ ទៅហើយ នៅតែ ៤-៥ ជំហានទៀត ដាច់ខ្យល់ម៉ាត់ហើយវុ! យី! តាមក្ដៅ អញចង់តែពួយនឹងបង្គោលរបងនេះ ឲ្យស្រុញកឥឡូវហ្នឹង!" ។ ម៉ប់ៈ "ក្ដើ ៗ! ចុះអាណាបេះបញ្ជាក់យ៉ាងម៉េចទៅទៀត បើគ្នាចាំស្រែកហៅខ្លួន ស្អកកអស់ទៅហើយតើថាឈប់ ៗ ខ្លួនរឹតតែលឿនឡើង ៗ នាំឲ្យគ្នាផាយតាមឯងរើះ ៗ តែផុតដង្ហើមដែរ" មោយៈ "ចុះអាណាស្គាល់សំឡេងបាន បើសំឡេងគឹងប៉ុនកង្កើរ ៗ មើលតែខ្មោចទើបនឹងរៀនលង! ហើយអញឯណះរត់ហ៊ុនគ្រាបៀកអស់ទៅហើយផង ហើយម៉្យាងទៀត ស្ដាប់សូរសន្ធឹកជើងឮតែព្រឹប ៗ ពីក្រោយស្ទើរគក្រើកដី គ្នាស្មានថាមានអ្នកដេញតាមក្រោយយ៉ាងតិចណាស់ក៏ ១០ នាក់ដែរ ម៉្លោះហើយគ្នាបេះតែពីកឲ្យតែខាំងលឿនតែម្ដង" ។ មោយ បន្ដសំដីទៅទៀតថា "ចុះម៉ប់ឯងម៉េចក៏រត់តាមក្រោយមកនេះដែរ ហើយពេលក្រោយដែលគ្នារត់បាត់មកនោះ តើកើតហេតុចលាចលយ៉ាងណា

ខ្វះ?" ។ ម៉ប់: "កុំបាច់សួរអីទៀត! ទឹកឡើងក្ដៅណាស់ ចង់តែលេង ក្បាលអាចប្រែងឯងនឹងពិលនេះឥឡូវហ្នឹង កំពុងនៅសុខ ៗ មកបង្ករឿងនាំឲ្យអំពល់ទុក្ខធំ" ។ មោឃ: "ចុះគ្នាមានទៅបង់បង្ករឿងបង្កើតហេតុអី បើពេលចេញពីវិហារមកនោះ ផងឹតព្រិល ៗ អញស្មានថាម៉ប់ឯងក៏លោតក្លូតគោងអៀវ ៗ អាចំប៉ាដូចតែមុន ៗ អីចឹង ព្រោះតាំងពីកាលណាមក គេជគុណយើងលោកមិនដែលចេញមកមុនគេដូច្នេះអី លោកធ្លាប់តែចេញក្រោយ ៗ គេជាធម្មតាដូចម៉ប់ឯងក៏ដឹងស្រាប់ហើយ, តែយប់នេះគឺជាយប់ស៊ិយតែម្ដង" ។ ម៉ប់: "ហ៊ឹះ! អគ្គីទេត្រយើងឯណោះលោកថាយប់នេះជាយប់ស៊ិយ ហើយអាំបល់ឯងឯណោះក៏ថាយប់នេះស៊ិយដែរ គិតទៅមិនដឹងជាអ្នកណាគ្រាន់ជាងអ្នកណាទេ គឺពស៊ិយទាំងអស់គ្នា! ណ្ហើយ! យើងកុំបង្អង់យូរនៅទីនេះ ប្រយ័ត្នក្រែងមានគេតាមមកទាន់ យើងត្រូវតែស្រូតទៅមុខបណ្ដើរនិយាយគ្នាបណ្ដើរទៅចុះ ដើម្បីឲ្យបានដៀនដំណើរបន្តិច" ។ កិក្ខុទាំងពីរក៏ក្រោកឡើងហើយចេញដំណើរតទៅទៀត ដើរបណ្ដើរពិគ្រោះគ្នាបណ្ដើរ ។ កិក្ខុម៉ប់បានរៀបរាប់ប្រាប់ខ្លី ៗ ថា គេជគុណយើងលោកបានប្រកាសយ៉ាងដាច់ខាតឲ្យលោកសង្ឃក្នុងវត្តតាមរកចាប់អាណា ដែលអៀវលោកនោះឲ្យបានជាប្រញាប់យកមកវ៉ៃផ្សែកវាលតែម្ដង ឯខ្លួនគ្នាឯណោះ ពិតមែនតែឥតបានប៉ះពាល់ក្នុងរឿងនោះសោះទេ តែថាទោះបីយ៉ាងណា ក៏គង់តែ

ជាប់ទាក់ទងបន្តបន្ទាប់ពីមោឃឯងមកជាពុំខានដែរ ព្រោះលោកថាយើងទាំងពីរនាក់សុទ្ធតែក្បាលវិលខ្ចូបដូចគ្នា ដូច្នេះ ឃើញថាយើងនៅស្រុកមិនបានជាជាប់ខាត គោងតែកៀសខ្លួនគេចរត់ទៅទីឆ្ងាយឲ្យបាត់ឈ្មោះតែម្តងទើបរួចខ្លួន បើយល់ស្របគ្នា យើងគិតទៅបាត់ដំបងព្រឹកស្អែកនេះ តើមោឃឯងយល់ថាម៉េច? ” ។ មោឃៈ “ទៅឯណាកើត បើគ្មានសំបុត្រធាយាជាប់មកជាមួយផង ហើយម្យ៉ាងទៀត ក៏គ្មានសោហ៊ុយសោះ” ។ ម៉ប់ៈ “ ធាយាយកមកហើយតើ ចំណែកសោហ៊ុយយើងនឹងទៅផ្ទះញោមឥឡូវនេះ សុំគាត់បន្តិចបន្តួចគ្រាន់នឹងជិះឡានតែប៉ុណ្ណោះក៏បានហើយ” ។ មោឃៈ “រឿងនេះបើឲ្យញោមយើងគាត់ដឹង ដូចជាមិនស្រួលទេខ្មាសគាត់ណាស់ ហើយខ្លាចគាត់ស្តីបន្ទោសផង ។ ម៉ប់ៈ “បើមិនឲ្យគាត់ដឹងដូចម្តេចកើត ព្រោះរឿងនេះជារឿងធំ ត្រូវតែគាត់កើ្តគាត់ខ្មាសប្រាប់គាត់ត្រង់ៗទៅ គាត់ស្តីបន្ទោសយ៉ាងម៉េចក៏ដោយ យើងចេះតែទទួលខុសហើយសុំឲ្យគាត់អត់ទោសទៅ ឥឡូវបើចង់ចៀសវាងលាក់បំពួនមិនឲ្យគាត់ដឹង តើយើងនឹងទៅសង្ឃឹមអ្នកឯណាវិញ” ។ មោឃៈ “បើដូច្នោះទៅក៏ទៅ ឯងគិតយ៉ាងណាស្រួល គ្នាឯណោះចេះតែតាមទាំងអស់ព្រោះគ្នាវិលខ្លួនអស់ទៅហើយ គិតអ្វីមិនលេចទេ ។ ភិក្ខុទាំងពីរក៏ស្រូតរូតដំណើរទាំងរាត្រីសំដៅទៅផ្ទះញោមដែលនៅភូមិជាមួយគ្នា ហើយផ្ទះក៏នៅក្បែរគ្នាទៀត ម៉ោងប្រហែលជាង ១០ ជាពេលដែលអ្នកភូមិដេកលក់អស់

ទៅហើយ, បានទៅដល់ផ្ទះនាំឲ្យផ្អើលក្កែព្រុសលាន់ ៗ កិត្តុមោយផាស់ហៅញោមប្រុសស្រីរបស់ខ្លួនឲ្យចុះមកដី ហើយឲ្យគាត់ទៅផាស់ហៅញោមប្រុសកិត្តុម៉ប់ទៀត (កិត្តុម៉ប់នៅតែញោមប្រុសទេ ឯញោមស្រីបានទទួលអនិច្ចកម្មយូរឆ្នាំហើយ ) ៗ កាលបានមកជួបជុំគ្នាហើយ កិត្តុម៉ប់បានរៀបរាប់ខ្សឹបប្រាប់ញោមហូរហែតាមដំណើរសព្វគ្រប់, ដល់ទីបំផុតក៏បានប្រាប់សេចក្តីសម្រេចរបស់ខ្លួនថា ត្រូវកៀសខ្លួនរត់ទៅបាត់ដំបងព្រមទាំងសុំសោហ៊ុយខ្លះផង ដើម្បីធ្វើដំណើរឲ្យផុតពីភ័យអាសន្នក្នុងមួយគ្រានេះសិន ៗ ញោមកិត្តុមោយ ដកដង្ហើមយូយ៉ាងតឹងទ្រូង ហើយគាត់ស្តីបន្ទោសកូនយ៉ាងធ្ងន់ អំពីកំហុសព្រោះតែល្បែងព្រើលដែលប៉ះពារទៅលើលោកគ្រូសង្ឃរាជនោះ ចំណែកញោមកិត្តុម៉ប់ក៏បន្ទោសកូនយ៉ាងខ្លាំងដែរ ៗ កិត្តុទាំងពីរបានលន់តួទទួលខុសឥតមានហ៊ានប្រកែកជជែកតក៉អ្វីឡើយ ព្រោះខ្លួនឯងខិលខូចមែន ៗ

ឧបាសកទាំងពីរ ក៏ពុំអាចឃាត់កូនឲ្យវិលត្រឡប់ទៅវត្តវិញ ឬនឹងជួយធានាអះអាងដោះស្រាយដោយឧបាយយ៉ាងណាក៏ពុំកើត ព្រោះធ្លាប់ដឹងព្រះទ័យលោកគ្រូចៅអធិការស្រាប់ហើយ បើលោកថាយ៉ាងណា គឺត្រូវតែធ្វើយ៉ាងនោះជាដាច់ខាត ជាហេតុនាំឲ្យអ្នកទាំងពីរនៅតែព្រួយចំពោះខ្លួនឯងមួយជាន់ទៀត កាលណាបើកូនគេចខ្លួនបាត់ទៅហើយ ដោយគាត់នឹកឃើញថាការប្រព្រឹត្តិអាក្រក់របស់កូន គឺជាការៈរបស់មាតាបិតា

ទាំងស្រុង ម្យ៉ាងទៀត គាត់នឹកអៀនខ្មាសណាស់ ខ្មាសដល់លោកគ្រូសង្ឃរាជ នឹងអ្នកស្រុកភូមិទាំងអស់ ពីព្រោះតែកូនខុសគេខុសឯងយ៉ាងនេះ តែមិនដឹងធ្វើដូចម្ដេច បើការណ៍នេះរហួសជ្រុលអស់ទៅហើយ ។ ពេលនោះញោមប្រុសភិក្ខុមោយ ចាប់ផ្ដើមពិគ្រោះឡើងថា " រូបលោកទាំងពីរអង្គកាលណានិមន្ដគេចខ្លួនបាត់ទៅ ទុកជាបានរួចខ្លួនក្នុងមួយគ្រានេះហើយ ចុះចំណែកយើងដែលនៅទីនេះតើគួរដោះស្រាយយ៉ាងណាឲ្យបានសុខស្រួលជាមួយលោកគ្រូសង្ឃរាជផង " ។ ភិក្ខុទាំងពីរតបថា " ការនេះស្រេចតែញោម លៃលកសម្រួលយ៉ាងម៉េចក៏ដោយ ឲ្យតែខាងស្របអបដើងជាមួយលោកទៅចុះ កុំឲ្យចូលដៃសមគំនិតខាងអាត្មាឲ្យសោះ ។ ញោមភិក្ខុ ម៉ប់ ដែលធ្លាប់តែមានប្រាជ្ញាស្មារតីរាងវៃគ្រាន់បើជាងគេឆ្លើយឡើងថា " ណ្ហើយ ! រឿងនេះចាំយើងលៃលកតទៅទៀតឥឡូវនេះ យើងគិតឲ្យតែបានលោកទាំងពីរអង្គនិមន្ដផុតទៅសិនចុះ ព្រោះកាន់តែយប់យន់ណាស់ទៅហើយ " ។ អ្នកទាំងអស់យល់ស្របតាមហើយក៏យកបច្ច័យប្រគេនលោកទាំងពីរតាមសមគួររួចផ្ដែផ្ដាំថា បើនិមន្ដទៅបាននៅអាស្រ័យជ្រកកោនកន្លែងណា បានសុខទុក្ខដូចម្ដេច ។ សុំឲ្យលបឲ្យដំណឹងផងក្នុងថ្ងៃក្រោយ ។ ឯលោកទាំងពីរអង្គ ក៏ចំរើនពរលាញោមដោយសេចក្ដីទុក្ខព្រួយទឹងអាឡោះអាល័យ នាំគ្នាស្រូតរូតទាំង-ពាក់កណ្ដាលអធ្រាត្រ ត្រាច់សំដៅទៅរកផ្លូវថ្នល់ ព្រលឹមស្រាង ៗ បាន

ឡើងជិះឡានធ្វើដំណើរទៅបាត់ដំបងបាត់ទៅ ។ ចំណែកញោមស្រី កិត្តិមោយ គ្មានមាត់កអ្វីសោះ គិតតែអង្គុយយំសម្រក់ទឹកភ្នែក ។

ក្រោយដែលកិត្តិទាំងពីរនិមន្តចេញផុតទៅ ញោមលោក ម៉ប់បាន គិតឃើញឧបាយមួយក្នុងការដោះស្រាយរឿងនោះ ហើយក៏ពន្យល់ញោមប្រុសស្រី កិត្តិមោយ ដោយសម្ងាត់តែ ៣ នាក់ប៉ុណ្ណោះ ។ ពេលមាន់រងាវម្តង អ្នកទាំងពីរក៏ទឹមរទេះបរទៅ មានទាំងបាយកញ្ចប់ដាក់ជាប់ទៅជាមួយផង ព្រលឹមស្រាង ៗ បានទៅដល់វត្ត ក៏តាំងធ្វើឧបាយកលភូតកុហកលោកគ្រូសង្ឃរាជ ដូចរឿងដែលបាននិយាយរួចមកហើយនោះឯង ។

ចំណែកខាងលោកគ្រូសង្ឃរាជវិញ ដែលបានចាត់ការឲ្យគេស៊ើបសួររកអស់កាលជាច្រើនថ្ងៃនោះ ក៏ឥតបានដំណឹងដំនួចអ្វីសោះ ម្លោះហើយលោករឹងរឹតតែមួម៉ៅក្តៅព្រះទ័យជាដកប លោកស្តាយណាស់ ស្តាយហើយស្តាយទៀត ស្តាយត្រង់អាក់ខានមិនបានសំពងកិត្តិទាំងនោះ ដោយមានបាសាក់ថ្មី ១ ពីរបីទៀត ដែលលោកបានឲ្យគេខំរកយកមកបំរុងទុកក្នុងរឿងនេះ ។

---

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## រឿងព្រេងនាក់ទងដោយការស្ថាបនាប្រាសាទអង្គរវត្ត

### លោក ញ៉ែម-ខឹម រៀបរៀង

(តមក)

គិតដូច្នោះហើយ ព្រះពិស្ណុការរត់ចូល ។ លុះស្រីទាំងឡាយនោះបានដើរមកជិតដល់កុមារ ៗ ក៏លើកដៃបួងសួងឡើងថា: "បើស្រីទាំងអស់នេះជាទេពធីតា ហើយឥតមានម្តាយខ្ញុំនៅក្នុងនេះផងទេ សូមឲ្យហោះហើរទៅកាន់ស្ថានលំនៅគេវិញកុំបីមានសល់ឡើយ; ប៉ុន្តែ បើមានម្តាយខ្ញុំមកនៅក្នុងទីនេះផង ខ្ញុំសូមកុំឲ្យម្តាយខ្ញុំហោះហើរទៅជាមួយនឹងគេបាន" ។

លុះបួងសួងដូច្នេះចប់ហើយ ព្រះពិស្ណុការក៏រត់ចេញសំដៅទៅកន្លែងដែលទេវធីតាទាំងនោះកំពុងលេង ។ នាងទេពធីតាទាំងឡាយ កាលបើឃើញកុមារជាបុត្រ ជាមនុស្សលោកដូច្នេះ មានសេចក្តីភ្ញាក់ផ្អើលពន់ប្រមាណ ហើយក៏បបួលគ្នាស្ទុះហោះទៅស្ថានលើអស់ នៅសល់តែនាងទេពសុគន្ធហោះទៅនឹងគេពុំរួច ។ ព្រះពិស្ណុការរត់យ៉ាងលឿនតម្រង់ទៅរកព្រះនាង ចាប់ឱបរឹតព្រះនាងយ៉ាងស្អិតស្អាលជាទីបំផុត ។

នាងទេពសុគន្ធ ស្រែកយ៉ាងខ្លាំងៗ ថា តើកម្មអ្វីតាមមកគ្របសង្កត់លើរូបខ្ញុំទៀតហើយ ខ្ញុំបានសោយទុក្ខសោយទោស បានរួចពី

ឋានៈជាមនុស្សលោកហើយ ម្ដេចឡើយក៏មានមនុស្សលោកមកចាប់រឹត ត្រខ្ញុំជាថ្មួងទៀតដូច្នេះ :

ព្រះពិស្ណុការស្រែកឡើងថា: ម៉ាក់ ! ម៉ាក់ ! ខ្ញុំនេះត្រូវជាកូនម៉ាក់ៗ កាលដែលម៉ាក់រត់ចេញពីផ្ទះបាត់ទៅ កូនក៏យំទួញសោកដើររកម្ដាយ គ្រប់ទីកន្លែងអស់ហើយ ប៉ុន្តែឥតបានឃើញសោះ ៗ លោកឪពុកបាន ចូលទៅរកម៉ាក់ក្នុងបន្ទប់ , ប៉ុន្តែឃើញតែផ្កាប្រាំមួយដាក់លើខ្នើយ , គាត់ក៏យល់ក្លាមថា ម៉ាក់ត្រឡប់ទៅនៅឯស្ថានទេវតាវិញហើយ , គាត់ មានសេចក្ដីកើតទុក្ខពន់ប្រមាណ ពុំអាចរកអ្វីមកប្រៀបបាននៅក្នុងលោក យើងនេះ, មិនតែប៉ុណ្ណោះ, អ្នកជិតខាង ក៏បានរត់មកជួយយំសោក ទឹកស្រណោះម៉ាក់ ជាមួយនឹងយើងដែរ ; តាំងពីពេលនោះមក ខ្ញុំចេះ តែនឹកមមៃមកម៉ាក់ពុំមានភ្លេចសោះឡើយ, លុះខ្ញុំធំដឹងក្ដីបន្តិចឡើង, ខ្ញុំ ក៏សុំលាលោកឪពុកចេញដើរផ្សងព្រេងតាមរកម៉ាក់ឯង. កូនទឹកស្មានថា កូនមុខជាស្លាប់ដោយអស់កំឡាំងបាក់ដួលបាយពុំខាន ; តែឥឡូវនេះ ខ្ញុំ បានមកជួបម៉ាក់ហើយ, ខ្ញុំសូមអង្វរម៉ាក់ឲ្យត្រឡប់ទៅវិញជាមួយនឹង កូន ! ៗ

នាងទេព្វសុគាចន្ទ ស្គាល់កុមារថាជាកូនរបស់ខ្លួនពិត ដោយសារ សំដីដែលកុមារនិយាយ ៗ ដូច្នេះ នាងក៏យំទួញសោកអាណិតកូនជាខ្លាំង ហើយមានវាចាទៅកាន់កូនថា :

"ម៉ាក់ឥតមានស្អប់ខ្ពើមឪពុកឯងទេ, ម៉ាក់តែងនឹកមកកូនឯង នឹងឪពុកឯងពុំមានភ្លេច ព្រមទាំងអ្នកភូមិផងរបងជាមួយឯទៀត ដែលម៉ាក់ធ្លាប់រស់នៅជាមួយ ប៉ុន្តែម៉ាក់ជាតិជាទេពធីតា ពុំអាចរស់នៅជាមួយមនុស្សលោកបានទេ, រាល់ថ្ងៃម៉ាក់តែងទៅបំពេញកិច្ចនៅចំពោះព្រះភក្ត្រព្រះឥន្ទ្រាធិរាជ គឺអង្វរសុំឲ្យព្រះអង្គប្រទានពរដល់កូនឯងនឹងឪពុកឯងកុំបីខាន; មិនតែប៉ុណ្ណោះ, ម្ដាយបានទាំងទូលសុំព្រះឥន្ទ្រ ឲ្យព្រះអង្គមេត្តាផ្សាយនូវសុភមង្គល ដល់មនុស្សណានៅស្ថាននេះទូទៅផង, កូនប្រុសពន្លកម្ដាយ ៗ ពុំអាចទៅរស់នៅជាមួយនឹងអ្នកបានទៀតទេ, តែម៉ាក់នឹងយកកូនឯងឲ្យទៅលេងកន្លែងម្ដាយឯស្ថានលើមួយដង, ម្ដាយនឹងនាំកូនឯងទៅមុជទឹកក្នុងអាងក្រអូបនៅក្នុងសួនព្រះឥន្ទ្រ ហើយទឹកនោះនឹងជុះជម្រះកាយកូនឯងឲ្យបាត់ធំខ្លួនមនុស្សលោក ។ បន្ទាប់ពីនោះម្ដាយនឹងនាំកូនឯងចូលទៅក្នុងប្រាសាទ, រួចនាំកូនឯងទៅថ្វាយបង្គំព្រះឥន្ទ្រ ៗ

( ទៅមានត )

ផ្នែកគាំណាត់ជីជ៍ប្រវត្តិការណ៍

# សេចក្តីកត់ហេតុនៃមហាសន្និបាត

## លើកទី ១២ នៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ

កាលពីថ្ងៃទី ២២ មករា ១៩៦១ វេលាម៉ោង ១៥ សមាគមមិត្តពុទ្ធិក-វិទ្យាល័យ បានបើកការប្រជុំមហាសន្និបាតសាមញ្ញនៅសាលាពុទ្ធិកបឋមសិក្សាវត្តលង្កា ។

បាននិមន្ត អញ្ជើញមកជួបជុំ ចំណែកខាងបព្វជិត គឺ:

- ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត អគ្គាធិការពុទ្ធិកសិក្សា
- ព្រះតេជព្រះគុណព្រះធម្មលិខិត ម៉ុង-សែស ចៅអធិការវត្តមហាមន្ត្រី
- ព្រះតេជព្រះគុណព្រះឃោសធម្ម កៅ-ស៊ុម ចៅអធិការវត្តលង្កា
- ព្រះតេជព្រះគុណ ព្រះញាណកោសល ញាណ-ឈឿន ក្រុមជំនុំព្រះត្រៃបិដក
- ព្រះតេជព្រះគុណ លោកអាចារ្យ ប៉ាង-ខាត់ ក្រុមជំនុំព្រះត្រៃបិដក

នឹងព្រះថេរានុត្ថេរៈ ទាំងឡាយ ។

ចំណែកខាងគ្រហស្ថ គឺ:

- លោក ព៉យ-លុត ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ
- សមាជិកខ្លះនៃរដ្ឋសភា-នៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ-មន្ត្រីធំ-តូច សមាជិក-សមាជិកា-ក្រុមអភិបាលនៃសមាគម ។

ម៉ោង ១៨, ៣០ នាទី លោក ក៉យ - ប៊ុក ប្រធានសមាគមបាន

បើកសម័យប្រជុំ ដោយថ្លែងនូវសុន្ទរកថាមួយរៀបរាប់អំពីសកម្មភាពនៃ

សមាគមពីឆ្នាំ ១៩៦០ ដូចបានចុះផ្សាយទៅខាងក្រោយ ។

លុះចប់សុន្ទរកថាលោកប្រធានហើយ លោកអគ្គហេរញ្ញិកបានថ្លែង

នូវសុន្ទរកថាមួយពណ៌នាអំពីស្ថានការណ៍ហិរញ្ញវត្ថុសមាគម ។

លុះចប់សុន្ទរកថាលោកអគ្គហេរញ្ញិកហើយ លោកក៉យ-ប៊ុក ប្រធាន

ក្រុមអភិបាលសមាគមក៏បានឡើងទៅលើវេទិកាប្រកាសថា ក្រុមអភិបាល

សមាគមឆ្នាំ ១៩៦០ សូមលាលែងពីត្រឹមថ្ងៃនេះតទៅ ។

លំដាប់តមកមហាសន្និបាត ក៏បានជ្រើសតាំងការិយាល័យសម្រាប់

បោះឆ្នោតមានសភាពដូចតទៅ ។

លោក ក៉យ . លុត ជាប្រធាន, លោក ឌៃ-វង្ស, លោក សៅ-វ៉ែន,

ជាលេខាធិការ, រួចទើបមហាសន្និបាតចាត់ពិធីបោះឆ្នោតជ្រើសតាំងក្រុម

អភិបាលសម្រាប់ឆ្នាំ ១៩៦១ ។

ក្រោយដែលបានសរសេរនាមសមាជិក សមាជិកា - ក្រុមអភិបាល

នៅលើក្តារឈ្នួនរួចហើយ; លោកប្រធានការិយាល័យបោះឆ្នោត ក៏បាន

ប្រកាសជំរាបមហាសន្និបាតឲ្យអនុម័តយកតែម្តងទៅ មហាសន្និបាត

ក៏បានព្រមព្រៀងជាឯកច្ឆ័ន្ទយកសមាជិក សមាជិកា - ក្រុមអភិបាលដែល

មាននាមដូចតទៅ ៖

លោកព៉យ-ប៊ុក, លោកអ៊ឹង-ឌួន, លោកផេង-ជ្រីវ លោកម៉ៅ-ម៉ី, លោក សៅ-រិន, លោក ប៊ិន-ហ៊ាក, លោកជា-ទន់, លោក ឆៃ-វង្ស, លោកស្រី គួច-ស្អាត, លោកស្រី សម-ណៃ, លោកស្រី ព៉យ-ប៊ុក, លោកស្រី សាខន-សាម៉ន, លោក យ៉ង-គឹមលន, លោក សម-សុខម, លោក មៃ-ប៉ាន់, លោក ឌី-រ៉េង, លោក មាស-ឆាន់ ។

មហាសន្និបាតក៏បញ្ចប់ទៅម៉ោង ១៧ ដោយបរិយាកាសយ៉ាងរីករាយ ។

X

X X

លុះដល់មកថ្ងៃសុក្រទី ២៦ មករា ១៩៦១ ពេលម៉ោង ១៧, ៣០ នាទី មានការប្រជុំគណៈកម្មាធិការនាយកនៃសមាគម ដើម្បីចែកមុខការសមាជិក-សមាជិកា ។ គណៈកម្មាធិការនាយកបានមូលមតិជាឯកច្ឆន្ទចែកមុខការសមាជិកដូចតទៅនេះ៖

១ លោក ព៉យ - ប៊ុក . . . . . . . . . . . ប្រធាន

២ លោក អ៊ឹង - ឌួន . . . . . . . . . អនុប្រធាន

៣ លោកស្រី គួច-ស្អាត . . . . . . . -ដ-

៤ លោក ម៉ៅ - ម៉ី . . . . . . . អគ្គហេរញ្ញិក

៥ លោក ឆៃ - វង្ស . . . . . . . . . អនុហេរញ្ញិក

៦ លោក យ៉ង - គឹមលន . . . . . . . . -ដ-

៧ លោក ប៊ិន - ហ៊ាក . . . . . . . . . លេខាធិការ

៨ លោក សៅ - វ៉ែន . . . . . អនុលេខាធិការ

៩ លោកស្រី សាខន - សាម៉ន . . . . . -ដ-

១០ លោក ជា - ទន់ . . . . . . . . បណ្ណារក្ស

១១ លោក សម - សុខម . . . . . . . . -ដ-

១២ លោក ម៉ែ - ប៉ាន់ . . . . . . . . ស្នងការ

១៣ លោក ផេង - ជ្រីវ . . . . . . . . -ដ-

១៤ លោកស្រី ក៉យ - ប៊ុក . . . . . . . . -ដ-

១៥ លោកស្រី សម - ណៃ . . . . . . . -ដ-

១៦ លោក ឌី - រ៉េង . . . . . . . . . -ដ-

១៧ លោក មាស - ឆាន់ . . . . . . . . . -ដ-

ក្រោយដែលបានជ្រើសរើសហើយ លោកប្រធានបានប្រកាស សូមឲ្យជ្រើសតាំងទីប្រឹក្សាសមាគម ។ គណៈកម្មាធិការនាយក ក្រោយដែលបានបួរយោបល់គ្នាទៅវិញ-មក បានសម្រេចយកទីប្រឹក្សាសមាគម ដូចមានពយនាមខាងក្រោមនេះ៖

## ១- ផ្នែកខាងបព្វជិត

ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត, ព្រះតេជព្រះគុណព្រះធម្មលិខិត ម៉ឹង-សែស, ព្រះតេជព្រះគុណព្រះឃោសធម្ម កៅ-ស៊ឹម,

ព្រះតេជព្រះគុណព្រះមុនីកោសល សូរ-ហាយ, ព្រះតេជព្រះគុណ ព្រះញាណកោសល ញាណ-ឈើន, ព្រះអាចារ្យ ប៉ាង-ខាត់, ព្រះអាចារ្យ ខៀវ-ជុំ ។

## ២_ ផ្នែកខាងគ្រហស្ថ

លោក សូ-ស៊ុផន ហៅ យ៉ាំ, លោក ខៀវ-ព្រីង, លោក ថៃ-សារិផលី, លោកស្រី ជុស-ដួង, លោក យក់-សាម៉េត, លោក សាម-ឡាម៉ុត, លោក តាប-ពិន ។

នៅម៉ោង ១៧ គណៈកម្មាធិការនាយកបានលើកពេលប្រជុំ ។

x

x x

# សុន្ទរកថា លោក រ៉ាយ-ប៊ុក

ប្រធាននៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ ថ្លែងក្នុងឱកាសមហាសន្និបាត

កាលពីថ្ងៃអាទិត្យទី ២៦ មករា ឆ្នាំ ១៩៦១ នៅវត្តលង្កា ។

---

សូមនមស្ការព្រះតេជព្រះគុណព្រះពោធិវង្ស អគ្គាធិការពុទ្ធិកសិក្សា

សូមនមស្ការព្រះតេជព្រះគុណ ព្រះធម្មលិខិត ចៅអធិការវត្តមហាមន្ត្រី ។

សូមនមស្ការព្រះតេជព្រះគុណ ព្រះឃោសធម្ម ចៅអធិការវត្តលង្កា ។

សូមនមស្ការព្រះថេរានុត្ថេរៈទាំងឡាយ សូមទូលទ្រង់ សូមជំរាប ព្រះតេជគុណ លោក-អ្នក, លោកស្រី-អ្នកស្រីទាំងឡាយ ។

ខ្ញុំបាទនាមសមាគមមិត្តពុទ្ធិកវិទ្យាល័យ សូមថ្លែងនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅ ចំពោះព្រះតេជព្រះគុណ ជាទីគោរព ព្រះថេរានុត្ថេរៈទាំងឡាយ និងទ្រង់ ព្រះតេជគុណ, លោក-អ្នក លោកស្រី-អ្នកស្រី ដែលនិមន្ត ស្តេចយាង អញ្ជើញមកកាន់មហាសន្និបាតនេះ ដើម្បីជាកិត្តិយសដល់សមាគមយើង ។

ថ្ងៃនេះ ជាអភិលក្ខិតសម័យ គឺសម័យដ៏ជាគជ័យមង្គលសិរីសួស្តី, យើងទាំងអស់គ្នា បានមកជួបជុំគ្នា ១ ឆ្នាំម្តង ដើម្បីនឹងញុំាងសាមគ្គីភាព ភាតរភាពឲ្យក្តីស្ថានរុងរឿង និងរឹតចំណងឲ្យកាន់តែមួនមាំឡើង តាមលំដាប់ ។

ខ្ញុំព្រះករុណា ខ្ញុំបាទ-ខ្ញុំ សូមពណ៌នាអំពីសកម្មភាពសមាគម ដែលបានធ្វើកន្លងឆ្នាំ ១៩៦០ ដូចតទៅនេះ ៖

១ - កាលពីថ្ងៃទី ៣ ធ្នូ មករា ១៩៦០

សមាគមបានប្រជុំមន្ទីរតំណាងសមាគមកម្ពុជរដ្ឋ និមន្តព្រះសង្ឃបំពេញសត្តប្បករណ៍ ឧទ្ទិសថ្វាយព្រះរាជកុសលចំពោះព្រះវិញ្ញាណក្ខន្ធ ព្រះបរមសពព្រះករុណាព្រះមហាក្សត្រនរោត្តម សមាគមបានចំណាយប្រាក់ចំនួន ១.២៥៤៛០០ តំណាងសមាគមកម្ពុជរដ្ឋ ចំនួនប្រាក់ ២.៥០៨៛០០ ក្នុងការកុសលនេះ ។

២- កាលពីថ្ងៃទី ២ វិច្ឆិកា ១៩៦០

សមាគមបានប្រជុំជាមួយតំណាងសមាគមកម្ពុជរដ្ឋ ធ្វើកឋិនទានប្រគេនព្រះសង្ឃ ដែលគង់ចាំវស្សាអស់ត្រៃមាស ក្នុងវត្តលាំងឈូក ភូមិត្រស ឃុំកាហែង ស្រុកសំពៅមាស ខេត្តកំពង់ស្ពឺ ចំណាយប្រាក់ ១.០០០៛០០ នឹងចីពរ ៩ ។

៣- កាលពីថ្ងៃទី ១៧ ធ្នូ ១៩៦០

សមាគមបានប្រជុំជាមួយតំណាងសមាគមកម្ពុជរដ្ឋ បានធ្វើទក្ខិណានុប្បទានវេរគ្គប្រគេនព្រះសង្ឃ ឧទ្ទិសកុសលប្រគេនទៅព្រះវិញ្ញាណក្ខន្ធនៃព្រះសពព្រះតេជព្រះគុណព្រះសាសនមុនី មាស-គង់ ចៅអធិការវត្ត

ពិភពលោក ដែលអនិច្ចធម្មពីថ្ងៃទី ៥ វិច្ឆិកា ១៩៦០ ព្រមទាំងបានចំណាយប្រាក់អស់ ៥០០៛០០ ។

៤- សមាគមបានធ្វើចុតហ្មាយ ជូនទៅរាជរដ្ឋាភិបាល សូមឲ្យទទួលស្គាល់សមាគមថា ជាសមាគមមានប្រយោជន៍សាធារណៈ ។ ចំពោះរឿងនេះ គណៈរដ្ឋមន្ត្រីបានបើកការៈប្រជុំកាលពីថ្ងៃទី ១៣ កញ្ញា ១៩៦០ សម្រេចយល់ព្រមតាមសេចក្តីសុំនៃសមាគម ។

៥- កាលពីថ្ងៃទី ១១ ធ្នូ ១៩៦០

សមាគមបានរួបរួមជាមួយនឹងពុទ្ធិកសមាគមកម្ពុជរដ្ឋ សមាគមគិលានុបដ្ឋានព្រះមហាក្សត្រិយានី បានធ្វើទក្ខិណានុប្បទានក្នុងឱកាសពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ ។

៦- សមាគមបានជួយឧបត្ថម្ភសមណនិស្សិត ដែលនៅសិក្សាឯប្រទេសឥណ្ឌាគឺ:

ក- សមណនិស្សិតនៃមហាវិទ្យាល័យនាលន្ទា ព្រះមហា ព៉ៃ-យ៉ាវ ដោយជំនួយមូលនិធិអាស៊ី; ព្រះមហា ស៊ុន-សារឿម ដោយជំនួយរដ្ឋាភិបាលកណ្តាលញូដែលីប្រទេសឥណ្ឌា; ចំណែកព្រះមហាប៉ែន-សាអឿន នឹង អ៊ុក-អ៊ុន, ព្រះមហា ប៉ែន-សាអឿន រដ្ឋាភិបាលប្រទេសឥណ្ឌា បានយល់ព្រមប្រគេនអាហារូបករណ៍ឆ្នាំ ១៩៦១ ហើយ ឯព្រះមហា អ៊ុក-អ៊ុន ក្រសួងធម្មការកំពុងសន្ទនាជាមួយនឹងមន្ទីរស្តីការនាយករដ្ឋមន្ត្រី ។

សមណនិស្សិតនៃមហាវិទ្យាល័យពារាណសី គឺព្រះមហា អាំ-សួន, មាស-បន, អ៊ុន-សំបេត ដោយជំនួយមូលនិធិអាស៊ី ។

សមណនិស្សិតនៃមហាវិទ្យាល័យក្រុងញូវដេលហ្ស៊ី ព្រះមហាឈឹម-ផន ដោយជំនួយមូលនិធិអាស៊ី ។

៧- កាលពីថ្ងៃទី ១៩ វិច្ឆិកា ១៩៦០

សមាគមបានរួបរួមជាមួយនឹងក្រសួងធម្មការ ព្រងទាំងពួកពុទ្ធបរិស័ទ ធ្វើបុណ្យព្រហ្មទានចែករង្វាន់សមណនិស្សិត ១៣១ អង្គ នៅក្រោមព្រះរាជាធិបតាទីភាពនៃសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ។ សម្តេចព្រះមហាក្សត្រិយានី ៧៦ កញ្ចប់ សមាគមនឹងពុទ្ធបរិស័ទ ៥៥ កញ្ចប់រួមជា ១៣១ កញ្ចប់ ។

៨- កាលពីថ្ងៃទី ២៦ កក្កដា ១៩៦០

សមាគមបានធ្វើពិធីទទួលលោក ដុ-រីសាដ៍ការដ៍ ទីប្រឹក្សាពុទ្ធសាសនានៃមូលនិធិអាស៊ី លោកដុកទ័រនេះជាអ្នកពហូសូត្រ នៃពុទ្ធសាសនា, សព្វថ្ងៃលោកកាន់ដំណែងជាសាស្ត្រាចារ្យ ខាងការសិក្សាពុទ្ធសាសនានៅមហាវិទ្យាល័យយ៉ាល-សហរដ្ឋអាមេរិក ។ សមាគមយើងបានចំណាយ ១.០០០៛០០ ក្នុងពិធីជប់លៀងកេសដ្ឋៈដល់លោកបណ្ឌិតនេះ ។

៩- កាលពីខែ ឧសភា ១៩៦០ លោកកុក្កាគហបតី ជាតិឥណ្ឌូនេស៊ីម្នាក់ នៅភ្នំពេញបានបូជាចំពោះសមាគម នូវប្រាក់ ៣-០០០៛០០ ដូរជារូពី

ចំនួន ៤០០ រៀល ហើយបានផ្ញើទៅប្រគេនព្រះមហា ប៉ែន-សាអឿន និង អ៊ុក-អ៊ុន ២០០ រៀលមួយអង្គ សមាគមសូមថ្លែងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ ចំពោះលោកជាមហាសប្បុរស ។

១០- អំពីកិច្ចការពារព្រះពុទ្ធសាសនា, សមាគមបានរួបរួមជាមួយ ពុទ្ធិកសមាគមនិងសមាគមគិលានុបដ្ឋានព្រះមហាក្សត្រិយានី បានធ្វើ បុគហ្វាយលេខ ៥០ ពុ-ម-ក- ចុះថ្ងៃទី ៣០ ខែសីហា ១៩៥០ ទៅ ប្រកាន់លើឈ្មោះ គឹម-សែត ដែលជាអ្នកនិពន្ធសៀវភៅនាមថា: "តែងិ សេចក្ដីខ្មែរអធិប្បាយសុភាសិត និងពាក្យចាស់" ដោយឈ្មោះនេះមាន តែងអត្ថបទខុះ បញ្ចេញយោបល់ជំទាស់និងព្រះពុទ្ធសាសនា ។

១១- អំពីសមាជិកគ្រប់ប្រភេទ សមាគមបានធ្វើការឃោសនា ផ្សាយ បានសមាជិកដូចតទៅនេះគឺ:

កិត្តិយសសមាជិក ៨ នាក់

- ជនកសមាជិក ៨ នាក់
- ឧបការីសមាជិក ៥ នាក់
- ទាយកសមាជិក ៤៦ នាក់
- កម្មកសមាជិក ៦៣២ នាក់
- បាសាទិកសមាជិក ៨៥៤ នាក់

បូករួម: ១.៥៥៣ នាក់

ក្នុងឆ្នាំ ១៩៥៩ មានចំនួន ១.៤៩៥ នាក់ ឃើញកើនជាងឆ្នាំចាស់ ៥៨ នាក់ ។

មុននឹងបញ្ចប់សុន្ទរកថា ខ្ញុំបាទសូមសរសើរលោក-អ្នក ព្រមទាំងលោកស្រី-អ្នកស្រី ដែលជាសមាជិក-សមាជិកាក្រុមអភិបាល ដែលបានព្យាយាមអញ្ជើញមកប្រជុំ ដើម្បីនឹងដោះស្រាយនូវបញ្ហាសមាគមដែលស្មុគ្រស្មាញ ព្រមទាំងជូនយោបល់ដ៏ប្រសើរគ្រប់ ៗ គ្នា ខ្ញុំសូមអរគុណជាអនេកប្បការ ។

អវសាន សូមឧទ្ទិសកុសលរាសី ដែលសមាគមបានបំពេញទាំងប៉ុន្មាន ថ្វាយទៅព្រះវិញ្ញាណក្ខន្ធនៃព្រះបរមសពសម្តេចព្រះមហាកាញ្ចនកោដ្ឋ សូមទ្រង់គង់ជាសុខក្នុងទិព្វវិមានស្ថានសួគ៌ អស់កាលជាអង្វែងតទៅ; សូមសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ទ្រង់ប្រកបដោយសុវត្ថិជ័យមង្គលសិរីសួស្តីគ្រប់ជំពូក, សូមសម្តេចសហជីវិនជាព្រះប្រមុខរដ្ឋ ទ្រង់ប្រកដោយសុខមាលភាព ប្រកបដោយអាយុៈ វណ្ណៈ សុខៈ ពលៈ បដិភាណៈ កុំបីឃ្លៀងឃ្លាតសោះឡើយ; សូមពួកពុទ្ធបរិស័ទទាំងឡាយ ទាំងបព្វជិតទាំងគ្រហស្ថ បានសេចក្តីសុខ-ចំរើនជាគេយ្យាភាពតទៅ ។

អធិបតីសមាគមមិត្តពុទ្ធិកវិទ្យាល័យ

ប៉ាយ-ប៊ុត

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣៣ លេខ ៣ ខែមីនា

ព.ស. ២៥០៣ គ.ស. ១៩៦១

ភ្នំពេញ

# ពុទ្ធសាសនា និងពុទ្ធសាសនិកបានទទួល

## ព្រះបរមរាជូបត្ថម្ភអំពីព្រះរាជបល្ល័ង្ក

កាលពីថ្ងៃទី ២ មីនា ១៩៦១ ក្នុងពេលដែលសម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងទៅសម្ពោធបើកការហត្ថកម្មផ្លូវរាជអយស្មយាន ភ្នំពេញ ក្រុងព្រះសីហនុលើកទី ២ នៅឃុំប្រទះឡាំង, ព្រះអង្គទ្រង់បានព្រះរាជ-បរិច្ចាគព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ចំនួន ៥០០០៛០០ ក្នុងការកសាងព្រះវិហារ វត្តតាំងនោម ឃុំប្រទះឡាំង ស្រុកភ្នំពេញ ខេត្តកណ្ដាល ។

កាលពីថ្ងៃទី ២៨ មីនា ១៩៦១ សម្ដេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិត ទ្រង់សព្វព្រះរាជហឫទ័យ ព្រះរាជទាននូវចីវរ ១៧ ស្បង់ ១៧ និងប្រាក់ ១២០០០៛ ដល់សហជីវិន សឺង-គៀក ៥ ដើម្បីយកទៅប្រគេនព្រះសង្ឃ និងជូនជនរួមជាតិខ្មែរកម្ពុជាក្រោម ដែលភៀសខ្លួនមកនៅក្នុងដែនស្រុកគិរីវង្ស ខេត្តតាកែវ ។

ព្រះរាជវិភាគទាននេះ ជាសក្ខីភាព បង្ហាញឲ្យឃើញព្រះរាជហឫទ័យប្រកបដោយព្រះរាជសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនា និងព្រហ្មវិហារ-ធម៌ចំពោះព្រះសង្ឃពុទ្ធសាសនិក និងកូនចៅព្រះអង្គដែលទទួលរងគ្រោះជាអាសន្ន ។

## ពិធីបុណ្យចំរើនព្រះជន្មាយុ

សម្ដេចព្រះមហាសុមេធាធិបតី (ជួន - ណាត ជោតញ្ញាណោ)
សង្ឃនាយកគណៈមហានិកាយ ក្នុងព្រះជន្មាយុគំរប់ ៧៧ ឆ្នាំ ។

កាលពីថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ១០-១១ រោច ខែផល្គុណ ឆ្នាំជូត ទោស័ក ព.ស. ២៥០៣ (១១-១២ មីនា ១៩៦១) ក្រុមសិស្សានុសិស្ស ទាំងបព្វជិតទាំងគ្រហស្ថ បានប្រជុំគ្នាធ្វើពិធីបុណ្យចំរើនព្រះជន្មវស្សា ប្រ-គេនសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ក្រោម

BIBLIOTHEQUE
EC. Fr.
D'EXTREME ORIENT

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

*ផ្នែកសាសនា* ទំព័រ

- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ២៣៧
- ព្រះនិព្វាន ឬនិព្វាណ លោកកុម្ម៉ង់ដង់ រូបែរត៍ រៀបរៀង ក្រមការ ជុំ-មៅ ប្រែ . ២៤៧
- ព្រះអភិធម្មបិដក គម្ពីរព្រះកថាវត្ថុ (តមក) លោក ប៊ូ-ប៊ូ រៀបរៀង . . . ២៥៨
- ចតុរសភិហិណី(ត)សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែ ព្រះញ.ញាណ–ឈឹន ពិនិត្យ ២៦៩
- មហោសថជាតក(ត):លោកអ៊ុម-ភនចម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-ត្វូរពិនិត្យ . ២៧៦

*ផ្នែកអក្សរសាស្ត្រ*

- វប្បធម៌ខ្មែរ (តមក) លោក លី-ធាមតេង រៀបរៀង . . . ២៨៤
- ពាក្យខ្មែរប្រតិបរទេស ដោយគណៈកម្មការវប្បធម៌ . . . . . . . . ២៩០
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ២៩១
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . ២៩២
- រឿងព្រេងទាក់ទងដោយការស្ថាបនាប្រាសាទអង្គរ (ត) លោក ញ៉ែម-ទឹម រៀបរៀង . ៣០៤
- រឿងព្រេងប្រទេសចិន ចែងអំពីបញ្ញាដិតនិងដើមពារ ភិក្ខុ ម៉ែន-វៀម ប្រែ . . ៣១៦
- រង្វើ១ ធ្វើឲ្យបាត់តោអស់ លោកញូក-សឿង រៀបរៀង . . . . , ៣២២
- អធិប្បាយសុភាសិត លោក ញ៉ែម-ទឹម រៀបរៀង . . ; , , . . ៣៣២

*ផ្នែកកំណត់ទិនប្បវត្តិការណ៍*

- មហាសន្និបាត នៃពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋលើកទី ៩ . . . . . . ៣៣៨
- ពិធីសម្ពោធបើកការអប់រំវិជ្ជាគរុកោសល្យ . . . . . . . . . . . ៣៤៧

មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជាវ ២៣០៛០០

33e Année — No 3 — Mars 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire

### Partie religieuse

Pages

— La Vie du Buddha (suite) par Vèn - *PANG KHAT* . . . . 237
— Le Nirvana par le Commandant *ROBERT* . . . . . . . . 247
— Prah Abhidhammapitaka, Kampi de Preâh Kathavathu (suite) par *M. BOU - PO* . . . . . 258
— Madhurasavahini (suite) par Samdech Preah Dhammalikhita *LOUIS - EM*, revu et corrigé par Vèn. *NHÉAN - CHHOEUN* . . . . 269
— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM - PHON*, revu et corrigé par Vèn. *KEM - TO* . . . . 276

### Partie littéraire

— La Culture Khmère (suite) par *M. LY - THEAM - TENG* . . 284
— Activités de la Commission Culturelle . . . . . . . . . . . . . . . 290
— Dictionnaire Sanscrit-Khmèr (suite) par Vèn. *PANG-KHAT* . . 291
— Histoire de Sam-Kok (suite) traduite par Oknha *NOU - KAN* . . . . . . . 292
— La Fondation d'Angkor d'après une légende khmère par *M. NHEM - KHEM* . . . . . 304
— Le bonze et le poirier (Contes et légendes de Chine) traduite par le bonze *MEN - RIEM* . . . . 316
— La disparition des bœufs (Conte khmère) d'après *M. NHOUNG - SŒUNG* . . . . 322
— Commentaire d'un proverbe par *M. NHEM - KHEM* . . . . . 332

### Notes et chroniques

— Le 9ème Congrès de l'Association des Bouddhistes Centre du Cambodge . . . 338
— Fête d'inauguration des Cours de pédagogie . . . . . . . . . . 347

Prix d'abonnement annuel (comprenant 12 numéros): 23o|oo

# ពរសព្ទសាធុការក្នុងឱកាសចូលឆ្នាំថ្មី

ក្នុងឱកាសចូលឆ្នាំឆ្លូវត្រីស័ក ជាឆ្នាំថ្មីនៃពុទ្ធសករាជ ២៥០៤ នេះ, ក្រុមពុទ្ធសាសនបណ្ឌិត្យ សូមបួងសួងចំពោះគុណព្រះរតនត្រ័យ និងវត្ថុសក្តិសិទ្ធិក្នុងលោក មានទេវតារក្សាស្វេតច្ឆត្រ, និងព្រះកែវមរកតនៃប្រទេសកម្ពុជាជាដើម ព្រមទាំងទេវតាព្រះនាម គិរិណីទេវី ដែលរក្សាឆ្នាំថ្មីនេះ សូមប្រសិទ្ធិពរថ្វាយ-ប្រគេន-ជូនចំពោះ៖

–សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត, សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ជាទីស្នេហាស្មើដោយជីវិត នៃប្រជាពលរដ្ឋខ្មែរ ព្រមទាំងព្រះរាជវង្សានុវង្ស សូមទ្រង់បានប្រកបដោយព្រះជោគជ័យសិរីមង្គលមហាប្រសើរ, ព្រះវឌ្ឍនភាព, ព្រះសុខមាលភាព និងព្រះជន្មាយុយឺនយូរអស់កាលជាអង្វែង ។

–សម្តេចក្រុមព្រះ ប្រធាន និងសមាជិក ក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ព្រមទាំងគ្រួសារ ។

–សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ព្រមទាំងព្រះសង្ឃគ្រប់វត្តអារាមក្នុងប្រទេសកម្ពុជា ។

–សមាជិកព្រះរាជរដ្ឋាភិបាល ព្រមទាំងគ្រួសារ ។

ប្រធាននិងសមាជិកសភាទាំងពីរ ព្រមទាំងគ្រួសារ ។

–អ្នករាជការគ្រប់ជាន់ថ្នាក់ ទាហាន-ស៊ីវិល ព្រមទាំងគ្រួសារ ។

–ប្រជាពលរដ្ឋ ពាណិជ្ជករ, កសិករ, កម្មករ ក្នុងព្រះរាជាណាចក្រទាំងមូល ព្រមទាំងគ្រួសារ ។

សូមបានប្រកបដោយសិរីសួស្តី និងជោគជ័យសេចក្តីសុខចំរើន គ្រប់ប្រការកុំបីឃ្លាត ។

ផ្នែកសាសនា

## ពុទ្ធជីវប្បវត្តិ

ព្រះមហា ប៉ាន់-ខាត់ រៀបរៀង

(តមក)

## ៦- ទ្រង់ជាកូនមាន់ច្បង

*ព្រះភគវាទ្រង់បានឃើញពន្ធ័មុនជានមនុស្ស ទេវតា មារ ព្រហ្ម ដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះវេរញ្ជព្រាហ្មណ៍ថា*(១)

ម្នាលព្រាហ្មណ៍! ប្រៀបដូចស៊ុតមាន់ទាំង ៨ ក្តី ១០ ក្តី ១២ ក្តី ស៊ុតមាន់ទាំងនោះ គឺមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់ក្តៅដោយប្រពៃហើយ ឲ្យជាប់ក្លិនវាជាមេដោយប្រពៃហើយ បណ្តាកូនមាន់ទាំងនោះ កូនមាន់ណាទំលាយសំបកស៊ុតដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលមុនគេបំផុត បើដូច្នេះតើ អ្នកផងគួរហៅកូនមាន់នោះថាកូនច្បងឬកូនពៅ? ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតមដ៏ចំរើន កូនមាន់នោះ គេគួរហៅថា កូនច្បង ព្រោះវាជាកូនបងគេបំផុត ។

---

១- មហាវិភង្គ វេរញ្ជកណ្ឌ សៀវ. ១ ទំព័រ ១១ ។

ម្នាលព្រាហ្មណ៍! កាលបើពពួកសត្វ ដូចស៊ុតមាន់កើតហើយ មានអវិជ្ជាសេចក្តីល្ងង់ ដូចជាសំបកស៊ុតកំពុងរួបរឹតក្នុងលោក មានតែតថាគតម្នាក់ឯង ដែលទំលាយសំបកស៊ុតគឺអវិជ្ជា ហើយត្រាស់ដឹងខ្លួនឯង ដោយប្រពៃនូវសម្មាសម្ពោធិញាណ ដែលមិនមានគុណជាតិឯទៀតប្រសើរជាងឡើយ ។ ម្នាលព្រាហ្មណ៍! តថាគតជាចម្បង ជាបុគ្គលប្រសើរបំផុតជាងសត្វលោក, ម្នាលព្រាហ្មណ៍! ព្យាយាមតថាគត បានតាំងផ្តើមហើយ មិនបន្ធូរបន្ថយ ទាំងស្មារតីតថាគត ក៏ប្រុងមិនឲ្យភ្លាត់ កាយសោតក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏នឹងល្អ ជាចិត្តមានអារម្មណ៍តែមួយ ។

ម្នាលព្រាហ្មណ៍! តថាគតស្ងាត់ចាកកាមទាំងឡាយ ចាកកុសលទាំងឡាយ ចូលបឋមជ្ឈានប្រកបដោយវិតក្កៈវិចារៈ បីតិ សុខៈ ដែលកើតពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍, ចូលដល់ទុតិយជ្ឈាន ជាទីផូរផង់ ញ៉ាំងចិត្តជាសមាធិឲ្យកើតឡើងមានតែបីតិនិងសុខៈ លះបង់បីតិៈបេញហើយ ចូលដល់តតិយជ្ឈានជាបុគ្គលមានចិត្តព្រងើយ នៅជាសុខ, លះបង់សុខផង

លះបង់ទុក្ខផង រំលត់នូវសោមនស្សនឹងទោមនស្សអំពីមុនផង តថាគតចូលដល់ចតុត្ថជ្ឈាន មិនមានទុក្ខ មិនមានសុខ មានតែសតិដ៏ស្អាតចំពោះត្រង់ឧបេក្ខា ។ កាលចិត្តបរិសុទ្ធផូរផង់ មិនមានកិលេស មិនសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ តថាគត បានបង្អោនចិត្តចូលទៅក្នុងបុព្វេនិវាសានុស្សតិញ្ញាណ ។ តថាគតរលឹកជាតិជាអនេក រលឹកបាន ១ ជាតិ ២ ជាតិ ។ល។ ១ សែនជាតិ រលឹកច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្ប ដូចនេះថា តថាគតកើតក្នុងភពឯណោះ ឈ្មោះយ៉ាងនេះ គោត្រ សម្បុរ អាហារ ទទួលសុខទុក្ខយ៉ាងនេះ កំណត់អាយុប៉ុណ្ណោះ ច្យុតចាកអត្តភាពនោះ បានទៅកើតក្នុងភពឯណោះ...តថាគត រលឹកតាមនូវជាតិ ដែលអាស្រ័យនៅពីមុនបានច្រើនជាតិ ព្រមទាំងអាការទាំងឧទ្ទេសយ៉ាងនេះ ។ ម្នាលព្រាហ្មណ៍! នេះជាបឋមវិជ្ជា ដែលតថាគតបានត្រាស់ដឹងក្នុងបឋមយាមនៃរាត្រី អវិជ្ជាបាត់ទៅ វិជ្ជាកើតឡើង ងងឹតបាត់ទៅ ពន្លឺកើតឡើង ដល់តថាគតដែលកំពុងអង្គុយប្រុង

ស្មារតី មិនប្រហែសធ្វេស ដុតបំផ្លាញកិលេស មានចិត្តមូលស្លុង ដូចបណ្ឌិតទាំងឡាយដែលបានបឋមវិជ្ជាដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍! នេះជាបឋមវិជ្ជា ដែលតថាគតបានត្រាស់ដឹង ដូចជាកូនមាន់ឬងញាស់ចេញចាកសំបកស៊ុត ។

ម្នាលព្រាហ្មណ៍! កាលចិត្តបរិសុទ្ធផូរផង់ មិនមានកិលេសប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រ យ៉ាងនេះហើយ តថាគតទើបបង្អោនចិត្តចូលទៅក្នុងញាណ ដែលនាំឲ្យត្រាស់ដឹងនូវចុតិនិងបដិសន្ធិនៃសត្វទាំងឡាយ ។ តថាគតពិចារណាមើលនូវសត្វទាំងឡាយ ដែលច្បុតនឹងចាប់បដិសន្ធិទាបថោក ឧត្ដម ល្អ អាក្រក់ ទៅកាន់សុគតិ ទុគ្គតិ ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធក្រៃលែង ជាងចក្ខុរបស់មនុស្សសាមញ្ញ ឃើញច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមយថាកម្មថា "អើហ្ន៎! សត្វទាំងនេះ ប្រព្រឹត្តអាក្រក់ ដោយកាយវាចាចិត្ត ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិ និយាយតិះដៀលអរិយបុគ្គលទាំងឡាយ សត្វទាំងនោះ លុះរំលាងខន្ធទៅ បន្ទាប់ពី

មរណៈ ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ មួយសោត អើហ្ន៎! សត្វទាំងនេះ ប្រព្រឹត្តល្អដោយកាយវាចាចិត្ត ជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ មិនតិះដៀលអរិយបុគ្គលទាំងឡាយ សត្វទាំងនោះ លុះរំលាងខន្ធទៅ បន្ទាប់ពីមរណៈ ទៅកើតឯសុគតិ ។ ម្នាលព្រាហ្មណ៍! នេះជាវិជ្ជាទី ២ ដែលតថាគតបានត្រាស់ដឹង ក្នុងមជ្ឈិមយាមនៃរាត្រី អវិជ្ជាបាត់ទៅ វិជ្ជាកើតឡើង ងងឹតបាត់ទៅ ពន្លឺកើតឡើង ដល់តថាគតដែលកំពុងប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្លុង ដូចបណ្ឌិតទាំងឡាយដែលបាននូវវិជ្ជាទី ២ ដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍! នេះជាវិជ្ជាទី ២ ដែលតថាគត បានត្រាស់ដឹង ដូចជាកូនមាន់ដែលញាស់ចេញចាកសំបកស៊ុត ។

ម្នាលព្រាហ្មណ៍! កាលចិត្តបរិសុទ្ធផូរផង់ មិនមានកិលេសមិនមានសេចក្តីសៅហ្មង ជាចិត្តទន់គួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រយ៉ាងនេះហើយ តថាគត ទើបបង្អោនចិត្តបំពោះទៅក្នុងញាណ ជាហេតុនាំឲ្យអស់ទៅ នៃអាសវៈ

ទាំងឡាយ (អាសវក្ខយញ្ញាណ) តថាគតដឹងប្រាកដតាមពិតថា នេះទុក្ខ នេះជាហេតុនាំឲ្យកើតទុក្ខ នេះសេចក្ដីរលត់ទុក្ខ នេះឧបាយឲ្យបានដល់នូវសេចក្ដីរលត់ទុក្ខ ធម៌ប៉ុណ្ណេះជាអាសវៈ ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ នេះសេចក្ដីរលត់នៃអាសវៈ នេះជាឧបាយឲ្យបានដល់នូវសេចក្ដីរលត់ទៅនៃអាសវៈ កាលតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តតថាគត ក៏ផុតចាកអាសវៈ គឺកាមផង ភពផង អវិជ្ជាផង លុះចិត្តតថាគតរួចផុតស្រឡះហើយ ប្រាជ្ញាកើតដល់តថាគតថា រួចផុតស្រឡះចាកអាសវធម៌ហើយ កំណើតអស់ហើយ ព្រហ្មចរិយធម៌បានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចបានធ្វើស្រេចហើយ មិនមានកិច្ចដទៃក្រៅពីសោឡសកិច្ចទៀតឡើយ ។ ម្នាលព្រាហ្មណ៍ ! នេះជាវិជ្ជាទី ៣ ដែលតថាគតបានត្រាស់ដឹងក្នុងបច្ឆិមយាមនៃរាត្រី អវិជ្ជាបាត់ទៅ វិជ្ជាកើតឡើង ងងឹតបាត់ទៅពន្លឺកើតឡើង ដល់តថាគតដែលកំពុងប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមុលស្លុងដូចបណ្ឌិតទាំងឡាយដែលបានវិជ្ជាទី ៣ ដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍

ការត្រាស់ដឹងរបស់តថាគតគម្រប់ ៣ នេះ ដូចគ្នានឹងការញាស់របស់កូនមាន់ប្លុងអំពីសំបកស៊ុត ។

## ៧- ទ្រង់ជាបុគ្គលខ្ពស់ផុត

*ព្រះភគវាទ្រង់ហាំនពោលអំពីគុណធម៌របស់ព្រះអង្គ ដែលឥតមានបុគ្គលណាមួយស្មើបាន ដូចពុទ្ធភាសិតដែលត្រាស់ចំពោះអចេលកស្សបថា(១) ។*

ម្នាលកស្សប ! សមណព្រាហ្មណ៍ពួកមួយ ជាសីលវាទ (ពោលអំពីសីលខ្លួន) សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរគុណរបស់សីលដោយអនេកបរិយាយ ។ ម្នាលកស្សប ! បើទុកជាអរិយសីលដ៏ក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញបុគ្គលណាត្រឹមស្មើតថាគតក្នុងអរិយសីលនោះទេ, ក្រៃលែងជាងមកពីណាបាន ! តថាគតជាអ្នកក្រៃលែងក្នុងគុណគឺអធិសីលនោះដោយពិត ។

ម្នាលកស្សប ! សមណព្រាហ្មណ៍ពួកមួយ ជាតបោជិគុច្ឆវាទ (ពោលអំពីការខ្ពើមកិលេស ) សមណព្រាហ្មណ៍ទាំងនោះ

---

១- មហាសីហនាទសូត្រ សីហនាទវគ្គ សៀវ. ១៥ ទំព័រ ១១២ ។

តែងសរសើរគុណនៃការខ្ពើមកិលេសដោយតបៈ ជាអនេកបរិយាយ ។ ម្នាលកស្សប! បើទុកជាការខ្ពើមកិលេសដោយតបៈដ៏ប្រសើរក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញបុគ្គលណាត្រឹមស្មើនឹងការខ្ពើមកិលេសរបស់តថាគតក្នុងតបៈនោះទេ, ក្រៃលែងជាងមកពីណាបាន? តថាគតជាអ្នកក្រៃលែងក្នុងគុណគឺការខ្ពើមកិលេសពិត, ។

ម្នាលកស្សប! សមណព្រាហ្មណ៍ពួកមួយ ជាវិមុត្តិវាទ (ពោលអំពីវិមុត្តិ) សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរគុណរបស់វិមុត្តិដោយអនេកបរិយាយ។ម្នាលកស្សប!បើទុកជាវិមុត្តិដ៏ប្រសើរក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញមានបុគ្គលណាត្រឹមស្មើនឹងវិមុត្តិរបស់តថាគតក្នុងវិមុត្តិនោះទេ, ក្រៃលែងជាងមកពីណាបាន? តថាគតក្រៃលែងក្នុងគុណគឺអធិវិមុត្តិនោះដោយពិត។

## ៨- ទ្រង់ជាព្រះតថាគត

*ទ្រង់ព្រះនាមថា "តថាគត" ព្រោះព្រះអង្គបានត្រាស់ដឹង ហើយដូចព្រះតម្រាស់ដែលទ្រង់ត្រាស់បំពោះភិក្ខុទាំងឡាយថា*(១)

---

១- បឋមបណ្ណាសក ខុរវេលវគ្គ សៀ. ៤២ ទំព័រ ៥៣ ។

ម្នាលភិក្ខុទាំងឡាយ! លោកគឺទុក្ខសច្ច តថាគតត្រាស់ដឹងហើយ តថាគតផុតចាកលោកគឺទុក្ខសច្ចហើយ, លោកសមុទយៈ គឺទុក្ខសមុទ័យ តថាគតបានត្រាស់ដឹងហើយ លះបង់ហើយ, លោកនិរោធ គឺទុក្ខនិរោធ តថាគតត្រាស់ដឹងហើយ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ, លោកនិរោធគាមិនីបដិបទា គឺទុក្ខនិរោធគាមិនីបដិបទា តថាគតបានត្រាស់ដឹងហើយ តថាគត បានចំរើនស្រេចហើយ ។

ម្នាលភិក្ខុទាំងឡាយ! អារម្មណ៍ណា ដែលលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោកដែលពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាតិ ជាសម្មតិទេព និងមនុស្សដ៏សេសឃើញឮពាល់ត្រូវ ដឹងច្បាស់ បានដើរស្វែងរកត្រាប់រង្គាត់រក អារម្មណ៍នោះ តថាគតបានដឹងជាក់ស្ដែងដោយសារចិត្ត ព្រោះហេតុនោះ បានជាគេហៅថា "តថាគត",

ម្នាលភិក្ខុទាំងឡាយ! តថាគតបានត្រាស់ដឹងក្នុងរាត្រីណា បរិនិព្វានក្នុងរាត្រីណា តែងពោលបរបា សំដែងបេញ

នូវវាចាណា ក្នុងបន្ទោះនោះ កិច្ចមានការត្រាស់ដឹងជាដើមទាំងនោះ ដូច្នោះមែន មិនមែនជាមិនមែនទេ ព្រោះហេតុនោះបានជាគេហៅថា "តថាគត",

ម្នាលភិក្ខុទាំងឡាយ! តថាគត ថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ហេតុនោះ ទើបបានជាគេហៅថា "តថាគត",

ម្នាលភិក្ខុទាំងឡាយ! តថាគត ជាអ្នកគ្របសង្កត់ អង់អាច ជាអ្នកឃើញពិត មានអំណាចគ្របសង្កត់លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេពនឹងមនុស្សដ៏សេសបាន ហេតុនោះទើបគេហៅថា "តថាគត" ។

( នៅមានត )

## ព្រះនិព្វាន ឬ និព្វាណ

## លោក កុម្មង់ដង់ រ៉ូបែរត៍ រៀបរៀង

ក្រមការ ជុំ-ម៉ៅ ប្រែជាភាសាខ្មែរ

(តមក)

---

គម្ពីរទីឃនិកាយសំដែងថា រូបអង្គតថាគតនៅប្រព្រឹត្តទៅជាធម្មតា ពិតមែនតែសេចក្ដីប្រាថ្នាក្នុងភពថ្មីនោះបានកាច់បំបាក់ចោលស្រឡះ, រូបអង្គតថាគតនៅប្រព្រឹត្តទៅដរាបណា មនុស្សនឹងទេវតាទាំងឡាយក៏នៅឃើញតថាគតដរាបនោះ; វេលាណាតែរូបអង្គតថាគត ប្រែក្លាយទៅហើយ មនុស្សព្រមទាំងទេវតាក៏លែងបានឃើញសោះឡើយ ។

មុននឹងឲ្យយោបល់បញ្ចប់សេចក្ដីនេះ យើងត្រូវត្រឡប់មកនិយាយអំពីនិព្វាន ដែលបានសម្រេចតាំងពីកាលរូបរស់នៅជាមុននិព្វាននោះវិញ គឺថាក្នុងនិព្វានដែលសល់នៅខន្ធនេះ ព្រះអរហន្តលោកសោយសុខ ក្នុងព្រះនិព្វានដែលលោកបានដល់នោះ ប៉ុន្តែសោយតែក្នុងពេលដែលលោកកំពុងផ្ចង់ឈានប៉ុណ្ណោះទេ វេលាដែលលោកចេញពីឈានសមាបត្តិមកវិញ លោកនៅចាំទាំងអស់ ប៉ុន្តែសេចក្ដីដែលលោកបានប្រទះឃើញ ឬដែលបានប៉ះពាល់ទាំងប៉ុន្មាននោះ នឹងយកមកប្រែស្រាយជាភាសាសម្រាប់មនុស្សថាដូច្នេះដូច្នោះមិនកើត ព្រោះគ្មានពាក្យសម្រាប់មនុស្សលោកនឹងនិយាយឲ្យចំ ។

មានពាក្យបុច្ឆាក្នុងគម្ពីរទិដ្ឋធម្មនិព្វានថា ដើម្បីនឹងឲ្យបានដល់នូវព្រះនិព្វាននោះត្រូវធ្វើដូចម្ដេច? វិសជ្ជនាថា: ដើម្បីឲ្យបាននូវព្រះនិព្វាននោះត្រូវចំរើននូវរូបជ្ឈាន ៤ អរូបជ្ឈាន ៤ ដែលហៅថា សមាបត្តិទាំង ៨ ប្រការនឹងឈានថ្នាក់បំផុត ១ ទៀតដែលហៅថា សញ្ញាវេទយិតនិរោធ ហើយដែលជាឈានផ្ទាល់នឹងគួព្រះនិព្វាន កាលណាតែបានធ្វើឈានទាំងប៉ុន្មាននេះហើយ អ្នកដែលធ្វើឈានក៏បានដល់នូវព្រះអរហត្ត ហើយបានទីជាព្រះអរហន្តក្នុងវេលានោះ ។

ឯឈានទាំងប៉ុន្មាននេះ របៀបដូចជាសេចក្ដីហាត់តម្រង់នៅសន្ទុះឬកំឡាំងចិត្តរបស់មនុស្ស, ឯកំឡាំងសន្ទុះរបស់ចិត្តនោះ អាចនឹងក្លាឡើងបាន ឬថយទៅវិញនោះ មកតែពីការព្យាយាមហាត់ ឬដោយធ្វេសប្រហែសបោះបង់ចោលប៉ុណ្ណោះ; មានគួរនាដូចជាគេហាត់កីឡាយកកំឡាំងពលំដោយក្បួនខាគដូចេ្នាះដែរ; គឺថាបើព្យាយាមហាត់កាល ១ ថ្ងៃទៅ នឹងមានកំឡាំងពលំច្រើនឡើង ហើយបើធ្វេសបោះបង់ចោលទៅវិញនោះ កំឡាំងក៏ដុនថយទៅវិញ ។

ក្នុងមហាទស្សនសុត្ត មានសំដែងអំពីឈានទាំង ៤ ថ្នាក់ខាងដើម គឺព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងប្រាប់ព្រះមហាអានន្ទថា ដើម្បីនឹងឲ្យបានដល់បឋមជ្ឈានឬឈានថ្នាក់ទី ១ នោះ ត្រូវតាំងសមាធិលះបង់នូវចិត្តអាក្រក់ គឺនីវរណទាំង ៥ ចោលទាំងអស់ ហើយចំរើននូវសមាសតិ

គឺសេចក្ដីរំឭកត្រូវឬគំនិតត្រង់ ដូចមានសំដែងក្នុងអដ្ឋង្គិកមគ្គ គឺផ្លូវប្រកបដោយអង្គ ៨ នោះឯង; ធ្វើដូច្នេះនឹងបានដល់នូវបឋមជ្ឈាន គឺសុខៈ សេចក្ដីស្រួលកាយស្រួលចិត្ត; បីតិ សេចក្ដីឆ្អែតកាយឆ្អែតចិត្ត; ឯកគ្គតា ការបានតាំងចិត្តនឹងនៅក្នុងអារម្មណ៍តែ ១; វិតក្កៈ សេចក្ដីរំពឹងគិតពិចារណា; វិចារៈ ការញុំាងចិត្តឲ្យជាប់នៅក្នុងអារម្មណ៍ ។

ចំរើនតពីនេះទៅទៀត ត្រូវលះបង់សេចក្ដីរំពឹង (វិតក្កៈ) ការញុំាងចិត្តឲ្យនៅក្នុងអារម្មណ៍ (វិចារៈ) ចេញ; នឹងបានដល់នូវទុតិយជ្ឈាន គឺសុខៈ សេចក្ដីស្រួលកាយស្រួលចិត្ត; បីតិ សេចក្ដីឆ្អែតកាយឆ្អែតចិត្ត ដែលកើតឡើងដោយសេចក្ដីភ្លឺច្បាស់ គឺសេចក្ដីមូលអារម្មណ៍ នឹងសេចក្ដីដែលមានចិត្តស្ទុះខ្ពស់ឡើង ។

លុះលះបង់នូវសេចក្ដីត្រេកក្នុងបីតិ គឺសេចក្ដីឆ្អែតកាយឆ្អែតចិត្តនេះចេញហើយ ព្រះយោគាវចរតាំងនៅក្នុងសេចក្ដីព្រងើយកន្តើយ សោយអារម្មណ៍ជាសុខធ្វើជាម្ចាស់ចិត្តបាន ហើយក៏ដល់ទៅថ្នាក់ឈានទី ៣ ឬតតិយជ្ឈាន គឺសេចក្ដីដែលពេញចិត្តរីករាយឥតរវើរវាយ ។

លុះវៀរចាកនូវសេចក្ដីស្រួលចិត្តគឺសុខចេញ ហើយលះបង់នូវសេចក្ដីឈឺចាប់គឺទុក្ខចោល មិនត្រេកអរនឹងសុខ មិនទោមនស្សនឹងទុក្ខ, ព្រះយោគាវចរក៏បានដល់ទៅឈានថ្នាក់ទី ៤ ឬចតុត្ថជ្ឈាន គឺសេចក្ដី

ដែលឈ្មោះចិត្តឬជាម្ចាស់ចិត្តរបស់ខ្លួនដោយពិតប្រាកដ នឹងជាសេចក្ដីដែលក្លៀវក្លាពិតប្រាកដ ។

អារម្មណ៍ទាំងប៉ុន្មាន ដែលជាប់ជួនទៅជាមួយនឹងឈានទាំង ៤ ថ្នាក់ខាងដើម ដែលព្រះយោគាវចរបានចំរើននោះ បានឈ្មោះហៅថាអារម្មណ៍ ៤ គ្មានទីបំផុត ឬអប្បមាណារម្មណ៍ ។ អារម្មណ៍ទាំងនេះជាឥស្សរភាព ក្នុងកិរិយាប្រព្រឹត្តទៅជាប្រក្រតី របស់ព្រះយោគាវចរដែលទៅកាន់ព្រះនិព្វាន ។

ឯសម្មាសមាធិ គឺការនាដ៏ប្រពៃនោះ ជាមែកទី ៨ នៃអដ្ឋង្គិកមគ្គនោះឯង ។

ឯថ្នាក់ឈានគតិនេះទៅទៀតនោះ នាំព្រះយោគាវចរដែលធ្វើឈានឲ្យបានដល់ទៅអរូបគត ។ ឈាននោះត្រូវចំរើននូវអាកាសទទេមិនចេះផុត គឺអាកាសានញ្ចាយតនៈ; ចិត្តមិនចេះផុតគឺវិញ្ញាណញ្ចាយតនៈ; សេចក្ដីដែលមិនមាននៅសល់អ្វីទាំងអស់ គឺអកិញ្ចញ្ញាយតនៈ, សភាពដែលមានវិញ្ញាណជាកណ្ដាលនៃសេចក្ដីកត់សំគាល់ គឺនេវសញ្ញានាសញ្ញាយតនៈ, ឯថ្នាក់ចុងបំផុតនោះ គឺសមាធិបំបាត់នូវសញ្ញានឹងវេទនា គឺជាវលត់នូវសេចក្ដីដែលដឹង ក្នុងវេលានោះហើយ ដែលព្រះយោគាវចរបានដល់នូវព្រះអរហត្ត គឺបានសម្រេចនូវព្រះនិព្វាន ។

ត្រូវសំគាល់ថា កិរិយាដែលហាត់ធ្វើឈានថ្នាក់ដំបូងនោះ មិនមែន

BIBLIOTHEQUE P.P. D'EXTREME ORIENT

ហាត់បានហើយ នាំឲ្យបានឈានថ្នាក់បំផុតតាំងប៉ុន្មាននោះទៀតឡើយ ។ គម្ពីរព្រះអភិធម្មមានសំដែងដោយជាក់ច្បាស់ណាស់ អំពីរឿងនេះ គឺថា ការដែលនឹងធ្វើឈានតាំងប៉ុន្មានខាងក្រោយនោះបាន មានតែអ្នកបួសប៉ុណ្ណោះទេ ទើបអាចនឹងធ្វើបាន, ឯយកវសេទោះបីបានហាត់ធ្វើឈានថ្នាក់ខាងដើមតាំងប៉ុន្មានឲ្យស្ទាត់ដូចម្តេចក៏ដោយ គង់មិនអាចនឹងចំរើននូវអាកាសានញ្ចាយតនៈ ឬវិញ្ញាណញ្ចាយតនៈ ។ល។ បានដែរ ។

គួរយើងចាំទុកថា ព្រះអរហន្តដែលចូលឈាននោះ មិនមែនជាការដែលខ្វិននៅនឹងស្លុកឥតវិញ្ញាណឥតស្មារតី ដូចជាអ្នកតែងសៀវភៅពុទ្ធសាសនាជាតិអឺរ៉ុប គេធ្លាប់ជឿមកនោះឡើយ, ព្រោះគម្ពីរព្រះអភិធម្មមានសំដែងថា ព្រះអរហន្តមានញាណយ៉ាងខ្ពស់មួយ ដោយអំណាចកិរិយាដែលបានឃើញច្បាស់ឥតទើសទាល់ ដែលហៅថាវិបស្សនាញាណនោះឯង ។

គម្ពីរនព្វាតិលោកមានសំដែងថា អ្នកឯណាដែលបានលះបង់នូវនីវរណធម៌ចោល បានឈ្មោះថាជាអ្នកត្រិះរិះដ៏ប្រពៃ ។

សេចក្តីដែលឈ្នះនូវចិត្តដោយដាច់ខាត សេចក្តីដែលបានសម្រេចព្រះអរហត្តនោះហើយ ជាគោលបំផុតរបស់ឈាន ។

សេចក្តីត្រង់នេះមានពាក្យចោទ ១ ដែលត្រូវចោទសួរ ហើយពាក្យចោទនេះបើទោះបីមិនមែនរកមិនឃើញ ក៏លំបាកនឹងឆ្លើយឲ្យចំ ដូចជា

ពាក្យដែលថានិព្វាននោះដែរ ប៉ុន្តែសេចក្តីវិសជ្ជនាក្នុងកន្លែងនេះ នាំឲ្យយើញផ្លូវជាក់ច្បាស់ទៅក្នុងនិព្វាន ឯពាក្យចោទនោះថា "អ្វីដែលចូលនិព្វានទៅវេលាក្រោយទំលាយខន្ធទៅ? " ៗ

សេចក្តីត្រង់នេះយើងមិនអាចនឹងហ៊ានថា: យើងឆ្លើយត្រូវឡើយ, ដោយហេតុសេចក្តីនេះ មានពាក្យដដែកមិនដាច់ស្រេចតាំងអំពីកើតព្រះពុទ្ធសាសនាម្ល៉េះ; មានសេចក្តីជឿងឆ្ងល់នោះក៏ច្រើន ហើយមានសេចក្តីដែលគេបានវិនិច្ឆ័យក៏ច្រើន ៗ ចំណែកយើងៗគ្រាន់តែយកសេចក្តីវិនិច្ឆ័យទាំងនោះខ្លះ ហើយស្រង់យកសេចក្តីផ្សេងៗ ដោយអាងដល់គម្ពីរខ្លះដែលត្រឹមត្រូវនោះ មកធៀបគ្នា ៗ ចំណែកអ្នកទាំងឡាយពល់គ្នាមានឯកចិត្តរៀងខ្លួននឹងជឿថាដូចម្តេច ១ ហើយនឹងបង្កើតគំនិតថ្មី ១ បាន តាមដែលខ្លួនយល់ឃើញថាគួរ ៗ

ធាតុទាំងឡាយផ្សេង ១ ជានាមធម៌ ដែលគេបានជឿមកថា មានដោយពិត នឹងសេចក្តីដែលផ្លាស់ប្តូរជាតិ ពីជាតិមួយទៅជាតិមួយ ព្រមទាំងផ្លូវដែលចូលទៅនិព្វាន គឺធាតុដែលសល់នៅជាខាងក្រោយពេលដែលស្លាប់នោះ ជាធាតុដែលមានតាំងអំពីដើមរៀងមក មានឈ្មោះដូចមានខាងក្រោមនេះ៖

ពាក្យថា អាត្មង ខ្មែរធ្លាប់ហៅថាអាត្មា ជួនកាលគេប្រែថា

ព្រលឹង ប៉ុន្តែក្នុងវេលានេះយើងយកសព្ទដែលសម្រាប់ប្រើក្នុងសាសនា ដែលគេធ្លាប់ប្រើក្នុងប្រទេសអឺរ៉ុបនោះមកនិយាយដូចតទៅនេះ ៖

គម្ពីរក្នុងពុទ្ធសាសនាមិនទទួលស្គាល់ មិនជឿថាមានអាត្មនទៀយ; ត្រង់នេះមានបុច្ឆាថា ចុះហេតុអ្វីបានជាព្រះសព្វញ្ញូពុទ្ធមិនព្រមទទួលឆ្លើយ អំពីការដែលលោកថាទៀងឬមិនទៀង ឬមួយក៏គេសំគាល់ថាលោកនោះ ហើយជាអាត្មន ? ឬជាខ្លួនប្រាណ ? ។ ដូច្នេះ បើជាគ្មានអាត្មន យើង មិនបាច់និយាយអំពីលោកនោះដែរ គឺថាលោកនោះក៏គ្មានដូចគ្នា ។

ពាក្យថាវិញ្ញាណដែលគេតែងប្រែថាសេចក្តីដឹង ឬប្រាជ្ញានោះ តាម ដោយគម្ពីរផ្សេង ៗ ក្នុងពុទ្ធសាសនាថាវិញ្ញាណនេះហើយ ជាមគ្គនាយក នៃកិរិយាផ្លាស់ជាតិមួយទៅជាតិមួយ (សំយុត្តនិកាយ) ក្នុងមួយជាតិ ៗ របស់មនុស្សនោះ វិញ្ញាណនេះឯងជាខន្ធមួយ ដោយធាតុឯទៀតផ្សេង ៗ ចូលផង គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ ដែលធ្វើឲ្យយើង កាន់ប្រឡំថាមានខ្លួនប្រាណ ដែលវិញ្ញាណនេះបណ្តាលមកពីសញ្ញាខន្ធ វេទនាខន្ធ នឹងសង្ខារក្ខន្ធ វិញ្ញាណឯងបានត្រួតបញ្ជាក់ម្តងទៀត ។ ដូច្នេះ ឃើញថាហាក់ដូចជាវិញ្ញាណនេះជាឥស្សរភាព ក្នុងប្រជុំធាតុទាំងឡាយ របស់មនុស្ស ។ រឿងឃោធិកកិក្កុដែលមានសំដែងក្នុងគម្ពីរទីឃនិកាយ មានសេចក្តីថា ខ្លួនខ្ញុំជារូបដែលអាស្រ័យដោយប្រជុំនៃធាតុ ៤, កើតឡើង ដោយមាតានឹងបិតា, រស់នៅដោយអាហារ ហើយមានធម្មតាឬមានជាតិ

ត្រូវតែរលាយទៅវិញ; ឯវិញ្ញាណរបស់ខ្ញុំ ដែលមកជាប់នៅជាមួយនោះ នៅជាប់នឹងខ្លួនទាំងនោះ ។

មានសេចក្តីមួយដែលព្រះសម្មាសម្ពុទ្ធ សំដែងប្រាប់ព្រះធម្មមហាអានន្ទ ក្នុងគម្ពីរទីឃនិកាយច្បាស់លាស់ណាស់, គឺព្រះអង្គទ្រង់សួរមហាអានន្ទថា "ម្នាលអានន្ទ! ប្រសិនបើវិញ្ញាណ មិនបានចូលទៅក្នុងគភ៌នៃមាតា តើនាមនិងរូបអាចតាក់តែងនៅក្នុងគភ៌នៃមាតាដែរឬទេ ?" ព្រះមហាអានន្ទឆ្លើយថា "នាមនិងរូប មិនអាចតាក់តែងនៅក្នុងគភ៌បានឡើយ" ។ ព្រះសព្វញ្ញុទ្រង់សួរទៀតថា "ប្រសិនបើវិញ្ញាណនោះចូលទៅក្នុងផ្ទៃនៃមាតាហើយ លុះក្រោយមកក៏ចេញចាកបោះបង់ទីកន្លែងនោះវិញ បើដូច្នេះ តើនាមនិងរូបអាចកើតឡើងបានឬមិនបាន ?" ព្រះមហាអានន្ទឆ្លើយទូលតបវិញថា "កើតមិនបានទេ" ។ វេលានោះព្រះបរមគ្រូទ្រង់សួរតទៅទៀតថា "ចុះប្រសិនបើវិញ្ញាណដែលមានក្នុងកុមារកុមារីនោះ បោះបង់ទីកន្លែងចោលចេញ តើនាមរូបនោះប្រព្រឹត្តទៅបានឬទេ ?" មហាអានន្ទឆ្លើយតបទៀតថា "ប្រព្រឹត្តទៅមិនបានទេព្រះអង្គ" ។

គម្ពីរដែលនេះសំដែងថា វិញ្ញាណនោះគឺធម្មជាតិដែលគ្មានចំនួន គ្មានទីបំផុត ដែលជាពន្លឺទូទៅ គឺធម្មជាតិដែលមិនមែនទឹក មិនមែនដី មិនមែនភ្លើង មិនមែនខ្យល់ និងថាធំក៏មិនបាន តូចក៏មិនបាន

ទ្រាយក៏មិនបាន ខ្ទាំងក៏មិនបាន ល្អក៏មិនបាន អាក្រក់ក៏មិនបាន គឺថាជាធម្មជាតិដែលកើតលេតជាមួយគ្នានឹងនាមរូប ។ ប៉ុន្តែបើនាមនិងរូបប្រាស្រ័យនឹងវិញ្ញាណ វិញ្ញាណក៏ប្រាស្រ័យនឹងនាមរូបដែរ ។

ព្រះបរមសាស្តាត្រាស់ទ្រង់សួរមហាអានន្ទថា “ម្នាលអានន្ទ! ប្រសិនបើវិញ្ញាណលែងពឹងពាក់អាស្រ័យនឹងនាមរូប តើជាតិ ជរា ព្យាធិ មរណៈ ដែលជាហេតុដើមរបស់ទុក្ខ នឹងនៅមានតទៅទៀតដែរឬអ្វី? ។

មហាអានន្ទឆ្លើយតបវិញថា “ជាតិ, ជរា, ព្យាធិ, និងមរណៈ មិនមានទៀតឡើយ ។ ព្រះបរមសាស្តាទ្រង់បញ្ជាក់ថា: បើដូច្នេះ ម្នាលអានន្ទ នេះហើយជាហេតុ នេះហើយជាគូ នេះហើយជាដើមចម នេះហើយជាគោលរបស់វិញ្ញាណ គឺនាមនឹងរូបនេះឯង ។

មានពុទ្ធបរិស័ទ ១ អង្គឈ្មោះ សាតិ ជឿថាវិញ្ញាណរបស់មនុស្សសព្វថ្ងៃនេះ ជាវិញ្ញាណដែលជាប់តគ្នាមកពីវិញ្ញាណកាលពីជាតិមុន ។ ។ គម្ពីរមជ្ឈិមនិកាយសំដែងថា សេចក្តីជឿនេះជាសេចក្តីជឿខុសស្រឡះ ។

មានគម្ពីរខ្លះក្នុងពុទ្ធសាសនា ដូចយ៉ាងគម្ពីរមជ្ឈិមនិកាយនឹងអភិធម្មកោស សំដែងថាវិញ្ញាណនោះបណ្តាលមកអំពីគន្ធរូប ដែលជាធម្មជាតិល្អិតក្រៃលែង ចេញមកពីខ្លួនមនុស្សម្នាក់ ដែលទៅបដិសន្ធិក្នុងគភ៌ថ្មី ប៉ុន្តែកន្លែងត្រង់នេះមិនបានសំដែងឲ្យច្បាស់ឡើយ ។

មានធាតុម្យ៉ាងទៀតដែលហៅថាសត្ត; ជួនកាលគេហៅថា ជាធម្មជាតិដែលទៀងជានិច្ចរបស់អត្តភាព, ប៉ុន្តែឯសត្តនេះក៏មិនប្លែកពីអាត្មន មិនប្លែកពីជីវៈ មិនប្លែកពីបុគ្គលឡើយ គឺជាឈ្មោះទាំងប៉ុន្មាននេះ សំដៅទៅលើអត្តភាពតែ ១ ប៉ុណ្ណោះ ប៉ុន្តែគម្ពីរទាំងអស់មិនបានសំដែងឲ្យជាការដាច់ស្រេចសោះ ។

ក្នុងគម្ពីរអភិធម្មកោសសំដែងថា ព្រះនាគសេនត្ថេរលោកពោលថា ធម្មជាតិដែលរស់នៅឬជីវៈនោះគ្មានទេ ហើយបើគ្មានដូច្នេះ ឲ្យថាជីវៈនោះមានសណ្ឋានដូចជារូប ឬប្លែកគ្នាពីរូបដូចម្តេចបាន? ។

ដូច្នេះឃើញថា បើជាជាតិកំណើតរបស់មនុស្សនិមួយ ៗ អាស្រ័យដោយអំពើ ឬកម្មរបស់ខ្លួនតាំងពីជាតិមុន ៗ មកនោះ ក៏គ្មានធម្មជាតិណាមួយដែលចេញផ្លាស់ពីជាតិមុន ៗ នោះឡើយ គឺថាបុគ្គលដែលបានសោយនូវផលកម្មក្នុងមួយជាតិ ៗ នោះ មិនមែនជាតួបុគ្គលដែលបានធ្វើកម្មនោះឡើយ ប៉ុន្តែបុគ្គលនោះមិនមែនជាបុគ្គលដទៃទេ គឺជាធម្មជាតិដែលទាក់ទងត ៗ គ្នា ។

ឯវិញ្ញាណនឹងធាតុឯទៀតនោះ សុទ្ធតែជារបស់បណ្តោះអាសន្នទាំងអស់ ប៉ុន្តែធាតុទាំងប៉ុន្មាននេះហើយដែលប្រាស្រ័យគ្នានឹងធាតុផ្សេងៗអំពីជាតិមុន ៗ រលកនៅក្នុងសមុទ្រនោះមិនមែនកើតដោយទឹកដែលផ្លាស់កន្លែងឡើយ គឺកើតអំពីអាការដែលទឹកកម្រើកជូនតគ្នាទៅ ឯទឹកនោះ

ឥតមានផ្លាស់កន្លែងឡើយ នៅតែកន្លែងដដែលដូចពីដើម ។ ជាតិរបស់មនុស្សវិញក៏មានសណ្ឋានដូចគ្នាដែរ គឺជាអាការដែលកម្រើកជួនគា ។ គ្នានោះឯង ឥតមានអ្វីជិតជាប់ទៅជាមួយអាការនោះឡើយ សេចក្តីនេះឃើញថាជាការលំបាកនឹងនិយាយឲ្យស្រឡះ អំពីសេចក្តីទាក់ទងនៃភពពីមួយទៅមួយ លំបាកនឹងគិតអំពីចំណោទខាងក្រោយនេះណាស់ គឺចំណោទដែលថាទថា តើធាតុអ្វីដែលចូលទៅក្នុងនិព្វាននោះ ត្រង់នេះយើងមានសេចក្តីដែលយើងមិនស្គាល់ ២ យ៉ាង នៅចំពោះមុខយើង គឺធាតុដែលចូលទៅកាន់និព្វាននោះ ១ តួព្រះនិព្វាន ១ សេចក្តីទាំង ២ នេះយើងមិនបានស្គាល់ទាំងអស់ ។

អំពីនិព្វានរបស់ព្រះអរហន្ត ដែលហៅថា សឧបាទិសេសនិព្វាន ឬនិព្វាននៅឧបាទិនោះ យើងបានដឹងថាព្រះអរហន្តលោកនៅមានអាយតនៈទាំងអស់ នៅមានប្រាជ្ញាមានវិញ្ញាណដែលសំអិតសំអាងដោយផ្ចិតផ្ចង់ ហើយម្យ៉ាងទៀតព្រះអរហន្ត លោកមានទាំងអានុភាពយ៉ាងខ្ពង់ខ្ពស់ផង ប៉ុន្តែលុះព្រះអរហន្តលោកចូលទៅកាន់ព្រះនិព្វានដែលគ្មានឧបាទិ ឬអនុបាទិសេសនិព្វាននោះ តើដូចម្តេចទៅវិញ ត្រង់នេះគម្ពីរសំយុត្តនិកាយមានសំដែងសេចក្តី ២ បទដូចមានខាងក្រោយ ។

(នៅមានត)

# ព្រះអភិធម្មបិដក

# គម្ពីរព្រះកថាវត្ថុ

លោកប៊ូ - ប៉ូ ប្រែរៀបរៀង

## អនេញ្ញគាថា

(តមក)

ឯការប្រាប់, ពន្យល់, បង្រៀន, សំដែងនូវព្រះពុទ្ធវចនៈឲ្យអ្នកដទៃបានយល់, បានចេះដឹងនោះ ចាត់ជាធម្មទានគឺការឲ្យធម៌ជាទាន ។

ធម្មទាននេះ មានផលានិសង្សវិសេសវិសាលណាស់ ដូចព្រះពុទ្ធភាសិតថា សព្វទានំ ធម្មទានំ ជិនាតិ ឲ្យទានធម៌ (មានផល) ឈ្នះទានទាំងអស់ ។ បើបុគ្គលណាមានទ្រព្យសម្បត្តិច្រើន ហើយជាអ្នកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានបរិច្ចាគចីវរ, បិណ្ឌបាត, សេនាសនៈ នឹងគិលានភេសជ្ជៈ គ្រប់បច្ច័យទាំងបួន ដ៏ច្រើនក្រៃលែង ហើយសុទ្ធតែថ្លៃថ្លាបំផុត ប្រគេនព្រះអរិយសង្ឃ មានព្រះពុទ្ធអង្គជាប្រធាន ដែលគង់ពេញផ្ទៃចក្រវាឡទាំងអស់ អ្នកនោះបានទទួលផលានិសង្ស នៃចតុប្បច្ច័យទាននេះជាច្រើនអនេកអនន្ត ។ ប៉ុន្តែ បើយកផលនៃអាមិសទាននេះមកប្រៀបផ្ទឹម ចំនឹងផលនៃធម្មទានតែមួយគាថាវិញ ឃើញថាផលអាមិសទានខាងដើមនោះ មិនស្មើនឹងផលនៃធម្មទានតែមួយចម្រៀកគំរប់ ១៦ ចុងបំផុត ដែលយកមួយចម្រៀកមកចែកជា ១៦

បម្រៀកទៀត ព្រោះធម្មទានជាបច្ច័យឲ្យកើតបញ្ញាល្អប្រពៃ អាចចេះដឹងក្នុងផ្លូវនៃព្រះត្រៃបិដករហូតដល់បានសម្រេចព្រះអរហត្ត បែកធ្លាយក្នុងបដិសម្ភិទាទាំងបួនទៀតផង ។

ប្រការមួយទៀត អ្នកចារឬសរសេរកត់ត្រាព្រះពុទ្ធវចនៈ ដោយលាយល័ក្ខណ៍អក្សរ ក៏រាប់ចូលក្នុងធម្មទាន ព្រោះការកត់ត្រាព្រះពុទ្ធវចនៈនោះ ទុកជាគម្ពីរក្បួនច្បាប់សម្រាប់ឲ្យមនុស្សទាំងពួង អ្នកចង់ចេះដឹងបានអាន, បានឃើញ នៅស្ថិតស្ថេរជាអង្វែងតទៅមុខ ។ ទោះអ្នកសំដែង, បង្រៀន, ចារ, សរសេរព្រះពុទ្ធវចនៈដោយខ្លួនឯងក្ដី ពឹងឬជួលអ្នកផងឲ្យសំដែង, ឲ្យបង្រៀន, ឲ្យចារសរសេរព្រះពុទ្ធវចនៈក្ដី ក៏លោកចាត់ជាធម្មទានមានផលដូចគ្នា ។

សកវាទី ចុះពួកមនុស្សបុថុជ្ជនស្ថិតនៅក្នុងអនេញ្ជធម៌ គឺមិនញាប់ញ័រដោយតណ្ហាមានៈទិដ្ឋិខ្លះដែរឬទេ ?

បរវាទី– ពួកមនុស្សបុថុជ្ជនមិនស្ថិតនៅក្នុងអនេញ្ជធម៌ទេ ព្រោះមានចិត្តញាប់ញ័រដោយ តណ្ហា មានៈ ទិដ្ឋិ ជាប្រាកដ ។ តណ្ហា, មានៈ នឹង ទិដ្ឋិ ទាំង ៣ នេះហៅថា ឥញ្ជិតធម៌ ប្រែថាធម៌ធ្វើចិត្តឲ្យញាប់ញ័រ ។ ចិត្តរបស់បុថុជ្ជនមានតណ្ហា, មានះនឹងទិដ្ឋិ ពេញបរិបូណ៌ ។ ប៉ុន្តែ បើបុថុជ្ជនណាៗស្វាហាប់សង្កត់សង្កិនលះបង់តណ្ហាមានះ ឬទិដ្ឋិចេញពីសន្តាន

បុថុជ្ជននោះក៏អាចសង្កត់សង្កិនលះបង់បានមួយក្អែក, មួយពេល, មួយខណៈប៉ុណ្ណោះ លះមិនដាច់ជ្រះស្រឡះទេ នៅមានតណ្ហា មានះទិដ្ឋិដដែល, ប៉ុន្តែ នឹងរលោះថយតិចខ្លះ ដោយអំណាចកម្លាំងខំព្យាយាមសង្កត់សង្កិន លះកាត់ជាញឹកញាប់ ៗ បុថុជ្ជនដែលព្យាយាមសង្កត់សង្កិនតណ្ហា មានះ ឬទិដ្ឋិ បានឃាត់ពីសន្តានមួយខណៈ ៗ នោះ មានឈ្មោះមួយជាន់ទៀតថាជាកល្យាណបុថុជ្ជន គឺបុថុជ្ជនល្អ ឬគួរពេញចិត្តបាន, ហៅម្យ៉ាងទៀតថា សាធុជនក៏បាន, ថាសប្បុរសក៏បាន ៗ កល្យាណបុថុជ្ជននេះហើយ ដែលត ទៅមុខនឹងក្លាយខ្លួនទៅជាអរិយជន ៗ សូម្បីបាននាមថាជាកល្យាណបុថុជ្ជនដូច្នេះហើយ ក៏នៅតែលោកមិនរាប់ថាជាអ្នកស្អិតនៅក្នុងអនេញ្ជធម៌ដែរ ព្រោះមិនបានលះបង់តណ្ហា មានះទិដ្ឋិឲ្យដាច់ជ្រះស្រឡះពីសន្តាន គ្រាន់តែសង្កត់សង្កិនបានមួយខណៈ ៗ ប៉ុណ្ណោះ ដូចជាគេយកដុំថ្មសង្កត់ស្មៅ ៗ

សកក់ទី - ចុះតណ្ហា, មានះ នឹងទិដ្ឋិទាំង ៣ នេះ តើឲ្យទោសយ៉ាងណា បានជាលោកខ្លាចខ្លាំងម្ល៉េះ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម តែងទូន្មានឲ្យបុថុជ្ជនខំព្យាយាមលះបង់ចេញ ?

បរក់ទី - តណ្ហាសេចក្តីប្រាថ្នាបង់បាន ៗ បើបុគ្គលណាបណ្តោយឲ្យចិត្តចង់បានកាន់តែច្រើន កាន់តែធំឡើង ៗ មិនអត់សង្កត់ មិនទប់ទល់

មិនបន្ថយឲ្យស្រកស្រុតខ្លះទេ បុគ្គលនោះឈ្មោះថា ជាអ្នកមានតណ្ហាច្រើន ៗ អ្នកមានតណ្ហាច្រើនហួសប្រមាណ តែងបានទទួលទុក្ខទោស សោក-ភ័យ សេចក្ដីវិនាសជាច្រើនប្រការ ដូចមានព្រះពុទ្ធភាសិតថា: តណ្ហាយ ជាយតេ សោកោ ជាដើម សេចក្ដីសោកកើតមកអំពីតណ្ហា សេចក្ដីទុក្ខភ័យកើតមកអំពីតណ្ហា បើបុគ្គលណាអស់តណ្ហាហើយ បុគ្គលនោះលែងមានសោក លែងមានទុក្ខភ័យទៀតឡើយ ៗ អ្នកមានតណ្ហាច្រើនលើសលុបនោះ មិនមែនត្រឹមតែធ្វើខ្លួនឲ្យវិនាសដល់ទៅក្ស័យជីវិតប៉ុណ្ណោះទេ សូម្បីតែនៅរស់ ក៏នាំឲ្យបែកបាក់ព្រាត់ប្រាសពីញាតិសន្ដានពីមិត្រសំឡាញ់ដែរ ដោយហោចទៅគ្រាន់តែចិត្តអៀនខ្មាសក៏គ្មានផង ព្រោះគិតតែចង់បានខ្លាំងពេក ទាល់តែភ្លេចខ្មាសគេអស់រលីង ដូចមានអតីតនិទានក្នុងព្រះសូត្រសំដែងឲ្យឃើញជាតំរូវថា ៖

អតីតេ កាលេ ក្នុងកាលកន្លងទៅហើយ ព្រះពុទ្ធជាម្ចាស់នៃយើងកាលសោយព្រះជាតិជាពោធិសត្វនៅឡើយ បានកើតក្នុងត្រកូលព្រះមហាក្សត្រ ៗ លុះចំណេរក្រោយមក ព្រះវររាជបិតាទ្រង់ទិវង្គតទៅ ព្រះរាជកុមារជាព្រះជេដ្ឋាប្រគល់រាជសម្បត្តិ ឲ្យព្រះបរមពោធិសត្វជាព្រះកនិដ្ឋាគ្រប់គ្រង ហើយចេញពីព្រះនគរទៅគង់នៅបច្ចន្តគ្រាមចុងស្រុកមួយ ប៉ុន្តែក្នុងអាណាខេត្តដែននៃព្រះរាជកនិដ្ឋានោះដែរ ៗ ពួកមហា-

ជនក្នុងស្រុកនោះបានដឹងស្គាល់ថាជាព្រះរាជបុត្រនៃព្រះមហាក្សត្រ ក៏នាំគ្នាគោរពប្រតិបត្តិស្រឡាញ់រាប់អានបម្រើឥតធុញទ្រាន់. យូរបន្តិចទៅទូលព្រះរាជជេដ្ឋា ឲ្យផ្ញើសារទៅសុំព្រះរាជទ្រព្យពីព្រះមហាក្សត្រ ជាព្រះកនិដ្ឋា ។ ក៏ព្រមថ្វាយព្រះរាជទ្រព្យទៅព្រះជេដ្ឋាតាមសុំ ។ ក្រោយមកទៀត ពួកមហាជនក្នុងស្រុកនោះទូលពន្យល់ព្រះជេដ្ឋា ឲ្យផ្ញើសារទៅសុំស្រុកមួយទៀត ព្រះរាជាក៏ព្រមថ្វាយ ។ មិនយូរប៉ុន្មាន អ្នកស្រុកទូលពន្យល់ព្រះជេដ្ឋាសុំស្រុក, សុំនិគម, សុំជនបទ រហូតដល់សុំទីសេនាបតី សុំទីឧបរាជ ។ ព្រះមហាក្សត្រជាព្រះកនិដ្ឋាធិរាជ ក៏ព្រមថ្វាយគ្រប់មុខតាមសុំ មិនឲ្យទើសទាល់អធ្យាស្រ័យនៃព្រះជេដ្ឋាឡើយ ។

អបរភាគេ ចំណេរក្រោយមក មិនជាយូរប៉ុន្មាន ព្រះជេដ្ឋាធិរាជដែលបានទីជាមហាឧបរាជហើយ ក៏មានតណ្ហាកាន់តែចំរើនច្រើនឡើងតាមវេលា, បើទុកជាបានទីមហាឧបរាជហើយ ក៏នៅតែមិនទាន់ល្មមព្រះទ័យ ប្រាថ្នាឲ្យបានរាជសម្បត្តិទៀត ទើបលើកសេនារេហ៍ពលទៅចោមព័ទ្ធព្រះនគរនៃព្រះរាជកនិដ្ឋា ហើយផ្ញើសារទៅថ្វាយថា សុំរាជសម្បត្តិបើមិនព្រមឲ្យទេ នឹងច្បាំងគ្នា ។

ព្រះកនិដ្ឋាធិរាជបានទ្រង់ជ្រាបសេចក្តីសារហើយ កើតព្រះទ័យសង្វេគតក់ស្លុតថា ឱហ្ន៎! ព្រះជេដ្ឋារបស់អញ ដើមដំបូងមិនព្រម

ទទួលរាជសម្បត្តិពីព្រះវររាជបិតា លើកប្រគល់ឲ្យអញហើយចេញទៅគង់នៅចុងកាត់មាត់ញក ដើម្បីឲ្យបានស្ងប់ស្ងាត់ព្រះទ័យ មិនដូច្នោះបែរជាទៅជឿស្តាប់ពាក្យសំដីរបស់ពួកមនុស្សអ្នកលោភយសសក្តិ ប្រាក់មាសទៅវិញ គេទូលឲ្យសុំអ្វី ៗ ពីអញចេះតែសុំតាមតាំងអស់ តាំងពីសុំរបស់តូច ៗ រហូតដល់របស់ធំ ៗ អញក៏ចេះតែថ្វាយគ្រប់មុខមិនទទឹងឥឡូវលើកទ័ពមកប្រុងនឹងច្បាំងដណ្តើមយករាជសម្បត្តិពីអញទៀត បើអញច្បាំងក៏អាចយកជ័យជំនះបានដែរ ប៉ុន្តែ ខ្លួនអញខូចខាតជេដ្ឋាបចាយនធម៌ គឺសេចក្តីគោរពកោតក្រែងចំពោះព្រះជេដ្ឋាធិរាជផង ធ្វើឲ្យអន្តរាយជីវិតមនុស្សជាច្រើនផង ព្រោះតែតណ្ហាជម្រុញអញឲ្យធ្វើសង្គ្រាម ។ គ្រានោះ ព្រះបរមពោធិសត្វ ឲ្យរាជបុរសទៅអញ្ជើញព្រះជេដ្ឋាធិរាជចូលមកក្នុងព្រះបរមរាជវាំងហើយ លើករាជសម្បត្តិថ្វាយឲ្យគ្រប់គ្រងតទៅរួចទ្រង់លាព្រះជេដ្ឋាស្តេចទៅគង់នៅព្រៃហិមពាន្ត សាងបណ្ណសាលាបួសជាតាបសចំរើនឈានជាសុខសម្រាន្តរៀងទៅ ។

ចំណែកមានះ គឺសេចក្តីប្រកាន់ខ្លួនប្រាណ លោកចាត់ជាឧបក្កិលេស តែងធ្វើចិត្តឲ្យសៅហ្មង ឲ្យញាប់ញ័រ ។ បើបុគ្គលណា ចេះតែសន្សំបណ្តុះបណ្តាលមានះឲ្យកើតមានច្រើនឡើងហើយ បុគ្គលនោះតែងមានទុក្ខទោស មានសេចក្តីវិនាសអន្តរាយជាច្រើនប្រការ តាំងពីខូច

ខាតរបស់បន្តិចបន្តួចរហូតដល់ខូចបង់ជីវិតខ្លួនជាទីបំផុត ដូចអតីតនិទាន នៃព្រះបរមវង្សសាក្យរាជ ជាព្រះញាតិរបស់ព្រះពុទ្ធជាម្ចាស់នៃយើង ព្រោះតែមានះប្រកាន់ខ្លួនថាមានជាតិ និងត្រកូលខ្ពង់ខ្ពស់ថ្លៃថ្នូរ បានជានៅវេលាដែលវិឌូឌភកុមារ ទៅគាល់ស្តេចមហានាមសាក្យរាជ ព្រះមហានាមប្រកាន់ព្រះអង្គថាមានជាតិមានត្រកូលខ្ពង់ខ្ពស់ជាសាក្យរាជ សំគាល់ថា វិឌូឌភកុមារនោះមានជាតិថោកទាប ជាបុត្ររបស់នាងវាសភខត្តិយទេវី ជាធីតារបស់នាងទាសី លុះដល់វិឌូឌភកុមារត្រឡប់ទៅវិញ ព្រះមហានាមសាក្យរាជ ប្រើឲ្យនាងទាសីលាងទីគង់របស់វិឌូឌភកុមារនឹងទឹកដោះ ៗ នាងទាសីនោះលាងបណ្តើរជេរបណ្តើរថា អញលាងក្តារជាកន្លែងអង្គុយរបស់វិឌូឌភកុមារ ជាបុត្រនៃនាងវាសភខត្តិយទេវី ជាធីតារបស់នាងទាសី ៗ ក្នុងពេលដែលនាងទាសីកំពុងតែជេរនោះ ជួនជាទាហានរបស់វិឌូឌភកុមារម្នាក់ភ្លេចអាវុធ ហើយវិលចូលទៅយកអាវុធរបស់ខ្លួនវិញ ស្រាប់តែបានឮសំដីនាងទាសី ជេរបណ្តើរលាងក្តារបណ្តើរ ទើបពាំនាំយកពាក្យនោះមកប្រាប់ដល់ទាហានទាំងពួង រឿងនោះល្បីសុះសាយពេញបន្ទាយ ទាល់តែលេចឮដល់វិឌូឌភកុមារ ៗ ត្រិះរិះថា ឥធំ ហោតុ ការដែលពួកសាក្យរាជលាងក្តារកន្លែងអញអង្គុយនឹងទឹកដោះនេះលើកទុកសិនចុះ ចាំដល់គ្រាអញបាន

សោយរាជសម្បត្តិហើយ អញនឹងត្រឡប់មកម្តងទៀត អញនឹងលាងក្តារដោយលោហិតបំពង់កនៃសាក្យរាជ គិតដូច្នេះហើយ ក៏ស្ងៀមទុកក្នុងហឫទ័យ ។ អបរភាគេ លុះចំណេរកាលក្រោយមក ព្រះវិឌូឌភរាជកុមារនោះ បានសោយរាជសម្បត្តិហើយ ក៏លើកកងទ័ពទៅធ្វើសង្គ្រាមនឹងស្តេចសាក្យរាជ ប្រាប់ឲ្យពួកយោធាចាប់សាក្យរាជទាំងឡាយសាកសួរ បើសាក្យរាជអង្គណាប្រាប់ថាយើងជាសាក្យរាជ ក៏បង្គាប់ឲ្យទាហានសម្លាប់សាក្យរាជអង្គនោះចោលទៅ ឋបេត្វា វៀរលែងតែពួកសាក្យរាជដែលនៅជិតព្រះមហានាមសាក្យរាជជាព្រះអយ្យកោ ។ មានសាក្យរាជអង្គខ្លះគិតទាន់ ចាប់យកដើមបបុះនឹងបាច់ស្មៅមកទុកនឹងខ្លួន ហើយប្រាប់ថានេះមិនមែនសាក្យរាជទេ នេះជាដើមបបុះ នេះជាបាច់ស្មៅ ។

ពួកយោធាឮដូច្នោះ ក៏មិនសម្លាប់សាក្យរាជទាំងពីពួកខាងដើមនេះ ចំណែកសាក្យរាជទាំងឡាយដទៃដែលឥតធ្វើឧបាយកលអ្វីសោះ ក៏ត្រូវយោធាចាប់សម្លាប់ចោលទាំងអស់ លុះសម្លាប់រួចហើយ បង្គាប់ឲ្យគ្រងយកឈាមបំពង់ករបស់សាក្យរាជទាំងអស់ ទៅលាងក្តារដែលព្រះបាទវិឌូឌភគង់ កាលពីព្រះកុមារនោះដូចសេចក្តីប្រាថ្នា ហើយឲ្យអញ្ជើញស្តេចមហានាមសាក្យរាជជាព្រះរាជអយ្យកោមក នឹងឲ្យសោយព្រះស្ងោយក្នុងព្រះសុវណ្ណភាជនៈជាមួយព្រះអង្គ ។

ស្ដេចមហានាមសាក្យរាជនោះ មានអស្មិមានៈជាខ្លាំងណាស់ត្រាស់ថា យើងនឹងទៅជម្រះសរីរកាយឲ្យស្អាតបាតសិន ចាំត្រឡប់មកវិញលុះយាងទៅដល់ឆ្នេរស្ទឹងគង្គា ចងផ្នួងព្រះកេសាឲ្យជាប់មាំ ហើយលោកចុះទៅក្នុងទឹក សិកម្រាមព្រះបាទក្នុងចំណងព្រះកេសា ដោយទ្រង់បំណងនឹងឲ្យអស់ព្រះជន្ម មិនព្រមសោយរួមជាមួយព្រះបាទវិឌូឌភៈជាកូនរបស់នាងកសកខត្តិយទេវីជាធីតារបស់នាងទាសី ។

នៅពេលដែលស្ដេចមហានាមសាក្យរាជ លោកចុះទៅក្នុងទឹកនោះស្ដេចនាគមកទទួលព្រះអង្គនឹងពាររបស់ខ្លួន ហើយនាំយកទៅទុកក្នុងពិភពនាគ ដោយហេតុនាគរាជគោរពក្នុងព្រះពុទ្ធគុណ ។

ម្យ៉ាងទៀត ដោយហេតុកុសលផលបុណ្យដែលស្ដេចមហានាមសាក្យរាជនោះ បានធ្វើទុកពីជាតិមុនមក ។

ចំណែកព្រះបាទវិឌូឌភៈនោះ កាលបើធ្វើសង្គ្រាមឈ្នះស្រេចហើយក៏លើកកងទ័ពត្រឡប់ទៅព្រះនគរវិញ ។

៦ទិដ្ឋិ គឺគំនិតគិតឃើញមាន ២ យ៉ាង បើគិតឃើញត្រូវតាមផ្លូវធម៌ ឬតាមក្រសែព្រះពុទ្ធដីកា ហៅថា សម្មាទិដ្ឋិ ។ នេះលោកមិនចាត់ជាឥញ្ចិតធម៌ គឺធម៌ធ្វើចិត្តឲ្យញាប់ញ័រទេ ។ បើគិតឃើញខុសពីគន្លងធម៌ ឬខុសពីព្រះពុទ្ធដីកា ហៅថា មិច្ឆាទិដ្ឋិ ។ នេះលោកចាត់ជាឥញ្ចិតធម៌ ប៉ុន្តែហៅកាត់ឲ្យខ្លីត្រឹមតែទិដ្ឋិប៉ុណ្ណោះ គឺលោកសំដៅយក មិច្ឆាទិដ្ឋិនោះឯង ។

បុគ្គលអ្នកមានគំនិតជាមិច្ឆាទិដ្ឋិ រមែងបានទទួលទុក្ខទោសផ្សេង ៗ តាំងពីស្រាល ៗ រហូតដល់ធ្ងន់បំផុតឃាត់សួគ៌ ឃាត់និព្វានដូចមានអតីតនិទានថា ឯកោ កិរ ឧបាសកោ បានឮថា មានឧបាសកម្នាក់ឈ្មោះមហារាបកឧបាសក ជាអ្នកបាននូវអនុលោមខន្តី ៗ ឧបាសកនោះខំប្រឹងបំពេញវិបស្សនាកម្មដ្ឋានខ្លាំងណាស់ ដើម្បីនឹងឲ្យបានសម្រេចព្រះសោតាឆាប់ ៗ លុះដល់មិនបានសម្រេចឲ្យទាន់តាមចិត្តប៉ុនប៉ង ក៏ត្រឡប់ជាយល់ឃើញខុសទៅវិញថា ព្រះពុទ្ធសាសនានេះមិនមែនជានិយ្យានិកោនាំសត្វចេញចាកវដ្តសង្សារទេ មានទិដ្ឋិឃើញវិបលាសដូច្នេះ លុះអស់ជីវិតហើយទៅកើតជាសត្វក្រពើយ៉ាងធំ ៗ នេះជាទោសនៃមិច្ឆាទិដ្ឋិដែលស្រាលល្មម ៗ

មានអតីតនិទានមួយទៀតថា សុនក្ខត្តលិច្ឆវី ចូលបួសក្នុងព្រះពុទ្ធ-សាសនាហើយបាននូវទិព្វចក្ខុ ខាងក្រោយមកលោកខំធ្វើបរិកម្មភាវនាដើម្បីឲ្យបាននូវទិព្វសោតញ្ញាណទៀត ប៉ុន្តែលោកប្រឹងបំពេញភាវនាអស់រយៈវេលា ៣ ឆ្នាំ ក៏នៅតែមិនបានសម្រេចដូចបំណងសោះ ទើបលោកកំណត់ក្នុងចិត្តថា ព្រះពុទ្ធអង្គបានតែទិព្វចក្ខុម្យ៉ាងប៉ុណ្ណោះ គ្មានទិព្វសោត-ញាណទេ យល់វិបលាសខុសដូច្នេះហើយ ក៏ហេសិក្ខាបទសឹកចេញពី

ព្រះពុទ្ធសាសនា ទៅចូលសិក្សាលទ្ធិនៃអន្យតិរ្ថិយ៍ពួកនិគ្រន្ថនាដបុត្រទៅវិញ ។ សុនក្ខត្តលិច្ឆវី លុះអស់ជីវិតហើយទៅកើតក្នុងនរកអស់កាលជាយូរអង្វែង ។ ជនទាំងឡាយដែលតាំងនៅក្នុងមិច្ឆាទិដ្ឋិនោះ បើលះបង់មិនបានទេ ក៏មានទោសឃាត់សួគ៌និងឃាត់និព្វាន ។

ហេតុនេះ បានជាព្រះអរហន្តមិនស្ថិតនៅក្នុងឥញ្ជិតធម៌ ១ ធ្វើចិត្តឲ្យញាប់ញ័រ គឺតណ្ហា មានៈ និងទិដ្ឋិ ដែលមានទោសដូចបានពណ៌នារួចមកហើយ ។

សំដែងមកក្នុងគម្ពីរព្រះកថាវត្ថុដោយសង្ខេបត្រឹមប៉ុណ្ណេះ ។ គម្ពីរព្រះកថាវត្ថុនេះ សម្ដេចព្រះមានព្រះភាគទេសនាដប់បី (១៣) វគ្គទើបចប់ គឺតជាព្រះធម្មក្ខន្ធប្រាំពីរពាន់មួយរយ (៧.១០០) ព្រះធម្មក្ខន្ធ, កាលទ្រង់សំដែងចប់ហើយ ទេវតាទាំងឡាយបានសម្រេចព្រះអរិយមគ្គព្រះអរិយផលបូករួមបានប្រាំពីរ (៧) កោដិដោយប្រមាណ ព្រះអាចារ្យកំណត់ទុកដូច្នេះ ។

ចប់ គម្ពីរព្រះកថាវត្ថុ តែប៉ុណ្ណោះ

---

( នៅមានត )

មធុរសវាហិណី

# សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ

( តមក )

---

បុរសកំសត់ក៏ញ៉ាំងចិត្តជ្រះថ្លាឲ្យកើតឡើងហើយពោលថា: ការឲ្យសំពត់នេះ សូមឲ្យសំរេចប្រយោជន៍ដល់អ្នក ដើម្បីប្រើប្រាស់ជាសុខសប្បាយចុះ ពោលយ៉ាងនេះហើយក៏ឲ្យសំពត់នោះដល់ចោរ ហើយលះបង់ចោលផ្លូវធំ វេះគេចដើរទៅតាមផ្លូវតូចដទៃល្មមដើរបានតែដើងមួយ សឹងចង្អៀតគាន់គាប់ដោយស្មៅជាដើម ហេតុតែសេចក្ដីភិតភ័យខ្លាចចោរ ព្រោះខ្លួនស្លៀកសំពត់ពីរជាន់នោះឯង ។ លុះបុរសនោះដើរតាមផ្លូវទៅ ក៏ប្រទះនឹងពស់វែកមួយពេននៅជិតផ្លូវ ពស់ពិចឹកបុរសនោះដកបដល់ក្សិណក្ស័យជីវិតទៅ បន្ទាប់ពីនោះ បានអន្ទោលទៅកើតជាទេវពជមួយអង្គមានស្ត្រីទេពអប្សរមួយពាន់ចោមរោមជាបរិវារ ស្ថិតនៅក្នុងវិមានមាសមានកំពស់ប្រមាណ ១២ យោជន៍ ក្នុងព្រៃហិមពាន្ត មានដើមកល្បព្រឹក្សដុះព័ទ្ធជុំវិញវិមានមាសនៃទេវបុត្រនោះ ក្នុងទីប្រមាណ ៣០ យោជន៍ សឹងប្រកបដោយសម្បត្តិទាំងពួងមានសំពត់ទិព្វជាដើម កើតឡើងដោយផលានិសង្សដែល ទេវបុត្រនោះនៅជាបុរសកំសត់ បានឲ្យទានសំពត់សាដកមួយដល់ចោរនោះឯង ។

ឯទេវបុត្រនោះសោត កាលបើបានសោយនូវទិព្វសម្បត្តិដ៏ប្រសើរយ៉ាងនេះហើយ ក៏ពោលនូវព្រះគាថាជាអាទិ៍ដូច្នេះថា: "បរិណាហិត មគ្គេន ធានស្ស សកាសព្ទតាំ" ជាដើម ។ អធិប្បាយថា ខ្ញុំបានឲ្យសំពត់ជារបស់ខ្លួនដល់ចោរគ្រាន់តែបង្អោនចិត្តឲ្យជាទានប៉ុណ្ណោះ សឹងមានឥស្សរិយយសដ៏ប្រសើរ មានវិមានផុសឡើងកំពស់ ១២ យោជន៍ ជាទីកំបាំងភ្នែក គឺបុគ្គលឃើញបានដោយក្រ សឹងប្រដាប់ដោយផ្ទះកំពូលដ៏ល្អប្រសើរមានពណ៌មាសសុទ្ធ បង្កើតឡើងដោយបុណ្យរបស់ខ្ញុំ មានប្រដាប់ដោយទង់ជាយទង់ជ្រុងដ៏ច្រើន ប្រកបដោយពិតានដ៏បរិសុទ្ធក្នុងព្រៃហិមពាន្តនោះឯង ។ ហើយមានសំពត់ទិព្វព្យួរសំយុងចុះ នៅចុងរងស្លាវនៃប្រាសាទដោយជុំវិញ នឹងសំយុងចុះមកក្រោមដេរដាសលើផែនដីល្អរុងរឿងក្រៃពេក ។

ម្យ៉ាងវិញទៀត ក្នុងទីបរិវេណប្រមាណ ៣ យោជន៍ដោយជុំវិញនៃប្រាសាទនោះ មានដើមកប្បព្រឹក្សជាច្រើនទៀតអាចឲ្យសម្រេចលទ្ធផលតាមតែចិត្តនឹក បើនឹកចង់បានវត្ថុណា ។ នឹងបាននូវវត្ថុនោះ ។ តាមប្រាថ្នាពិត ។

ឯខ្ញុំសឹងមានចិត្តរីករាយក្នុងគតរបស់ខ្ញុំ ដោយស្រីទេពអប្សរប្រមាណមួយពាន់ ចោមរោមបំរើដោយល្បែងរាំច្រៀងផ្គុំតន្ត្រីប្រគំភ្លេងគ្រឿងតន្ត្រីក្នុងវិមាននោះឯង ។

ផលដែលប្រាកដយ៉ាងនេះ មិនមែនជាផលដែលខំឲ្យទានសំពត់ដោយសទ្ធាល្អឡើយ គ្រាន់តែជាផលដែលបានឲ្យទានសំពត់ដល់ទោះមិនមែនជាស្រែបុណ្យល្អប៉ុណ្ណោះឯង ។ ប្រសិនបើបុគ្គលបានឲ្យទានដោយប្រណីតបញ្ចង់ ដល់បុគ្គលអ្នកមានសីលជាស្រែបុណ្យល្អហើយ នរណាមួយអាចនឹងពណ៌នាសរសើរ នូវផលានិសង្សរបស់បុគ្គលនោះបាន ។

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយ លោកពោលជាបទព្រះគាថាដូច្នេះថា :

ឯវំ វិធម្បិ កុសលំ មនុជោ ករិត្វា
បប្បោតិ និព្វិករំ មុនិវណ្ណនីយំ
មត្វាន យោ ធនាតិ ធានវរំ សុសីលេ
សទ្ធាយ សុទ្ធមនសា សវិសេសកាតិតិ

អធិប្បាយថា: សត្វដែលបានកើតជាមនុស្ស បានធ្វើនូវកុសលមានប្រការយ៉ាងនេះហើយ រមែងបានដល់នូវសម្បត្តិទិព្វដ៏ប្រសើរ គួរអ្នកប្រាជ្ញពណ៌នាសរសើរដោយពិត បុគ្គលណាបានដឹងផលយ៉ាងនេះហើយបានឲ្យទានដ៏ប្រសើរ ដល់បុគ្គលអ្នកមានសីលល្អបរិសុទ្ធ ដោយចិត្តដ៏ស្អាតដោយសទ្ធាជឿកម្មជឿផលឥតគម្រើក បុគ្គលនោះនឹងមានចំណែកសម្បត្តិទិព្វដ៏វិសេសក្នុងលោក អាចនឹងបាននូវសេចក្ដីសុខទាំង ៣ ប្រការគឺសុខមនុស្ស ១, សុខទេវតា ១, សុខក្នុងព្រះនិព្វាន ១ ដោយពិត ។

សំដែងរឿងនិទានអញ្ញតរបុរសមានឈ្មោះពុំប្រាកដ ជាគំរប់ពីរក្នុងវគ្គទីពីរ គឺចប់សេចក្ដីជាសង្ខេបតែប៉ុណ្ណេះឯងហោង ។

## វិសមលោមកុមារវត្ថុកថា

សំដែងរឿងនិទានវិសមលោមកុមារតទៅទៀត ដោយបាលីថា: អតីតេ កិរ ជម្ពូទីបេ ដូច្នេះជាដើម ។

អធិប្បាយថា: កិរ បានឮរៀង ៗ មក នាកាលអតីតកាលកន្លងរំលងទៅយូរណាស់ហើយ ក្នុងជម្ពូទ្វីបនេះ មានព្រះសម្មាសម្ពុទ្ធមួយព្រះអង្គទ្រង់ព្រះនាមកស្សបៈ ព្រះអង្គបានបំពេញព្រះបារមីពេញលេញបរិបូណ៌ហើយ បានដល់នូវសម្បត្តិសព្វញ្ញុតញ្ញាណ ជាអង្គព្រះសម្មាសម្ពុទ្ធត្រាស់ដឹងប្រាកដក្នុងលោក ព្រះអង្គតែងសំដែងធម៌បន្ទោបង់នូវកង្វល់ទុក្ខទាំងពួងរបស់សត្វលោក ព្រះអង្គនាំមកនូវសេចក្ដីសុខដល់សត្វលោក ហើយញ៉ាំងសត្វលោក ឲ្យស្ថិតនៅក្នុងគុណធម៌សម្រាប់ដល់នូវនគរគឺអមតមហានិព្វានដោយពិត ។

សម័យនោះ មានអញ្ញតរបុរសម្នាក់ បានស្ដាប់ធម៌ទេសនាហើយក៏មានចិត្តជ្រះថ្លាបានថ្វាយទានដល់ព្រះសង្ឃជាច្រើន បានរក្សាសីលប្រាំសីលប្រាំបី តែងប្រព្រឹត្តធ្វើនូវបុញ្ញកម្មទាំងឡាយផ្សេង ៗ ដរាបដល់អស់អាយុ ហើយបានទៅកើតក្នុងស្ថានទេវលោកដោយឆាប់រហ័ស បីដូចជា

ភ្ជាក់អំពីដេកលក់ដូច្នោះ សឹងមានស្រីទេពអប្សរមួយពាន់ចោមរោមជាបរិវារ ស្ថិតនៅក្នុងទិព្វវិមានដ៏សម្រេចដោយកែវ ៧ ប្រការ ជាសុខក្សេមក្សាន្ត ។ លុះស្ថិតនៅក្នុងស្ថានទេវលោកនោះ កំណត់អស់អាយុហើយច្យុតចុះមកអំពីស្ថានទេវលោកនោះ ក្នុងកាលព្រះមានព្រះភាគជាម្ចាស់នៃយើងព្រះអង្គចូលព្រះនិព្វានទៅហើយ បានមកកើតក្នុងផ្ទៃព្រះអគ្គមហេសីនៃព្រះនរិន្ទ្រាធិបតីធម្មាសោកកជ ជាស្ដេចចុល្លចក្ក សោយរាជ្យក្នុងនគរបាតលីបុត្តព្វដ៏ជម្ពូទ្វីបនេះឯង ។ ព្រះបាទធម្មាសោករាជ ព្រមទាំងព្រះរាជវង្សានុវង្ស បានសន្មតនាមព្រះរាជកុមារថា វិសមលោមកុមារ ព្រោះកុមារនោះ កាលកើតឡើងមានរោមក្រញាញ់ពុំស្មើ តែមានសម្បុររូបរាងល្អពន់ពេក គួរជាទីស្រឡាញ់ពេញចិត្តនៃជនទាំងពួង ។

លុះវិសមលោមកុមារនោះ បានដល់នូវការដឹងក្ដីចំរើនវ័យធំឡើងជាលំដាប់ហើយ សឹងបរិបូណ៌ដោយកម្លាំងកាយ វិសេសជាងជនទាំងឡាយនានា ដោយផលានិសង្សដែលកុមារបានឲ្យទានគោជនមានបាយទឹកជាដើម អំពីជាតិមុននោះឯង ។

ម្យ៉ាងទៀត កុមារនោះមានកម្លាំងច្រើន មានរូបល្អគួរជាទីជ្រះថ្លាដល់ប្រជុំជន ទាំងគួរដល់កិរិយាគយគន់មើលនៃជនទាំងឡាយ ហើយបរិបូណ៌ដោយបរិវារគាមហែហមគាល់បំរើជាច្រើន ។

លុះដល់សម័យមួយជាខាងក្រោយ សម្ដេចព្រះនរិន្ទ្រាធិបតី ធម្មា-

សោកកជ ដែលមានស្តេចប្រាំបីម៉ឺនបួនពាន់ព្រះអង្គ តាមកេមជាបរិវារ ព្រមទាំងពួកពលពាហនដ៏ច្រើន ព្រះអង្គប្រាថ្នាចង់ប្រពាតព្រៃក៏សាន្ត ព្រះទ័យ ហើយស្តេចយាងចេញទៅកាន់ព្រៃហិមពាន្ត ដើម្បីក្រសាល សប្បាយដោយសមគួរតាមអធ្យាស្រ័យហើយ លុះស្តេចត្រឡប់មកវិញបាន ដល់ស្ទឹងឈ្មោះចន្ទភាគា ឯស្ទឹងនោះសោត មានទទឹងមួយយោជន៍ មានជម្រៅបីគាវុតជាកំណត់ វេលានោះស្ទឹងនោះឯងសឹងមានខ្យល់បក់ មកខ្លាំង កើតជារលកទឹកបោកមកជួបនឹងច្រាំងទាំងសងខាង បែកពពុះ ទឹកដុំ ៗ មុខគួរខ្លាចពន់ពេក ហើយហូរទៅហស ។

កាលនោះ ព្រះបាទធម្មាសោកកជ ទ្រង់បានទតទៅឃើញស្ទឹង នោះហើយ ទ្រង់ត្រាស់សួរថា: បណ្តាបុរសក្នុងចំណោមនេះ មាន បុរសណាមួយ អាចហ៊ានហែលឆ្លងស្ទឹងធំមានសភាពយ៉ាងនេះដែរឬ ?

ឯបុរសទាំងឡាយក៏ពុំអាចនឹងហែលឆ្លងបានឡើយ មានតែវិសម-លោមកុមារម្នាក់ឯង បានស្តាប់ព្រះរាជឱង្ការត្រាស់សួរដូច្នោះហើយ ក៏ដើរ សសៀរចូលមកជិតលើកដៃឡើងប្រណម្យ ក្រាបបង្គំទូលថា: បពិត្រ ព្រះសម្មតិទេព ! ខ្ញុំព្រះករុណាថ្វាវិសេសអាចហ៊ានហែលឆ្លងស្ទឹងនេះ ទៅត្រើយខាងនាយ ហើយហែលត្រឡប់មកវិញបាន សូមព្រះអង្គ ទ្រង់ជ្រាប ។

លុះព្រះបរមក្សត្រិយ៍ ទ្រង់ព្រះសណ្តាប់ហើយក៏ទទួលព្រម ទ្រង់

ត្រាស់ថា សាធុប្រពៃហើយ ៗ បា ! ត្រូវអ្នកឯងហែលចូលចុះ យើងនឹងរង់ចាំមើលក្នុងទីនេះឯង ។

កាលនោះ វិសមលោមកុមារ បានទទួលព្រះរាជឱង្ការស្រេចហើយ ក៏ស្លៀកសំពត់កៀតយ៉ាងមាំចងសក់ឲ្យជាប់ ហើយឈរទៀបមាត់ប្រាំងក៏លោតឡើងទៅលើអាកាស កំពស់ ១៨ ហត្ថ ធ្លាក់ចុះទៅក្នុងស្ទឹងមានចម្ងាយអំពីមាត់ប្រាំងប្រមាណមួយឧសភ ហើយប្រាណត្រដើម្បីហែលចូលទៅ ។

លំដាប់ដែល វិសមលោមកុមារ ហែលកាត់ខ្សែទឹកដ៏កាចចូលទៅចូលមក សឹងមានក្រពើ ឆ្លាម-មករ កាចសាហាវទាំងឡាយ រវែលចេញតាមមក ដើម្បីចាំចាំនាំយកទៅ ជាចំណីអាហារ ៗ វិសមលោមកុមារក៏យកដៃប្រហារទះតប់ក្រពើឆ្លាម-មករទាំងឡាយឲ្យក្ស័យខ្ទេចខ្ទី ជាកំទេចតូច-ធំ ព្រមទាំងសម្លាប់សត្វដែលមានពិសអស់ជាច្រើនក៏បានត្រឡប់ឡើងមកកាន់ត្រើយខាងទីគោកវិញ ហើយចូលក្រាបថ្វាយបង្គំព្រះបរមក្សត្រ ឋិតនៅក្នុងទីដ៏សមគួរក្នុងកាលនោះឯង ។

(នៅមានត)

# លោក អ៊ុម-ភគ បម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស កិម - តូរ ពិនិត្យ

( តមក )

---

ភណា សេនកំ រុក្ខិ ៗ ព្រះបាទវិទេហរាជ មានព្រះបន្ទូលដណ្ដឹងអាចារ្យសេនកថា សេនក នៃអាចារ្យសេនកអើយ, រំអាចិ ប្រស្នាអញ តើអាចារ្យដឹងហើយឬនៅឡើយ, អាចារ្យសេនក ទូលថា បពិត្រព្រះមហារាជអើយ, បើអញខ្ញុំមិនដឹងហើយ តើនឹងមានអ្នកឯណាដទៃដឹងក្រៃលែងជាងខ្ញុំវិញ; ស្ដេចថា បើអាចារ្យដឹងដូច្នោះ ចូរឆ្លើយមកៗ ទើបអាចារ្យសេនកទូលថា ទេវ បពិត្រមហារាជអើយ, អញ្ជើញព្រះអង្គទ្រង់ព្រះសណ្ដាប់ ខ្ញុំនឹងឆ្លើយថ្វាយព្រះអង្គហោង ៗ ទើបអាចារ្យសេនកសូត្រនូវបទព្រះគាថា ដែលអាត្មាបានរៀនយកមកអំពីពោធិសត្វនោះថា :

ឱក្កបុត្តរាជបុត្តិយានំ
ឱរត្ភមំសំ ប៉ិយំ មជាបំ
ន តេ សុនខស្ស អទេត្តិ មំសំ
អថ មេណ្ឌស្ស សុនេន សំខ្យមស្សត្តិ ៗ

មហារាជ បពិត្រមហារាជអើយ, ឱរត្ភមំសំ វិសាច់ពពែ,

សាច់ព្រាយទាំងឡាយ, ពិរោះ មនោរំ ជាទីស្រឡាញ់គាប់ចិត្ត, ឧត្តមបុត្តរាជបុត្តិយោ នៃកូនព្រះរាជវង្សនិងកូនមន្ត្រីទាំងឡាយ, តេ ឧត្តមបុត្តរាជបុត្តី រកូនព្រះរាជវង្សនូវកូនមន្ត្រីទាំងឡាយនោះ, ន អទេន្តិ មិនដែលឆី, មំសំ នូវសាច់ សុនខស្ស នៃឆ្កែ; អថ បចដូច្នោះហោង, សាខ្យំ សេភាពជាមិត្ត មេណ្ឌស្ស នៃពពែ, សុនេន នូវឆ្កែនោះ, អស្ស ករេយ្យ គប្បីមានហោង ។

អាចារ្យសេនក សូម្បីសូត្រនូវគាថាអម្បាលនោះហើយក្តី ក៏មិនដឹង នូវរាបសេចក្តីនោះឡើយ ។ ព្រះមហាក្សត្រ ព្រះអង្គស្តាប់ពាក្យអាចារ្យ សេនកទូលឆ្លើយដោះសាអាថ៌ប្រស្នានូវប្រការអម្បាលនោះគួរ ស្តេចជ្រាប សុភាពដោយនូវហេតុហើយ ស្តេចដណ្តឹងទៅអាចារ្យបុក្កុសថា ហៃ អាចារ្យបុក្កុសអើយ, ប្រស្នានេះ អាចារ្យសេនកនេះដឹងហើយ, ចុះអាចារ្យ ឯងតើដឹងឬទេ? ។ អាចារ្យបុក្កុសទូលថា បពិត្រមហារាជអើយ, ខ្ញុំមិន ជាអ្នកប្រាជ្ញ ឬ ម្តេចព្រះអង្គ? ទើបអាចារ្យបុក្កុសសូត្រនូវគាថាដែល អាត្មាបានរៀនមកនោះថា :

ចម្មំ វិហនន្តិ ឯឡកស្ស
អស្សបិដ្ឋត្ថរណំ សុនខស្ស ហេតុ
ន តេ សុនខស្ស អស្សបិដ្ឋត្ថរណំ
អថ មេណ្ឌស្ស សុនេន សំខ្យស្សសក្កតិ ។

មហារាជ បពិត្រមហារាជអើយ, ជនា រីអ្នកផងទាំងឡាយ, វិហានន្តិ សម្លាប់, ឯឡកស្ស នូវពពែ, ចម្មំ យកស្បែក អស្សបិដ្ឋត្ថរណំ ប្រយោជន៍ជាកំរាលលើខ្នង, សុនខស្ស ហេតុ ព្រោះហេតុនៃឆ្កែ; តេ ជនា រីអ្នកផងទាំងឡាយនោះ, ន វិហានន្តិ មិនដែលសម្លាប់, សុនខស្ស នូវឆ្កែ, អស្សបិដ្ឋត្ថរណំ ដ៏ជាកំរាលខ្នងសេះ, អថ បទហេតុដូច្នោះ, សំខ្យំ រីសភាពជាមិត្ត, មេណ្ឌស្ស នៃពពែ, សុនខេន នូវឆ្កែ, អស្ស ករេយ្យ គប្បីមានហោង ៗ

ស្ដេចស្ដាប់ហើយ មានព្រះបន្ទូលដណ្ដឹងទៅអាចារ្យកាមិន្ទថា រីអាចារ្យបុក្កុសនេះដឹងហើយ, ចុះឯអាចារ្យឯង តើញុំងដឹងហើយឬនៅឡើយ ៗ រីអាចារ្យកាមិន្ទសូត្រនូវព្រះគាថាដូចអាត្មាបានរៀននោះថ្វាយព្រះមហាក្សត្រថា :

អាវេល្លិតសិង្គិកោ ហិ មេណ្ឌោ
ន ហិ សុនខស្ស វិសាណកានិ អត្ថិ
តិណភក្ខោ មំសភោជនោ ច
អថ មេណ្ឌស្ស សុនេន សំខ្យមស្សាតិ ៗ

មហារាជ បពិត្រមហារាជអើយ, មេណ្ឌោ រីពពែ, តិណភក្ខោ សឹងតែស្មៅ, សុនខោ រីឆ្កែ, មំសភោជនោ

មានសាច់ជាចំណី, អជ បទហេតុដូច្នោះ, សំខ្យំ សេភាពជាមិត្ត, មេណ្ឌស្ស នៃពពែ អស្ស- គវេយ្យ គប្បីមាន, សុណខេន ដោយក្តីនោះហោង ។

ស្តេចស្តាប់ពាក្យនោះហើយដណ្តឹងទៅអាចារ្យទេវិន្ទថា ហៃអាចារ្យទេវិន្ទអើយ, អាចារ្យកាមិន្ទនេះដឹងហើយ ចុះអាចារ្យឯង តើញុំាងដឹងហើយឬនៅឡើយ ។ អាចារ្យទេវិន្ទសូត្រនូវព្រះគាថាថ្វាយព្រះមហាក្សត្រ ដោយអាត្មាបានរៀននោះថា :

តិណមាសិ បលាសមាសិ មេណ្ឌោ
ច សុនោ តិណមាសិ នោ បលាសំ
គណ្ហេយ្យ សុណខោ សសំ វិឡារំ
អជ មេណ្ឌស្ស សុណេន សំខ្យមស្សាតិ ។

បពិត្រមហារាជអើយ, មេណ្ឌោ គឺពពែ, តិណមាសិ គឺស៊ីស្មៅ បលាសមាសិ គឺស៊ីឈើ, សុណខោ គឺឆ្កែ គណ្ហេយ្យ ចាប់យក សសំ នូវទន្សាយ វិឡារំ នូវឆ្មា, អជ បទដូច្នោះ, សំខ្យំ សេភាពជាមិត្ត មេណ្ឌស្ស នៃពពែ សុណខេន នូវឆ្កែ អស្ស គវេយ្យ គប្បីមានហោង ។

លំដាប់នោះ ស្តេចស្តាប់ពាក្យអាចារ្យទាំង ៤ រូបដោយខ្លួនទីទៃ ៗ

ដូច្នោះហើយ, ស្ដេចមានព្រះបន្ទូលដណ្ដឹងទៅកាន់ពោធិសត្វថា: តាត មហោសធ ម្នាលបាមហោសធអើយ ! អាថ៌ប្រស្នានៃអញនោះ តើបានដឹងហើយ ឬនៅឡើយ ? ។ ពោធិសត្វទូលថា បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ ! ចាប់តាំងពីអវិចិនរក ដរាបដល់ភវគ្គព្រហ្ម បើវៀរតែខ្ញុំឯងហើយ តើមានអ្នកឯណាមួយដទៃ ក៏នឹងអាចដឹងនូវអាថ៌ប្រស្នាព្រះអង្គនោះបាន ? ។ ស្ដេចស្ដាប់ហើយមានព្រះបន្ទូលថា បើដឹងដូច្នោះចូរប្រាប់សំដែងមកហោង ។ ពោធិសត្វនឹងសំដែងនូវសភាពប្រាកដនៃអាត្មាបានដឹងកិច្ចការនោះទូលព្រះមហាក្សត្រថា មហារាជបពិត្រមហាក្សត្រថ្លៃប្រសើរអើយ ! សុណាថ អញ្ជើញស្ដេចស្ដាប់ ខ្ញុំនឹងឆ្លើយថ្វាយព្រះអង្គហោង, ទើបពោធិសត្វសូត្រនូវព្រះគាថាពីរបទថា៖

អឌ្ឍុឌ្ឍបាទោ ចតុប្បទស្ស មេណ្ឌោ
អដ្ឋនខោ អទិស្សមានកាយោ
ឆាទិយំ អាហរតិ អយំ ឥមស្ស
មំសំ អាហរតិ អយំ អមុស្ស ។
បាសាទវរគតោ វិទេហសេដ្ឋោ
វីតិហារំ អញ្ញោញ្ញភោជនានិ
អនត្វា ករំ សក្ខិតំ ជនិន្ទោ
ភោកុក្ខស្ស បុណ្ណាមុខស្ស ចេតន្តិ ។

បពិត្រមហារាជអើយ ! មេណ្ឌោ គឺពពែ, អដ្ឋក្ខុរចារោ មានជើង ៨ កន្ទុះ, ចតុប្បទស្ស នៃជើង ៤, អដ្ឋនខោ មានក្រចក ៨, អទិស្សមានកាយោ មានខ្លួនពុំឲ្យប្រាកដកាលយកសាច់នោះ, អយំ មេណ្ឌោ គឺពពែនេះ, អាហរតិ នាំមក, មំសំ នូវសាច់, ឥមស្ស ដល់ឆ្កែនេះ, អាហរតិ នាំមក, តិណំ នូវស្មៅ ឆាទិយំ ដែលគេគ្របទុកក្រោមផ្ទះ ឯឥមស្ស ដល់ពពែនេះ ៗ

មហារាជ បពិត្រមហារាជអើយ កិរ ដោយឮមក, ហិយ្យោ នាអំពីម្សិលមិញ, ជនិន្ទោ គឺព្រះមហាក្សត្រដ៏ជាធំនៃក្រៃលែងអ្នកផង, វិទេហាសេដ្ឋោ ប្រសើរក្រៃលែងអ្នកស្រុកវិទេហកស្រុកទាំងឡាយ, បាសាទវរគតោ ឡើងទៅលើប្រាសាទ, អទ្ទក្ខិ ក៏បានយល់, ឯតំ សក្ខិតំ នូវសភាពជាមិត្តនោះ, ទ្វិន្នំ សត្តានំ នៃសត្វទាំងពីរ, វីតិហារំ ដ៏រើសអាហារឲ្យគ្នា, អញ្ញោញ្ញភោជនានំ ដ៏នាំអាហារឲ្យគ្នាទៅវិញទៅមក, ភោកុក្កុរស្ស ច នៃឆ្កែក្តី, បុណ្ណមុខស្ស ច នៃពពែក្តី ៗ

ស្តេចស្តាប់ហើយ មានព្រះហឫទ័យត្រេកអរសោមនស្សក្រៃ ទ្រង់ព្រះចិន្តាថា ប្រស្នាអញនេះ អ្នកប្រាជ្ញទាំង ៤ ដឹងដោយនូវអំណាចនៃអាត្មាឯង ស្តេចពុំជ្រាបសភាពជាអ្នកប្រាជ្ញទាំង ៤ ទៅអាស្រ័យរៀនអំពីពោធិសត្វឡើយ ហើយស្តេចមានព្រះបន្ទូលថា នែអ្នកប្រាជ្ញទាំងឡាយ

អើយ មានសំដីនោះពិកេះអាចដោះនូវអាថ៌ប្រស្នាដ៏ល្អិតក៏ប៉ុនជ្រៅ បិតព្ធ ដ៏ត្រកូលជាលាកនៃអញ គឺអញអរក្រៃពេក អញឲ្យនូវកដរថទឹមនូវសេះ អាជានេយ្យនោះមួយម្នាក់ នូវស្រុកប្រសើរមានទ្រព្យច្រើននោះមួយម្នាក់ ហោង, ស្តេចមានព្រះបន្ទូលដូច្នោះហើយ ព្រះរាជទានឲ្យទ្រព្យនូវស្រុក ទាំងនោះ មកអ្នកប្រាជ្ញទាំង ៤ នោះហោង ។

ទ្វាឧសង្ឃាតោ មេណ្ឌបញ្ហោ ឆដ្ឋោ ។ រីនឹងស្រដី ប្រស្នាក្នុងនឹងពពែ មានក្នុងទ្វាទសនិបាតនោះមិញ គឺស្រេចនូវប្រការ អម្បាលនោះឯងហោង ។ ឧទុម្ពរទេវី បង បពិត្រអើយ! រីនាង ឧទុម្ពរទេវី នាងដឹងថាអ្នកប្រាជ្ញទាំង ៤ នោះ ទៅអាស្រ័យរៀនអាថ៌ប្រស្នា នោះ អំពីម៉ហោសថប្រាកដដូច្នោះក្ដី នាងលីលាទៅកាន់ព្រះមហា- ក្សត្រ ហើយទូលដណ្ដឹងថា ទេវ បពិត្រមហារាជអើយ អម្ចាស់ធ្វើ នូវសក្ការបូជាអ្នកប្រាជ្ញទាំង ៤ នោះស្មើគ្នា ប៉ុនគ្រាប់សណ្ដែកមួយនោះ ក៏យល់ពុំគួរឡើយ, គួរតែព្រះអង្គបូជាមហោសថប្អូនខ្ញុំ ឲ្យលើសនោះ ក៏យល់ថាគួរ, រីអាថ៌ប្រស្នាអម្ចាស់នោះ តើអ្នកឯណាឯងអាចឆ្លើយបាន ? ស្តេចស្តាប់ហើយថា ភទ្ទេ ម្នាលនាងអើយ ! រីអាថ៌ប្រស្នាអញនេះ គឺអ្នកប្រាជ្ញទាំង ៤ ឯងអាចដឹងឆ្លើយបាន ។ នាងទូលថា បពិត្រមហា- រាជអើយ ! រីអ្នកប្រាជ្ញទាំង ៤ ដឹងអាថ៌ប្រស្នាអម្ចាស់នេះ, ហេតុអាស្រ័យ នឹងអ្នកឯណា ? ។ ស្តេចថា អញមិនបានដឹងឡើយ ។ ទើបនាងទូល

វិញថា បពិត្រអម្ចាស់ដ៏ជាស្ដេចធំឧត្ដមប្រសើរអើយ ! អាចារ្យទាំង ៤ នោះដឹងអ្វីព្រះអង្គ, អាថ៌ប្រស្នានេះ គឺមហោសថអ្នកប្រាជ្ញ អាច ប្រដៅពុំឲ្យអ្នកកំឡោះទាំងនេះវិនាសចេញអំពីស្រុកឡើយ, ហេតុម្ដេចក៏ អម្ចាស់ធ្វើសក្ការបូជាអស់អ្នកទាំងនោះស្មើនឹងមហោសថប្អូនខ្ញុំដូច្នេះ អែ- ពើនោះយល់ពុំគួរឡើយ, គួរតែអម្ចាស់បូជាមហោសថឲ្យលើស ឲ្យ ផ្សេងហោង ។

ស្ដេចស្ដាប់ហើយ មានព្រះទ័យនោះត្រេកអរនឹងពោធិសត្វ ទ្រង់ ព្រះចិន្ដាគិតថា រីមហោសថនេះ មានប្រាជ្ញានោះអាចដឹងអាថ៌ប្រ ស្នាផងទាំងពួងនោះ ឥតទើសទាល់អាស្រ័យនៃអាត្មាឯង ឥតអ្នកឯណា ប្រាប់ឡើយ បើដូច្នោះ អ្នកនឹងជណ្ដឹងនូវប្រស្នាឈ្មោះ សិរីមេណ្ឌបញ្ហា ឲ្យមហោសថកូនអញធ្វើយ ហើយអញនឹងបូជាសក្ការៈនោះច្រើន ក្នុង កាលដែលឆ្លើយបាននោះហោង ។

ឯការធិវសំ មានកាលសម័យថ្ងៃមួយ អ្នកប្រាជ្ញទាំង៥ឡើង គាល់អង្គុយនាឋានមួយសមគួរនឹងអាត្មាហើយ ស្ដេចមានព្រះបន្ទូលទៅ នឹងអាចារ្យសេនកថា សេនក ហៃអាចារ្យសេនកអើយ អញនឹងជណ្ដឹង នូវប្រស្នាមួយ ៗ អាចារ្យសេនកថា ចូរអម្ចាស់បន្ទូលជណ្ដឹងមកហោង ។

( នៅមានត )

**ផ្នែកអក្សរសាស្ត្រ**

### វប្បធម៌ខ្មែរ

# គុណប្រយោជន៍នៃសារមន្ទីរ

លោក លី · ធាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

នៅក្នុងរាជធានីភ្នំពេញ ដែលជាមជ្ឈដ្ឋានធំបំផុតខាងវប្បធម៌នៃប្រទេសកម្ពុជា យើងឃើញមានសារមន្ទីរ, សាលាវិចិត្រសិល្បៈខេមរៈ, បណ្ណាល័យ, មន្ទីរស្រាវជ្រាវមុខវិជ្ជាផ្សេង ៗ ល ៗ អាគារទាំងនោះហើយដែលជាជម្រកនៃវត្ថុជាក់ស្តែងរបស់វប្បធម៌បុរាណយើង ។

ពេលនេះ យើងល្បងរែកញែកបន្តិចបុះពីវត្ថុទាំងនោះ ដើម្បីបើកស្មារតីយើងឲ្យឃើញកាន់តែប្រាកដឡើង ។ មើលចុះ នៅក្នុងសារមន្ទីរជាតិ ដែលពាក្យសាមញ្ញខ្ចះនិយមហៅថាសាលារចនា ឃើញមានវត្ថុបុរាណច្រើនណាស់ ដែលច្រើនតែធ្វើអំពីលោហធាតុ ឬពីសិលាជាតិ ។ ពិតមែនហើយ លោហធាតុនឹងសិលាជាតិទាំងនោះ ពុំចេះបញ្ចេញពាក្យប្រាប់យើងអំពីតម្លៃនឹងរឿងរ៉ាវរបស់ខ្លួនមែន ប៉ុន្តែបើយើងសង្កេតយ៉ាងពិនិត្យឲ្យមែនទែន វត្ថុទាំងនេះច្បាស់ជាចេះញញឹមនឹងនិទានប្រាប់យើងហូរហែពីពត៌មានផ្សេង ៗ ក្នុងប្រទេសជាតិនៅសម័យនិមួយ ៗ ដែលវត្ថុទាំងនោះ

ចាប់កំណើតឡើង ៗ មើចុះដុំថ្មធំ ១ ដ៏មានធ្លាក់ជារូបផ្សេង ៗ ដំណាង វប្បធម៌បូរាណខ្មែរ បានកម្រៀបគ្នាជាជួរជាសង្កាត់ ចាំទទួលអស់លោកអ្នកជាអ្នកសិក្សា ពោលគឺជាអ្នកដែលត្រូវការទៅសាកសួរដល់ខ្លួន ៗ រូបជាដំណាងព្រហ្មញ្ញសាសនាក្ដី , ជាដំណាងព្រះពុទ្ធសាសនាក្ដីសុទ្ធតែជាសក្ខីភាព បង្ហាញយើងអំពីលទ្ធិសាសនានៅសម័យនិមួយ ៗ ព្រោះលទ្ធិសាសនានេះហើយ ជាមេ, ជាទីប្រជុំ, ជាដើមហេតុនាំឲ្យកើតបានជាវប្បធម៌នៃជាតិ ដែលបំបែកទៅជាសាខាយ៉ាងច្រើនបែបច្រើនយ៉ាងទៅទៀត ៗ បានជាយើងហ៊ានថាលទ្ធិសាសនាទាំងនេះ ជាមេគំនិតនឹងជាមូលហេតុរបស់វប្បធម៌យើង ព្រោះដោយសារតែលទ្ធិសាសនាទាំងនេះហើយ ទើបខ្មែរមានទេពកោសល្យជាច្រើន ក្នុងរចនារូបចំឡាក់ក្បាច់ក្បូរពណ៌នាពីរឿងរ៉ាវ ឬ រូបបុគ្គលអស្ចារ្យរបស់សាសនាទាំងនោះ ៗ ដោយសារលទ្ធិសារ លទ្ធិសាសនានេះទៀត ដែលបង្កើតគំនិតខ្មែរពីបូរាណទៀត ឲ្យនិយមចងក្រងនូវក្បួនខ្នាតផ្សេង ៗ ដែលចារឹកលើក្រាំង ឬ មួយចារឹកលើផែនសិលាដ៏ធំៗ សំរាប់ឲ្យយើងជាន់ក្រោយបានក្រេបរសជាតិអំពីក្បួនខ្នាតនឹងច្បាប់ទំលាប់ទាំងនោះ ៗ បើនិយាយឲ្យខ្លីថា លទ្ធិសាសនានេះហើយ ដែលមានអានុភាពផ្ដល់នូវនិន្នាការផ្សេង ៗ ទៅលើស្ថាបនកម្មគ្រប់បែបរបស់ខ្មែរយើង ៗ ដោយហេតុ យល់ថាលទ្ធិសាសនាពិតជាគោលគំនិតយ៉ាងធំ ឬ ជាជំនួយស្មារតីពេញលក្ខណៈ ក្នុងការដឹកនាំ

សតិបញ្ញានៃជនជាតិឲ្យមានលក្ខគោលត្រឹមត្រូវក្នុងវប្បធម៌ ទើបបណ្ដាជនខ្មែរនិយមគោរពលទ្ធិសាសនាតាំងពីបូរាណរៀងរហូតមកដល់សព្វថ្ងៃនេះយ៉ាងខ្ជាប់ខ្ជួនបំផុត ។ បើយើងពោលតាមហេតុភេទរបស់ស្រុកវិញ ក៏យើងឃើញមានប្រយោជន៍សំខាន់មួយទៀត គឺកាលពីសម័យមានសង្គ្រាមដោយជនបរទេសបានចូលមករុកពនក្នុងប្រទេសយើង បង្កើតឲ្យមានចលាចល ឬប្រើមធ្យោបាយបន្ទាបបន្ថោកវប្បធម៌ឲ្យបាត់ឈ្មោះសោះសូន្យនោះ ក៏មានខ្មែរមិនបាត់បង់ក្បួនខ្នាតតម្រាប់តម្រារបស់ខ្លួនឡើយ ព្រោះមានទីជម្រកយ៉ាងស្កុកស្កម្ភដោយវត្តអារាមនៃសាសនាយើង ។ មិនតែប៉ុណ្ណោះទៀត តាំងពីសម័យអង្គរៀងមកដល់សព្វថ្ងៃនេះ សាលារៀនដែលជាទីអប់រំកុលបុត្រខ្មែរទាំងចំណេះវិជ្ជាទាំងចរិយា ក៏តែងស្ថិតនៅក្នុងវត្តអារាមដែរ ។ វេលានេះយើងពុំបាច់រ៉ាយរ៉ាប់ពីប្រយោជន៍លទ្ធិសាសនាទៅទៀតទេ ដ្បិតលោកអ្នក គង់សង្កេតឃើញនិងបានពិចារណារួចមកហើយ ។ យើងសុំពោលបន្តទៅទៀតអំពីគុណសម្បត្តិនៃរូបចំឡាក់ដែលបានរ៉ាយរ៉ាប់មកហើយខាងលើ ។

ក្រៅពីការបង្ហាញឲ្យយើងស្គាល់ពីលទ្ធិសាសនា រូបទាំងនេះបានបង្ហាញឲ្យយើងស្គាល់ថែមទៀតខាងទំនៀមទម្លាប់ស្រុក ដែលជាដើមនៃអារ្យធម៌របស់ជាតិនិមួយ ៗ ព្រោះបើមើលសង្កេតចំពោះរូបរាងការប្រើសំលៀកបំពាក់ ឬរូបខ្លះនិទានពីពិធីកម្មរបស់អ្នកស្រុកផង នោះយើង

រីឯរឹតតែឃើញច្បាស់ណាស់ទៅទៀត នូវអារ្យធម៌របស់យើង ៗ តទៅទៀត រូបទាំងនេះ នាំឲ្យយើងស្គាល់ពីប្រវត្តិនៃប្រទេសជាតិយើងទៀត គឺយើងតែងបានដឹងថា នៅសម័យណាប្រទេសយើងមានព្រឹត្តិការណ៍ដូចម្ដេច ១ ៗ

បើយើងបែរមកមើលខាងសិលាចារឹកវិញ ក៏ឃើញមានច្រើនសន្ធឹកណាស់ដែរ ខ្លះធំខ្លះតូច ខ្លះបាក់បែកអន្តរាយស្ទើរតែអស់ ខ្លះទៀតក៏នៅគង់វង់ល្អមើលបាន ៗ អក្សរដែលចារឹកលើផ្ទាំងសិលានេះ មិនមានកិនកាតដូចគ្នាទាំងអស់ទេ គួព្យញ្ជនៈតែងប្រែប្រួលប្លែក ១ ពីគ្នាខ្លះ ១ ៗ ព្រោះនេះជាការបញ្ជាក់ប្រាប់យើងឲ្យឃើញថា ការកសាង គាលចារឹកទាំងនេះ មិនមែនក្នុងពេលតែមួយទេ ប្រាកដជាបុព្វបុរសយើងស្វះស្វែងកសាងមកអស់រយៈពេលជាច្រើនសតវត្សរ៍ណាស់ ហើយកិច្ចការនេះត្រូវធ្វើដោយព្យាយាមនឹងដោយផ្ចិតផ្ចង់ជាបំផុត ៗ តួអក្ខរទាំងនេះទៀតបានចរចាដំហូវហៃប្រាប់យើងឲ្យស្គាល់ពីប្រវត្តិដើម របស់ប្រទេសជាតិនៅសម័យដែលកន្លងមកហួសយូរយារណាស់ហើយ ៗ លក្ខណៈសំខាន់ក្នុងសិលាចារឹកទាំងនេះម្យ៉ាងទៀត គ្រង់ផ្នែកអក្សរសាស្ត្រដែលបុព្វបុរសយើងមិនភ្លេចសោះទេ នូវការលើកដំកើងមុខវិជ្ជាផ្នែកនេះ ឲ្យបានត្រកំត្រកាលឡើងតាំងពីដើមមក ៗ លោកចង់ពោលពតិមានប្រាប់យើងលោកតែងសរសេរជាកំណាព្យកាព្យឃ្លោង ប្រកបដោយសំនួនអលង្ការ

លួងល្ហាយបញ្ចូលក្នុងនោះផង ។ ហេតុនេះហើយ បានជាអ្នកសិក្សាអក្សរសាស្ត្រទាំងអស់គ្នា អាចការកឃើញនូវគោលចារឹកអក្សរសាស្ត្រពិតប្រាកដ ។

ក្រៅពីនេះ យើងឃើញមានឧបករណ៍តូរ្យតន្ត្រីគ្រប់បែបគ្រប់យ៉ាងទៀត គឺវត្ថុទាំងនេះហើយ ដែលនិទានបញ្ជាក់ប្រាប់យើងអំពីសេចក្តីចំរើនលូតលាស់នៃតន្ត្រីខ្មែរតាំងពីព្រេងនាយរហូតមកដល់បច្ចុប្បន្នកាលនេះ ។ ហេតុម្តេចបានជាយើងលើកយកគ្រឿងតន្ត្រីមកពោលក្នុងទីនេះដែរ ? យើងឆ្លើយភ្លាមថា តន្ត្រីជាផ្នែកមួយយ៉ាងសំខាន់ណាស់ក្នុងវប្បធម៌ជាតិ ។ មើលចុះ ការផ្សព្វផ្សាយនៃវប្បធម៌រវាងប្រទេសមួយនឹងប្រទេសមួយក្នុងសម័យឥឡូវនេះ គេច្រើនតែលើកយកផ្នែកតន្ត្រីនេះហើយធ្វើជាត្រីមុខ ៗ ព្រោះតន្ត្រីជាគ្រឿងបំពេអារម្មណ៍ផង, ជាគ្រឿងសំគាល់ពីសិល្បៈស្នូរសំនៀងរបស់ជនជាតិនិមួយ ៗ ផង ។ ដូច្នេះ បានជាសព្វថ្ងៃនេះមានការប្រកួតប្រជែងខាងតន្ត្រីជាញឹកញាប់ រវាងប្រទេសទំនើបទាំងឡាយក្នុងសាកលលោក ។

បន្ទាប់ទៀត យើងប្រទះឃើញវត្ថុធ្វើអំពីការស្មូនដីហើយវិចិត្ររចនាជាច្រើនពណ៌ ព្រមទាំងមានលំនាំជាវត្ថុប្រើប្រាស់ផ្សេង ៗ ពីគ្នា ។ ក្នុងនោះមានក្អមក្រឡល្អឥតខ្ចោះលាយលុកជាមួយពណ៌យ៉ាងភ្លឺត្រចះផង ។ ត្រង់នេះ មិនត្រឹមតែបង្ហាញយើងអំពីសិល្បកម្មក្នុងការឆ្លាក់នឹងការស្មូនរូប

តាំងនេះទេ គឺជាកស្តុតាងជាក់ស្តែងមួយ ខាងផ្នែកវិទ្យាសាស្ត្រដែលជាមែកធាងយ៉ាងធំក្នុងវប្បធម៌ទំនើប ។ បានជាបែរវេរគិតទៅរកវិទ្យាសាស្ត្រវិញ ព្រោះឃើញថា បើសិល្បករខ្មែរធ្វើតែនេះពុំបេះក្បួនខ្នាតគម្ពីជាក់ប្រាកដទេ ពុំអាចលាយវត្ថុធាតុឲ្យកើតបានជាគ្រឿងរលោង ឬ ជាពណ៌ធ្អិនឆ្អៅជាប់លាប់យ៉ាងយូរដូចនេះបានទេ ។

សេចក្តីបរិយាយខាងលើនេះ គ្រាន់ជាការពណ៌នាគ្រួស ៗ ចំពោះប្រយោជន៍នៃអាគារដ៏វិចិត្រមួយ ដែលយើងហៅថា សារមន្ទីរ បានន័យថា "កន្លែងដែលប្រកបដោយខ្លឹមសារ" ។ ឥឡូវយើងគ្រាន់តែក្រឡេកមើលហើយល្បងពិចារណាបន្តិចមើលក៏ឃើញថា ត្រូវតាមន័យរបស់ពាក្យជាឈ្មោះរបស់អាគារនេះមែន ។ តែបើនិយាយឲ្យខ្លីងាយយល់ថាសារមន្ទីរជា ឃ្លាំង ឬជាជង្រុក នៃវប្បធម៌ក៏បាន ។ ដូចនេះ ការទស្សនារបស់កុលបុត្ត-កុលធីតាខ្មែរនៅក្នុងមន្ទីរនេះ ពិតជាការក្រេបជញ្ជក់នូវវប្បធម៌ជាតិខ្លួនយ៉ាងជាក់ច្បាស់ជាមិនខាន ។

---

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Communion | *n. f.* | អាគន្លុមកម្ម |
| Excommunication | *n. f.* | និគន្លុទកម្ម |
| Thallophytes | | សុត្តភូគាម |
| Algue | *n. f.* | សារាយ |
| Lichen | *n. m.* | ករកាប្យ |
| Muscinées | | សេវាលជាតិ |
| Mousse | *n. f.* | ស្លែ |
| Hépatique | *n. et a.* | យក្រឹត |
| Cryptogames vasculaires | | បដិច្ឆន្នជាតិ |
| Fougère | *n. f.* | បណ្ណង្គជាតិ |
| Licopode | *n. m.* | លីកូបាទ |
| Gymnosperme | *n. m.* | អច្ឆន្នបុប្ផាទជាតិ |
| Angiosperme | *n. m.* | ឆន្នបុប្ផាទជាតិ |
| Conifère | *n. m.* | សរលជាតិ |
| Cotylédon | *n. m.* | ពីជបត្រ |
| Dicotylédone | *n. m.* | ទ្វិពីជបត្រជាតិ |
| Monocotylédone | *n. m.* | ឯកពីជបត្រជាតិ |
| Graminée | *n. f.* | ឃាសជាតិ |
| Bruine | *n. f.* | រលឹមត្រជាក់ |
| Pluie | *n. f* | ភ្លៀង |
| Ondée | *n. f.* | ភ្លៀងរគំ |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ប៉ាង - ខាត់ រៀបរៀង

(តមក)

**អតិប្បវត្ត** បុំ. កិរិយាចូលក្រៃលែង, កិរិយាចូលលាយឡំក្រៃលែង ។

**អតិប្បសំសិ** ធាតុ សរសើរក្រៃលែង ។

**អតិប្បសាន្ត** គុ. ដែលស្ងាត់ក្រៃលែង ។

**អតិប្បញ្ញ** បុំ. ប្រាជ្ញាក្រៃលែង, ប្រាជ្ញាពិបាក ។

**អតិប្បសត្ត** គុ. ដែលជាប់ក្រៃលែង; អតិប្បសត្តិ ស្រី,
កិរិយាជាប់ក្រៃលែង ។

**អតិប្បសង្គ** បុំ. កិរិយាជាប់ក្រៃលែង (កាមារម្មណ៍) ការជៀស,
កិរិយាប៉ះទង្គិចក្រៃលែង ។ អតិប្បសង្គិន គុ. ដែលពាក់ព័ន្ធ
(ទៅរកកាមារម្មណ៍) ។

**អតិប្បសិទ្ធ** ធាតុ. តម្កើង, លើកតម្លៃ ។ អតិប្បសន្ន គុ. ដែលថ្លៃថ្លើង,
ដែលថ្លៃថ្លា ។

**អតិប្បហារ** បុំ. ប្រហារក្រៃលែង ។

**អតិប្បាកដ** គុ. ដែលនៅប្រាកដក្រៃលែង ។

**អតិប្បមាណ** ក្រិ. វិ. ដោយប្រមាណក្រៃលែង ។

**អតិប្បិយ** គុ. ប្រិយប្រិយក្រៃលែង ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៤

ឧកញ៉ាវិបុលរាជសេនា ញូ-កាន ប្រែរៀបរៀង

( តមក )

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកវាងវៃឆ្លាសបើបានអាន<br>នឹងបេះឧបាយកលបំណាន<br>ទាំងមានសន្ដានស្នេហាជាតិ ។ |

តាំងពីហោយិន ហោហង ធ្វើឧបាយរត់ចោលស្រុកឡាំកុន ដីវយី ត្រូវព្រួញរងើជាស្លាប់ ។ ហោយិនត្រឡប់វាញ់ទ័ពដីវយី ។ ខុទបេង ផ្ដើមយកស្រុកឡាំកុនបាន, ខ្សៀពី វាយយកស្រុកឡេងឡេងបាន ហើយឲ្យភ្ជិឡុងទៅវាយយកស្រុកហ៊ុយអៀងបានទៀត ។

---

បើឃើញដីវយីលើកទាហានចូលមក ក៏ឲ្យច្បាំងកាំងកក្តាម ១ បើឮសំឡេងផាវវេលាណា ត្រូវឲ្យទាហានជួបាញ់ព្រួតគ្នាបម្រុះចូលទៅឲ្យមាំមួន លុះបង្គាប់ធ្វើស្រេចហើយ ហោយិន, ហោហងក៏នាំទាហានដែលស្ពាយស្បៀងនោះ ធ្វើជារត់ចេញចោលស្រុកទៅ ។

ឯដីវយីក៏ឡើងមើលលើសើនបន្ទាយ មិនបានឃើញទាហាននៅក្រុងបន្ទាយក្នុងស្រុក ឃើញតែហោយិន ហោហងនាំទាហានស្ពាយរែកស្បៀងអាហារចេញពីស្រុកទៅប្រពាក់ប្រពូនក៏នឹកថា ហោយិន ហោហង

រត់បោលស្រុកហើយ ជីវយ៉ក៏ចុះពីលើសេះបន្ទាយ ហើយបង្គាប់ទាហាន កងមុខឲ្យចូលច្បាំងនឹងពោយិន, ពោហង ឲ្យប៉ែកឆ្វេង-ស្តាំ ចូលប្រសព្វ គ្នាច្បាំងជាជ្រួលច្របល់ ឯខ្លួនយើងនឹងលើកទាហានជាទ័ពជំនួយទៅជួយ បើកងមុខឮសំឡេងឃោះហើយ ឲ្យបង្ខំស្រូតបំពារចូលទៅ ៗ ឯទាហាន កងមុខនឹងប៉ែកឆ្វេង-ស្តាំ ក៏លើកចូលទៅប្រយុទ្ធគ្នានឹងពោយិនពោហង ជាច្រឡំបល់ ៗ ជីវយ៉ក៏ឲ្យជីវថាយ បរសេះចេញទៅច្បាំងនឹង:ពោយិនបាន ១០ ក្វេង មិនចាញ់មិនឈ្នះ ជីវយ៉ក៏ប្រើហ័នគុងឲ្យជិះសេះចូលទៅតនឹង ពោហងបាន៣០ក្វេង ៗ ពោយិនពោហងធ្វើជាថយរត់ទៅទិសខាងជើង មិនបានចូលស្រុកឡាំកុន ៗ ជីវថាយ ហ័នគុងឃើញដូច្នោះក៏បរសេះ ដេញតាមទៅ ៗ ជីវយ៉ក៏ដេញទាហានជំនួយទៅផុតជើងកំពែងស្រុក ឃើញទ្វារបើកចំហ ក្រឡេកមើលទៅ មិនឃើញមានមនុស្សម្នានៅក្នុង បន្ទាយនោះសោះ ជីវយ៉ក៏នាំទាហានប្រហែល ៥០ នាក់ ចូលទៅតាមទ្វារ ដល់ក្នុងស្រុក ៗ

ឯត័នកៀវក៏និយាយថា គំនិតដែលរិះគិតរបស់មហាឧបរាជឲ្យសំបុត្រ នោះល្អណាស់ ឧបមាដូចទេពតាមកបញ្ចូលចិត្ត ទទួលឮសម្លេងផាវ ក៏ឲ្យទាហានបាញ់ធ្នូចម្រុះចូលទៅជាច្រើន, ឯត័នកៀវក៏បាញ់តម្រង់ទៅ ត្រូវជើងឆ្វេងជីវយ៉ធ្លាក់ពីលើសេះ ៗ នីវយឹមឃើញដូច្នោះ ក៏លើកទាហាន ចូលទៅនឹងចាប់យកជីវយ៉ ៗ ទទួលឈើសេង, គេងហងចូលមកទាន់

ក៏ជួយគ្នាការពារដីវយើបាន ហើយគ្រាហ៍ឡើងសេះថយចេញមកពីស្រុក ៗ ឯតំនកៀក៏បរពលចូលច្បាំង ៗ ពួកទាហានដីវយើក៏រត់ទៅធ្លាក់អន្លង់ជាច្រើន ៗ តំនកៀក៏ចាប់បានសម្លាប់ខ្លះចេញ ៗ ឈើសេង, តេងហងទំការពារដីវយើនាំចេញទៅក្រៅបាន ៗ ទៀកៅ ឃើញដីវយើថយមកក៏ពាយឃោះជាសញ្ញា ប្រាថ្នានឹងហៅទាហានឲ្យថយមកពល់គ្នា ៗ ឯដីវថាយនឹងហ៍នតុង លុះឮសម្លេងឃោះក៏នាំទាហានថយមកតាមសញ្ញា ៗ

ចោយិន, ចោហង់ឃើញដូច្នោះ ក៏លើកទាហានញែកគ្នាជាពីរកងតាមពាយផ្លូវប្រសព្វចូលទៅ ៗ ដីវយើនឹងទាហានក៏ថយចូលទៅក្នុងបន្ទាយវិញ ៗ ដីវយើក៏កន្ត្រាក់ដកព្រួញចេញបាន ហើយឲ្យពេទ្យថែរក្សារបួសតែនៅឈឺចាប់ក្នុងរបួសនោះម្តង ១ ៗ ពេទ្យក៏និយាយថា ព្រួញនេះដាក់ថ្នាំពិស សុំឲ្យលោករម្ងាប់កំហឹងក្នុងខ្លួនកុំឲ្យមាន បើកាលណាមានកំហឹងហើយ ពិសថ្នាំក៏នឹងកំរើកឡើងវិញ ៗ ទៀកៅ ក៏បង្គាប់ទាហានទាំងពួងឲ្យត្រួតត្រារក្សាបន្ទាយឲ្យមាំមួន កុំឲ្យទំប្រឹក្សានឹងទាហានទាំងពួងយកការអ្វីចូលទៅនិយាយនឹងដីវយើឲ្យសោះ បើធ្លូល់ពីការអ្វី ក៏ឲ្យនាយទំពនាយកងជួយគ្នារិះគិតការឲ្យបានសម្រេច កុំឲ្យអន្ទពយទំពាំតែរបួសដីវយើនោះសះជា ៗ

ឯចោយិន, ចោហង់ ក៏ឲ្យដីវឃើមលើកទាហានទៅស្រែកជេរដីវយើនៅមុខបន្ទាយ ជាពាក្យអសុរោះគ្រប់ ៣ ថ្ងៃ ៗ ទៀកៅ ក៏ហាមប្រាម

ទាហានទាំងពួងមិនឲ្យចេញច្បាំង ហើយប្រឹក្សានឹងនាយទ័ពនាយកងថា គ្រានេះ ដីវយើឈឺត្រូវតែយើងរិះគិតឧបាយ ឲ្យដីវយើលើកកងទ័ពត្រឡប់ទៅវិញ ដើម្បីនឹងឲ្យស៊ុនគួនជ្រាបកិច្ចការ រួចសឹមលើកកងទ័ពមកធ្វើសង្គ្រាមវិញ នាយទ័ពនាយកងទាំងពួងក៏នៅស្ងៀម មិនថាប្រការម្ដេច ៗ

ខណៈនោះ ដីវយើបានឮសម្លេងទាហានតោយិនមកស្រែកជេរជៀមដាម ដីវយើខំអត់សង្កត់ចិត្តកុំឲ្យកំហឹងកើតឡើងបាន ព្រោះខ្លាចពិសថ្នាំកំរើកឡើងវិញ ៗ ថ្ងៃមួយតមក តោយិនក៏លើកទាហានទៅដល់មុខបន្ទាយដីវយើ ហើយឲ្យពលគងស្គរស្រែកហ៊ោកញ្ជ្រៀវអឺងកង ដើម្បីផ្ដើនចំអកដីវយើ ៗ ដីវយើឮហើយ ក៏បណ្ដាលចិត្តគិតចង់ដឹង ទើបសួរពួកមនុស្សដែលនៅបំរើថា សម្លេងអ្វីឮសន្ធឹកសន្ធាប់នោះ? ៗ ពួកអ្នកបំរើឆ្លើយថា ទាហានកងទ័ពយើងកំពុងហ្វឹកហាត់ គ្រឿងសាស្ត្រាវុធ ៗ ដីវយើឮដូច្នោះខឹងណាស់ ទើបថាសម្លេងនេះ គឺទាហានតោយិន មកស្រែកជេរជៀមដាមច្រើនថ្ងៃហើយ, យើងក៏ដឹងដែរ ទើបឲ្យហៅទៀកៅមក ហើយនិយាយថា ខ្លួនយើងជាមេទ័ពដេកឈឺ គួរឬ? ខ្លួនអ្នកជាបាឡាត់ទ័ពនៅស្ងៀមព្រងើយ មិនដឹងជាតោយិនវាប្រើទាហានមកស្រែកជេរជៀមដាម ៣-៤ ថ្ងៃហើយ ហេតុអ្វីក៏មិនប្រាប់យើងឲ្យដឹងផង ៗ ទៀកៅឆ្លើយថា បានជាខ្ញុំបាទមិនជំរាបលោកឲ្យជ្រាបនោះ ព្រោះក្រែងលោកជ្រាបទៅហើយ នឹងបណ្ដាលឲ្យមានចិត្តខឹងឡើង រួសព្រួញដែលមានក្នុងខ្លួន

លោកនឹងកំរើកពិសឡើងវិញ ។ ជីវយីថា បើអ្នកនៅស្ងៀមមិនចេញច្បាំងដូច្នេះ តើគិតដូចម្តេចទៅវិញ ? ។ ទៀកៅថា ខ្ញុំបាទនឹងទាហានទាំងពួងប្រឹក្សាគ្នាទៅឃើញថា ខ្លួនលោកនៅឈឺដូច្នេះ ខ្ញុំបាទចង់អញ្ជើញលោកលើកទ័ពត្រឡប់ទៅស្រុកកាំងតាំងសិន បើលោកគ្រាន់បើថ្ងៃណាសឹមលើកទ័ពមកធ្វើសង្គ្រាមនឹងហោយ៉ិនវិញ ។ ជីវយីឮដូច្នោះ ស្ទុះក្រោកឈរឡើងហើយថា ខ្លួនយើងនឹងអស់អ្នកពល់គ្នា សុទ្ធតែជាទាហានស៊ីបៀវត្សរ៍ ត្រូវតែគិតតបស្នងសងគុណចៅហ្វាយនាយ បានជាទំមកធ្វើការប្តូរស់ប្តូរស្លាប់ ទោះបីក្ស័យជីវិតក្នុងសង្គ្រាម គឺឲ្យគេយកអានសេះបិទបាំងសាកសពទៅចុះ ដែលនឹងពថយដោយញញើតខ្លាចនោះមិនគួរសោះឡើយ ត្រូវតែទំស្រួតទៅខាងមុខ ហេតុអ្វីអស់អ្នកពល់គ្នាសុទ្ធតែជានាយកងនាយទ័ព នាំគ្នាមកកើតទុក្ខធុញថប់ដល់យើងដែលឈឺប៉ុណ្ណោះ ហើយមិនគិតលើកកងទ័ពចេញទៅច្បាំងនឹងសត្រូវ ថាហើយជីវយីតែងខ្លួនពាក់គ្រោះកាន់លំពែងឡើងសេះ ។ ទាហានទាំងពួងឃើញដូច្នោះ នាំគ្នាតាមជីវយីចេញទៅដល់ទ្វារបន្ទាយ ។

ឯហោយ៉ិនកំប្រើទាហានចេញទៅស្រែកដេរថា អាជីវយីនោះ អាយុវានៅក្មេងនៅឡើយ តែចិត្តគំនិតវាក្អេងក្អេងខ្លាំងណាស់ ជីវិតវានឹងស្លាប់ក្នុងកណ្តាលសង្គ្រាមឥឡូវហើយ ។ ជីវយីឮដូច្នោះ កំបរសេះចេញទៅក្រៅបន្ទាយហើយស្រែកថា ខ្លួនអញនេះ ទោះបីអាហោយ៉ិននឹងចេញមក

គស៊ីប្រទល់ខ្លួនក៏អញមិនខ្លាចដែរ អាឯងកុំរត់ល់គ្នាកុំមកជេរប្រមាថអញឡើយ ៗ និយាយរួចក៏ប្រើក្លូជៀង ឲ្យបរសេះចេញទៅច្បាំងនឹងចោយិន ហើយបន្ទំដេញទាហានជាជំនួយតាមទៅ , លុះនិយាយអស់ពាក្យកាលណា ថ្នាំពិសក៏កំរើកឡើងក្អួតឈាមធ្លាក់មកពីលើខ្នងសេះ ៗ ចោយិនឃើញដូច្នោះ ក៏លើកទាហានចូលទៅប្រយុទ្ធគ្នា, ពួកទាហានជីវយីក៏ពារប្រទល់តទៅវិញ ហើយគ្រាហ៍យកជីវយីចូលទៅក្នុងបន្ទាយ ខ្លះរត់រួច ខ្លះគេកាប់ប្រហារ ជីវយីក៏ភ្ញាក់ស្មារតីដឹងខ្លួនឡើងវិញ ៗ ឯចោយិនបានលើកទ័ពចូលស្រុក ៗ

ទៀកៅសួរជីវយីថា បើលោកកំពុងឈឺដូច្នេះ តើគិតជាយ៉ាងម្ដេចទៅទៀត ៗ ជីវយីក៏ឆ្លើយប្រាប់ថា អ្នកកុំព្រួយឡើយ យើងគិតការឃើញស្រួលហើយ ហើយប្រាប់ទៀកៅថា យើងត្រូវប្រើទាហាននឹងមនុស្សទំនុកទុកចិត្តចេញទៅនិយាយថា យើងដល់នូវសេចក្ដីស្លាប់ទៅហើយ ដែលនឹងនាំគ្នានៅជាមួយនាយទ័ពនាយកងនោះមិនស្រួលគិតនាំគ្នាទៅចូលខាងចោយិន ១ ក៏នឹងមានចិត្តក្អេងក្អេងលើកទ័ពមកវាយបន្ទាយយើងជាប្រាកដ រួចយើងត្រូវដោះខ្លួនចេញពីបន្ទាយឲ្យអស់នាំទាហានយើងនៅបង្កប់ទុកជា ៤ កង ហើយឲ្យវាយខ្ទប់គ្រឡប់មកវិញនឹងចាប់យកខ្លួនចោយិនបានដោយងាយ ៗ ទៀកៅស្ដាប់ហើយក៏យល់ត្រូវផង ជីវយីក៏ប្រើទាហានទាំងពួងឲ្យដើរចេញទៅស្រែកយំថា ជីវយីស្លាប់ទៅហើយ

ឲ្យយកទន់សដោតនៅមុខបន្ទាយ ទាហានទាំងឡាយក៏ឲ្យស្លៀកសពាក់សទាំងអស់ ហើយបង្គាប់ទាហានឲ្យធ្វើការតាមគំនិតដែលគិតនោះ ។

ឯចៅយិនក៏ប្រឹក្សានឹងទាហានទាំងពួងថា យើងឲ្យទៅស្រែកជេរជីវយីជាពាក្យអសុរោះមើលងាយ ជីវយីខឹងចេញមកតច្បាំង ក៏ធ្វើអ្វីយើងមិនបាន ឈឺចិត្តណាស់ទាល់តែក្អួតធ្លាក់ឈាមចេញមក យើងយល់ថាជីវិតជីវយីក្នុងគ្រានេះ មុខជាស្លាប់ពិតប្រាកដណាស់ ។ ទទួលទាហានចូលមកប្រាប់ថា ឥឡូវទាហានជីវយី១២នាក់ចូលមករកលោក ។ ចៅយិនក៏ឲ្យហៅចូលមកហើយសួរថា អ្នកឯងកល់គ្នាចូលមកនេះមានធុរៈអ្វី? ។ ទាហានទាំង ១២ នាក់ក៏ឆ្លើយព្រមគ្នាថា ទាហាន ១០ នាក់ជារបស់ជីវយីឯទាហាន ២ នាក់ជាទាហានចូច្ចូ ដែលជីវយីចាប់បានមក កាលជីវយីចេញមកច្បាំងនឹងលោកនោះ ជីវយី ក៏ក្អួតធ្លាក់ឈាមចេញមក ហើយត្រឡប់ចូលទៅក្នុងបន្ទាយវិញបានមួយស្របក់ក៏ដាច់ខ្យល់ស្លាប់ ឥឡូវទៀតៅជាមេទ័ពបង្គាប់បញ្ជាពុំត្រឹមត្រូវ ធ្វើតែតាមអំពើចិត្ត យើងខ្ញុំទាំងអស់ទ្រាំមិនបាន ទើបនាំគ្នារត់មកប្រាប្តានឹងជ្រកកោននៅនឹងលោកតទៅ ។

ចៅយិនឮដូច្នោះ ក៏ពិនិត្យមើលទាហានទាំង១២នាក់នោះ ក៏ចាំបានថាជាទាហានចូច្ចូ ទើបប្រឹក្សានឹងទាហានទាំងពួងថា ឥឡូវជីវយី ស្លាប់ហើយ យប់នេះយើងត្រូវលើកទាហានទៅលុកបន្ទាយទៀតៅ ដណ្ដើម

យកសពដីវយើឲ្យបាន ដើម្បីកាត់យកក្បាលបញ្ជូនទៅឲ្យចូចូឯស្រុកក្រុង ៗ ទាហានទាំងពួងក៏យល់ឃើញត្រូវផង ៗ ចោយិន ក៏ប្រើត័នគៀវ ឲ្យនៅរក្សាបន្ទាយស្រុក, ឲ្យងីវឃឹម លើកទាហានចេញទៅជាទ័ពស្រួច, ឲ្យចោយិនលើកទ័ពជាកងហ្លួង, ឲ្យចោហងនឹងចោស៊ុន លើកទាហានជាកងក្រោយ ៗ លុះពេលយប់ប្រហែលជាយាមមួយប្លាយ ក៏លើកទ័ពចេញទៅដល់មុខបន្ទាយទៀកៅ មិនឃើញមានមនុស្សនៅក្នុងបន្ទាយសោះ ៗ ចោយិន ក៏គិតពិកល់ក្នុងចិត្តថា ប្រហែលជាដីវយើ ធ្វើកលឧបាយទេដឹង គិតហើយក៏ឲ្យលើកទ័ពចេញមកវិញនឹងចូលទៅក្នុងស្រុក, ទទួលឮស្គរផាវនឹងមាត់ទាហានស្រែកហ៊ោផ្ទុះចេញមកពីទិសទាំង ៤ ហើយឃើញទិសខាងកើតនោះ ហ័នតុងនឹងដីវឃឹមលើកទាហានចូលមកទិសខាងលិចឃើញកួជៀង នឹងដីវថាយវាខ្ទប់ចូលមកទៀត ឃើញឈីសេងនឹងតេង-ហង លើកទាហានចេញមកពីទិសខាងត្បូង ឃើញត័នប៉ូនឹងលីបង លើកទាហានចេញមកពីទិសខាងជើង ប្រជុំគ្នាជុំវិញជាច្រឡំបល់, កងទ័ពដីវយើ ក៏ព្រួតគ្នាកាប់សម្លាប់ទាហានចោយិន ស្លាប់ច្រើនណាស់ ៗ ចោ-យិន នឹងទាហានទាំងពួងតទល់ពុំបាន ក៏នាំគ្នាបាក់រត់ចេញទៅជា ៣ ផ្លូវ ចោយិន សល់តែទាហាន ២០ នាក់ ៗ លុះដល់យាម ៣ ប្លាយ ទទួលប្រទះគ្នានឹងទ័ពចោហង គិតគ្នាថានឹងចូលទៅក្នុងស្រុក, ឃើញឡេងថងលើកទាហានមកស្ទាក់នៅពីមុខ ចោយិន ក៏នាំចោហងរត់ទៅដល់មាត់ផ្លូវ

ប្រទះនឹងកាំភ្លើង ស្ទាក់នៅពីមុខទៀត ហោយ៉ិននឹងហោហង ច្បាំងគ្នានឹងកាំភ្លើងជាពន្លឹក ទប់កម្លាំងទ័ពរបស់កាំភ្លើងមិនបាន ក៏នាំទាហានប្រហែល ២០ នាក់ រត់តម្រង់ទៅស្រុកសុងយ៉ុង ៗ លុះពេលព្រឹកឡើងនាយទាហានទាំងពួងក៏នាំគ្នាទៅរកដីវយើ ៗ ក៏នាំទាហានទាំងអស់ចូលទៅស្រុកឡាំកុន ៗ

កាលដែលដីវយើលើកកងទ័ពទៅវាយយកស្រុកឡាំកុននោះ ឡៅពីនឹងខុងបេង ក៏នាំគួនអ៊ូ ទៀវហ៊ុយ ជូឡុងនឹងឡៅគី នូវទាហានទាំងពួងលើកទ័ពតាមដីវយើ ទៅបង្កប់នៅកណ្ដាលផ្លូវ ៗ ខុងបេង ក៏ឲ្យបំរើសេះទៅលបចាំមើលហេតុការណ៍ ដែលដីវយើនឹងហោយ៉ិនច្បាំងគ្នា ៗ បំរើសេះក៏ត្រឡប់មកប្រាប់ខុងបេងថា ឥឡូវ ដីវយើស្លាប់ទៅហើយ ៗ ខុងបេងឮដូច្នោះក៏ដឹងថា គំនិតដីវយើក្លែងកលឧបាយ ទើបនាំឡៅពីនឹងសេនាទាហានកាត់វាងផ្លូវទៅបង្កប់ក្បែរស្រុកឡាំកុន មិនឲ្យដីវយើដឹងសោះ ៗ លុះហោយ៉ិន លើកទ័ពទៅប្លន់យកបន្ទាយដីវយើ, ខុងបេងក៏ឲ្យទាហានស្រែកប្រាប់ទៅអស់ពួកអ្នកស្រុកថា ឥឡូវទ័ពហោយ៉ិនបែកមកហើយ ឲ្យប្រញាប់បើកទ្វារទទួល ៗ តិនកៀវគិតថាប្រាកដមែន ក៏ឲ្យទាហានបើកទ្វារទទួល ៗ ឡៅពីនឹងខុងបេងក៏ចូលទៅព្រមទាំងសេនាទាហានទាំងពួង ហើយឲ្យជូឡុងនឹងទាហានទាំងពួង ឡើងរក្សានាទីសើនបន្ទាយជាមាំមួនជុំវិញ ៗ

ឯជូឡុង កាលបើឃើញជីវយីលើកទាហានចូលមកដល់ជើងកំពែងបន្ទាយស្រុក ក៏ស្រែកប្រាប់ទៅថា ខ្ញុំបាទសូមអភ័យទោសនឹងជីវយីចុះ ដ្បិតខុងបេងប្រើខ្ញុំបាទលើកទាហានមកវាយយកស្រុកឡាំកុន បានមុនទៅហើយ ជីវយីឮដូច្នោះក៏ខឹងណាស់ ប្រើទាហានទៅតប្បាំងវាយទំលាយទ្វារទឹងកំពែង ជូឡុងឃើញដូច្នោះ ក៏ឲ្យទាហានបោលដុំថ្មបាញ់ធ្នូចម្រុះទៅជាខ្លាំងណាស់ ជីវយីឃើញថា ទាហាននឹងចូលដណ្ដើមយកកំពែងមិនបាន ក៏ថយទាហានត្រឡប់ទៅបន្ទាយវិញ ហើយប្រឹក្សានឹងទាហានទាំងពួងថា ឥឡូវខុងបេង នាំឡៅតីទៅដណ្ដើមស្រុកឡាំកុនបានហើយ ឯស្រុកកេងជីវនឹងស្រុកសុងយ៉ុងនោះ បើនឹងបង្អង់ទុកឲ្យយូរមិនលើកទ័ពទៅវាយយកឲ្យបានមុនទេ មុខជាខុងបេងនឹងលើកទាហានទៅវាយដណ្ដើមយកទៀត តទៅមុខយើងក៏គង់នឹងបានសេចក្ដីទញ់ទាល់ចង្អៀតនឹងធ្វើការ ទីប្រឹក្សាទាំងពួងយល់ឃើញត្រូវផង ជីវយីក៏ប្រើកាំឡេងឲ្យលើកទាហាន ៣ ពាន់ទៅវាយយកស្រុកកេងជីវ ឲ្យឡេងថងលើកទាហាន ៣ ពាន់ ទៅវាយយកស្រុកសុងយ៉ុង ។

កាលដែលជីវយីចាត់ប្រើកាំឡេង, ឡេងថងនោះ ទទួលបំរើសេះមកប្រាប់ជីវយីថា ឥឡូវខុងបេងឲ្យទាហានបន្ទំជាទាហានចោយ៉ិនកាន់ត្រានឹងទង់សម្រាប់ហៅទាហានក្នុងស្រុកកេងជីវ អ្នករក្សាស្រុកមិនបានដឹងកលឧបាយ ក៏ចាត់ទាហានបញ្ចូនទៅឲ្យហើយ ទៀវហ៊ុយលើកទៅវាយ

យកស្រុកកេងជីវ ឯស្រុកសុងយ៉ុង ក៏ខុងបេងឲ្យទាហានបន្ទំទៅនិយាយដូចគ្នា ទាល់តែហែហួនលើកទាហានមកឲ្យស្រុកសុងយ៉ុងនោះ គឺគួនអ៊ូលើកទ័ពទៅវាយ ជីវយីឮដូច្នោះក៏ភ័យស្លុតស្មារតីនិយាយថា ចុះខុងបេងបានគ្រាប់ទង់ជ័យពីណាមក ទៀតទៅថា កាលវាយបានស្រុកឡាំកុននោះ ត័នគៀវក៏នៅក្នុងកណ្ដាប់ដៃគេ ខុងបេងក៏ហៅយកគ្រាប់ទង់ប្រើឲ្យគួនអ៊ូ នឹងទៀវហ៊ុយទៅធ្វើការយ៉ាងនេះ ជីវយីឮដូច្នោះ ក៏រឹតតែតូចចិត្តទោមនស្សទើងខ្លាំងណាស់ ស្រែកដោយសំឡេងយ៉ាងខ្លាំងថា ខ្លួនអញជាជាតិទាហានបានមកធ្វើការដល់ប៉ុណ្ណោះហើយ មិនគួរខុងបេងមកដណ្ដើមយកស្រុកទាំង ៣ អន្ទើនេះសោះ អញត្រូវតែគិតសម្លាប់ខុងបេងចេញឲ្យបាន ហើយនឹងដណ្ដើមយកស្រុកទាំង ៣ ទៅឡើងស្ដាប់បង្គាប់ស្រុកកាំងតាំងឲ្យបានវិញ ឯពិសថ្នាំនោះក៏បណ្ដាលកំរើកឡើង ជីវយីក៏ដួលសន្លប់ចុះ មនុស្សក្នុងទីនោះក៏នាំគ្នាកែខែឲ្យដឹងខ្លួនឡើងវិញ ជីវយីក៏ឲ្យទៅហៅឡោសុកចូលមកប្រឹក្សាថា ឥឡូវខុងបេងគិតការក្បត់ដណ្ដើមយកស្រុកបានដល់ ៣ ដំបន់ហើយ យើងត្រូវតែលើកកងទ័ពទៅកំចាត់ឡៅពី, ខុងបេងចេញឲ្យបាន អ្នកនឹងយល់ឃើញប្រការម្ដេច ? ។

ឡោសុកថា ដែលចូច្ឆូបែកទ័ពទៅគ្រានេះ មិនមែននឹងស្ងៀមព្រមបាញ់តែម្ដងទេ មុខជានឹងរិះគិតសងសឹកវិញជាប្រាកដ ឯស៊ុនគួនទៅហ្វាយយើងឥឡូវនេះ ក៏លើកទ័ពទៅវាយយកស្រុកហ័បប៉ា យើង

ក៏មិនទាន់បានដឹងដំណឹងយ៉ាងណានៅឡើយ វេលានោះឡៅពីនឹងយើង ក៏ធ្វើដូចជាពួកក្រុមជាមួយគ្នា ដែលលោកនឹងលើកកងទ័ពទៅវាយកំចាត់ឡៅពី, ខុងបេងចេញនោះ ខាចក្រែងបួធ្ងដឹងទៅនឹងលើកទ័ពមកវាយយកស្រុកកាំងតាំងវិញ យើងក៏នឹងបានសេចក្ដីព្រួយការជា ២ ចំណែកប្រការ ១ ទៀត ឡៅពីក៏ជាមនុស្សធ្លាប់ស្គាល់រាប់អានគ្នាមកពីដើម ខាចឡៅពីនឹងនាំយកស្រុកទាំង ៣ ដំបន់នេះ ទៅប្រគល់ឲ្យបួធ្ង ហើយខ្លួនឡៅពី, ខុងបេង ក៏នឹងចូលគំនិតគិតទៅធ្វើការសង្គ្រាមនឹងបួធ្ងវិញ ស្រុកកាំងតាំងក៏នឹងអន្តរាយជាប្រាកដ ។

ដីវយីគបថា ដែលយើងធ្វើការសង្គ្រាមនឹងបួធ្ងគ្រានេះ យើងក៏បានខូចខាតសោហ៊ុយ ចំណាយជាមាសប្រាក់ស្បៀងអាហារ នឹងឲ្យបំណាច់រង្វាន់ទាហានជាច្រើន ហើយក៏បានលើកមកធ្វើការគេប្រាំងនឹងតោយិនដល់ស្រុកឡាំកុនទៀត ឯឡៅពីនឹងខុងបេងមិនបានខូចខាតរបស់ទ្រព្យសព្វសារៈពីអ្វីឬទាហានដល់ម្នាក់សោះ មកចាំតែលាងដៃទទួលយកស្រុកទាំងបីដំបន់នោះដោយងាយ មុខគួរឲ្យយើងមានសេចក្ដីខឹងខ្ញាំងណាស់ឡោសុកថា លោកមានសេចក្ដីខឹងនេះក៏គួរហើយ តែសុំបង្គង់ឲ្យខ្ញុំទៅនិយាយនឹងឡៅពី ខុងបេងដោយល្អសិន បើឡៅពីខុងបេងរឹងទទឹងប្រការម្ដេច សឹមរិះគិតគទៅទៀត ។

( នៅមានត )

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## រឿងព្រេងទាក់ទងដោយការស្ថាបនាប្រាសាទអង្គរវត្ត

### លោក ញ៉ែម-ខឹម រៀបរៀង

(តនឹងចប់)

នាងទិព្វសុតាចន្ទក៏ហុចក្រមាទៅឲ្យព្រះពិស្ណុការផ្លាស់ រួចនាងលើកពបុត្រឡើង ហោះកាត់អាកាស ៗ នាងយកបុត្រទៅឲ្យមុជទឹកក្រអូប, នាំចូលក្នុងលំនៅនាង, នាងយកសំលៀកបំពាក់ស្អាត ៗ មកស្លៀកពាក់ឲ្យ, យកម្ហូបសួគ៌មកឲ្យបុត្រញុំា រួចនាំចូលទៅក្នុងមហាប្រាសាទព្រះឥន្ទ្រ ៗ ព្រះវិស្ណុការក៏កើតសេចក្ដីសប្បាយអស្ចារ្យណាស់, ប៉ុន្ដែ លុះដល់កុមារចូលទៅក្នុងបន្ទប់សម្រាប់ចូលជួបនឹងព្រះឥន្ទ្រ, អ្នកក៏មានសេចក្ដីចាប់អារម្មណ៍ជាក្រៃលែងចំពោះលំអនៃបន្ទប់នោះ ជាហេតុនាំឲ្យកុមារទៅជាញ័រដៃជើង ( ចាញ់បុណ្យ ) ហើយដួលសន្លប់នៅទីនោះ ៗ នៅខណៈដែលព្រះឥន្ទ្រាធិរាជយាងចេញមកតាមនោះ ទ្រង់ទតឃើញកុមារ ទ្រង់សួរទៅនាងទិព្វសុតាចន្ទថា: "តើមនុស្សនេះជានរណា បានជាឯងនាំមកដល់ក្នុងប្រាសាទយើង?"

– ជាបុត្រខ្ញុំម្ចាស់ កាលដែលខ្ញុំម្ចាស់បានចុះទៅនៅឯស្ថានមនុស្សលោក រៀបការជាមួយនឹងលោកតាលឹម-សេង (នាងទិព្វសុតាចន្ទទូល)ៗ

– នែកុមារដ៏ប្រសើរ ចូរឯងក្រោកឡើង (ព្រះឥន្ទ្រមានព្រះបន្ទូល)ៗ

ព្រះពិស្ណុការក៏បានដឹងស្មារតីឡើង, ទនលុតជង្គង់នៅចំពោះព្រះភក្ត្រនៃស្តេចទេវតា ។ ព្រះឥន្ទ្រក៏នាំកុមារចូលទៅក្នុងបន្ទប់ប្រាសាទព្រះអង្គ, ហើយទ្រង់ត្រាស់សួរកុមារជាច្រើនបញ្ហា អំពីស្ថានមនុស្សលោកដែលកុមារបានរស់នៅ ។ ចម្លើយនៃព្រះពិស្ណុការ បានធ្វើឲ្យព្រះអង្គសព្វព្រះទ័យពន់ពេក ។ នៅពេលនោះ នាគទិព្វសុភាចន្ទ បានទូលព្រះឥន្ទ្របន្ថែមថា: បុត្រខ្ញុំម្ចាស់មានការប៉ិនប្រសប់ណាស់ គឺចេះគូរ, ចេះឆ្លាក់, ចេះសង់ប្រាសាទ, សង់បន្ទាយយ៉ាងល្អៗ នាំឲ្យមនុស្សលោកមានសេចក្តីកោតសរសើរស្ញប់ស្ញែងជាក្រៃលែង ។ ប៉ុន្តែ, ទាស់តែកូនខ្ញុំម្ចាស់ចេះចំណេះទាំងនេះដោយឥតបានរៀនពីគ្រូណាសោះ គឺវាចេះដោយសារគំនិតវាតែម្តង ។ ព្រះឥន្ទ្រឆ្លើយថា: " មិនហើយ, មនុស្សណាដែលចេះវិជ្ជាអ្វីឥតគ្រូ លោកប្រដូចទៅនឹងមនុស្សឆ្កួតៗ បើដូច្នេះ ចូរឯងនាំកុមារទៅជួបនឹងទេវបុត្រ ដែលជានាយកងជាងយើង, គេនឹងបង្រៀនកុមារឲ្យចេះមុខវិជ្ជាប្លែកៗ សិន រួចសឹមឲ្យកុមារ ត្រឡប់ចុះទៅស្ថានមនុស្សលោកវិញ, ព្រោះកុមារមានសញ្ជាតិជាមនុស្សលោក ពុំអាចមករស់នៅក្នុងទីនេះរហូតបានទេ " ។

ព្រះពិស្ណុការក៏ទៅនៅជាមួយនឹងពួកទេវបុត្រ ដែលជាអ្នកបច្ចេកទេសខាងវិជ្ជាសិល្បៈនឹងខាងសំណង់ ។ យុវជននោះខំរៀនគូរ, រៀនឆ្លាក់, រៀនលេងភ្លេងពីសំណាក់ទេវបុត្រជាគ្រូទាំងនោះ បានចេះទាំ

ស្ទាត់សព្វគ្រប់ទាំងអស់ គឺចេះសង់នាវាអាចបើកបរលើគោកបាន, ចេះធ្វាក់ប្រាក់, ធ្វាក់មាស, ចេះស្លដែកគ្រប់យ៉ាង ចេះវិជ្ជាលាយទឹក ហើយទឹកនោះ បើកាលណាគេចាក់ពយលើដីឥដ្ឋ ដីនេះនឹងក្លាយទៅជាថ្ម ។ សរុបសេចក្ដីទៅ គឺកុមារបានចេះចាំទាំងអស់ នូវមុខវិជ្ជាទាំងឡាយណា ដែលទេវបុត្របានបង្រៀន ហើយទេវបុត្របាននិយាយលើកទឹកចិត្តកុមារដូច្នេះទៀតផងថា: " កិច្ចការដែលឯងបានចេះធ្វើទាំងប៉ុន្មាននេះ អាចគង់ស្ថិតថេរ នៅបានអស់ពេលជាច្រើនពាន់ឆ្នាំ ។ ចំណែកឯការងាររបស់ខ្ញុំវិញ អាចមានជីវិតតែត្រឹមមួយរជ្ជកាលស្ដេចមួយព្រះអង្គ ។ ប៉ុណ្ណោះទេ, ឧបមាថា បើមហាក្សត្រអង្គណាមួយបានឡើងសោយរាជសម្បត្តិ ហើយទ្រង់សព្វព្រះរាជហឫទ័យ ឲ្យខ្ញុំសង់ប្រាសាទថ្វាយ, ខ្ញុំអាចសង់ថ្វាយបានមួយរំពេច ប៉ុន្តែនៅថ្ងៃណាមួយ ដែលព្រះមហាក្សត្រអង្គនោះទ្រង់សោយព្រះទិវង្គតទៅ, ប្រាសាទនោះក៏ត្រូវរលាយបាត់ក្នុងពេលនោះដែរ, ដូច្នេះឃើញថាឫទ្ធិអំណាចរបស់ឯង មានអានុភាពខ្លាំងលើសលុបលើឫទ្ធិអំណាចរបស់យើង ។

ទេវបុត្រក៏នាំសេចក្ដីទៅក្រាបទូលព្រះឥន្រ្ទាធិរាជ អំពីលទ្ធផលដ៏ប្រសើរក្រៃលែង ដែលកើតមានមកអំពីការអប់រំព្រះពិស្ណុការ ។ ព្រះឥន្រ្ទក៏ទ្រង់សព្វព្រះទ័យជាខ្លាំង ហើយទ្រង់ទទួលស្គាល់ថា ព្រះពិស្ណុការនឹងទៅជាអ្នកអប់រំ ជាអ្នកបង្ហាត់បង្រៀនមនុស្សលោកទាំងអស់ ដែលកាន់

លទ្ធិពុទ្ធសាសនា ។ បន្ទាប់មកព្រះឥន្ទ្រក៏មានព្រះពជនុង្ការថា :

" ជានសំណាន់ទាំងអស់ ដែលជាតិជាមនុស្សលោកមុននឹងកសាង អ្វី១ ត្រូវតែរៀបដង្ហាយថ្វាយព្រះពិស្ណុការសិន ។ ឯប្រដាប់ដង្ហាយមានដូចតទៅនេះ គឺស្រា ១ ដប, ប្រាក់ ១ បាទ (១ រៀល), ដើមចេក ៤ គង់, មានដោតម្ជុលនឹងស្លាលើនោះផង, សំពត់ស ៥ ហាត់, អង្ករ ១ ផ្តិលនឹងទៀន ១ បើជនណាមួយចាប់ធ្វើកិច្ចការអ្វី ១ មិនបានរៀបដង្ហាយនេះ ថ្វាយព្រះពិស្ណុការទេ អ្នកនោះឯងនឹងបើកភ្នែកពុំរួចឡើយ កាលបើឃើញពន្លឺថ្ងៃ; ដោយសារពពឹកភ្នែកគ្របភ្នែក ( ភ្នែកអៀស៊ី ) ។

កាលបើព្រះឥន្ទ្រមានបន្ទូលមកដល់ត្រង់នេះ ព្រះអង្គនឹកឃើញដល់ព្រះកេតុមាលា ។ ព្រះអង្គក៏ទ្រង់ហោះចុះមកកាន់ប្រទេសកម្ពុជា ។ ពេលនោះជារាត្រីកាល មនុស្សលោកទាំងឡាយ មានសេចក្តីភ្ញាក់ផ្អើលជាខ្លាំងដោយឃើញពន្លឺភ្លឺត្រចះត្រចង់នៅលើមេឃ ហើយក៏ដណ្តឹងសួរគ្នាថាតើនរណាធ្វើអ្វីឲ្យរំដួលនៅលើមេឃ ។ ព្រះឥន្ទ្រក៏បានចុះមកដល់ក្នុងប្រាសាទស្តេច ។ ពួកអ្នកយាមក៏រត់ទៅទូលព្រះបាទទេវង្សអស្ចារ្យថា:

" មានសត្វលោកពុំដែលស្គាល់ចុះមកពីស្ថានទេវតា, មានរបៀបហាក់ដូចជាមនុស្សលោក, ប៉ុន្តែ មានពណ៌ខៀវ, មានពន្លឺចាំងដូចជាភ្លើង, បានចុះមកក្នុងប្រាសាទ " ។

ព្រះបាទទេវង្សអស្ចារ្យ យាងប្រញាប់តម្រង់ទៅប្រាសាទព្រះអង្គ

ហើយទ្រង់បានស្គាល់ថាជាព្រះឥន្ទ្រ, ព្រះរាជទ្រង់ទនលុតជង្គង់ថ្វាយបង្គំព្រះឥន្ទ្រ ។ ទ្រង់សួរថាៈ តើព្រះអង្គមានស្គាល់ព្រះរាជបុត្រខ្ញុំឬទេ ?

- ទូលព្រះបង្គំពុំដែលស្គាល់ទេ ។

- តើព្រះកេតុមាលាមានកំណើតយ៉ាងដូចម្ដេច ?

- ពន្លឺខៀវមានលាតសន្ធឹងនៅលើមេឃ រូបស្រាប់តែមានកម្រង ផ្កាធ្លាក់មកលើអត្តមហេសីទូលព្រះបង្គំ ហើយតមកមហេសីទូលព្រះបង្គំមានផ្ទៃពោះ ឥឡូវប្រសូតមកមានវ័យចម្រើនហើយ ។

- ហ្នឹងហើយ! គឺកូនខ្ញុំ ជាចុះមកចាប់បដិសន្ធិ ។

ព្រួដូច្នោះ ព្រះបាទទេវង់អស្ចារ្យ ក៏ទ្រង់ត្រាស់ហៅ ព្រះកេតុមាលាឲ្យចូលមក ។ ព្រះឥន្ទ្រក៏ចាប់លើកព្រះរាជកុមារ ឲ្យអង្គុយលើព្រះឧរូ(ភ្លៅ) រួចទ្រង់មានព្រះបន្ទូលថា "ពីដើមខ្ញុំឈ្មោះហៅថា មឃមាណព ។ ខ្ញុំបានសង់ផ្លូវថ្នល់ សង់ទំនប់ទឹក, សង់សាលា, សង់ស្ពាន, ខ្ញុំបានធ្វើបុណ្យដាក់ទានដល់អ្នកក្រីក្រលំបាក ដោយផលនេះ ខ្ញុំបានកើតទៅជាព្រះឥន្ទ្រ ។ ដូច្នេះ ខ្ញុំមានចិត្តនឹកអាណិតមកដល់ប្រទេសកម្ពុជាណាស់ ព្រោះជាប្រទេសទើបនឹងកកើតឡើងថ្មី ។ ហើយតាំងពីពេលនោះ មកទល់ឥឡូវនេះ គ្មានមនុស្សខ្លាំងពូកែណាម្នាក់ មកសៅនៅគង់នគរនេះសោះ ដូច្នេះ, យើងនឹងជួយធ្វើឯងឲ្យបានសប្បាយ ហើយឲ្យ-នអាយុវែងផងផ្សេងអី, មនុស្សលោកសម័យនេះអាយុខ្លីណាស់, កម្រមាននរណាអាយុ

បានមួយរយឆ្នាំ ។ យើងនឹងនាំឯងយកទៅក្នុងប្រាសាទយើង ហើយឲ្យឯងចុះមុជទឹកក្នុងអាងមួយ ដើម្បីឲ្យបានអាយុវែង " ។

ព្រះឥន្ទ្រក៏លើកពព្រះកេតុមាលា ហោះទៅកាន់ស្ថានទេវតា ។ នៅក្នុងសួនច្បារព្រះឥន្ទ្រមានអាងទឹកមួយ, ព្រះឥន្ទ្រក៏យកព្រះកេតុមាលាទៅឲ្យមុជទឹកក្នុងអាងនោះមួយថ្ងៃ ៧ ដង លុះគ្រាតែគ្រប់ ៧ ថ្ងៃ ។ បន្ទាប់មក ព្រះឥន្ទ្រនាំព្រះកេតុមាលាចូលទៅក្នុងប្រាសាទព្រះអង្គ រួចព្រះឥន្ទ្រអញ្ជើញព្រាហ្មណ៍ ៧ នាក់ឲ្យមកសូត្រសែកមន្តគាថា និងប្រោះព្រំទឹកមន្តទៅលើព្រះកេតុមាលា ដើម្បីឲ្យបានអាយុមួយរយឆ្នាំ ។

កាលបើពិធីនេះ បានចប់សព្វគ្រប់ហើយ ព្រះឥន្ទ្រក៏ទ្រង់បង្គាប់ឲ្យគេទឹមព្រះកជរថបញ្ជិះព្រះកេតុមាលា បរហោះព័ទ្ធជុំវិញប្រាសាទព្រះអង្គ ដើម្បីឲ្យព្រះកេតុមាលាអាចមើលឃើញលំអប្រាសាទសព្វគ្រប់ទាំងអស់ ។

កាលបើព្រះកេតុមាលា បានសង្កេតមើលប្រាសាទព្រះឥន្ទ្រសព្វគ្រប់អស់ហើយ, នាយសារថីក៏នាំព្រះកេតុមាលាទៅមើលក្រោលគោសួគ៌ទៀត ។

ព្រះឥន្ទ្រក៏សួរទៅព្រះកេតុមាលាថា: " អ្នកពេញចិត្តនឹងវត្ថុអ្វី ៗ ដែលអ្នកបានឃើញឬទេ ? "

– ខ្ញុំមានសេចក្ដីស្ញប់ស្ញែងណាស់ !

– ដូច្នេះ. ខ្ញុំប្រគល់អាណាចក្រកម្ពុជានេះឲ្យឯង ។ ហេតុនេះ

បើឯងពេញចិត្តនឹងប្រាសាទណាមួយដែលឯងបានឃើញ ហើយចង់សង់ប្រាសាទមួយនៅប្រទេសកម្ពុជាឲ្យល្អដូច្នេះ, ចូរឯងគ្រាន់តែសំដែងទឹកចិត្តឡើង, យើងនឹងបញ្ជូនស្ថាបនិកម្នាក់ ឲ្យទៅសង់ឲ្យឯងនៅក្នុងនគរឯងមួយរំពេច ។ នៅពេលនោះ ព្រះកេតុមាលាទើបតែនឹងមានអាយុ១៤ ឆ្នាំ ។ ដូច្នេះ កុមារមានសេចក្ដីតក់ស្លុតខ្លាចព្រះឥន្ទ្រពន់ប្រមាណ ហើយបានគិតឃើញដូច្នេះថា "នៅក្នុងនគរអញ, អញពុំត្រូវធ្វើអ្វីឲ្យល្អជាងប្រាសាទព្រះឥន្ទ្រទេ បើសិនជាអញចង់ធ្វើអ្វីឲ្យល្អជាង ឬប្រហែលព្រះអង្គនោះព្រះអង្គមុខជាអាក់អន់ព្រះទ័យពុំខាន " ។

គិតដូច្នេះហើយ ព្រះកេតុមាលាឆ្លើយថា " ទូលព្រះបង្គំចង់ឲ្យគេសង់ប្រាសាទមួយ ដែលមានលំអប្រហែលក្រោលគោព្រះអង្គ " ។

ព្រះឥន្ទ្រក៏ទ្រង់ព្រះសម្រួលថា:

" ក្រោលនេះជារបស់ល្អចំពោះភ្នែកចៅឯងហើយឬ ?

ហើយទ្រង់មានព្រះបន្ទូលថា:

" ចៅឯងជាជាតិមនុស្សលោក ពុំអាចស្ថិតនៅក្នុងស្ថានលើនេះបានរហូតទេ យើងនឹងបញ្ជូនចៅឯងចុះទៅកាន់នគរកម្ពុជា ហើយត្រូវឯងសង់ប្រាសាទឲ្យព្រះរាជបុត្រយើងមួយ ឲ្យមានសោភណភាពល្អជាងក្រោលគោយើង, កាលបើចៅឯងសង់រួចស្រេចហើយ យើងនឹងចុះទៅធ្វើជាអធិបតីក្នុងពិធីរៀបចំអភិសេកព្រះរាជបុត្រយើងឲ្យឡើងសោយរាជ្យ " ។

កាលបើព្រះពិស្ណុការ បានពិនិត្យមើលគ្រោលគោព្រះឥន្ទ្រសព្វគ្រប់ហើយ, ព្រះឥន្ទ្រក៏ទ្រង់ព្រះរាជបញ្ជា ឲ្យគេរៀបចំទឹមព្រះរាជរថព្រះអង្គបញ្ជូនព្រះកេតុមាលា និងព្រះពិស្ណុការចុះមកកាន់ផែនដីនឹងនគរកម្ពុជា ។

ព្រះពិស្ណុការក៏ចាប់សង់ប្រាសាទភ្នាម គឺនៅ ព.ស. ៦២០ ។ លោកបានបង្គាប់ឲ្យជីកស្នាមភ្លោះ យកអាចម៍ដីចាក់គរលើគ្នាយ៉ាងខ្ពស់ រួចទើបព្រះពិស្ណុការយករូបចម្លាក់ផ្សេង ៗ ទៅបិតលើដីនោះគ្រប់ទិសទាំងអស់ ។

ដំណាលពីកូនមេកូម៌ម្នាក់ឈ្មោះសុវណ្ណ ។ អ្នកកម្លោះបានចូលធ្វើជាកម្មករព្រះពិស្ណុការ ។ លុះសុវណ្ណបានយល់ការយ៉ាងចំណេះធ្វើការខ្លួនឯងកើត, ព្រះពិស្ណុការក៏ដឹកទូកទៅកាន់សមុទ្រ ដើម្បីរកសម្បកខ្យងមកដុតធ្វើជាកំបោរដើម្បីបូកប្រាសាទ ។ លុះត្រឡប់មកវិញ, មកដល់ត្រង់សំពេងសែន ស្រុកកំពង់លែង, ទូកក៏ត្រូវលិចទឹក ។ ព្រះពិស្ណុការក៏បានស្តារដំនិះនោះឡើង ប៉ុន្តែឥតកើបយកសម្បកខ្យងវិញទេ ។ អាស្រ័យហេតុនោះហើយ បានជាសព្វថ្ងៃនេះ គេឃើញមានសម្បកខ្យងជាច្រើនគរកប់នៅក្នុងដីក្នុងភូមិសំពេងសែន ។ ចាប់តាំងពីច្រើនឆ្នាំណាស់មកហើយ, អ្នកស្រុកក្នុងភូមិនោះ តែងបបួលគ្នារើសយកសម្បកខ្យងនោះមកដុតធ្វើជាកំបោរ, ប៉ុន្តែសម្បកខ្យងនៅតែមានចំនួនជាច្រើនក្រៃលែងរហូតមកដល់សព្វថ្ងៃនេះ ។

ថ្ងៃក្រោយមកទៀត ព្រះពិស្ណុការក៏ធ្វើដំណើរទៅកាន់សមុទ្រ ដើម្បី

រើសសម្បុកខ្យងទៀត ។ ប៉ុន្តែម្តងនេះ មានទូកសំពៅច្រើនណាស់ហើយ ក៏បានសម្បុកខ្យងមកជាច្រើនក្រៃលែង ។ បន្ទាប់មកទៀត, ព្រះពិស្ណុការក៏ចេញសំពៅបីដើម្បីទៅរកគ្រាប់ល្ង, ប៉ុន្តែ លុះត្រឡប់មកមានខ្យល់ព្យុះបោកបក់សំពៅមួយលិចទៅត្រង់កោះកញ្ជាន ខាងលិចដូនទ្រី ។ ព្រះពិស្ណុការក៏ចាក់គ្រាប់ល្ងក្នុងសំពៅនោះចោលទាំងអស់ រួចក៏ធ្វើគ្រាប់ល្ងនោះឲ្យរឹងក្លាយទៅជាកោះមួយ ។ ហេតុនោះហើយ, បានជាសព្វថ្ងៃនេះ គេសង្កេតឃើញក្នុងកោះកញ្ជានមានពណ៌ខ្មៅ ដូចជាគ្រាប់ល្ង, គ្មានដីអ្វីទៀតនៅលាយជាមួយឡើយ ។

ចំណែកឯគ្រាប់ល្ងនៅក្នុងសំពៅពីរទៀត, ព្រះពិស្ណុការក៏យកទៅលាយបូកពីលើប្រាសាទដី ដែលលោកបានសង់នោះ ។ ដីនោះក៏បានក្លាយទៅជាថ្មមួយរំពេច ។ ដើម្បីនឹងសង់ប្រាសាទ ព្រះពិស្ណុការឥតចាំបាច់ចងខ្នោ, ដាំសសរមួយម្តង ៗ ដូចជាយើងទេ គឺលោកយកដីមកសង់ជាប្រាសាទ ៥ ជាន់តែម្តង ទើបយកទឹកថ្នាំលាយទៅលាបពីលើតួប្រាសាទដីទាំងមូលតែម្តង ៗ ប្រាសាទនោះក៏ក្លាយទៅជាថ្ម ។

អាស្រ័យហេតុនេះហើយ បានជាយើងឃើញត្រង់ៈង់កោងនៃដំបូលប្រាសាទឥតមានរនូតឬសសរទ្រពីក្រោមទេ ។

លុះការស្ថាបនាបានរួចស្រេចកាលណា, ព្រះពិស្ណុការក៏លាបថ្នាំលើរូបចម្លាក់ទាំងនោះ, តម្រូវទៅតាមពណ៌ផ្សេងៗ ធ្វើឲ្យប្រាសាទមាន

លំអឡើងយ៉ាងគ្រប់គ្រាន់ គឺល្អដូចជាក្រោលគោព្រះឥន្ទ្រ ។

ព្រះកេតុមាលាពេញចិត្តនឹងប្រាសាទនោះណាស់, បានពោលសរសើរព្រះពិស្ណុការជាច្រើន ហើយបានសុំឲ្យព្រះពិស្ណុការសង់ប្រាសាទឯទៀតជាច្រើនតាមដោយរូបចម្លាក់យ៉ាងឆើតឆាយ ។

ព្រះឥន្ទ្រាធិរាជដោយមានពួកទេវតាជាច្រើនតាមដង្ហែផង បានយាងចុះមកស្ថានក្រោម ប្រសិទ្ធិពរអភិសេកព្រះរាជបុត្រព្រះអង្គ ហើយព្រះអង្គក៏ថ្វាយព្រះនាមថា អរិដ្ឋពលពាហនោ (ព្រះកេតុមាលា) រួចទ្រង់ហៅឈ្មោះប្រទេសខ្មែរយើងថា កម្ពុជាដូចសព្វថ្ងៃនេះ ។

នៅពេលក្រោយមក, ព្រះកេតុមាលាទ្រង់បានសង្កេតឃើញកំពូលប្រាសាទមួយពុំសូវត្រង់ ទ្រង់ក៏មានបន្ទូលប្រាប់ព្រះពិស្ណុការឲ្យឡើងតម្រង់កំពូលនោះ ។ ព្រះពិស្ណុការបានឆ្លើយថា "សូមព្រះអង្គទ្រង់ប្រើស្រីម្នាក់ ឲ្យយកផ្លៃឃ្លោកទុំទៅរាយកំពូលនោះៗនឹងងើបត្រង់ឡើងវិញ" ។

ទ្រង់ព្រះសណ្ដាប់ដូច្នេះ ព្រះកេតុមាលាក៏ទ្រង់ព្រះពិរោធជាខ្លាំង ។ ព្រះអង្គទ្រង់បានបញ្ចេញនូវព្រះសូរសៀងយ៉ាងខ្លាំងៗថា "តើឯងចង់និយាយយ៉ាងម៉េច, កំពូលប្រាសាទធ្វើសុទ្ធតែអំពីថ្ម, ឯងប្រាប់ឲ្យយកផ្លៃឃ្លោកទុំទៅរាយតម្រង់?" ។ ចំណែកឯព្រះពិស្ណុការក៏ខឹងនឹងព្រះរាជាដែរ ហើយបានឆ្លើយថា:

បើព្រះអង្គមិនទ្រង់ជឿទូលព្រះបង្គំទេ សូមឲ្យកំពូលប្រាសាទស្ពឹក

នៅតែទ្រេតដូច្នេះទៅ ។ ហើយតទៅមុខទៀត, សូមឲ្យកុំពូលប្រាសាទដូចជាប្រាសាទអង្គរនេះទ្រេតដូចជាប្រាសាទនេះដែរ ៗ

ពេលក្រោយបន្តិចមកទៀត, ព្រះកេតុមាលាបានប្រគល់ដែកទម្ងន់បីហាប, ដើម្បីឲ្យព្រះពិស្ណុការធ្វើព្រះខ័នមួយ ជានិមិត្តរូបនៃតេជានុភាពព្រះអង្គថ្វាយព្រះអង្គ ៗ ព្រះពិស្ណុការបានយកដែកនោះទៅសូរំលាយនៅសល់តែល្មមធ្វើព្រះខ័នតូចមួយ, មានមុខស្តើងជាងស្លឹកស្រូវទៅទៀត ប៉ុន្តែមុតជាក្រៃលែង គឺថាបើគេយកព្រះខ័ននេះទៅកាប់ខ្លួនមនុស្សជាពីកំណាត់, គេពុំអាចមើលដឹងជាខ្លួនមនុស្សដាច់ឡើយ, គេស្មានថាគេកាប់ឥតត្រូវខ្លួនទេ, មនុស្សនោះប្រហែលជានៅនិយាយបានដូចពីដើម, ប៉ុន្តែបើគេយកដៃទៅប្រាន, ខ្លួនមនុស្សនោះនឹងដាច់ធ្លាក់ជាពីរភ្លាម ៗ ម្យ៉ាងទៀត, បើគេយកពាងមួយធ្វើអំពីដីមានដាក់ទឹកពេញ គេអាចកាប់ពាងនោះឲ្យដាច់ជាពីរបាន ដោយឥតធ្វើឲ្យទឹកហូរចេញបានឡើយ លុះតែគេយកដៃទៅពាល់ពាងនោះ ទើបពាងបែកដាច់ជាពីរហើយ ទឹកក៏កំពប់ចេញ ៗ

ព្រះពិស្ណុការបានយកព្រះខ័នដែលទើបនឹងធ្វើហើយ ទៅលត់ទឹកយ៉ាងត្រឹមត្រូវ រួចក៏យកទៅថ្វាយព្រះកេតុមាលា ៗ ព្រះកេតុមាលាកាលបើទតឃើញទំហំព្រះខ័នភ្លាម ក៏ទ្រង់ក្រោធជាខ្លាំងក្រៃលែង, ព្រមទាំងទ្រង់បន្ទោសព្រះពិស្ណុការយ៉ាងគំរោះគំរើយ នៅចំពោះមុខនាហ្មឺនសព្វ

មុខមន្ត្រីទាំងអស់ថា " អ្នកឯងបានលួចដែកខ្ញុំ យកទៅប្រើជាប្រយោជន៍ផ្ទាល់ខ្លួន បានជាអ្នកឯងធ្វើព្រះខ័នឲ្យយើងតូចដូច្នេះ! ។ ព្រះពិស្ណុការក៏ខឹងប្រឡោតតូងតាងដែរ ហើយឆ្លើយថា "ខ្ញុំលែងនៅប្រទេសកម្ពុជាទៀតហើយ, ខ្ញុំនឹងត្រឡប់ទៅនៅឯប្រទេសចិននោះវិញ " ។

ថាដូច្នេះហើយ, ព្រះពិស្ណុការក៏ក្រោកដើរចេញ ដោយបង្អួសមុខព្រះខ័នលើក្តារ ។ លុះព្រះពិស្ណុការចេញផុតទៅ, គេសង្កេតឃើញក្តារដាច់ជាពីរដោយអំណាចមុខព្រះខ័នដែលព្រះពិស្ណុការបានអូសពីលើ ។ ទ្រង់ទតឃើញដូច្នោះ, ព្រះកេតុមាលាក៏ត្រាស់បង្គាប់ឲ្យគេរត់តាមស្រែកហៅព្រះពិស្ណុការ ហើយទារយកព្រះខ័នមកថ្វាយព្រះអង្គវិញ ។ ប៉ុន្តែព្រះពិស្ណុការប្រកែកពុំព្រមឲ្យ ហើយគ្រវែងចោលទៅកណ្តាលទន្លេសាប រួចក៏ចុះសំពៅបើកក្តោងសំដៅទៅស្រុកចិន ដែលជាស្រុកកំណើតរបស់គាត់ ។

នេះហើយជារឿងព្រះពិស្ណុការ ដែលមនុស្សភាគតិចណាស់បានដឹង, ហើយដោយសារការពុំដឹងនេះហើយ បានជាមនុស្សភាគច្រើនបានយល់ខុសថា គឺទេវតាដែលបានកសាងប្រាសាទអង្គរ ។

---

## រឿងព្រេងប្រទេសចិន

# រឿងអំពីបព្វជិតនឹងដើមព័រ

ភិក្ខុ ម៉ែន-វៀម

*សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ*

ប្រែចាកភាសាអង់គ្លេស

---

*នៅក្នុងទីផ្សារនៃភូមិមួយ, ថ្ងៃមួយមានកសិករម្នាក់ ដែលមានរទេះផ្ទុកពេញទៅដោយផ្លែព័រដ៏ល្អ ៗ ។ មនុស្សទាំងឡាយ បានមកមើលផ្លែព័រនោះ ជិតជុំវិញរទេះគាត់ ព្រោះគេទាក់ចិត្តចំពោះផ្លែព័រទាំងនោះជាខ្លាំង ។ ម្ល៉ោះហើយ កិត្តិស័ព្ទរបស់គាត់ ត្រូវតែផ្សាយទៅក្នុងទីពប់ម៉ៃល៍ ដោយសារតែគុណភាពនៃផ្លែឈើរបស់គាត់នោះ ។*

*លាយជាមួយគ្នានឹងកិត្តិស័ព្ទចំពោះគុណភាពនៃផ្លែឈើ, កសិករបានទទួលនូវកិត្តិនាមខាងសេចក្ដីកំណាញ់ស្វិតស្វាញ នឹងខាងការវាយតម្លៃផ្លែឈើរបស់ខ្លួនយ៉ាងខ្ពស់ថែមទៀត ។*

*កាលដែលហ្វូងមនុស្ស កំពុងតែឈរជិតជុំវិញរទេះគាត់តាមរបៀបនេះ ស្រាប់តែមានបព្វជិតចពចរ រខេករខាកចាស់កន្ទ្របមួយអង្គ និមន្តជែកគេ-ឯង មកទតផ្លែព័រនោះដែរ ។ ដោយការកំសត់អត់ឃ្លានខ្លាំង; ស្រមណ៍អង្គនេះ បានសុំបិណ្ឌបាតផ្លែព័រមួយពីកសិករ ។ ប៉ុន្តែ កសិករជាអត្តទត្តបុគ្គលប្រកបដោយសន្តានចិត្តអាក្រក់ បានប្រកែកមិនព្រម*

ប្រគេនសោះ ៗ បព្វជិតកំសត់ ដោយគ្មានសេចក្ដីទៀយណាយចំពោះចម្អើយដ៏គ្រោតគ្រាត ដែលលោកបានទទួល, មិនសុខចិត្តនិមន្តចេញពីមុខរទេះ នឹងការសំឡឹងមើលនូវផ្លែឈើនោះសោះឡើយ ៗ

កសិករ ទៅជាក្ដៅក្រហាយចំពោះអាកប្បកិរិយាបែបនេះជាខ្លាំង, ថែមទាំងដេរប្រទេចលោក ហៅលោកតាមឈ្មោះដែលមិនជាទីគាប់ចិត្តជាច្រើនបែបទៀត ៗ តែស្រមណ៍ នៅតែឈរតាមរបៀបដដែល ហើយមានថេរដីកាថា: "ម្នាលអ្នកជនបទ ផ្លែពីររបស់អ្នកមានចំនួនជាច្រើនរយ, តាមពិត បើអ្នកប្រគេនអាត្មាតែមួយមក ក៏អ្នកគ្មានបង់ខាតអ្វីដែរ!" ៗ

ជនខ្លះនៅក្នុងហ្វូងនោះ និយាយឡើងនៅពេលនោះថា: "យី! ម៉េចអ្នកមិនប្រគេនលោកមួយទៅ? បើមិនឲ្យលោកអាល្អទេ ក៏គួរឲ្យអាណាមួយដែលទន់ទៅ អ្នកមិនខាតទេ!" ៗ

កសិករ ដោយរឹតតែក្ដៅខ្លាំង ព្រមទាំងមុខរឹងផងនោះ ក៏បររទេះទៅមុខទៀត, គាត់ពោលថា: "មិនលេងទេណា! ខ្ញុំដែលដាំដើមឈើនេះនឿយណាស់, ខំធ្វើការណាស់, ខ្ញុំគ្មានធន: នឹងដឹកយកផ្លែពីរនេះមកកាន់ទីផ្សារ ដើម្បីចែកដោយសប្បុរសនោះទេ!" ៗ

មនុស្សដទៃទៀតក្នុងទីផ្សារ ក៏ចាប់និយាយអ៊ូអរឡើង, ខ្លះកាន់ជើងកសិករ ខ្លះកាន់ជើងបព្វជិត ៗ សំរេចមនុស្សទាំងនោះ បានទៀវិញ

អឺងកងទៀង, មានការពិភាក្សា មានការគំហកដាក់គ្នា ៗ សួរអ៊ីអែ ចេះតែខ្លាំងឡើង ៗ ៗ ទីបំផុត ស្រាប់តែមានជនម្នាក់ដើរចូលទៅ ហើយយកប្រាក់មួយយ៉័ន (Coin) ហុចទៅអ្នកស្រែ ដោយពោលថា: " អ្នកឯងគាប់ចិត្តនឹងទិដ្ឋភាពដ៏អាប់អួរ ចំពោះកុសលកម្មដ៏តូចតាចនេះឬ ? ហ៎ ! នេះប្រាក់, ប្រគេនផ្លែព័រទៅលោកមួយទៅ ! " ៗ

កសិករបានហុចផ្លែព័រមួយទៅបព្វជិត ហើយលោកបានទទួលយកនូវអំណោយនេះ ដោយអាការទុនយ៉ាងទាប ៗ រួចហើយ លោកមានថេរដីកាទៅកាន់ប្រជុំជននោះថា " អាត្មាមានការស្មុគ្រស្មាញពិបាកចិត្តខ្លាំងណាស់ ចំពោះមនុស្សដែលមានកំពូលសំណាងល្អ ដូចជាអ្នកលក់ផ្លែព័រនេះ ហើយត្រូវរាប់ជាអ្នកកំណាញ់ស្វិតរឹតតៀត មិនព្រមចំណាយសូម្បីតែផ្លែព័រមួយយ៉ាងនេះ; អាត្មាដែលមកសុំបិណ្ឌបាតផ្លែព័រមួយនេះ បានបរិច្ចាគតែគ្រប់យ៉ាងអស់រលីង ទៅពេលដែលអាត្មាមកបួស; អាត្មាគ្មានបច្ច័យទេ, គ្មានផ្ទះទេ, គ្មានគ្រួសារទេ, ប៉ុន្តែអ្វីដែលអាត្មាមាន អាត្មាតែងយកចែកដល់អ្នកដទៃទៀត ដោយសោមនស្ស; ដើម្បីជាតឹកតាង អាត្មាមានដើមព័របរិបូណ៌ដោយផ្លែមួយដើម, អាត្មាសុំឲ្យអស់អ្នកឈររង់ចាំមួយភ្លែត ដើម្បីអាត្មានឹងចែកឲ្យអ្នកគ្រប់គ្នា ជាមួយនឹងអាត្មា ៗ

ឮដូច្នេះ, បុរសម្នាក់សួរថា " ចុះបើលោកតា មានផ្លែព័រច្រើន

មើចក៏ចាំបាច់មកសុំគេ? ។ "ទេ! ដំបូងអាត្មាត្រូវដាំកសិន!" (បញ្ជិតឆ្លើយ) ។

ក្លាមនោះ ព្រះសង្ឃអង្គនេះ បានឆាន់ផ្លែពីរដែលគេប្រគេននោះ រួចបន្ទេចគ្រាប់មួយចេញមក ។ លោកជីករណ្ដៅមួយទៅកន្លែង ហើយដាក់គ្រាប់ទៅក្នុងរណ្ដៅ, រួចលុបដីដោយថ្នមៗ ឲ្យពេញរណ្ដៅនោះ ។ លុបដីរួច លោកមានថេរដីការថា "អាត្មាត្រូវការទឹក" ។ ឃើញដូច្នោះ, មនុស្សក្នុងហ្វូង នាំគ្នាសើចហោះឡើង, ប៉ុន្តែមានកុមារម្នាក់បានរត់យកក្អមទឹកមួយមកប្រគេនលោក ហើយលោកក៏ស្រោចទៅលើកន្លែងដាំនោះ ។

តែមួយភ្លែតប៉ុណ្ណោះ, គេបានឃើញពន្លកខៀវតូចមួយ ទំលុះស្រទាប់ដីចេញមកក្រៅ ។ ពន្លកបានចាប់លូតលាស់ខ្ពស់ឡើងៗ យ៉ាងរហ័ស ។ សាខាទាំងឡាយ ក៏ប្រាកដលើក្នុនរុក្ខជាតិ ហើយស្លឹកទាំងឡាយ ក៏ចេញពីមែកទាំងនោះមក ។ ពន្លក បានក្លាយទៅជាដើមឈើរួចចេះតែងើបខ្ពស់ឡើងៗ ។ ស្លឹកដ៏ខៀវងងឹត ចេះតែលេចចេញមក, រួចចេញត្រួយ . . . បន្ទាប់មកចេញជាផ្កាពីរ ។ ផ្កាបានជ្រុះអស់ ក្ដិបពីរក៏ជាក់ស្ដែងឡើង ។ ហើយក្ដិបចេះតែរីកធំឡើង ដកបដល់ពេញរូបរាង ។ ផ្លែដ៏ល្អស្រស់ បានទម្ងន់ធ្ងៃមែកឲ្យទោរទន់ចុះ ដោយសារចំនួនច្រើនខ្នួន ។

ឃើញយ៉ាងនេះ ហ្វូងមនុស្សបានទះដៃឡើង ដោយសោមនស្ស

ចិត្ត ។ បព្វជិតដែលមានព្រះកត្រើកថ្វាដោយសេចក្តីសប្បាយ បានបេះផ្លែព័រមួយម្តង ៗ ចែកទៅក្រុមប្រជាជន តាមរបៀបអំណោយ ។

កសិករលក់ផ្លែព័រ ដែលកំណាញ់មិនព្រមប្រគេនអ្វីទៅព្រះសង្ឃនោះ ក៏ឈរមើលប្រហមាត់ធ្ងង ៗ ទីបំផុត, ព្រះសង្ឃបានបេះផ្លែព័រចុងក្រោយមួយ អំពីរុក្ខជាតិដ៏អស្ចារ្យហើយចំណាយចេញទៅ ។ អស់ផ្លែហើយ លោកទាញយកពូថៅដៃមួយពីចង្កេះលោក ទៅកាប់រំលំឈើនោះ ។ លោកលើឈើនោះ និមន្តចេញពីផ្សារ, ចេញពីហ្វូងមនុស្ស ដែលកំពុងតែទំពាស៊ីផ្លែព័រ ។

កសិករលក់ផ្លែព័រ ក៏ដូចជាអ្នកដទៃទៀតដែរ បានឈរមើលបព្វជិតកំសត់ លុះគ្រាលោកនិមន្តផុតពីកន្ទុយភ្នែក លែងមើលឃើញ ។ ពេលនោះ គាត់ងាកត្រឡប់មកមើលរទេះគាត់វិញ ស្រាប់តែទៅជារន្ធត់ញាប់ញ័រ ដោយឃើញរទេះខ្លួនទទេស្អាត, បាត់ផ្លែព័រអស់ សូម្បីតែមួយក៏មិនសល់ ! ។

ក្នុងពេលភ្លាម ៗ នោះ គាត់បានយល់នូវហេតុការណ៍ ដែលកើតឡើងថា ផ្លែព័រដែលលោកតាកញ្ចាស់យកមកចែកដោយសប្បុរសចិត្តនោះ គឺបានមកពីក្នុងរទេះគាត់ ។ ផ្លែឈើទាំងនោះ សុទ្ធតែជារបស់គាត់ ។

កាលគាត់ឈរពិចារណាអំពីព្រឹត្តិការណ៍ នៃហាយនភាពក្នុងទីនោះ, កសិករបានឃើញថា ទូករទេះរបស់គាត់ បាត់ម្ខាងទៅហើយ ។ គាត់រក

មើលដោយពិនិត្យពិច័យទៅ ក៏បានកត់សំគាល់ថា ទូករទេះនោះ ត្រូវបញ្ជិតកាប់ពោលដោយព្រៅដៃលោកទៅហើយ ។ ដូច្នេះ គឺជាទូករទេះនេះហើយ ដែលបញ្ជិតបានក្រលៃលំពោល នៅពេលមុនពេលលោកនិមន្តចេញពីប្រជុំជន ។

កសិករលក់ផ្លែព័រ ទៅជាប្រឡាតខឹងយ៉ាងពន្ទឹក, គាត់រត់ចេញពីផ្សារ ទៅតាមបញ្ជិត, តែគាត់ឥតជួបលោកឡើយ គាត់បានឃើញទូករទេះបាក់បែកមួយ នៅតាមផ្លូវក្បែរចិញ្ចើមថ្នល់ ។

កាលដែលមហាជននៅទីផ្សារ បានយល់ច្បាស់នូវការកំផ្លែងសួននៃបញ្ជិតចកបរនេះហើយ ក៏កើតមានការច្រលច្របល់យ៉ាងខ្លាំង មានតែអ្នកស្រែលក់ផ្លែព័រតែម្នាក់ឯងប៉ុណ្ណោះទេ ដែលមិនអាចហាមាត់សើចដូចគេបាន ។

ចំណែកលោកតាចាស់ គ្មានអ្នកណាឃើញ–ជួបក្នុងចំណែកណាមួយនៃស្រុកស្រែនោះទៀតឡើយ ។

# រដ្ដើ ៗ ធ្វើឲ្យចាស់គោអស់

## លោក ញូង·សឿង រៀបរៀង

ពូប្រេស មីងប្រែង គាត់មានកូនតែពីរនាក់ប្រុស ១ ស្រី ១ ៗ គាត់បានរៀបចំកូនប្រុសឲ្យមានប្រពន្ធ នៅភូមិឆ្ងាយបន្តិចពីភូមិរបស់គាត់ ព្រមទាំងបានចែកកេរ្តិ៍មរតកមានស្រែនឹងគោជាដើម ឲ្យកូនប្រុសគាត់តាមសមគួរដល់ធនធានដែលគាត់មាន ៗ កាលកូនប្រុសបែកផ្ទះសម្បែងទៅនៅខាងប្រពន្ធគេទៅ ពូ-មីង គាត់នៅតែ ៣ នាក់នឹងកូនស្រី ៗ

លំដាប់តមក មិនយូរប៉ុន្មាន, មានគេចូលមកគិតគូរដណ្តឹងកូនស្រីគាត់ ៗ ក៏ព្រមព្រៀងឲ្យហើយក៏បង្គាប់ឲ្យខាងប្រុសធ្វើផ្ទះមួយខ្នង ដើម្បីនឹងរៀបចំមង្គលការ ៗ

នៅពេលដែលកូនប្រសាបានសង់ផ្ទះរួចស្រេចហើយ កិច្ចអាពាហ៍ពិពាហ៍ ក៏ផ្តើមឡើងយ៉ាងអឹកអធឹកតាមគន្លងប្រពៃណី ៗ លុះរៀបមង្គលការកូនស្រីហើយបានប្រហែលកន្លះឆ្នាំ, ពូ ប្រេស មីងប្រែង ក៏លក់ផ្ទះថ្មីដែលកូនប្រសាសង់ជូននោះទៅ ដើម្បីយកប្រាក់កាសទិញគោមួយនឹមឲ្យកូនធ្វើស្រែ ផ្សំនឹងគោគាត់មួយនឹមដែលមានស្រាប់ពីមុនមកនោះ ឲ្យបានជាពីរនឹម ហើយគាត់ឲ្យកូនមកនៅផ្ទះចាស់ជាមួយ, គាត់នៅល្វែងខាងមុខ កូនប្រសានៅល្វែងខាងក្រោយ ៗ ឯផ្ទះចាស់គាត់នោះ មិនសូវជាមាំមួនប៉ុន្មានទេ ជើងសសរខ្លះដីស៊ីពុកអស់ហើយ តែគាត់បាន

ទល់ទ្រនៅជាបណ្ដោះអាសន្នសិនទៅ គាត់ថាចាំរកស៊ីធូរធារបន្តិច សឹមលៃលកធ្វើផ្ទះថ្មីមួយទៀតឲ្យបានសុកសុម ។

វេលាសម័យថ្ងៃមួយ ពូ ប្រេស មឹង ប្រែង ក្រាក់ឡើងពីព្រលឹមស្រាងៗ ក្រឡេកមើលក្រោមផ្ទះ ស្រាប់តែបាត់គោអស់ទាំងពីរនឹម គាត់នឹកស្រងាកចិត្តជាខ្លាំង បានស្រែកហៅកូនយ៉ាងឆោឡោសាកសួរពីរឿងនេះ ។ អ្នកទាំងអស់គ្នា មានសេចក្ដីស្ដាយក្រៃលែង ព្រោះជិតដល់រដូវធ្វើស្រែផង ។ ពួកអ្នកភូមិជាមួយ កាលបានដឹងដំណឹងនេះហើយ ក៏នាំគ្នាមកសួរគាត់ ជាការជួយព្រួយនឹងជួយស្ដាយជាមួយផង ។ គ្រានោះ ពូ ប្រេស បានប្រើកូនប្រុសាឲ្យទៅប្រាប់ ពូ ជ្រា សំឡាញ់គាត់ ដែលនៅភូមិមួយឆ្ងាយពីភូមិនោះ ដើម្បីឲ្យជួយស៊ើបសួររកគោពីរនឹម ដែលចោរបានលួចបាត់ពីយប់មិញ ព្រោះ ពូ ជ្រា ជាមនុស្សម្នាក់ដែលធ្លាប់ស្គាល់ដើងចោរស្ទើរគ្រប់សល់ចន្ទោះ ។ កូនប្រុសាកាលបានទទួលពាក្យឪពុកគេហើយ ក៏ប្រញាប់ប្រញាល់ស្រូតរូតទៅដល់ផ្ទះ ពូ ជ្រា ហើយប្រាប់អំពីរឿងបាត់គោតាមដំណើរ ។ ពូ ជ្រា បន្ទោស: " ក្មួយឯងប្រហែសណាស់! ចុះនាំគ្នាដេកទ្រមក់អីខ្លាំងម៉្លេះ ទាល់តែចោរគាស់រនុកយួងក្រោមផ្ទះលួចគោបាត់អស់រលីងយ៉ាងនេះ ? " ។ បុរសតប: " ទេពូ! ពូថាប្រហែសក៏បានដែរ តែពេលនោះ ដូចជាសើយតែម្ដង កុំអីមិនបាត់សោះទាស់តែ..." ។ ពូជ្រា: "រឿងនោះកយ៉ាងម៉េច ទាស់តែ... ស្អី?" ។

កូនប្រសាពូប្រេស (ញញឹមខ្ជិប): "ខ្ញុំស្ទើរមិនហ៊ានជំរាបពូទេ ក្រែងពូងងមាត់មិនជិត" ។ ពូជ្រា: "ព្រើល ៗ! ជាតិមនុស្សគ្មានអ្នកណាមាត់ជិតជាងពូទៀតទេ រឿងយ៉ាងម៉េច និយាយទៅមើល ឲ្យគ្នាបានដឹងផងក្រែងលោគ្រាន់បានជាគ្រឿងបំភ្លឺខ្លះ ដល់ការលៃលកកេគោនោះ" ។ កូនប្រសាពូប្រេស (ខ្សឹប ៗ) "ខ្ញុំស្តាយណាស់ពូអើយ! ស្តាយហើយស្តាយទៀត ស្តាយលែងឃុំទបាយតែម្តង! ពាក់កណ្តាលអធ្រាត្រយប់មិញ គឺពេលដែលចោរលួចគោនោះ ខ្ញុំក៏បានដឹងដែរ តែចាស់មកពីស្ងាតទុសស្រឡះ គុំអើមិនបាត់សោះ, មុនដំបូង រ៉េគ្គី ១ រញ្ជួយ ១ អស់ទាំងល្វែងផ្ទះ ខ្ញុំក៏ភ្ញាក់ព្រើតឡើងនឹកថា យី! រង្គើស្អីអេះ? ផ្ទៀងត្រចៀកស្តាប់បន្តិចទៅទៀត នៅតែរង្គើ ១ ដដែល ខ្ញុំក៏គិតថា ន! ប្រហែលរង្គើល្វែងខាងឪពុកក្មេកពីរឿងនុះដូចធម្មតាមុន ៗ ទេមើលទៅ" ។ និយាយដល់ត្រង់នេះ ពូជ្រាគាត់អត់ទ្រាំមិនបាន ក៏ធ្លាយសំណើចយ៉ាងខ្លាំងលាន់ឮហះ ១ ហើយគាត់សួរថា រួចពីនេះយ៉ាងម៉េចទៅទៀត ។ កូនប្រសាពូប្រេសក៏បានបន្តរឿងទៅទៀតថា រួចពីនេះ ខ្ញុំក៏សម្ងំដេកលក់ទៅវិញទៅ លុះព្រលឹមឡើង ស្រាប់តែឮមាត់ឪពុកក្មេកនឹងម្តាយក្មេកខ្ញុំ គាត់ស្រែកឡូឡាឆោឡោថាបាត់គោពីក្រោមផ្ទះអស់រលីងទៅហើយ ខ្ញុំប្រហោងពោះធុនតែម្តង ទើបខ្ញុំនឹកឃើញច្បាស់

ថា ឱ ! រឿងរង្គើ ១ ពីយប់មិញនោះ គឺរង្គើមកពីចោរការរន្ទៀកដកស្នៀត រនុកឃ្លងក្រោមផ្ទះសោះទេតើ ! រឿងហ្នឹងគឺមកពីខ្ញុំស្មានខុសយ៉ាងនេះ ឯងណាពូ កុំអីគោទាំងនោះ មិនបាត់សោះ, ឥឡូវឪពុកក្មេកខ្ញុំនឹងខ្ញុំមាន សេចក្តីសង្ឃឹមទុកចិត្តលើពូទាំងអស់ សុំពូអាណិតជួយខ្វះខ្វែងយ៉ាងណា រកគោទាំងនោះឲ្យឃើញវិញកុំខានណាពូ ព្រោះរដូវស្រូវឆ្នាំនេះ បើ រកគោមិនឃើញទេមុខជានឹងខកខានធ្វើស្រែហើយ, តែទីបំផុត ខ្ញុំសុំ ចិត្តពូថា រឿងរង្គើដែលខ្ញុំបានជំរាបពូអម្បាញមិញនេះ សុំពូអាណិតកុំមាត់ កឲ្យលេចឮឲ្យសោះ តិចលោដឹងដល់ឪពុកក្មេក ឆាប់ខ្ញុំតែម្តងហើយ ។ ពូជ្រាតប : " ពូមិនឆាយឲ្យលេចឮផ្តេសផ្តាសទេ ចំណែករឿងគោនោះ ពូនឹងជួយស៊ើបដើងការមើលតាមដំណើរការណ៍តទៅ " ។ កូនប្រសា ពូប្រេសបានជំរាបលាពូជ្រាវិលត្រឡប់ទៅផ្ទះវិញ ទៅដល់ហើយក៏ពឹង ពាក់ញាតិមិត្រជិតខាងភូមិផងរបងជាមួយឲ្យជួយស្កាត់រកមួយប៉ែកខាងនេះ ដែរ ស៊ើបសួរគ្រប់ច្រកល្ហកអស់ ៣-៤ ថ្ងៃតែគ្មានឮដំណឹងអ្វីសោះ ។

រំលងមកមួយអាទិត្យ, វេលាព្រឹកថ្ងៃមួយ ស្រាប់តែលេចពូជ្រាជិះ សេះធ្លក់ ១ មកដល់មុខផ្ទះពូប្រេស ។ កាលចងសេះក្រោមម្លប់ដើមស្វាយ ក្បែរផ្ទះរួចស្រួលបួលហើយ ពូជ្រាក៏ឡើងទៅលើផ្ទះ ។ ម្ចាស់ផ្ទះទាំង ប្តីប្រពន្ធ បានទទួលភ្ញៀវដោយសេចក្តីរីករាយ ព្រមទាំងសួរភ្លាមអំពី ដំណើររកគោនោះ តើបានការយ៉ាងណាខ្លះ ។ សំឡាញ់តបវិញថា

" ស្ងាត់ស្ងៀមដូចចោរលួចគោតែម្តងហើយរ៉ឺអាសំឡាញ់ ពួកចោរជាន់នេះស្ងួតតែជើងឯកហើយ បានជាគ្មានលេចឮដំណឹងល្ហិចល្ហៀងបន្តិចបន្តួចសោះ" ។ ពូប្រុស : " ខ្មោចអាចោរគេកាប់អម្បែងក្បាល ! អញពីម្តងដូចខ្យល់ពកអាចម៍ ! មកនិយាយលេងព្រើល ៗ ផ្តេសផ្តាស ! ។ មីងប្រែងបន្ទោសថែម : " អ្នកជ្រាឯងបើគេឯទៀតដែលបាត់គោពីមុន ៗ បេះតែជួយរកទាល់តែឃើញ គ្រង់ខ្ញុំវិញពីងម្តងគ្មានបានការសោះ" ។ កៀវ " ខ្ញុំខិតខំរកអស់ប៉ុណ្ណឹងហើយអ្នក តែពេលនេះគឺរាប់បប់គ្នាត្រឹមស្ងាត់ស្ងូន្យឈឹងហ្នឹងឯង មិនដឹងជាលៃលកទៅតាមប្រកណាទៀតទេ " ។ មីងប្រែង ក៏ចូលដើងក្រានដាំបាយធ្វើម្ហូប ដើម្បីទទួលកៀវ ។ ពូប្រុសនៅដេកលេងជាមួយមិត្រ ទំរាំដល់ពេលបាយឆ្អិន, គាត់និយាយតែរឿងបាត់គោនោះឯងដដែល ៗ ។ ពូជ្រាបន្ទោស : " អាឯងនេះបានជាថ្មស់ព្រោយបាត់ទ្រព្យរបស់យ៉ាងនេះ មកពីដេកទ្រមក់ពេក មិនប្រតិបត្តិតាមដំបូន្មានចាស់ទុំសោះ, សាស្ត្រាច្បាប់ប្រុសដែលយើងធ្លាប់បានរៀនសូត្រតាំងពីក្មេងមកនោះ អាឯងនៅចាំបានខ្លះឬទេ ? លោកថា . . .
នឹងដេកកុំទ្រមក់ ឲ្យលង់លក់ក្រៅពីក្បួន បើភ្ញាក់ឲ្យដឹងខ្លួន ទៀងអង្គុយកុំមាត់ខ្លាំង; ប្រែប្រាណរាប្រងវិញ្ញាណ ខ្វាចក្រែងមានចោរចិត្តខ្លាំងប្រួញប្រាណប្រឫជញ្ជាំង ជញ្ជូនទ្រព្យលួចយកចេញ; បើឥតមោះមន្ទិលកុំឲ្យខ្ជិលដេកទៅវិញ ភ្ញាក់ហើយឲ្យក្រោកចេញ រកជក់ថ្នាំស៊ីម្លូស្លា ... ។

ប្រែស : "អាចោលម្សៀត ! ច្បាប់នេះអញក៏នៅចាំដែរ អញមានដេកទ្រមក់កាលណា គឺពេលយប់នោះអញភ្ញាក់ឡើងដឹងខ្លួនដែរ តែមកពីអញស្មានខុសស្រឡះ កុំអីមិនបាត់សោះ ! អញនឹកឡើងក្តៅក្រហាយស្តាយក្រោយស្ទើរតែបោកក្បាលបំបែកនឹងសសរទ្រូងផ្ទះហ្នឹងឥឡូវ " ។ ពូជ្រានឹកតែក្នុងចិត្តថា អានេះធ្លាក់គន្លងកូនប្រសារៈទៀតហើយ ទើបបញ្ឆ្លក់ថា : " ស្មានខុសយ៉ាងម៉េច ? " ។ ប្រែស ( ខ្សឹបបណ្តើរញញឹមបណ្តើរ ) : " រឿងនេះមិនគួរនិយាយទេ វាជ្រុលហួសអស់ទៅហើយ តែថា ណ្ហើយ ! និយាយប្រាប់អាឯងបន្តិចទៅចុះ ពាក់កណ្តាលអធ្រាត្រយប់នោះ អញភ្ញាក់ឡើងស្រាប់តែរង្គើ ៗ អស់ទាំងល្វែងផ្ទះ អញក៏បង្ហើបក្បាលពីខ្នើយបន្តិចចំផ្ទៀងស្តាប់មើលតើរង្គើស្អីពេលនោះនៅតែរង្គើ ៗ ដដែល អញនឹកស្មានថាប្រាកដជារង្គើខាងល្វែងកូនប្រសាពីរឿងអ៊ីៗ ហើយមើលទៅ អញសម្ងំដេកលក់ទៅវិញទៅ" ។ ពូជ្រា ខំទប់សំណើចយូរណាស់ហើយ តាំងពីផ្តើមរឿងបន្តិចមកម៉្លេះដល់ត្រង់នេះគាត់សើចឃឹក ហើយគាត់ដេរប្រែសថា " ខ្មោចអាកំពូដរង្គើ! រឿងអាឯងនេះវាអស្ចារ្យចំឡែកណាស់ ! អាកូនស្មានថារង្គើខាងល្វែងឪពីរឿងនុង ចំណែកអាឪថារង្គើខាងល្វែងកូនប្រសា ពីរឿងអ៊ី ៗ នុងដែរ គិតទៅពួកអាឯងៈនេះសុទ្ធតែអារង្គើទាំងអស់គ្នា រង្គើទាំងឪ រង្គើទាំងកូន រង្គើប្រណាំងគ្នាហោងហ្នឹង បានជាវានាំឲ្យគាន់ប្រឡំ ទាល់តែបាត់គោអស់

ឡើង! ថាអាកូនប្រសាប៉ុះគ្នានៅក្មេង គួរតែរាប់ឡើងរឿយ ៗ ទៅចុះ , បំណែកកោងក្បាលកញ្ចាស់ឯណោះ សក់ល្វាយកាចម៍ខ្វាទៅហើយ ក៏នៅតែចូលចិត្តលេងល្បែងឡើងប្រណាំងដេញដើងទឹងកូនប្រសាធ្វើអីដែរ ៗ

ពេលនោះ ពូប្រេស ដេញតាក់ពូជ្រាំ រត់ឡើងពេញទាំងផ្ទះ ហើយដេរថែមទៀត " អាចោររន្ទះដើមឆ្នាំបាញ់! អាឯងហារឡើងដៀលពូជអម្បូរអញ ថាសុទ្ធតែអាកំពូដរឡើ! អាឯងប្រហែលឡើជាងអញទៅទៀត : " ៗ ជ្រាំ: " បើទុកជារឡើក៏អញរឡើតែម្នាក់អញ ឥតមានប្រឡំទឹងរឡើអ្នកណា នាំឲ្យបង់ខាតទ្រព្យរបស់ដូចអាចង្រៃឯងនេះអី " ៗ គ្រានោះ ម៉ែងប្រែង លបស្ដាប់ពីក្នុះដើងក្រានមកពុះខ្ទេះខ្ទេះ គាត់ក៏ស្រែកថា " ហៅសែនស្អប់អស់យ៉ាងហើយអញ! ស្អប់មនុស្សនិយាយខ្សិបៗ ហើយស្រាប់តែសើចពុ, ក្បាលកញ្ចាស់ហើយ នៅតែប្រឡែងគ្នាដូចកូនក្មេង រឿងបាត់គោឯណោះមិនគិតទេ ទៅគិតតែរឿងផ្ដេសផ្ដាសឯណាទៅវិញ " ៗ ជ្រាំតប " ទេអ្នក! គ្មាននិយាយរឿងអីក្រៅពីរឿងចោរលួចគោនោះទេ! អាប្រេស វាកំពុងតែរៀបរាប់ប្រាប់ខ្ញុំពីរឿងហ្នឹងហើយតើ! " ៗ ជ្រាំបន្តសំដី : " ឥឡូវអាឯងបន្តរឿងទៅទៀតមើលតើយ៉ាងម៉េចទៀត? " ៗ ប្រេស : " រួចពីនោះអញសម្ងំដេកលក់ទៅវិញទៅ ភ្ញាក់ព្រលឹមឡើងឈ្ងោកមើលក្រោមផ្ទះ ស្រាប់តែបាត់គោអស់រលីង អញហួសចិត្តតែម្ដង ទើបទឹកឃើញថា ឱ! រឿង

រង្គើៗ នោះគឺចោរវ៉ារង្កៀកដកស្មៀតរនុកឃ្នង់ក្រោមផ្ទះសោះ" ។ ពេលកំពុងសន្ទនាគ្នានោះ កូនប្រសាតូប្រេស ត្រឡប់មកពីផ្ការព្រៃឯស្រែជាមួយប្រពន្ធ មកពួនលបស្តាប់នៅក្រោមផ្ទះ បានឮរឿងនោះសព្វគ្រប់ ក៏នឹកអៀនខ្មាសជាខ្លាំង នឹកមួម៉ៅនឹងតូជ្រាណាស់ទៅទៀត ដោយដឹងថាគាត់បាននិយាយរឿងដែលខ្លួនរៀបរាប់ពីថ្ងៃមុននោះ ប្រាប់ឪពុកក្មេក ៗ បុរសនេះ ក៏គេចខ្លួនដើរទៅលេងផ្ទះគេនៅចុងភូមិបាត់ទៅ ។ ពេលដើរទៅនោះ បុរសពោលរអ៊ូតែម្នាក់ឯងថា " បង់គំនិតតែម្តងហើយអញ ! គិតទៅមនុស្សឈ្មោះជ្រាចង្រៃមែន ! ឯងចំអង្វរគាត់ជាច្រើនដង អង្វរហើយអង្វរទៀតថាសុំឲ្យគាត់លាក់រឿងនេះឲ្យជិត គាត់ថាគ្មានអ្នកណាមាត់ជិតជាងគាត់ទេ ឯងចំជឿគាត់ស្លាប់ចិត្តស្លូត ! តាមក្តៅអញចង់តែកាប់ តូជ្រាចោលឲ្យងាប់ស្រឡះឥឡូវហ្នឹង . . ." ។ ឯកូនស្រីតូប្រេសឡើងតាមជណ្តើរផ្ទះបាយ ទៅជួយដោះដួសបាយនឹងម្ហូបលើកយកមកជូនក្មៀវនឹងឪពុករបស់ខ្លួន ។ លុះបរិភោគបាយរួចហើយ, តូជ្រា ផ្តើមនិយាយទៀតថា " អាប្រេស ! ណ្ហើយ ! អញនិយាយម្តងលេងម្តងមែនឥឡូវ អាឯងហៅប្រពន្ធកូនឲ្យជួបជុំមកមើល អញនឹងជួយលៃលកឲ្យបានស្រួល បើអាឯងនៅសល់ប្រាក់កាសខ្វះល្មមទិញគោមួយនឹមទៀតបាន ត្រូវទិញទៅ ដើម្បីធ្វើស្រែក្នុងរដូវវស្សានេះ តែបើទិញបានមកម្តងនេះ ប្តូរអាឯងប្រុងប្រយ័ត្នឲ្យមែនទែនពីរឿងរង្គើនោះទើបបានស្រួល ។

ប្រុស : " អាចំកួត ! ព្រើល ៗ ! រឿងគោនោះ មុខតែត្រូវទិញ ហើយ បើមិនទិញបានអ្នកស្រែ " ។ ជ្រា " អើបើដូច្នោះ តទៅមុខទៀត អាឯងធ្វើតាមរបៀបអញបានឬទេ ? ។ ប្រុស : " ធ្វើយ៉ាងម៉េច ! " ។ ជ្រា បឺតបារីបង្ហុយផ្សែងទ្រលោមរួចហើយតបថា : " តាមយោបល់អញថា តទៅត្រូវអាឯងលែលករៀបចំចែករឿងរង្គើនោះឲ្យរាំងដាច់ស្រឡះពីគ្នាទៅ គឺរបៀបរង្គើលើផ្ទះនោះ មានបែបដូច្នេះ ឬដូច្នោះ ពុំនោះសោតទេ ត្រូវសន្មតគ្នាទៅថា រង្គើល្វែងខាងអាឯងគឺរាំយ៉ាងនេះ ឯរង្គើខាងល្វែងកូនប្រសាគឺរាំយ៉ាងនោះ ដូច្នេះទៅ ដើម្បីឲ្យស្រណុកបំណាំ កុំឲ្យរាំប្រទាំទឹងរង្គើរឿងចោរគាស់ទ្រុកយួងគោក្រោមផ្ទះនោះ, យ៉ាងនេះទើបលែងបាត់គោតទៅទៀត ព្រោះពីមុនរាំបានជាជោយអស់ទៅហើយ ឪពុកក្មេកថារង្គើខាងកូនប្រសា ៗ ថារង្គើខាងឪពុកក្មេក ទាល់តែបាត់គោអស់លើង, ម៉េចស្ដាប់អញបានទេ អាប្រុស " ។ ពូប្រុស ក្រោកឡើងទាក់ពូជ្រាពីរបីដើង ត្បកក្បាលពីរបីក្រញាំហើយជេរ: "ខ្មោចអានរក ! ឯងប្រើងស្ដាប់ស៊ីកត្រចៀកខ្ទប រាងៅតែនិយាយលេងដដែល ៗ ! " ។ ជ្រា : " ទេ អញនិយាយនេះសុទ្ធតែមែន ៗ ទាំងអស់ ព្រោះអញចង់ឲ្យអាឯងការពារកុំឲ្យបាត់គោដូចមុនទៀត, តែបើអាឯងមិនស្ដាប់ពាក្យអញ ហើយចូលចិត្តប្រព្រឹត្តតែលេងល្បែងរង្គើ ៗ ឲ្យប្រទាំគ្នា យ៉ាងនេះដដែលទេ អាឯងមុខជាខ្វះគោភ្ជួរស្រែជាប្រាកដពុំខាន " ។

មុននឹងលាសំឡាញ់ត្រឡប់ទៅផ្ទះវិញ ,  ពូជ្រាបានបន្ថែមសំដីថា "អាប្រេស !  អញតាំងពីតូចក្រចធាត់មកដល់ចំណាស់ប៉ុណ្ណេះហើយ មិនដែលបានដឹងពុះរឿងផុពុកក្រេក  នឹងកូនប្រុសាច្រឡំរង្គើគ្នាទាល់តែបាត់គោអស់ឈើងយាំងនេះសោះ,  ទើបតែមកដល់ពេលនេះ  អញបានជួបប្រទះនឹងរឿងអាឯងនេះតែម្តង  អញសុំផ្តាំក្រោយបង្អស់ថា  តទៅថ្ងៃមុខអាឯងត្រូវរៀបចំកែប្រែរបៀបរង្គើ  ដូចអញបានប្រាប់ខាងដើមមកហើយអម្បាញមិញនេះ  ឲ្យបានស្រួលបួលកុំខាន  ដើម្បីចៀសកងកុំឲ្យបាត់ទ្រព្យរបស់ដូចគ្រានេះទៀត  ឥឡូវនេះ អញសុំបញ្ចប់រឿងអាឯងត្រឹមនេះចុះថា " រង្គើ ១ ធ្វើឲ្យបាត់គោអស់ពីរនឹម " ។

---

## អធិប្បាយសុភាសិត

# ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស

លោក ញ៉ែម - ទឹម រៀបរៀង

---

សុភាសិតទាំងឡាយរបស់ខ្មែរ សុទ្ធតែកើតឡើងដោយស្នាដៃបុព្វបុរសខ្មែរយើងបានបន្សល់ទុកមក ព្រោះលោកបានពិសោធឃើញ ឬក៏បានជួបប្រទះនូវឧបសគ្គអ្វីមួយក្នុងការបំពេញបេសកកម្ម ឬ អនុវត្តន៍គោលបំណងអ្វីមួយពុំបានសម្រេច, ពុំបានល្អសមរម្យ ។ អាស្រ័យហេតុផ្សេង ៗ នេះហើយ ទើបលោករិះគិតបន្សល់ជាសុភាសិតនេះឡើង ទុកទូន្មានដាស់តឿនក្រើនរំលឹកយើងជាកូនចៅក្រោយ ៗ តមក ឬក៏ទុកជាបទសម្រាប់ពិចារណា ដើម្បីកុំឲ្យប្រព្រឹត្តអ្វីខុសឆ្គង ដែលនាំឲ្យខាតពេល ខាតប្រយោជន៍ ឬអាចនឹងកើតក្តីឈ្លោះក៏សឹងមាន ។

ដូច្នេះ សុភាសិតថា ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស នេះក៏ជាដំបូន្មានមួយបទ ដែលលោកអ្នកមានការពិសោធន៍ច្រើន បានតែងទុកមក ដើម្បីទូន្មានប្រាប់ផ្លូវដល់បុគ្គលណាដែលទៅកាន់បរទេស ឬដែលធ្វើបេសកកម្មទៅកាន់ស្រុកដទៃផ្សេង ៗ នឹងដល់ជនដែលត្រូវការទៅចាប់ភូមិករនៅកន្លែងថ្មី ក្រៅពីស្រុកកំណើតរបស់ខ្លួន ។

ពាក្យទាំងពីរឃ្លាក្នុងសុភាសិតនេះ មានន័យស្រដៀងគ្នា គេអាចរួប

រមែតែមួយឃ្លាបាន ដ្បិតឃ្លាទីមួយគ្រាន់តែជាឧទាហរណ៍នៃអាថ៌របស់ឃ្លាទីពីរប៉ុណ្ណោះ ។

" ចូលស្ទឹងតាមបទ..." ការចូលស្ទឹងគេតែងចូលទៅតាមទិនងតាមរបត់ពង់ពែនរបស់ស្ទឹង ។ ពាក្យនេះរំលឹកដល់នាយនាវិក អ្នកបើកបរទូកកប៉ាល់, សំពៅកេត្រាទាំងឡាយ ឲ្យប្រយ័ត្នចំពោះរបត់ប្រាំង, របត់ខ្សែទឹកឲ្យឈ្លាសវៃរំពៃស្មានថា ត្រង់នេះមានថ្ម ត្រង់នេះមានគល់ដង្គត់ ដែលជាឧបសគ្គពំនឹងកល្បឿននាវាមិនឲ្យទៅមុខរួច ។ ដូច្នេះ អ្នកបើកបរនាវាមិនគេចតាមរបត់ក្រឡិចក្រឡក់នៃប្រាំងស្ទឹងទេ នោះនាវាមុខជាទៅមុខពុំរួច ឬប៉ះទង្គិចខូចខាតបាក់បែកអសារឥតការ ឬក៏គឿងទៅណាមកណាលែងរួច ។ ពាក្យមួយឃ្លាខាងដើម មានន័យត្រង់ ៗ ដូច្នេះឯងគឺជាឧទាហរណ៍ ឬ ជាបទប្រៀបធៀបដល់ពាក្យមួយឃ្លាខាងចុង ញុំាងពាក្យមួយឃ្លាខាងចុងឲ្យច្បាស់ប្រាកដឡើង ។

ចូលស្រុកតាមប្រទេស ស្រុកក្នុងទីនេះ បានន័យថា ទីដទៃក្រៅពីស្រុកកំណើត, ភូមិលំនៅរបស់ពួកមនុស្ស, (ជំនុំចំណោមឬពិធីបុណ្យអ្វីមួយ) ។ ប្រទេស បានន័យថា ទីលំនៅរបស់ជនជាតិសាសន៍នីមួយ ៗ បើតាមសេចក្ដីក្នុងសុភាសិតនេះបានសេចក្ដីថា ទំនៀមទម្លាប់, ច្បាប់, អារ្យធម៌សុជីវធម៌ប្រពៃណី ជាដើម ។ ដូច្នេះ ចូលស្រុកតាមប្រទេស បានន័យថា បើយើងបានទៅកាន់ទីដទៃ, កន្លែង

ដទៃណា ត្រូវយើងប្រព្រឹត្តតាមទំនៀមទម្លាប់ ឬច្បាប់ដែលគេនិយមគេប្រតិបត្តិនៅទីនោះ កន្លែងនោះ ប្រទេសនោះ ព្រោះទំនៀមទម្លាប់ ឬច្បាប់តែងមានសណ្ឋានមានការនិយមខុសគ្នាពេញទីកន្លែង ឬប្រទេសមួយនឹងប្រទេសមួយ, ឬដំបន់មួយនឹងដំបន់មួយ ៗ ច្បាប់ខ្លះឬទំនៀមខ្លះដែលយើងយល់ថាប្រសើរថាល្អនៅក្នុងស្រុកយើង ពុំអាចយកទៅអនុវត្តនៅប្រទេសដទៃបានដូចគ្នាទេ ព្រោះមនុស្សយើងមានអធ្យាស្រ័យ, ចរិត, ឬកពាលក្ខណៈខុសគ្នា ៗ

ដូច្នេះ បើយើងត្រូវការធ្វើដំណើរទៅកាន់ទីណា ប្រទេសណា យើងត្រូវប្រព្រឹត្តឲ្យស្របទៅតាមប្រពៃណីនិយមរបស់ទីនោះ ប្រទេសនោះ យើងត្រូវធ្វើយ៉ាងណាកុំឲ្យឆ្គងខុសពីគេពេក ៗ បើមិនដូច្នោះទេ គេមុខជាសើចតិះដៀលនិន្ទាឲ្យយើង នាំឲ្យយើងអាម៉ាស់មុខជាខ្លាំង ចូលរួមសមាគមជាមួយនឹងគេមិនបាន ៗ

ឧទាហរណ៍ ដូចជាទេសចរទៅលេងប្រទេសអង់គ្លេស ប្រទេសសៀម យើងត្រូវគោរពតាមច្បាប់ប្រទេសនោះ គឺថាយើងត្រូវការដើរ ឬបើករថយន្តប្រកាន់យកខាងឆ្វេង ព្រោះច្បាប់ចរាចរនៅស្រុកគេ ៗ និយមឆ្វេងជាត្រូវ ខុសពីស្រុកយើងយកខាងស្តាំជាត្រូវ ៗ ហេតុនេះ បើយើងហើយមិនប្រកាន់យកឆ្វេងតាមច្បាប់ស្រុកគេទេ នោះយើងមុខជាបើកបររថយន្តទៅប៉ះទង្គិចគេ បណ្តាលឲ្យយើងសងគេផតគាំពើ ហើយក្រុម

គម្រូគេនឹងពិន័យធ្វើទោសយើងពុំខាន ។

ឧទាហរណ៍មួយទៀត ដូចជាយើងត្រូវការទៅនៅប្រទេសជ្វា ឬអាហ្វ្រិក, យើងត្រូវដឹងថា សាសន៍ជ្វាឬអាហ្វ្រិក គេកាន់សាសនាខុសពីជាតិយើង ដូច្នេះ,ដើម្បីធ្វើឲ្យគេស្រឡាញ់រាប់អានយើង ហើយយើងក៏អាចស្ថិតនៅក្នុងទីនោះបានសុខផង យើងត្រូវតែនិយមធ្វើតាមគេ ។ បើយើងមិនព្រមធ្វើតាមគេ នោះខ្លួនយើងហាក់ដូចជារស់នៅកណ្ដាលព្រៃតែម្នាក់ឯង ៗ

តើយើងត្រូវប្រតិបត្តិតាមសុភាសិតនេះទាំងស្រុងឬ? ការ ចូលស្រុកតាមប្រទេស មិនមែនរមែងតែអាចប្រព្រឹត្តទៅបានស្រួល ៗ ដោយគ្មានការរញ្ជួយក្នុងចិត្ត ឬគ្មានឧបសគ្គខ្លះនោះទេ ប៉ុន្តែ ចូរយើងយល់ថា ធម្មតាសុភាសិតទាំងឡាយ ច្រើនមានគុណសម្បត្តិច្រើនជាងគុណវិបត្តិ ។ ការ ចូលស្រុកតាមប្រទេស នោះនាំមកនូវគុណប្រយោជន៍ដល់ខ្លួនយើងច្រើនជាងគុណវិបត្តិ យើងត្រូវតែធ្វើតាមសុភាសិតនេះ ។ ឧទាហរណ៍ ដូចជាសមណនិស្សិតយើងដែលនិមន្តទៅសិក្សានៅប្រទេសជប៉ុន ត្រូវលាចាកភេទពីបព្វជិតមកជាគ្រហស្ថ ទើបអាចនៅបន្តការសិក្សាតទៅទៀតបាន បើមិនដូច្នោះទេ មានតែនិមន្តត្រឡប់មកស្រុកយើងវិញ ព្រោះនៅគេហស្ថានដែលគេទទួលសមណនិស្សិតយើង ឲ្យនៅសំណាក់អាស្រ័យ, ម្ចាស់ផ្ទះគេពុំយល់នូវសិក្ខាបទរបស់ព្រះសង្ឃខ្មែរយើងទេ ។ ដូច្នេះ នៅពេលឆាន់គេរៀបចំភ្ញាន់ប្រគេនព្រះសង្ឃយើងឆាន់

ជាមួយនឹងគ្រួសារគេដែលមានប្រុស-ស្រី ហើយសុទ្ធតែគ្រហស្ថទាំងអស់គ្នាតែម្តង ។ ហេតុនេះ ដើម្បីចូលរួមរស់ក្នុងគ្រួសារគេបាន ព្រះសង្ឃយើងត្រូវលាចាកសិក្ខាបទ បើមិនដូច្នេះទេ ឃើញថាទាស់ខុសនឹងវិន័យក្នុងព្រះពុទ្ធសាសនា នឹងខាងរៀនសូត្រ ។

ផ្ទុយទៅវិញ បើសិនជាការ ចូលប្រកាតាមប្រទេស នោះធ្វើឲ្យយើងមើលទាល់ក្នុងចិត្តខ្លាំងពេក យើងក៏មិនគួរអនុវត្តតាមដែរ បើជាការមិនអនុវត្តតាមនោះគ្មានទោសពៃរ៍អ្វីដល់យើងទេ ដូចជានៅក្នុងតំបន់មួយនៃប្រទេសឥណ្ឌូណេស៊ី ហៅគេណាកន់ (ស្រុកលើព្រៃភ្នំ) មានគេដំណាលថា គៀវដែលជួយហែសពទាំងឡាយ ត្រូវតែទទួលទានបាយដែលគេដាំដោយទឹក ដែលគេបានយកទៅស្រោចពីលើសាកសពដែលកំពុងរលួយហើយដែលគេត្រងយកពីក្រោមក្តារមឈូសមកវិញ ព្រោះទំនៀមគេយល់ថា ការធ្វើដូច្នេះ នឹងនាំឲ្យអ្នកដែលនៅរស់អាចទទួលយកគុណសម្បត្តិប្រសើរពីបុគ្គលស្លាប់បាន ។ ចំពោះឧទាហរណ៍ត្រង់នេះ តាមយោបល់ខ្ញុំយល់ថា បើយើងគ្រាន់តែទៅលេងស្រុកនោះ ចំនួនតែ ៨-១០ ថ្ងៃប៉ុណ្ណោះទេ, យើងពុំចាំបាច់ប្រតិបត្តិតាមសុភាសិតនេះទេ ព្រោះការប្រព្រឹត្តខុសនឹងទំនៀមទម្លាប់ គ្មានទោសធ្ងន់ដូចជាការប្រព្រឹត្តខុសនឹងច្បាប់សម្រាប់ផ្លូវ ។ ម្យ៉ាងទៀតដោយយើងខ្លាចមានជម្ងឺធ្ងន់ ព្រោះតំណើរដែលធ្វើដូច្នេះ នាំឲ្យពាសខុសនឹងក្បួនអនាម័យផង ។ បើ

បុគ្គលអ្នកស្លាប់នោះ ស្លាប់ដោយរោគធម្មតានោះមិនជាការទាស់ខុសប៉ុន្មានទេ ប៉ុន្តែបើបុគ្គលអ្នកស្លាប់នោះ ស្លាប់ដោយជម្ងឺឆ្លងវិញ ដូចជាអាសន្នរោគ, អុត, របេងជាដើម នោះយើងប្រាកដជាកើតជម្ងឺឆ្លងជាពុំខាន, នាំឲ្យស្លាប់ខ្លួនអសារឥតការ ។ ប៉ុន្តែបើសិនជាយើងបម្រុងទៅតាំងភូមិលំនៅជាប់រហូតនៅត្រង់នោះ យើងត្រូវតែប្រតិបត្តិតាមសុភាសិតនេះ ។

ជាទីបញ្ចប់ សុភាសិត "ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស" នេះ មានប្រយោជន៍សំខាន់ណាស់ដល់អ្នកទេសចរទៅកាន់ប្រទេសនានាក្នុងលោកនេះ ព្រោះនៅក្នុងកាលៈទេស.បច្ចុប្បន្ននេះ ដែលប្រទេសយើងកំពុងមានកិត្តិនាមល្បីខ្ទរខ្ទារនេះ, ប្រទេសឯទៀតគេចង់ស្គាល់ប្រជាជនខ្មែរយើងណាស់ ។ ដូច្នេះហើយ បើយើងបានប្រព្រឹត្តអំពើអ្វីពុំគប្បីខុសអំពីទំនៀមទម្លាប់ច្បាប់ស្រុកគេនោះ គេមុខជាពេបជ្រាយ មើលងាយដល់ខ្លួនយើង ទឹងដល់ប្រទេសជាតិយើងទាំងមូលទៀត សមដូចសុភា-សិតមួយទៀតពោលថា "សំដីសរជាតិ មារយាទសរពូជ" ។

ផ្នែកកំណត់ហេតុព្រឹត្តិការណ៍

# កត់ហេតុមហាសន្និបាតលើកទី ៩

## នៃពុទ្ធិកសមាគម មជ្ឈមណ្ឌលកម្ពុជ

ពុទ្ធសករាជពីរពាន់ប្រាំរយបី ឆ្នាំជូតទោស័ក ខែបុស្ស ថ្ងៃពុធ ៣ កេត ត្រូវនឹងថ្ងៃទី ៤ មករា ១៩៦១ ម៉ោង ១៦ ។

នៅមន្ទីរសំណាក់ការនៃពុទ្ធិកសមាគមកម្ពុជរដ្ឋ សមាជិក-សមាជិកាទាំងពីរប្រភេទ បានទិមន្ត - អញ្ជើញមករួមប្រជុំ ដើម្បីធ្វើមហាសន្និបាតប្រចាំឆ្នាំគំរប់ទី ៩ ក្រោមអធិបតីភាពនៃលោក ពយ - លួត ដើម្បីពិភាក្សារបៀបវារៈដែលបានកំណត់ទុកក្នុងលិខិតទិមន្ត - អញ្ជើញជាមុន ។

របៀបវារៈ

១– ស្ដាប់សេចក្ដីរាយការណ៍របស់គណៈកម្មាធិការនាយក អំពីសកម្មភាពក្នុងឆ្នាំដែលកន្លងទៅហើយ;

២–អំពីស្ថានភាពហិរញ្ញវត្ថុ ក្នុងឆ្នាំ ១៩៦០;

៣–បោះឆ្នោតជ្រើសរើសក្រុមអភិបាលសម្រាប់ឆ្នាំ ១៩៦១;

៤ ការផ្សេង ៗ ។

ដល់ម៉ោង ១៦ និង ៣០ នាទី មានការរាប់ចំនួនសមាជិក - ជិកាតាមប្រការ ៣០ នៃលក្ខន្តិកៈគឺៈ

ក ផ្នែកខាងព្រះសង្ឃ មានសម្ដេចព្រះមហាសុមេធាធិបតី ជ. ណា.

ដោតញាណោ ជាប្រធានចំនួន . . . . . . ៣៧ អង្គ

១ - ផ្នែកខាងគ្រហស្ថមានចំនួន . . . . . ១០៦ រូប

រួមសមាជិកទាំងពីរប្រភេទ . . . . . . . . ១៤៣ រូប

បន្ទាប់មក ដោយឃើញថា សមាជិក-ជិកា បាននិមន្ត-អញ្ជើញមកកាន់មហាសន្និបាតគ្រប់អង្គប្រជុំ តាមប្រការ ៣៩ នៃលក្ខន្តិកៈហើយនឹងតាមប្រការ ២ នៃបទបញ្ជា; លោក ពៃយ-ល្អុត ប្រធានគង្គតំណែងបានប្រកាសសុំបើកពេលប្រជុំ នឹងថ្លែងអំណរគុណចំពោះសមាជិកមហាសន្និបាត រូបហើយថ្លែងសេចក្ដីរាយការណ៍រៀបរាប់អំពីសកម្មភាពដោយសង្ខេបដែលគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៦០ បានបំពេញរួចមានសេចក្ដីជាអាទិ៍ថា :

១ បានជួយចេញថ្លៃផុសថប្រគេនលោកគ្រូអនុគណ ខែត្រកោះកុងចំនួនបច្ច័យមួយពាន់រៀល (១០០០ៜ០០;)

២ បាននិមន្តព្រះសង្ឃ ៦៦ អង្គ ស្វាធ្យាយសត្តប្បករណ៍ ឧទ្ទិសព្រះរាជកុសលថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ ដោយមានគ្រឿងបរិក្ខារផ្សេង ១ ប្រគេនព្រះសង្ឃបំណាយបច្ច័យចំនួន ៣ ៧៦២ រៀល;

៣-បានរួបរួមជាមួយព្រះរាជរដ្ឋាភិបាល ព្រមទាំងពុទ្ធបរិស័ទធ្វើបុណ្យនមស្ការព្រះសក្យមុនីចេតិយ ដាក់បាត្រព្រះសង្ឃប្រហែល ២.០០០ អង្គ;

៤ បានទំនុះខ្មែរ សុំឲ្យព្រះរាជរដ្ឋាភិបាលទទួលស្គាល់ ពុ.ម.ក. ថាជាសមាគមមានប្រយោជន៍សាធារណៈ ដែលបានសម្រេចដោយព្រះរាជក្រឹត្យលេខ ២២៤ ក.ប.រ. ចុះថ្ងៃទី ៣ មិថុនា ១៩៦០;

៥- ក្នុងឱកាសព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង ព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ បានបោះពុម្ពព្រះបរមធាយាល័ក្ខណ៍របស់ព្រះអង្គ ចំនួន ៥.០០០ ច្បាប់ ចែកជូនជាសាធារណៈអស់ប្រាក់ ៦.០០០ រៀល;

៦- បានបង្កើតគណៈកម្មការទស្សនាវដ្ដី "ពន្លឺពុទ្ធចក្រ" ចេញផ្សាយរាល់ត្រីមាស ចាប់ចេញលេខ ១ នៅថ្ងៃទី ១ មករា ១៩៦១ នេះតទៅ;

៧- បានចូលធ្វើព្រហ្មទាន ប្រគេនសមណនិស្សិតដែលប្រឡងចេញពីសាលាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ១.០០០ រៀល;

៨- បានផ្ដើមធ្វើអង្គកឋិនទាន ដង្ហែទៅវេរប្រគេនសង្ឃដែលគង់ចាំវស្សាក្នុងវត្តលាំងឈូក ឃុំកាហែង ស្រុកសំពងទង (កំពង់ស្ពឺ); ក្រោមការឧបត្ថម្ភនៃសម្ដេចព្រះមហាសុមេធាធិបតី ជ.ណ. ព្រះតេជ-ព្រះគុណព្រះពោធិវង្ស ហ-គាត និងព្រះតេជព្រះគុណព្រះឧបាលីវង្ស កែ-ពីន បំណាយប្រាក់ថវិកា ពុ.ម.ក. ចំនួន ១០.០០០ រៀល សូមបញ្ជាក់ថា ក្នុងពិធីបុណ្យកឋិនទាននេះ បានបច្ច័យសង្កាត់ត្រៃចំនួនជាង ៣០ ០០០ រៀល;

៩- បានធ្វើបុណ្យទក្ខិណានុប្បទាន ឧទ្ទិសកុសលប្រគេនចំពោះ

វិញ្ញាណក្ខន្ធ ព្រះសពព្រះតេជព្រះគុណព្រះសាសនមុនីនាម មាស កង អតីតអធិការវត្តពិកទ្វេង្ស ក្រុងភ្នំពេញ មាននិមន្តព្រះសង្ឃបំរើនព្រះបរិត្ត ទេសនា វេរភត្ត ... (ល) ចំណាយបច្ច័យចំនួន ១.០០០ រៀល ដោយមានពុទ្ធបរិស័ទជាច្រើន មានសេចក្ដីជ្រះថ្លាបានជួយឧបត្ថម្ភផង នៅសល់បច្ច័យបានចូលក្នុងបេឡាបំរុងនៃវត្តនេះចំនួន ២ ០៥០ រៀលថែមទៀត;

១០- បានរៀបចំផ្គត់ផ្គង់បង្ហាន់ក្នុងឱកាសបុណ្យ អនុសាវរីយ៍មហាសន្និបាតលើកទី ១៧ នៃមន្ត្រីសង្ឃចំនួនបច្ច័យ ១០ ០០០ រៀល;

១១- ពុ.ម.ក. បានទទួលអំណោយពីមូលនិធិអាស៊ី ជាប្រាក់ចំនួន ៩៨.៩០០ រៀល មកបញ្ចូលក្នុងទីឯប្រាក់ ពុ.ម.ក. ចំនួនទាំងអស់ ៣៦.១៨១ រៀល ៦៨ សេន ប្ដូរមកត្រូវជាប្រាក់ចំនួន ៩៣៥ ០៨១ រៀល ៦៨ សេន សម្រាប់ចេញថ្លៃអាហារូបករណ៍ប្រគេនសមណនិស្សិត ៦ រូប ដែលនិមន្តទៅនៅសិក្សាបន្តវិជ្ជាឯបរទេស,

១២- បានប្រាស្រ័យទាក់ទងជាមួយនឹងព្រះសង្ឃពីរអង្គ នឹងគ្រហស្ថមួយរូប ជាដំណាងនៃពុទ្ធសមាគមស្រីលង្កា;

១៣- បានប្រាស្រ័យទាក់ទងជាមួយនឹងលោកបណ្ឌិត វិហ្សាវ៉េអាគ្គារដ៍ ជាតិអាមេរិកកាំងហើយជាសាស្ត្រាចារ្យបង្រៀនខាងផ្នែកពុទ្ធសាសនានៅមហាវិទ្យាល័យ យ៉ាល៍ (University yalle);

១៤- ក្នុងកិច្ចការពារព្រះពុទ្ធសាសនា, ពុ.ម.ក. បានប្រឆាំងនឹងសៀវភៅមួយរបស់ឈ្មោះ គឹម-សែត ដែលមានចំណងជើងថា "ការកែងសេចក្ដីខ្មែរ" មានអត្ថបទប៉ះពាល់ជាខ្លាំងដល់លទ្ធិពុទ្ធសាសនា ។

ដទៃពីនេះ សឹងមានសេចក្ដីសព្វគ្រប់ក្នុងសេចក្ដីថ្លែងការណ៍សម្រាប់ឆ្នាំ ១៩៥០ ដែលឲ្យដំកល់ទុកជាឯកសារស្រាប់ ។ បន្ទាប់មក លោក ស៊ៅ-ហៃម អគ្គហេរញ្ញិកបានថ្លែងពយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ ក្នុងឆ្នាំ ១៩៦០ ដែលបានបម្រុងសេចក្ដីដូចខាងក្រោមនេះ៖

អំពីប្រាក់ចំណូល

ប្រាក់សល់ត្រឹមថ្ងៃទី ៣១. ១២. ៥៩ ចំនួន . . . ១០១.០៣៩$^៛$៥២

- ភាគទាន ក្នុងឆ្នាំ ១៩៦០ „ . . . ៦៤.៧៦៩,០០
- ប្រតិលាភ „ ១៩៦០ " . . . ២៥.២០០,០០
- អំណោយមូលនិធិអាស៊ី „ . . . . ៩៨.៩០០,០០
- អំណោយពីពិធីបុណ្យទមស្ការព្រះសក្យមុនីចេតិយ ១.៧៦៧,៥០
- ឈ្នួលផ្ទះ ពុ.ម.ក. . . . . . . ២៤.០០០,០០

បូករួម . . . . . . ៣១៥.៦៣៦$^៛$០២

អំពីប្រាក់ចំណាយ

- បៀវត្សរ៍បុគ្គលិកពីររូប . . . . . . . ៤៤.៤០០$^៛$០០
- ថ្លៃអាហារូបករណ៍សមណនិស្សិត ៦ រូប . . ១៣៥.០៥១,៦៥

- បោះពុម្ពព្រះបរមធាយាលក្ខណ៍ . . . . . ៦.០០០,០០
- ធ្វើអគ្គិកឋិនទាន . . . . . ១០.០០០,០០
- ប្រគល់ឲ្យគណៈកម្មការទស្សនាវដ្តីពន្លឺពុទ្ធចក្រ . ៥០.០០០,០០
- ទទួលបង្ហាន់ចំពោះមន្ត្រីសង្ឃ . . . . ១០.០០០,០០
- ទិញសម្ភារៈផ្សេង ៗ នៅការិយាល័យ . . . . ៦៨៤,០០
- ទិញទឹកក្រូចទឹកកកប្រគេនមន្ត្រីសង្ឃ . . . ១.៧៩៩,០០
- ជួយលោកគ្រូអនុគណខេត្តកោះកុង . . . . ១.០០០,០០
- កម្រងផ្កាដង្ហែព្រះសពព្រះមុនីកោសល (សោម-ឈុន) ៤៥០,០០
- ធ្វើកត្តប្រគេនព្រះសពព្រះសាសនមុនី (មាស-កង) ១.០០០,០០
- ឈ្នួលមនុស្សចាំផ្ទះ ពុ ម.ក. . . . . . ១.៨០០,០០
- បុណ្យថ្វាយព្រះរាជកុសល . . . . . ២.៥០៨,០០
- ចេញថ្លៃអាកាសយានឲ្យនិស្សិត គួប-គីឡេង . . ៣.៧៥០,០០
- ព្រហ្មទាននឹងវត្តផ្សេង ៗ . . . . . ១.៦២៥,០០

បូករួម . . . ២៧០.២៦៧៛៦៨

កាត់ប្រាក់ចំណាយនេះចេញអំពីប្រាក់ចំណូល ឃើញថាប្រាក់នៅសល់ត្រឹមថ្ងៃទី ៣១.១២.៦០ មានចំនួន៖

៣១៥.៦៧៦៛០២ ២៧០.២៦៧៛៦៨=៤៥.៤០៨៛៣៤ ៗ

សូមមហាសន្និបាតជ្រាបថា ពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ មានធនធានគិតត្រឹមថ្ងៃទី ៣១.១២.៦០ ដូចតទៅនេះ៖

- ប្រាក់ផ្ញើយកប្រតិលាភ . . . . . . . ៨៦០.០០០៛,០០
- ប្រាក់ផ្ញើនៅធនាគារ . . . . . . . . . ៨៧០៛,០០
- ប្រាក់សល់អំពីការិយបរិច្ឆេទឆ្នាំ ១៩៦០ . . . ៤៥.៤០៨៛,៣៤

រួមទាំងអស់ . . . ៩០៦ ២៧៨៛៣៤

បន្ទាប់មក លោក ញ៉យ-លុត បានដាក់បមហាសន្និបាតថា តាមប្រការ ៣ នៃបទបញ្ញាមានចែងថា មុននឹងបោះឆ្នោតជ្រើសរើសគណៈកម្មាធិការនាយកថ្មី, គណៈកម្មាធិការនាយកក្នុងដំណែង ត្រូវតែប្រកាសលាលែងតាមសម្ដេចរបស់ប្រធាន ៗ អាស្រ័យហេតុនេះគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៦០ ដែលមានខ្ញុំជាប្រធាន សូមប្រកាសលាលែងហើយ សូមមហាសន្និបាត ចាត់តាំងក្រុមអធិបាលបណ្ដោះអាសន្នមួយដែលមានប្រធាន ១ រូបនឹង លេខាធិការ ២ រូប ឲ្យធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការនាយក សម្រាប់ឆ្នាំ ១៩៦១ តទៅ ។

មហាសន្និបាតបានចាត់តាំងលោកហ្លួងសេនិយ អ៊ុក-ផាន់ ឲ្យធ្វើជាព្រឹទ្ធប្រធាន លោកឆៃ-វង្ស នឹងលោក សៅ-វ៉ែន ឲ្យធ្វើជាលេខាធិការ ។

អស់លោកដែលស្ម័គ្រចិត្ត ឈរឈ្មោះធ្វើជាគណៈកម្មាធិការនាយក សម្រាប់ឆ្នាំ ១៩៦១ ដូចមាននាមខាងក្រោមនេះ៖

១- លោក ញ៉យ-លុត
២- " គង់-សារ
៣- លោក នូ-ឯម
៤- " សំ-ហែម

៥- លោក បេ-យាន

៦- " អ៊ុង-គឹមងន

៧- " សោម-នៅ

៨- " ទា-ដាវលី

៩- " ប៊ុន-ថាន់

១០- " តាប-ខាន់ ហៅង៉ាន់

១១- " សោម-ដាំ

១២- លោកស្រី ដោក-ស៊ុដេត

១៣- លោកស្រី អ៊ុង-គឹមងន

១៤- " គង់-សារ

១៥- " ដុស-ដួង

១៦- " ចាយ-ធុល

១៧- " អ៊ុក-ដី

១៨- " ប៊ិន-ឈឹមសួន

១៩- " ព៉ាយ-លុត

២០- " សួរ-ធុំ

ក្រោយការប្រកាសសុំនាម អស់លោកឲ្យឈរឈ្មោះជាបេក្ខជនរួច ហើយលោក ឆៃ-វង្ស លេខាធិការព្រឹទ្ធប្រធានបានប្រកាសថា បើមហា-សន្និបាតពុំយល់ទាស់ទេ សូមអនុម័តិយកនាមអស់លោកដែលសុំគ្រប់ត្ត ទាំង ២០ រូបនេះ ឲ្យទៅជាគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៦១ តែម្តង ដោយពុំចាំបាច់បោះឆ្នោតជ្រើសរើសអ្វីឡើយ; ប៉ុន្តែរឿងនេះស្រេចនៅយោបល់ភាគច្រើននៃមហាសន្និបាត បើអស់លោកណាយល់ឃើញថាពុំចាំបាច់បោះឆ្នោតសូមមេត្តាលើកដៃ ។ ខណៈនោះ សមាជិកមហា-សន្និបាតបានលើកដៃជាឯកច្ឆន្ទ ពេញចិត្តទទួលយកអស់លោកទាំង ២០ រូប ដែលមាននាមខាងលើ ឲ្យធ្វើជាគណៈកម្មាធិការនាយកនៃពុទ្ធិកសមាគមកម្ពុជរដ្ឋសម្រាប់ឆ្នាំ ១៩៦១ ។

យើងសូមកត់សំគាល់ថា នៅពេលមហាសន្និបាតនេះ សម្ដេចព្រះមហាសុមេធាធិបតីជ.ណ.ព្រះសង្ឃនាយកគណៈមហានិកាយ បានធ្លៀតពេលនិមន្តមកថ្លែងអំណរចំពោះសមាជិក-ជិកាមហាសន្និបាត ជាពិសេសចំពោះសមាជិក-ជិកាគណៈកម្មាធិការនាយកសម្រាប់ ឆ្នាំ ១៩៦០-៦១ ដែលស្ម័គ្រចិត្តយកខ្លួនមកបំរើព្រះពុទ្ធសាសនា ដោយឥតគិតខ្ចាចនឿយហត់នឹងខាតបង់ផលប្រយោជន៍ផ្ទាល់ខ្លួន ។ ទីបំផុត សម្ដេចបានមានថេរដីកាផ្ដែផ្ដាំចំពោះសមាជិកទូទៅ ជាពិសេសសមាជិកផ្នែកខាងព្រះសង្ឃសុំឲ្យជួយយកព្រះទ័យយកចិត្តទុកដាក់ ធ្វើយ៉ាងណាឲ្យ ពុ ម.កមានដំណើរជឿនលឿនទៅមុខ កុំឲ្យចាញ់ប្រៀបពុទ្ធសមាគមនៅប្រទេសនានាខ្លះដែលពីដើមពុំធ្លាប់ចាំងជឿកាន់ពុទ្ធសាសនាផង, ឥឡូវនេះពុទ្ធសមាគមនៅប្រទេសនោះៗ ចំរើនរុងរឿងណាស់ទៅហើយ ដូចប្រទេសឥណ្ឌូនេស៊ីបែលហ្ស៊ិក និងម៉ាឡាយូជាដើម ។ សម្ដេចបានប្រសិទ្ធពរជ័យសិរីមង្គលសុំឲ្យអស់លោកសមាជិក-ជិកានៃ ពុ ម.ក ទូទៅបានប្រកបដោយពុទ្ធពរ ៤ គឺ អាយុៈវណ្ណៈសុខៈពលៈ គរៀងទៅ កុំបីប្រែក្លាយជាប្រការអ្វីឡើយៗ

គ្មានហេតុអ្វីប្លែក មហាសន្និបាតបានលើកនៅម៉ោង ២១ ។

កត់ហេតុធ្វើនៅមន្ទីរសំណាក់ការ ថ្ងៃ-ខែ ឆ្នាំដូចខាងលើ ។

ព្រឹទ្ធប្រធានៈ អ៊ុក-ផាន់

លេខាធិការ { សៅ-វ៉ែន / ឆៃ-វង្ស

# ពិធីសម្ពោធបើកការអប់រំវិជ្ជាគរុកោសល្យ

កិច្ចបើកពិធីសម្ពោធការអប់រំវិជ្ជាគរុកោសល្យ នៃលោកអាចារ្យបង្រៀនសាលាពុទ្ធិកបឋមសិក្សា ដែលនិមន្តមកពីខេត្តនានានឹងក្រុងភ្នំពេញ នៅថ្ងៃសុក្រទី៣ មីនា គ.ស. ១៩៦១ ។

កាលពីថ្ងៃទី ៣ មិនា ១៩៦១ ពេលម៉ោង ៧.៣០ នាទី នៅយ៉ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត មានកិច្ចបើកពិធីសម្ពោធការអប់រំវិជ្ជាគរុកោសល្យនៃលោកអាចារ្យសាលាពុទ្ធិកបឋមសិក្សា មានចំនួន ៣០០ អង្គ ជាលើកទី ៤ ។

បាននិមន្តនឹងអញ្ជើញមកជួបជុំ ផ្នែកខាងបព្វជិត :

- សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ
- សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ
- ព្រះតេជព្រះគុណព្រះពោធិវង្ស អគ្គាធិការពុទ្ធិកសិក្សា
- លោកសាស្ត្រាចារ្យ ពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត

ផ្នែកខាងគ្រហស្ថ :

សហជីវិន ស៊ិន-ប៊ុយកោ រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនៈសិក្សាធិការ

សហជីវិន កួង-សន នាយកការិយាល័យ ក្រសួងធម្មការ

សហជីវិន កែ-មេងហាប់ អគ្គលេខាធិការ ពុទ្ធិកមហាវិទ្យាល័យ

ព្រះសីហនុរាជ

លោកសាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត -

ពេលម៉ោង ៨ ព្រះតេជព្រះគុណព្រះពោធិវ័ង្ស ហួត-តាត អគ្គាធិការ ពុទ្ធិកសិក្សា បានហ្វាងនៃការអប់រំវិជ្ជាគរុកោសល្យនេះ មានព្រះពុទ្ធដីកា ដោយសេចក្ដីសង្ខេប ដាស់តឿនក្រើនរំលឹកលោកអាចារ្យជាគ្រូបង្រៀន ពុទ្ធិកបឋមសិក្សាឲ្យព្យាយាមសិក្សាវិជ្ជានេះ ជាយ៉ាងមាំមួនព្រោះជាវិជ្ជា មានសារៈសំខាន់ចំពោះគ្រូបង្រៀន ។

បំផាប់តមកសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហា-និកាយ ទ្រង់មានព្រះពុទ្ធដីកាទៅកាន់លោកសាស្ត្រាចារ្យពុទ្ធិកបឋមសិក្សា ថាៈ វិជ្ជាគរុកោសល្យនេះ ដែលជាវិជ្ជាសម្រាប់រចនាមនុស្សធម្មតាឲ្យទៅ ជាគ្រូអាចារ្យ លោកជាសាស្ត្រាចារ្យពុទ្ធិកបឋមសិក្សា ដែលបាននិមន្តមក ទទួលការអប់រំវិជ្ជានេះ សូមបំពេញកល្យាណកិច្ចរបស់លោក ដោយកុំ ប្រមាថចំពោះការសិក្សានេះ ព្រោះជាវិជ្ជាមានប្រយោជន៍ដ៏សំខាន់បំផុត ។

ក្រោយដែលសម្ដេចបានមានពុទ្ធដីកាអំពីលក្ខណៈវិជ្ជាគរុកោសល្យ គោលការណ៍នៃការបង្ហាត់បង្រៀនជមិសាមគ្គីជាដើម សម្ដេចបានបញ្ចប់ ព្រះសង្កថាៈ ប្រគេនពរសព្វសាធុការ ចំពោះលោកសាស្ត្រាចារ្យ ដែល បាននិមន្តមកទទួលការអប់រំជាអវសាន ។

រួចទើបសម្ដេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិកនិកាយ

បានមានព្រះពុទ្ធដីកា ទៅកាន់លោកអាចារ្យទាំងឡាយថា: ពេលនេះ ជាពេលដ៏ប្រសើរ លោកអាចារ្យបានមកទទួលការអប់រំជាដ៏វិសេសវិសាល កុំធ្វើវេលានេះឲ្យខូចទៅទទេ គួរតែប្រញាប់ប្រញាល់ធ្វើវេលានេះឲ្យមានសារៈប្រយោជន៍គ្រប់យ៉ាងតទៅ ព្រមទាំងខិតខំប្រឹងប្រែងនូវការសិក្សានេះឲ្យបានចម្រើនទៅមុខជាដើម ។

លំដាប់ពីនេះ សហជីវិន ស៊ុន-ប៊ុយកា រដ្ឋលេខាធិការ ក្រសួងធម្មការ នឹងសាសនៈសិក្សាធិការ បានថ្លែងនូវសុន្ទរកថាមួយដូចតទៅនេះ

X

X X

សុន្ទរកថា

សូមនមស្ការដោយគារវភាពយ៉ាងខ្ពង់ខ្ពស់ ចំពោះសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ។

សូមនមស្ការដោយគារវភាពយ៉ាងខ្ពង់ខ្ពស់ ចំពោះសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ។

សូមថ្វាយបង្គំ ចំពោះព្រះតេជព្រះគុណមហាថេរានុត្ថេរៈទាំងឡាយ,

សូមជំរាបអស់លោក-អ្នកទាំងឡាយ,

ខ្ញុំព្រះករុណា ខ្ញុំបាទគាំងនាមក្រសួងធម្មការ នឹងសាសនសិក្សាធិការ សូមថ្លែងនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅ ចំពោះសម្តេចទាំងពីរ

ព្រះឥន្ទ-ព្រះតេជព្រះគុណ ទាំងអស់លោក-អ្នកជាសប្បុរសទាំងឡាយ ដែលបាននិមន្ត ទាំងអញ្ជើញមកប្រមូលផ្តុំកិច្ចបើកពិធីសម្ពោធការអប់រំវិជ្ជាគរុកោសល្យ នៃលោកអាចារ្យជាគ្រូបង្រៀន សាលាពុទ្ធិកបឋមសិក្សា នៃព្រះរាជអាណាចក្រ ។ ការនិមន្តនិងអញ្ជើញមកនេះ ទុកជាកិត្តិយសដ៏ប្រសើរចំពោះក្រសួងនិងជាកិច្ចដ៏ប្រសើរពិសេស សម្រាប់លើកទឹកព្រះទ័យព្រះតេជព្រះគុណជាអាចារ្យគ្រប់អង្គ ឲ្យមានការព្យាយាមយ៉ាងម៉ឺងម៉ាត់ ចំពោះការសិក្សាវិជ្ជាគរុកោសល្យ នេះតទៅខាងមុខទៀត ។

ការអប់រំវិជ្ជាគរុកោសល្យនេះ មានមកបីលើកហើយ គឺលើកទី ១ ក្នុងឆ្នាំ ១៩៥៦ លើកទី ២ ក្នុងឆ្នាំ ១៩៥៨ លើកទី ៣ ក្នុងឆ្នាំ ១៩៦០ ។ ថ្ងៃនេះជាកាលបរិច្ឆេទនៃការបើកកិច្ចអប់រំវិជ្ជាគរុកោសល្យជាលើកទី ៤ ។ កល្យាណកិច្ចដ៏ប្រសើរនេះ ដែលនឹងកើតមានឡើងបានដោយសេចក្តីខ្នះខ្នែងនៃព្រះតេជព្រះគុណព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សាលោកយកព្រះទ័យទុកដាក់ចំពោះការរៀបចំពុទ្ធិកសិក្សា ឲ្យមានវឌ្ឍនភាពតទៅអនាគត ។ បើយើងសង្កេតមើលដាក់លាក់ចំពោះការអប់រំវិជ្ជាគរុកោសល្យទាំងបីលើកកន្លងទៅហើយ យើងអាចបានឃើញនូវលទ្ធផលដ៏ប្រសើរ គឺលោកអាចារ្យពុទ្ធិកបឋមសិក្សា ដែលបាននិមន្តចូលមកអប់រំវិជ្ជានេះហើយ ៗ ដែលមានចំណេះនឹងមធ្យោបាយបង្ហាត់បង្រៀនសមណសិស្សគ្រប់គ្រាន់បរិបូណ៌ ដើម្បីនឹងញ៉ាំងពុទ្ធិកសិក្សាឲ្យមានរបៀបរៀបរយល្អ

ឲ្យមានក្បួនច្បាប់សិក្សាដ៏ប្រសើរដែលបណ្ឌិតខាងវិជ្ជាគរុកោសល្យ បានពិសោធពីអតីតកាលមក បានសុកផលយ៉ាងក្រៃពេក ៗ ក្នុងការអប់រំនេះ យើងអាចសង្កេតឃើញ លោកអាចារ្យគ្រូបង្រៀនទាំងឡាយដែលបានមកទទួលការអប់រំរួចមកហើយ ពុំសូវជួបប្រទះនឹងការលំបាកក្នុងកិច្ចប្រតិបត្តិមុខងាររបស់លោក ៗ ឯលទ្ធផលនៃការបង្រៀនរបស់លោកទៀត ក៏ឃើញបានចំរើនដោយប្រពៃដែរ ៗ ព្រោះហេតុដូច្នេះ ព្រះតេជព្រះគុណគ្រូបង្រៀន ដែលបាននិមន្តមកអប់រំវិជ្ជាគរុកោសល្យនៅទីនេះ ព្រះតេជព្រះគុណនឹងបានក្រេបជញ្ជក់នូវវិជ្ជាដ៏វិសេសវិសាលនេះ លុះដល់ព្រះតេជព្រះគុណនិមន្តត្រឡប់ទៅកាន់វត្តអារាមវិញ ព្រះតេជព្រះគុណនឹងបានញុំាងពុទ្ធិកសិក្សាឲ្យមានពន្លឺភ្លឺស្វាងរុងរឿងតទៅអនាគត ៗ

ព្រះតេជព្រះគុណជាអាចារ្យបង្រៀនទាំងឡាយ ! ខ្ញុំព្រះករុណាសូមថ្លែងនូវសេចក្តីស្ញប់ស្ញែងដោយគោរព ចំពោះព្រះទ័យព្រះតេជព្រះគុណដែលបានព្យាយាមលះបង់នូវពេលវេលានិមន្តចូលមកទទួលការអប់រំ ក្នុងឱកាសនេះអស់រយៈកាលមួយខែ ដើម្បីជាប្រយោជន៍នៃពុទ្ធិកសិក្សារបស់យើង ៗ ពិតមែនតែព្រះតេជព្រះគុណបានអប់រំខាងវិជ្ជាគរុកោសល្យល្អហើយ តែបើគ្មានធម៌សាមគ្គី ព្រះពុទ្ធសាសនាប្រទេសយើង មិនអាចឡើងទៅកាន់វឌ្ឍនភាពបាន ៗ ដោយហេតុនេះហើយបានជាខ្ញុំព្រះករុណាមានសេចក្តីសង្ឃឹមយ៉ាងមាំ ចំពោះព្រះតេជព្រះគុណជាគ្រូបង្រៀន

ទាំងឡាយ ជាព្រះអង្គមុខជានឹងប្រព្រឹត្តប្រតិបត្តិតាមធម៌និងវិន័យដែលជាឪវាទនៃព្រះបរមគ្រូសម្មាសម្ពុទ្ធជាម្ចាស់នៃយើង ញ៉ាំងសាមគ្គីធម៌ឲ្យកើតមានឡើងនៅក្នុងខន្ធសន្តាន ជួយរម្ងាប់អធិករណ៍ដែលផុសផុលឡើងឲ្យវិនាសសាបសូន្យ រក្សាសេចក្តីស្ងប់រៀបរយនៅក្នុងវត្តអារាម បំពេញវត្តនភាពនូវកល្យាណកិច្ច សន្តោសគ្នាទៅវិញទៅមកដោយមិត្តភាពការភាព និងសីលធម៌ ទើបព្រះពុទ្ធសាសនាប្រទេសកម្ពុជា និងបានអណ្តែតត្រសែត និងសន្តិភាព ព្រមទាំងសេចក្តីសុខជាកិយ្យាភាពតទៅៗ

ជាអវសានខ្ញុំព្រះករុណាសូមគុណានុភាពព្រះរតនត្រ័យ ប្រសិទ្ធិពរសូមសម្តេចទាំងពីរព្រះអង្គ ព្រះតេជព្រះគុណគ្រប់អង្គ និងអស់លោកអ្នកទាំងឡាយ ប្រកបដោយសុវត្ថិជ័យមង្គលសិរីសួស្តីគ្រប់យ៉ាង ព្រមទាំងអាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ; សូមព្រះពុទ្ធសាសនាផ្សាយរីកពេញសាកលលោក ទៅកាន់សន្តិភាពដ៏ប្រសើរ កុំបីអាក់ខានឡើយ ៗ

ពិធីបើកការអប់រំវិជ្ជាគរុកោសល្យនៃលោកអាចារ្យ ជាគ្រូបង្រៀនសាលាពុទ្ធិកបឋមសិក្សា បានបញ្ចប់នៅពេលម៉ោង ១០ ៗ

# ដំណឹងផ្សាយចេញពីក្រសួងធម្មការ

នៅឱកាសដែលបងប្អូនខ្មែរកម្ពុជាក្រោម បានទទួលរងទុក្ខវេទនា ដោយការជិះជាន់ពីរដ្ឋាភិបាល ង៉ោ-ឌិន-យៀម ហើយបានភៀសខ្លួន មកនៅ វត្តកំផិន ស្រុកគិរីវង្ស ខេត្តតាកែវ ដោយនៅក្នុងចំណោមនោះ មានព្រះសង្ឃចំនួន ១៧ អង្គផង, ដើម្បីជួយសម្រាលព្រះទ័យនៃព្រះសង្ឃ ទាំងនោះ លោក ស៊ិន · ប៊ុយកោ រដ្ឋលេខាធិការក្រសួងធម្មការបាននាំ យកគ្រឿងបរិក្ខារ ដែលបានមកពីសេចក្តីជ្រះថ្លានៃបុគ្គលិកនៅក្រសួងនេះ ទៅប្រគេនកាលពីថ្ងៃទី ២២ មីនា ១៩៦១ គឺព្រះសង្ឃមួយអង្គ ៗ បាន ប្រគេនស្បង់ ១, តែ ១ កញ្ចប់, ស្ករ ១ ប្រអប់, ឈើគូស ១ ហោ, បារី ៤ កញ្ចប់, ទៀន-ធូប, សាប៊ូ ១ ដុំ នឹងផ្ទឹក ១ ។

កាលពីថ្ងៃទី ២៤ មីនា ១៩៦១ លោករដ្ឋលេខាធិការក្រសួងធម្មការ និងសាសនសិក្សាធិការ បានចាត់សហការីរបស់លោក ឲ្យនាំយកគ្រឿង បរិក្ខារ ដែលបានមកពីសេចក្តីជ្រះថ្លា នៃបុគ្គលិកនៅក្រសួងនេះដដែល ទៅជូន សហជីវិនចៅហ្វាយខេត្តតាកែវ ដើម្បីចាត់ឲ្យប្រគេនព្រះសង្ឃ ៦ អង្គជាលើកទី ២ ម្តងទៀត ដែលទើបនិមន្តមកពីកម្ពុជាក្រោម ហើយ មកគង់នៅ វត្តកំផិន ស្រុកគិរីវង្ស ខេត្តតាកែវ ដែលបណ្តាលមកពីការ ជិះជាន់នៃរដ្ឋាភិបាល ង៉ោ-ឌិន-យៀម ។ ឯគ្រឿងបរិក្ខារនោះ មានដូចកាលប្រគេនលើកមុនដែរ ។

ព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត និងសម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ។ ក្នុងពិធីបុណ្យនេះ បាននិមន្តព្រះសង្ឃព្រះរាជាគណៈ ព្រះនានុក្រម-មេគណ-អនុគណ ចៅអធិការវត្ត ក្នុងព្រះរាជធានីនិងខេត្តក្រៅ ចំនួន ១១១ អង្គ ដើម្បីទទួលទេយ្យទាន ។

នៅថ្ងៃសៅរ៍វេលាម៉ោង ១៩, សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត និងសម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងមកដល់ ។ ភ្លាមនោះទ្រង់ប្រគេនចីវរចំពោះព្រះសង្ឃចំនួន ១១១ អង្គគ្រង់ ។ ក្រោយពីការប្រគេនចីវរ, ទ្រង់នមស្ការព្រះរតនត្រ័យ សមាទាននិច្ចសីល និងទ្រង់ព្រះសណ្តាប់ព្រះបរិត្តមួយអន្លើ ជាមួយពុទ្ធបរិស័ទរួចហើយ សម្តេចព្រះមាតាជាតិ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ព្រះរាជនិវត្តន៍ទៅកាន់ព្រះរាជដំណាក់វិញ ។ តពីនោះមក ពុទ្ធបរិស័ទបាននិមន្តព្រះធម្មកថិក ២ អង្គ សំដែងធម៌ទេសនា បុច្ឆាវិសជ្ជនា ត្រៃគីរ ។

ព្រឹកឡើងថ្ងៃអាទិត្យ វេលាម៉ោង ៩ សម្តេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិត និងសម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងទៅព្រះរាជទានការប្រោះព្រំព្រះសុគន្ធវារី លើព្រះហស្តសម្តេចព្រះសង្ឃនាយកជានិម្មិតរូប, នៃការប្រគេនស័ព្ទុការភារ ។

ក្រុមពុទ្ធសាសនបណ្ឌិត្យ បានចូលរួមក្នុងពិធីបុណ្យនេះដែរ សូមប្រសិទ្ធិពរបវរសួស្តី សិរីមង្គលវិបុលសុខមហាប្រសើរគ្រប់ប្រការ ចំពោះសម្តេច សូមសម្តេចជាម្ចាស់មានព្រះជន្មវស្សាយឺនយូរតទៅ ។ ដើម្បីដឹកនាំពុទ្ធបរិស័ទនិងពុទ្ធសាសនានៅប្រទេសកម្ពុជា ឲ្យបានរុងរឿងភ្លឺត្រចះត្រចង់ផ្សព្វផ្សាយពេញសាកលលោក ។

ពុទ្ធសាសនបណ្ឌិត្យ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣៣ លេខ ៤ ខែមេសា

ព.ស. ២៥០៤ ; គ.ស. ១៩៦១

ភ្នំពេញ

# ពិធីបុណ្យបូជាសពព្រះតេជព្រះគុណ អ៊ុក អ៊ុន មេគណ

## ខេត្តតាកែវ

កាលពីថ្ងៃទី ២១ ខែមេសា ១៩៦១ សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ បានស្តេចយាងជាព្រះរាជាធិបតីភាព ក្នុងពិធីបុណ្យបូជាសពព្រះតេជព្រះគុណមង្គលទេព្វលោករង្សី អ៊ុក-អ៊ុន (សុទ្ធបញ្ញោ) រាជាគណៈ អតីតមេគណខេត្តតាកែវ ដែលប្រារព្ធធ្វើនៅវត្តសីហាតេនាកម ។

នៅឱកាសនោះ គេសង្កេតឃើញ ផ្នែកខាងឥស្សរសមណៈគឺ: សម្តេចព្រះសង្ឃនាយកគណៈមហានិកាយ និងព្រះសង្ឃជាច្រើនរយអង្គ ។

ផ្នែកខាងឥស្សរជនជាអាទិ៍គឺ : ឯ.ឧ. គូ-រុន សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក, សហជីវិន ស៊ិន - ប៊ុបូកោ រដ្ឋលេខាធិការក្រសួងធម្មការ, សហជីវិន កុល - ឈឺន, សហជីវិន អ៊ុន - គាំ ចៅហ្វាយខេត្តតាកែវ និងឥស្សរជនឯទៀតជាច្រើនដែលយើងពុំអាចកប់នាមឲ្យសព្វគ្រប់, បាននិមន្ត-អញ្ជើញទៅរួបរួមក្នុងពិធីនេះដែរ ។

ក្រោយដែលសហជីវិន ខេស-លឹម អតីតតំណាងរាស្ត្រ ជាប្រធានគណៈកម្មការបុណ្យ បានថ្លែងនូវជីវប្រវត្តិនៃព្រះសព និងវិយោគកថារួចហើយ, សម្តេចព្រះបិតាឯករាជ្យជាតិទ្រង់បានថ្លែងនូវព្រះសង្កថា ឥតព្រាងទុកមួយយ៉ាងវែង ហើយពីរោះក្បោះក្បាយ ។ បន្ទាប់មកទ្រង់ប្រារព្ធពិធីខមាទោស ដោយបូជាភ្ញីផ្កានិងគ្រឿងក្រអូបចំពោះព្រះសព រួចទ្រង់ប្រទានភ្លើង ។

តទៅ . . .

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ


*ផ្នែកសាសនា* បញ្ជីរឿង *ទំព័រ*

- វិហារណកថា អំពីគោលសំខាន់នៃព្រះពុទ្ធសាសនា លោក ផល-ទិត្យ រៀបរៀង ៣៥៧
- ពុទ្ធដីវប្បវត្តិ (តមក) ព្រះមហា ប៉ាង - ខាត់ រៀបរៀង . . . ៣៦៨
- ព្រះនិព្វាន ឬនិព្វាណ លោកកុម្ម៉ង់ដង់ រូបែរត៍ រៀបរៀង ក្រមការ ដុំ - មៅ ប្រែ· ៣៨១
- ព្រះអភិធម្មបិដក គម្ពីរព្រះយមក លោក ប៉ូ - ប៉ូ រៀបរៀង . . . ៣៩២
- មធុរសវាហិណី(ត)សម្ដេចព្រះធម្មលិខិតល្វី-ឯម ប្រែ ព្រះញ.ឈីន ពិនិត្យ . . . ៤០១
- មហោសថជាតក(ត):លោកអ៊ុម-ភនចម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-គួរពិនិត្យ . ៤០៦

*ផ្នែកអក្សរសាស្ត្រ*

- វប្បធម៌ខ្មែរ (តមក) លោក លី-ធាមតេង រៀបរៀង . . . ៤១២
- ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការវប្បធម៌ . . . . . . . . ៤១៦
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង - ខាត់ រៀបរៀង . . . ៤១៧
- រឿងសាមកុក (តមក) ឧកញ៉ា នូ - កន ប្រែ . . . . ៤១៨
- រឿងមនុស្សចិត្តប្រែប្រួល លោក ប៉ូ - ប៉ូ រៀបរៀង . . ៤២៩
- រឿងចៅកំដិលហៅចៅគ្រឹប លោក ម៉ាន់-អេង រៀបរៀង ៤៤០
- រឿងព្រេងប្រទេសម៉ិចហ្សិក អំពីផ្លែព្រៃនិងផ្លែស្រុក ភិក្ខុ ម៉ែន-រៀម ប្រែ . . ៤៤៥
- រឿងអ្នកតាក្រហមក (តាមឯកសារទំនៀមទម្លាប់ខ្មែរ) . . . . . . . ៤៥២

*ផ្នែកកំណត់នឹងប្រវត្តិការណ៍*

- ពិធីទទួលសៀវភៅ នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ . . . . . ៤៦៥



មួយឆ្នាំ មាន ១២ សៀវភៅ តំលៃជារៀល ២៣០ រ ០០

33e Année — N° 4 — Avril 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire

### Partie religieuse

Pages

— Editorial " Les principes du Bouddhisme " par *M. PHAL TIT* . 357

— La Vie du Buddha (suite) par Vèn · *PANG-KHAT* . . . . 368

— Le Nirvana par le Commandant *ROBERT* . . . . . . . . . 381

— Prah Abhidhammapitaka (Kampi preah Yamaka) par *M. BOU - PO* . . . . . 392

— Madhurasavahini (suite) par Samdech Preah Dhammalikhita *LOUIS - EM*, revu et corrigé par Vèn · *NHÉAN - CHHOEUN* . . . 401

— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM - PHON*, revu et corrigé par Vèn · *KEM - TO* . . . . 406

### Partie littéraire

— La Culture Khmère (suite) par *M. LY-THEAM-TENG* . . 412

— Activités de la Commission Culturelle . . . . . . . . . . . . . . 416

— Dictionnaire Sanscrit-Khmèr (suite) par Vèn · *PANG-KHAT* . . 417

— Histoire de Sam-Kok (suite) traduite par Oknha *NOU - KAN* . . . . . . . 418

— Histoirè d'un homme au caractère changeant par *M.BOU PO* 429

— Chau kreb le pàresséux, par *M. MANN ENG* . . . . . 440

— Légende du mexique "Le loup et le chien" par Vén *MEN-RIEM* . 445

— Nak - tà kraham - kàr d'après les documents dè la commission des mœurs et coutumes . . . . . 452

### Notes et chroniques

La remise des livres par l'Ambassade le Chine Populaire à l'Université Preah Sihanouk Reach . . . . 456

Prix d'abonnement annuel (comprenant 12 numéros): 23o/oo

## ផ្នែកសាសនា

### វិចារណកថា

# អំពីគោលសំខាន់នៃពុទ្ធសាសនា

លោក ជល ធិត្យ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

សព្វថ្ងៃនេះ ទ្រឹស្ដីខាងវិទ្យាសាស្ត្រ ដែលមានសម្ភារនិយមជាទីតាំង បានឡើងដល់កំរិតអតិបរមានៃការវិវឌ្ឍន៍ ៗ ឯទ្រឹស្ដីខាងចិត្តនិយម បើកំណត់តាមភាគប្រតិបត្តិក៏ឃើញថា មានដំណើរយឺតជាទីបំផុត ៗ

ដោយករណីនេះ ទើបខ្ញុំចង់មករួមសន្ទនាជាមួយនឹងលោកអ្នកអានទូទៅ ដើម្បីជាសេចក្ដីរំឭកដាស់តឿនមនោសញ្ចេតនានៃពលរដ្ឋខ្មែរយើង ដែលធ្លាប់ផ្ដាតទឹកចិត្តយ៉ាងធ្ងន់ទៅក្នុងពុទ្ធសាសនា មកយូរកាលហើយ ឲ្យបានរឹងរឹតតែយល់ច្បាស់ឡើងវិញថា ពុទ្ធសាសនា ជាទ្រឹស្ដីចិត្តនិយម ដែលយើងពេញចិត្តកាន់ប្រតិបត្តិតាមជាតំណពីបុព្វបុរសរបស់យើងមកនេះ មានគោលបំអាងជាក់ច្បាស់ណាស់ ហើយជាងជាសាសនាអាចប្រគល់នូវឧត្តមប្រយោជន៍ ដល់យើងដែលជាពុទ្ធជនពិតមែនៗ

បច្ចុប្បន្នកាលនេះ យើងបានដឹងច្បាស់ថា មានមតិរបស់ជនខ្លះ ក្នុងលោកសម័យនេះ ដែលមិនត្រឹមតែមិនជឿពុទ្ធសាសនាប៉ុណ្ណោះទេ
ៗ

ថែមទាំងបញ្ចេញរូបភាពយ៉ាងច្បាស់លាស់ដោយពេលហារមិនគប្បី ជាហេតុនាំពុទ្ធជនឲ្យរាកចិត្ត បែរចេញចាកព្រះពុទ្ធសាសនាទៀតផង ។ គោលសំខាន់បំផុតក្នុងខបំបែកបំបាក់សាសនិកសាមគ្គីរៀងនេះ គេចំដើរស្រាវជ្រាវរកប្រកពសំខាន់ ៗ នៃកំហុសខ្វះ ក្នុងវណ្ណកម្មរបស់ពុទ្ធជនយើងពីសម័យបុរាណ ដែលជាការនិពន្ធហួសកាលៈទេសៈទៅហើយ មកជាគោលការប្រតិវត្តន៍ គឺគេចាប់យកកំហុសទាំងនោះលើកឡើងបង្ហាញយុវជនខ្មែរយើងគ្រប់ប្រភេទថា "ពុទ្ធសាសនា មិនមែនជាលទ្ធិពិតទេ គឺជាលទ្ធិប្រកបដោយការល្ងង់ខ្លៅនៃមនុស្សបុរាណ ឬក៏ជាការបោកប្រាស់នៃពួកមូលធននិយម" ទៅវិញ ។ គេយកជញ្ជាំងផ្សេងខ្លៅមកបាំងក្នែកយុវជនយើង ដែលនៅខ្វះយការចេះដឹងផ្លូវពុទ្ធសាសនា ហើយហ៊ានសំដែងចេញទ្រឹស្តីមួយដែលឥតច្បាស់លាស់ក្នុងខ្លួនសោះថា "មនុស្សស្លាប់ហើយ សូន្យ, គ្មានបរលោក, គ្មានសួគ៌និព្វាន គ្មានបុណ្យ-បាបណា សម្រាប់មនុស្សស្លាប់ទៅហើយនោះឡើយ" ។ គេពន្យល់ដោយបញ្ជាក់យ៉ាងមាំទៀតថា "សម័យនេះ ជាសម័យបរមាណូ ជាសម័យស្ពុតនិក គឺជាសម័យហួសការជឿរបស់ស្រពេចស្រពិលស្រមើស្រមៃដែលមិនដឹងជានៅឯណានោះទៀតហើយ, គេត្រូវជឿយកតែរបស់ប្រត្យក្សមែន ៗ ប៉ុណ្ណោះ" ។ មិនត្រឹមតែប៉ុណ្ណោះ គេហ៊ានបដិសេធ សីល-

ទាន ភាវនា ដែលជាគោលធំមួយផ្នែក នៃការប្រតិបត្តិរបស់ពុទ្ធសាសនា ថា "ជារបស់គ្មានផលទៅលោកឯណាសោះ" ទៀតផង ៗ ឯអ្នកនិពន្ធសម័យបុរាណ ដែលរៀបចំអត្ថបទតាមលំនាំពុទ្ធសាសនានោះ ត្រូវគេចាត់ទុកថាជា "មនុស្សល្ងង់ មានប្រែះនៅក្នុងខ្លួន មិនចេះរិះគិតរកសេចក្ដីពិតតាមហេតុ-ផល ចេះតែជឿគេទាំងងងឹតងងល់" ៗ តើលោកអ្នកអានយល់ថា គេនិយាយសមដែរឬទេ ?

បើតាមយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំ ដែលជាពុទ្ធសាសនិកជនមួយរូបវិញ អស់លោកអ្នកនឹងឃើញច្បាស់តាមដំណើរសេចក្ដីដែលខ្ញុំសរសេរទុកខាងមុខនេះ ប៉ុន្តែមុនដំបូង ខ្ញុំគ្រាន់តែសូមបិត្តជនទាំងនោះ ឲ្យរើគំនិតពិនិត្យជាថ្មី នូវគោលសំអាងនៃពុទ្ធសាសនាឲ្យច្បាស់លាស់សិនសឹមវិនិច្ឆ័យថា "ល្អ ឬអាក្រក់" ព្រោះពុទ្ធសាសនា ជាវិស័យរបស់អ្នកដែលចេះដឹង បរិបូណ៌ដោយទស្សនៈ នឹងមានឧត្តមគតិពិរោះ ៗ តែប៉ុណ្ណោះ ហើយនៅឆ្ងាយណាស់ អំពីពួកមនុស្សដែលមិនយល់ព្រះសទ្ធម្មគោលគឺសេចក្ដីពិតក្នុងសាសនា ៗ

តទៅនេះ ជាការបើកបញ្ចាក់ទ្រឹស្ដី ដែលគេប្រកាន់យកសព្វថ្ងៃនេះ នឹងជាសេចក្ដីបញ្ជាក់ឲ្យឃើញកស្តុតាងនៃពុទ្ធសាសនា ដើម្បីយកមកប្រៀបធៀបនឹងការស្វែងរកសេចក្ដីពិត តែនៅខាងដើម សូមលោកអ្នកអានពិនិត្យយ៉ាងម៉ត់

ចត់នូវទ្រឹស្ដីចាស់បុរាណ ២ ប្រភេទ ដែលកើតឡើងប្រែនសតវត្សរ៍មុនពុទ្ធសាសនាមកហើយនោះឲ្យច្បាស់លាស់សិន ។ ទ្រឹស្ដី ២ ប្រភេទនោះគឺ

១– ទ្រឹស្ដីថា: មនុស្ស ឬសត្វ ស្លាប់ហើយពិតជាសូន្យគឺគ្មានទៅកើតក្នុងពិភពលោកឯណាទៀតឡើយ (ឧច្ឆេទទិដ្ឋិ);

២– ទ្រឹស្ដីថា: មនុស្ស ឬសត្វ ស្លាប់ហើយត្រូវទៅកើតទៀត ប៉ុន្តែកើតមកទៀត គឺធ្លាប់កើតជាអ្វី ក៏មកកើតជានោះដដែល ឥតប្រែក្លាយពីសភាពដើមឡើយ ដូចជាធ្លាប់កើតជាមនុស្ស លុះស្លាប់ទៅ ក៏មកកើតជាមនុស្សវិញដដែល មិនប្រែក្លាយមកកើតជាសត្វឡើយ, ឯសត្វក៏ដូចគ្នា គឺមិនប្រែក្លាយទៅកើតជាមនុស្សវិញបានឡើយ ( សស្សតទិដ្ឋិ ) ។

ទ្រឹស្ដីទាំង ២ ប្រភេទនេះ បើសង្កេតឲ្យល្អិតទៅ ក៏អាចយល់បានថា វានៅរួមចូលក្នុងគោលគំនិតតែមួយថា ការធ្វើបាប-បុណ្យ, អាក្រក់-ល្អគ្រប់យ៉ាង ជាការឥតអំពើ គឺគ្មានផលទៅក្នុងពិភពលោកឯណាទៀតឡើយ, ប្រៀបដូចជាអ្នកណាមួយធ្វើខុសនឹងច្បាប់ដែលមានសម្រាប់គេជាដើម អ្នកនោះត្រូវតែវែលគិតយ៉ាងម៉េច ឲ្យតែខំខ្វះខ្វែងក្នុងបច្ចុប្បន្ននេះ គឺជាការស្រេច ។ ដំណើរដូច្នេះហើយ បានជាទ្រឹស្ដីទាំង ២ នេះ មាន

ពួកវណ្ណៈខ្ពស់ នឹងពួកមូលធននិយមទូទាំងសកលលោក នាំគ្នាទទួលយកទៅធ្វើតាមប្រតិបត្តិ ហើយទាំងជួយជ្រោមជ្រែងយ៉ាងមាំមួន ទៅជាទ្រឹស្តីល្អបំផុតក្នុងពិភពលោកនេះទៀតផង ព្រោះថា ពួកវណ្ណៈខ្ពស់ បើអនុវត្តតាមទ្រឹស្តីនេះ ក៏ស្រួលងាយដល់ការរស់នៅក្នុងឋានៈដ៏ថ្លៃរបស់គេៗ

លុះពេលខាងក្រោយមកជាច្រើនសតវត្សរ៍ ព្រះពុទ្ធបរមគ្រូនៃយើង កាលទ្រង់នៅជាព្រះសិទ្ធត្ថមហាសត្វនៅឡើយ ទ្រង់ចេញពីចំណោមពួកវណ្ណៈខ្ពស់ ( មូលធននិយម ), ដែលជាអ្នកបរិបូណ៌ដោយគ្រឿងកាមគ្រប់បែប ( កាមសុខល្លិកានុយោគ ), ហើយទ្រង់ប្រឹងដើរស្វែងរកឧបាយបំបាត់សេចក្តីទុក្ខរបស់ពិភពលោក ( នេក្ខម្ម: ), រហូតទ្រង់បានធ្វើទុក្ករ-កម្មគ្រប់បែបឥតបន្ទោះ តាមរបៀបលទ្ធិចាស់ ដែលគេធ្លាប់ប្រព្រឹត្តមកយូរកាលហើយ ដើម្បីពិសោធរកសេចក្តីពិត ក្នុងលទ្ធិទ្រឹស្តីទាំងអស់នោះ ប៉ុន្តែលទ្ធផលក៏បានផ្ទុយពីសេចក្តីព្យាយាមទៅវិញ គឺបានត្រឹមតែការនឿយលំបាកកាយទៅទទេប៉ុណ្ណោះ (អត្តកិលមថានុយោគ) ឥតបានផលពិសេសណាមួយ ដើម្បីយកមកដោះស្រាយពិភពលោកនេះ ឲ្យរួចពីសេចក្តីទុក្ខលំបាកបានសោះឡើយ ។ លុះទីអវសាន ទ្រង់ក៏ត្រូវតែលះបោលទ្រឹស្តីទាំងនោះចេញ ដោយទស្សនវិជ្ជាយ៉ាងខ្ពស់បំផុត ហើយទ្រង់ប្រតិបត្តិតាមផ្លូវល្មម ( មជ្ឈិមាបដិបទា ) ដែលកើតជាក់ច្បាស់អំពី

ការពិសោធន៍យ៉ាងម៉ត់ចត់របស់ព្រះអង្គ ។ លុះផ្លូវល្អ (អដ្ឋង្គិកមគ្គ) កើតឡើងយ៉ាងនេះហើយ លទ្ធផលយ៉ាងល្អបណ្តាច់ គឺសព្វញ្ញុតញ្ញាណ (ប្រាជ្ញាដែលដឹងច្បាស់ឥតក្លាត់នូវហេតុ-ផលគ្រប់យ៉ាង) ក៏កើតឡើងដោយពេញលក្ខណៈ ឥតខ្ចោះ ចំពោះព្រះអង្គគ្មានលំបាក ។ ក្រោយពីពេលនេះមក ព្រះអង្គក៏បានប្រកាសជាឧឡារិកនូវទ្រឹស្តី (សាសនា) ដែលទ្រង់បានត្រាស់ដឹងហើយនោះដល់ពិភពលោក ។ ការប្រកាសទ្រឹស្តីថ្មីនៃព្រះពុទ្ធបរមគ្រូជាម្ចាស់នេះ ក៏លេចចេញអានុភាពយ៉ាងអស្ចារ្យហាក់ដូចជាខ្ទះទាំង ៧ មកបាញ់ខ្ទប់ ទ្រឹស្តីទាំងពីរខាងលើនេះឲ្យតាំងគ្រឿងចក្រមិនឲ្យធ្វើវិវត្តន៍ទៅបាន ហើយទៅទីបំផុត ទ្រឹស្តីទាំងពីរនេះក៏វិលថយក្រោយទៅរកកន្លែងលាក់ខ្លួនពួនអាត្មាវិញ ។ ឯលទ្ធផលនៃការប្រកាសទ្រឹស្តីរបស់ព្រះបរមគ្រូក៏ឃើញថា តាំងតែពីសម័យនោះមក មនុស្សលោកមានការវិវត្តន៍យ៉ាងខ្លាំងក្នុងការបំបាត់ចោលនូវពួកមូលធននិយម និងការរំលាយវណ្ណៈខ្ពស់-ទាបឲ្យចូលគ្នាបានជាដើម ហើយទាំងបានសម្រេចបុទ្ធិ អំណាចផ្សេង ៗ ដែលគេចផុតពីការរំលោភសិទ្ធិរវាងគ្នា និងការនៅរួមរស់ជាមួយគ្នាជាសុខយ៉ាងប្រពៃ រហូតដល់បានរួចផុតចាកសេចក្តីទុក្ខលំបាកក្នុងពិភពលោក (និព្វាន) ជាច្រើនទៀតផង ។ នេះឯងជាដំណើរនៃលទ្ធផលនៃការប្រកាសទ្រឹស្តីរបស់ព្រះពុទ្ធបរមគ្រូនៃយើង ។

ដូច្នេះ យើងអាចយល់បានដោយងាយថា ទ្រឹស្ដីដែលបដិសេធផលនៃបាប-បុណ្យនេះ មិនមែនជាទ្រឹស្ដីថ្មីទេ គឺជាទ្រឹស្ដីចាស់បុរាណជាងគេយូរណាស់មកហើយ, ជាទ្រឹស្ដីធ្លាប់ធ្វើជាគ្រឿងចក្រឲ្យពួកវណ្ណៈខ្ពស់ជិះជាន់លើពួកវណ្ណៈទាប, ជាទ្រឹស្ដីដែលព្រះពុទ្ធទ្រង់លុបចោលទៅហើយ ទាំងជាទ្រឹស្ដីមានប្រៃះចាប់ដិតនឹងរលាយខ្លួនបាត់ទៅហើយផង ប៉ុន្តែជាក័ព្វល្អ ទ្រឹស្ដីចាស់នេះបែរជាមានមនុស្សលោកគាគខ្លះ លើកយកមកក្រៀឡខាត់លាបលនបន្ទំថាជារបស់ថ្មី មិនទាន់មានប្រៃះចាប់ទៅវិញ ។ គ្រង់នេះ សូមលោកអ្នកអានកុំសន្មត់ថា ខ្ញុំជាអ្នកប្រមាថបៀតបៀនមើលងាយលទ្ធិ ទ្រឹស្ដី សាសនាឯទៀតឡើយ គឺខ្ញុំគ្រាន់តែចាប់បើកបង្ហាញនូវការតែបន្ទំថា ជារបស់គ្មានប្រៃះចាប់ នៃមនុស្សខ្លះក្នុងលោកនេះ ដែលស្មានដោយឥតខ្មាសថា គំនិតរបស់ខ្លួនជាគំនិតត្រូវប៉ុណ្ណោះ ។ ចំណែកការត្រូវនឹងខុសរបស់ទ្រឹស្ដីទាំងនេះ សូមលោកអ្នកអានមករួមគិតវិនិច្ឆ័យជាមួយនឹងខ្ញុំតទៅទៀត ដើម្បីឲ្យឃើញសំអាងរឹតតែច្បាស់លាស់ឡើង ។

កាលបើនឹងវិនិច្ឆ័យរកសេចក្ដីពិតក្នុងរឿងនេះ យើងគប្បីកស្រាវជ្រាវដល់រឿងកើត (ជាតិ) នឹងរឿងស្លាប់ (មរណៈ) មកជាមួយផង ព្រោះវាមានដំណើរទាក់ទងគ្នា ។ កាលណាយើងដោះស្រាយបញ្ហាការកើត (ជាតិ) នឹងបញ្ហាការស្លាប់ (មរណៈ) រួចហើយ; ការសម្រេចថា

ទ្រឹស្តីណាជារបស់ពិត ណាជារបស់មិនពិត នឹងផ្តល់នូវភស្តុតាងជាសំអាង ដល់យើងបានភ្លាម ។

តាមពិត ធម្មជាតិគ្រប់យ៉ាង មានរុក្ខជាតិ នឹងតិណជាតិជាដើម ដំបូងកើតចេញមកពីមូលធាតុ (អវិជ្ជា) ដែលរួបរួមផ្សំផ្គុំគ្នា (សង្ខារ) ឡើង ។ លុះដុះចេញជារូបរាងសណ្ឋានទ្រង់ទ្រាយទៅតាមសភាពរៀងខ្លួនហើយ វាក៏ប្រឹងបញ្ចេញល្បឿនលូតលាស់ឡើងទៅទៀតតាមលំដាប់ ដោយស្រូបយកធម្មជាតិដដែលនេះជាអាហារចិញ្ចឹមខ្លួន ។

សូមបញ្ជាក់ថា ដើម្បីងាយយល់ ខ្ញុំសូមលើកយកតែពួករុក្ខជាតិ ម្យ៉ាងប៉ុណ្ណោះមកជាឧទាហរណ៍ ។ គឺតាមធម្មតា ពួករុក្ខជាតិ វាគ្មានចេះដឹងឈឺចាប់ ក្តៅត្រជាក់ ឬនិយាយស្តីអ្វីទេ, វាមិនចេះកំរើកដោយខ្លួនឯង មិនចេះដេក-ដើរជាដើមគ្រប់យ៉ាង ព្រោះវាជាធម្មជាតិគ្មានចិត្ត-វិញ្ញាណ តិចតួច ដើម្បីជាគ្រឿងដឹងស្គាល់ដំណើរពិតពលោកនេះសោះឡើយ ប៉ុន្តែ បើទុកជារុក្ខជាតិទាំងនោះ គ្មានមនោ-ចិត្ត-វិញ្ញាណឲ្យមាំមួនក៏ដោយ បើ ពិនិត្យទៅក៏គង់ឃើញមានមនោធាតុយ៉ាងស្តួចស្តើងមួយ ដែលមិនទាន់ យកជាការបាននៅជាប់ក្នុងវានោះដែរ គឺក្នុងខណៈដែលធម្មជាតិ ដី ទឹក ភ្លើង ខ្យល់ អាកាសរួមចូលលាយឡំនឹងគ្នាយូរទៅ ផលនៃសម្បយោគ ធម្មជាតិនេះ ក៏ក្លាយចេញជាធម្មជាតិម្យ៉ាងឡើងទៀត គឺដុះចេញជារុក្ខ-

ជាតិមួយដើមឡើង ហើយរុក្ខជាតិនេះ មិនមែនមានតែកង់ដើម-ស្លឹក-មែក ជាងប៉ុណ្ណោះទេ វាមានធម្មជាតិម្យ៉ាងដែលនៅជាប់នឹងវា សម្រាប់បង្គាប់បញ្ជាប្រហែលគ្នានឹងមនោរបស់មនុស្សដែរ តែវានៅស្ងួចស្តើងណាស់ មិនមែនពេញលក្ខណៈដូចជាមនោរបស់មនុស្សឡើយ ។ ហេតុនេះ បានជារុក្ខជាតិទាំងនោះ ចេះដឹងបញ្ចេញឫសទៅចាក់ទៅរកចំណីអាហារដីជាតិមកចិញ្ចឹមដើមវា ឬដូចជារុក្ខជាតិខ្លះមានដើមទនោងជាដើមដែលចេះបញ្ចេញដៃ ទៅតាប់តោងបង្អោងឡើងបាន ។ ដូច្នេះ យើងសូមសន្មតហៅធម្មជាតិនោះថា មនោធាតុនៃរុក្ខជាតិ ចុះ ដើម្បីឲ្យងាយដល់ការយល់ ប៉ុន្តែ សូមកុំប្រឡំថា មនោធាតុនេះ ដូចជាមនោធាតុនៃមនុស្សឡើយ ព្រោះមនោធាតុនៃរុក្ខជាតិនេះ ទន់ខ្សោយ ហើយស្ងួចស្តើងពេកណាស់ មានការៈត្រឹមតែចេះរេបន្តិចបន្តួចប៉ុណ្ណោះ មិនអាចចេះដឹងស្គាល់ដំណើរសុខ-ទុក្ខជាដើមនៃពិភពលោក ដូចមនោធាតុរបស់មនុស្សឡើយ ។ លុះដល់រយៈកាលរស់នៅនៃរុក្ខជាតិដែលដុះមកនេះអស់កំរិត គឺរុក្ខជាតិនោះវាចាស់ខ្លាំង ឬក៏មានអ្វីមួយបៀតបៀន ធ្វើឲ្យវាខ្សោយអស់កំឡាំង មិនអាចនឹងស្រូបដញ្ជក់យកធាតុចំណីអាហារមកចិញ្ចឹមខ្លួនបាន ហើយវាក៏ត្រូវងាប់ ។ ឯមនោធាតុដែលនៅក្នុងរុក្ខជាតិនោះ កាលបើលំ-នៅខ្លួនត្រូវងាប់ហើយ វាមិនរលាយសូន្យទៅអស់ទេ គឺវានៅមានហុយ

ហើរចេញអណ្តែតទៅកាន់ទីផ្សេងៗ ដែរ ។ កាលដែលមនោធាតុយ៉ាងដ៏ទន់ល្អិតនេះ ចេញផុតពីលំនៅដើមហើយ វាក៏ត្រូវអណ្តែតទៅរកធាតុដែលមានកំឡាំងគួរដល់ការស្រូបឆក់យកទៅ, លុះវាចូលទៅធ្វើសម្ប-យោគថ្មីជាមួយនឹងអ៊ីមួយថ្មីមានទីទឹកឬទីដីជាដើមហើយ ដោយកំឡាំងជំនួយពីធាតុឯទៀតតាមរដូវផ្សេងៗ វាក៏បានតជារូបរាងសណ្ឋានថ្មីមួយឡើងទៀត ។ រូបថ្មីនេះ ក៏មានមនោធាតុដែលហុយហើរមកធ្វើសម្ប-យោគនោះជាគ្រឿងបញ្ជាដែរ ប៉ុន្តែមនោធាតុនេះ ក្លាយទៅជាមានកំ-ឡាំងខ្លាំងជាងមុនបន្តិច ព្រោះវាចាស់ពេលវេលាជាងមុនមកហើយ ។ លុះរូបថ្មីនេះ ផុតរយៈកាលរស់នៅទៀត មនោធាតុដែលអាស្រ័យនៅក្នុងរូបវានោះ ក៏ត្រូវហុយចេញទៅធ្វើសម្បយោគជាមួយនឹងអ៊ីមួយទៀតតាមដំណើរដូចគ្នា ហើយលុះតជារូបឡើង មនោធាតុនោះ ក៏រឹតតែមានកំ-ឡាំងជាងមុនឡើងជាលំដាប់ ។ ចេះតែមានការផ្លាស់ប្តូររូប និងធាតុបែបនេះជាច្រើនលើកទៅ, មនោធាតុនោះ ក៏រឹតតែមានការចេះដឹងខ្លាំងឡើងបន្តិចម្តងៗ តាមលំដាប់ជាហូរហែ រហូតបានមកកើតជាសត្វ ដូចជាដង្កូវ-ទឹក, មូស, សុច, ចាប, ព្រាប, ឆ្មា, ឆ្កែ, គោ, ក្របី, សេះ, ដំរី និងស្វាជាដើម ដែលចេះចាប់ផ្តើមស្គាល់ដំណឹងដំណើរសុខ - ទុក្ខ និងវត្តក្នុងពិភពលោកឡើងកល់វិនាទី ។ នៅទីបំផុត ទើបបានមកកើតជាមនុស្ស ព្រោះមនោ

ធាតុថ្មីនេះ វាចំរើនឡើងដល់កំរិតល្មមហៅថា មនោ, ចិត្ត, វិញ្ញាណ បានហើយ ។ ការរីកចំរើននៃមនោធាតុនេះ បើនិយាយឲ្យងាយយល់ទៅ យើងគប្បីប្រៀបធៀបនឹងទារកតូច ៗ ចុះ, ព្រោះថា ទារកតូច ៗ ដែលទើបប្រសូតចេញពីឧទរមាតាមកថ្មី ៗ, មនោ, ចិត្ត, វិញ្ញាណ របស់វានៅទន់ខ្ចីណាស់ ឥតមានដឹង-មានស្គាល់អ្វីក្នុងពិភពលោកក្រៅពីការចេះត្រឹមតែស្រែកឃ្លាន នឹងស្រែកយំប៉ុណ្ណោះឡើយ ប៉ុន្តែ លុះវាចំរើនធំឡើងៗ ជាលំដាប់, មនោ, ចិត្ត, វិញ្ញាណ របស់វាក៏រីកចំរើនការចេះដឹង ស្គាល់ដំណើរ ដំណឹង នឹងវត្ថុក្នុងពិភពលោកកាន់តែច្បាស់ឡើងជាហូរហែដែរ យ៉ាងណាមិញ, មនោធាតុដែលផ្ដួចឡើងថ្មីនោះ ក៏វាមានការរីកចំរើនអំពីការទន់ខ្ចីល្វិតល្វន់មកកាន់ការចេះដឹង តាមហេតុការណ៍ដែលវាជួបប្រទះ នឹងតាមកាលវេលា ដែលកន្លងទៅជាលំដាប់ដូច្នោះដែរ ។ ចុះបើមនោធាតុ មានកំឡាំងពេញលក្ខណៈតាំងពីដំបូងជាលំដាប់រហូតដល់មកកើតជាមនុស្សបានហើយ កើតទៅមុខវាមានដំណើរការយ៉ាងណាទៅវិញ ? សូមលោកអ្នកអានចាំពិនិត្យគោលសំខាន់ទៅទៀត ។

(នៅមានត)

# សន្តិកេនិទានព្រហ្មយាចនកថាទី ១០

១- ទ្រង់ខ្វល់ខ្វាយតិច ២- ព្រហ្មអារាធនា ៣- ទ្រង់រំពឹងមើលសត្វលោក ៤- ទ្រង់ប្រារព្ធព្រះបឋមទេសនា ៥. ទ្រង់ជួបឧបកាជីវក ។

## ១- ទ្រង់ខ្វល់ខ្វាយតិច

*លំដាប់នោះ ព្រះភគវាស្ដេចចេញចាកសមាធិទៅក្រោមរាជាយតនព្រឹក្ស ហើយស្ដេចយាងចូលទៅកាន់អជបាលនិគ្រោធម្ដងទៀត ស្ដេចទៅដល់ហើយ ទ្រង់រំពឹងដល់ធម៌ដែលព្រះអង្គបានត្រាស់ដឹង ហើយទ្រង់ជ្រាបថា សត្វទាំងឡាយមិនងាយយល់ធម៌ព្រះអង្គបានទេ សមដូចសេចក្ដីដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារ ថា* (១)

“ម្នាលរាជកុមារ! តថាគតត្រិះរិះថា ធម៌ដែលតថាគតត្រាស់ដឹងហើយនេះ ជាធម៌ជ្រាលជ្រៅដែលសត្វឃើញបាន ដោយកម្រ ដែលសត្វត្រាស់ដឹងបាន ដោយកម្រ ជាធម៌ស្ងប់រម្ងាប់

---

១-ពោធិរាជកុមារសូត្រ ម.ម. សៀវ. ២៤ ទំព័រ ៣៩ (វិន័យបិដកមហាវគ្គបឋមភាគ សៀវ- ៦ ទំព័រ ១៦) ។

ថ្លៃថ្លា មិនជាទីត្រាប់ចុះនៃតក្កៈបាន ជាធម៌ល្អិត ជាធម៌ដែលអ្នកប្រាជ្ញគប្បីដឹងបាន ។ ពួកសត្វទាំងនោះសុទ្ធតែនៅកំពុងរីករាយក្នុងអាល័យ កំពុងស្រើបស្រាលចំពោះកាមនៅឡើយ។

មួយទៀត បដិច្ចសមុប្បាទធម៌ គឺធម៌ជាបច្ច័យនៃគ្នានឹងគ្នាណា បដិច្ចសមុប្បាទធម៌នោះ ជាហេតុឲ្យពពួកសត្វដែលនៅរីករាយ ក្នុងអាល័យ នៅត្រេកត្រអាល ក្នុងអាល័យ នៅស្រើបស្រាលក្នុងអាល័យឃើញបានដោយក្រក្រៃពេកណាស់។

មួយវិញទៀត ធម៌ណា សម្រាប់រម្ងាប់បង់នូវសង្ខារទាំងពួង សម្រាប់លះបង់បោលនូវឧបធិគឺកិលេសទាំងអស់ ជាទីអស់ទៅនៃតណ្ហា ជាទីនឿយណាយចាករាគៈ ជាទីរលត់ទៅនៃសេចក្ដីទុក្ខគឺព្រះនិព្វាន ធម៌ទាំងអម្បាលនេះ ជាហេតុនាំឲ្យពួកសត្វឃើញបានដោយក្រក្រៃពេកណាស់ ។ បើទុកជា តថាគតសំដែងធម៌ទៅ ក៏គង់សត្វទាំងឡាយដទៃ មិនអាចនឹងត្រាស់ដឹងនូវធម៌របស់តថាគតបានឡើយ សេចក្ដីលំបាកនឹងសេចក្ដីនឿយព្រួយនោះ មុខជានឹងមានដល់តថាគតមិនខាន ។

ម្នាលរាជកុមារ! កាលនោះ គាថាទាំងឡាយមិនស្ធូវជា

អស្ចារ្យណាស់ណាទេ ដែលតថាគតមិនដែលបានឮក្នុងកាលមុន ក៏កើតប្រាកដ ដល់តថាគត ថា

កិច្ឆេន មេ អធិគតំ
ហលន្ទានិ បកាសិតុំ
រាគទោសបរេតេហិ
នាយំ ធម្មោ សុសម្ពុធោ
បដិសោតគាមី និបុណំ
គម្ភីរំ ទុទ្ទសំ អណុំ
រាគរត្តា ន ទក្ខន្តិ
តមោក្ខន្ធេន អាវុតា ។

"ណ្ហើយបុះឥឡូវនេះ តថាគតគួរសំដែងធម៌ដែលតថាគតបានត្រាស់ដឹងហើយ ដោយសេចក្តីលំបាកនេះបុះ សត្វទាំងឡាយដែលរាគៈទោសៈគ្របសង្កត់ហើយ មិនងាយនឹងត្រាស់ដឹង នូវធម៌នេះបានទេ សត្វទាំងឡាយ ដែលកំពុងត្រេកអរដោយរាគៈ ដែលងងឹតគឺអវិជ្ជាកំពុងរួបរឹត មិនឃើញនូវធម៌ដែលនាំឲ្យពួកសត្វដល់នូវព្រះនិព្វាន ជាធម៌ដ៏ល្អិតសុខុមជ្រាលជ្រៅ ដែលសត្វឃើញបានដោយកម្រនោះបានទេ ។

ម្នាលរាជកុមារ! កាលដែលតថាគត ពិចារណាឃើញដោយន័យដែលត្រិះរិះដូច្នេះហើយ ចិត្តក៏ឱនទៅ ដើម្បីសេចក្ដីខ្វល់ខ្វាយតិច មិនឱនទៅ ដើម្បីសំដែងធម៌ឡើយ" ។

## ២- ព្រហ្មអារាធនា

*សហម្បតីព្រហ្ម បានយល់ពុទ្ធអាធ្យាស្រ័យដូច្នេះហើយត្រិះរិះឃើញថា បើព្រះលោកនាថ មានព្រះទ័យខ្វល់ខ្វាយតិច ពុំសំដែងធម៌ទេ លោកនេះមុខជាវិនាសហើយ ទើបមកប្រាកដខ្លួនចំពោះព្រះមានព្រះភាគ មានសំពត់ព័ទ្ធឆៀងស្មាម្ខាង លុតជង្គង់ស្ដាំលើផែនដី ប្រណម្យអញ្ជលីហើយក្រាបទូលអារាធនាថា សូមព្រះអង្គមេត្តាប្រោសសំដែងធម៌ ដូចសេចក្ដីដែលទ្រង់ត្រាស់ចំពោះរាជកុមារថា*(១)

បពិត្រព្រះអង្គដ៏ចំរើន! សូមព្រះមានព្រះភាគ សំដែងធម៌ សូមព្រះសុគតសំដែងធម៌ ដ្បិតសត្វទាំងឡាយ ដែលមានភ្នែកមានធូលីគឺរាគាទិក្កិលេសដ៏ស្រាលតិច តែបើខានស្ដាប់ធម៌មុខជានឹងសាបសូន្យមិនខាន សត្វទាំងឡាយដែលបំរុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ ។

---

១ ពោធិរាជកុមារសូត្រ រាជវគ្គ ម.ម. សៀវ- ២៤ ទំព័រ ៣៩៣ (វិន័យបិដក មហាវគ្គ សៀវ- ៦ ទំព័រ ១៦) ។

ម្នាលរាជកុមារ! សហម្បតីព្រហ្ម បានពោលពាក្យនេះ លុះពោលពាក្យនេះរួចហើយ ក៏ពោលពាក្យដទៃតទៅទៀតថា

បាតុរហោសិ មគធេសុ បុព្វេ
ធម្មោ អសុទ្ធោ សមលេហិ ចិន្តិតោ
អបាបុរេ តំ អមតស្ស ទ្វារំ
សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ
សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ ។

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយ អ្នកប្រកបដោយមន្ទិល តែងគិតថា ធម៌មិនបរិសុទ្ធទេ កើតប្រាកដហើយក្នុងដែនមគធៈ សូមព្រះអង្គបើកទ្វារនៃព្រះនិព្វានចុះ សត្វទាំងឡាយប្រុងប្រាំស្តាប់ធម៌ ដែលព្រះអង្គជាអ្នកប្រាសចាកមន្ទិលទ្រង់ត្រាស់ដឹង ( តាមលំអានព្រះពុទ្ធអំពីបូរាណ ) ដូចបុរសអ្នកមានចក្ខុ ឈរលើកំពូលភ្នំថ្មសុទ្ធ ក្រឡេកមើលឃើញប្រជុំជនដោយជុំវិញយ៉ាងណាមិញ បពិត្រព្រះអង្គអ្នកមានបញ្ញាល្អ ព្រះអង្គមានសមន្តចក្ខុ មានសេចក្តីសោកទៅប្រាសហើយ សូមទ្រង់ឡើងកាន់ប្រាសាទគឺធម៌ ពិចារណាមើលប្រជុំជន

អ្នកប្រឡើដោយសេចក្ដីសោក ដែលជាតិជរាកំពុងគ្របសង្កត់ មានឧបមេយ្យដូច្នេះដែរ, បពិត្រព្រះអង្គអ្នកមានព្យាយាម អ្នកឈ្នះសង្គ្រាម អ្នកនាំពួកសត្វ អ្នកមិនជំពាក់បំណុលគឺកាមសូមព្រះអង្គក្រោក សូមត្រាច់ទៅក្នុងលោក សូមព្រះមានព្រះភាគសំដែងធម៌ សត្វទាំងឡាយដែលបម្រុងត្រាស់ដឹងធម៌ក៏មាន ។

ម្នាលរាជកុមារ! គ្រានោះឯងតថាគតដឹងច្បាស់នូវសេចក្ដីអារាធនារបស់សហម្បតីព្រហ្មផង អាស្រ័យនូវសេចក្ដីករុណាដល់ពួកសត្វផង ទើបរមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ។

៣ - ទ្រង់រំពឹងមើលសត្វលោក

*ព្រះសម្ពុទ្ធបានទទួលអារាធនាព្រហ្មហើយ ទ្រង់ប្រមើលមើលសត្វលោក ដូចសេចក្ដីដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារ ថា(១)*

ម្នាលរាជកុមារ! កាលតថាគត ប្រមើលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញសត្វទាំងឡាយ ដែលមានភ្នែកមានធូលីគឺរាគាទិក្កិលេសតិចខ្លះ ច្រើនខ្លះ មានឥន្ទ្រិយក្លាខ្លះ ទន់ខ្លះ មានអាការល្អខ្លះ អាក្រក់ខ្លះ ជាសត្វដែលគួរឲ្យត្រាស់

---

១- ពោធិរាជកុមារសូត្រ រាជវគ្គ ម.ម. សៀវ. ២៤ ទំព័រ ២៥៤ ។

ដឹងបានដោយងាយខ្លះ ដោយក្រខ្លះ ជាអ្នកឃើញទោសនឹងភ័យក្នុងបរលោកខ្លះ ប្រៀបដូចជាផ្កាជលជាតិខ្លះ ផ្កាព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី តែងកើតក្នុងទឹក ចំរើនក្នុងទឹក លូតលាស់ក្នុងទឹក ខ្លះលិចនៅក្នុងទឹកនៅឡើយ ខ្លះឋិតនៅត្រឹមស្មើនឹងទឹក ខ្លះដុះខ្ពស់ឡើងពីទឹក មិនជាប់ជំពាក់ដោយទឹកទេ ។

ម្នាលរាជកុមារ! គ្រានោះតថាគតសំដែងនូវបទគាថានឹងសហម្បតីព្រហ្ម ថា

✓ អបារុតា តេ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ
វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។

ទ្វារនៃព្រះនិព្វានទាំងនោះ គឺតថាគតបើកហើយ សត្វទាំងឡាយណា មានសោតប្រសាទ សត្វទាំងឡាយនោះ ចូរបញ្ចេញនូវសទ្ធាមកចុះ ម្នាលមហាព្រហ្ម! តថាគតសំគាល់ថាលំបាក បានជាមិនសំដែងធម៌ឧត្តម ដែលតថាគតស្ទាត់

ហើយក្នុងសំណាក់មនុស្សទាំងឡាយ ។

ម្នាលរាជកុមារ ! គ្រានោះឯង សហម្បតីព្រហ្ម គិតថា អាត្មាអញជាបុគ្គលដែលព្រះមានព្រះភាគទ្រង់យល់ព្រម ដើម្បីសំដែងធម៌ហើយ លុះគិតរួចហើយ ក៏ថ្វាយបង្គំលាតថាគត ធ្វើប្រទក្សិណហើយក៏អន្តរធានបាត់ពីទីនោះទៅ ។

## ៥- ទ្រង់ប្រារព្ធព្រះបឋមទេសនា

*កាលសហម្បតីព្រហ្មក្រាបបង្គំលាវិលទៅវិញបាត់ទៅ ទ្រង់ប្រមើលមើលសត្វដែលមានឧបនិស្ស័យគួរទ្រង់ប្រោសមុន ដូចសេចក្ដីដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារថា*(១)

ម្នាលរាជកុមារ ! តថាគតត្រិះរិះថា តថាគតគួរសំដែងធម៌ដល់អ្នកណាមុនហ្ន៎ ! អ្នកណាអាចនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន? ទ្រង់ពិចារណាតទៅទៀតថា អាឡារកាលាម-គោត្រ ជាបណ្ឌិតជាអ្នកឈ្លៀវឆ្លាសជាអ្នកមានប្រាជ្ញា មានភ្នែកមានធូលីគឺរាគាទិក្កិលេសតិចយូរមកហើយ បើដូច្នេះគួរតថា-គតសំដែងធម៌ ដល់អាឡារកាលាមគោត្រមុនចុះ តាបសនោះ

---

១ ពោធិរាជកុមារសូត្រ រាជវគ្គ ម.ម. សៀវ ២៤ ទំព័រ ៣៩៦ ។

អាចនឹងត្រាស់ដឹងធម៌ នេះឆាប់រហ័សបាន ។

ម្នាលរាជកុមារ ! គ្រានោះមានទេវតាចូលមកប្រាប់តថាគតថា បពិត្រព្រះអង្គដ៏ចំរើន អាឡារកាលាមគោត្រ ធ្វើកាលកិរិយាក្ស័យទៅ ៧ ថ្ងៃហើយ ។ ឯញាណទស្សនៈក៏កើតឡើងដល់តថាគតថា អាឡារកាលាមគោត្រ ធ្វើកាលកិរិយាទៅ ៧ ថ្ងៃមែនហើយ ។ តថាគតត្រិះរិះយ៉ាងនេះថា ឱអាឡារកាលាមគោត្រ មានសេចក្ដីវិនាសធំណាស់ ប្រសិនបើបានស្ដាប់ធម៌នេះ នឹងគប្បីត្រាស់ដឹងធម៌បានមួយរំពេច ។

ម្នាលរាជកុមារ ! តថាគតត្រិះរិះថា បើដូច្នោះតើតថាគតគួរសំដែងធម៌ដល់អ្នកណាមុនហ្ន៎ អ្នកណាអាចនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ! តថាគតត្រិះរិះទៅទៀតថា ឧទ្ទករាមបុត្រ ជាបណ្ឌិតមានបញ្ញាឆ្លៀវឆ្លាស ជាមេធាវីមានភ្នែកមានធូលីគឺរាគាទិក្កិលេសតិចមកយូរហើយ បើដូច្នោះគួរតថាគតសំដែងធម៌ដល់ឧទ្ទករាមបុត្រមុនចុះ គាត់នោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ ! គ្រានោះមានទេវតាចូលមកប្រាប់តថាគតថា បពិត្រព្រះអង្គដ៏ចំរើន ឧទ្ទករាមបុត្រ ធ្វើកាល-

កិរិយាក្បែយទៅពីពេលព្រលប់ទៅហើយ ។ ញាណទស្សនៈក៏កើតឡើងដល់តថាគតថា ឱទ្ធករាមបុត្រ ធ្វើកាលកិរិយាពីព្រលប់ទៅមែនហើយ តថាគតត្រិះរិះថា ឱ! ឧទ្ធករាមបុត្រវិនាសធំណាស់ ប្រសិនបើបានស្តាប់ធម៌នេះ នឹងគប្បីត្រាស់ដឹងនូវធម៌ដោយឆាប់រហ័ស ។

ម្នាលរាជកុមារ! តថាគតត្រិះរិះទៀតថា បញ្ចវគ្គិយតាបស មានឧបការច្រើនដល់តថាគត ព្រោះបានបំរើតថាគតដែលកំពុងបញ្ជូនចិត្តទៅកាន់ព្យាយាម បើដូច្នោះគួរតែតថាគតសំដែងធម៌ដល់បញ្ចវគ្គិយតាបសមុនចុះ ។ ម្នាលរាជកុមារ! តថាគតត្រិះរិះឃើញថា ឥឡូវនេះ បញ្ចវគ្គិយតាបសនេះ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុស្អាតកន្លងលើសចក្ខុរបស់មនុស្ស ។ ម្នាលរាជកុមារ! កាលនោះ តថាគតនៅក្នុងឧរុវេលប្រទេស តាមសមគួរដល់អធ្យាស្រ័យ ទើបបានបរទៅកាន់ចារិក សំដៅទៅរកក្រុងពារាណសី ។

## ៥– ទ្រង់ជួបឧបកាជីវក

*កាលព្រះតថាគតធ្វើដំណើរចេញពីឧរុវេលប្រទេស ឆ្ពោះទៅកាន់ក្រុងពារាណសីតាមផ្លូវ ទ្រង់បានជួបសន្ទនាជាមួយឧបកាជីវកដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារ ថា(១)*

ម្នាលរាជកុមារ ! មានអាជីវកម្នាក់ឈ្មោះឧបកៈបានឃើញតថាគតទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះគយាប្រទេស និងពោធិព្រឹក្ស លុះឃើញហើយ បានពោលពាក្យនេះចំពោះតថាគតថា ម្នាលអាវុសោ ! លោកមានឥន្ទ្រិយគួរជ្រះថ្លាណាស់ឆវិវណ្ណៈរបស់លោកបរិសុទ្ធផូរផង់, ម្នាលអាវុសោ ! លោកបួសចំពោះគ្រូណា? អ្នកណាជាគ្រូរបស់លោក! លោកពេញចិត្តនឹងធម៌របស់គ្រូណា! កាលឧបកាជីវក សួរយ៉ាងនេះហើយ តថាគតឆ្លើយតបទៅវិញឧបកាជីវកជាបទគាថាយ៉ាងនេះ ថា

សព្វាភិភូ សព្វវិទូហមស្មិ
សព្វេសុ ធម្មេសុ អនូបលិត្តោ ។ល។
អន្ធភូតស្មឹ លោកស្មឹ
អាហាញ្ញឹ អមតទុន្ទុភឹ ។

---

១ ពោធិរាជកុមារសូត្រ រាជវគ្គ ម ម  រៀប ៤៤ ទំព័រ . . .

តថាគតជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវចតុភូមិកធម៌ទាំងអស់ បានលះបោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះហើយព្រោះអស់តណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ដោយខ្លួនឯង (ហាំបាច់) ចំពោះបុគ្គលណា? តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃ ស្មើនឹងតថាគតឡើយ ក្នុងលោកនេះព្រមទាំងទេវលោក មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ព្រោះតថាគតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់ផុត មានតែតថាគតមួយ ជាសម្មាសម្ពុទ្ធ តថាគតមានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់អស់ហើយ តទៅទៀត តថាគតទៅកាន់បុរីនៃពួកជនអ្នកកាសី ដើម្បីសំដែងធម្មចក្រ តថាគតនឹងវាយស្គរគឺអមតនិព្វាន ដល់សត្វលោកដែលងងឹតគឺអវិជ្ជាកំពុងគ្របសង្កត់ ។

ឧបកាជីវកតបថា ម្នាលអាវុសោ! អ្នកប្តេជ្ញាខ្លួនយ៉ាងណា អ្នកគួរដើម្បីបាននូវឈ្មោះថា " អនន្តជិនៈ អ្នកឈ្នះអនេកអនន្ត " យ៉ាងនេះ ។ ព្រះតថាគត តបថា

---

មាទិសា វេ ជិនា ហោន្តិ

យេ បត្តា អាសវក្ខយំ
ជិតា មេ បាបកា ធម្មា
តស្មាហំ ឧបក ជិនោ ។

ជនទាំងឡាយណា បានដល់នូវអាសវក្ខយ ជនទាំងនោះឈ្មោះថាជិនៈប្រាកដដូចតថាគតដែរ ។ តថាគតបានឈ្នះបាបធម៌ទាំងអស់ហើយ

ម្នាលឧបកៈ ព្រោះហេតុនោះ ទើបតថាគតឈ្មោះថា "ជិនៈអ្នកឈ្នះ"

ម្នាលរាជកុមារ! តថាគតពោលយ៉ាងនេះហើយ ឧបកាជីវកពោលថា ម្នាលអាវុសោ! យ៉ាងហ្នឹងហើយ ថាហើយក៏ងក់ក្បាលលៀនអណ្តាត កាន់យកផ្លូវមួយផ្សេងចៀសចេញទៅ ។

( នៅមានត )

## ព្រះនិព្វាន ឬ និរ្វាណ

## លោក កុម្មង់ជិង់ រ៉ូបែរត៍ រៀបរៀង

ក្រមការ ជុំ-មៅ ប្រែជាភាសាខ្មែរ

(តនិងចប់)

---

បទទី ១ ថា កាលនោះមានពុទ្ធបរិស័ទ ១ អង្គ ចូលនិព្វានហើយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សំដែងថា រូបក្ខន្ធនោះក្លាយអស់ទៅហើយ វេទនាខន្ធក៏ស្ងួតស្រពោនអស់ សញ្ញាខន្ធក៏រលត់ សង្ខារក្ខន្ធក៏ឈប់សម្រាក វិញ្ញាណក្ខន្ធក៏ចូលអាស្រ័យក្នុងទីជ្រក ។

បទទី ២ ថា កាលនោះមានពុទ្ធបរិស័ទ ១ អង្គ នាមថាគោធិកភិក្ខុ ចូលនិព្វានដោយការធ្វើនូវអត្តឃាដ ហើយព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះបន្ទូលប្រាប់ពុទ្ធបរិស័ទទាំងឡាយថា តើវិញ្ញាណរបស់គោធិកៈនេះទៅចូលជ្រកក្នុងទីណា ? ។ គោធិកៈចូលនិព្វានហើយ វិញ្ញាណរបស់គោធិកៈនេះឥតសល់ជ្រកនៅក្នុងទីណាឡើយ ។

ក្នុងនិទានទាំង ២ បទខាងលើនេះ ខ្ញុំសំគាល់ឃើញថា បទទី ១ ដែលសំដែងថា វិញ្ញាណចូលឈប់សម្រាកនោះ មិនមែនត្រូវយល់ថាជាគ្មានវិញ្ញាណឬថាសូន្យវិញ្ញាណឡើយ ហើយបទទី ២ ដែលសំដែងថា វិញ្ញាណឥតសល់ជ្រកនៅក្នុងទីត្រង់ណានោះ ត្រូវយល់ថាឥតសល់នៅក្នុងភពយើងវិញ ព្រោះនិព្វានជាភពដទៃ ។

សេចក្តីទាំងនេះ នាំយើងឲ្យនឹកឃើញពាក្យបុច្ឆាខាងក្រោយនេះទៀត គឺពាក្យដែលថា ព្រះនិព្វាននោះជាអ្វី? មានសណ្ឋានដូចម្តេច? ព្រះសម្មាសម្ពុទ្ធសំដែងទុកថា អ្វី ៗ ទាំងអស់សុទ្ធតែមិនទៀង ជាអនិច្ចំទាំងអស់ ប៉ុន្តែមិនទៀងតែក្នុងលោកនេះទេ តពីសេចក្តីនេះមក យើងត្រូវពិចារណាខ្លួនយើងថា ចុះអ្វី ៗ ដែលមិនមែនជាក្នុងលោកនេះ តើជាធាតុទៀងឬទេ ជាធាតុមិនស្លាប់ឬទេ ជាអមតធាតុឬទេ មានឧទាន ១ សំដែងថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយអើយ សេចក្តីដែលមិនកើតឡើង មិនកឡើង មិនតាក់តែងឡើង មិនបដិសន្ធិឡើងនោះមានពិតហើយ ប្រសិនបើគ្មានធម៌ដែលមិនកើតនោះទេ ជាតិដែលកើតឡើងហើយ រកទីបំផុតគ្មានឡើយ ប៉ុន្តែបើមានធម៌ដែលមិនកើតដូច្នេះហើយ ក៏មានទីបំផុតដូចគ្នា ។

គម្ពីរទាំងប៉ុន្មាន យើងមិនឃើញមានត្រង់សេចក្តីណាដែលសំដែងឲ្យច្បាស់លាស់ជាងនេះទៅទៀតឡើយ យើងយល់ឃើញថាគួរតែទុកដាក់សេចក្តីទៀង ដែលមានសភាពផ្ទុយគ្នានឹងសេចក្តីមិនទៀងក្នុងលោកនេះថាជាគូគ្នានឹងព្រះនិព្វានដែលមិនមែនជាក្នុងលោកនេះ និព្វានគឺជាសេចក្តីទៀងមិនប្រែប្រួល ជាសេចក្តីដែលមិនកើតទៀត ជាសេចក្តីដែលមិនតាក់តែងឡើងដោយអំពើកាលជាតិមុន ៗ ។

មុននឹងវិនិច្ឆ័យសេចក្តីថា ច្បាស់ឬមិនច្បាស់តាមស្ថានដូចដែលបាន

BIBLIOTHEQUE P.P. D'EXTREME ORIENT

ពោលមកនេះ  យើងត្រូវពិចារណារកសេចក្តីនេះ ១ សិន  គឺសេចក្តីដែលថាៈ  ចុះហេតុអ្វីបានជាព្រះសព្វញ្ញុពុទ្ធមិនបានសំដែងឲ្យច្បាស់ប្រាកដ អំពីធាតុទាំងអស់ ដែលប្រាសចាករូបមួយទៅកាន់រូបមួយ ?, អំពីធាតុណាដែលទៅកាន់ព្រះនិព្វាន ហើយព្រះនិព្វាននោះដូចម្តេចខ្លះ ? ។

ដែលសួរយ៉ាងនេះ  មិនជាខុសឆ្គងទេ  ប៉ុន្តែយើងបានដឹងថាមានសេចក្តីខ្លះ ដែលឥតប្រយោជន៍ដល់ព្រះសម្មាសម្ពុទ្ធ  ព្រោះថាសេចក្តីទាំងនោះជាការហួសវិស័យរបស់មនុស្សគឺប្រាជ្ញាចាក់មិនដល់  លើកតែព្រះអរិយបុគ្គល  ដែលលោកបានដល់ថ្នាក់បំផុតនៃព្រះអរហត្ត  កាលណាតែមានពុទ្ធបរិស័ទណា ១  ទូលសួរព្រះអង្គអំពីសេចក្តីណាដែលប៉ះពាល់ដល់បរមត្ថកថា នោះព្រះអង្គមិនព្រមឆ្លើយតាមពាក្យសួរឡើយ, លុះពុទ្ធ-បរិស័ទ ១ អង្គនាមថា  មាលុងក្យាបុត្ត បង្គំទូលសួរព្រះអង្គ ៗ មានព្រះបន្ទូលថា "ចុះតថាគតបានអនុញ្ញាតឲ្យអ្នកវិះគិតអំពីលោក តើទៀងឬមិនទៀង  មានទីបំផុតឬគ្មានទីបំផុត ? តថាគតបានអនុញ្ញាតឲ្យអ្នកគិតថា ជីវៈឬធម្មជាតិដែលរស់នៅនោះមានសណ្ឋានដូចជារូបឬមិនដូច ? ព្រះអរហន្តរស់នៅក្រោយពេលដែលទំលាយបញ្ចក្ខន្ធទៅឬមិនរស់នៅ ? ឬជារស់នៅផងមិនរស់នៅព្រមគ្នា" ? ។ មាលុងក្យាបុត្ត ទូលតបវិញថា "ព្រះអង្គមិនបានអនុញ្ញាត  ឲ្យគិតអំពីសេចក្តីទាំងប៉ុន្មាននោះឡើយ" ។ អើ! បានជាតថាគតមិនបានពន្យល់អ្នកអំពីផ្លូវទាំងនេះ  ព្រោះវិជ្ជាទាំងនេះ

ឥតបានប្រយោជន៍អ្វីដល់ផ្លូវព្រះអរិយទៀយ ហើយមិនមែនជាសេចក្ដីសុខ មិនមែនជាសេចក្ដីត្រាស់ដឹងទេ; ដែលមានប្រយោជន៍ក្នុងផ្លូវទាំងប៉ុន្មាននេះ គឺធម៌ដែលតថាគតបានសំដែងហើយអំពី ទុក្ខសច្ច គឺសេចក្ដីពិតអំពីទុក្ខ ឬកិរិយាឈឺចាប់; ឯ សមុទយសច្ច គឺសេចក្ដីពិតអំពីកិរិយាដែលលេតទុក្ខ ឬលេតសេចក្ដីឈឺចាប់; មគ្គសច្ច គឺសេចក្ដីពិតអំពីផ្លូវដែលនាំទៅកាន់ទីលេតទុក្ខ ឬលេតសេចក្ដីឈឺចាប់ ដោយហេតុនេះ មាលុង្ក្យបុត្ត អ្វីៗ ដែលតថាគតមិនបានសំដែងនោះ ត្រូវទុកឲ្យនៅដូចដែលចុះ (មជ្ឈិមនិកាយ) ។

អ្នកដែលប្រាថ្នានឹងរិះគិតអំពីផ្លូវទាំងអស់ ដែលព្រះសម្មាសម្ពុទ្ធមិនបានសំដែង ដោយព្រះអង្គយល់ឃើញថាឥតប្រយោជន៍នោះ ត្រូវពិចារណាដល់សេចក្ដីដែលព្រះអង្គបានឆ្លើយនឹង មាលុង្ក្យបុត្ត ខាងលើនេះ ។ ឯរឿងក៏រ កាលដែលព្រះបរមគ្រូប្រថាប់នៅក្នុងព្រៃសំសាបានោះ ធ្វើឲ្យយើងយល់បានថាៈ ព្រះអង្គបានរិះគិតអំពីសេចក្ដីទាំងនោះឥតចន្លោះ, កាលនោះព្រះអង្គសំដែងប្រាប់ពួកភិក្ខុបរិស័ទទាំងឡាយថា ឯស្លឹកឈើសំសាបាដែលតថាគតកាន់ក្នុងព្រះហស្ត មានចំនួនតិចជាងស្លឹកដែលជាប់នៅលើដើមមានប្រការយ៉ាងណា ធម៌ដែលតថាគតបានសំដែងប្រាប់អ្នកទាំងឡាយកាលក្នា ក៏មានប្រការដូច្នោះដែរ គឺធម៌ដែលបានសំដែងនោះ តិចតួចស្តួចស្តើងណាស់ ធម៌ដែលតថាគតបានរកឃើញ

ច្រើនជាអនេកឥតគណនា ។

ក្នុងគម្ពីរមិលិន្ទបញ្ហា យើងបានឃើញសេចក្ដីដែលនិយាយតគ្នាពីបទដែលសំដែងខាងលើមករួចហើយ គឺព្រះបាទក្រុងមិលិន្ទសង្ស័យ អំពីរឿងដែលព្រះសម្មាសម្ពុទ្ធមិនព្រមឆ្លើយប្រាប់ដល់ មាលុង្ក្យបុត្ត ហើយព្រះនាគសេនឆ្លើយតបទៅវិញថា ចំណោទឬសេចក្ដីចោទសួរនោះមាន ៤ យ៉ាង គឺ:

១– ចំណោទ ដែលគេអាចនឹងឆ្លើយប្រាប់ដោយត្រង់ ហើយឲ្យជាក់ច្បាស់ ។

២– ចំណោទ ដែលគេនឹងពន្យល់បានលុះតែពិនិត្យមើលដោយល័ក្ខឋាន ។

៣–ចំណោទ ដែលគេនឹងពន្យល់បានលុះតែធៀបទៅនឹងចំណោទឯទៀតដូចគ្នា ដែលបានរកឃើញហើយ ។

៤– ចំណោទដែលត្រូវតែជៀសវាងចេញឲ្យឆ្ងាយ ដូចជាសេចក្ដីចោទសួរអំពីលោកថា ផុតឬមិនផុត រូបនឹងជីវៈតើមានសណ្ឋានដូចគ្នាឬមិនដូច ។ល។

គឺសេចក្ដីដែលទូលសួរអំពីព្រលឹងនៅមានឬមិនមាន នឹងគុណជាតិរបស់ព្រះនិព្វាននោះ ចូលទៅក្នុងចំណោទដែលព្រះសម្មាសម្ពុទ្ធមិនព្រមទទួលឆ្លើយឡើយ ។

មុននឹងពិចារណាទៅឆ្ងាយពីនេះទៅទៀត យើងត្រូវពិចារណាមើលសេចក្ដីដែលថាមិនចំ ដែលគ្មាននរណាថាឲ្យប្រាកដបានថា ជាអ្វី ៗ នោះសិន ។ មិនមែនមានតែក្នុងក្បួនក្បាលពុទ្ធសាសនាទេ, ទោះបីក្នុងវិទ្យាសាស្ត្រប្រទេសអឺរ៉ុប ក៏មានសណ្ឋានដូចគ្នាដែរ, វេលាណាប្រាព្វដល់សេចក្ដីដែលនិយាយអំពីវិញ្ញាណ ឬចិត្តនោះ; វេលានោះ សេចក្ដីមិនច្បាស់ប្រាកដក៏កើតឡើងភ្លាម ហើយគេឯងយកវិធីយ៉ាងចង្អៀត មិនមែនជាវិធីយ៉ាងឆ្ងាយយល់មកនិយាយវិញ ។ មិនដឹងជាដោយហេតុអ្វីបានជារូបទាំងឡាយដែលមកប៉ះពាល់ដល់ចក្ខុ ហើយទៅបានឯសញ្ញាឯណោះជាអ្នកកត់សំគាល់វិញ; អំពីប្រាជ្ញាស្មារតីនោះយើងមិនអាចដឹងឡើយ; ក្នុងសាសនាកាតូលិកគេមិនបានពន្យល់អំពីឋានសួគ៌ នឹងឋាននរកឲ្យច្បាស់លាស់ទេ ហើយអ្នកដែលមើលសេចក្ដីអធិប្បាយ អំពីឋានទាំងនោះ បានសេចក្ដីផ្សេងពីគ្នា តាមយោបល់តែរៀងខ្លួន ព្រោះសេចក្ដីដែលពន្យល់នោះ មានសភាពព្រាលាំមិនពិស្ដារ ឲ្យជាការដាច់ខាតឡើយ ។

តាមយោបល់យល់ឃើញរបស់យើង ដែលខំប្រឹងទាញយកមកនិយាយនោះ គឺយើងគិតនិយាយយ៉ាងណាឲ្យតែស្រួលស្ដាប់ ។ មុនដំបូងបង្អស់ ព្រះពុទ្ធសាសនាជាសាសនាដែលមានធម៌អាថ៌ ឆ្ងាយនឹងសិក្សារៀនសូត្រណាស់ វិធីដំបូងមិនមែនជាផ្លូវបរមត្ថទាំងអស់ ដែលស្ទើញ

ស្អាញក៏ចុកក់នោះឡើយ ជាវិន័យជាក្បួនខាតដែលធ្វើខ្លួនឲ្យរួបអំពីទុក្ខ ដោយការប្រព្រឹត្តតាមសិក្ខាបទផ្សេង ៗ ដែលមានសេចក្ដីពិតប្រាកដនៅក្នុងនោះ; ទាំងនេះហើយជាសម្បត្តិដើមរបស់ព្រះពុទ្ធសាសនា លុះកាលជាខាងក្រោយមកជាច្រើនសតវត្សរ៍ សេចក្ដីឆ្លល់ សេចក្ដីសង្ស័យរបស់មនុស្សនាំឲ្យធម៌ទាំងនោះចង្អៀតទៅអស់ ប្រឡូលខ្ទិសាសនាចូលគ្នាទៅទៀត បោះបង់សម្បត្តិដើមដែលស្រណុករៀនស្រណុកគិត ទៅយកឯសេចក្ដីដែលលំបាករៀនលំបាកគិតវិញ ៗ ទុបមាដូចជាគេចង់ដឹងថា តើតាបសដែលប្រាថ្នានឹងធ្វើនូវអត្តឃាដ (ការសម្លាប់ខ្លួនឯង) នោះត្រូវប្រើខ្សែ-កាំបិត-អាវុធ អត់បាយឲ្យស្លាប់-ឬលោតទៅក្នុងជ្រោះភ្នំ? ៗ ត្រង់នេះមានបែបដូចជាក្នុងប្រទេសអឺរ៉ុប ក្នុងមជ្ឈិមកាលដែរ គឺគេជជែកពិគ្រោះគ្នាអំពីការដែលឥតប្រយោជន៍ឥតសមហេតុសមផលនេះ ៗ អំពីសាសនាកាតូលិក មានជជែកហួសអំពីសេចក្ដីបញ្ញត្តិ ដែលព្រះគ្រិស្តបានលាក់ទុកទៅទៀត ៗ

ដូច្នេះ យើញថានិព្វាននេះ យើងគ្មានអ្វីជាប្រាកដឡើយ ឯគម្ពីរដីកានានា ក្រៅពីគម្ពីរទាំងប៉ុន្មានដែលបានពោលមកហើយ ក៏សំដែងតែត្រឹមថា ព្រះនិព្វាននេះជាភាពសណ្ឋានក្រៅអំពីមនុស្សលោកយើងនេះ ៗ

មានទិទាន ១ សំដែងថា ព្រះនិព្វានោះ គឺជាកន្លែងដែលគ្មានទឹក, ដី, ភ្លើង, ខ្យល់, មិនមែនជាអាកាសទទេ, មិនមែនជាវិញ្ញាណ

ទេ, មិនមែនជាគ្មានអ្វីសោះ, មិនមែនជាសញ្ញា, មិនមែនជាអសញ្ញា, មិនមែនជាលោកឯណោះ, មិនមែនជាលោកឯណេះ មិនមែនជាយប់ មិនមែនជាថ្ងៃ ។

បើដូច្នេះ គឺថាគតមិនហៅថាមក មិនហៅថាទៅ មិនហៅថានៅ មិនហៅថាស្លាប់ មិនហៅថាកើត; ហៅថាគ្មានមេ គ្មានពូជជារ គ្មានអស់ គឺជាទីបំផុតនៃទុក្ខ ជាទីបំផុតនៃសេចក្ដីឈឺចាប់, គឺមិនមានបដិសន្ធិថ្មីទៀត ។ល។

ព្រះនាគសេនបានពន្យល់ទៅក្រុងមិលិន្ទថា ព្រះនិព្វាននោះ មិនអាចនឹងបណ្ដាលឡើងដោយហេតុអ្វីមួយឡើយ ព្រោះថាព្រះនិព្វាននោះ មិនមែនជាប្រជុំនៃធាតុផ្សេង ៗ ដែលអាស្រ័យនូវគ្នានឹងគ្នា នាំឲ្យមានភាពសណ្ឋាន ជាទីសំគាល់បានឡើយ ។

ព្រះនិព្វាននោះ មិនមែននៅកង់លោកយើងនេះទេ ដោយហេតុនេះបានជាយើងមិនអាចដឹងបានដោយឈាយតនៈរបស់យើង ដែលជាសេក្ខបុគ្គលនោះ ។ គម្ពីរសំយុត្តនិកាយសំដែងថា មហាសមុទ្រនោះជ្រៅណាស់នឹងពាស់មិនបាន នឹងស្ទង់ក៏មិនបានហោងណា រីឯព្រះនិព្វាននោះមនុស្សដែលនៅជាសេក្ខបុគ្គលនៅឡើយ នឹងដឹងស្គាល់ថាដូច្នេះដូច្នោះមិនបានដូច្នោះឯង ។ ព្រះអរហន្តដែលលោកដល់ហើយនូវព្រះនិព្វាននោះ មានជម្រៅនឹងពាស់មិនបាននឹងស្ទង់មិនបាន ដូចយ៉ាងមហាសមុទ្រ

ដូច្នោះដែរ ។

កាលណាព្រះអរហន្ត លោកចេញពីចំរើនឈានសមាបត្តិមកវិញនោះ លោកបន្លឺនូវវាចាគេថា ព្រះនិព្វាននោះជាទីរលត់នូវសេចក្តីទុក្ខ ជាទីសុខជាទីប្រសើរ ។ ប៉ុន្តែនឹងអធិប្បាយស្រាយសេចក្តីសុខនោះឲ្យបានយល់ដល់មនុស្សឯទៀត អំពីសេចក្តីសុខដែលបានសោយក្នុងពេលចូលឈាននោះផងមិនកើត ព្រោះតែកាលណាចេញពីឈានមកវិញហើយ ព្រះអរហន្តលោកមានរាងកាយ អវយវៈ អាយតនៈ ឥន្ទ្រិយ នឹងសំដីភាសា តាមធម្មតាដូនដែលជាសេក្ខបុគ្គលដូច្នោះ ។ ដោយហេតុនេះហើយ បានជាគ្មានពាក្យអ្វីនឹងពោលប្រាប់ឲ្យបំ អំពីសេចក្តីសុខក្នុងព្រះនិព្វាននោះ បើដូច្នេះគេត្រូវវិនិច្ឆ័យសេចក្តីថា ព្រះនិព្វាននោះគ្មាននៅសល់វិញ្ញាណអ្វីដែលមិនមែនជាវិញ្ញាណធម្មតាទេឬអ្វី ? ។

ប្រាជ្ញារបស់មនុស្សយើង ដែលនៅជាបុថុជ្ជននៅឡើយ មិនអាចនឹងយល់បានឡើយ អំពីធម្មជាតិអ្វីដែលសល់នៅរបស់ព្រះនិព្វាន ។ បើដូច្នេះយើងនឹងថាព្រះនិព្វាននោះគ្មាននៅសល់គុណធម៌អ្វីសោះ ក៏ថាមិនបាន មានអ្នកប្រាជ្ញជាតិអឺរ៉ុបម្នាក់ឈ្មោះ អ៉ាគស្ទ-ឌុល្សែរ ដែលជាអ្នកប្រាជ្ញមួយរូបខាងលទ្ធិព្រះពុទ្ធសាសនា បានពោលទុកថា ព្រះនិព្វាននេះយើងនឹងថាជាអ្វីមិនបាន យើងគ្រាន់តែដឹងថា មានព្រះនិព្វានប៉ុណ្ណោះ តែគ្មានអ្នកណាមួយអាចនឹងដឹងឲ្យប្រាកដថាដូច្នេះដូច្នោះបានឡើយ ។

មនុស្សភ្ញាក់ព្រោះតែខ្លួនមើលមិនឃើញពណ៌ទៀត ឬលឿង នឹងថាមនុស្សដែលមានភ្នែកក្លីមើលមិនឃើញដូចខ្លួន ឬក៏គ្មានពណ៌យ៉ាងនេះយ៉ាងនោះក៏ថាមិនបាន ( សង្ស័យក្រៃ ) ។

ចំណែកខាងព្រះអរហន្តក្នុងសាសនាកាតូលិក ដែលបានធ្វើឈានដ៏ជ្រៅជ្រះ ហើយនៅវេលាដែលចេញពីឈានមកវិញ ក៏មិនអាចនឹងអធិប្បាយ អំពីសេចក្តីដែលប្រទះឃើញក្នុងវេលាដែលចូលឈាននោះប្រាប់យើងបានឡើយ ។

ដើម្បីនឹងបញ្ជាក់សេចក្តីនេះយើងត្រូវដឹងថា និព្វានលើដីដែលហៅថាឧបាទិសេសនិព្វានឬនិព្វានរបស់ព្រះអរហន្តនោះគឺជាអារម្មណ៍របស់លោកដែលប៉ះពាល់នូវអមតៈ គឺសេចក្តីពិតប្រាកដ សេចក្តីទៀងជានិច្ច ឥតកើត ឥតស្លាប់, នៅវេលាដែលលោកកំពុងធ្វើឈាន ព្រះអរហន្តលោកបានដល់ទីដៅ ស្ទើរតែនឹងផុតពីលោកយើងទៅហើយ ដោយអំណាចឧត្តមវិជ្ជាឬដោយប្រាជ្ញាញាណយ៉ាងខ្ពស់ដែលលោកបានដល់ នៅវេលាដែលលោកតាំងចូលឈានសមាបត្តិនោះ ។ ឈាននោះឯងនាំទៅប៉ះផ្ទាល់នឹងព្រះនិព្វាន ក្នុងវេលានោះលោកបាននូវញាណមួយយ៉ាងដែលអាចនឹងកត់សំគាល់ផ្ទាល់តែម្តងបាន មិនបាច់ត្រូវការដល់ខន្ធទាំងឡាយឡើយ ។

ចំណែកខាងនិព្វានឥតសល់ ដែលហៅថា អនុបាទិសេសនិព្វាន

ប្តូរវិញ្ញាណនោះ គឺជាសេចក្តីដែលទៀងជានិច្ច សេចក្តីដែលពិតប្រាកដ សេចក្តីដែលគ្មានបច្ច័យទាក់ទងតទៅទៀត ។ យើងមិនអាចនឹងយល់បានថា នៅវេលាក្រោយដែលបុគ្គលទំលាយខន្ធទៅ តើអ្វីដែលចេញពីខ្លួននោះទៅ ? ត្រង់នេះទៀតយើងក៏មិនបានដឹងជាយ៉ាងដូចម្តេច ? ព្រោះប្រាជ្ញាបុថុជ្ជនមិនអាចនឹងឈ្វេងយល់បានឡើយ យើងត្រូវត្រឡប់សាទៅរកសេចក្តីដែលនិយាយអំពីផ្លូវជាតិ ពីកពមួយទៅកពមួយវិញ ត្រង់នេះទំនងជាគ្រាន់តែផ្លូវបញ្ចប់ផ្តល់ប៉ុណ្ណោះ គឺថាជាកិរិយាដែលញ័ររញ្ជួយដែលត្រឹតទុកហើយអំពីជាតិមុនប៉ុណ្ណោះ ឥតមានធាតុអ្វីរបស់មនុស្សទៅជារណបក្នុងកិរិយាដែលផ្លូវជាតិនោះឡើយ ។

សេចក្តីយល់ឃើញនេះ ហាក់ដូចជាប្រកបនឹងគោលចារឹករបស់ក្រុនវិជ្ជាក្នុងសម័យថ្មី ដែលអធិប្បាយអំពីកិរិយាដកបន្ទយនៃចិត្តដែលរឹងត្អឹងចេញ ។ ៙

# ព្រះអភិធម្មបិដក

# គម្ពីរព្រះយមក

លោកប៊ូ - ប៊ូ ប្រែរៀបរៀង

---

## នមត្ថុ សុគតស្ស

សព្វេទេវេ ទេភវំ ទេវទេវោ សុកលយេ
កថាវត្ថុប្បការណំ ទេសយិត្វា រណញ្ជហោ
យមស្ស វិសយាតីតោ នានាយមកប្បដិមណ្ឌិតំ
អភិធម្មំ បការណំ យមកំ នាម ទេសយិ ។

បទនេះ នឹងបានវិសជ្ជនាក្នុងគម្ពីរព្រះយមក:ជាគំរប់ប្រាំមួយតទៅ ដំណើរសេចក្ដីតាមព្រះបាលីថា ទេវទេវោ សម្ដេចព្រះមានព្រះភាគ ជាវិសុទ្ធិទេវតា ដ៏ប្រសើរជាងទេវតាទាំងបីពួក គឺព្រះអរហន្តទាំងឡាយ ជាវិសុទ្ធិទេវតា ១ ពួក ទេវតាទាំងឡាយដែលកើតជាឧបបាតិកកំណើត ១ ពួក ព្រះមហាក្សត្រទាំងឡាយ ដែលទ្រង់សោយរាជសម្បត្តិ លើផ្ទៃផែនដីជាសម្មតិទេវតា ១ ពួក ។ រណញ្ជហោ សម្ដេចព្រះមានព្រះភាគ កាប់ចំបុកនូវគន្ធនៃកិលេសរាសី ដ៏ជាប់ជំពាក់នៅក្នុងខន្ធសន្តាន យមស្ស វិសយាតីតោ ព្រះអង្គកន្លងបង់នូវវិស័យនៃមច្ចុរាជ លោកនាថោ ទ្រង់ព្រះនាមថាលោកនាថ ព្រោះហេតុជាទីពឹងរបស់សព្វសត្វ កថាវត្ថុប្បការណំ ទេសយិត្វា កាលព្រះអង្គត្រាស់

សំដែងព្រះសទ្ធម្មវិសេសទេសនា នូវគម្ពីរព្រះកថាវត្ថុបករណ៍ចប់ចុះហើយ លំដាប់ពីនោះ ទើបទ្រង់ទេសនានូវគម្ពីរព្រះយមកបករណ៍តទៅទៀត ព្រះអង្គសំដែងក្នុងសុភល័យពិភពនៃសម្តេចអមរិន្ទទេវរាជ ភរផ្ទេបេដេះ ព្រះបរមលោកនាថត្រាស់ទេសនាដោយសង្ខេប ប្រដាប់ដោយយមកមានប្រការផ្សេង ៗ រាប់ចូលក្នុងព្រះអភិធម្មបិដក ។

មានពាក្យបុច្ឆាថា កេនដ្ឋេន យមកំ គម្ពីរនេះឈ្មោះថាយមកដោយអត្ថមានប្រការដូចម្តេច ?

មានពាក្យវិសជ្ជនាថា យមកដ្ឋេន គម្ពីរនេះបានជាឈ្មោះថាយមកព្រោះអត្ថថា សម្តេចព្រះមានព្រះភាគត្រាស់ទេសនាជាគូ ៗ នឹងគ្នា គឺបុច្ឆាក៏ជាគូ វិសជ្ជនាក៏ជាគូ ហេតុនោះ បានជាគម្ពីរនេះឈ្មោះថាយមកប្រៀបដូចដើមពាំងទាំងគូ ហៅថាយមកសាលា នឹងប្រៀបដូចយមកប្បាដិហារ្យ ដែលសម្តេចព្រះបរមសាស្តាធ្វើក្រោមដើមស្វាយនៃនាយឧយ្យានបាលឈ្មោះគណ្ឌាមព្រឹក្ស ព្រះអង្គធ្វើបាដិហារ្យបណ្តាលឲ្យទឹកនឹងអគ្គីកើតឡើងជាគូ ៗ គ្នា ឯយមកប្បាដិហារ្យនោះមានឧបមាដូចម្តេច គម្ពីរព្រះយមកនេះទ្រង់ត្រាស់ទេសនាជាគូ ៗ នឹងគ្នា មានឧបមេយ្យដូច្នោះដែរ ។ អាស្រ័យហេតុព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាជាគូ ៗ នឹងគ្នាយ៉ាងនេះ បានជាគម្ពីរនេះឈ្មោះថាយមក; ឧសភេន វិភត្តិំ គម្ពីរព្រះយមកនេះ សម្តេចព្រះមានព្រះភាគត្រាស់ទេសនា ចែកចេញទៅដោយ

អំណាចនៃយមក ១០ ប្រការគឺ:

| | |
|---|---|
| ១-មូលយមក | ៦-សង្ខារយមក |
| ២-ខន្ធយមក | ៧ អនុសយយមក |
| ៣-អាយតនយមក | ៨-ចិត្តយមក |
| ៤-ធាតុយមក | ៩ ធម្មយមក |
| ៥ សច្ចយមក | ១០-ឥន្ទ្រិយយមក (១) ។ |

មូលយមក ព្រះពុទ្ធអង្គទេសនាជាគូគ្នាទៅខាងដើមយមកទាំង៩ ។ ខន្ធយមក ព្រះពុទ្ធអង្គទេសនាដោយខន្ធទាំងប្រាំជាគូគ្នា ។ អាយតនយមក ព្រះពុទ្ធអង្គទេសនាដោយអាយតន ១២ ជាគូ ១ គ្នា ។ ធាតុយមក ព្រះពុទ្ធអង្គទេសនាដោយធាតុ ១៨ ជាគូ ១ គ្នា ។ សច្ចយមក ព្រះពុទ្ធអង្គទេសនា ដោយព្រះចតុរារិយសច្ចជាគូ ១ គ្នា ។ សង្ខារយមក ព្រះពុទ្ធអង្គទេសនាដោយសង្ខារទាំង ៣ គឺ: កាយសង្ខារ ១, វចីសង្ខារ ១, មនោសង្ខារ ១ ជាគូ ១ គ្នា ។ អនុសយយមក ព្រះពុទ្ធអង្គទេសនាដោយអនុស័យ ៧ មានកាមរាគានុស័យជាដើម ជាគូ ១ គ្នា ។ ចិត្តយមក ព្រះពុទ្ធអង្គទេសនាដោយចិត្ត ៨៩ ដួងជាគូ ១ គ្នា ។ ធម្មយមក ព្រះពុទ្ធអង្គទេសនាដោយចេតសិកធម៌ ៥២ ជាគូ ១ គ្នា ។ ឥន្ទ្រិយយមក ព្រះ

---

១- ពាក្យក្នុងគម្ពីរព្រះអភិធម្មនេះ ត្រូវអានតាមរបៀបភាសាបាលីថាយមកៈ មូលៈ កុសលៈ ។ល។ មិនបាច់ប្រើយុគលពិន្ទុទេ ។

ពុទ្ធអង្គទ្រង់ទេសនាដោយឥន្ទ្រិយ ២២ ជាគូ ។ គ្នា ។

អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ព្រះពុទ្ធអង្គទេសនានូវព្រះអរិយសច្ច, សង្ខារ, អនុស័យ, ចិត្ត, ចេតសិក និងឥន្ទ្រិយជាគូ ។ គ្នា ហេតុនោះទើបឈ្មោះថា សច្ចយមក, សង្ខារយមក, អនុសយយមក ចិត្តយមក, ធម្មយមក, និង ឥន្ទ្រិយយមក, ដោយលំដាប់គ្នា ។

ក្នុងយមក ១០ ប្រការ មានមូលយមកជាដើម មានឥន្ទ្រិយយមកជាបរិយោសាននោះ មានយមកបែកចេញទៅទៀតជាច្រើនក្រៃលែង នឹងអធិប្បាយក្នុងមូលយមកជាមុន ។

មានពាក្យបុច្ឆាថា គោ ឆគ្គេឆ ព្រោះអត្ថដូចម្ដេច បានជាឈ្មោះថា មូលយមក ?

មានពាក្យវិសជ្ជនាថា មូលគ្គេឆ យមកនេះឈ្មោះមូលយមក ព្រោះអត្ថថាជាដើមជាទីតាំងនៃយមកទាំងឡាយ ។ មានពាក្យអធិប្បាយថា ព្រះពុទ្ធអង្គទេសនាយមកនេះ ទុកជាខាងដើម ហើយទើបទ្រង់សំដែងយមកទាំងឡាយដទៃទៀត ឲ្យបែកខ្វែកចេញ ទៅទៀតជាច្រើនក្រៃលែង ហេតុដូច្នោះ យមកនេះទើបបានឈ្មោះថា មូលយមក ។ ឯមូលយមកនេះព្រះពុទ្ធអង្គទេសនាប្រដាប់ដោយវារៈ ២ ប្រការគឺ ឧទ្ទេសវារ ១ និទ្ទេសវារ១ ។

ឧទ្ទេសវារនោះ គឺទេសនាដោយបំប្រួញ លើកឡើងសំដែងតែខ្លីៗ ប៉ុណ្ណោះឈ្មោះថា ឧទ្ទេសវារ ។

ដែលទេសនាដោយពិស្តារ ចែកចេញជាពួក ៗ ទៅទៀតឈ្មោះជា និទ្ទេសវារ ។

ឯមូលយមក មានយមកជាបរិវារចែកចេញទៅទៀតជា ៣ ប្រការ គឺ អត្ថយមកា ១ ធម្មយមកា ១ បុច្ឆាយមកា ១ ជាបរិវារនៃមូលយមកទាំង ៣ ប្រការ ។

អត្ថយមកនោះ ព្រះពុទ្ធអង្គសំដែងនូវសេចក្តី ២ ប្រការគឺកុសល ១ មូលនៃអកុសល ១ ។

ធម្មយមកនោះ ព្រះពុទ្ធអង្គសំដែងនូវបាលីជាគូ ១ គ្នា ត្រាស់ជាអនុលោមបដិលោមត្រឡប់ទៅត្រឡប់មក ព្រះបាលីដែលសំដែងនោះជាអនុលោមទីមួយ ជាបដិលោមទីមួយ អាស្រ័យហេតុនេះ ទើបបាន ឈ្មោះថា ធម្មយមកា ។

បុច្ឆាយមកនោះ ព្រះពុទ្ធអង្គទេសនាបុច្ឆាជាគូ ១ សួរម្តងមួយ ១ ៗ ជាគូ ១ គ្នា ហេតុនោះទើបឈ្មោះថា បុច្ឆាយមកា ។

យមកទាំង ៩ ប្រការ មានខន្ធយមកជាដើម មានឥន្ទ្រិយយមកជាបរិយោសាន មានយមកបរិវារចែកចេញទៅទៀតជា ៣ ប្រការគឺ អត្ថ-យមកា ១ ធម្មយមកា ១ នឹង បុច្ឆាយមកា ១ ដូចគ្នា ។

យមក ៣ គឺ: អត្ថយមកា ១ ធម្មយមកា ១ បុច្ឆាយមកា ១ នោះ ក្នុងយមកមួយ ៗ មានន័យបួន ៗ គឺមូលន័យ ១ មូលកន័យ ១ មូលមូល-

ន័យ ១ មូលមូលកន័យ ១ ជាន័យ ៤ ប្រការ ។

ន័យទាំង ៤ នោះ ក្នុងន័យមួយ ៗ មានយមកបរិវារបី ៗ គឺ: មូល-យមក ១ ឯកមូលយមក ១ អញ្ញមញ្ញមូលយមក ១ ។

យមកទាំង ៣ នោះ ក្នុងយមកមួយ ៗ មានបុច្ឆាពីរ ៗ គឺ: អត្ថសង្ស័យ ១ អត្ថសន្និដ្ឋាន ១ ។

យមកដែលជាពួកធំមួយ ៗ នោះ មានន័យបួនជាបរិវារហើយមានបុច្ឆា ២៤ មានអត្ថ ៤៨ ដូចគ្នាទាំង ១០ យមក ។

ពណ៌នាយមកទាំងនេះ ប្រាថ្នានឹងឲ្យឃើញជាពួកជាក្រុមគ្នា ហេតុនោះ អ្នកប្រាជ្ញចូលកំណត់ចាំទុកក្នុងសន្តានចុះ ។

## មូលយមក

ពណ៌នាក្នុងមូលយមកខាងដើម សេចក្តីថា លោកជាជោ សម្តេចព្រះមានព្រះភាគជាទីពឹងរបស់សត្វក្នុងសកលលោកធាតុ ព្រះអង្គត្រាស់ទេសនាតាំងផ្តើមជាបុច្ឆាមុនដំបូងថា យេ កេចិ កុសលា ធម្មា ធម៌ទាំងឡាយណាជាកុសល ធម៌ទាំងឡាយនោះជាមូលនៃកុសល, ធម៌ទាំងឡាយណាជាមូលនៃកុសល ធម៌ទាំងឡាយនោះ ជាមូលនៃកុសល ឬ ? ត្រាស់បុច្ឆាដូច្នេះហើយ ទើបត្រាស់វិសជ្ជនាដោយព្រះអង្គឯងថា អាមន្តា អើ! ធម៌ទាំងឡាយពួកណាមួយជាកុសល ធម៌ទាំងឡាយពួកនោះឯងជាមូលនៃកុសល, ធម៌ពួកណាដែលជាមូលនៃកុសល ធម៌

ពួកនោះឈ្មោះថាកុសល ។ ត្រាស់វិសជ្ជនាដោយព្រះអង្គឯងដូច្នេះហើយ ទើបត្រាស់បុច្ឆាតទៅទៀតថា កតមេ ធម្មា កុសលា ធម៌ទាំងឡាយដែលថាជាមូលនៃកុសលនោះ គឺធម៌ពួកណា ? ទើបត្រាស់វិសជ្ជនាថា តយោ ធម្មា កុសលា ធម៌ទាំងឡាយបីប្រការ ជាមូលនៃកុសលបី ។ ទើបត្រាស់បុច្ឆាថា ធម៌ទាំងបីប្រការដែលឈ្មោះថាជាមូលនៃកុសលបីប្រការនោះ តើបានដឹងធម៌ពួកណា ? ទើបត្រាស់វិសជ្ជនាថា ធម៌បីប្រការដែលជាមូលនៃកុសលនោះគឺៈ អលោភោ ១, អទោសោ ១, អមោហោ ១ ។

មានពាក្យព្រះអដ្ឋកថាចារ្យ ពោលបន្ថែមសេចក្ដីអនុលោមតាមព្រះពុទ្ធដីកានៃសម្ដេចព្រះបរមទសពល ដើម្បីនឹងញុំាងកុលបុត្រអ្នកកើតខាងក្រោយ ឲ្យបានដឹងសេចក្ដីដោយងាយ ។ អធិប្បាយថា មូលន្តិ បតិដ្ឋា មូលសព្ទនោះ ប្រែថាឫស, គល់, ទីតាំង ។ ធម៌ទាំងបីប្រការគឺៈ អលោភោ, អទោសោ, អមោហោ នោះជាឫស ជាគល់ ជាទីតាំងនៃកងកាកុសលទាំងពួង ។ អាស្រ័យធម៌បីប្រការនេះឯងជាមូល បានជាកុសលទើបកើតឡើងបាន ប្រៀបដូចឫសនៃដើមឈើដែលជាទីកើតជាទីតាំងនៃដើមឈើ មូលំ និស្សាយ ចម្មតាព្រឹក្សាជាតិទាំងអស់ រមែងអាស្រ័យនូវឫសទើបដុះឡើងបាន បើគ្មានឫសកែវទេ មិនអាចនឹងដុះលូតលាស់ឡើងបានឡើយ ។ សេចក្ដីនេះដូចម្ដេច ? កុសល-

ធម៌ទាំងឡាយទាំងពួងនឹងកើតមានឡើងបាន ក៏អាស្រ័យតែធម៌បីប្រការគឺ អលោភោ ១, អទោសោ ១, អមោហោ ១ ។ បើធម៌ទាំងបីប្រការនេះគ្មានទេ ការកុសលទាំងពួងក៏គ្មានដែរ ។ ការកុសលនឹងកើតមានឡើងបាន ក៏អាស្រ័យនូវធម៌បីប្រការ ដូចជាដើមឈើអាស្រ័យឫសនោះដែរ ។

អលោភោ

អលព្ភតីតិ អលោភោ ធម៌ដែលឈ្មោះថា អលោភោ នោះបាននឹងហេតុមិនប្រាថ្នាមិនចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ ។ អទោសោ នោះ បាននឹងសភាពគ្មានចិត្តប្រទូសរ៉ាយអ្នកដទៃ នឹងទ្រព្យសម្បត្តិរបស់គេ ។ អមោហោ នោះ គឺការមិនវង្វេង មិនប្រាសចាកស្មារតី ។

អលោភោ នាមហេតុ សេចក្តីមិនលោភកើតមានក្នុងសន្តានចិត្តរបស់អ្នកណា ជាហេតុនឹងឲ្យអ្នកនោះបរិច្ចាគទានបាន ដោយហោចទៅសូម្បីខ្លួនមិនបានឲ្យ បើឃើញគេឲ្យ ក៏មានចិត្តត្រេកអរដែរ ជួយអនុមោទនាទានរបស់គេ លុះបានអនុមោទនាទានហើយ ក៏នឹងបានតាំងនៅក្នុងបុញ្ញកិរិយាវត្ថុ ។ ការបំពេញទាននោះអាស្រ័យតែចិត្តមិនលោភ ហេតុនេះអលោភោ ទើបរាប់ចូលក្នុងមូលនៃកុសល ។ អលោភោ មានក្នុងសន្តានចិត្តហើយ ជាហេតុនឹងឲ្យរួចផុតពីសេចក្តីទលិទ្រ ហើយនឹងឲ្យជាទីស្រឡាញ់របស់ទេវតានឹងមនុស្សទាំងឡាយ ហេតុតែបានបរិច្ចាគទាន ។

ធាតុ ឥលិទ្ធហារិកា ពានទឹងនាំឲ្យកំចាត់បង់ចេញនូវសេចក្ដីទ័លក្រ កំសត់ទុគ៌ត ។ ធាតុ ពន្ធត ធាជយ្យំ ពានទឹងឲ្យបានខ្ជាប់វេចស្ពាយស្បៀងជាប់តាមខ្លួនទៅក្នុងផ្លូវកន្ដារ គឺសង្សារវដ្ដ បើមិនទាន់ដល់ព្រះនិព្វានដរាបណា ក៏មិនបានក្រលំបាកអត់ឃ្លានគ្មានអាហារទឹងបរិបូណ៌ដោយទ្រព្យសម្បត្តិ គ្រប់ជាតិគ្រប់ភពដរាបនោះ ។ ធាតុ សហាយសម្ពុត្តំ ពានជាមិត្រសំឡាញ់ដើរផ្លូវទៅ រហូតដល់ខ្លងមហាណ្ណពទៅដល់ត្រើយ ។ ធាតុ អោគន្ធបថំ វរំ ពានជាផ្លូវសម្រាប់ដើរទៅកាន់អមតវិថី ។

ការបំពេញពាននេះ បុគ្គលមិនងាយនឹងធ្វើបានទេ ទាល់តែមិនលោភហើយពិចារណាឃើញជាក់ច្បាស់ថា ផលពានដែលអាត្មាបានបំពេញនោះ នឹងបានធ្វើជាស្បៀងទៅខាងមុខ ឃើញដូច្នេះទើបបំពេញពានបាន ។ បុគ្គលអ្នកបំពេញពាន បានឲ្យភោជនាហារជាពាននោះ បានឈ្មោះថាឲ្យជីវិត, ឲ្យអាយុ, ឲ្យកម្លាំង, ឲ្យបញ្ញា, ព្រោះថាភោជនាហារតែកាលណាបរិភោគរួចហើយ ក៏អាចរក្សាជីវិតឲ្យចំរើនវឌ្ឍនាការញុំាងអាយុឲ្យនៅយូរអង្វែងបាន, នឹងឲ្យមានកម្លាំងមាំមួន ព្រោះបានបរិភោគភោជនាហារ លុះតែបានបរិភោគអាហាររួចហើយ ទើបធ្វើការងារឲ្យសម្រេចទៅបាន ។

(នៅមានត)

មធុរសវាហិណី

# សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ

(តមក)

---

ឯសម្តេចព្រះជម្ពូទីបេស្សរាធិបតីធម្មាសោករាជ ព្រះអង្គបានទតឃើញហេតុនោះហើយ ក៏ដល់នូវសេចក្តីស្ញប់ស្ញែងភ័យស្លុតក្នុងព្រះហឫទ័យ ទើបរំពឹងគិតថា: កុមារដែលមានឫទ្ធិអានុភាពយ៉ាងនេះ ជាបុគ្គលអាចនឹងសម្លាប់យើងហើយដណ្តើមយកនូវរាជសម្បត្តិអំពីយើង សោយរាជ្យបានដោយងាយពួដ៏អនាគតដ៏ខ្លីខាងមុខពុំលែងឡើយ ដូច្នេះត្រូវតែយើងសម្លាប់កុមារនេះជាមុនទើបបាន ។

ព្រះបរមក្សត្រិយ៍ទ្រង់ព្រះចិន្តាដូច្នេះហើយ ក៏ត្រឡប់មកកាន់ព្រះនគរវិញ, លុះបានចូលមកដល់នគរហើយ ក៏ត្រាស់ឲ្យហៅ វិសមលោមកុមារ ចូលមកកាន់សំណាក់ព្រះអង្គ ហើយបង្គាប់អាមាត្យទាំងឡាយថា: ម្នាលអ្នកទាំងឡាយដ៏ចំរើន ត្រូវអ្នកទាំងឡាយចាប់ចងកុមារនេះនាំយកទៅដាក់ក្នុងពន្ធនាគារឃុំរក្សាទុកកុំឲ្យចេញទៅណារួចឡើយ ។ ឯអាមាត្យទាំងឡាយ ក៏បានធ្វើតាមបង្គាប់ព្រះបរមក្សត្រិយ៍នោះឯង ។

គ្រាន់តែ វិសមលោមកុមារ ដេកនៅក្នុងគុកនេះ អស់រយៈវេលាកន្លងទៅបានប្អូនខែគត់ ក្រោយនោះព្រះបាទធម្មាសោករាជព្រះអង្គ

ត្រាស់បង្គាប់អាមាត្យឲ្យយកឫស្សីមកបន្ទាត់ជាបាច់ចំនួនហុកសិបបាច់ ក្នុងមួយបាច់ហុកសិបដើម ៗ ប្រវែងហុកសិបហត្ថ ហើយប្រមូលឲ្យមូលគ្នាជាដុំឲ្យដាក់សួលដែកវានក្នុងហើយលើកទៀងបញ្ឈរនៅមុខព្រះលាន ទើបព្រះអង្គត្រាស់បង្គាប់អាមាត្យឲ្យទៅដោះ វិសមលោមកុមារ ចេញអំពីគុកនាំចេញមកកាន់សំណាក់ព្រះអង្គ ហើយទ្រង់ត្រាស់បង្គាប់ជាថ្មីទៀតថាៈ ម្នាលអ្នកទាំងឡាយដ៏ចំរើន ត្រូវអ្នកបង្ខំឲ្យកុមារកាន់យកដាវនេះកាប់បាច់ឫស្សីទាំងហុកសិបបាច់ឲ្យដាច់ខ្ទី ៗ ប្រមាណបួន ៗ ធ្នាប់ឲ្យត្រឹមគ្នា បើកុមារនេះកាប់ពុំបានដាច់ទេ ត្រូវអ្នកទាំងឡាយសម្លាប់កុមារនេះ កុំវានឡើយ ៗ

ឯ វិសមលោមកុមារ លុះបានស្តាប់ព្រះរាជឱង្ការត្រាស់បង្គាប់ដូច្នោះហើយ ក៏សួនទាចំពោះអាមាត្យទាំងនោះថាៈ បពិត្រអ្នកទាំងឡាយខ្លួនខ្ញុំបានដេកនៅក្នុងពន្ធនាគារជាយូរហើយ ត្រូវអត់បាយអត់ទឹកលំបាកដោយអាហារ ខ្ញុំស្រេកឃ្លានពន់ពេកណាស់ ដូច្នេះ ត្រូវតែខ្ញុំបរិភោគបាយ ផឹកទឹកឲ្យឆ្អែតជាមុនសិន ទើបកាប់បាច់ឫស្សីនេះជាខាងក្រោយ ៗ

ពួកអាមាត្យបានស្តាប់ហើយ ក៏ពោលតបវិញថាៈ ឥឡូវនេះយើងគ្មានអាហារណាសម្រាប់ឲ្យអ្នកបរិភោគទេ ៗ កុមារស្តាប់ហើយពោលថាៈ បើដូច្នេះខ្ញុំសុំលាទៅផឹកទឹកក្នុងស្រះបោក្ខរណីនេះសិន ៗ

អាមាត្យទាំងឡាយក៏ទទួលព្រមថាៈ សាធុ ៗ ប្រពៃហើយ ៗ ក៏នាំ

កុមារទៅកាន់ស្រះបោក្ខរណីនោះឯង ។

ចំណែកខាងវិសមលោមកុមារ ក៏ចុះទៅក្នុងស្រះបោក្ខរណីបានផ្លូតហើយមុជចុះទៅកាន់បាតស្រះបរិកោគកកដីកបដល់ផ្អែត ផឹកទឹករួចស្រេច ទើបត្រឡប់ឡើងមកវិញយកដែតាប់ដងដាវ នៅវេលាដែលមហាជនទាំងអស់ក៏តុងប្រជុំគ្នាចាំមើល ហើយស្ទុះលោតឡើងឮដីអាកាសកំពស់ប្រមាណ ៨០ ហត្ថ ដោយកំឡាំងឆាប់រហ័សហើយចុះមកកាប់បាច់ឫស្សីទាំងអស់ឲ្យដាច់ជាកំណាត់តូច កំណាត់ធំ ប្រមាណបួន ។ ធ្លាប់ដោយដាវ តាំងពីចុងដកបដល់គល់ ស្រាប់តែបានឮសំឡេងគ្រឹកៗ ដោយត្រូវស្នួលដែកនៅខាងក្នុង លុះបានដឹងហើយ ក៏បោះដាវចោលទ្រហោយំបំរះនទៀលក្នុងកាលនោះឯង ។

ទើបពជបុរសទាំងឡាយគេសួរថា: ព្រោះហេតុអ្វី បានជាអ្នកយំ? ព្រះពជកុមារក៏និយាយប្រាប់ទៅពជបុរសទាំងនោះថា: បានជាខ្ញុំយំ ព្រោះខ្ញុំគិតថា: បណ្ដាបរិស័ទច្រើនជាម៉ឺនទាំងម៉្លេះ មិនមានបុរសណាមួយ មានសន្ដានល្អស្រឡាញ់រាប់អានខ្ញុំដល់ម្នាក់សោះ ប្រសិនបើមានបុរសមានសន្ដានល្អ គង់នឹងនិយាយប្រាប់ខ្ញុំថា:ខាងក្នុងបាច់ឫស្សីទាំងនេះ មានស្នួលដែកបង្កប់នៅខាងក្នុង, ចំណែកខ្ញុំ លុះបានដឹងហើយក៏នឹងប្រុងប្រយ័ត្នកាប់បាច់ឫស្សីទាំងឡាយនេះ ឲ្យដាច់ជាកំណាត់តូច កំណាត់ធំប្រមាណបួន ។ ធ្លាប់បានដោយពិត ។

លំដាប់នោះ ព្រះបាទធម្មាសោករាជព្រះបរមក្សត្រិយ៍ទ្រង់បានរមិលមើលនូវអំពើដែលរាជកុមារបានធ្វើជាអស្ចារ្យដូច្នោះហើយ ព្រះអង្គក៏មានព្រះរាជហឫទ័យសោមនស្សជ្រះថ្លា បានព្រះរាជទានទ្រព្យសម្បត្តិ មានប្រមាណច្រើន ហើយព្រះអង្គតាំងឲ្យអភិសេក វិសមលោមកុមារ ឲ្យស្ថិតនៅក្នុងឋានៈជាព្រះឧបរាជក្នុងកាលនោះហោង ។

ឯកំឡាំងរបស់ វិសមលោមកុមារ នោះបានឈ្មោះថាជាលាភ បាននូវសម្បត្តិដ៏វិសេសយ៉ាងនេះឯង ។

ពាក្យបុច្ឆាសួរថា: កំឡាំងនេះនឹងថាជាកំឡាំងនៃជាតិនឹងគោត្រជាដើមក៏ទេ នឹងថាជាកំឡាំងនៃអំពើទុច្ចរិតទាំង ១០ មានបាណាតិបាតជាដើមក៏ទេ កំឡាំងរបស់ វិសមលោមកុមារ នេះ ជាកំឡាំងកើតមកអំពីតែអ្វី ?

វិសជ្ជនាថា: កំឡាំងនេះជាកំឡាំងកើតមកអំពីសេចក្ដីសុចរិតដែលកុមារបានឲ្យទានបាយជាដើម ដល់ព្រះភិក្ខុសង្ឃក្នុងសាសនាព្រះពុទ្ធកស្សបនោះឯង ។ ឯវិសមលោមកុមារ លុះបានទទួលទីជាឧបរាជហើយ សោយមហាសម្បត្តិដ៏ប្រសើរយ៉ាងនេះ ក៏មានព្រះហឫទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានធ្វើសក្ការបូជាដល់ភិក្ខុសង្ឃជាច្រើន មានព្រះមហាមោគ្គល្លីបុត្តតិស្សត្ថេរជាអាទិ៍ ដោយអំណាចនៃទានវត្ថុមានចីវរបិណ្ឌបាតសេនាសនគិលានភេសជ្ជៈជាដើមហើយ បានរក្សាសីលប្រាំសីលប្រាំបី

ជាប់ពុំដាច់ដរាបដល់អស់អាយុទៅ ក៏បានឡើងទៅសោយសម្បត្តិទិព្វក្នុងស្ថានទេវលោកនាយ ដោយសមគួរតាមបុញ្ញកម្មរបស់ខ្លួនដោយពិត ៗ

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយ លោកពោលជាបទព្រះគាថាដូច្នេះថា:-

ឯវំ តិវិធំ សុចរិតំ សុមនោ ករិត្វា
លភតិ ពលនេកវិកវស្ស កុមារកោ សោ
តម្ហា ជិរតា សុចរិតំ វិកភិឆុរូបំ
កត្វាន និព្វុតិបទករណំ ករោថ ។

អធិប្បាយថា ឯវិសមលោមកុមារនោះ មានចិត្តល្អជ្រះថ្លា បានធ្វើនូវអំពើសុចរិតទាំង ៣ ប្រការយ៉ាងនេះហើយ ជាបុគ្គលបាននូវកំឡាំង គួរដល់ការបាននូវសម្បត្តិច្រើនជាអនេកនឹងគណនាគ្រាប់ពុំបានឡើយ ៗ អ្នកទាំងឡាយដែលមានព្យាយាម បើបានបំពេញនូវសុចរិតឲ្យល្មមសមគួរដល់សម្បត្តិរបស់ខ្លួនហើយ បានឈ្មោះថាបានបំពេញនូវហេតុជាឧបាយដើម្បីដល់នូវព្រះនិព្វាន ជាទីរលត់នូវកងទុក្ខទាំងពួងបានដោយពិត ៗ

សំដែងរឿងនិទានវិសមលោមកុមារ ឧបកដជាគំរប់បី ក្នុងវគ្គទីពីរ ក៏ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណោះឯង ៗ

---

(នៅមានត)

## មហោសថជាតក

# លោក អ៊ុម-ភន ចម្លងពីសាស្ត្រាស្លឹករឹត

*ព្រះពុទ្ធវង្ស គិប-តូរ ពិនិត្យ*

( តមក )

---

លំដាប់នោះព្រះមហាក្សត្រទ្រង់ផ្ដើមផ្ដាំនូវសេនកបណ្ឌិត ស្ដេចសូត្រនូវបទព្រះគាថា ជាបឋមថា៖

បញ្ញាយុបេតំ សិរិយា វិហីនំ
យសស្សិនំ វាបិ អបេតបញ្ញំ
បុច្ឆាមិ តំ សេនក ឯតមត្ថំ
កមេត្ថ សេយ្យោ កុសលា វទន្តិ ។

សេនក នៃអាចារ្យសេនកអើយ ! អញនឹងដណ្ដឹងអាថិប្រស្នានោះនឹងព្រះស្ដេង, អ្នកមួយដ៏ប្រកបនូវប្រាជ្ញា ហើយថយលែងយស-សម្បត្តិបរិវារ, អ្នកមួយមានយសសម្បត្តិបរិវារច្រើន ហើយប្រាសចាកប្រាជ្ញា; អ្នកទាំងពីរនេះ តើអ្នកឯណាប្រសើរ ? ។

អាចារ្យសេនក ស្ដាប់អាថិប្រស្នានោះហើយ លុះនូវអំណាចនៃអាត្មាឆ្លើយនូវអាថិប្រស្នាទូលព្រះមហាក្សត្រជាបទព្រះគាថាថា៖

ធីរា ច ពាលា ច ហវេ ជនិន្ទ
សិប្បូបបន្នា ច អសិប្បិនោ ច

សុជាតិមន្តោបិ អជាតិមស្ស
យសស្សិនោ បេសកការា ភវន្តិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ និហីនោ សិរិមាវ សេយ្យោតិ ។

បពិត្រក្សត្រថ្លៃប្រសើរអើយ ! រីអ្នកប្រាជ្ញក្តី អ្នកខ្លៅក្តី អ្នកមានសិល្បសាស្ត្រក្តី អ្នកឥតសិល្បសាស្ត្រក្តី អ្នកមានជាតិឧត្តមក្តី អ្នកមានជាតិថោកថយក្តី; រីអ្នកទាំងអម្បាលនេះ សឹងដ៏ទៅបំរើអ្នកមានយស, ហេតុនោះខ្ញុំយល់ហើយ ខ្ញុំថាអ្នកមានប្រាជ្ញា ឥតសម្បត្តិមិនប្រសើរ រីអ្នកដ៏មានសិរីសម្បត្តិនោះទើបប្រសើរ ។

ស្តេចស្តាប់ពាក្យអាចារ្យសេនកដូច្នោះហើយ, ស្តេចមិនដណ្តឹងទៅអាចារ្យទាំង ៣ នោះឡើយ, ហេតុដ្បិតអំពីមុនមកស្តេចរែងដណ្តឹងកិច្ចការអ្វីមួយហើយ អាចារ្យទាំង ៣ សឹងឆ្លើយតាមពាក្យអាចារ្យសេនក ហេតុនោះ ស្តេចមិនដណ្តឹងឡើយ, ស្តេចដណ្តឹងទៅកាន់ពោធិសត្វថា:

មហោសថ បណ្ឌិត ម្នាលបាមហោសថ! អ្នកប្រាជ្ញអាចមានប្រាជ្ញាមិនចេះថយយល់អាថ៌ប្រស្នាទាំងពួង អញនឹងដណ្តឹងថា រីអ្នកខ្លៅមានបរិវារច្រើន, រីអ្នកមានប្រាជ្ញាហើយហីននូវសម្បត្តិ, អ្នកទាំងពីរនេះតើឯណាប្រសើរ ? ។

លំដាប់នោះ, ពោធិសត្វទូលថា បពិត្រមហារាជអើយ ! សូម

អញ្ជើញស្តេចស្តាប់ ខ្ញុំនឹងសំដែងថ្វាយព្រះអង្គហោង ។ ទើបពោធិសត្វសូត្រនូវព្រះគាថានេះថា :

ចាចាធិ កម្មានិ ករោន្តិ ពាលា
ឥធមេវ សេយ្យោ ឥតិ មញ្ញមានោ
ឥធលោកាធសព្ទំ បរលោកំ អធសព្ទំ
ឧភយត្ថ ពាលោ កលិមគ្គហេសិ
ឃតម្បិ ធិសាន អហំ វទាមិ
បញ្ញាវ សេយ្យោ ន យសស្សី ពាលោតិ ។

សេចក្តីថា: បពិត្រមហាពជអើយ ! ពួកអ្នកកំឡៅទាំងឡាយ ក៏សំគាល់ទុកចិត្តថា សម្បត្តិប្រសើរ ហើយក៏ធ្វើនូវអំពើបាបទាំងឡាយយល់តែលោកិយនេះ ហើយមិនយល់បរលោក ហើយកាន់យកនូវការអកុសលអំពលញជំលោកនេះ, ហេតុដូច្នោះ ខ្ញុំថា អ្នកមានប្រាជ្ញាប្រសើរឯអ្នកខ្លៅមានយសបរិវារច្រើននោះពុំប្រសើរឡើយ ។

ស្តេចស្តាប់ពាក្យពោធិសត្វទូលដូច្នោះហើយ, ស្តេចមើលមើលទតទៅកាន់អាចារ្យសេនកថា ឥឡូវនេះ, មហោសថថា អ្នកប្រកបនូវប្រាជ្ញាឯងនោះឧត្តមប្រសើរ ។ ឯអាចារ្យសេនកឯង តើថាដូចម្តេច ? អាចារ្យសេនកស្តាប់ហើយទូលថា បពិត្រមហាពជអើយ ! វីមហោសថនេះនៅក្មេងក្តាត់ ពុំក្ងិនក្បីរអំពីមាត់នៅឡើយ ទើងបេះអ្វីព្រះអង្គ ; សូម

ព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យខ្ញុំជាអ្នកចាស់ទុំបរមបូរាណ នឹងនិទានថ្វាយ និយាយពីមហាសេដ្ឋីមួយឈ្មោះ គោវិន្ទ ស្ថិតនៅឰដ៏នគរនេះ មានទ្រព្យ ៨០ កោដិឃ្លាំង មានអ្នកផងទាំងឡាយមកគាល់ហៅ នៅបំរើជាប្រក្រតី, សេដ្ឋីនោះមានរូបអាក្រក់ក្កាត់ ឥតកូនប្រុស-ស្រី មិនចេះសិល្បសាស្ត្រអ្វីដល់តិច ឥតសាច់ផៅ កាលណាស្រដីទៅមានទឹកមាត់នោះហូរហៀរចេញពេញថ្ពាល់ទាំងសងខាង មាននាងពីរនាក់ពាក់នូវគ្រឿងប្រ-ដាប់ល្អចំណាប់ដូចស្រីសួគ៌ មុខគួរតែអាណិតពិតពិលរមិលមើលនូវលំអ ហើយកាន់យកនូវផ្កានីលុប្បលរីកថ្មី នៅសងខាងសេដ្ឋីនោះ តែងនឹងទទួលជូតទឹកមាត់នោះបោះចោលដោយបន្ទួចទៅក្រៅ, រីអ្នកប្រមឹកស្រាផងទាំងពួង ដើរទៅកាន់រោងស្រាហើយប្រាថ្នាចង់បានផ្កានីលុប្បល ទៅដល់ផ្ទះគោវិន្ទសេដ្ឋី ស្រដីហៅទៅថា បពិត្រអ្នកគោវិន្ទសេដ្ឋីអើយ ! រីគោវិន្ទសេដ្ឋីនោះស្ថិតនៅទៀបមាត់បង្អួច ស្ដាប់ឮពាក្យអ្នកប្រមឹកស្រាផងទាំងឡាយហៅទៅដូច្នោះ មហាសេដ្ឋីនោះក៏ឆ្លើយថា ហៅអ្វី ? ស្រដីតែម្ដោះហើយ ទឹកមាត់នោះហូរហៀរសសៀរអំពៀរចេញពេញថ្ពាល់ទាំងសងខាងនោះ, រីស្រីដែលស្អាងនោះ ជូតទឹកមាត់នឹងផ្កានីលុប្បលចោលទៅដល់លើផ្លូវ អ្នកប្រមឹកស្រារើសទៅលាងទឹកយកទៅសៀតត្រចៀកអាត្មា ហើយដើរទៅកាន់រោងស្រានោះបោង ៗ រីអាចារ្យសេនកនាំឧទាហរណ៍មកអធិប្បាយនិយាយនូវប្រការអម្បាលនេះហើយ ទូលព្រះ

មហាក្សត្រថា បពិត្រក្សត្រថ្លៃប្រសើរអើយ ! រីគោវិន្ទសេដ្ឋីនោះ គាត់មានប្រាជ្ញាអ្វី គាត់ជាអ្នកកំឡៅទេហ៎ះ ហេតុតែមានសម្បត្តិ ទើបគាត់មានអ្នកផងមកចាំបំរើជាបរិវារ ហេតុនោះខ្ញុំថា អ្នកដ៏ប្រកបនូវសិរីសម្បត្តិនោះប្រសើរ ។

ស្តេចស្តាប់ពាក្យអាចារ្យសេនកទូលដូច្នោះហើយ មានព្រះបន្ទូលទៅនឹងពោធិសត្វថា កឹំ ធិ សិ តាត មហោសធ បណ្ឌិត ហៃមហោសថអ្នកប្រាជ្ញអើយ បានឹងឆ្លើយម្តេចទៅ ? រីឯមហោសថអ្នកប្រាជ្ញទូលព្រះមហាក្សត្រថា ទេវៈ បពិត្រព្រះមហារាជអើយ ! រីអាចារ្យសេនកនេះ គាត់ដឹងអ្វីព្រះអង្គ; ឧបមាដូចក្អែកក្អែករកចាយគេ ឬហាក់ដូចក្តៃស្រែករកអាហារមិនយល់ មហាមុគ្គរំ គឺដំបងដ៏ធំត្រូវត្រង់ក្បាលនោះឡើយ, បពិត្រអម្ចាស់ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ខ្ញុំនឹងឆ្លើយថ្វាយ ទើបពោធិសត្វសូត្រជាបទព្រះគាថា ដូច្នេះថា :

លទ្ធា សុខ មជ្ជតិ អប្បបញ្ញោ
ទុក្ខេន ផុដ្ឋោបិ បមោហមេតិ
អាគន្តុនា សុខទុក្ខេន ផុដ្ឋោ
សោ វេធតិ វារិចរោវ ឃម្មេ
ឯតម្បិ និស្សាយ អហំ វទាមិ
បញ្ញាវ សេយ្យោ ន យសស្សិ ពាលោតិ ។

បពិត្រមហារាជអើយ ! រីអ្នកឥតប្រាជ្ញា មានសក្តិយសសិរីពិធសម្បត្តិភ្លេចស្មារតី ហើយធ្វើបាបអោយនូវខ្លួនឯង កាលណាទុក្ខមកដល់ខ្លួនហើយ ក៏នឹកញ័ររំប្រប់ ឧបមាដូចត្រីលើកឡើងអំពីទឹកបោលទៅត្រូវកំដៅថ្ងៃ មានប្រការម្តេចមិញ, ហេតុនោះ ខ្ញុំយល់ហើយខ្ញុំថា អ្នកមានប្រាជ្ញានោះប្រសើរ, រីអ្នកកំឡៅអន្ធពាល ហើយមានយសបរិវារនោះពុំប្រសើរឡើយ ។

ស្តេចស្តាប់ហើយ មានព្រះបន្ទូលទៅអាចារ្យសេនកថា ហៃអាចារ្យសេនកអើយ ! អ្នកនឹងឆ្លើយម្តេចទៅ ? រីអាចារ្យសេនកទូលថា បពិត្រមហារាជអើយ ! រីមហោសថនោះនឹងដឹងអ្វីព្រះអង្គ, រីមនុស្សផងខ្ញុំមិនស្រដី នៅបំរើអ្នកធំសំរិទ្ធិបានសម្បត្តិ មានទ្រព្យច្រើន ហេតុឧបមាបទប្រាជ្ញា ប្រយោជន៍ ដូចឈើមានផ្លែពិសាជា ហើយមានសត្វបក្សីបក្សាគណនា ក៏ទោមរោមពិភក្តិរក្សានោះហោង; រីឈើនោះ គឺមានប្រាជ្ញាអ្វី, ហេតុតែមានផ្លែពិសា ឧបមាដូចមានសម្បត្តិ, ហេតុនោះខ្ញុំយល់ហើយខ្ញុំថា អ្នកមានប្រាជ្ញាឥតសម្បត្តិពុំប្រសើរឡើយ, រីអ្នកកំឡៅមានសម្បត្តិនោះប្រសើរ ។

(នៅមានត)

# ផ្នែកអក្សរសាស្ត្រ

## វប្បធម៌ខ្មែរ

# សារៈសំខាន់នៃបណ្ណាល័យ

លោក លី · ធាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

ក្នុងទស្សនាវដ្ដីយើងលេខមុន ខ្ញុំបានលើកយកសារៈប្រយោជន៍ នៃសារមន្ទីរមកអធិប្បាយយ៉ាងហូរហែ ដើម្បីជួយទាញសតិអារម្មណ៍របស់ជនរួមជាតិយើង ឲ្យចាប់ក្ដីកនឹកដល់គ្រឹះស្ថានដ៏សក្ដិសមនេះ កុំឲ្យមានចិត្តគិតទុកដាក់ថាទីជាទីស្មសានឡើយ ៗ តទៅនេះ ខ្ញុំសូមលើកយកសារៈសំខាន់នៃបណ្ណាល័យមកអធិប្បាយម្ដង ព្រោះជនជាតិយើងភាគច្រើននៅពុំទាន់យកចិត្តទុកដាក់ខាងមន្ទីរនេះនៅឡើយ ៗ ជាភស្ដុតាងនៅក្នុងបណ្ណាល័យនីមួយៗ ពុំសូវឃើញមានអ្នកអានចេញចូលញឹកញាប់ទេ ច្រើនតែឃើញនៅស្ងាត់ជ្រងំ មានអ្នកខ្លះដល់ទៅមិនទាំងដឹងថាទីនេះគេធ្វើអ្វី មានប្រយោជន៍អ្វីផង ៗ

សព្វថ្ងៃនៅរាជធានីយើង មានបណ្ណាល័យធំ ៗ ពីរ ដែលជារបស់រាជការគឺ: បណ្ណាល័យជាតិ និងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ៗ បណ្ណា-ល័យទាំងពីរនេះ មានសៀវភៅនិងក្បួនខ្នាតក្រាំងសាស្ត្រា ទាំងភាសា

ជាតិ ទាំងភាសាបរទេស ជាច្រើនមុឺនក្បាលដំកល់នៅក្នុងទូធំៗ ៗ ប៉ុន្តែ មានអ្នកចេញចូលអាន, ខ្ចីយកទៅអាន មានចំនួនស្តួចស្តើងណាស់ ហើយបើមានខ្លះក៏គគេច្រើន ច្រើនតែជាផនបរទេសថែមទៀត ៗ ត្រង់នេះ ក៏ជាភស្តុតាងមួយទៀត បង្ហាញឲ្យឃើញថាជាតិយើងពុំទាន់យកចិត្តទុក ដាក់នឹងបណ្ណាល័យនៅឡើយ ៗ តែទោះបីយ៉ាងនេះក៏ដោយ រាជរដ្ឋាភិ-បាលយើងក្រោមព្រះកិច្ចដឹកនាំយ៉ាងក្លៀវក្លា នៃសម្តេចព្រះប្រមុខរដ្ឋបិតា ឯករាជ្យជាតិរមែងខិតខំកសាងបណ្ណាល័យនេះ ឲ្យកាន់តែមានច្រើនឡើង ទៀត ដូចបង្កើតឲ្យមាននៅតាមក្រុមផ្សេងៗ ដើម្បីជាប្រយោជន៍ដល់ ការស្រាវជ្រាវរបស់ក្រុមទាំងនោះ ទីងកសាងបានជាបណ្ណាល័យយ៉ាង ទំនើបមួយ នៅក្រុងកំពង់ចាម ៗ

បើយើងឃើញដូចនេះ យើងល្បងពិចារណាបន្តិចទៅមើល ថាតើ ហេតុអ្វីបានជារាជរដ្ឋាភិបាលខិតខំយ៉ាងហ្នឹង ៗ មិនមែនជាការអាថ៌កំ-បាំងសោះ បើយើងទោលភ្នែកក្រឡេកទៅមើលអារ្យប្រទេសនានា ជា ពិសេសគឺប្រទេសដែលទើបតែកសាងឯករាជ្យថ្មីៗ ដូចប្រទេសយើងដែរ ៗ យើងឃើញថាមន្ទីរនេះ ហុចផលប្រយោជន៍ឲ្យដល់អ្នកស្រុកសន្ធឹកណាស់ ហើយជាការអប់រំមួយយ៉ាងស្ងប់ស្ងាត់ ហើយជ្រួតជ្រាបបានផលជាបំផុតៗ ព្រោះថា មនុស្សនឹងមានបញ្ញាស្មារតីឡើង ដើម្បីឲ្យបានជាពលរដ្ឋវិសេស បាន អាស្រ័យតែមានចំណេះវិជ្ជាក្លៀវក្លា ពោលគឺជម្រះឲ្យអស់នូវអវិជ្ជា

ងងឹតងងល់អំពីសន្តានចិត្ត ៗ បើពុំដូច្នោះទេ តើនឹងអាចគិតគូរអ្វីឲ្យជ្រះស្រឡះសមបំណងបាន ? ៗ យើងដឹងទៀតថា ការបណ្ដុះនិស្ស័យចំពោះកុមារ-កុមារី ត្រូវមានមាតាបិតាគ្រូបាធ្យាយជាអ្នកណែនាំ ! ចុះបើមនុស្សចាស់វិញ ហួសអាយុ ហួសវ័យពីការប្រៀនប្រដៅរបស់មាតាបិតាគ្រូអាចារ្យហើយ តើមានអ្វីជាអ្នកដឹកនាំខ្លួនប្រាណទៀត ? គឺមានតែសៀវភៅគម្ពីរដីកាក្បួនខ្នាតនានានេះឯង ជាគ្រូបាអាចារ្យរបស់យើង ៗ ឯក្បួនខ្នាតទាំងនោះ ពុំអាចមានគ្រប់គ្រាន់ផ្ទាល់ខ្លួនម្នាក់ ៗ ទេ ហេតុនេះគឺមានតែបណ្ណាល័យហ្នឹងហើយ ជាអ្នករក្សានិងផ្គត់ផ្គង់ក្បួនខ្នាតទាំងនេះឲ្យដល់យើង ៗ បានសេចក្ដីថា មានតែបណ្ណាល័យនេះហើយ ជាអ្នកដុះខាត់សតិបញ្ញាយើងឲ្យភ្លឺថ្លាគ្រប់មុខវិជ្ជា គ្រប់កិច្ចការទាំងពួង ៗ ចំពោះក្បួនខ្នាតដែលជាប្រភពនៃអារ្យធម៌របស់ជាតិវិញ ក៏មានតែទីនេះឯង ជាអ្នករក្សាឃុំគ្រងទុកឲ្យបានយូរយារពេលទៅមុខបាន ៗ ប្រសិនជាពលរដ្ឋនិយមរៀសគិតរកក្បួនខ្នាតកំដរខ្លួន គ្រាន់នឹងបង្កើនវិជ្ជាក្នុងខ្លួនរៀងពល់អាត្មា នោះប្រទេសក៏ពិតជាបានសម្បូណ៌ដោយអ្នកមានប្រាជ្ញាវាងវៃពួកដៃគ្នាដើរតាមផ្លូវត្រូវ ឆ្ពោះទៅកាន់វឌ្ឍនធម៌បានយ៉ាងរួសរាន់ ៗ

អាស្រ័យហេតុទាំងនេះហើយ បានជាប្រទេសផងទាំងឡាយ គេតែងទុកបណ្ណាល័យជាឃ្លាំងវិជ្ជា ជាជម្រុកចំណេះប្រាជ្ញាសំរាប់បណ្ដុះជនពល់គ្នា ដែលគេធ្លៀតពេលរៀយ ១ ទៅសំងំអានឬកត់ត្រាគោលគំនិត ឬ

វិជ្ជាណាដែលគេនៅងឿងឆ្ងល់ រហូតដល់ទៅទុកបណ្ណាល័យជាការចាំបាច់របស់ជីវភាពគេ គឺថាឲ្យតែមានភូមិនៅត្រង់ទីណា គេតែងតែបង្កើតឲ្យមានបណ្ណាល័យនៅទីនោះ ៗ ចំណែករាជរដ្ឋាភិបាលយើង ដោយយល់ច្បាស់នូវសារៈសំខាន់នៃបណ្ណាល័យដូច្នេះហើយ បានជាសព្វថ្ងៃតែងតែប្រឹងប្រែងកសាងមន្ទីរនោះ ឲ្យមាននៅគ្រប់ខេត្ត ក្នុងព្រះរាជ-អាណាចក្រ និងជួយឧបត្ថម្ភកន្លែងដែលមានស្រាប់ ឲ្យរឹងរឹតតែបានធំទូលាយឡើង ៗ

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Déluge | *n. m.* | ភ្លៀងរំលា |
| Orage | *n. m.* | ព្យុះភ្លៀង |
| Tempête | *n. f.* | ព្យុះសមុទ្រ |
| Typhon | *n. m.* | ព្យុះសង្ឃរា |
| Embrun | *n. m.* | មេឃអ័ព្ទ |
| Bourrasque | *n. f.* | ពលវាត |
| Ouragan | *n. m.* | វេគវាត |
| Brouillard | *n. m.* | អ័ព្ទ |
| Crachin | *n. m.* | រលឹមរុយ ៗ; រលឹមរោយ ៗ |
| Brume | *n. f.* | អ័ព្ទងងឹត |
| Cyclone | *n. m.* | ខ្យល់កំបុតត្បូង |
| Trombe | *n. f.* | ខ្យល់កួចទឹក |
| Aseptique | *n. et a.* | អបូតិករ |
| Septique | *n. et a.* | បូតិករ |
| Plâtre | *n. m.* | សម្រោបម្នាងសិលា |
| Réanimation | *n. f.* | ប្រពោធនកម្ម |
| Stérilisation | *n. f.* | និទ្ទោសកម្ម, វិញ្ញនកម្ម |
| Magasin stérile | | ឃ្លាំងនិទ្ទោស, ភណ្ឌាគារវិញ្ញ |
| Approvisionnement | *n. m.* | សំវិធានការ, ការបំរុងទុក |
| Pansement | *n. m.* | វណវេឋន៍ |
| Brossage | *n. m.* | ការជម្រះ |
| Médecin-résident | | គ្រូពេទ្យប្រចាំទី |

(នៅមានទៀត)

# វចនានុក្រមសំស្រ្កឹត.ខ្មែរ

*ព្រះមហា ប៉ាង - ខាត់ រៀបរៀង*

(តមក)

អតិប្រៀលយៅវន គុ. ដែលនៅកំពុងពេញពាល ។

អតិពន្ធុរ គុ. ដែលងក្រៃពេក, ដែលវិលវល់ក្រៃលែង ។

អតិពល អតិពលវន្ត, អតិពលិន, គុ. អតិពល, ដែលមាន
កម្លាំងក្រៃពេក, ដែលមានពលក្រៃពេក ។ *អតិពលា*,
ស្ត្រី. ឈ្មោះមន្តមាយាកា; ឈ្មោះបុត្រីនៃទក្ស ។ *អតិពលាក្រាន្ត*
គុ. ដែលធ្វើដោយកម្លាំង ក្រៃលែង ។

អតិពហុ គុ. ដែលច្រើនក្រៃពេក ។

អតិពាធិ ឆាគុ. បៀតបៀនក្រៃពេក ។

អតិពាប គុ. ដែលពាបក្រៃពេក ។

អតិពីភត្ស អតិពិភត្សិត គុ. ដែលខ្ពើមរអើមក្រៃលែង (រស) ។
ប៉ុ. កិរិយាខ្ពើមក្រៃលែង ។

អតិព្រុហិត គុ. ដែលធំក្រៃលែង ។

អតិពោធិសត្វ គុ. ដែលជាពោធិសត្វក្រៃលែង ។ ប៉ុ ពោធិសត្វ
ក្រៃលែង ។

អតិព្រូ ឆាគុ. ពោលក្រៃលែង, ដេរ, ប្រទេច ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៤

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ |
| អ្នកវាងវៃឆ្លាសបើបានអាន |
| នឹងបេះឧបាយកលបំណាន |
| ទាំងមានសន្តានស្នេហាជាតិ ។ |

ជីវយីត្រូវដូច្នោះក៏ប្រឹក្សានឹងទាហានទាំងពួងថា អស់អ្នកយល់ឃើញដូចម្តេច? ទាំងអស់គ្នាក៏ឆ្លើយថា ដែលឡោសុកឆ្លើយជំរាបលោកនោះត្រូវហើយ ជីវយីក៏ព្រមឲ្យឡោសុកទៅ ។

ឡោសុកក៏លាជីវយី នាំទាហានប្រហែល ១០ នាក់ ទៅឯស្រុកឡាំកុនជួបនឹងជូឡុង, ឡោសុកថា អ្នកចូលទៅជំរាបឡៅពីថា ខ្ញុំមានការមកជួប ជូឡុងថា ឥឡូវឡៅពីនឹងខុងបេងនាំគ្នាទៅនៅស្រុកកេងជីវហើយ ឡោសុកក៏នាំទាហានស្រូតទៅឯស្រុកកេងជីវ ឃើញទង់ជោតនៅលើសើនបន្ទាយជុំវិញ ឡោសុកក៏នឹកថា ជម្រះប្រាជ្ញាខុងបេងនេះជ្រៅឆ្ងាយណាស់កម្រនឹងដឹងបាន ហើយក៏ប្រាប់នាយទ្វារថា យើងត្រូវការ

ចូលទៅជួបនឹងឡៅពីនាយទ្វារ រួចក៏ចូលទៅដំកបតាមដំណើរ ខុងបេងឲ្យបើកទ្វារទទួលឡៅស៊ុកចូលទៅជួបនឹងខុងបេង ។ ក៏អញ្ជើញឲ្យទៅអង្គុយក្នុងទីដ៏សមគួរ តែឡៅពីនោះ ខុងបេងឲ្យនៅខាងក្នុង ឡៅស៊ុកគំនាប់ខុងបេងហើយថា ដែលបូជូលើកពលទាហានប្រហែល ១០០ មុឺនមកនោះ មិនមែននឹងប៉ងធ្វើអន្តរាយបំពោះតែស្រុកកាំងតាំងប៉ុណ្ណោះក៏ទេ បូជូគិតប្រាថ្នានឹងចាប់យកខ្លួនឡៅពីជាតួដើមហេតុ វេលានោះស៊ុនគួននឹងជីវយីក៏មានចិត្តអាណិតឡៅពី ទើបច្រកក្បាគ្នាយល់ព្រមឲ្យជីវយីលើកកងទ័ពចេញមកតទល់នឹងបូជូ ប្រាថ្នានឹងជួយឡៅពីឲ្យរួចពីសេចក្តីស្លាប់ ទាំងនឹងបានការពាររក្សាស្រុកកាំងតាំងផង ដែលស៊ុនគួន-ជីវយីធ្វើការសង្គ្រាមគ្រានេះ លោកក៏ល្មមជ្រាបយល់ហើយ គឺថាការដែលធ្វើនោះបានខាតបង់របស់ទ្រព្យសព្វសារពើគ្រប់មុខជាច្រើនណាស់ លុះចោយិន, ទោហាងបែកទ័ពទៅទៀត ស្រាប់តែលោកនឹងឡៅពីមកជ្រែកដណ្តើមយកស្រុកកេងជីវ, ស្រុកស៊ុងយ៉ុង, ស្រុកឡាំកុនដោយស្រួលទទេដូច្នេះ មិនសមគួរសោះ ខ្ញុំយល់ឃើញថាខុសនឹងប្រវេណី ទើបមកដំកបដើម្បីជាផ្លូវតឿនរំលឹកស្មារតីឲ្យលោកយល់ ។

ខុងបេងតបថា ខ្លួនអ្នកជាមនុស្សមានជម្រះប្រាជ្ញា គួរឬ ? មកនិយាយដូច្នេះ ឯស្រុក ៣ ដំបន់នេះ បើស្រុករបស់បូជូ ខ្ញុំក៏នឹងលើកទៅឲ្យស៊ុនគួនតែម្តង មិនបាច់ចាំអ្នកមកតឿនក្រើនដូច្នេះទេ តែថាគឺ

ស្រុកទាំង៣នេះ ជារបស់ឡៅពៀវអ្នកក៏ដឹងយល់ស្រាប់ថា ឡៅពៀវនឹងឡៅពីជាសាច់សាលោហិតនឹងគ្នា ទោះបីឡៅពៀវស្លាប់ទៅហើយក្តី ក៏មានឡៅគីជាបុត្រារស់នៅត្រូវតែទទួលមត៌ក បានជាខ្ញុំនឹងឡៅពីចំស្រុកមកជ្រែកយកស្រុកទាំង ៣ ដំបន់នេះ ទុកប្រយោជន៍ឲ្យឡៅគីតាមប្រវេណីពីបុរាណ ដែលអ្នកមកថាខ្ញុំធ្វើខុសនោះមិនបាន ឡោស៊ុកថា ស្រុកទាំង ៣ នេះ ជារបស់ឡៅពៀវក៏មែនហើយ តែថាឡៅគីជាបុត្រទៅឈរនៅឯស្រុកតាំងហៃ នឹងបានមកនៅស្រុកទាំងនេះក៏ទេ ហេតុម្តេចបានជា
៧ លោកថាយកទុកឲ្យឡៅគីទៀត ខុងបេងថា អ្នកនឹងចង់ឃើញឡៅគីឬ? ឥឡូវឡៅគីឈឺហើយ ក៏ឲ្យមនុស្សគ្រាហ៍ឡៅគីចេញមក ឡៅគីក៏និយាយនឹងឡោស៊ុកថា ខ្ញុំសូម[illegible] ព្រោះខ្ញុំឈឺនឹងទៅគំនាប់គួរសមនឹងលោកមិនកើត ហើយក៏ឲ្យគ្រាហ៍ចូលទៅក្នុងវិញ ឡោស៊ុកក៏និយាយនឹងខុងបេងថា ដែលលោកបានប្រកាសន៍មកមុននោះក៏ត្រូវហើយ តែបើឡៅគីមានអាយុសោះ[illegible] ក៏គួរបានស្រុកទាំងនេះជាជំនួសបិតា ចុះបើសិនណាឡៅគីស្លាប់ទៅវិញ លោកនឹងថាដូចម្តេច ខុងបេងថា បើសំណាងបុណ្យឡៅគីរស់នៅបានតែ ១ ថ្ងៃ ២ ថ្ងៃក្តី ខ្ញុំក៏ត្រូវតែជួយទំនុកបំរុងតាមការ បើអស់បុណ្យវាសនាឡៅគីទៅហើយ សឹមគិតតទៅទៀត ។

ឡោស៊ុកក៏ថែមសួរបញ្ជាក់បញ្ជាក់ដោយចង់ដឹងច្បាស់ថា បើឡៅគី

អស់បុណ្យទៅហើយ លោកនឹងបន្ទិលស្រុកដំបន់នេះឲ្យស៊ីនគួនឬ? ខុនបេងក៏ទទួលពាក្យបែបបន្ទិថាល្អហើយ ៗ ក៏អញ្ជើញឡេសុកឲ្យបរិភោគអាហារផឹកស្រាជាមួយគ្នា ឡេសុកលុះបរិភោគរួចហើយក៏លាខុនបេងត្រឡប់ទៅដល់បន្ទាយវិញ ហើយយកសេចក្ដីទៅជំរាបដីវយីស្ដាប់គ្រប់ប្រការ ដីវយីឮដូច្នោះក៏និយាយថា ឡេគីនោះនៅក្មេងនៅឡើយ កាលណានឹងដល់នូវសេចក្ដីស្លាប់ឆាប់ ហេតុម្ដេចអ្នកទៅប្រញាប់សន្យាដូច្នេះ ឡេសុកតបថា ឯខ្លួនឡេគីនោះក៏ឈឺធ្ងន់ណាស់ទៅហើយ សេចក្ដីនេះខ្ញុំសុំកុំឲ្យលោកព្រួយចាំខ្ញុំ គិតយកស្រុកទាំង ៣ ដំបន់នេះ មកឡើងស្រុកកាំងតាំងឲ្យបាន ដីវយីថា អ្នកគិតឃើញយ៉ាងម្ដេច បានជាថាដូច្នេះ ឡេសុកតបថា ឡេគីនោះនៅក្មេងក៏មែន តែចូលចិត្តផឹកស្រាលេងស្រី ដែលបង្កើតកេតឈឺនោះព្រោះទោសទាំង ២ ប្រការនេះ ខ្ញុំយល់ឃើញថា អាយុឡេគីមិនយឺនទៅមុខដល់កន្លះឆ្នាំឡើយ បើស្លាប់កាលណាហើយ ខ្ញុំនឹងទៅទារយកស្រុកទាំង ៣ ដំបន់នេះឲ្យបានវិញ ។

ខណៈនោះមានបំរើសេះ កាន់សំបុត្រស៊ីនគួនមកឲ្យដីវយីសេចក្ដីថា ស៊ីនគួនលើកទ័ពទៅធ្វើសង្គ្រាមឯស្រុកហ័បប៉ា បានគតាំងច្បាំងនឹងទៀវលៀវតាហានច្បូនៅមិនទាន់ចាញ់ឈ្នះ ឲ្យដីវយីរៀបកតាហានលើកទៅជួយនឹងបាន.ធ្វើការតទៅ ដីវយីដឹងដូច្នោះ ក៏ចាត់ចែងបែងតាហានឲ្យទៀកៅជានាយកងលើកទៅជួយស៊ីនគួន ឯដីវយីក៏នៅដេកឈឺ ទើបលើក

កងទ័ព ត្រឡប់ទៅស្រុកឆសេងកុនងាត់កំពង់ស្រុកកាំងតាំង ។

ឯឡៅពីកាលបានស្រុក ៣ ដំបន់ហើយ ក៏តាំងចិត្តគិតបំរុងរក្សាអាណាប្រជានុរាស្ត្រឲ្យបានសេចក្តីសុខ លុះនៅមក ថ្ងៃ ១ ឡៅពីក៏ប្រឹក្សានឹងខុងបេងនូវអស់ទាហានទាំងពួងថា យើងនឹងរិះគិតប្រការម្តេច ទើបនឹងរក្សាស្រុកកេងជីវទុកបាន, ហើយនឹងបានគិតការទំនុកបំរុងផែនដីតទៅ ខុងបេងនឹងទាហានទាំងពួងនៅមិនទាន់ឆ្លើយថាប្រការម្តេច អ៊ុំជៀឆ្លើយថា ខ្ញុំបាទសូមជំរាបលោក ១, ឡៅពីឮដូច្នោះក៏មានអំណរណាស់ ដោយគិតដល់គុណអ៊ុំជៀដែលបានប្រាប់ហេតុ កាលនៅស្រុកសុងយុងនោះ ឡៅពីក៏ចាប់ដៃអ៊ុំជៀឲ្យឡើងទៅអង្គុយថ្នាក់ខាងលើហើយ សួរថាអ្នកនឹងប្រាប់ ខសេចក្តីអ្វីដល់យើងក៏ឲ្យថាទៅចុះ អ៊ុំជៀឆ្លើយថា ខ្ញុំបាទដឹងថាក្នុងដែនស្រុកកេងជីវនេះមានសែម៉ានៅ ៤ នាក់ជាបងប្អូននឹងគ្នា ឯម៉ាបេកជាប្អូននោះ មានចូដៃខ្លាំងពូកែណាស់ តែម៉ាលៀងជាបងមិនសូវខ្លាំងពូកែទេ តែមានជម្រះប្រាជ្ញាជ្រាលជ្រៅពន់ពេក បើលោកយកបានមកទុកជាទីប្រឹក្សានឹងទាហាននឹងបានជួយជាកំឡាំងមាំមួនឡើងទៀត ឡៅពីឮដូច្នោះក៏ត្រេកអរណាស់ ទើបប្រើទាហានទៅហៅម៉ាលៀងមកជួប ហើយឲ្យអង្គុយទីសមគួរ ក៏គំនាប់គ្នាទៅវិញទៅមក ឡៅពីនិយាយថា ផែនដីសព្វថ្ងៃនេះកើតកែវវេចលាចលៈផ្សេងៗ យើងគិតនឹងទំនុកបំរុងឲ្យបានសេចក្តីសុខរាស្ត្រ បានជាជូលមកនៅក្នុងស្រុកកេងជីវនេះ ប្រាជ្ញានឹង

វិះគិតការតទៅ  តែយើងនៅព្រួយចិត្តដ្បិតនឹងគិតការពារប្រការម្ដេច ទើបនឹងបានឲ្យអាណាប្រជាពន្ធុរាស្ត្របានសេចក្ដីសុខ  ម៉ាលៀងឆ្លើយថា ឯកេងជីវនេះជាមុខសឹកសង្គ្រាមគ្រប់ទាំង ៤ ទិស  កម្រដែលនឹងគិតការ ពាររក្សាឲ្យបានស្រួល  គួរលោកតាំងឡៅគីឲ្យធ្វើចៅហ្វាយស្រុកកេងជីវ ជាបណ្ដោះអាសន្ន  ហើយពន្យល់ឲ្យទៅបញ្ចុះបញ្ចូលមនុស្សខ្ញុំរាជការ ចាស់របស់ឡៅពៀវឲ្យចូលមកប្រមូលគ្នាជាសេនាទាហានឲ្យច្រើន  ទើប ពស្ត្រទាសទាំងពួងនឹងបាននៅជាសុខតាមប្រក្រតី  ព្រោះឃើញថាឡៅគី ជាចៅហ្វាយស្រុកកេងជីវស្រាប់ហើយ  ទើបឲ្យវាត់កងទ័ពទៅវាយយក ស្រុកខាងទិសទក្សិណដែលឡើងដល់ស្រុកកេងជីវនេះ  គឺស្រុកប៉ុឡេង, ស្រុកទៀងសា, ស្រុកហ៊ុយអៀង, ស្រុកឡេងឡេង, ទាំង ៤ ដំបន់នេះ សឹងប្រកបដោយមាសប្រាក់  នឹងស្រូវអង្ករចំណីត្រីសាច់បរិបូណ៌ណាស់ បើបានហើយនឹងជួយជាកំឡាំងតទៅ ។

ឡៅតីក៏សួរថា  អ្នកនឹងឲ្យយើងទៅវាយយកស្រុកណាជាមុន  ម៉ាលៀងឆ្លើយថា សុំឲ្យរៀបកងទ័ពលើកទៅវាយយកស្រុកឡេងឡេងជាមុន ព្រោះជាដើមផ្លូវ  ហើយទើបវាយយកស្រុកប៉ុឡេងជាបន្ទាប់  ឯស្រុកទៀងសា នឹងស្រុកហ៊ុយអៀងនោះនៅខាងទិសឯលិច  ឲ្យលើកទៅវាយជាក្រោយក៏បាន  ឡៅតីយល់ឃើញផង  ទើបតាំងឲ្យម៉ាលៀងជាទីប្រឹក្សា ឲ្យឡៅគីជាចៅហ្វាយស្រុកកេងជីវ  តែឲ្យទៅនៅស្រុកសុងយ៉ុង  នឹងបាន

បញ្ចុះបញ្ចូលមនុស្សឡៅពៀវទុកជាកំឡាំង ហើយឡៅពីក៏ប្រឹក្សានឹងខុនបេង នូវអស់ទាហានទាំងពួងតាមពាក្យម៉ាលៀង ខុនបេងក៏យល់ត្រូវផង ឡៅពីក៏ឲ្យហៅគួនរ៉ូមកពីស្រុកសុងយ៉ុង ឲ្យមកនៅរក្សាស្រុកកេងជីវ ហើយឡៅពីក៏ប្រមូលទាហានបាន ១ ម៉ឺន ៥ ពាន់ ឲ្យទៀវហ៊ុយជាកងមុខ ខ្លួនឡៅពីនឹងខុនបេងជាកងល្វង ជូឡុងជាកងក្រោយ ហើយក៏លើកទ័ពទៅតាំងនៅជិតស្រុកឡេងឡេង ។

ឯឡៅតៅបៅ ហ្វាយស្រុកឡេងឡេង លុះដឹងថាឡៅពីលើកកងទ័ពមក ក៏ប្រឹក្សានឹងឡៅហៀនជាបុត្រថា ឡៅពីលើកកងទ័ពមកនឹងច្បាំងយកស្រុកយើង តើនឹងរិះគិតប្រការម្ដេច ? ឡៅហៀនឆ្លើយថា ពុល្បី, គេនិយាយថា ឡៅពីមានទាហានឯកឈ្មោះទៀវជូឡុងមានថ្វីដៃខ្លាំងពូកែណាស់ តែកូនទាហានមានតិច ឯស្រុកយើងនេះតុះអេងក៏ជាទាហានឯក ស៊ូនឹងពលបាន ១ ម៉ឺន នឹងខ្លាចអ្វីដល់ឡៅពីនោះ ខ្ញុំបាទនឹងសុំយកការសារនេញទៅកយឲ្យបែកទាល់តែបាន ។

ឡៅតៅបានឮដូច្នោះក៏ពេញចិត្ត ទើបចាត់ទាហានឲ្យឡៅហៀន ចំនួន ១ ម៉ឺន ឡៅហៀនក៏លាបិតាឡើងសេះនាំទាហានចេញទៅ ចម្ងាយផ្លូវប្រហែល ១០០ សិន (៤ គី) ទើបឲ្យតាំងបន្ទាយនៅជើងភ្នំ ១ ។ ខុនបេងឃើញកងទ័ពស្រុកឡេងឡេងលើកចេញមក ក៏ឡើងជិះរទេះកាន់ក្ងោកពេបសត្វមានទង់លឿងដោតលើរទេះ ១ ហើយនាំទាហានចេញទៅ

ដល់មុខបន្ទាយ តុះអេងឃើញដូច្នោះក៏ឡើងសេះកាន់ពូថៅធំលើកទាហាន ចេញមកហើយស្រែកថា អាពួកចោរ ហេតុម្តេចបានជាហ៊ានលើកទ័ព កន្លងចូលមកក្នុងដែនស្រុករបស់ចៅហ្វាយអញ ឯងមិនខ្លាចស្លាប់ទេឬ? ខុងបេងឮដូច្នោះក៏ឆ្លើយតបថា ខ្លួនអញឈ្មោះខុងបេងនៅដែនស្រុកឡាំ-យ៉ុង គ្រាដែលចូឆូលើកពល ១០០ ម៉ឺន ជាក្បួនទ័ពគោកទ័ពទឹកមកនឹង វាយយកខែត្រខណ្ឌខាងទិសទក្សិណនេះ អញគិតកលឧបាយតែ ខ ១ ក៏ ដុតកងទ័ពចូឆូបានទាំងទ័ពគោកទ័ពទឹក ដែលចៅហ្វាយអញលើកកង ទ័ពមកនេះ បើឯងព្រមអង្វរលន់តួដោយល្អក៏នឹងរួចជីវិត ។

តុះអេងបានឮដូច្នោះក៏ខឹងណាស់ឆ្លើយថា អញដឹងឯងហើយ ឯងកុំអួត អាងអ្វីឡើយ កាលចូឆូបែកទ័ពទៅនោះ ព្រោះគំនិតរបស់ជីវយ៉េទេ ហើយ បរសេះចូលដេញចូលទៅនឹងចាប់ខ្លួនខុងបេង ។ ក៏ប្រើអ្នកបររទេះឲ្យថយ រទេះត្រឡប់ក្រោយ តុះអេងក៏បរសេះដេញទៅដល់ជើងកំពែង ឃើញ ទង់លឿងដែលដោតលើរទេះនោះ កំបាំងបាត់ទៅក្នុងកៀនភ្នំ ឃើញ ឯទៀវហ៊ុយបរសេះពំលំពែងចេញមកស្រែកថា ខ្លួនអញឈ្មោះទៀវហ៊ុយ ឯងអាចមកតស៊ូនឹងដៃអញឬ? តុះអេងឮដូច្នោះក៏ខឹងណាស់ បរសេះចូល ទៅប្រយុទ្ធនឹងទៀវហ៊ុយមិនបានក៏បំផាយសេះរត់ទៅ ទៀវហ៊ុយក៏ដេញ ជិតតាមពីក្រោយ តុះអេងខំស្រូតៈទៅដល់មាត់ផ្លូវ ទទួលឮសំឡេងស្រែក ហោអឺងកងឡើង ហើយឃើញទាហានសន្ធាំងផ្លូវចេញមកស្កាត់ពីមុខ

ផ្ទុងស្រែកថា អញឈ្មោះផ្ទុង មកចាំយកជីវិតឯងហើយ ៗ ក៏ដេញទាហានឲ្យព័ទ្ធឡោមជុំវិញ គុះអេងទាល់ច្រកនឹងរកផ្លូវចៀសទៅមិនរួច ក៏ចោលតួថៅចុះពីដៃ ហើយភេកចុះពីលើខ្នងសេះបួលមកគំនាប់ផ្ទុង ៗ ក៏ឲ្យទាហានចងគុះអេងជាប់ ហើយនាំយកខ្លួនទៅជូនឡៅពីក្នុងបន្ទាយ ឡៅពីក៏បង្គាប់ឲ្យយកខ្លួនគុះអេងទៅសម្លាប់ចេញ ខុងបេងដឹងដូច្នោះក៏ហាមឃាត់ឡៅពីឲ្យបង្អង់ ហើយសួរពិចារណាគុះអេងថា បើខ្លួនអ្នកឯងព្រមនៅនឹងចៅហ្វាយ យើង ៗ នឹងលែងឲ្យរួចខ្លួនទៅវិញ ហើយត្រូវខំរិះគិតយកខ្លួនឡៅហៀនមកឲ្យយើងនឹងបាន ឬ មិនបាន? គុះអេងក៏ថា បើលោកទុកជីវិតខ្ញុំបាទហើយ ខ្ញុំបាទនឹងរិះគិតយក, ខ្លួនឡៅហៀនមកជូនលោកឲ្យទាល់តែបាន បើលោកបានខ្លួនឡៅហៀនក៏ដូចជាខ្លួនឡៅគៅជាបិតាដែរ ៗ

ខុងបេងសួរថា អ្នកឯងនឹងទៅគិតធ្វើប្រការម្ដេចនឹងបានឡៅហៀននោះ? គុះអេងថា ពេលយប់ក្នុងថ្ងៃនេះ ឲ្យលោកលើកកងទ័ពទៅប្លន់បន្ទាយឡៅហៀនចុះ ខ្ញុំបាទនឹងធ្វើជាគលសឹកខាងក្នុង ចាប់យកខ្លួនឡៅហៀនមកជូនលោក ឡៅពីឮដូច្នោះក៏និយាយនឹងគុះអេងថា ពាក្យនេះយើងយល់ឃើញថាមិនមែនទេ គឺអ្នកឯងក្លែងយកតែជីវិតឲ្យរស់ ៗ ខុងបេងថា គុះអេងនេះជាមនុស្សមានពាក្យសត្យពិតត្រង់ណាស់ ល្មមនឹងជឿស្ដាប់បាន ហើយក៏ឲ្យស្រាយចំណងចេញលែងទៅ គុះអេងលុះទៅ

ដល់បន្ទាយក៏ពណ៌នាសេចក្ដីទាំងពួងឲ្យឡៅហៀនស្ដាប់គ្រប់ប្រការ ។

ឡៅហៀនថា យើងនឹងរិះគិតប្រការម្ដេចទើបស្រួល? គុះអេងថា លោកកុំវិតក្កជាទុក្ខព្រួយឡើយ ខ្ញុំបាទនឹងគិតកែវៃឲ្យបាន ក្នុងថ្ងៃនេះ ទាហានឡៅពីនឹងលើកមកតាមពាក្យខ្ញុំបាទនិយាយ យើងត្រូវតែលះបង់ចោលបន្ទាយនេះចេញ ហើយលើកទាហានចេញទៅពួនបង្កប់ខាងក្រៅបន្ទាយជា ២ កង បើឃើញទាហានឡៅពីលើកមកយើងនឹងលើកចេញមកវាយខ្ទប់ទាំងសង្ខាង ឡៅហៀនយល់ឃើញត្រូវ ក៏ឲ្យធ្វើតាមពាក្យគុះអេង លុះវេលាយាម ២ បាយ ឃើញទាហានឡៅពី ១ កងកាន់គប់ចម្បើងគ្រប់ដៃ លបទៅដុតបន្ទាយនេះឡើង ឡៅហៀននឹងគុះអេងក៏លើកទាហានវាយខ្ទប់ទាំងសង្ខាងចូលមក ពួកទាហានឡៅពីក៏លបរត់ទៅ ឡៅហៀននឹងគុះអេងតាមទៅមិនទាន់ក៏វិលត្រឡប់មកជិតដល់បន្ទាយវិញ ភ្លើងនោះក៏ឆេះភ្លឺខ្លាំងឡើង ក្រឡេកមើលទៅឃើញទៀវហ៊ុយជិះសេះមកឈរស្កាត់ពីមុខ ។

ឡៅហៀនក៏និយាយនឹងគុះអេងថា ឡៅពីលើកទ័ពមកលុកបន្ទាយយើង តែទាហានដែលនៅក្នុងបន្ទាយឡៅពីនោះស្ទួចស្ដើងណាស់ បើយើងនឹងលើកទៅប្លន់យកបន្ទាយឡៅពីវិញក៏នឹងបានដោយងាយ គុះអេងយល់ឃើញត្រូវ ក៏លើកទៅប្លន់យកបន្ទាយឡៅពី លុះលើកទៅដល់ពាក់កណ្ដាលផ្លូវ ក៏ប្រទះនឹងជូឡុងលើកទាហានមកស្កាត់ពីមុខ ជូឡុង

ក៏បរសេះពុះទំលាយយកកងទ័ពសម្លាប់ទាហានទន្ទ្រានចូលទៅ ហើយ
យកលំពែងចាក់ត្រូវគុះអេងធ្លាក់ពីលើសេះស្លាប់ ឡេវហៀនឃើញដូច្នោះ
ក៏តក់ស្លុតក្នុងចិត្តបំផាយសេះតេ់ទៅជួបនឹងទៀវហ៊ុយ ។ ចូលច្បាំងហើយ
ក៏ព័ទ្ធចាប់ឡេវហៀនបាន ចងយកខ្លួនទៅឲ្យខុងបេង ខុងបេងក៏ពិចារ-
ណាសួរឡេវហៀនថា យើងចាប់គុះអេងបាន ហើយ យើងដោះលែង
ទៅវិញ ក៏ត្រឡប់គិតប្រទូសរ៉ាយបញ្ឆោតយើងដោយអំពើទុច្ចរិត ឡេវ
ហៀនថា ដែលគុះអេងធ្វើការបញ្ឆោតលោកនោះ ជាគម្រិះរិះគិតរបស់
គុះអេងខ្លួនឯង ។ ខុងបេងក៏ឲ្យស្រាយចំណងឡេវហៀនចេញ ហើយ
យកអាវព្រៃយ៉ាងល្អឲ្យឡេវហៀនពាក់ រួចហៅឲ្យឡើងគុបរិភោគអា-
ហារ ហើយថា យើងនឹងបើកលែងអ្នកឯងឲ្យទៅទៀត ដើម្បីឲ្យទៅប្រាប់
បិតារបស់អ្នកឯងឲ្យចេញមកលន់តួបំណុះចុះចូលយើង ដោយសុភាពល្អ
បើអ្នកឯងទៅហើយមិននាំបិតាចេញមកទេ យើងនឹងលើកទ័ពចូលទៅ
វាយយកស្រុក ហើយនឹងកាប់សម្លាប់គ្រប់គ្រួសារនូវបណ្ដាញាតិបងប្អូន
ឲ្យអស់កុំឲ្យសល់ ។

(ទៅមានត)

# រឿងមនុស្សពិតប្រែប្រួល

## ឃុងបណ្ឌាគុរក្ស ប៊ូ-ប៉ូ រៀបរៀង

ថ្ងៃមួយ អ្នកកើត នាងរស់ បរិភោគបាយល្ងាចរួច អង្គុយនិយាយគ្នាអំពីរបរចិញ្ចឹមជីវិតរាល់ថ្ងៃ ។ នាងរស់ជាប្រពន្ធរបស់អ្នកកើតជាប្តីថា យើងគិតដូចម្តេចអំពីដីចម្ការយើង ១ ក្បាល នៅឃុំថ្កូ ស្រុកល្វាឯម ខេត្តកណ្តាល យើងដាំពោតខ្លួនឯងទៀត ឬក៏ជួលដីនោះឲ្យគេធ្វើទៅ កន្លងឆ្នាំថ្មីខាងមុខនេះ ? ។

អ្នកកើត- យើងធ្វើដីនោះខ្លួនឯងមិនបានទេ ព្រោះដីនៅឆ្ងាយពីផ្ទះយើងកន្លងឃុំកោះរះនេះផង យើងកាន់តែចាស់ណាស់ហើយ លំបាកដើរទៅដើរមកណាស់ផង ជួលឲ្យគេធ្វើវិញទៅស្រួលជាង ។

នាងរស់- ខ្ញុំគិតឃើញថា កុំជួលឲ្យគេអីវាខាតណាស់ ព្រោះចម្ការនោះខ្លាញ់ ដាំពោតមួយឆ្នាំ ៗ បានផលច្រើន យើងឲ្យ ជីប្រែ ទៅធ្វើម្នាក់វាចុះ ដ្បិតវាឈប់រៀនហើយ គ្រាន់នឹងផ្សេផ្សំប្រាក់ទុករកប្រពន្ធឲ្យវា ដ្បិតវាពេញកម្លោះហើយ ។

អ្នកកើត- ទេ ! អញមិនឲ្យ ជីប្រែ ទៅធ្វើចម្ការទេ ឲ្យវាទៅធ្វើរដ្ឋការឯភ្នំពេញវិញ គ្រាន់បានប្រាក់ខែចិញ្ចឹមប្អូនវាតូចៗ បីនាក់ផង ចិញ្ចឹមយើងចាស់ៗ ធ្វើការលែងកើតផង ។

នាងរស់- បើដូច្នោះ, ស្រេចលើគំនិតគាត់ចុះ ខ្ញុំមិនដឹងទេ តែ

ខ្ញុំយល់ថា ជីប្រែ វាធំហើយ មិនត្រូវបណ្ដោយឲ្យវានៅឆ្ងាយពីខ្លួនទេ ដ្បិតចាស់ទុំលោកថា ចិត្តមនុស្សបុរសគ្រប់រូបតែងតែប្រែប្រួល ម្ដងគិតឃើញយ៉ាងនេះ ម្ដងគិតឃើញយ៉ាងនោះ មិននៅទៀងតែម្យ៉ាងៗទេ ។

អ្នកតាកើត ឯងយល់យ៉ាងនេះគួរហើយ ប៉ុន្តែត្រូវហៅវាមកសួរឲ្យដឹងចិត្តគំនិតវាសិន តើវាចូលចិត្តយ៉ាងណា ។

ឈាងរស់—ហៅ ជីប្រែ មកជិតសួរថា តាំងពីឯងឈប់រៀនមករាង ២ ខែហើយ ឯងមានគំនិតគិតទុកដូចម្ដេចដែរឬទេ ? ។

ជីប្រែ— បាទ ! ខ្ញុំគិតខ្លះដែរ ម៉ែ ! គិតថាខ្ញុំឈប់រៀនហើយត្រូវមកនៅផ្ទះជួយធ្វើចម្ការម៉ែ ។

ឈាងរស់— អើ ! បើឯងចូលចិត្តធ្វើចម្ការក៏ធ្វើចុះ, ប៉ុន្តែ ខ្លួនឯងពេញកម្លោះហើយ ល្មមគិតរកប្រពន្ធ បើឯងពេញចិត្តកូនចៅអ្នកណាប្រាប់ម៉ែចុះ ម៉ែនឹងទៅស៊ើបសួរស្ដីដណ្ដឹងគេទុកឲ្យឯង ។

ជីប្រែ—ម៉ែ! កុំគិតគូពីរឿងប្រពន្ធកូនអី ខ្ញុំមិនព្រមយកប្រពន្ធទេៗ

ឈាងរស់— ម៉េចក៏ឯងថាដូច្នោះ ? កើតមកជាប្រុសត្រូវតែមានប្រពន្ធ កើតមកជាស្រីត្រូវតែមានប្ដី ទើបសមគួរតាមទម្លាប់អ្នកស្រុកដូចពាក្យចាស់ទុំលោកថា ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស ។ បើឯងមិនយកប្រពន្ធទេ ម៉េចក៏ឯងមិនទៅបួសនៅក្នុងវត្តដូចលោកសង្ឃទៅ ។

ដីប្រែ- ទេ ! ខ្ញុំមិនបួសទេ ព្រោះខ្ញុំចង់មកនៅផ្ទះជួយធ្វើបេរម៉ែ ។

ណាងរស់ - បើឯងមិនបួសទេ ត្រូវតែឯងយកប្រពន្ធខានមិនបាន កុំឲ្យខុសពីអ្នកស្រុក ចុះឯងគិតឃើញដូចម្ដេចបានជាមិនព្រមយកប្រពន្ធ ប្រាប់ម្ដាយផង ម្ដាយឆ្ងល់នឹងចិត្តឯងណាស់ ។

ដីប្រែ- ខ្ញុំមិនដែលទុកចិត្តស្និទ្ធស្នាលនឹងស្រីណាទេម៉ែ ! ប៉ុន្តែ កាលខ្ញុំកំពុងរៀនក្នុងសាលានោះ លោកគ្រូនិទានពីរឿងស្រីឲ្យខ្ញុំស្ដាប់ ខ្ញុំក៏ចាប់ខ្លាចស្រីតាំងពីពេលនោះមក គិតថាលែងយកប្រពន្ធមួយជាតិ ។

ណាងរស់ ចុះលោកគ្រូឯងនិទានពីរឿងស្រីថាម៉េចខ្លះ ឯងដំណាលឲ្យម៉ែស្ដាប់ផងមើល ? ។

ដីប្រែ- ម៉ែចាំស្ដាប់ខ្ញុំដំណាលពីរឿងស្រីដែលមានពុតត្បុតចិត្ត មិនស្មោះត្រង់នឹងប្ដី សូម្បីប្ដីស្រឡាញ់ខ្លាំងណាស់ ស្ទើរតែលេបទៅទុកក្នុងពោះហើយ ក៏នៅតែប្រែចិត្តក្បត់ប្ដី ទៅលួចសហាយស្មន់នឹងប្រុសដទៃទៀតដូចជា ៖

## ១– រឿងស្រីក្នុងស្មុគ្រ[1]

កាលពីព្រេងនាយ ព្រះពោធិសត្វលះបង់ទ្រព្យសម្បត្តិចេញបួសជាតាបសឬសី បានសម្រេចឈានអភិញ្ញាសមាបត្តិជាលោកិយ គង់នៅក្នុងព្រៃហិមពាន្ត ។

---

១- សមុគ្គជាតក ក្នុងនិបាតជាតក របស់ព្រះពុ ស. សៀវភៅលេខ ម ១ / ១០ ។

គ្រានោះ មានយក្សម្នាក់នៅក្នុងព្រៃជិតអស្រមរបស់តាបស តែងចូលទៅស្តាប់ធម៌តាបសជារឿយ ៗ លុះស្តាប់ធម៌រួចហើយ ទៅឈរនៅត្រង់ផ្លូវបំបែក ដែលមនុស្សដើរកាត់ទៅមកតាមដងព្រៃនោះ បើបានឃើញមនុស្សណា ក៏ចាប់អ្នកនោះបរិភោគជាអាហារ ។ ថ្ងៃមួយ មាននាងកុលធីតាម្នាក់រូបឆោមល្អស្អាតបាតកំពុងពេញក្រមុំ នៅស្រុកមួយក្នុងដែនកាសី នាងនាំពួកបរិវារទៅសួរមាតាបិតាឯនគរពារាណសី យាត្រាកាត់ព្រៃទៅតាមផ្លូវដែលយក្សនៅចាំស្កាត់នោះ ខ្លួននាងជិះលើរទេះគោ ឯពួកបរិវារដើរពីមុខរទេះខ្លះ ពីក្រោយរទេះខ្លះ ។ យក្សក្រឡេកឃើញនាងបររទេះទៅដល់កន្លែងនោះ ក៏ក្រឡាខ្លួនយ៉ាងធំសំបើមគួរឲ្យខ្លាច រត់ដេញតាមរទេះ ។ ពួកបរិវារមើលទៅឃើញយក្សធំណាស់ ដេញពីក្រោយក៏កិតភ័យយ៉ាងខ្លាំង នាំគ្នារត់ចោលនាងកុលធីតាអស់ ។ នាងកុលធីតានៅក្នុងរទេះតែម្នាក់ឯង ។ យក្សដេញតាមទាន់ហើយ ឃើញនាងរូបល្អស្អាតក៏ចាប់ចិត្តស្រឡាញ់ ទើបនាំយកនាងទៅឯគោហាលំនៅខ្លួនទុកធ្វើជាភរិយារួមសង្វាសជាមួយគ្នារៀងមក ។ យក្សស្រឡាញ់នាងកុលធីតានោះណាស់ ខំស្វះស្វែងដណ្តើមយកសំពត់អាវអាហារគោជន និងគ្រឿងមាសពេជ្រពីមនុស្សអ្នកដំណើរ មកឲ្យប្រពន្ធបរិភោគប្រើប្រាស់ មិនហ៊ានឲ្យខ្វះខាត បើប្រពន្ធបង្គាប់ឲ្យធ្វើដូចម្តេច ចេះតែធ្វើតាមទាំងអស់ មិនប្រកែកឲ្យទាស់ចិត្តប្រពន្ធទេ បើចេញទៅទីណាឆ្ងាយពីគោហា តែង

យក្សប្រពន្ធជាប់ទៅជាមួយផង មិនហ៊ានទៅចោលប្រពន្ធទេ ខ្លាចគេមកលួចស្រឡាញ់ប្រពន្ធ ។ យក្សគិតថា កុំឲ្យលំបាករក្សាប្រពន្ធពេកត្រូវអញលេបទុកក្នុងពោះទើបស្រួលទៅណាមកណា កុំឲ្យប្រពន្ធឃើញប្រុសដទៃ ក្រែងស្រឡាញ់គេចោលខ្លួន ។ ថ្ងៃមួយ យក្សរកបានស្គរ ១ យកមកឲ្យប្រពន្ធចូលទៅនៅក្នុងស្គរ ហើយលេបស្គរនោះទៅទុកក្នុងពោះ ។

ខាងក្រោយមក យក្សទៅងូតទឹកឯស្រះ លុះទៅដល់មាត់ស្រះហើយយក្សខ្ជាក់ស្គរពីក្នុងពោះចេញក្រៅ ហើយដឹកដៃប្រពន្ធឲ្យចុះងូតទឹកក្នុងស្រះដុះលាងខ្លួនប្រាណឲ្យប្រពន្ធស្អាតបាតហើយ នាំប្រពន្ធមកឲ្យអង្គុយលើមាត់ស្គរស្ថិតសក់លាបប្រេងម្សៅនៅក្រៅស្គរ ឲ្យត្រូវខ្យល់អាកាសបន្តិច ។ យក្សគយគន់មើលនាយអាយ មិនឃើញមានប្រុសណាម្នាក់នៅក្បែរស្រះនោះសោះ ក៏ផ្តាំប្រពន្ធឲ្យអង្គុយចាំ ហើយចុះទៅងូតទឹកស្រះ ងូតបណ្តើរក្រឡេកមើលមកប្រពន្ធបណ្តើរ ខ្លាចក្រែងប្រពន្ធដើរទៅណា លុះឃើញប្រពន្ធអង្គុយស្ងៀមលើមាត់ស្គរហើយ ក៏អស់សង្ស័យទើបមុជទឹកហែលលេងទៅឆ្ងាយពីប្រពន្ធបន្តិច ។

ជួនជាគ្រានោះ មានពិទ្យាធរម្នាក់សៀតព្រះខាន់នៅបង្ហើរហោះឯអាកាស មកដិតកាត់រំលងលើក្បាលនាងប្រពន្ធយក្ស ។ នាងក្រឡេកឃើញបក់ដៃហៅពិទ្យាធរឲ្យចុះមក ដោយចិត្តនាងល្មោភនឹងកាមគុណ

ខ្លាំង ៗ ពិទ្យាធរជើងអាកាសនោះ ក៏ចុះមកក្តាមបំបាំងខ្លួននឹងស្ត្រី សម្រេចកិច្ចស្រេចហើយ នាងឲ្យពិទ្យាធរហូលទៅពួនសម្ងំកន្សែង រួបនាងអង្គុយលើមាត់ស្ត្រីបែរមុខមើលទៅយក្សប៊ីធ្មើបុកព្រះងើយ លុះនាងឃើញយក្សឡើងពីទឹកដើរមកជិតឃើញខ្លួននាងច្បាស់ហើយ នាងក៏ចូលកន្សែងអង្គុយសង្កត់លើពិទ្យាធរ យកសំពត់ដណ្តប់គ្របជិតខ្លួនមិនឲ្យយក្សឃើញពិទ្យាធរ ៗ យក្សមកដល់ក្នុងទឹកសង្ស័យអ្វីបន្តិចសោះ សំគាល់ថាប្រពន្ធបរិសុទ្ធណាស់នៅក្នុងស្ត្រីតែម្នាក់ឯងគត់ ក៏ចាប់គ្របស្ត្រីបិទជិតហើយលេបទៅទុកក្នុងពោះខ្លួនទៅ របដើរត្រឡប់មកលំនៅខ្លួនវិញ លុះមកដល់ជិតអស្រមតាបសគិតថា អញបានចូលទៅជួបសាប់ធម៌តាបសជាយូរថ្ងៃហើយ ព្រោះរវល់ខ្វល់តែស្រឡាញ់ប្រពន្ធ ពេលនេះគួរតែអញចូលទៅសួរសុខទុក្ខលោកម្តង គិតហើយក៏ដើរដេប្រន៍ចូលទៅរកតាបស ៗ

ចំណែកតាបសគង់នៅក្បែរទ្វារអស្រម ក្រឡេកឃើញយក្សដើរចូលទៅពីចម្ងាយ ក៏ជ្រាបច្បាស់ថាយក្សនេះលេបមនុស្សស្រីម្នាក់នឹងពិទ្យាធរប្រុសម្នាក់ទុកក្នុងពោះ ទើបនាំស្រកបួកទៅយក្សថា នែអ្នកទាំងបី អ្នកនាំគ្នាចកកំណាច មកពីក្នុងណាក ទើបក៏ថ្កាត់យូរម្ល៉េះ? អ្នកទាំងបីចូលមកអង្គុយឯណោះសិន ៗ យក្សក្តីតាបសស្រកសួរខ្លួនដូច្នោះនឹកងល់ណាស់ថា ខ្លួនមកម្នាក់ឯងគត់ ចុះហេតុអ្វី [illegible] តាបសនេះ សួរថាអ្នក [illegible] ? [illegible] ខ្លួនអ្នកបួនឥតបាប្ងប ៗ

ឲ្យរួចពីមាត់ទៅទេ  គិតហើយដើរចូលទៅដល់ក្រាបថ្វាយបង្គំរួចទូលសួរថា បពិត្រព្រះករុណា! លោកម្ចាស់សួរថាអ្នកទាំងបីមកពីណាដូច្នេះ តើសួរអ្នកណា បើខ្ញុំព្រះករុណាមកតែម្នាក់ឯងគត់យ៉ាងនេះ? តាបសឆ្លើយថា បើអ្នកចង់ដឹងរឿងអាត្មានឹងប្រាប់អ្នក, ចូរអ្នកប្រុងស្ដាប់ចុះ ទើបតាបសប្រាប់ថា ខ្លួនអ្នកឯងម្នាក់, ប្រពន្ធសំឡាញ់ក្នុងស្នូកដែលអ្នកឯងលេបទៅលាក់ទុកក្នុងពោះម្នាក់, ពិទ្យាធរឈ្មោះវាយុបុត្រ ជាសហាយរបស់ប្រពន្ធអ្នកនៅជាមួយគ្នាក្នុងស្នូកម្នាក់ទៀត ជាគំរប់បីនាក់, ខ្លួនអ្នកតាំងចិត្តថា អញនឹងរក្សាការពារប្រពន្ធ កុំឲ្យមានប្ដីច្រើនក្នុងស្នូក ហើយមិនហ៊ានទុកខាងក្រៅលេបទៅលាក់ក្នុងពោះ បែរជាលេបទាំងប្រុសសហាយរបស់ប្រពន្ធឲ្យទៅនៅជួបគ្នាក្នុងពោះទៀត ។

យក្សបានឮតាបសប្រាប់ដូច្នោះ ភិតភ័យណាស់គិតថា ធម្មតាពួកពិទ្យាធរជាអ្នកមានកិច្ចកលមាយាច្រើន បើប្រសិនជាវាមានកាំបិតឬព្រះខាន់ជាប់ទៅនៅដៃផង មុខជាវាចាក់វះពោះអញរត់ចេញទៅ អញនឹងស្លាប់មិនខាន គិតដូចយ៉ាងនេះហើយ ក៏ខ្ជាក់ស្នូកចេញមកក្រៅវិញភ្លាម ដាក់នៅមុខតាបស ហើយបើកគ្របស្នូកឡើងមើល ក៏ឃើញពិទ្យាធរនៅក្នុងស្នូកជាមួយប្រពន្ធ ។ ឯពិទ្យាធរគ្រាន់តែយក្សបើកគ្របស្នូកភ្លាម ក៏[illegible]ស្នូក សូត្រមន្តគាថាហោះ[illegible]តាមអាកាសបាត់[illegible]ពិទ្យាធរហោះ[illegible]ថា៖

---

ÉCOLE FRANÇAISE D'EXTRÊME-ORIENT BIBLIOTHÈQUE P.94

ត្រេកអរណាស់ និយាយសរសើរគុណតាបសថា លោកម្ចាស់ជាអ្នកប្រព្រឹត្តធម៌ដ៏ខ្ពង់ខ្ពស់ បានជាមានប្រាជ្ញាមោះមុតរកជ្រាបរកចិតចាំងល្អិតសុខុមបែបនេះបានយ៉ាងច្បាស់លាស់ ឯខ្ញុំព្រះករុណា ជាមនុស្សប្រព្រឹត្តអាក្រក់ បានជាគ្មានប្រាជ្ញាមិនដឹងកិរិយាប្រពន្ធក្នុងពោះក្បត់ចិត្តលួចមានសហាយ ព្រោះខ្ញុំព្រះករុណាវង្វេងស្មារតី ទៅក្នុងអំណាចកាមគុណខ្លាំងណាស់ នាំឲ្យវង្វេងដល់ម្ល៉េះ ស្រឡាញ់ប្រពន្ធស្មើជីវិតទាល់តែលេបទៅលាក់ទុកក្នុងពោះខ្លួន តែប្រពន្ធនោះក្បត់ចិត្តគិតប្រទូសរ៉ាយខ្លួនវិញទៅត្រេកត្រអាលនឹងប្រុសដទៃ គិតសម្លាប់ប្ដីដែលចិញ្ចឹមរក្សារាល់ថ្ងៃ កុំតែបានលោកម្ចាស់ប្រាប់រឿងនេះឲ្យដឹង កុំអីខ្ញុំព្រះករុណាស្លាប់នឹងដៃវិទ្យាធរមិនខាន, ឱគួរឲ្យស្លុតចិត្តណាស់! ប្រុសណាប្រាថ្នាឲ្យបានសេចក្ដីសុខចំរើនដល់ខ្លួន ប្រុសនោះត្រូវតែប្រុងប្រយ័ត្នពីរឿងស្រឡាញ់ស្រីឲ្យណាស់ កុំនៅប្រទូកប្រឡំនឹងស្រី ព្រោះថាបើដក់ចិត្តស្រឡាញ់ស្រីជ្រុលពេកហើយ មុខជាខូចចំណេះវិជ្ជា, ខាតលាភសក្ការៈ, ឬធ្លាក់បុណ្យសក្ដិមិនខាន ។

តាបសឆ្លើយថា នែយក្ស! អ្នកថាដូច្នោះមិនត្រូវសព្វគ្រប់ទេ ដ្បិតប្រុសក្ដី ស្រីក្ដី មានល្អមានអាក្រក់ដូចគ្នា មិនមែនសុទ្ធតែល្អឬអាក្រក់ទាំងអស់គ្នាទេ ស្រីដែលល្អក៏មានច្រើន ធម្មតាប្រុសនឹងវៀសវាងពីស្រីមិនផុតទេ ចំណែកស្រីវិញក៏វៀសវាងពីប្រុសមិនរួចដែរ អ្នកទាំងពីរត្រូវ

តែពឹងពាក់ប្រាស្រ័យជាប់ទាក់ទងគ្នា ជានិច្ចតាមធម្មតាលោក ហេតុនេះ ប្រុសនឹងស្រឡាញ់ស្រីយកធ្វើជាប្រពន្ធ ឬស្រីនឹងស្រឡាញ់ប្រុសយកធ្វើជាប្ដី ត្រូវតែសង្កេតឲ្យម៉ត់ចត់ ឲ្យដឹងលក្ខណៈប្រុសស្រីនោះថាល្អ ឬអាក្រក់ជាមុនសិនកុំចេះតែស្រឡាញ់ឥតគំនិត ។

យក្សព្រះតាបសពន្យល់ដូច្នោះហើយ ក៏ដាច់ចិត្តលែងស្រឡាញ់នាងកុលធីតាបណ្ដេញឲ្យដើរចេញពីខ្លួនទៅ រួចថ្វាយបង្គំលាតាបសវិលទៅលំនៅខ្លួនវិញ ។

រឿងស្រីក្នុងស្មុគ្រចប់ប៉ុណ្ណោះ

ម៉ែព្រះទេ ! មកពីខ្ញុំព្រះរឿងស្រីក្នុងស្មុគនេះហើយ បានជាខ្ញុំខ្លាចស្រីណាស់ តាំងចិត្តថាលែងយកប្រពន្ធមួយជាតិ ស៊ូនៅតែម្នាក់ឯងល្អជាងកុំឲ្យកើតទុក្ខដោយសារតែប្រពន្ធ ។

ធាជូវស់ – ងើបមើលមុខ ជីប្រែ, ឯងថានោះមិនត្រូវសោះ ស្រី ៗ ក៏មានខូចកាចអាក្រក់ដូចប្រុស ៗ ដែរ, ប៉ុន្តែមិនមែនសុទ្ធតែខូចកាចអាក្រក់ទាំងអស់គ្នាទេ ស្រីដែលល្អមានច្រើនជាងស្រីអាក្រក់ ប្រសិនបើស្រី ៗ សុទ្ធតែខូចទាំងអស់នោះ គ្មានអ្នកណាតាំងវង្សត្រកូលកើតទេ ដូចជាគេមានប្ដីប្រពន្ធ កើតកូនពូនជាចៅនៅពេញភូមិកោះរះថ្កុតនេះឯង ឃើញដែរឬទេ ឯស្រីខូចក៏មានខ្លះដែរ, ប៉ុន្តែមានមួយ ៗ ចាស់ទុំលោកប្រដៅឲ្យចៀសវាងស្រីខូច ដូចមានសុភាសិតថា : ៈកុំគាត់ស្របខ្សៀ

កុំប្រដៅស្រីឡូក ហេតុនេះ ត្រូវឯងយកប្រពន្ធទៅចុះ ម៉ែនឹងរើសកេស្រីដែលមានគំនិតមារយាទល្អត្រឹមត្រូវឲ្យឯង តាមសុភាសិតបុរាណថា ធុរៈជាការក្រឡូងបេរ ឲ្យមើលដៅពង្ស ។

ជីប្រែ— ទេ! ទេ! ម៉ែ! ខ្ញុំមិនព្រមយកប្រពន្ធទេ សូមម៉ែលែងគិតគូទៅ កុំរកស្ដីដណ្ដឹងកូនចៅអ្នកណាឲ្យសោះ ។

វរនារេត្រី—ដេកស្ដាប់កូនប្រកែកនឹងម្ដាយដាច់អហង្ការដូច្នោះ គឹងក្រូងពេក ទ្រាំមិនបាន ក្រោកអង្គុយ ទាញស្រ្គួចថ្នាំមូរបារីស្លឹកសង្កែ ១ ធំ បឺតហុយទ្រលោម ឆ្លើយកាត់កូនក្លាមថា ឯងស្ងប់លែងយកប្រពន្ធមួយជាតិនោះ អញមិនជឿសោះ ថ្ងៃនេះឯងថាមិនយក ក្រែងដល់ទៅថ្ងៃមុខឆ្នាំក្រោយ ឯងប្រែចិត្តព្រមយកវិញ ដៀតបាស់ទុំថា ចិត្តមនុស្សប្រុសស្រីគ្រប់រូបតែងតែប្រែប្រួលជាធម្មតា មិននឹងនៅឲ្យទៀងទាត់តែម្យ៉ាង ១ ទេ មួងគិតឃើញយ៉ាងនេះ មួងគិតឃើញយ៉ាងនោះ ដូចខ្លួនអញនេះជាគឺ កាលអញបួសកំពុងតែរីករាយនឹងផ្នួស អញតាំងចិត្តថាបួសមួយជីវិត លែងសឹកមកយកប្រពន្ធ ព្រោះឃើញអ្នកស្រុកមានប្ដីប្រពន្ធលំបាកណាស់ ណាព្រួយនឹងរកស៊ី ណាមួយព្រួយនឹងប្ដីប្រពន្ធកូនចៅឈឺចាប់ស្លាប់ទៅ កើតទុក្ខសោករកសុខគ្មាន បើនៅបួសខ្លួនតែមួយគ្មានកើតទុក្ខព្រួយចិត្តនឹងអ្នកណាទេ ចិត្តអញ ប្ដេជ្ញាយ៉ាងនេះរួចមកហើយ ប៉ុន្តែ ទុះបស្រឡះ ដៀតឆ្នាំក្រោយមកមានគេធ្វើឲ្យចាស់ចិត្តកើត

ខឹងលែងចង់បួសក៏សឹក លុះសឹកមកហើយនៅតែម្នាក់ឯង គ្មានប្រពន្ធ គ្រាន់តឹងពាក់អាស្រ័យក្នុងពេលមានទុក្ខធុរៈយប់ថ្ងៃ លំបាកណាស់ដូចទូកមានតែក្បាលឥតកន្ទ្រឹងទៅណាមិនរួច ទ្រាំមិនបានក៏រៀបការនឹងម្តាយឯងនេះ ដូច្នេះត្រូវតែឯងយកប្រពន្ធទៅកុំប្រកែក ។

ជីប្រែ— ទេផុ! ចិត្តផុម្យ៉ាង ចិត្តខ្ញុំម្យ៉ាង ចិត្តមិនដូចគ្នាទេ ។

អ្នកតាគៀត អើ! ឯងថានុះមែនហើយ ចិត្តមនុស្សគ្រប់រូបសុទ្ធតែខុសគ្នា ប៉ុន្តែត្រង់ចិត្តប្រែប្រួលមិនទៀងទាត់ដូចគ្នាទាំងអស់ ដូចជាអ្នកខ្លះកាលខ្លួននៅក្មេងមិនសូវចូលចិត្តបង្អែមទេ លុះដល់ចាស់ប្រែជាចូលចិត្តបង្អែមណាស់ទៅវិញ ។

ជីប្រែ ទេផុ! ចិត្តខ្ញុំមិនប្រែប្រួលដូចគេ ព្រោះខ្ញុំបានរៀនសូត្រចេះដឹងពីរឿងចិត្តគ្រាន់បើដែរ បានជាខ្ញុំហ៊ានសម្រេចចិត្តយ៉ាងដាច់ខាតថា លែងយកប្រពន្ធមួយជាតិ ។

(នៅមានត)

# រឿងចៅតាំងិល យាយចៅក្រឹប

លោក ម៉ាត់-អេង លេខាធិការ

នៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ រៀបរៀង

---

ក្នុងកាលកន្លងទៅហើយ នៅស្រុកមួយមានជនពីរនាក់ប្ដីប្រពន្ធ មានកូនស្រី ៣ នាក់ កូនប្រុស ៣ នាក់ ៗ ឪពុកម្ដាយជាមេគ្រួសារចាស់ៗហើយ ៗ

កាលនោះ ជាវេលាខែចេត្រដើមឆ្នាំជារដូវទំនេររួចរាល់ស្រូវ-អង្ករអស់ហើយ. តាជាប្ដីក៏ផ្ដើមបបួលយាយជាប្រពន្ធនិងកូនស្រី-ប្រុសថានឹងទៅច្រូតស្បូវក្នុងព្រៃស្បាតដើម្បីយកមកក្រងប្រក់ផ្ទះ ពីព្រោះដំបូលផ្ទះស្បូវចាស់ពុករលួយធ្លុះធ្លាយអស់ ៗ យាយជាភរិយានិងកូនទាំងអស់ក៏ស្រុះស្រួលព្រមព្រៀងគ្នា ៗ

ក្នុងវេលាយប់នោះ ម្ដាយបង្គាប់ឲ្យកូនស្រីរៀបចំអង្ករ-អំបិល-ប្រហុកត្រីងៀត ឆ្នាំងបាយឆ្នាំងសំឡ បានក្បានដាក់ក្នុងកញ្ជើរួចស្រេចពីល្ងាច ៗ

ចំណែកឪពុកបង្គាប់ឲ្យកូនប្រុសៗ ប្រមូលកាំបិត-ពូថៅ និងកណ្ដៀវ ទុកឲ្យមូលមួយកន្លែង, រួចគាត់បង្គាប់ឲ្យកូនប្រុសទាំង ៣ នាក់ ចុះទៅរុញរទេះគោចេញពីក្រោមផ្ទះ រកចំណងចងព្រែកហោះស្នៀតកង់កាំទឹម ចងនឹមទ្រូង ត្រៀមរទេះឲ្យជាប់លាប់ ៗ

កូនប្រសាទី ១ នឹងទី ៣ នាំគ្នាធ្វើតាមបង្គាប់ឪពុកក្មេកទាំងអស់ ។ ឯកូនប្រសាទី ២ គ្រាន់តែចុះបាត់ពីលើផ្ទះ ដើរទ្រលទ្រល ។ ទៅឯណោះ បន្តិច ឯណោះបន្តិច លុះគេធ្វើរួចស្រេច, ទើបឡើងទៅលើផ្ទះវិញជាមួយនឹងគេដែរ ។

ព្រឹកព្រាងស្វាងព្រះសុរិយាកាលណា, ឪពុកម្ដាយមេគ្រួសារ នាំកូនបង្កើត - កូនប្រសាទឹមរទេះផ្ទុកអង្ករឈើព្រៃដាក់លើរទេះមួយបរសំដៅទៅកាន់ព្រៃស្បាត, ដល់ហើយនាំគ្នាដាក់រទេះ ដោះគោយកទៅចងឲ្យស៊ីស្មៅ ។ ឯកន្លែងប្រូតស្បូវនោះ មានតែស្បូវ-ស្មៅនឹងកូនឈើតូចតាចបន្តិចបន្តួច រកម្លប់ជ្រកគ្មានទេ ។

ឪពុកដឹងថាមុខជាក្ដៅណាស់ ព្រោះរដូវខែចេត្រផង ទើបគាត់ហៅកូនប្រសាទាំង ៣ នាក់មកប្រើថា៖ កូនឯងនាំបងប្អូនទៅរកកាប់កូនឈើខ្លះនឹងប្រូតស្បូវខ្លះ ពោចវល្លិ ពោចរពាក់ខ្លះ យកមកចងប្រក់ធ្វើជាដំរំមួយគ្រាន់ជ្រក ព្រោះដល់ពេលថ្ងៃឡើងក្ដៅណាស់ ។

កូនប្រសាទី ១ នឹងទី ៣ ទទួលថាបាទ ។ ហើយស្រាវចាប់កាំបិតពូថៅនឹងកណ្ដៀវ នាំគ្នាទៅរកក្ដាម ។

ឯកូនប្រសារទី ២ ធ្វើទឹមទាម ។ ស្ទើរទៅស្ទើរនៅ ក៏ដើរលយតាមគេទៅព្រៃដែរ, ប៉ុន្តែលុះទៅដល់ព្រៃពុំបានធ្វើអ្វីទឹទៃគេទេ ទៅពួនអង្គុយ

សំកុកយកដៃប្រឋាប់ពោះប្ញថា "ឈឺពោះណាស់ ធ្វើអ្វីមិនកើតទេ" ៗ

កូនប្រសា ២ នាក់ខំកាប់-រោប-ច្រូត-ឈើឫស្សីល្ងនឹងស្រូវបាន គ្រប់គ្រាន់ ក៏នាំគ្នាកងលើយកមកចងប្រក់ ធ្វើជំរំមួយបានហើយស្រេច ទើបនាំគ្នាទៅខំច្រូតស្រូវ, លុះដល់ថ្ងៃខ្ពស់ជិតដល់ពេលបាយ ក៏នាំគ្នាមក ឈប់សម្រាក ខ្លះដាំបាយ ៗ ឪពុកបង្គាប់កូនខ្លះឲ្យទៅដងទឹក ខ្លះទៅរកឧសមកដុត ៗ កូនឯទៀត ៗ គេទៅធ្វើបានសម្រេចអស់តាមបង្គាប់ឪពុក ៗ

ចំណែកចៅចុកពោះមិនគិតជួយធ្វើអ្វីគេទេ, ចេះតែគេចមុខទៅឯ-ណោះបន្តិចឯណោះបន្តិច, លុះដល់ត្រូវកំដៅថ្ងៃខ្លាំង គាត់ទ្រាំឈរនៅកណ្ដាលវាលមិនបាន ហើយគាត់មិនហ៊ានចូលជ្រកក្លាម ពីព្រោះពុកគាត់ខ្លួលមិនបានជួយធ្វើនឹងគេ គាត់គ្រាន់តែដើរកាប់ពង់ក្បែរ ៗ ជំរំនោះ បែកញើសហោមដាមពាសពេញមុខមាត់ ហើយគាត់ចេះតែទន្ទេញថា "តិចផុកផ្ទេវ ៗ" ៗ គាត់ថាច្រើនដង ប៉ុន្តែគ្មានអ្នកណាស្បិតហៅឲ្យចូលជ្រកសោះ សូម្បីតែនាងជាប្រពន្ធខ្លួននោះក៏មិនហ៊ានផង ព្រោះខ្លាចឪពុក ៗ ទើបម្ដាយក្មេកគាត់ក្រឡេកមើលទៅ ឃើញដូចជាវេទនាក្មេកគាត់ពេក គាត់ក៏ហៅថា "លោកកូនឯណោះ នៅឈរហាលថ្ងៃដល់ណាទៀត ម៉េចក៏មិនចូលមកជ្រកទៅ" ៗ ចៅនោះក៏ចូលមកជ្រក

ទាំងញញើតញញើម ៗ តាទឹងកូនឯទៀត គេមិនមាត់ទាំងអស់គ្នា ៗ គ្រួសារនោះនាំគ្នាសម្រាកមួយស្របក់ ក៏នាំគ្នាទៅប្រុតស្រូវទៀត ខ្លះនៅដាំបាយ ឪពុកក៏ប្រើចៅចុកពោះឲ្យទៅជួយរកឧសមកថែមជាមួយកូនប្រុសា ១ នាក់ទៀត, ចៅចុកពោះគ្រាន់តែចេញទៅឲ្យបាត់ពីមុខតាប៉ុណ្ណោះ ប៉ុន្តែពុំបានជួយរកឧសគេទេ ៗ

ចំណែកឯតាវិញ ភ្នែកគាត់ចេះតែរំពៃលួចគន់មើលដំណើរចៅនោះ គាត់ដឹងច្បាស់ក្នុងចិត្តគាត់ថា "អានោះជាមនុស្សខ្ជិលមិនមែនជាឈើទេ, ត្រូវបង្អត់បាយវាកុំឲ្យវាធ្លាប់ អាមនុស្សខ្ជិល" ៗ និមិត្តតែដល់បាយនឹងម្ហូបឆ្អិនអស់ហើយ គាត់បង្គូកហៅប្រមូលកូនឯទៀតៗ ឲ្យមកជួបជុំគ្នានឹងបរិភោគបាយ, គាត់ក៏ហាមប្រពន្ធនឹងកូនឯទៀតថា "នែវ៉ុយ! នរណាកុំហៅអាមួយនោះមកស៊ីឲ្យសោះ ឲ្យវាស្គាល់ចិត្តឪម្តងមើល!" ម្តាយនឹងកូនទាំងអស់គ្នាក៏នៅស្ងៀម ៗ គេក៏នាំគ្នាអង្គុយរាងវង់ ដួសដោះបាយបរិភោគយ៉ាងសប្បាយ, ស្រាប់តែឃើញចៅកំជិលដើរចេញពីក្នុងព្រៃស្បាតយ៉ាងវួតរះសំដៅមកជំរំ ប៉ុន្តែពុំហ៊ានចូល គ្រាន់តែដើរក្រឡឹងជុំវិញ ចាំឲ្យគេហៅដូចមុនទៀត ៗ

ទោះបីចៅនោះដើរក្រឡឹងជុំវិញដល់ទៅ ១០ ជុំ ក៏គ្មាននរណាគេហៅសោះ, មើលទៅមុខគាត់ក្រៀមក្រោះបាក់ពោះសន្លៃ កាន់តែម្លាន

បាយខាំង គាត់អត់ទ្រាំពុំបាន ក៏ធ្លាយសំដីថា៖ "តិចគ្រឹបឥឡូវ ៗ បានជាគ្រឹប គ្រឹបឲ្យអស់" ។ ឪពុកក្មេកឮដូច្នោះ គាត់ថាឲ្យវិញថា "តិចផសឥឡូវ ៗ! បានជាផស ផសឲ្យឆាប់" ។

ចៅកំដិលដីខ្លួន ក៏អៀនខ្មាសអស់បងប្អូនថ្លៃនឹងប្រពន្ធណាស់, ប្រាសបោលកីងរហូតដល់ផ្ទះទាំងអត់បាយដេកសន្ទឹកសន្ថៃ ទន្ទឹងចាំតែដល់ពេលព្រលប់គេវិលមកពីច្រូតស្រូវវិញ ទើបបានចុះបាយបរិភោគ ។

អំពីនោះតមកទៀត ចៅគ្រឹបស្ញប់ប្រាំបាន រាងចាលមួយអាយុ លែងខ្ជិលលែងមានពុតត្បុតដូចមុនទៀត, ខំធ្វើការរកស៊ីដូចជនទាំងពួង ជាមួយភរិយាដរាបដល់អស់ជីវិតរៀងខ្លួន, ប៉ុន្តែគេក៏ហៅឈ្មោះចៅគ្រឹប អ្នកស្រុកគេនាំគ្នាដំណាលទៅជាប់រហូតមកដល់សព្វថ្ងៃ ។

# រឿងព្រេងប្រទេស មុងហ្សិកា

ចែងអំពីឆ្កែព្រៃ និងក្រុមឆ្កែស្រុក

## ភិក្ខុ ម៉ែន - វៀម

*សិស្សពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ*

ប្រែពីភាសាអង់គ្លេស

---

នេះគឺជារឿងឆ្កែព្រៃ ដែលជាសត្វបោកប្រាស ហើយជាសត្វក្វើផង ៗ ចំពោះសត្វនេះ, សត្វដទៃទៀតបាននិយាយដោយពិតថា ការឈ្លាសវាងវៃរបស់វា មានទំហំស្មើនឹងដំណើរក្វើល្វើរបស់វាដែរ ៗ

ថ្ងៃមួយ ឆ្កែព្រៃនេះ កំពុងតែត្រាច់ចរតាមជ្រលងរាបបុចនោះភ្នំពីរ ស្រាប់តែឆ្កែស្រុកពីរធំ ៗ ដែលបោលកេដេញខាំខ្លួនវាយូរហើយនោះ បានលោតពីក្រោយមហាសិលាពីរផ្ទាំងមក ៗ ឆ្កែព្រៃយើង ក៏ដាក់មេជាយ យ៉ាងលឿនឆ្ពោះទៅរកព្រៃ ៗ ប៉ុន្តែ ឆ្កែស្រុក ទៅជាវ៉ៃស្មានថា វាបោលទៅរកទីវាលបំការវិញ ៗ កាលដែលឆ្កែព្រៃបោលជុំវិញព្រៃស៊ុមទ្រុម លោតផ្លោះរំលងថ្ម រំលងព្រែកឥតទឹក បង្ហុយធូលីទ្រលោមឡើង ពីក្រោយនោះ វាស្មានថាមុខជាបានរួចពីកណ្ដាប់ដៃឆ្កែស្រុកហើយ ដោយបានឮសូរសំឡេងព្រុះយ៉ុះ! យ៉ុះ! យ៉ុះ! នៃឆ្កែស្រុក យ៉ាងខ្សោយពីចម្ងាយមក ៗ វាផ្អាក់ រួចមៀងមើលជុំវិញខ្លួនរកជម្រកដ៏ល្អ សំរាប់សំរាក ៗ

ប៉ុន្តែកាលដែលវាកំពុងតែសំរេចចិត្តដូច្នេះ ស្រាប់តែលេចឆ្កែស្រុក

ពីរទៀត មិនដឹងជាមកពីកន្លែងណា ស្ទុះដេញវាព្រមគ្នាតែម្តង ៗ ពេលនោះ ខ្លែព្រៃ ក៏ត្រូវខ្លែស្រុកបីទាំងពីរនោះ បំផាយឲ្យត្រឡប់ទៅកន្លែងដើមរបស់ខ្លួនវិញ ៗ ពួកខ្លែស្រុកបេះតែប្រដេញវាមុខក្រោយៗ ធ្វង កាត់វាលខ្សាច់ ដកបដល់វាហោះអស់កំឡាំង យ៉ាងខ្លាំងគេបោលឲ្យឆ្ងាយ តទៅទៀតមិនបាន ៗ ខ្លែស្រុកពីរនៅខាងក្រោយ កាន់តែជិតមក ៗ ហើយនៅខាងមុខឯណោះ មានខ្លែស្រុកពីរទៀតនោះ កំពុងតែរង់ចាំខ្លួន ម្ល៉ោះហើយវាដឹងថា ត្រូវតែធ្វើការឲ្យរហ័សរហួនទើបរួចខ្លួន ៗ

នៅលើចំហៀងភ្នំ ខ្លែព្រៃបានឃើញសភាពខ្មៅងងឹតកងមូលមួយកន្លែង នាំឲ្យវាមានសេចក្តីក្លាហានឡើងវិញ ៗ វាស្មានថា សភាពខ្មៅនោះ កាន់តែជិតមកខ្លួនវាហើយ គឺជាគុហា (Cave) មួយ ៗ ហើយឥឡូវ វាមើលទៅឃើញខ្លែស្រុកដែលនៅខាងមុខទាំងពីរនោះហើយ ថែមទាំងព្រួសស្ទុះ ខ្លែស្រុកខាងក្រោយថែមទៀតផង ៗ វាបានបោលគេចយ៉ាងរហ័សក្រៃត ហើយស្ទុះបោលសំដៅជើងភ្នំឲ្យផុតពីកណ្តាប់ដៃពួកខ្លែស្រុក, ប៉ុន្តែពួកនេះ បោលដេញយ៉ាងលឿនអស្ចារ្យ ហើយកាន់តែជិតចូលទៅជិតខ្លែព្រៃបន្តិចម្តង ៗ ជិតដល់ខ្លែព្រៃឮពួកគេពិភាក្សាគ្នាថាតើឲ្យនរណាមួយ ចូលចាប់ខ្លួនវា ៗ ឥឡូវ វាបោលចូលទៅជិតគុហានោះ តែវាភ័យដោយគិតថា បើវាចូលទៅក្នុងគុហា គុហានោះល្មម

ឲ្យពួកឆ្កែស្រុកចូលដេញតាមបានមិនទាន ៗ ប៉ុន្តែ ឥឡូវ ឆ្កែស្រុកបាន ហ្វាលមកជិតប្រកិតនឹងកន្ទុយរបស់វា, ម្ល៉ោះហើយ ដោយការលោតដូច នោះ វាក៏បានជាន់ចុះទៅក្នុងមាត់គុហា ផុតពីកណ្តាប់ដៃឆ្កែស្រុកក្លាម ៗ

ឆ្កែព្រៃ ជាសត្វមានភ័ព្វ ដោយមាត់គុហានោះតូចមិនល្មមឲ្យពួកឆ្កែស្រុកចូលតាមបានឡើយ, ហើយវាបោលយ៉ាងឆ្ងាយពីមាត់គុហា ដែលអាចទៅឆ្ងាយបាន ។

ខាងក្រៅគុហា ពួកឆ្កែស្រុករត់ប្រាស់ប្រាល់ កោះនាយកោះអាយ ដ្រញ៉ុំដើរជុំវិញមាត់គុហា, មួយសន្ទុះក្រោយមក ទើបបាត់ស្ងូវ ៗ

នេះជាសេចក្តីតក់ស្លុតមួយដ៏អាក្រក់បំផុត ដែលឆ្កែព្រៃស្រាប់តែបានជួបប្រទះដោយស្រួល ៗ ។ ប៉ុន្តែ គ្រាដែលបានជួបនិរទុក្ខ ខាងក្នុងគុហាហើយ វាក៏មានសេចក្តីក្លាហានឡើងវិញ ៗ វាបែកគំនិតផ្តើមគិតថា តួខ្លួនវាជាមិត្រម្នាក់របស់វា ដែលអាចរើខ្លួនរួចស្រឡះពីពួកឆ្កែស្រុក, ហើយការដែលអវយវៈដ៏ល្ហិតល្ហៃ របស់វា បានសំរាកស្រួលហើយ, បំណងខាងអួតសរសើរខ្លួន ក៏កើតឡើងដល់វា, ប៉ុន្តែគ្មាននរណាមួយក្នុងគុហា និយាយជាមួយវាសោះ, ម្ល៉ោះហើយ វាចាប់ផ្តើមព្រោកប្រាជ្ញជាមួយនឹងអវយវៈផ្សេង ៗ របស់វា ដែលមានអវយវៈខ្លះ បានប្រណាំងជាមួយពួកឆ្កែស្រុកនោះថា ៖

– ជើង ! តើជើងឯងបានធ្វើការអ្វីខ្លះ ? , ( កនិយាយដោយពោល ក្រឡេកមើលទៅជើងទាំងបួនរបស់ក ) ។

ជើងឆ្លើយដោយមាត់របស់កថា៖

– ពួកយើង បាននាំខ្លួនអ្នកឯង ឲ្យឃ្លាតឆ្ងាយមកកាន់ទីនេះ, យើងបង្ហុយធូលីឲ្យហុយទ្រលោមឡើង ដើម្បីធ្វើឲ្យខ្វាក់ភ្នែកឆ្កែស្រុកចចៃ្រ, យើងលោតផ្លោះថ្ម, ផ្លោះព្រៃស៊ឹមទ្រុម ហើយនាំខ្លួនអ្នកឯងមកដល់គុហានេះ ! ។

– អើល្អ ! ល្អ ! ជើងឯងធ្វើការល្អណាស់ ! ។

– ចុះត្រចៀក ? ត្រចៀកឯងបានធ្វើអ្វីដែរ ? ។

– យើងស្តាប់ឆ្វេង-ស្តាំ, ស្តាប់ឲ្យដឹងចម្ងាយដែលឆ្កែស្រុកបោលដេញពីក្រោយ ដើម្បីឲ្យសញ្ញាដល់ជើងដែលត្រូវបង្កើនល្បឿនប៉ុន្មាន ៗ ទើបផុតពីអន្តរាយ ។

– អើ ! អស្ចារ្យមែន ! ។

– ចុះភ្នែក, ឯងធ្វើការអ្វីដែរ ? ។

– យើងបង្ហាញផ្លូវ ឲ្យដឹងកន្លែងថ្ម ព្រៃស៊ឹមទ្រុម ជ្រលងជង្ហុក, យើងគយគន់ទៅឆ្ងាយ ដើម្បីរកកន្លែងនិរទុក្ខឲ្យអ្នក ហើយយើងឃើញគុហានេះ ! ។

– អើ! ខ្ញុំមែន! ។

ផ្កាព្រៃ និយាយសួរខ្លួនឯង ឆ្លើយខ្លួនឯង យ៉ាងនេះហើយ ក៏សើចសប្បាយចិត្តយ៉ាងអស្ចារ្យ ដោយបន្ទឺសំដីថា ៖

– ចុះភ័ព្វអីអញ ក៏មានមិត្តភ័ក្តិល្អ ៗ ដូចជាក្មេកត្រចៀកយ៉ាងហ្នឹងហ្ន៎! ។

ផ្កាព្រៃ ដែលមានជ័យជំនះ ដោយសារអវយវៈខ្លួនបានធ្វើការគ្រប់បែបគត់ទំនេរក្នុងជីវិតដូច្នេះហើយ, ក៏ងើបក្បាលបែរទៅក្រោយ ប៉ងនឹងទះខ្នងខ្លួន ( បែបឥស្សរជនគាប់ចិត្តចំពោះអ្នកតូចណាមួយហើយ ទះខ្នងអ្នកនោះតិច ៗ ) ។ ស្រាប់តែឃើញកន្ទុយខ្លួនឯង ក៏លាន់មាត់ថា ៖

– អ៊ូកន្ទុយ! អញរវល់តែនឹងក្មួយឯងទៅហើយ! មក! ប្រាប់អញមើល តើឯងបានធ្វើអ្វីខ្លះ ប្រឆាំងនឹងផ្កាស្រុក ក្នុងជ័យជំនះរបស់យើងនេះ ? ។

កន្ទុយ ក៏និយាយប្រាប់ដោយសំឡេងផ្កាព្រៃឯងថា ៖

– អ្នកឯងមិនសូវជាគិតដល់ខ្ញុំប៉ុន្មានទេ! ។ ដូច្នេះហើយ បានជាកន្ទុយគ្មានចម្លើយថាដូចម្តេចឡើយ ។

វានិយាយទៅកាន់កន្ទុយទៀតថា ៖

– ដោយទូទៅ អាឯងនេះ គ្រាន់តែជាអវយវៈបន្ថែមមួយ ឥតផលដល់យើង, អាឯងនាំឲ្យយើងថយក្រោយ ជាងអ្វីៗ ទៅទៀត, ថែមទាំង

វះតែឲ្យគេចាប់ខ្លួនអញបានផងទៀត ; អាឯង នាំឲ្យពួកឆ្កែស្រុក ចាប់ចុងអាឯងកន្ទ្រាក់ទៅក្រោយ ; ប៉ុន្តែ យើងចាំស្ដាប់ពាគាត់ឯងមុន, និយាយមក ! អាឯងបានធ្វើអ្វីខ្លះ ? ។

ខ្ញុំបានធ្វើអ្វីទៅ ? គឺខ្ញុំបានបក់បុះ-ទៀងយ៉ាងនេះទៅរកពួកឆ្កែស្រុក ហើយប្រាប់ពួកវាឲ្យមកចាប់អ្នកឯង; កាលអ្នកកំពុងតែបោល ខ្ញុំនៅខាងក្រោយអ្នក បង្ខំពួកឆ្កែស្រុកឲ្យវាបោលកាន់តែជិតមក, ទុកណាជាមានធូលីហុយឡើងក៏ដោយពួកវានៅតែអាចឃើញខ្ញុំ ដោយសារបលនាពណ៌សរបស់ខ្ញុំ ។

មុខក្រញូវរបស់ឆ្កែព្រៃ កាន់តែខ្មៅឡើង ៗ ហើយស្រែកគំហករកាក់រអ៊ូល ជាប់ ៗ ដោយកំហឹងថា ៖

- ស្ងៀមទៅ ! កុំមាត់ ! អាឯងនិយាយបែបហ្នឹងតើវាមានន័យយ៉ាងម៉េច ?

ពេលនោះ កបែរទៅរកខ្ទង់ របត់កន្ទុយយ៉ាងធ្ងន់មួយដៃ ដោយពាក្យថា ៖

- អាឯង មិនត្រូវនៅក្នុងគុហានេះ ជាមួយអាយវៈដ៏សេសរបស់យើងទៀតទេ ! អាឯងនេះ ជាអ្នកក្បត់ ! ។

---

ថាះហើយឆ្កែព្រៃក៏ញាក់កន្ទុយខ្លួនផ្ទោះទៅទ្វារគុហា :

– ទៅក្រោយ! កុំនៅជាមួយអញ! ទៅក្រៅទៅ, គ្មានបន្ទប់ឯណាសំកប់អាចផ្ទៃងឯងក្នុងទីនេះទេ, អាឯងត្រូវតែទៅនៅខាងក្រៅ ព្រោះអាឯងជាបក្សពួកខាងខ្លាស្រុក, អាឯងជួយគេឲ្យចាប់អញ រួចហើយអាឯងអួតសរសើរពីក !, ទៅក្រៅទៅ ! ។

ខ្លាព្រៃ បានបង្អិលទៅកន្ទុយខ្លួនដោយដៃម្ខាង ហើយបង្អិលទៅទ្វារគុហាដែលមានពន្លឺថ្ងៃចាំងចូលមក ដោយដៃម្ខាងទៀត ។

– ទៅក្រៅទៅ ! ។

ពេលនោះ ក៏បានរុញកន្ទុយឲ្យចេញទៅខាងក្រៅទ្វារដែលជាល-ហអាកាស ។ ពួកខ្លាស្រុក ដែលចាំស្តាប់ការនិយាយរបស់ខ្លាព្រៃខាងក្នុងគុហា បានលាក់ខ្លួនពួននៅខាងក្រៅ, កាលបានឃើញកន្ទុយខ្លាព្រៃលេចធ្លុយចេញមកតាមទ្វារគុហាដូច្នោះ ក៏នាំគ្នាទៅចាប់ទាញឡើង ៗ ម៉្លោះហើយ ខ្លាព្រៃនោះ ក៏ត្រូវពួកខ្លាស្រុកទាំងអស់ កន្ត្រាក់ទាញចេញមកក្រៅគុហា ពីព្រោះតែកន្ទុយនោះឯង ។

---

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## រឿងអ្នកតាក្រហមគរ

### នៅខេត្តកំពង់ធំ

នៅក្នុងវត្តកំពង់ធំ មានរូបអ្នកតាមួយធ្វើពីថ្មហៅថា អ្នកតាក្រហមគរ ជាអ្នកតាមានឫទ្ធានុភាពយ៉ាងពូកែ អ្នកស្រុកទីនោះហ្នឹងក្នុងខេត្តកំពង់ធំតែងគោរពខ្លាចពន់ពេក ៗ

រឿងរ៉ាវអ្នកតានោះ ដូចមានអធិប្បាយខាងក្រោមនេះ :

ប្រមាណជាជាង ១០០ ឆ្នាំមកហើយ មានបុរសមួយនាក់ជាតិខ្មែរ ឈ្មោះជ័យ ប្រពន្ធឈ្មោះនាងខុង ។ មានបាវក្មេងប្រុសម្នាក់នៅក្មេងជំទង់ឈ្មោះយ៉ត ផ្ទះនៅក្បែរភ្នំសន្ទុក ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ។ ចៅជ័យ ជាគ្រូសិល្បសាស្ត្រយ៉ាងពូកែ ធ្វើជាគ្រូពេទ្យហ្មផង ជាអ្នករកទទួលទានរែកលក់ផង ។ ចៅជ័យនោះ តែងចេញរែកលក់ជាមួយនឹងចៅយ៉ត ។ ពេលព្រឹកព្រលឹមចេញដំណើរពីផ្ទះទៅភ្នំសន្ទុក ទៅលក់ឥវ៉ាន់នៅស្រុកជីក្រែង(១) ដល់ពេលព្រលប់ត្រឡប់មកផ្ទះវិញ ។ ចម្ងាយផ្លូវទៅមកក្នុងមួយថ្ងៃ ៗ ចំនួនជា ២០០ គីឡូម៉ែត្រ ។

មានថ្ងៃមួយ ចៅជ័យរែកអម្រែក បណ្ដើរចៅយ៉តចេញពីស្រុកជី-ក្រែង ប៉ងនឹងត្រឡប់ទៅផ្ទះខ្លួនវិញ តែមកដល់ត្រឹមវត្តកំពង់ធំ អស់

---

១. ស្រុកជីក្រែង កាលពីជាន់មុននៅក្នុងខេត្តកំពង់ធំ ទើបតែនឹងកាត់បញ្ចូលទៅក្នុងខេត្តសៀមរាប ក្នុងពេល [illegible]

កម្លាំងពេកទៅទៀតពុំរួច ក៏ចូលទៅក្នុងវត្ត រកលោកគ្រូចៅអធិការ ដែលជាភ្ញៀវនឹងគ្នាកាលនៅពីក្មេង ធ្លាប់បួសរៀនជាមួយគ្នា ។ គ្រូជ័យនោះចូលដល់កុដិហើយក៏ដាក់អម្រែកចុះ ឡើងទៅថ្វាយបង្គំលោកគ្រូចៅអធិការ ។ ក៏សាកសួរសព្វគ្រប់តាមភាពមនុស្សធ្លាប់ស្គាល់ស្និទ្ធស្នាលនឹងគ្នា ។ រួចស្រេច ចៅជ័យនិយាយផ្ដាំលោកគ្រូថា " ដល់ឆាន់ហើយសុំឲ្យទុកបាយឲ្យទទួលទានផង " ។ ជាតែប៉ុណ្ណោះ ក៏ចុះទៅទទួលទានដំណេកក្នុងវិហារលក់ទៅ ។ ចៅយ៉តក៏នៅលេងជាមួយនឹងលោកគ្រូឯកុដិ ។

នៅពេលដែលបុរសនេះដេកលក់ មានរន្ធីព្រះអាទិត្យចាំងចូលតាមជម្រួលវិហារ(១)ទៅលើបុរសនោះ ស្រាប់តែមានពស់នាគពជមួយដែលនៅក្នុងទីវត្តនោះ ចេញទៅវៀនក្ដោយរង្វើលនៅពីលើក្បាលបុរស ហើយបើកពពារក្បាល ៤ ចាំង កុំឲ្យកំដៅព្រះអាទិត្យចាំងទៅលើបុរសនោះ ជាគេទអស្ចារ្យពន់ពេក ។ ដល់ចាំងយូរទៅ បណ្ដាលឲ្យទឹកមាត់ពស់នាគពជហៀរហូរពីមាត់ធ្លាក់ទៅលើកបុរសដែលដេកលក់ ។

ដល់ពេលលោកឆាន់ហើយ លោកគ្រូមេវត្តបានឲ្យលោកភិក្ខុ ១ អង្គទៅហៅចៅជ័យពីក្នុងវិហារមកបរិភោគបាយ ក៏ស្រាប់តែលោកជាបំរើចូលដល់មាត់ទ្វារ ក្រឡេកទៅឃើញពស់បើកពពារលើចៅជ័យ ក៏ភ្ញាក់

---

១ - កាលជាន់ដើម វិហារសង់ពីឈើ ប្រក់ក្បឿងដំរែង គឺជាបន្ទះក្ដារធ្វើរបៀបផ្លូវដាក់ក្បឿងសព្វថ្ងៃ, តែខុសគ្នាត្រង់ : ធ្វើពីគន្លឹះ : ធ្វើពីឈើអាដោយបន្ទះក្ដារតូច ៗ ។

ខ្លួនស្រែកឡើងថា " ពស់ធំណាស់ ៗ នៅក្នុងវិហារ " ។ ពេលនោះ លោកសង្ឃផ្សេងៗទៀត ក៏រត់មកមើល ។ ឯពស់ក៏លូនចុះពីវិហារចូលរូងវានក្រោមវិហារនោះបាត់ទៅ ។ បុរសដែលបើកលក់ ក៏ភ្ញាក់ស្មើងស្មឹង គិតភ័យខ្លួនញាប់ញ័រ តែដោយសារនឹងប្រាស់ថាពស់នាគពុជមកបើកពពារចាំងគម្ពីព្រះរាជទ្រព្យឲ្យខ្លួន ហើយនឹកឃើញសិល្បសាស្ត្រការពារ បំបាត់ភ័យខ្លាចទៅ រួចក៏ចុះពីវិហារដើររកបាយបរិភោគតទៅ ។

លុះចៅល័យបរិភោគបាយហើយ ក៏សាកសួរលោកគ្រូថា ធ្វើដូចម្ដេចឲ្យជ្រុះទឹកមាត់ពស់ចេញពីក តែចៅល័យនឹកថា ខ្លួនមុខជាមានបុណ្យ ។ ចំណែកលោកគ្រូក៏នឹកថា "ល័យមុខជាមានបុណ្យដែរ ព្រោះពស់នាគ-ពពារ្តនេះ ពុំដែលចេញមកបើកពពារចាំងឲ្យមនុស្សណាសោះ ទើបតែពេលម្ដងនេះចេញមកចាំងឲ្យ ។ បើអញឲ្យថ្នាំលាបលាងទឹកមាត់ពស់ឲ្យជ្រុះអស់ចេញ មុខជាគ្មានបុណ្យបារមីអ្វីទេ " ។ លោកក៏ប្រាប់ថា "អាល័យឯង បើចង់ឲ្យអស់ទឹកមាត់ពស់ពីកឯង ។ ត្រូវយកទឹកនោមអញទៅលាប បើពុំដូច្នោះទេ ឯងជាប់ទឹកមាត់ ១ ជីវិតហើយ " ។ ចៅល័យតបទៅលោកគ្រូវិញថា " គ្មាននរណាយកទឹកនោមលោកលាបទេ បើជាប់ក៏ជាប់ទៅចុះ " ។ ចៅល័យថាតែប៉ុណ្ណោះ ក៏ថ្វាយបង្គំលាលោកគ្រូត្រឡប់ទៅផ្ទះខ្លួន ជាមួយនឹងចៅយ៉ាតទៅ ។

លុះមកដល់ផ្ទះ បុរសជាអ្នកយកប៉ែតាមដំណើរប្រាប់ប្រពន្ធ ចាន់ឡុង

ជាប្រពន្ធទឹកធ្លល់ថា ប្អូនមុខជាមានបុណ្យសក្តិអ្វីមួយជាមិនខាន ។

បីថ្ងៃក្រោយមក គេរបស់ចៅជ័យ ដែលពស់នាគពជបង្កៀវទឹកមាត់ធ្លាក់មកលើក៏ឡើងជាកណ្តាប់ មានពណ៌ក្រហមដូចប្រឡាក់ឈាមធ្វើដូចម្តេចក៏ពុំជ្រះ ប្រែទៅជាមនុស្សក្រហមក ។

ប្រមាណជា ៧ ថ្ងៃពីនោះមកទៀត មានពួកកងទ័ពបះបោរនៅប៉ែកស្រុកពោធិ៍កេង បឹងល្វា បំណាងចូលមកលុកលុយក្រុងកំពង់ធំ ។ បណ្តាជន នឹងនាហ្មឺននៅទីក្រុងនោះ ច្របូលច្របល់ភិតភ័យ រត់ចោលផ្ទះសម្បែងសឹងតែគ្រប់គ្នា ។ ទើបលោកតេជោ(១) ហ៊ូ ធ្វើចុតហ្មាយបង្គាប់ទៅគ្រប់លោកដីមឿង(២)ក្នុងខេត្ត ឲ្យរកគេណាមនុស្សខ្លាំងពូកែយកទៅតស៊ូសង្គ្រាមជាមួយនឹងពួកខ្មាំង ។ ដីមឿងឯទៀត ៗ រកអ្នកខ្លាំងពូកែពុំបាន មានតែដីមឿងសន្ទុក ១ ប៉ុណ្ណោះ, ទើបធ្វើសំបុត្របកប្តឹងមកលោកតេជោវិញថា "សឹកសង្គ្រាមដែលមានបះបោរនៅពោធិ៍កេង នឹងបឹងល្វានោះ ខ្ញុំបាទបានរកមនុស្សខ្លាំងពូកែបានម្នាក់ឈ្មោះជ័យ ហើយគេស្ម័គ្រចិត្តធ្វើជាមេកងទ័ព ហើយបានអ្នកស្រុក ៗ សន្ទុកចំនួន ៣០០ នាក់ទៀតស្ម័គ្រចិត្តទៅជាមួយផង ។ តាមសំបុត្របកប្តឹងទៅលោកតេ-ជោនោះថា "ខ្ញុំដីមឿងខ្ញុំបាទមានសង្ឃឹមលើរូបចៅជ័យមេកងជាមុខ

១ - ងារនេះជាប់ជាងារចៅហ្វាយខែត្រកំពង់ធំឥឡូវមក ហៅថាអ្នកឧកញ៉ាតេជោពុករណាពង។

២- ដីមឿង ជាគោរម្យងារនាហ្មឺនស្រុកក្រៅទំនោះ ។ ដីមឿងមានឋានន្តរសក្តិស្មើនឹងចៅហ្វាយស្រុកសព្វថ្ងៃ ។ ឯតេជោស្មើនឹងចៅហ្វាយខេត្តសព្វថ្ងៃ ។

ជានឹងនាំយកជ័យជំនះមកបានជាមិនខាន, ព្រោះចៅជ័យនោះចេះសិល្បសាស្ត្រលើសអស់អ្នកស្រុកឯទៀតៗ ឥតមានឈ្មោះណាហ៊ានតតាំងទេ" ។

លោកតេជោក៏តបទៅជីមឿងវិញថា " យល់ព្រមឲ្យចាត់ចៅជ័យនឹងអ្នកស្រុក ៣០០ នាក់ទៅតទល់ចុះ " ។

បីថ្ងៃមុនលើកទ័ពចេញទៅ អ្នកឡុងជាប្រពន្ធចៅជ័យ រៀបរណ្ដាប់ប្រសិទ្ធិឲ្យប្ដី ហើយសាកមើលតាមបំណាំខ្លួន ដែលជាស្រីចេះសិល្បសាស្ត្របន្តិចបន្តួចដែរ ក៏បង្គាប់ឲ្យមនុស្សយកឫស្សីបានចំនួនមួយពាន់ដើម មកគរដាក់ជាគំនរលើគ្នា ហើយនាងឡុងឡើងអង្គុយនោមដាក់លើគំនរឫស្សីនោះ ។ លុះនោមរួចស្រេច ក៏បានចាត់ឲ្យគេពិនិត្យមើលឫស្សីទាំងមួយពាន់ដើម ឃើញថាបែកប្រេះទាំងអស់ ក៏គាត់ប្រាប់ប្ដីគាត់ថា ចេញទៅធ្វើសឹកសង្គ្រាមចុះ មុខជាមានជ័យជំនះហើយ ។ ក៏បង្គាប់ឲ្យប្ដីគាត់លើកទ័ពចេញទៅភ្លាម ។

ចៅជ័យនឹងអ្នកស្រុកបីរយនាក់ក៏ចេញទៅ តែពេលនោះបាវប្រុសឈ្មោះយ៉ត ក៏ទៅតាមផងដែរ ។ លុះទៅជិតដល់ពោធិ៍កេងបឹងល្វា ពួកខ្មាំងនោះចាំយាមត្រៀបត្រាទាំងយប់ទាំងថ្ងៃ ។ ពេលយប់ ចៅជ័យនាំទ័ពលុកចូលកាប់សម្លាប់ពួកខ្មាំង ។ នោះ ក៏ភ្ញាក់បបខ្វបខ្វាចដោយពេលបោះសម្លាប់ពួកមេ ១ ស្លាប់អស់ ។ រីឯពលដែលសេសសល់ខកខានទាំងប៉ុន្មាន ក៏រត់ចុះដើសស្រាក ។

ដល់មានជ័យជំនះហើយ នាយជ័យជាមេកងទ័ព នាំរេហ៍ពលខ្លួនចូលមកស្រុកវិញ រួចចូលដំរាបប្រាប់ដីមឿងស្រុកសន្ទុក ។ ធ្វើសំបុត្របកប្ដឹងទៅលោកតេជោនៅកំពង់ធំ ។ មានសេចក្ដីសរសើរមេកងជ័យជាក្រៃលែង ហើយលើកឲ្យធ្វើជាដីមឿងសន្ទុក តែចៅជ័យប្រកែកក៏អាក់ខានធ្វើទៅ ។

កន្លង ១ ឆ្នាំតមកទៀត មានទ័ពពួកខ្មាំងស្រុកកញ្ចប (ស្រុកឆែប) ព្រហ្មទេព-ជាំខ្សាន ចូលមកលុកលុយខេត្រកំពង់ធំម្ដងទៀត សម្លាប់លោកតេជោហ៊ូស្លាប់ទៅ ។ ទើបបានមានដំណឹងជ្រាបដល់ព្រះករុណាជាម្ចាស់ជីវិតគង់នៅក្រុងឧត្តុង្គមានជ័យ ។ ទ្រង់ក៏ស្រាវជ្រាវរកមនុស្សខ្លាំងពូកែ ក្នុងខេត្រកំពង់ធំ ដែលបានច្បាំងឈ្នះពួកបះបោរលើកមុន នៅពោធិ៍ពេង-បឹងល្វា ក៏ទ្រង់ជ្រាបថា មេកងទ័ពឈ្មោះជ័យនៅក្នុងសន្ទុក ។ ទ្រង់មានព្រះរាជឱង្ការត្រាស់បង្គាប់ឲ្យនាំយកខ្លួននាយជ័យ ទៅកាន់ព្រះបរមរាជវាំង ។ នាយជ័យទៅដល់ក្រាបថ្វាយបង្គំទូលតាមដំណើរសព្វគ្រប់ តែទ្រង់ត្រាស់បន្ទមថា " ម្ដងណោះបើឈ្នះ អញឲ្យឯងធ្វើជាតេជោជំនួសតេជោហ៊ូ តែបើជាចាញ់វិញនោះត្រូវអញប្រហារជីវិតឯង " ។ នាយជ័យទទួលព្រះរាជឱង្ការដម្កល់លើត្បូង ។ ពេលនោះ ព្រះរាជអគ្គមហេសីព្រះនាមអាំ មានប្អូនប្រុសម្នាក់ធ្វើចាងហ្វាងក្នុងព្រះបរមរាជវាំង ក្រាបបង្គំទូលព្រះរាជា សុំធ្វើប្អូនឲ្យទៅរៀនធ្វើចម្បាំងជាមួយផង ។

នាយជ័យសុខចិត្តទទួលឥតប្រកែក តែបានទូលស្នងសុំព្រះករុណាថា "សូមទ្រង់ព្រះមេត្តាប្រោស ! សូមទ្រង់ជ្រាបជាមុនថា ! ទ័ពមុខទូលព្រះបង្គំជាខ្ញុំសូមប្តូរជីវិត យកឈាមក្រាលផែនដីក៏បាន តែត្រង់ទ័ពក្រោយបើមានសេចក្តីឆាំឆ្ង ទូលព្រះបង្គំជាខ្ញុំ សូមមេត្តាប្រោសអនុញ្ញាតទោស" ។ ព្រះករុណាមានព្រះរាជតម្រាស់ត្រាស់តបវិញ "មិនអីទេ ! ទ័ពក្រោយនឹងអនុញ្ញាតឲ្យបាន" ។ រួចហើយ ព្រះរាជាទ្រង់ព្រះរាជទានកងទ័ពឲ្យនាយជ័យមួយពាន់នាក់ ទាំងឲ្យចាងហ្វាងជាប្អូនព្រះអគ្គ-មហេសីធ្វើជាពលនឹងជាមេកងរង ទៅក្រោមបង្គាប់មេកងជ័យ ។

កងទ័ពចេញពីទុគ្គង កាត់ទៅខេត្តកំពង់ឆ្នាំង ចូលទៅខេត្តកំពង់ធំ ។ លុះរៀបចូលដល់ទីក្រុងកំពង់ធំ នាយជ័យជាមេកងបានឲ្យកេណ្ឌអ្នកស្រុកជាច្រើនឲ្យកាប់ឫស្សីទុកតាំងមែកទុកតាំងស្លឹក ប្រគល់ឲ្យពួកកងទ័ពអូសព្រួសចុង ។ គ្រានោះ ជារដូវរំហើយភ្លើងទើបនឹងឆេះព្រៃថ្មី ៗ លុះកងទ័ពនាយជ័យអូសឫស្សីព្រួសពីចុង ក៏កំទេចផេះដែលនៅលើដីហុយហើរឡើងទៅលើអាកាស ។ តែពេលនោះ លោកចាងហ្វាងជាមេកងរងពុំព្រមឲ្យកងទ័ពខ្លួនអូសឫស្សីព្រួសចុងទេ ថាពិបាក ។ នាយជ័យជាមេកងធំ បញ្ជាឲ្យចាប់ខ្លួនមេកងរងប្រហារជីវិតនៅទីនោះទៅ ។ មេកងជ័យ មានប្រាជ្ញាណាស់ ដែលឲ្យពួកទ័ពអូសឫស្សីព្រួសចុងនោះ ដើម្បីឲ្យពួកខ្មាំងស្មានថាគ្នាច្រើន ។ លុះកងទ័ពឈប់សំចតឲ្យយកឫស្សីនោះ

ស្រះព័ទ្ធឲ្យជិត កុំឲ្យសត្រូវមើលកងទ័ពខ្លួនឃើញបាន ។

លុះកងទ័ពនោះ ធ្វើដំណើរទៅដល់ខេត្តកំពង់ធំហើយ កងទ័ពខាងសត្រូវដែលនៅខេត្តកំពង់ធំ ក៏ភ្ញាក់ផ្អើលដោយសារឃើញផេះ និងដីហុយឡើងទៅលើអាកាសច្រើនពេក ទើបនឹកស្មានថា ទ័ពខ្លួនតិចជាងទ័ពគេ ក៏បាក់ទ័ពបរាជ័យក្នុងពេលនោះទៅ ខ្លះក៏រត់ទៅស្រុកដើមកំណើតគឺស្រុកជាំខ្សាន - កញ្ជប - ម្លូព្រៃអស់ទៅ ។

ទ័ពមេកងជ័យមិនឈប់ ក៏ដេញតាមរហូតទៅគ្រាតែពួកខ្មាំងសត្រូវចូលក្នុងដងរែក កាត់ទៅស្រុកសៀមបាត់អស់ ។

ក្រោយដែលមានជ័យជំនះមក មេកងជ័យនឹងពួកទ័ពក៏វិលចូលទៅឧត្តុង្គមានជ័យថ្វាយបង្គំគាល់ព្រះករុណា ។ តែមុនចូលដល់ព្រះបរមរាជ-វាំងមេកងជ័យមានប្រាជ្ញាគិតថា ខ្លួនបានសម្លាប់លោកចាងហ្វាងជាប្អូនព្រះរាជអគ្គមហេសី រួចក៏បង្គាប់ពួកកងទ័ពឲ្យយកច្រវាក់៣ខ្សែមកដាក់ខ្លួន គឺ ១ខ្សែឲ្យដាក់ក, ១ ខ្សែទៀតឲ្យដាក់ចង្កេះនឹងដៃ, ១ ខ្សែទៀតឲ្យដាក់ជើងទាំង ២ បណ្ដើរចូលគាល់ព្រះរាជា ។ ដល់ចំពោះព្រះភក្ត្រព្រះរាជា មេកងជ័យឱនកាយថ្វាយបង្គំហើយរ៉ាយរ៉ាប់ថា បម្បាំងមុខទូលព្រះបង្គំមានជ័យជំនះហើយ តែបម្បាំងក្រោយទូលព្រះបង្គំសូមជ្រកកោនក្រោមម្លប់ព្រះបារមីល្អងធូលីព្រះបាទ សូមទុកជីវិត ។

គ្រានោះ ព្រះរាជាមានព្រះបន្ទូលថា "អាណាដាក់ច្រវាក់វា ត្រូវ

ដោះលែងឲ្យទៅ ក៏គ្មានទោសពៃរ៍អ្វីទេ ព្រោះច្បាំងឈ្នះហើយ ” ។ ព្រះពជរង្គមហេសី កាលបើពុំបានឃើញប្អូនក៏យំទួញថា “ប្រាកដជាស្លាប់ក្នុងចម្បាំងហើយ ឯស្លាប់នោះគឺដោយសារឈ្មោះជ័យសម្លាប់ ” ។ មេកងជ័យក៏ទូលតបទៅវិញថា “ ទូលព្រះបង្គំជាខ្ញុំសម្លាប់មែន ព្រោះមុខទ័ពពុំព្រមស្លាប់បង្អាប់ បើទុកទៅនឹងមានជំទាស់ក្នុងចម្បាំងធំ ហើយមុខជាបរាជ័យពុំខាន ។ ដូច្នេះហើយ, បានជាទូលព្រះបង្គំជាខ្ញុំ ធ្វើឃាតឲ្យហើយមុន ។ មួយទៀត សូមក្រាបបង្គំទូលថា បើទ័ពទូលព្រះបង្គំជាខ្ញុំចាញ់ហើយ មុខជាសត្រូវចូលមកលុកលុយក្នុងនគរ មិនដឹងជាបែបណាទេ ” ។ ពេលនោះ ព្រះករុណាទ្រង់ឈ្ងល់ ទ្រង់វិនិច្ឆ័យថា “មេកងជ័យត្រូវរួចខ្លួន ត្រូវតាំងឲ្យធ្វើជាតេជោ ជាជំនួសលោកតេជោហ៊ូ ដែលខ្មាំងសម្លាប់បាត់ទៅ ។

ចាប់តាំងពីមេកងជ័យបានឡើងធ្វើជាតេជោជាវេលាណាមក ខេត្តកំពង់ធំបានសុខសប្បាយរហូតមក ឥតមានខ្មាំងសត្រូវណាហ៊ានលុកលុយបានឡើយ ។ ព្រះរាជាទ្រង់ឲ្យពង្រីកខេត្តនេះឲ្យធំ គឺខាងជើងទល់ត្រឹមស្រុកដីក្រែង ដែលសព្វថ្ងៃនៅក្នុងខេត្តសៀមរាប ។ ខាងត្បូងទល់នឹងខេត្តកំពង់ចាម, ខាងកើតទល់នឹងក្រចេះ, ខាងលិចទល់នឹងទន្លេសាប ។

តេជោជ័យ មានអំណាចមានបុណ្យានុភាពយ៉ាងសម្បើម បណ្ដាជនក៏ចេះតែខ្សឹបខ្សៀវគ្នា ហៅតែលោកតេជោក្រហមក ព្រោះតែលោកមាន

ពណ៌ក្រហមដូចប្រឡាក់ឈាម តាមស្នាមទឹកមាត់ពាសទាគកជដូចនិទាន ខាងដើម ៗ ឯបំណែកនាងឡុងជាប្រពន្ធក៏ឡើងជាជំទាវឡុង ៗ ឈ្មោះ យ៉ែតជាបាវលោកតេជោក្រហមក គ្រាន់តែជាបាវស្និទ្ធស្នាលតែប៉ុណ្ណោះ ឥតមានបុណ្យស័ក្តិអ្វីទេ ៗ

លោកតេជោក្រហមកនេះ មានអាយុវែងប្រហែលជាជាង ៩០ ឆ្នាំ ទើបទទួលអនិច្ចកម្ម ៗ ហេតុដែលបណ្ដាលឲ្យលោកទទួលអនិច្ចកម្ម គឺមកពីលោកទៅមានសហាយជាមួយនឹងកូនស្រីចិនមួយនាក់ នៅក្នុងខេត្ត កំពង់ធំ ៗ នាងនោះមានរូបឆោមលោមពណ៌ល្អលើសលប់ស្រីឯទៀត ក្នុងខេត្តនោះ ៗ លុះបានរួមរក្សនឹងនាងនេះទៅ លោកតេជោក៏ស្រឡាញ់គាប់ចិត្តជាទីបំផុត ៗ មានថ្ងៃមួយលោកប្រឡែងលេងនឹងនាងជា ប្រពន្ធក្រោយនេះ នាងនោះកំពុងតែកាន់ម្ជុលដេរអាវ ៗ លុះលោក យកដៃបញ្ឆោសអង្អែល នាងនោះយកម្ជុលចាក់ដៃ លោកក៏ភ្ញាក់ព្រើត ៗ ៗ នាងនោះនិយាយលេងថា " គោតណាស់ លោកជាមេទ័ពយ៉ាងធំ ហ៊ាន ពួក ឥតខ្លាចដាវលំពែង ; ប៉ុន្តែកាលញ៉ាំង ប្រហែលជាវេញតែគេឲ្យទៅ មុខទេះមើលទៅ ? ប្រើតែពួកហេតុពលឲ្យគាប់សម្លាប់ទេមើលទៅ ? " ៗ នាងនោះថាតែប៉ុណ្ណោះ លោកតេជោក្ដៅឈួលក្នុងចិត្ត ក្រោកអង្គុយ លែងស្ដីនិយាយរកប្រពន្ធសំណប់ ៗ បែរទៅហៅអាយ៉ែតវិញថា " អា យ៉ែត ! ឯងមកណេះ មកៈទៅជាមួយនឹងអញ រួចចុះទៅដីហើយថា អញ

មុខជាអស់អាយុថ្ងៃនេះហើយ , នៅរស់តទៅទៀតពុំបានទេ ខ្មាសពាក្យស្រីនិយាយបន្អាប់ណាស់, អាឯងធ្លាប់ដើរតាមអញទៅច្បាំងហើយ អញក្លាហានបែបណា ពេលនេះ ត្រូវតែឯងសម្លាប់អញឲ្យស្លាប់បែបនោះ" ។

នាយយ៉តថា “ ខ្ញុំពុំហ៊ានសម្លាប់ទេលោកតា ” ។ លោកតេជោថា “ អញធ្វើសំបុត្រចុតហ្មាយឲ្យឯង គ្មាននរណាហ៊ានធ្វើទុក្ខធ្វើបាបឯងទេ ក្រៅពីឯងគ្មាននរណាសម្លាប់អញឲ្យស្លាប់បាន ទាល់តែឯងជាអ្នកបានរៀនសិល្បសាស្ត្រពីអញច្រើនណាស់ បានសម្លាប់អញបាន ” ។ នាយយ៉តថា “ ជូនតាខ្ញុំសាសន៍ពួង តែចាស់ហើយគេតែងសម្លាប់គាត់ធ្វើបុណ្យ គេមិនទុកឲ្យស្លាប់ឯងៗ ដូចខ្មែរទេ តែលោកតាឲ្យខ្ញុំសម្លាប់លោកតាដោយលោកតាទុកចុតហ្មាយឲ្យខ្ញុំកាន់បែបនេះ ខ្ញុំត្រេកអរណាស់ ” ។ នាយយ៉តសួរថែមទៀតថា “ ចុះលោកតាឲ្យខ្ញុំសម្លាប់បែបណា ? ” ។ លោកតេជោក្រហមកឆ្លើយថា “នែ! អាយ៉ត, ឯងដឹងអញស្រាប់ហើយ, ខ្លួនអញគេកាប់មិនមុត បាញ់មិនចេញទេ ចូរឯងដុតអញចុះ ឯងធ្វើឥឡូវនេះទៅ ” ។ នាងប្រពន្ធចុងមកឃាត់សុំទោសតែយ៉ាងណាក៏ពុំស្ដាប់ សុខចិត្តតែពីស្លាប់ ។

លុះគេអុសបានច្រើនមកគរជាគំនរហើយ លោកតេជោឡើងទៅអង្គុយលើគំនរអុសនោះ ទើបនាយយ៉តដាក់ភ្លើងដុត ឆេះសុសលោកតេជោក្រហមក នៅពេលនោះទៅ ។

ព្រះរាជាទ្រង់ជ្រាបថា លោកតេជោក្រហមក ត្រូវបាវព្នងឈ្មោះយ៉កផុតសម្លាប់ដូច្នោះ ក៏ត្រាស់បង្គាប់ឲ្យចាប់ខ្លួននាយយ៉កទៅធ្វើទោសៗ ឈ្មោះនោះបានថ្វាយសំបុត្របុះកិច្ចសន្យានោះសុំកុំឲ្យធ្វើទោសខ្លួន ទ្រង់ជ្រាបសព្វសេចគ្រប់ហើយ ក៏ទ្រង់តាំងនាយយ៉កឲ្យធ្វើជាតេជោ ជំនួសលោកតេជោក្រហមក ដ្បិតនាយយ៉កពិតមែនជាជាតិព្នង តែចូលមកនៅស្រុកខ្មែរយូរណាស់ហើយ ដោយគេចាប់មកលក់តាំងពីតូច ដល់ធំឡើង បានរៀនសិល្បសាស្ត្រពីលោកតេជោក្រហមក បានទៅធ្វើចម្បាំងជាមួយគ្នាជាច្រើនលើក បានជាព្រះករុណាទ្រង់សព្វព្រះរាជហឫទ័យតាំងឲ្យនាយយ៉កធ្វើជាតេជោរៀង ។

នាយយ៉កក៏បានឡើងជាតេជោ ។ នៅពេលដម្បូង មានមន្ត្រីក្នុងខេត្តជាច្រើន ពុំស្តាប់បង្គាប់គាត់ដោយអន់ចិត្តថា នាយយ៉កជាតិព្នង ហើយគ្មានចេះសិល្បសាស្ត្រអ្វីផង, នាយយ៉កក៏ចាប់កាប់សម្លាប់ចោលអស់ទៅ ។

ដើម្បីឲ្យអ្នកផងអស់សង្ស័យ តេជោយ៉កឲ្យយកក្តារស្ពានចាស់ដែលអ្នកផងធ្លាប់ដើរជាន់គ្រប់គ្នាមកឲ្យជាងឆ្លាក់ធ្វើជាព្រះពុទ្ធរូបតូច ១ ព្រះអង្គ ហើយធ្វើបុណ្យអភិសេកឡើង ។ នៅពេលដែលអ្នកផងមកជួបជុំធ្វើបុណ្យនោះហើយ តេជោយ៉ក សួរទីប្រជុំថា “ ព្រះពុទ្ធរូបនេះពីដើមជាអ្វី ? ” ។ ទីប្រជុំឆ្លើយថា “ ពីដើមជាក្តារស្ពាន ” ។ តេជោយ៉កថា “ កាល

ទៅជាក្ដារស្ពានគេដើរជាន់ ឥឡូវជាព្រះពុទ្ធរូបគេថ្វាយបង្គំ ដូចខ្លួនយើងពីដើមជាបាវលោកតេជោក្រហមក គ្មាននរណាគោរពយើងទេ ឥឡូវនេះយើងជាតេជោត្រួតខេត្រនេះហើយ អ្នកទាំងអស់គ្នាត្រូវតែកោតខ្លាចយើង គោរពយើង មើលងាយយើងពុំបានជាដាច់ខាត បើមើលងាយយើង ។ នឹងសម្លាប់ឥតត្រាប្រណី ,, ។

តាំងពីនោះមក លោកតេជោយ៉ត ធ្វើការត្រួតត្រាខេត្របានយ៉ាងស្រួល ឥតមានខ្មាំងសត្រូវមកលុកលុយឡើយ រហូតដល់លោកអស់អាយុសង្ខារទៅ ។

រូបដំណាងលោកតេជោយ៉ត ក៏មានធ្វើទុកក្នុងវត្តកំពង់ធំសព្វថ្ងៃនេះដែរ តែឥតពូកែដូចរូបលោកតេជោក្រហមកដែលហៅថា អ្នកតាក្រហមកទេ ។ មកដល់សព្វថ្ងៃនេះ ពួកនាហ្មឺនទាំងធំទាំងតូច គ្មានលោកណាមួយហ៊ានចូលវិហារវត្តកំពង់ធំពីទ្វារមុខទេ ហ៊ានចូលតែតាមទ្វារក្រោយ ដោយខ្លាចអំណាចអ្នកតាក្រហមក ។

ចំណែកលោកតេជោ ហ៊ូ ដែលពួកខ្មាំងវាសម្លាប់នៅក្នុងបន្ទាយនោះ សព្វថ្ងៃនេះ អ្នកជិតខាង ហៅភូមិត្រង់កន្លែងបន្ទាយលោកតេជោហ៊ូនោះ ជាភូមិព្រៃតាហ៊ូ ។ ភូមិព្រៃតាហ៊ូនោះ នៅពីខាងក្រោយវត្តកំពង់ធំ ។

## ផ្នែកកំណត់និងប្រវត្តិការណ៍

### ពិធីទទួលសៀវភៅជាអំណោយបណ្ឌិតសភាពុទ្ធសាសនសិក្សាចិនប្រជាមានិត ដល់ពុទ្ធិក-មហាវិទ្យាល័យ ព្រះសីហនុរាជ

---

កាលពីថ្ងៃ ៧ ខែមេសា ១៩៦១ នៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ មានធ្វើពិធីទទួលសៀវភៅពុទ្ធសាសនាជាភាសាចិន និងភាសាអង់គ្លេស ជាអំណោយរបស់បណ្ឌិតសភាពុទ្ធសាសនសិក្សា នៃប្រទេសចិនប្រជាមានិត ។

ម៉ោង ៨, ៣០ នៃថ្ងៃនោះ, ឥស្សរសមណៈ និងឥស្សរជនជាច្រើន បាននិមន្តបានអញ្ជើញមកជួបជុំគឺ :

ផ្នែកព្រះសង្ឃជាអាទិ៍គឺៈ ព្រះទេពសត្ថា ថាង-អ៊ិត តំណាងសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, សម្ដេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ, ព្រះពោធិវង្សហួត-តាត អគ្គាធិការពុទ្ធិកសិក្សា, ព្រះមហាព្រហ្មមុនី ទេព-អ៊ូ ចាងហ្វាងរងនៃពុទ្ធិកវិទ្យាល័យ ព្រះសុភម្រឹត ព្រមទាំងព្រះថេរានុត្ថេរៈជាគណៈឋានានុក្រម និងព្រះសង្ឃសាស្ត្រាចារ្យជាច្រើនអង្គទៀត ។

ផ្នែកគ្រហស្ថគឺៈ សហជីវិន ស៊ិន ប៊ុប្បកា រដ្ឋលេខាធិការក្រសួងធម្មការ, លោក កួង-សន នាយកការិយាល័យ, លោក លឹម-ង្ហួនសេង

នាយខុទ្ទកាល័យ, ព្រះអគ្គមហាសិរីសុវត្ថិ - សាក់រ៉េត នាយការិយាល័យបុគ្គលិក, លោក ព៉យ-ប៊ុក នាយការិយាល័យសាសនសិក្សាធិការ នៃក្រសួងធម្មការ, លោក តៃ-ម៉េង-ហាប់ អគ្គលេខាធិការ នៃពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ, លោក ថាច់-សេក៉ញ ទីប្រឹក្សាបច្ចេកទេស ព្រមទាំងបុគ្គលិកក្រសួងធម្មការ-ពុទ្ធសាសនបណ្ឌិត្យ-ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ជាច្រើនទៀតបាននិមន្ត បានអញ្ជើញមកជាកិត្តិយសក្នុងពិធីនេះ ។

ម៉ោង ៩, ឯកឧត្តម រ៉េង-យូពឹង ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋចិនប្រជាមានិត ប្រចាំប្រទេសកម្ពុជា ជាតំណាងនៃបណ្ឌិតសភាពុទ្ធសាសនសិក្សាចិន ដោយមានសហការីរបស់លោក ៤ នាក់ជូនដំណើរផង បានអញ្ជើញមកដល់ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ដោយនាំយកមកនូវសៀវភៅ សារមោធានធម្មបវត្តន៍ ជាភាសាចិន ៤៨ ក្បាល,ជាភាសាអង់គ្លេស ១ ក្បាល ដែលសុទ្ធតែជាសៀវភៅនិយាយអំពីព្រះពុទ្ធសាសនា មកជូនទុកជាកេរ្តិ៍សម្បត្តិរបស់ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ។

ក្រោយពីការធ្វើការកិច្ចចំពោះព្រះសង្ឃ ទីងឥស្សរជនទាំងឡាយរួចហើយ ឯកឧត្តម រ៉េង យូពឹង បានថ្លែងនូវសុន្ទរកថាជាភាសាចិន ដោយមានអ្នកបកប្រែជាភាសាខ្មែរដូចតទៅនេះ ៖

# សុន្ទរកថា

## នៃ ឯកឧត្តម ភ៉ាង-យូពឹង

សូមនមស្ការ សម្តេចព្រះសង្ឃនាយកទាំង ២ គណៈ !

សូមនមស្ការ ព្រះថេរានុត្ថេរៈ !

ឯកឧត្តម-អស់លោក !

ខ្ញុំព្រះករុណា-ខ្ញុំបាទ ពោរពេញដោយក្តីសំណាង នឹងកិត្តិយសដ៏ជ្រាលជ្រៅក្រៃលែង ដែលមានតំណាងបណ្ឌិតសភា ពុទ្ធសាសនសិក្សានៃប្រទេសចិនមកផ្ទេរជូនដល់ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ នូវ សមោធានធម្មបរិវត្តន៍ ដែលជាស្នាព្រះហស្តនៃព្រះតេជព្រះគុណ ហ៊ាន់ ចាន់ ។ ព្រមជាមួយនេះ ខ្ញុំព្រះករុណា-ខ្ញុំបាទក៏សូមសំដែងនូវសេចក្តីអំណរគុណ ប្រគេននឹងជូនដល់ព្រះអង្គ ឯកឧត្តម នឹងអស់លោក ដែលបានប្រទាននឹងផ្តល់នូវព្រះទ័យ នឹងទឹកចិត្តកប់អាន ចំពោះខ្លួនខ្ញុំព្រះករុណា-ខ្ញុំបាទ ។

តាំងពី ១ ពាន់ឆ្នាំមកហើយម៉្លេះ គឺតាំងពីពេលដែលប្រជាជននៃប្រទេសយើងទាំងពីរ បានចាប់ផ្តើមឡើងនូវការរាប់រកគ្នាជាប្រពៃណីមក, ការប្រាស្រ័យទាក់ទងគ្នាខាងផ្លូវវប្បធម៌ពុទ្ធសាសនារវាងប្រទេសយើងទាំង ២ ក៏បានប្រព្រឹត្តទៅនូវដំណើរយ៉ាងរស្សកន់, ហើយក្នុងរយៈកាលដ៏យូរអង្វែងនោះ ប្រជាជននៃប្រទេសយើងទាំង ២ បានសុខដុម

ជាមួយនឹងគ្នា, ពុទ្ធសាសនិកជននៃប្រទេសយើងទាំង ២ បានខំព្យាយាម តស៊ូ និងពុះពារនូវគ្រប់ឧបសគ្គ បានលុកលុយនូវសមុទ្រសាគរ និងកាត់កលធ្លងព្រៃ បំពេញនូវការចងស្ពានមេត្រីនឹងគ្នា ព្រមទាំងបកប្រែនូវធម្មវិន័យដែលជាសារប្រយោជន៍ ដល់ព្រះពុទ្ធសាសនសិក្សា ។ ព្រឹត្តិ-ការណ៍ទាំងនេះបានចងក្រងរៀបរៀងដោយយ៉ាងច្បាស់លាស់ នឹងមានឧទាហរណ៍ដ៏រស់រវើកនៅក្នុងឯកសារប្រវត្តិសាស្ត្ររបស់ចិន ដូចជានៅដើមសតវត្សរ៍ទី ៦ នៃគ្រិស្តសករាជ មានព្រះភិក្ខុសង្ឃនៃប្រទេសហ្វូណន ២ ព្រះអង្គ គឺព្រះនាមសង្ឃបាលៈ ១ និងព្រះនាមមន្ទ្រសេនៈ ១ ព្រះអង្គបាននិមន្តទៅកាន់ក្រុងណាន់កាំងនៃប្រទេសចិន បានខំបំពេញនូវការប្រែធម្មវិន័យអស់រយៈពេល ១៧ ឆ្នាំ ; ព្រះត្រៃបិដកដែលប្រែសម្រាយជាភាសាចិន ហើយសព្វថ្ងៃបានតំកល់ទុកជាកេរ្តិ៍សម្បត្តិ នៅឯប្រទេសចិននោះ គឺជាស្នាព្រះហស្ត នៃព្រះភិក្ខុសង្ឃទាំង ២ អង្គនេះ ; ក្រៅពីនេះ នៅមានព្រះសង្ឃខ្មែរ ១ ព្រះអង្គទៀត ព្រះនាមសុភោធិ ក៏ព្រះអង្គបានបំពេញនូវការប្រែធម្មវិន័យខាងផ្នែកមហាយានជាច្រើនក្បាល ក្នុងកាលដែលព្រះអង្គនិមន្តទៅស្នាក់នៅក្នុងវត្តជីកេន ស្រុកអាជីវ នៃរជ្ជកាលឈិន ។ ជិត ១ សតវត្សរ៍មកនេះ ដោយប្រទេសយើងទាំង ២ បានជួបប្រទះនូវសេនាដ៏អាក្រក់ , មិត្តភាពនៃប្រទេសយើងទាំង ២ ក៏បានត្រូវទទួលការរំខាន, ឥតការប្រាស្រ័យទាក់ទងគ្នា ខាងវប្បធម៌ពុទ្ធសាសនា

និងការចងស្ពានមេត្រីនិងគ្នា រវាងពុទ្ធសាសនិកជននៃប្រទេសយើងទាំង២ ក៏ពុំអាចនឹងរួចខ្លួនផុតពីគ្រោះថ្នាក់នេះដែរ ។ តែគួរជាទីរីករាយពេកណាស់ ចំពោះយើងទាំងអស់គ្នា ដោយយើងទាំងអស់គ្នា បានឈានដំណើរមកកាន់សម័យ មៅ-សេទុង និងសីហនុពជ ។ គឺសម័យហ្នឹងហើយដែល ជានាអះអាងដល់ការស្ដាបនាឡើងវិញ និងពង្រីកឲ្យទូលាយឡើងទៅទៀត នូវសម្ពន្ធមេត្រីរវាងប្រទេសយើងទាំង២ ។ សម័យហ្នឹងដែរ ដែលបានសម្រេចជាសមិទ្ធិយ៉ាងប្រសើរ ដល់ការប្រាស្រ័យទាក់ទងគ្នា រវាងពុទ្ធសាសនិកជននៃប្រទេសយើងទាំង ២ ។ ក្នុងករណីយដដែលនេះ, ខ្ញុំព្រះករុណា-ខ្ញុំបាទ ក៏ពុំអាចនឹងបំភ្លេចបានឡើយ នូវដំណើរទស្សនា-ការមកកាន់ប្រទេសកម្ពុជាកាលពីឆ្នាំ ១៩៥៧ នៃគណៈប្រតិភូពុទ្ធសាសនាចិន និងទស្សនកិច្ចនៃគណៈប្រតិភូពុទ្ធសាសនាខ្មែរ ដែលមានព្រះពោធិវង្ស ហួត-តាត ជាប្រធាន ដែលបានទៅកាន់ប្រទេសចិន កាលពីឆ្នាំ ១៩៥៨ ។ គឺជាកិច្ចទស្សនាទាំងនេះហើយ ដែលបានផ្ដល់ជាភាគទានមួយយ៉ាងប្រសើរ ដល់ការចងស្ពានមេត្រីរវាងប្រជាពលរដ្ឋ និងពុទ្ធ-សាសនិកជននៃប្រទេសយើងទាំង ២ ។

សម្ដេចសង្ឃជាទីគោរព ! ព្រះថេរានុត្ថេរៈទាំងឡាយ !

ឯកឧត្ដម ! អស់លោក !

ឥឡូវនេះ ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមតាងនាមនៃបណ្ឌិតសភាពុទ្ធ-

សាសនសិក្សាចិន សូមចាប់ផ្តើមនូវការជូនសៀវភៅធម៌ ដែលជាគេន-សម្បត្តិយ៉ាងថ្លៃថ្លា ខាងវប្បធម៌អតីតកាលនៃប្រទេសចិន ចំពោះពុទ្ធិក-មហាវិទ្យាល័យ ព្រះសីហនុរាជ ៗ ខ្ញុំព្រះករុណា-ខ្ញុំបាទ ជឿជាក់ថា: ការជូននូវសៀវភៅធម៌នេះ ជាសក្ខីភាពសបញ្ជាក់នូវមនោមិត្តភាពជាតិយេ្យ-ភាពនៃប្រជាជននិងពុទ្ធសាសនិកជនចិន ចំពោះប្រជាជននិងពុទ្ធសាស-និកជនខ្មែរ ៗ

ជាអវសានកថា ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមប្រសិទ្ធិនូវសព្ទសាធុការពរសូមឲ្យ:

- ការប្រាស្រ័យទាក់ទងគ្នា ខាងផ្លូវវប្បធម៌រវាងប្រទេសយើងទាំង ២ បានចំរើនជាមិនដាច់តទៅទៀត ៗ

- សូមឲ្យមិត្តភាពរវាងពុទ្ធសាសនិកជនចិន និងកម្ពុជាប្រកបដោយយុវភាពអស់កាលជាយូរអង្វែងតទៅ ៗ

- សូមជ័យមង្គល និងសេចក្តីចំរើនគ្រប់ប្រការបូលមានដល់សម-ណសិស្ស នៃពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ៗ

លុះចប់សុន្ទរកថារបស់ឯកឧត្តម ពាំង-យូពឹង ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋចិនប្រជាមានិត ប្រចាំប្រទេសកម្ពុជា និងជាតំណាងនៃបណ្ឌិតសភាពុទ្ធសាសនសិក្សាចិនហើយ សហជីវិនសុិន-ប៊ុយកោ រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនសិក្សាធិការ បានថ្លែងនូវសុន្ទរកថា

មួយ ដែលមានអ្នកបកប្រែម្នាក់ប្រែជាភាសាចិនដូចតទៅនេះ ៖

សុន្ទរកថា

នៃសហជីវិន ស៊ុន-បុប្ដកោ

---

សូមនមស្ការ សម្ដេចទាំងពីរព្រះអង្គ !

សូមនមស្ការ ព្រះថេរានុត្ថេរៈ ទាំងឡាយ !

សូមជំរាប ឯកឧត្ដម - លោកអ្នកទាំងឡាយ !

ក្នុងនាមនៃក្រសួងធម្មការ និងសាសនសិក្សាធិការ និងក្នុងនាមខ្ញុំព្រះករុណា-ខ្ញុំ, ខ្ញុំព្រះករុណា ខ្ញុំ សូមថ្លែងនូវសោមនស្សយ៉ាងខ្លាំងខ្លួស់ចំពោះសម្ដេចទាំងពីរព្រះអង្គ - ព្រះថេរានុត្ថេរៈ - ឯកឧត្ដម ព្រមទាំងអស់លោកទាំងឡាយ ដែលបាននិមន្ត-អញ្ជើញមកជាកិត្តិយសដ៏ប្រសើរ ក្នុងឱកាសពិធីទទួលសៀវភៅជាអំណោយនៃបណ្ឌិតសភាចិនចំពោះបណ្ណា-ល័យពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជនេះ ។

ខ្ញុំព្រះករុណា - ខ្ញុំ សូមអនុញ្ញាតពីសំណាក់សម្ដេច ព្រះថេរានុត្ថេរៈទាំងឡាយ ឯកឧត្ដម និងអស់លោក ដើម្បីថ្លែងនូវមនោសញ្ចេតនាយ៉ាងស្មោះស្ម័គ្រ ព្រមទាំងកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅចំពោះឯកឧត្ដម ឯក-អគ្គរដ្ឋទូតប្រទេសចិនប្រជាមានិត ប្រចាំប្រទេសកម្ពុជា ដែលបានអញ្ជើញមកប្រគល់សៀវភៅ ដល់បណ្ណាល័យនៃពុទ្ធិកមហាវិទ្យាល័យ ព្រះ-សីហនុរាជយើង ក្នុងពេលនេះ ។

ឯកឧត្តម -

ខ្ញុំមានបសន្នចិត្តជាយ៉ាងពន់ពេក ដោយខ្ញុំបានទទួលភារៈ ធ្វើជាអធិបតីក្នុងការទទួលសៀវភៅដែលជាអំណោយបណ្ឌិតសភាចិន ហើយដែលឯកឧត្តមបាននាំមកដាក់ទុកនៅចំពោះមុខយើងខ្ញុំនេះ ដើម្បីជាវត្ថុសម្បត្តិនៃបណ្ណាល័យ សម្រាប់ឲ្យសិស្សទាំងឡាយសិក្សាតទៅអនាគត ។

សៀវភៅនេះ ទុកជាឯកសារដ៏វិសេសវិសាល ដែលឯកឧត្តមនឹងបណ្ឌិតសភាចិន បានផ្តល់ដល់ពុទ្ធិកមហាវិទ្យាល័យ ។ ឯកសារទាំងនេះអាចផ្សាយនូវវិជ្ជាទាំងឡាយចំពោះនិស្សិតគ្រប់ ៗ គ្នា ដែលត្រូវការបំពេញវិជ្ជាបានបរិបូណ៌តទៅអនាគត នឹងជួយឧបត្ថម្ភបណ្ណាល័យឲ្យមានវឌ្ឍនភាព នឹងសម្បូរណភាព ។ កុសលចិត្តដ៏ប្រពៃដែលទុកជាស្រែបុណ្យសម្រាប់បណ្តុះនូវពូជដ៏ល្អគឺវិជ្ជានេះឯង នាំឲ្យខ្ញុំព្រះករុណា -ខ្ញុំ នឹកឃើញដល់សុភាសិត ១ កន្លែងដែលលោកសុត្តន្តប្រើជា ៩ ក្នុ បានបង្ក្រងជាពាក្យកាព្យក្នុងសៀវភៅ លោកនីតិបករណ៍ : ថា :

មានទ្រព្យមិនស្មើមានវិជ្ជា វិជ្ជាចោរលួចយកមិនបាន

វិជ្ជាទុកជាមិត្តកាលប្រាណ សព្វានជួយពីងពុំនឹងអើយ ។

ម្យាងវិញទៀត ខ្ញុំព្រះករុណា-ខ្ញុំ សូមសម្តេច-ឯកឧត្តម-លោកអ្នកមេត្តាអនុញ្ញាតឲ្យខ្ញុំដំពបបន្តិច អំពីប្រវត្តិដោយសង្ខេបនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជនេះ ។

ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជនេះ បានកើតឡើងក្នុងឆ្នាំ ១៩៥៤ សព្វថ្ងៃឋិតនៅក្នុងការឧបត្ថម្ភនៃរាជរដ្ឋាភិបាល ។ គោលបំណងនៃពុទ្ធិកមហាវិទ្យាល័យនេះ គឺដើម្បីពង្រីកពុទ្ធិកសិក្សាដែលមានឋានៈពុំទាន់សមល្មមនៅឡើយ ។ ការពង្រីកនេះ សូមជ្រាបថាពុំមែនចំពោះតែពុទ្ធិកសិក្សាទេ គឺពង្រីកទាំងការសិក្សាខាងវិជ្ជាផ្លូវលោក និងភាសាជាន់បុរាណផង ។ សព្វថ្ងៃនៅក្នុងមហាវិទ្យាល័យនេះ មានការបង្រៀនភាសាបាលី-សំស្ក្រឹត អង់គ្លេស-បារាំង និងវិជ្ជាទំនើបផ្សេង ៗ ទៀត ដោយមធ្យ័ត ។ នៅឆ្នាំក្រោយប្រហែលជានឹងមានបង្រៀនភាសាហិណ្ឌីដែលជាភាសាសម្រាប់រដ្ឋឥណ្ឌាទៀត ។ មហាវិទ្យាល័យនេះ មានសាស្ត្រាចារ្យយ៉ាងចំណានៗខាងភាសាដូចពោលមកខាងលើនេះ ។

ក្នុងរយៈកាលដ៏ខ្លីតែប៉ុណ្ណេះ ឃើញថាវឌ្ឍនភាពនៃមហាវិទ្យាល័យនេះ បេះតែជឿនលឿនទៅមុខជាដរាប ហើយនឹងមានសេចក្ដីសង្ឃឹមយ៉ាងមាំថា តទៅអនាគតនឹងរីករឹតតែចម្រុងចម្រើនជាកិយ្យោភាពជាងនេះទៅទៀត នៅក្រោមការដឹកនាំនៃព្រះតេជព្រះគុណ ព្រះពោធិវង្ស អគ្គាធិការពុទ្ធិកសិក្សា ក្នុងព្រះរាជអាណាចក្រកម្ពុជា ។

ឯកឧត្តម !

សៀវភៅទាំងនេះ ជាអំណោយមួយដ៏ប្រសើរបំផុតមានប្រយោជន៍ច្រើនពេកណាស់ ព្រោះជាសៀវភៅដែលពុទ្ធិកមហាវិទ្យាល័យកំពុងតែ

ត្រូវការ ៗ ជនជាតិចិនតែងតែមានសទ្ធាបរិច្ចាគធនធានធ្វើបុណ្យទានដូចពុទ្ធសាសនិកជនខ្មែរយើងដែរ ៗ ប្រជាជនខ្មែរពុំដែលភ្លេចដល់ម្តងសោះឡើយថា មហាប្រទេសចិន ជាប្រទេសដែលមានការប្រាស្រ័យទាក់ទងនឹងប្រទេសកម្ពុជាតាំពីបុរាណកាលមក ៗ ដោយអាស្រ័យហេតុនេះ កម្ពុជាទុកប្រទេសចិនដូចជាបងប្អូនរួមសាច់ឈាមជាមួយគ្នា ៗ ម្យ៉ាងទៀត ក្នុងសម័យនេះ ប្រទេសចិនជាមិត្តដ៏ឧត្តមរបស់ប្រទេសកម្ពុជា ៗ

នៅទីបំផុតនេះ ក្នុងនាមនៃរដ្ឋាភិបាលខ្មែរ និងក្នុងនាមនៃព្រះសង្ឃទាំងអស់ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ជាមគ្គុទ្ទេសក៍ ព្រមទាំងក្នុងនាមផ្ទាល់របស់ខ្ញុំ ខ្ញុំសូមថ្លែងបន្ថែមទៀតនូវសេចក្តីគោរពជាអភិវន្ទភាពចំពោះអំណោយដ៏ថ្លៃថ្លានេះ ៗ សូមឯកឧត្តមមេត្តាទទួលនូវឥដ្ឋមនុញ្ញផលដ៏ខ្ពង់ខ្ពស់ និងសមានចិត្តដ៏ជ្រាលជ្រៅអំពីខ្ញុំ ដើម្បីនឹងរឹតចំណងមិត្តភាពរវាងប្រទេសទាំងពីរ ដែលមានគោលបំណងតែមួយដូចគ្នា គឺសន្តិភាពឲ្យបានរឹងរឹតតែជិតស្និទ្ធ ជាស្ថានពរតរៀងទៅ ៗ

លុះចប់សុន្ទរកថានេះហើយ ព្រះសង្ឃក៏បានជយន្តោប្រសិទ្ធិពរជ័យជូនចំពោះជនទាំងពីរផ្នែក និងជាកិច្ចបញ្ចប់ពិធីប្រគល់សៀវភៅនេះ ៗ

---

តពីនោះ ព្រះបិតាជាតិទ្រង់ប្រគេនសញ្ញាប័ត្រតាំងព្រះតេជព្រះគុណ ធ្យោ·ណរាង៉ (សុជម្មគោ) ឲ្យឡើងកាន់ឋានៈ ជាព្រះមង្គលទេព-លោករង្សី មេគណខេត្តតាកែវ ជាជំនួសព្រះសពគេទៅ ។

បន្ទាប់មក សម្តេចព្រះបិតាជាតិ ទ្រង់ប្រគេនទេយ្យទានចំពោះសម្តេចព្រះសង្ឃនាយក ព្រមទាំងបវារណាបច្ច័យ ចូលក្នុងពិធីបុណ្យ ៥០០០៛ នឹងប្រគេនលោកគ្រូចៅអធិការ ៥០០០៛ សម្រាប់ចាត់ចែងតាមត្រូវការក្នុងវត្ត ។